ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ
# និង
# គំរូវការជំនួយអភិវឌ្ឍន៍




ខែ វិច្ឆិកា ឆ្នាំ ២០០៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# ការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ

# និង

# គំរូងការជំនួយសំរាប់កិច្ចអភិវឌ្ឍន៍

ឯកសាររៀបចំសំរាប់កិច្ចប្រជុំពិគ្រោះយោបល់ឆ្នាំ ២០០៤

# មាតិការឿង


ទំព័រ

អារម្ភកថា

ខ្លឹមសារសង្ខេបប្រតិបត្តិ I-XXXVII

ជំពូកទី១ : សេចក្តីផ្តើម ១

ជំពូកទី២ : សមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាលចាប់ពីកិច្ចប្រជុំពិគ្រោះយោបល់ លើកទី៦ ខែមិថុនា ឆ្នាំ២០០២ ៥

២.១- លទ្ធផលការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល ៦

២.១.១ កំណែទំរង់ច្បាប់ និងតុលាការ និងអភិបាលកិច្ច ៦

កំណែទំរង់ច្បាប់ និងតុលាការ ៦

ការប្រឆាំងអំពើពុករលួយ ៩

លទ្ធកម្មសាធារណៈ ១០

២.១.២ ការគ្រប់គ្រងប្រភពធនធានធម្មជាតិ ១០

២.១.៣ វិស័យសង្គមកិច្ច ១៤

២.១.៤ ការគ្រប់គ្រងហិរញ្ញវត្ថុ និងកំណែទំរង់រដ្ឋបាលសាធារណៈ ១៧

២.២- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ២១

២.៣- ស្ថានភាពរូបិយវត្ថុ និងសារពើពន្ធ ២៣

ចំណូលថវិកា ២៦

ចំណាយសាធារណៈ ២៨

២.៤- ការអភិវឌ្ឍន៍តាមវិស័យ ៣២

២.៤.១ វិស័យសង្គមកិច្ច ៣២

វិស័យអប់រំ ៣២

វិស័យសុខាភិបាល ៣៦

២.៤.២ វិស័យសេដ្ឋកិច្ច ៣៩

វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៣៩

វិស័យកម្មន្តសាល និងរ៉ែ ៤៤

វិស័យទេសចរណ៍ ៤៦

វិស័យពាណិជ្ជកម្ម ៤៨

២.៤.៣ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ៥២

ការដឹកជញ្ជូន ៥២

ធនធានទឹក និងឧតុនិយម ៥៥
ទឹកស្អាត ៥៧
ការផលិតថាមពលអគ្គិសនី និងប្រព័ន្ធចែកចាយ ៥៨
វិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងសេវាកម្មពត៌មាន ៦០
២.៥- កម្មវិធីអន្តរវិស័យ ៦២
ការអភិវឌ្ឍន៍ជនបទ ៦២
ការងារបរិស្ថាន និងអភិរក្ស ៦៨
ការរៀបចំដែនដី និងនគរូបនីយកម្ម ៧០
ការបោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ៧៣
ការងារ និងការផ្តល់សេវាសង្គម ៧៤
យេនឌ័រ និងការអភិវឌ្ឍន៍ ៧៦

ជំពូកទី ៣ : កម្មវិធីនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល : យុទ្ធសាស្ត្រចតុកោណ ៨១

ជំពូកទី ៤ : អាទិភាពសំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ ៨៦
៤.១- អភិបាលកិច្ចល្អ ៨៦
ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ៨៧
កំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ៨៨
កំណែទំរង់រដ្ឋបាលស៊ីវិល ៨៩
វិមជ្ឈការ និងវិសហមជ្ឈការ ៩០
កំណែទំរង់កងកំលាំងប្រដាប់អាវុធ ៩១
៤.២- បរិស្ថានគ្របដណ្តប់សំរាប់ការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ ៩១
សុខសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម ៩២
ភាពជាដៃគូនៅក្នុងការអភិវឌ្ឍន៍ ៩២
បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានលក្ខណៈអនុគ្រោះ ៩៨
សមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក ១០៣
៤. ៣ កំណើន ១០៥
៤. ៣. ១ វិស័យកសិកម្ម ១០៥
ការលើកកំពស់ផលិតភាព និងពិពិធកម្មវិស័យកសិកម្ម ១០៥
កំណែទំរង់ដីធ្លី និងការបោសសំអាតមីន ១០៨
កំណែទំរង់ដីធ្លី ១០៩
ការបោសសំអាតមីន ១១១

កំណែទំរង់នេសាទ ១១២
កំណែទំរង់ព្រៃឈើ ១១២
៤.៣.២ ការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធ ១១៤
ការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ១១៤
ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្រ្ត ១១៨
ការអភិវឌ្ឍន៍វិស័យថាមពល និងបណ្តាញអគ្គិសនី ១២១
ការអភិវឌ្ឍន៍បច្ចេកវិទ្យាពត៌មាន និងទូរគមនាគមន៍ ១២៣
៤.៣.៣ ការអភិវឌ្ឍន៍វិស័យឯកជន និងការងារ ១២៤
ការពង្រឹងវិស័យឯកជន និងការទាក់ទាញវិនិយោគ ១២៤
ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម ១២៨
ការបង្កើតការងារ និងការធានាលក្ខខ័ណ្ឌការងារល្អប្រសើរជូនកម្មករ
និងនិយោជិត ១២៩
ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម សំរាប់មន្ត្រី បុគ្គលិក កម្មករ ១៣០
៤.៣.៤ ការកសាងសមត្ថភាព និងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ធនធានមនុស្ស ១៣១
ការពង្រឹងគុណភាពសេវាអប់រំ ១៣១
ការកែលំអសេវាសុខាភិបាល ១៣៤
ការអនុវត្តន៍គោលនយោបាយយេនឌ័រ ១៣៩
ការអនុវត្តន៍គោលនយោបាយប្រជាសាស្រ្ត ១៤១

ជំពូកទី៥ : តំរូវការហិរញ្ញប្បទាន និងទិសដៅកៀងគរជំនួយផ្លូវការ ១៤២

ជំពូកទី៦ : សេចក្តីសន្និដ្ឋាន ១៤៩

## តារាង

តារាងទី១ : សូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច ២៥
តារាងទី២ : សូចនាករនៃថវិការដ្ឋ ២៧
តារាងទី៣ :ការសន្យា និងការប្រើប្រាស់ជំនួយ ឆ្នាំ២០០១-២០០៣ ១៤៣
តារាងទី៤ : កម្មវិធីអភិវឌ្ឍន៍តាមវិស័យ ឆ្នាំ២០០៥-២០០៧ ១៤៦
តារាងទី៥ : កម្មវិធីនិងគំរោងកំពុងដំណើរការបានសន្យា និងក្នុងផែនការជាអទិភាពខ្ពស់តាមវិស័យ ១៤៧

ឧបសម្ព័ន្ធទី១ : កម្មវិធីវិនិយោគសាធារណៈសំរាប់កៀងគរជំនួយ ឆ្នាំ២០០៥-២០០៧ I-XX

# អារម្ភកថា

គោលដៅនៃឯកសារជំហរនេះគឺការបង្ហាញជូនដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ នូវរបាយការណ៍សង្ខេបរបស់រាជរដ្ឋាភិបាលស្តីពីបណ្តាអាទិភាពសំរាប់អនុវត្ត «***យុទ្ធសាស្ត្រចតុកោណ***» និងតំរូវការជំនួយបរទេសសំរាប់រយៈពេល៣ឆ្នាំ ២០០៥-២០០៧ ។ ឯកសារជំហរក៏ផ្តល់ពត៌មានថ្មីៗស្តីពីវឌ្ឍនភាព ដែលរាជរដ្ឋាភិបាលបានសំរេច បន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់ឆ្នាំ២០០២មក ។ មូលដ្ឋាននៃឯកសារជំហរនេះគឺយុទ្ធសាស្ត្រចតុកោណ ដែលបានរៀបចំឡើងដោយផ្អែកលើសមាសធាតុសំខាន់ៗពី «គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា (CMDGs)» «ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច៥ឆ្នាំ២០០១-២០០៥» របស់កម្ពុជា ពី «យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រឆ្នាំ ២០០៣-២០០៥» និងពីគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីកំណែទំរង់សំខាន់ៗជាច្រើនទៀត ។ ឯកសារយុទ្ធសាស្ត្រទាំងអស់ត្រូវបានរៀបចំឡើង តាមរយៈការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយបណ្តាភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិទាំងអស់ រួមទាំងតំណាងរបស់សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ។ «***យុទ្ធសាស្ត្រចតុកោណ***» នេះ គឺជារបៀបវារៈសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល សំរាប់អនុវត្តកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី៣នៃរដ្ឋសភា ។

តំរូវការហិរញ្ញប្បទាន និងការកៀងគរជំនួយផ្លូវការសំរាប់អភិវឌ្ឍន៍ ដែលបានបង្ហាញក្នុងឯកសារជំហរនេះត្រូវបានរៀបចំដោយផ្អែកលើកម្មវិធីវិនិយោគរំកិល៣ឆ្នាំ ២០០៤-២០០៦ របស់រាជរដ្ឋាភិបាល និងកម្មវិធីនិងគំរោងអាទិភាពតាមវិស័យ ។

ឯកសារជំហរនេះ គឺជាលទ្ធផលនៃកិច្ចដំណើរការមួយយ៉ាងវែង ក្នុងនោះ មានការពិគ្រោះយោបល់ និងសំរបសំរួលអន្តរក្រសួងជាច្រើនលើកច្រើនសារ ចាប់ពីខែមេសា មកដល់ខែវិច្ឆិកា ឆ្នាំ២០០៤ ។ បន្ថែមលើការវិភាគ និងសំណើដែលបានវែកញែកក្នុងឯកសារជំហរនេះ រាជរដ្ឋាភិបាលក៏បានរៀបចំឯកសារជំហរដោយឡែកផ្សេងៗទៀតផងដែរ ។ ឯកសារទាំងនេះបានឆ្លុះបញ្ចាំងអំពីបណ្តាអាទិភាព និងធនធានសន្យារបស់រាជរដ្ឋាភិបាល ទាំងសំរាប់រយៈពេលខ្លី និងមធ្យម ដើម្បីសំរេចចក្ខុវិស័យរយៈពេលវែងក្នុងកិច្ចអភិវឌ្ឍន៍របស់កម្ពុជា ។ រាជរដ្ឋាភិបាលនឹងបំពេញកាតព្វកិច្ច និងបុរេលក្ខខ័ណ្ឌទាំងឡាយសំរាប់កំណែទំរង់ ហើយជឿជាក់ថា កម្ពុជាប្រាកដជាអាចដោះស្រាយបានដោយជោគជ័យ នូវកន្សោមបណ្តាបញ្ហាប្រឈមក្នុងពេលអនាគត ។

រាជរដ្ឋាភិបាលសូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណចំពោះសហគមន៍អ្នកផ្តល់ជំនួយ ដែលបានផ្តល់ជំនួយដ៏ថ្លៃថ្លា សំរាប់ជួយគាំទ្រដល់កម្មវិធីអភិវឌ្ឍន៍របស់កម្ពុជា ហើយជឿជាក់ថា សហគមន៍អ្នកជំនួយទាំងអស់

នឹងបន្តផ្តល់ជំនួយ  ដើម្បីអោយកម្ពុជាឈានទៅសំរេចបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ ។ តាងនាមរាជរដ្ឋាភិបាល ខ្ញុំសូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ ពិសេស ចំពោះអង្គការសហប្រជាជាតិសំរាប់កិច្ចអភិវឌ្ឍន៍ ធនាគារពិភពលោក និងប្រទេសស៊ុយអែត ដែលបានផ្តល់ការគាំទ្រដល់ការរៀបចំ និងដំណើរការរបស់កិច្ចប្រជុំដ៏មានសារៈសំខាន់នេះ ។

រាជធានីភ្នំពេញ  ថ្ងៃទី ១២  ខែវិច្ឆិកា ឆ្នាំ២០០៤



**គាត ឈន់**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

# ខ្លឹមសារសង្ខេបប្រតិបត្តិ

១- ក្នុងរយៈពេលជាច្រើនទសវត្សរ៍កន្លងមក កម្ពុជាបានចំណាយពេលវេលា និងបានខិតខំប្រឹងប្រែងយ៉ាងពេញទំហឹង ដើម្បីស្តារ និងកសាងប្រទេសឡើងវិញ ពីការបំផ្លិចបំផ្លាញនៃរបបប្រល័យពូជសាសន៍ និងសង្គ្រាមរ៉ាំរ៉ៃ ទម្រាំសំរេចបាននូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម លទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធមនុស្ស និងស្ថិរភាពសេដ្ឋកិច្ចរឹងមាំ ចាប់ពីឆ្នាំ១៩៩៩មក ។ កន្លងមក យើងបានអនុវត្តកម្មវិធីកំណែទំរង់គ្រប់វិស័យ ដោយបានឆ្លងកាត់ការលំបាក និងឧបសគ្គធំតូចច្រើនរាប់មិនអស់ ។ យើងបន្តសំរេចបានវឌ្ឍនភាពក្នុងការឆ្លងកាត់អន្តរកាលពីសេដ្ឋកិច្ចបែបផែនការចាប់ពីទស្សវត្សរ៍ឆ្នាំ៨០ មកបង្កើតបាននូវប្រព័ន្ធសេដ្ឋកិច្ចទីផ្សារដ៏រស់រវើក ព្រមទាំងបង្កើតបានលក្ខខ័ណ្ឌល្អប្រសើរសំរាប់ស្តារនិងអភិវឌ្ឍប្រទេសនៅលើគ្រប់វិស័យ សំដៅដឹកនាំកម្ពុជាលើមាគ៌ាដ៏វែងមួយឈានទៅសំរេចគោលដៅក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។

២- តាមការអនុវត្តន៍យ៉ាងប្តូរផ្តាច់ឥតរាថយនូវ *«យុទ្ធសាស្ត្រត្រីកោណ»* រាជរដ្ឋាភិបាលសំរាប់នីតិកាលទី២ នៃរដ្ឋសភាកន្លងមកនេះ បានបង្កើតឡើងនូវបរិស្ថានអនុគ្រោះ និងលក្ខខ័ណ្ឌចាំបាច់ និងគ្រប់គ្រាន់ ទាំងក្នុង និងក្រៅប្រទេស សំរាប់អោយកម្ពុជាអាចបោះជំហានទៅមុខប្រកបដោយក្តីសង្ឃឹម និងជំនឿទុកចិត្តយ៉ាងមុតមាំ នៅលើមាគ៌ានៃកំណែទំរង់ និងការអភិវឌ្ឍន៍ ។ ជោគជ័យនៃការអនុវត្តន៍យុទ្ធសាស្ត្រនេះ បានធ្វើអោយប្រទេសកម្ពុជាឆ្លងកាត់ដំណាក់កាលប្រែប្រួលយ៉ាងធំធេង ពីចំណុចមួយនៃផែនទីពិភពលោក ដែលប្រកបដោយភាពមិនច្បាស់លាស់ ដោយសារកលយុគសង្គ្រាម ជម្លោះផ្ទៃក្នុង អស្ថិរភាព និងភាពអន់ថយ ហើយក្លាយទៅជាប្រទេសមួយដែលមានសុខសន្តិភាពពេញលេញ មានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម មានការគោរពលទ្ធិប្រជាធិបតេយ្យ គោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងមានកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ ។ ឆ្លងកាត់រយៈពេលដ៏ខ្លីបំផុត ប្រសិនបើប្រៀបធៀបទៅនឹងប្រវត្តិសាស្ត្រនៃប្រទេសជឿនលឿននានា រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញដោយគ្មានការសង្ស័យថា កម្ពុជាពិតជាមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីចូលប្រឡូកដោយស្មើភាព និងស្មើសិទ្ធិក្នុងកិច្ចការតំបន់ និងពិភពលោក ។ ប្រការទាំងនេះបានប្រែក្លាយទៅជាការកើនឡើងនៃជំនឿទុកចិត្តមកលើប្រទេសកម្ពុជា ហើយផ្តល់ជាផលប្រយោជន៍មកវិញតាមរយៈការកើនឡើងនៃពាណិជ្ជកម្ម និងលំហូរនៃការវិនិយោគ និងភ្ញៀវទេសចរណ៍ចូលមកក្នុងកម្ពុជា ដែលជាកត្តាយ៉ាងសំខាន់សំរាប់ជួយបង្កើតការងារ និងបង្កើនចំណូលដល់ពលករកម្ពុជា ។

៣- ចំពោះវឌ្ឍនភាពដ៏គួរកត់សំគាល់ក្នុងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច រយៈពេល៥ឆ្នាំកន្លងមកនេះរួមមាន÷ការអនុវត្តន៍បណ្តាគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមដោយផ្តោតទៅលើអ្នកក្រីក្រ ការរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច កំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ការបន្តអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ ពង្រឹងនីតិរដ្ឋ និងអភិបាលកិច្ចល្អ ការកែលំអការផ្តល់សេវាសាធារណៈ ដើម្បីឆ្លើយតបទៅនឹងតំរូវការនិងសំណូមពររបស់ប្រជាជន ។ កិច្ចប្រឹងប្រែងទាំងអស់នេះត្រូវបានអនុវត្ត ក្នុងគោលដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងដើម្បីឈានទៅសំរេចគោលដៅអភិវឌ្ឍន៍របស់កម្ពុជា ។ ទោះបីមានការខិតខំប្រឹងប្រែង ហើយទទួល

ជោគជ័យក្នុងជំហានដំបូងយ៉ាងណាក្តី ក៏រាជរដ្ឋាភិបាលមិនអាចជៀសផុតពីការខ្វះខាតបានឡើយ ។ ជាក់ស្តែង រចនាសម្ព័ន្ធផលិតកម្មរបស់ជាតិយើងដែលនៅមានទំហំតូច ហើយច្រើនប្រមូលផ្តុំនៅតាមតំបន់មួយចំនួន ត្រូវតែពង្រីក និងធ្វើពិពិធកម្ម ដើម្បីធានាកំណើនសេដ្ឋកិច្ចមួយប្រកបដោយចីរភាព ។ ទោះបីជាយើង បានអនុវត្តយន្តការនិងនីតិវិធីមួយចំនួនសំរាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈចាប់ពីឆ្នាំ១៩៩៤ ដើម្បីបង្កើន ចំណូលរដ្ឋក៏ដោយ ក៏យន្តការនិងទំរង់ការមួយចំនួននៅពុំទាន់ចាប់ដំណើរការអោយបានពេញលេញនៅឡើយ ព្រោះការប្រើឥទ្ធិពលមិនស្របគ្នាបានប៉ះពាល់យ៉ាងខ្លាំង ដល់ទិសដៅបង្កើនចំណូល និងកែលំអរិភាជន៍ ចំណាយសាធារណៈ ។ ក្រសួងជំនាញមួយចំនួននៅខ្វះយន្តការទំនាក់ទំនង និងសំរបសំរួលនៅឡើយ ។ ទន្ទឹមនេះ ដើម្បីពង្រឹងនីតិរដ្ឋ រាជរដ្ឋាភិបាលកំពុងរៀបចំសេចក្តីព្រាងច្បាប់ថ្មីៗ ហើយកំពុងរង់ចាំការផ្តល់ សច្ចាប័នពីស្ថាប័ននីតិបញ្ញត្តិ ។ លើសពីនេះ ការរៀបចំ និងកែទំរង់ឡើងវិញនូវបរិធានតុលាការមួយអោយរឹងមាំ នៅតែជាអាទិភាពរបស់រាជរដ្ឋាភិបាល ។ ចំពោះការផ្តល់ជំនួយអន្តរជាតិ ទោះបីអ្នកផ្តល់ជំនួយ ភាគច្រើនបានផ្តល់ជំនួយយ៉ាងថ្លៃថ្លា ដែលមានខ្លះជាលក្ខណៈមនុស្សធម៌ក្តី ក៏នៅមានប្រទេសផ្តល់ជំនួយ មួយចំនួនបានផ្សារភ្ជាប់ការផ្តល់ជំនួយទៅនឹងលក្ខខ័ណ្ឌខ្លះៗមិនសមហេតុសមផល ទាំងទិដ្ឋភាពបច្ចេកទេស ទាំងទិដ្ឋភាពនយោបាយ ។ សរុបមក ទន្ទឹមនឹងសមិទ្ធផលដែលសំរេចបានកន្លងមក រាជរដ្ឋាភិបាលសំរាប់ នីតិកាលទី៣នៃរដ្ឋសភាមានភារកិច្ចដោះស្រាយបណ្តាបញ្ហាប្រឈមជាច្រើន ។

៤- សំរាប់រយៈពេលវែងខាងមុខ បញ្ហាប្រឈមចំបងបំផុតចំពោះកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីអភិវឌ្ឍ គឺការកាត់បន្ថយភាពក្រីក្រ និងការធ្វើអោយប្រសើរឡើងនូវគុណភាពនៃជីវភាពរស់នៅរបស់ប្រជាជន ដែល មានកំណើនខ្ពស់ ។ រាជរដ្ឋាភិបាលយល់ច្បាស់ និងបានចាត់ទុកភាពក្រីក្រថាជាការខាតបង់ខាងសេដ្ឋកិច្ចដ៏ ធ្ងន់ធ្ងរ និងជាការដែលមិនអាចទទួលយកបានខាងសីលធម៌ ដែលអាចនាំទៅដល់ការបែកបាក់ និងអស្ថិរភាព សង្គមជាតិ ។ ដើម្បីសំរេចគោលដៅកាត់បន្ថយភាពក្រីក្រដែលបានដាក់ចេញ រាជរដ្ឋាភិបាលបានប្រកាស យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ដែលមានគោលដៅជាគន្លឹះដូចខាងក្រោម÷

- ទី១- ការពង្រឹងសន្តិភាព សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម តាមរយៈវិធានការជាក់ស្តែងនានា សំដៅលើកស្ទួយនីតិរដ្ឋ ការពារសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ដើម្បីបង្កើតឡើងនូវបរិស្ថាន នយោបាយ និងសន្តិសុខ ដែលអនុគ្រោះសំរាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងរយៈពេលវែង ។
- ទី២- ការធានាអោយបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ក្នុងរយៈពេលវែង ក្នុងអត្រាខ្ពស់ ពី ៦ ទៅ ៧% ក្នុងមួយឆ្នាំ ។
- ទី៣- ការបែងចែកផ្លែផ្កានៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ រវាងអ្នកមាន និងអ្នកគ្មាន រវាងទីក្រុង និងជនបទ និងរវាងស្ត្រីនិងបុរស ។
- ទី៤- ការធានាការគ្រប់គ្រង និងប្រើប្រាស់ប្រកបដោយចីរភាព បរិស្ថាននិងធនធានធម្មជាតិ ។

៥- ការបោះឆ្នោតនាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣ កន្លងមក ត្រូវបានបណ្តាអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ទទួលស្គាល់ថាជាការបោះឆ្នោតមួយសេរី យុត្តិធម៌ និងត្រឹមត្រូវ មានតំលាភាព និងអាចទទួលយកបាន

ហើយរដ្ឋសភានិងរាជរដ្ឋាភិបាលថ្មីត្រូវបានប្រសូតឡើង ស្របតាមឆន្ទៈរបស់ប្រជាជន ។ រាជរដ្ឋាភិបាលកម្ពុជាបានឈានចូលកាន់អំណាចក្នុងនីតិកាលទី៣នៃរដ្ឋសភា ស្របទៅតាមឆន្ទៈរបស់ប្រជារាស្ត្រ ជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងពេញទំហឹង ដើម្បីបំរើនូវឧត្តមប្រយោជន៍របស់ប្រទេសជាតិមាតុភូមិ និងឆ្លើយតបទៅនឹងសំណូមពរ និងសេចក្តីត្រូវការទាំងឡាយរបស់ប្រជាពលរដ្ឋកម្ពុជា ដែលរាជរដ្ឋាភិបាលបានទទួលតាមរយៈសម្លេងឆ្នោតផ្តល់ការទុកចិត្តនៅក្នុងកិច្ចដំណើរការបោះឆ្នោតប្រជាធិបតេយ្យ ដោយសេរី និងយុត្តិធម៌ ។ បន្ទាប់ពីឡើងកាន់កាប់ការងារភ្លាមមក រាជរដ្ឋាភិបាលបានរៀបចំ «**យុទ្ធសាស្ត្រចតុកោណ**» **ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា** ដែលនឹងដើរតួជាឧបករណ៍ដ៏សំខាន់សំរាប់ទ្រទ្រង់ការអនុវត្តន៍ «**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នៃរដ្ឋសភា**» ។ ***សម្តេច ហ៊ុន សែន*** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានឧទ្ទេសនាម «**យុទ្ធសាស្ត្រចតុកោណ**» នេះ នៅក្នុងឱកាសបើក កិច្ចប្រជុំលើកទី១របស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០០៤ ។

**យុទ្ធសាស្ត្រចតុកោណ**

៦- «***យុទ្ធសាស្ត្រចតុកោណ***» នេះ គឺជារបៀបវារៈសេដ្ឋកិច្ច ដែលជាការបន្តសកម្មភាព និងការបន្តពង្រឹងនូវសមិទ្ធផលនានា ដែលរាជរដ្ឋាភិបាលកម្ពុជាសំរេចបានក្នុងនីតិកាលទី ២ តាមរយៈការអនុវត្តន៍ **យុទ្ធសាស្ត្រត្រីកោណ** និងការជ្រើសរើសចេញនូវសមាសធាតុសំខាន់ៗពី *«គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍(MDGs)»* *«ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ ឆ្នាំ ២០០១-២០០៥»* របស់កម្ពុជាបច្ចុប្បន្ន ពី *«យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រឆ្នាំ ២០០៣-២០០៥»* និងពីគោលនយោបាយ យុទ្ធសាស្ត្រ ផែនការនិងកម្មវិធីកំណែទំរង់សំខាន់ៗជាច្រើនទៀត ។ យុទ្ធសាស្ត្រចតុកោណគឺជាឧបករណ៍សំរាប់អនុវត្ត «**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សំរាប់នីតិកាលទី៣ នៃរដ្ឋសភា**» ដែលបានឯកភាពមតិជាឯកច្ឆន្ទៈរវាងគណបក្សដៃគូទាំងពីរក្នុងរាជរដ្ឋាភិបាល ។ គោលដៅចំបងរបស់យុទ្ធសាស្ត្រចតុកោណ គឺ ÷ ការជំរុញលើកកំពស់កំណើនសេដ្ឋកិច្ច ការបង្កើតការងារសំរាប់ពលករកម្ពុជា ការធានាសមធម៌ និងយុត្តិធម៌សង្គម និងការលើកស្ទួយប្រសិទ្ធភាពនៃវិស័យសាធារណៈ តាមរយៈផែនការសកម្មភាពអភិបាលកិច្ច និងកំណែទំរង់ ស៊ីជំរៅ និងប្រទាក់ក្រឡាគ្នាក្នុងគ្រប់ផ្នែក-គ្រប់វិស័យ ។ តាមខ្លឹមសារនេះ រាជរដ្ឋាភិបាលនីតិកាលទី ៣ នៃរដ្ឋសភាត្រូវបានប្រសិទ្ធនាមថាជា «រាជរដ្ឋាភិបាលដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព» ។

៧- ឯកសារ «**យុទ្ធសាស្ត្រចតុកោណ**» ត្រូវបានបោះពុម្ព និងផ្សព្វផ្សាយយ៉ាងទូលំទូលាយ អោយដល់ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិទាំងអស់ ព្រមទាំងសង្គមស៊ីវិល ។ យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងតាមរចនាសម្ព័ន្ធជាចតុកោណដែលបានប្រទាក់ក្រឡាជាប់គ្នាគ្រប់ជ្រុងជ្រោយទាំងអស់ និងមានសមាសធាតុដូចតទៅ ÷

ទី១- <u>ស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺ **អភិបាលកិច្ចល្អ**</u> ដែលផ្តោតការយកចិត្តទុកដាក់ទៅលើកំណែទំរង់បួនយ៉ាង គឺ ÷ ទី១- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ ទី២- កំណែទំរង់ច្បាប់និងប្រព័ន្ធ

យុត្តិធម៌ ។ ទី៣- កំណែទំរង់រដ្ឋបាលសាធារណៈ រួមមានទាំងកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ ផង ។ និងទី៤- កំណែទំរង់កងកំលាំងប្រដាប់អាវុធ ពិសេសគឺ កម្មវិធីកាត់រំសាយកងទ័ព ។

ទី២- **បរិស្ថានគ្របដណ្តប់**សំរាប់ការអនុវត្តន៍យុទ្ធសាស្ត្រទាំងមូល ដែលមានបួនដែរ គឺ ÷ ទី១-សុខសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម ។ ទី២-ភាពជាដៃគូនៅក្នុងការអភិវឌ្ឍន៍ រួមមានភាពជាដៃគូជាមួយវិស័យឯកជន និងសហគមន៍អ្នកផ្តល់ជំនួយ ព្រមទាំងភាពជាដៃគូជាមួយនឹងសង្គមស៊ីវិល ។ ទី៣-បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានលក្ខណៈអនុគ្រោះ ។ និងទី៤-សមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក ។

ទី៣- **ចតុកោណយុទ្ធសាស្ត្រសំរាប់ជំរុញកំណើន** មាន៤ គឺ ÷ ទី១-ការលើកស្ទួយវិស័យកសិកម្ម ។ ទី២-ការអភិវឌ្ឍផ្នែកឯកជន និងការងារ ។ ទី៣-ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ។ និងទី៤-ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស ។

ទី៤- ចតុកោណយុទ្ធសាស្ត្រនីមួយៗមាន**មុំយុទ្ធសាស្ត្រ** ៤ គឺ ÷

ចតុកោណទី១ - ការលើកស្ទួយវិស័យកសិកម្ម មាន ÷ ទី១-ការលើកកំពស់ផលិតភាព និងពិពិធកម្មវិស័យកសិកម្ម ។ ទី២-កំណែទំរង់ដីធ្លី និងការបោសសំអាតមីន ។ ទី៣-កំណែទំរង់វិស័យនេសាទ និងជលផល ។ និង ទី៤-កំណែទំរង់ព្រៃឈើ ។

ចតុកោណទី២ - ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មាន ÷ ទី១-ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ (ផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស) ។ ទី២-ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ ។ ទី៣-ការអភិវឌ្ឍន៍វិស័យថាមពល និងបណ្តាញអគ្គិសនី ។ និងទី៤-ការអភិវឌ្ឍន៍បច្ចេកវិទ្យាពត៌មាន និងទូរគមនាគមន៍ ។

ចតុកោណទី៣ - ការអភិវឌ្ឍន៍ផ្នែកឯកជន និងការងារ មាន ÷ ទី១-ការពង្រឹងវិស័យឯកជន និងការទាក់ទាញទុនវិនិយោគ ។ ទី២-ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម ។ ទី៣-ការបង្កើតការងារ និងការធានាលក្ខខ័ណ្ឌការងារល្អប្រសើរជូនដល់កម្មករ និងនិយោជិត ។ និង ទី៤- ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គមសំរាប់មន្ត្រីបុគ្គលិក និងកម្មករ ។

ចតុកោណទី ៤ - ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស រួមមាន ÷ ទី១-ការលើកកំពស់ និងពង្រឹងគុណភាពនៃវិស័យអប់រំ ។ ទី២-ការលើកកំពស់សេវាសុខាភិបាល ។ ទី៣-ការអនុវត្តន៍គោលនយោបាយយេនឌ័រ ។ និងទី៤-ការអនុវត្តន៍គោលនយោបាយប្រជាជន ។

៨- ទោះបីរាជរដ្ឋាភិបាលបានសំរេចនូវវឌ្ឍនភាពគួរអោយកត់សំគាល់ក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួន ភាពប្រឈមចំបងបំផុតរបស់រាជរដ្ឋាភិបាល គឺការកាត់បន្ថយនូវភាពក្រីក្រ និងការធ្វើអោយប្រសើរឡើង នូវគុណភាពនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាដែលកំពុងតែមានកំណើនយ៉ាងលឿន ។ យុទ្ធសាស្ត្រចតុកោណគឺជាឧបករណ៍ខាងគោលនយោបាយ សំរាប់អោយរាជរដ្ឋាភិបាលអនុវត្ត ដើម្បីកាត់បន្ថយភាពក្រីក្រ ក្នុងនីតិកាលរបស់ខ្លួន ក្នុងគោលដៅឈានទៅសំរេចអោយបាន នូវបណ្តាគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា ។ រាជរដ្ឋាភិបាលទទួលស្គាល់ថា កម្ពុជានៅមានផ្លូវដ៏វែងអន្លាយសំរាប់ធ្វើដំណើរទៅមុខ ហើយត្រូវពុះពារ

ឆ្លងកាត់ឧបសគ្គរាប់មិនអស់ថែមទៀត ដើម្បីសំរេចបាននូវវឌ្ឍនភាព និងវិបុលភាពដ៏រុងរឿងថ្កើងថ្កានជូនប្រទេសជាតិ និងប្រជាជន ។ ពិតណាស់ រាជរដ្ឋាភិបាលទទួលស្គាល់ថា គ្រប់បញ្ហានៃភាពក្រីក្រពុំអាចនឹងត្រូវបានដោះស្រាយរួចស្រេចបាច់អស់ក្នុងរយៈពេលតែមួយថ្ងៃ ឬមួយខែ ឬមួយឆ្នាំនោះឡើយ ។ ក៏ប៉ុន្តែដោយមានកម្មវិធីច្បាស់លាស់ និងដោយមានការខិតខំប្រឹងប្រែងរួមគ្នាយ៉ាងឥតសំចៃពីបណ្តាភាគីពាក់ព័ន្ធ រាជរដ្ឋាភិបាលប្រាកដជាអាចធ្វើអោយមានការផ្លាស់ប្តូរជាវិជ្ជមានយ៉ាងច្រើន ក្នុងការលើកស្ទួយកំរិតជីវភាពរបស់ប្រជាជនក្នុងរយៈពេល៤ឆ្នាំខាងមុខ ។ តាមរយៈការអនុវត្តន៍នូវយុទ្ធសាស្ត្រចតុកោណ រាជរដ្ឋាភិបាលនឹងបន្តជំរុញអនុវត្តយ៉ាងម៉ឺងម៉ាត់ និងមធ្យ័តបំផុត នូវកម្មវិធីកំណែទំរង់ទាំងឡាយដែលមានលក្ខណៈកាន់តែទូលំទូលាយឡើង និងកាន់តែស៊ីជំរៅឡើង ពីព្រោះកំណែទំរង់គឺជាកិច្ចការស្លាប់រស់របស់កម្ពុជា ។

៩- រាជរដ្ឋាភិបាលសូមអំពាវនាវដល់គ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ រួមមានសហគមន៍អ្នកផ្តល់ជំនួយ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការនៅគ្រប់ក្រសួង- ស្ថាប័ន ទាំងស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ព្រមទាំងតុលាការ កងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋគ្រប់រូប សូមផ្តល់ការគាំទ្រគ្រប់បែបយ៉ាង និងសូមយកចិត្តទុកដាក់ចូលរួមអោយបានសកម្មជាមួយនឹងរាជរដ្ឋាភិបាល ដើម្បីអនុវត្តអោយបានជោគជ័យនូវ «កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី៣នៃរដ្ឋសភា» ពិសេសគឺយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដែលជារបៀបវារៈគោលនយោបាយសេដ្ឋកិច្ចនៃកម្មវិធីនយោបាយ នេះ ។

## សមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាលចាប់ពីកិច្ចប្រជុំពិគ្រោះយោបល់លើកទី៦ ខែមិថុនា ឆ្នាំ២០០២

១០- ចាប់តាំងពីកិច្ចប្រជុំពិគ្រោះយោបល់ដែលបានប្រារព្ធ ជាលើកទី១ នៅរាជធានីភ្នំពេញ នាខែមិថុនា ឆ្នាំ ២០០២ កន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងច្រើន សំដៅឈានទៅសំរេចអោយបាននូវគោលដៅជាយុទ្ធសាស្ត្រនានាដែលមានចែងនៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា ។ រាជរដ្ឋាភិបាលបានប្តេជ្ញាយកអស់កំលាំងកាយចិត្ត អនុវត្តតាមអនុសាសន៍ដ៏មានសារៈប្រយោជន៍របស់ដៃគូអភិវឌ្ឍន៍របស់កម្ពុជា ដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកមុន ។ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ត្រូវបានរៀបចំ និងប្រកាសអោយអនុវត្តនាខែមិនា ឆ្នាំ២០០៣ កំណែទំរង់ក្នុងវិស័យសារពើពន្ធ និងធនាគារត្រូវបានអនុវត្តកាន់តែស៊ីជំរៅ យុទ្ធសាស្ត្រស្តីពីកំណែទំរង់រដ្ឋបាលសាធារណៈត្រូវបានរៀបចំបញ្ចប់ និងកំពុងដាក់អោយអនុវត្ត យន្តការបែងចែកអំណាចដល់ថ្នាក់មូលដ្ឋានឃុំ- សង្កាត់តាមរយៈការបោះឆ្នោតក្រុមប្រឹក្សាឃុំ- សង្កាត់ក្នុងឆ្នាំ២០០២ កំពុងតែបានដំណើរការនិងពង្រឹងបន្ថែម យុទ្ធសាស្ត្រស្តីពីកំណែទំរង់ច្បាប់ និងតុលាការត្រូវបានរៀបចំនិងអនុវត្ត ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាពត្រូវបានពង្រឹងបន្ថែមតាមរយៈការអនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រងដីធ្លី ច្បាប់ព្រៃឈើ និងច្បាប់ស្តីពីសហគមន៍ព្រៃឈើ និងការបង្កើនលទ្ធភាពរបស់ជនក្រីក្រក្នុងការនេសាទ ។ អនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈត្រូវបានពង្រីកគ្របដណ្តប់លើចំណាយគ្រប់ក្រសួងនិងស្ថាប័នទាំងអស់ លើកលែងតែក្រសួងព្រះបរមរាជវាំង ។ ច្បាប់វិនិយោគត្រូវបាន

ធ្វើវិសោធនកម្មបន្ថែម ហើយអាជ្ញាធរសវនកម្មជាតិបានចាប់ដំណើរការ ។ ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសំរាប់រយៈពេល១០ឆ្នាំ២០០១-២០១០ត្រូវបានអនុម័ត និងកំពុងអនុវត្ត ។ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម៥ឆ្នាំ២០០១-២០០៥ ត្រូវបានរៀបចំ និងដាក់អោយអនុវត្ត ។

១១- នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ នាខែមិថុនា ឆ្នាំ២០០២ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បានឯកភាពកំណត់វិស័យអាទិភាពមួយចំនួនភ្ជាប់ជាមួយនឹងលក្ខខ័ណ្ឌវិនិច្ឆ័យ សំរាប់ការត្រួតពិនិត្យរួមគ្នា ។ កិច្ចខិតខំប្រឹងប្រែងរួមរបស់រាជរដ្ឋាភិបាលកន្លងមក បានស្តែងចេញជាវឌ្ឍនភាពគួរអោយកត់សំគាល់ នៅក្នុងវិស័យជាច្រើន ។ យើងគួរកត់សំគាល់ដែរថា បន្ទាប់ពីការបោះឆ្នោតសកលនាខែកក្កដា ឆ្នាំ២០០៣មក ការពន្យារពេលក្នុងការបង្កើតរាជរដ្ឋាភិបាល រួមជាមួយនឹងភាពមិនប្រាកដប្រជាមួយចំនួន បាននាំអោយមានការយឺតយ៉ាវជាបណ្តោះអាសន្ន ក្នុងការបន្តពង្រឹងចលនការដែលបានបង្កើតឡើងក្នុងរាជរដ្ឋាភិបាលសំរាប់នីតិកាលទី២ នៃរដ្ឋសភា ។ បន្ទាប់ពីការបង្កើតរាជរដ្ឋាភិបាលសំរាប់នីតិកាលទី៣ នៃរដ្ឋសភា នាខែកក្កដា ឆ្នាំ២០០៤ រួចមករាជរដ្ឋាភិបាលនៅតែបន្តអនុវត្តការប្តេជ្ញាយ៉ាងហ្មត់ចត់ ក្នុងការដ្ឋានកំណែទំរង់របស់ខ្លួន ។ ខាងក្រោមនេះគឺជាការសង្ខេបអំពីវឌ្ឍនភាពតាមវិស័យអាទិភាព ចាប់ពីកិច្ចប្រជុំពិគ្រោះយោបល់ខែមិថុនា ឆ្នាំ២០០២ ទោះបីរាជរដ្ឋាភិបាលត្រូវជួបប្រទះបញ្ហាប្រឈមជាច្រើនក៏ដោយ ។

១២- **កាលបរិច្ឆេទច្បាស់លាស់ក្នុងការរៀបចំបញ្ចប់យុទ្ធសាស្ត្រស្តីពីកំណែទំរង់ច្បាប់និងតុលាការ** : រាជរដ្ឋាភិបាលបានសំរេចលទ្ធផលមួយចំនួនគួរអោយកត់សំគាល់ ក្នុងការដ្ឋានកំណែទំរង់ច្បាប់ និងតុលាការ ។ រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងតុលាការ កាលពីខែមិថុនាឆ្នាំ២០០២ ដែលសហដឹកនាំដោយអតីតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានតុលាការកំពូល ។ អង្គភាពសំរបសំរួលអចិន្ត្រៃយ៍ត្រូវបានបង្កើតឡើង កាលពីខែសីហា ឆ្នាំ២០០២ ដោយមានការចូលរួមពីតំណាងស្ថាប័នពាក់ព័ន្ធសំខាន់ៗរបស់រាជរដ្ឋាភិបាល ។ បន្ទាប់មក ក្នុងខែធ្នូ ឆ្នាំ២០០២ អង្គភាពគ្រប់គ្រងគំរោងមួយក៏ត្រូវបានបង្កើតឡើង ដើម្បីជួយការងារអង្គភាពសំរបសំរួលអចិន្ត្រៃយ៍ និងក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និង តុលាការ ។ ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងតុលាការ យុទ្ធសាស្ត្រស្តីពីកំណែទំរង់ច្បាប់និងតុលាការត្រូវបានរៀបចំបញ្ចប់ និងត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីកាលពីខែមិថុនា ឆ្នាំ២០០៣ ។ យុទ្ធសាស្ត្រនេះមានគោលដៅជាសារវន្ត ៧ ដូចខាងក្រោម ÷

ទី១-លើកកំពស់ការការពារសិទ្ធិ និងសេរីភាពជាមូលដ្ឋាន ។

ទី២-ទំនើបកម្មក្របខ័ណ្ឌច្បាប់ ។

ទី៣-កែលំអការផ្តល់ពត៌មានលើបញ្ហានានាដែលពាក់ព័ន្ធនឹងច្បាប់ និងតុលាការ ។

ទី៤-លើកកំពស់គុណភាពនៃដំណើរការយុត្តិធម៌ និងសេវាតុលាការ ។

ទី៥-ពង្រឹងការផ្តល់សេវាយុត្តិធម៌ ដូចជាអំណាចតុលាការ និងសេវារបស់ព្រះរាជអជ្ញា ។

ទី៦-ជំរុញអោយមានយន្តការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ ។

ទី៧-ពង្រឹងសមត្ថភាពខាងស្ថាប័នតុលាការនិងយុត្តិធម៌ ដើម្បីបំពេញភារកិច្ច ។

១៣- ព្រមជាមួយគ្នានេះ សេចក្តីព្រាងផែនការសកម្មភាពសំរាប់អនុវត្តយុទ្ធសាស្ត្រកំណែទំរង់ច្បាប់និងតុលាការ ក៏ត្រូវបានរៀបចំ នាខែមិថុនា ឆ្នាំ២០០៣ ។ ផែនការសកម្មភាពនេះបានក្លាយជាមូលដ្ឋានសំរាប់ការពិភាក្សានៅក្នុងសិក្ខាសាលាថ្នាក់ជាតិ ដែលត្រូវបានរៀបចំឡើងក្រោមការដឹកនាំរបស់អង្គភាពសំរបសំរួលអចិន្ត្រៃយ៍ ដោយមានការចូលរួមពីក្រសួងនិងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកផ្តល់ជំនួយ ។ បន្ទាប់ពីសិក្ខាសាលា ការពិគ្រោះយោបល់ដ៏ទូលំទូលាយត្រូវបានរៀបចំឡើង ដែលនាំទៅដល់ការរៀបចំផែនការអាទិភាពសំរាប់រយៈពេលខ្លី និងមធ្យម ។ ផែនការសកម្មភាពរយៈពេលខ្លី ២០០៤-២០០៦ រួមមានចំណុចជាអាទិភាពចំនួន ៣៣ ដែលគ្របដណ្តប់លើគោលដៅយុទ្ធសាស្ត្រទាំង៧ខាងលើ ។ ផែនការសកម្មភាពរយៈពេលមធ្យមបានកំណត់អាទិភាព ២៧បន្ថែមទៀត ដែលត្រូវសំរេចអោយបាននាដំណាច់ឆ្នាំ ២០០៨ ។ ផែនការសកម្មភាពទាំងនេះបានទទួលស្គាល់នូវដំណើរការដ៏រស់រវើកមួយ សំដៅឈានទៅសំរេចអោយបាននូវគោលដៅជាយុទ្ធសាស្ត្រដែលបានកំណត់ឡើងនៅក្នុងយុទ្ធសាស្ត្រកំណែទំរង់ច្បាប់និងតុលាការ ។

១៤- **ការកែសំរួលរចនាសម្ព័ន្ធនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម** : វិសោធនកម្មលើច្បាប់ស្តីពីអង្គការ ចាត់តាំង និងការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី ហើយបច្ចុប្បន្នកំពុងរង់ចាំការអនុម័តពីស្ថាប័ននីតិបញ្ញត្តិ ។ ទន្ទឹមនេះ ការកែសំរួលរចនាសម្ព័ន្ធនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកំពុងត្រូវបានដំណើរការ ។ អគ្គលេខាធិការដ្ឋានត្រូវបានបង្កើត ដែលបច្ចុប្បន្នកំពុងពិនិត្យអំពីតំរូវការនានា ដើម្បីអោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចដំណើរការបានពេញលេញ ។ នាខែមករា ឆ្នាំ២០០៣ រាជរដ្ឋាភិបាលបានសំរេចតំលើងប្រាក់បំណាច់ជូនចៅក្រម និងអយ្យការតុលាការ ។ សាលាភូមិន្ទនៃអង្គចៅក្រម និងមជ្ឈមណ្ឌលបណ្តុះបណ្តាលអ្នកច្បាប់បាន និងកំពុងដំណើរការ ។«តុលាការគំរូ»មួយត្រូវបានបង្កើតឡើងនៅខេត្តកណ្តាល ដើម្បីសាកល្បងអនុវត្តនូវគំរូប្រតិបត្តិល្អៗក្នុងការដោះស្រាយរឿងក្តី ។ ទព្វសំភារៈសំរាប់បំរើការចាំបាច់ដល់ការប្រព្រឹត្តិទៅរបស់តុលាការគំរូ នឹងត្រូវបញ្ចប់ត្រឹមដំណាច់ ឆ្នាំ ២០០៦ ។ យើងកំពុងដំណើរការបង្កើតតុលាការឯកទេសមួយចំនួនផងដែរ ដូចជាតុលាការពាណិជ្ជកម្ម តុលាការអនីតិជន និងតុលាការរដ្ឋបាល ។ ស្ថាប័នគាំទ្រស្នូល ដូចជាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រុមប្រឹក្សាអ្នកច្បាប់ ក្រសួងយុត្តិធម៌ និងយន្តការគាំទ្រកម្មវិធីកំណែទំរង់ច្បាប់និងតុលាការ ដូចជាអង្គភាពសំរបសំរួលអចិន្ត្រៃយ៍ និងអង្គភាពគ្រប់គ្រងគំរោងកំពុងត្រូវបានពិនិត្យមើលឡើងវិញនិងពង្រឹងបន្ថែមទៀត ។ រាជរដ្ឋាភិបាលកំពុងតំរែតំរង់ធនធានសំរាប់អនុវត្តកម្មវិធីកំណែទំរង់ទាំងនេះ ។ ប៉ុន្តែ មកទល់ពេលនេះ ថវិកាសំរាប់ការងារនេះភាគច្រើនបានមកតែពីថវិកា របស់រាជរដ្ឋាភិបាលប៉ុណ្ណោះ ។

១៥- **ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម** : រាជរដ្ឋាភិបាលកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈរបស់ចៅក្រម និងច្បាប់អង្គការស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់អង្គតុលាការ ។ សេចក្តីព្រាងច្បាប់ទាំងនេះគ្រោងនឹងដាក់ជូនស្ថាប័ននីតិបញ្ញត្តិអនុម័តក្នុងឆ្នាំ២០០៥ ស្របតាមអាទិភាពការងារដែលមានចែងក្នុងផែនការសកម្មភាពសំរាប់កំណែទំរង់ច្បាប់ និងតុលាការរយៈពេលខ្លី ។

១៦- **សមិទ្ធផលផ្សេងៗទៀត** រួមមានការអនុម័តច្បាប់ស្តីពីការការពារសិទ្ធិមនុស្ស ច្បាប់ស្តីពីការវិនិយោគ ច្បាប់ពាណិជ្ជកម្ម និងច្បាប់ស្តីពីការគ្រប់គ្រងធនធានធម្មជាតិ ។ លើសពីនេះ ក្រម និងនីតិវិធីច្បាប់រដ្ឋប្បវេណី ព្រមទាំងក្រម និងនីតិវិធីព្រហ្មទណ្ឌត្រូវបានរៀបចំ ហើយកំពុងពិនិត្យឡើងវិញដោយក្រុមប្រឹក្សាអ្នកច្បាប់ ដើម្បីស្នើជូនគណៈរដ្ឋមន្ត្រី និងស្ថាប័ននីតិបញ្ញត្តិពិនិត្យ និងអនុម័ត នាឆ្នាំ២០០៥ ។

១៧- ទោះបីដៃគូអភិវឌ្ឍន៍របស់កម្ពុជាបានយល់អំពីសារសំខាន់នៃកំណែទំរង់ប្រព័ន្ធតុលាការក៏ដោយ ក៏រហូតមកដល់ពេលនេះ កំណែទំរង់នេះបានទទួលការជួយឧបត្ថម្ភតិចតួចបំផុតពីដៃគូអភិវឌ្ឍន៍ ។ «ការអង្កេតស្តីពីបរិយាកាសវិនិយោគ» បានកំណត់ថាកំណែទំរង់តុលាការជាការងារសំខាន់បំផុតមួយ សំរាប់បង្កើតបរិយាកាសអំណោយផលដល់ការអភិវឌ្ឍន៍វិស័យឯកជន ។ ការបង្កើនលទ្ធភាពរបស់ជនក្រីក្រក្នុងការទទួលសេវា យុត្តិធម៌ និងតុលាការគឺជាកត្តាសំខាន់មួយក្នុងការដោះស្រាយភាពអយុត្តិធម៌ លើកកំពស់ទំនុកចិត្តរបស់ប្រជាពលរដ្ឋលើនីតិរដ្ឋ កែលំអស្ថានភាពរស់នៅ និងកាត់បន្ថយភាពក្រីក្រលំបាក ។

១៨- ភាពស្មុគស្មាញនៃកំណែទំរង់ច្បាប់និងតុលាការក៏បណ្តាលមកពីបរិស្ថានសង្គមរបស់កម្ពុជាផងដែរ ។ សង្គ្រាមរ៉ាំរ៉ៃជាងបីទសវត្សរ៍ និងជំលោះផ្ទៃក្នុង បានបន្សល់នូវស្លាកស្នាមអតីតកាលមួយដ៏តានតឹង ។ កំណើនយ៉ាងឆាប់រហ័សនៃចំនួនប្រជាជនដែលមានវ័យក្មេង និងបំរែបំរួលដ៏ឆាប់រហ័សនៃសង្គមដែលបណ្តាលមកពីការរីកចំរើននៃបច្ចេកវិទ្យា និងការចូលរួមក្នុងតំបន់និងពិភពលោក បាននាំអោយមានការប្រែប្រួលនូវតំលៃ និងសេចក្តីថ្លៃថ្នូរសង្គម ។ សង្គមកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលអន្តរកាលនេះ ។ ព្រមជាមួយនេះ ដោយសារកង្វះខាតអ្នកឯកទេសច្បាប់ ក្របខ័ណ្ឌច្បាប់របស់កម្ពុជាបច្ចុប្បន្នទទួលឥទ្ធិពលយ៉ាងច្រើន ពីសំណាក់អ្នកឯកទេសបរទេស ។ កត្តានេះបានបង្កើតអោយមានភាពមិនស៊ីសង្វាក់គ្នា ដែលធ្វើអោយការអនុវត្តន៍ច្បាប់ជួបប្រទះការលំបាក ។ ការអនុវត្តន៍ច្បាប់នៅតែជាបញ្ហាប្រឈម ដោយមានមូលហេតុជាច្រើន ក្នុងនោះមានកំរិតប្រាក់បៀវត្សទាប ។ យើងពិតជាមានការលំបាកក្នុងការអនុវត្តន៍ច្បាប់អោយបានត្រឹមត្រូវ ច្បាស់លាស់ និងមានតំលាភាព នៅពេលដែលប្រាក់បៀវត្សរបស់មន្ត្រី អនុវត្តច្បាប់មានកំរិតទាបជាងកំរិតអប្បបរមាសំរាប់ជីវភាពរស់នៅ ។

១៩- រាជរដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់ទៅលើការរៀបចំក្របខ័ណ្ឌគតិយុត្តិ សំរាប់ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចទីផ្សារ និងសំរាប់ជំរុញការរីកចំរើនខាងផ្នែកពាណិជ្ជកម្មនិងការវិនិយោគ ដោយបានរៀបចំក្របខ័ណ្ឌគតិយុត្តិស្តីពីកម្មសិទ្ធិ ការបង្កើតអត្តសញ្ញាណធុរៈកិច្ច ប្រព័ន្ធធនាគារ ប្រព័ន្ធពន្ធដារនិងគណនេយ្យ ការធានារ៉ាប់រង សន្តិសុខអន្តរកម្ម ច្បាប់សហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីក្ស័យធន ច្បាប់ស្តីពីកិច្ចសន្យា និងឥណទានពាណិជ្ជកម្ម ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ដើម្បីធានាកិច្ចដំណើរការក្នុងវិស័យហិរញ្ញវត្ថុអោយមានប្រសិទ្ធភាព ។

២០- ដើម្បីបង្កើនលទ្ធភាពទទួលពត៌មានរបស់ប្រជាពលរដ្ឋទូទៅស្តីពីប្រព័ន្ធច្បាប់និងតុលាការ រាជរដ្ឋាភិបាលបានបង្កើតអគ្គនាយកដ្ឋានរាជកិច្ច ដែលដំណើរការក្នុងទ្រង់ទ្រាយជាអង្គភាពពាណិជ្ជកម្ម ។ ប្រធានតុលាការ

កំពូល (ចៅក្រមកំពូល) បានប្ដេជ្ញាបោះពុម្ពផ្សាយនូវសេចក្ដីសំរេចរបស់តុលាការ ដើម្បីធានាតំលាភាពនៃសេចក្ដីសំរេចទាំងនេះ ព្រមទាំងដើម្បីចងក្រងទុកជាយុត្តិសាស្ត្រកម្ពុជា (Cambodiam Jurisprudence) ។ ការប្រមូលសាលក្រមរបស់តុលាការកំពុងដំណើរការនាពេលបច្ចុប្បន្ននេះ ។

២១- សេចក្ដីព្រាងច្បាប់ប្រឆាំងនឹងអំពើពុករលួយត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣ កន្លងមក ហើយក៏បានស្នើជូនសភាជាតិអនុម័ត កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៣ ។ សភាជាតិបានបញ្ជូនសេចក្ដីព្រាងច្បាប់នេះត្រឡប់មករាជរដ្ឋាភិបាល ដើម្បីពិនិត្យឡើងវិញ ។ ការពិនិត្យសេចក្ដីព្រាងច្បាប់ឡើងវិញត្រូវបានដំណើរការយឺតៗដោយសារការពន្យារពេលក្នុងការបង្កើតរាជរដ្ឋាភិបាល ។ ផ្អែកតាមធាតុចូល ដែលផ្ដល់ដោយដៃគូអភិវឌ្ឍន៍ក្នុងកិច្ចប្រជុំត្រៀម នាខែកញ្ញា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលនឹងពិនិត្យ បញ្ចប់ ហើយសេចក្ដីព្រាងច្បាប់នឹងត្រូវបញ្ជូនទៅស្ថាប័ននីតិបញ្ញត្តិក្នុងពេលឆាប់ៗខាងមុខនេះ ។ រាជរដ្ឋាភិបាលបាន ឯកភាពជាមួយដៃគូអភិវឌ្ឍន៍ថា យើងត្រូវអនុវត្តតាមអភិក្រមប្រកបដោយលក្ខណៈសន្តនិយម (Holistic Appraoch) ក្នុងការប្រឆាំនឹងអំពើពុករលួយ ។ ទន្ទឹមនឹងការអនុម័តច្បាប់ដែលជាជំហានសំខាន់មួយ ការកសាងសមត្ថភាពសំរាប់អនុវត្តច្បាប់ក៏ជាកត្តាសំខាន់ស្មើគ្នាដែរ ។ ក្នុងការប្រឆាំងនឹងអំពើពុករលួយ ដែលជះឥទ្ធិពលដល់ស្ថានភាពសេដ្ឋកិច្ចជាទូទៅ និងការកាត់បន្ថយភាពក្រីក្រ យើងក៏ត្រូវយកចិត្តទុកដាក់ដល់វិធានការមួយចំនួនផ្សេងទៀតដែរ ។ វិធានការទាំងនោះរួមមាន ÷ ការកែលំអទំរង់ការបែបបទរដ្ឋបាល ការធ្វើអោយសាមញ្ញ និងទំនើបកម្មប្រព័ន្ធពន្ធដារ ការកាត់បន្ថយលិខិតបទដ្ឋានច្រើនហួសហេតុ ការលើកទឹកចិត្តមន្ត្រីរាជការ តាមរយៈប្រាក់បៀវត្ស ដើម្បីកាត់បន្ថយកាលានុវត្តភាពនៃអំពើពុករលួយ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏យល់ថា ការកែប្រែឥរិយាបថរបស់ប្រជាជនទាមទារនូវពេលវេលាសមស្របដែរ ។

២២- **ករណីអំពើពុករលួយដែលបានរកឃើញ និងផ្ដន្ទាទោស** : ទោះជាមានការលំបាក និងស្មុគស្មាញយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលបានសំរេចលទ្ធផលគួរអោយកត់សំគាល់មួយចំនួន ក្នុងការប្រយុទ្ធប្រឆាំងដល់ឬសគល់នៃអំពើពុករលួយ ។ ការប្រយុទ្ធនឹងអំពើកាប់ឈើខុសច្បាប់ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវចំណូល- ចំណាយរដ្ឋ ការកាត់បន្ថយចំនួនខ្មោចចេញពីបញ្ជីមន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធ ការរឹបអូសដីដែលលក់ ឬកាន់កាប់ខុសច្បាប់ គឺជាបណ្ដាវិធានការប្រឆាំងនឹងអំពើពុករលួយ ។ ទន្ទឹមនេះ អាជ្ញាធរជាតិសវនកម្មត្រូវបានបង្កើត និងកំពុងដំណើរការ សំរាប់ជាយន្តការត្រួតពិនិត្យ (Check and Balance Mechanism) សំរាប់ត្រួតពិនិត្យការប្រមូលចំណូល និងការគ្រប់គ្រងចំណាយ ។ អង្គភាពសវនកម្មផ្ទៃក្នុងតាមក្រសួងត្រូវបានបង្កើត និងកំពុងពង្រឹងសមត្ថភាព ។ អាជ្ញាធរជាតិសវនកម្មបាននិងកំពុងធ្វើការជាមួយបណ្ដាអង្គភាពសវនកម្មផ្ទៃក្នុងទាំងនេះ ដើម្បីពង្រឹងតំលាភាព និងគណនេយ្យភាព ។

២៣- ការអនុវត្តន៍អនុក្រឹត្យស្ដីពីលទ្ធកម្មសាធារណៈ បានពង្រីកវិសាលភាពគ្របដណ្ដប់លើគ្រប់ប្រភេទចំណាយរបស់គ្រប់ក្រសួងទាំងអស់របស់រាជរដ្ឋាភិបាល លើកលែងតែក្រសួងព្រះបរមរាជវាំង ។

២៤- ដោយរក្សាបាននូវការប្តេជ្ញាចិត្តដែលមានកន្លងមក រាជរដ្ឋាភិបាលមិនបានផ្តល់សម្បទានព្រៃឈើថ្មីណាមួយឡើយ ចាប់តាំងពីថ្ងៃទី១ ខែមករា ឆ្នាំ២០០២ ។ ប៉ុន្តែ រាជរដ្ឋាភិបាលបានអនុញ្ញាតអោយមានប្រតិបត្តិការទ្រង់ទ្រាយតូចលើសំណល់ព្រៃឈើ (ដូចជា ការកាប់គាស់ប្រមូលគល់ឈើ) និងការងារមួយចំនួនទៀត ដែលត្រូវបានអនុញ្ញាតក្រោមបញ្ញត្តិ និងច្បាប់របស់កម្ពុជា ។ សម្បទានិកត្រូវស្នើផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងព្រៃឈើ (Strategic Forest Management Plan-SFMP) ដោយភ្ជាប់ជាមួយនឹងការវាយតំលៃផលប៉ះពាល់សង្គមនិងបរិស្ថាន (Environment and Social Impact Assessments-ESAI) ក្នុងខែកញ្ញា ឆ្នាំ ២០០២ ។ សម្បទានិកចំនួន ១៣ បានស្នើឯកសារទាំងនេះ នៅខែវិច្ឆិកា ឆ្នាំ២០០២ ហើយដែលឯកសារទាំងនេះត្រូវបានប្រើប្រាស់សំរាប់ពិគ្រោះយោបល់ជាមួយនឹងសហគមន៍ដែលទទួលផលប៉ះពាល់ ។

២៥- ចំពោះការផ្សព្វផ្សាយជាសាធារណៈ និងការផ្តល់កាលានុវត្តភាពអោយអ្នកជំនាញឯករាជ្យផ្តល់អនុសាសន៍មុនការសំរេចរបស់រាជរដ្ឋាភិបាលលើផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងព្រៃឈើ និងការវាយតំលៃផលប៉ះពាល់សង្គមនិងបរិស្ថាន ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីធនាគារពិភពលោក រាជរដ្ឋាភិបាលបានពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងព្រៃឈើ និងការវាយតំលៃផលប៉ះពាល់ ដែលបានស្នើឡើងដោយសម្បទានិក ។ រាជរដ្ឋាភិបាលបានធ្វើការផ្សព្វផ្សាយឯកសារទាំងនេះ ជូនដល់សហគមន៍ពាក់ព័ន្ធ ។ ដោយសារភាពស្មុគស្មាញផ្នែកបច្ចេកទេសនៃផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងព្រៃឈើ និងការវាយតំលៃផលប៉ះពាល់ សហគមន៍មូលដ្ឋានមិនអាចផ្តល់យោបល់ភ្លាមៗបានទេ ។ ដូចនេះ រដ្ឋបាលព្រៃឈើបានផ្តល់ពេលវេលាដោយគ្មានកំណត់សំរាប់បញ្ចប់ដំណើរការពិគ្រោះយោបល់របស់ពួកគេ ។ រដ្ឋបាលព្រៃឈើបានផ្សព្វផ្សាយឯកសារទាំងនេះ ដល់សហគមន៍មូលដ្ឋាន ២៨៥ភូមិ ដែលមានទីតាំងនៅក្នុង ឬនៅជុំវិញតំបន់ព្រៃសម្បទាន ។ ក្រុមការងាររបស់រដ្ឋបាលព្រៃឈើបានពិភាក្សាជាមួយសហគមន៍មូលដ្ឋាន ហើយបានកត់ត្រាបណ្តាកង្វល់ទាំងឡាយដែលសហគមន៍បានលើកឡើង ។ លើសពីនេះ រដ្ឋបាលព្រៃឈើបានតំរូវអោយសម្បទានិកស្វែងរកដំណោះស្រាយ អំពីកង្វល់ដែលបានលើកឡើង និងបញ្ចូលដំណោះស្រាយទាំងនេះទៅក្នុងផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងព្រៃឈើ និងការវាយតំលៃផលប៉ះពាល់ ។ នៅត្រឹមដំណាច់ខែកក្កដា ឆ្នាំ២០០៣ ក្រុមការងារត្រួតពិនិត្យផ្នែកបច្ចេកទេសរបស់រដ្ឋបាលព្រៃឈើ ដោយមានជំនួយឧបត្ថម្ភ បច្ចេកទេសពីធនាគារពិភពលោក បានបញ្ចប់ការពិនិត្យដំបូងរបស់ខ្លួន លើផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងព្រៃឈើចំនួន១២ ។ ផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងព្រៃឈើ ដែលបានពិនិត្យឡើងវិញនេះកំពុងត្រូវបានត្រួតពិនិត្យមើលបន្ថែមទៀត ដោយក្រុមការងារឯករាជ្យស្តីពីការគ្រប់គ្រងធនធានធម្មជាតិរបស់សហគមន៍អ្នកផ្តល់ជំនួយ ។ ដើម្បីធានាតំលាភាពក្នុងដំណើរការវាយតំលៃ និងដើម្បីកាត់បន្ថយ " ការមិនជឿទុកចិត្ត និងការមន្ទិលសង្ស័យ " ដែលអាចកើតមាន ហើយដែលក្នុងករណីខ្លះ អាចបំភ្លៃមតិសាធារណៈ រដ្ឋបាលព្រៃឈើបានផ្តួចផ្តើមគំនិតបង្កើតការិយាល័យកិច្ចការសាធារណៈ ដើម្បីពង្រឹងការប្រាស្រ័យទាក់ទងជាមួយភាគីពាក់ព័ន្ធ ។

២៦- រាជរដ្ឋាភិបាលបានលុបអជ្ញាប័ណ្ណរបស់សម្បទានិក ដែលមិនបានស្នើផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងព្រៃឈើ និងការវាយតំលៃផលប៉ះពាល់ ។ ចាប់ពីឆ្នាំ១៩៩៩ រហូតមកដល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលបានប្រកាសលុបកិច្ចព្រមព្រៀង និងដកហូតអជ្ញាប័ណ្ណពីក្រុមហ៊ុនចំនួន១៧ លើផ្ទៃដីចំនួន២៤កន្លែង ដែលមានផ្ទៃដីប្រមាណ ៣,៥លានហិកតា ។ រាជរដ្ឋាភិបាលបានលុបចោលកិច្ចព្រមព្រៀងសម្បទានចំនួន៥(ក្រុមហ៊ុន Hero Taiwan, Wood Tee Peanich, GAT International, Mieng LY Heng និង Kignwood) ក្នុងពេលដំណើរការពិនិត្យមើលពីផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងព្រៃឈើ ។ រហូតមកដល់ពេលនេះ ក្រុមហ៊ុនសម្បទានព្រៃឈើចំនួន ១២ កំពុងរៀបចំកិច្ចព្រមព្រៀងសម្បទានឡើងវិញ ដើម្បីធានាចីរភាពនៃព្រៃឈើស្របតាមស្តង់ដារអន្តរជាតិ ។ ក្រុមហ៊ុនទាំង១២ នេះទទួលសម្បទានផ្ទៃដីព្រៃតិចជាង ៤,៤លានហិកតា ។ លើសពីនេះ រាជរដ្ឋាភិបាលបានផ្អាកការធ្វើអាជីវកម្មឈើរបស់សម្បទានិកទាំងអស់ រហូតដល់ពេលណាដែលផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងព្រៃឈើ និងការវាយតំលៃផលប៉ះពាល់ខាងបរិស្ថាន និងសង្គម ត្រូវបានពិនិត្យ វាយតំលៃ និងអនុម័តជាផ្លូវការពីរាជរដ្ឋាភិបាល ។

២៧- រាជរដ្ឋាភិបាលបានប្រឹងប្រែងយ៉ាងសកម្មក្នុងការទប់ស្កាត់ការធ្វើអាជីវកម្មឈើខុសច្បាប់ ។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីរដ្ឋបាលព្រៃឈើ ៧ រូបត្រូវស្លាប់ និង៣៤ រូបទៀត ត្រូវរងរបួស ។ រោងចក្រអារឈើខុសច្បាប់ប្រមាណ១.៣៨៦ សិប្បកម្មកែច្នៃឈើ៦៥៣ សិប្បកម្មកែច្នៃវល្លិ៍៣៩ សិប្បកម្មកែច្នៃជ័រឈើ២៤ និងឧបករណ៍កែច្នៃមួយចំនួន១៥៩ត្រូវបានរឹបអូស បំផ្លាញចោល និងបិទជាស្ថាពរ ។ អ្នកការពារអំពើខុសច្បាប់ចំនួន៣៣២ នាក់ ត្រូវបានឃាត់ខ្លួន ហើយរៀបចំសំណុំបែបបទបញ្ជូនទៅតុលាការ ។

២៨- ការកាប់ព្រៃឈើខុសច្បាប់ ការរត់ពន្ធសត្វព្រៃ ការទន្ទ្រានដីព្រៃ ត្រូវកាត់បន្ថយមកនៅត្រឹមកំរិតអាចគ្រប់គ្រងបាន ។ វិធានការដែលរាជរដ្ឋាភិបាលប្រកាន់យកក្នុងការបង្ក្រាបបទល្មើសព្រៃឈើ មាន ÷ ការរឹតបន្តឹងក្នុងការអនុវត្តន៍ច្បាប់ព្រៃឈើ បង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើស ។ អភិក្រមដែលរាជរដ្ឋាភិបាលប្រកាន់យកក្នុងការគ្រប់គ្រងធនធានធម្មជាតិ ដែលរួមមានកំណែទំរង់ក្នុងការគ្រប់គ្រងសម្បទាន សហគមន៍ព្រៃឈើ និងការគ្រប់គ្រងតំបន់ព្រៃការពារ គឺសំដៅកាត់បន្ថយបទល្មើសព្រៃឈើនានា ។ ក្នុងពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានចេញសារាចរណែនាំលេខ ០១ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៤ ដើម្បីទប់ស្កាត់ និងលុបបំបាត់ការទន្ទ្រាន និងការរំលោភដីព្រៃ ហើយក៏បានបង្កើតគណៈកម្មាធិការថ្នាក់ជាតិ និងអនុគណៈកម្មាធិការថ្នាក់ខេត្ត ដើម្បីអនុវត្តសារាចរនេះ ។

២៩- ដូចបានជំរាបជូនខាងដើម ការអនុវត្តន៍អោយបានស្របនឹងតំរូវការនៃការវាយតំលៃអំពីផលប៉ះពាល់ខាងបរិស្ថាន និងសង្គមកិច្ច គឺជាផ្នែកមួយនៃការពិនិត្យឡើងវិញអំពីព្រៃសម្បទាន ។ នៅខែធ្នូ ឆ្នាំ២០០៣ រាជរដ្ឋាភិបាលបានអនុម័តអនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើ ។ អនុក្រឹត្យនេះបានអនុញ្ញាតអោយរាជរដ្ឋាភិបាលប្រគល់ទ្រព្យសម្បត្តិព្រៃឈើសាធារណៈ អោយស្ថិតនៅក្រោមការទទួលខុសត្រូវរបស់សហគមន៍មូលដ្ឋាន ក្នុងក្របខ័ណ្ឌផែនការគ្រប់គ្រង និងការរៀបចំបែងចែកផលប្រយោជន៍ ។ អនុក្រឹត្យនេះ គឺជាលទ្ធផលនៃការពិគ្រោះយោបល់រយៈពេលជាង ៦ឆ្នាំ ជាមួយនឹងភាគីពាក់ព័ន្ធ និងទីប្រឹក្សាជាច្រើន ហើយនេះក៏ជាការបំពេញ

បន្ថែមលើវិធានការផ្សេងទៀត ដូចជា អនុក្រឹត្យស្តីពីការផ្តល់សម្បទានដីសង្គមកិច្ច ដែលរាជរដ្ឋាភិបាលកំពុងបន្តអនុវត្ត ដើម្បីធានាការគ្រប់គ្រងធនធានដីធ្លីមានភាពប្រសើរ និងមានប្រយោជន៍ជាងមុន ។ រាជរដ្ឋាភិបាលបានធ្វើការក្នុងភាពជាដៃគូជាមួយអ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលជាច្រើន ក្នុងការសាកល្បងអនុវត្តគំរោងសហគមន៍ព្រៃឈើនៅតាមតំបន់នានា ។ ផ្ទៃដីប្រមាណ ១១០.០០០ហិកតា ត្រូវបានអភិវឌ្ឍតាមយន្តការ «សហគមន៍ព្រៃឈើ» ។

៣០- រាជរដ្ឋាភិបាលបានអនុម័តអនុក្រឹត្យស្តីពីសម្បទានដីសង្គម នៅខែមិនា ឆ្នាំ២០០៣ ។ ដោយអនុវត្តស្មារតីនៃអនុក្រឹត្យនេះទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ខេត្ត-ក្រុង និងថ្នាក់ស្រុក-ខ័ណ្ឌ គំរោងសាកល្បងត្រូវបានអនុវត្តនៅក្នុងឃុំ ៣ និង សង្កាត់ ១ ក្នុងខេត្តបាត់ដំបង កំពត កំពង់ស្ពឺ និងក្រុងភ្នំពេញ ។ ផ្អែកតាមលទ្ធផលនៃគំរោងសាកល្បង និងការវាយតំលៃផលប៉ះពាល់សង្គមនៃភាពក្រីក្រ (Poverty Social Impact Assessment) នៃគំរោងសម្បទានដីសង្គមកិច្ច ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដោយបានសហការជាមួយបណ្តាដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា បាននិងកំពុងរៀបចំកម្មវិធីបែងចែកដីធ្លី សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច (Program for Land Allocation for Social and Economic Development-LASED) ។

៣១- ព្រះរាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទត្រូវបានពិភាក្សាបញ្ចប់រួចជាស្ថាពរ ហើយកំពុងរង់ចាំការអនុម័តរបស់គណៈរដ្ឋមន្ត្រី នាពេលឆាប់ៗខាងមុខនេះ ។ បច្ចុប្បន្ន ទោះបីជារាជរដ្ឋាភិបាលពុំទាន់បានអនុម័តលិខិតបទដ្ឋានទាំងនេះក្តី ក៏សហគមន៍នេសាទចំនួន ៣៦០ ត្រូវបានបង្កើតនៅទូទាំងប្រទេស ក្រោមជំនួយឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍ ។ រីឯច្បាប់ជលផលក៏ត្រូវបានពិនិត្យឡើងវិញដោយគណៈរដ្ឋមន្ត្រី ហើយនឹងត្រូវដាក់ជូនស្ថាប័ននីតិបញ្ញត្តិពិនិត្យអនុម័តក្នុងពេលដ៏ខ្លីខាងមុខនេះ ។

៣២- **ថវិកាចំណាយសំរាប់ក្រសួងអាទិភាពទាំងបួន បានកើនឡើងដល់ ៣,៦% នៃផ.ស.ស** : បន្ទាប់ពី កិច្ចប្រជុំពិគ្រោះយោបល់លើកទី៦ ដោយមានការជួយឧបត្ថម្ភពីមូលនិធិរូបិយវត្ថុអន្តរជាតិ វិទ្យាស្ថានជាតិស្ថិតិបានធ្វើបច្ចុប្បន្នភាពបញ្ចប់នាចុងឆ្នាំ២០០២ អំពីទិន្នន័យ ផ.ស.ស ដែលមានចាប់ពីឆ្នាំ១៩៩៣មក ។ វិទ្យាស្ថានស្ថិតិបានផ្លាស់ប្តូរទិន្នន័យ ផ.ស.ស ខ្លះ ដោយផ្អែកតាមតួលេខកែសំរួលរបស់ក្រសួងជំនាញ និងស្ថាប័នរបស់រាជរដ្ឋាភិបាល ព្រមជាមួយនឹងវិធីសាស្រ្តប្រមូលទិន្នន័យដែលបានកែសំរួល ។ ជាលទ្ធផលយើងកត់សំគាល់ឃើញមានកំណើន ផ.ស.ស ចាប់ពីឆ្នាំ១៩៩៣មក ។ ក្នុងដំណាក់កាលឆ្នាំ១៩៩៨-២០០២ តាមតំលៃចរន្ត ផ.ស.ស បានកើនឡើងខ្ពស់ជាងមុនបន្តិច ជាក់ស្តែង ១០,១% សំរាប់ឆ្នាំ១៩៩៨ និង១៥,៨% សំរាប់ឆ្នាំ២០០២ ។ ដោយសារមានការកែតំរូវបែបនេះ លក្ខខ័ណ្ឌវិនិច្ឆ័យដែលបានកំណត់នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់កាលពីខែមិថុនា ឆ្នាំ២០០២ មានការិតទាបបន្តិច ។ បើផ្អែកតាមតួលេខកែតំរូវនេះ ចំណាយថវិកាសំរាប់បណ្តាក្រសួងអាទិភាពមាន ៣,៣% នៃ ផ.ស.ស ក្នុងឆ្នាំ២០០២ ។ តាមច្បាប់ហិរញ្ញវត្ថុសំរាប់គ្រប់គ្រងថវិកាឆ្នាំ ២០០៣ ថវិកាវិភាជន៍សំរាប់ក្រសួងអាទិភាពស្មើ ៣,៦% នៃ ផ.ស.ស ។ ប៉ុន្តែ ដោយសារការប្រមូលចំណូលមានការិតទាប ព្រោះបណ្តាលមកពីកត្តាក្នុងស្រុក (បាតុកម្មហិង្សានៅភ្នំពេញកាលពីដើមឆ្នាំ២០០៣ និងភាពមិនប្រាកដប្រជានៅពេលមុន និងក្រោយបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ) និងកត្តា

ក្រៅស្រុក (ជំងឺសារសីក្នុងតំបន់ និងសង្គ្រាមនៅអ៊ីរ៉ាក់) ចំណាយថវិកាត្រូវបានកាត់បន្ថយនៅតាមផ្នែកជាច្រើន ដោយរួមទាំងក្រសួងអាទិភាពផងដែរ ។ ចំណាយថវិកាសំរាប់ក្រសួងអាទិភាពមានរហូតដល់ ៣,៣% នៃ ផ.ស.ស ក្នុងឆ្នាំ២០០៣ ។ នៅក្នុងឆ្នាំ២០០២ ចំណាយទូទាត់សំរាប់ក្រសួងអាទិភាព មានចំនួន ៥១២,១ពាន់លានរៀល បើប្រៀបធៀបនឹងឆ្នាំ២០០៣ មាន ៤២៩,៤ពាន់លានរៀល ។

៣៣- **ចំណាយថវិការបស់ក្រសួងសុខាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត មានយ៉ាងតិច ៣៥% នៃ ថវិកាក្នុងជំពូក ១១ និង ៤០% នៃថវិកាជំពូក ១៣ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ហើយចំណាយថវិការបស់ក្រសួងអប់រំ មានយ៉ាងតិច ៤០% នៃថវិកាជំពូក ១១ និង ៥០% នៃថវិកាជំពូក ១៣ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត** : ការអនុវត្តន៍លក្ខខ័ណ្ឌវិនិច្ឆ័យទាំងពីរនេះតំរូវអោយវិភាជន៍ ៧៥% នៃថវិកាជំពូក ១១ និង៩០% នៃថវិកាជំពូក១៣ អោយដល់ក្រសួងអប់រំ និង ក្រសួងសុខាភិបាល ។ ការវិភាជន៍ថវិកាបែបនេះមិនអាចធ្វើទៅកើតឡើយ ។ ប៉ុន្តែ វិភាជន៍ថវិកាជំពូក ១១ និង ១៣ អោយក្រសួងសុខាភិបាលបានកើនឡើងពី ១៥២,៤ពាន់លានរៀល សំរាប់ឆ្នាំ២០០២ ដល់ ១៦៦,៥ពាន់លានរៀល នាឆ្នាំ២០០៣ ។ ចំពោះក្រសួងអប់រំ វិភាជន៍ថវិកាត្រូវបានបង្កើនពី ១៣០,១ពាន់លានរៀលក្នុងឆ្នាំ២០០២ ដល់ ១៣៦,១ ពាន់លានរៀល ក្នុងឆ្នាំ២០០៣ ។

៣៤- **ចំណាយថវិកាសំរាប់ក្រសួងអប់រំ និងសុខាភិបាល មានប្រមាណ ១០០% នៃថវិកាជំពូក ១១ និង ១៣** : ចំណាយថវិកាសំរាប់ក្រសួងសុខាភិបាលក្នុងឆ្នាំ២០០២ មាន ៨៨,១% នៃថវិកាក្រោមជំពូក ១១ និង ៩៩,៩% សំរាប់ជំពូក ១៣ ។ សំរាប់ឆ្នាំ ២០០៣ ចំណាយថវិកាក្រោមជំពូក ១១ មាន ៨៤,៦% និង ក្រោមជំពូក ១៣ មាន ៩៣,៥% ។ រីឯចំណាយថវិកាសំរាប់ក្រសួងអប់រំក្នុងឆ្នាំ ២០០២ មាន ៨៧,១% នៃថវិកាសំរាប់ជំពូក ១១ និង ១០៧,២% សំរាប់ជំពូក ១៣ ។ ចំណែកក្នុងឆ្នាំ ២០០៣ ចំណាយថវិកាក្រោមជំពូក ១១ មាន ៩៥,១% និងក្រោមជំពូក ១៣ មាន ៨៥,១%

៣៥- **ការអនុម័តច្បាប់អេដស៍** : ច្បាប់ស្តីពីការទប់ស្កាត់ និងបង្ការការឆ្លងរាលដាលនៃជំងឺអេដស៍ ត្រូវបានអនុម័តដោយស្ថាប័ននីតិបញ្ញត្តិកាលពីខែមិថុនា ឆ្នាំ២០០២ ។ ការបង្ការជំងឺអេដស៍ ការផ្តល់សេវាថែទាំ និងព្យាបាលដល់អ្នកឆ្លងមេរោគអេដស៍ គឺជាសកម្មភាពអាទិភាពមួយរបស់រាជរដ្ឋាភិបាល ។ ច្បាប់ស្តីពីការទប់ស្កាត់ និងបង្ការការឆ្លងមេរោគអេដស៍ គឺជាក្របខ័ណ្ឌសំរាប់រាជរដ្ឋាភិបាលអនុវត្តគោលនយោបាយបង្ការព្យាបាល និងកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីការឆ្លងមេរោគនេះ ។

៣៦- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបានបង្កើតឡើងក្នុងខែមករា ឆ្នាំ១៩៩៩ មានតួនាទីសំរបសំរួលការអនុវត្តន៏វិធានការបង្ការ ព្យាបាល និងកាត់បន្ថយផលប៉ះពាល់ ដែលបណ្តាលមកពីការឆ្លងមេរោគនេះ ។ ក្នុងឆ្នាំ២០០១ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានប្រកាស «ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យ ក្នុងការទប់ទល់នឹងការឆ្លងរាលដាលជំងឺអេដស៍ ឆ្នាំ២០០១-២០០៥» ។ បន្ទាប់មក ក្រសួងសុខាភិបាល ក្រសួងការពារជាតិ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ សង្គមកិច្ច និងយុវនីតិសម្បទា

និងក្រសួងអភិវឌ្ឍន៍ជនបទ ក៏បានរៀបចំផែនការយុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីទប់ទល់នឹងបញ្ហាជំងឺអេដស៍នេះផងដែរ ។ ខេត្តបាត់ដំបង និងសៀមរាបក៏បានរៀបចំផែនការយុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីទប់ទល់នឹងការរីករាលដាលនៃជំងឺអេដស៍ផងដែរ ។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានក្រសួង ២៦ និង ២៤ខេត្ត- ក្រុងជាសមាជិក ។ គណៈកម្មការសំរបសំរួលនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបានបង្កើតឡើងកាលពីខែមិនា ឆ្នាំ២០០៣ ដោយជួបប្រជុំគ្នាជាទៀងទាត់រៀងរាល់ខែ ដើម្បីសំរបសំរួលទំនាក់ទំនងជាមួយនឹងអង្គការសហប្រជាជាតិ ដៃគូផ្តល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ។ ដើម្បីសំរួលការរៀបចំយុទ្ធនាការផ្សព្វផ្សាយសំរាប់ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ពិធីបុណ្យអុំទូក និងទិវារំលឹកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ដោយសារមេរោគអេដស៍ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក៏បានបង្កើតនូវយន្តការសំរាប់សំរបសំរួលទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលផងដែរ ។

៣៧- កិច្ចខំប្រឹងប្រែងរួមគ្នាជាមួយនឹងដៃគូអភិវឌ្ឍន៍ទាំងអស់ បានផ្តល់លទ្ធផលគួរជាទីពេញចិត្ត ។ អ្នកផ្ទុកមេរោគអេដស៍បានថយចុះពី ១៧៥.០០០នាក់ ក្នុងឆ្នាំ១៩៩៨ មកនៅត្រឹម ១៥៧.៥០០នាក់ ក្នុងឆ្នាំ២០០៣ ។ ការឆ្លងជំងឺអេដស៍ក្នុងចំណោមអ្នកមានវ័យ ១៥ ដល់ ៤៩ឆ្នាំ បានថយចុះពី ៣,៣% កាលពីឆ្នាំ១៩៩៨ មកនៅត្រឹម ២,៦% នៅឆ្នាំ២០០៣ ។ មនុស្សប្រមាណ ១០០.០០០នាក់បានមកពិនិត្យឈាម ។ សេវាពិនិត្យឈាមនិងពិគ្រោះយោបល់ត្រូវបានអនុវត្តនៅតាម ១៣ខេត្ត- ក្រុង តាមរយៈមជ្ឈមណ្ឌលផ្តល់សេវាចំនួន ៤៩ ដែលក្នុងនោះ ១៨កន្លែងបានដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាល ។ អ្នកជំងឺអេដស៍ ២.០០០នាក់បានទទួលថ្នាំប្រឆាំងនឹងវីរុស ។ ការអនុវត្តន៍កម្មវិធីប្រើប្រាស់ស្រោមអនាម័យអោយបាន ១០០% នៅទូទាំងប្រទេស បានជួយកាត់បន្ថយអត្រាឆ្លងមេរោគអេដស៍របស់ស្ត្រីរកស៊ីផ្លូវភេទ ពី ៥៤% ក្នុងឆ្នាំ១៩៩៨ មកនៅត្រឹម ៣៧% ក្នុងឆ្នាំ២០០៣ ។ កម្មវិធីមិត្តអប់រំមិត្តកំពុងត្រូវបានអនុវត្តដោយជោគជ័យ នៅក្នុងមជ្ឈដ្ឋានមន្ត្រីរាជការស៊ីវិលនិងកងកំលាំងប្រដាប់អាវុធ ។ ព្រះសង្ឃប្រមាណ ៥០.០០០អង្គ បានបញ្ចូលបញ្ហាអេដស៍ ទៅក្នុងកម្មវិធីទេសនាដល់ពុទ្ធបរិស័ទ ។ ព្រមជាមួយនេះ ការអប់រំពីជំងឺអេដស៍ក៏កំពុងត្រូវបានដំណើរការក្នុងវិស័យឯកជនផងដែរ ។

៣៨- **កម្មវិធីផ្សព្វផ្សាយពីជំងឺអេដស៍តាមវិទ្យុ និងទូរទស្សន៍** ៖ ការផ្សព្វផ្សាយពីជំងឺអេដស៍តាមកម្មវិធីវិទ្យុនិងទូរទស្សន៍ដោយមិនគិតថ្លៃ មានការជឿនលឿនគួរអោយកត់សំគាល់ ។ ស្ថានីយ៍ទូរទស្សន៍មួយចំនួនបានចែករំលែកពេលវេលាដល់ការផ្សព្វផ្សាយកម្មវិធីបង្ការជំងឺអេដស៍ ដោយមិនយកកំរៃ ។ ចំណែកឯផ្នែកឯកជនក៏បានជួយផ្សព្វផ្សាយកម្មវិធីជំងឺអេដស៍ផងដែរ ដូចជាក្រុមហ៊ុន Cambrew បានបញ្ចូលកម្មវិធីខ្លីៗពីជំងឺអេដស៍ ក្នុងកម្មវិធីខារ៉ាអូខេតាមទូរទស្សន៍ប្រចាំសប្តាហ៍របស់ខ្លួន ។ យើងក៏គួរអោយកត់សំគាល់ នូវចំនួនកើនឡើងនៃការជួយគាំទ្រពីសំណាក់ប្រទេសអ្នកផ្តល់ជំនួយ សំរាប់ការផលិតកម្មវិធីផ្សព្វផ្សាយ ដូចជាការគាំទ្ររបស់ DFID ដល់វិទ្យុ BBC ក្នុងការផលិតរឿងខ្លីតាមវិទ្យុនិងទូរទស្សន៍ ។ ចំណែកឯ UNDP UNESCO និង UNICEF ក៏បានផលិតកម្មវិធីខ្លីៗរបស់ខ្លួនផងដែរ ។ ព្រមជាមួយនេះ អ្នកផ្តល់ជំនួយក៏បានបង្កើនការគាំទ្រដល់ការផ្សព្វផ្សាយដំណឹងស្តីពីមេរោគអេដស៍តាមទូរទស្សន៍ផងដែរ ដូចជា DFID បាន និង

កំពុងឧបត្ថម្ភការផ្សព្វផ្សាយតាមទូរទស្សន៍ប៉ុស្តិ៍លេខ ៥ ។ ចំណែកឯ UNICEF ក៏បានឧបត្ថម្ភការផ្សាយតាមស្ថានីយ៍ដទៃៗទៀត ។

៣៩- **កំណែទំរង់រដ្ឋបាលស៊ីវិល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** : នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ នាខែមិថុនា ឆ្នាំ២០០២ លក្ខខ័ណ្ឌវិនិច្ឆ័យដែលពាក់ព័ន្ធនឹងផ្នែកនេះ ត្រូវបានកំណត់ដូចតទៅ ÷ ដោយផ្អែកលើការសិក្សារបស់ធនាគារពិភពលោក រាជរដ្ឋាភិបាលត្រូវរៀបចំផែនការកំណែទំរង់សំរាប់មន្ត្រីរាជការរយៈពេលមធ្យម ដើម្បីកែលំអប្រាក់បៀវត្សមន្ត្រីរាជការ ដែលអាចប្រកួតប្រជែង ជាមួយនឹងទីផ្សារពលកម្មឯកជន រួមទាំងការផ្តល់ការឧបត្ថម្ភសំរាប់សុវត្ថិភាពមន្ត្រីដែលត្រូវរំសាយ និងផ្តល់ជំរើសហិរញ្ញវត្ថុ ដែលមានសង្គតិភាពជាមួយក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។

៤០- រាជរដ្ឋាភិបាលបានអនុម័តកម្មវិធីជាតិកំណែទំរង់រដ្ឋបាល នាពាក់កណ្តាលឆ្នាំ ១៩៩៩ ។ នៅខែតុលា ឆ្នាំ២០០១ រាជរដ្ឋាភិបាលបានអនុម័តយុទ្ធសាស្រ្តស្តីពីការធ្វើសនិទានកម្មនៃមន្ត្រីរាជការ ។ ក្នុងផ្នែកមួយនៃយុទ្ធសាស្រ្តនេះ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានស្នើអំពីជំរើសនានា សំរាប់ពន្លឿនកំណែទំរង់ក្នុងការបើកប្រាក់បៀវត្ស និងក្របខ័ណ្ឌការងារ ។ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលក៏បានធ្វើការសិក្សាចំនួន ៦ ដើម្បីប្រមូលពតិមាន និងធ្វើការវិភាគ សំរាប់ជាមូលដ្ឋានក្នុងការជំរុញល្បឿនកំណែទំរង់បៀវត្ស និងក្របខ័ណ្ឌការងារ ព្រមទាំងពង្រឹងការគ្រប់គ្រងរដ្ឋបាលស៊ីវិល ។

ទី១- ការកែលំអការផ្តល់សេវាសាធារណៈ ។

ទី២- ការធ្វើលក្ខខ័ណ្ឌវិនិច្ឆ័យទីផ្សារពលកម្ម ។

ទី៣- ការពិនិត្យឡើងវិញអំពីកិច្ចប្រតិបត្តិការ ។

ទី៤- បង្កើនប្រាក់បៀវត្ស និងលាភការ ដើម្បីប្រសិទ្ធភាពការងារ ។

ទី៥- កែលំអការងារដើម្បីគាំទ្រការផ្តល់សេវាសាធារណៈ ។

ទី៦- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ។

៤១- កាលពីខែមេសា ឆ្នាំ២០០២ ធនាគារពិភពលោកបានយល់ព្រមផ្តល់ហិរញ្ញប្បទានសំរាប់ការសិក្សាចំនួន ៥ ក្នុងគំរោងសិក្សាទាំង៦ ។ លក្ខខ័ណ្ឌយោងសំរាប់ការសិក្សាទាំងនេះ ត្រូវបានអនុម័តយល់ព្រមកាលពីខែមិនា ឆ្នាំ២០០៣ ហើយទទួលហិរញ្ញប្បទាន កាលពីខែឧសភា ឆ្នាំ២០០៣ ។ ចាប់ពីពេលនោះមក ការសិក្សាស្តីអំពីការកែលំអការផ្តល់សេវាសាធារណៈ ត្រូវបានបញ្ចប់កាលពីខែកញ្ញា ឆ្នាំ២០០៣ ។ ការអង្កេតអំពីទីផ្សារពលកម្មនៃបៀវត្ស និងប្រាក់បំណាច់ ក៏ត្រូវបានបញ្ចប់កាលពីខែកញ្ញា ឆ្នាំ២០០៤ ផងដែរ ។ ដោយមានជំនួយបច្ចេកទេសពីប្រទេសប្រ៊ុយណេ ការពង្រឹងការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស កំពុងដំណើរការ ។ ដោយមានការជួយគាំទ្រពីសហភាពអឺរ៉ុប ការគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធពតិមានវិទ្យាត្រូវបានពង្រឹង សំរាប់ជាឧបករណ៍ក្នុងការត្រួតពិនិត្យបែបបទជ្រើសរើសបុគ្គលិក និងជំរុញការអភិវឌ្ឍន៍ធនធានមនុស្ស ។

៤២- ការពិនិត្យឡើងវិញនូវកិច្ចប្រតិបត្តិការ (Operations Review) នឹងចាប់ផ្តើមអនុវត្តក្នុងពេលឆាប់ៗខាងមុខ នៅក្នុងក្រសួងអាទិភាព (អប់រំ សុខាភិបាល កសិកម្ម និងយុត្តិធម៌ ) ។ ការសិក្សានេះនឹងពិនិត្យមើលពីវឌ្ឍនភាពដែលសំរេចបានកន្លងមក និងរៀបចំវិធីសាស្រ្តនិងក្របខ័ណ្ឌសំរាប់ការពិនិត្យឡើងវិញនូវកិច្ចប្រតិបត្តិការទាំងនេះ ។ ការពិនិត្យឡើងវិញនូវកិច្ចប្រតិបត្តិការនឹងអនុវត្តសាកល្បង សំដៅដាក់អោយដំណើរការនូវវិធីសាស្រ្តដែលបានរៀបចំឡើង ព្រមទាំងបណ្តុះបណ្តាលសមត្ថភាពរបស់រាជរដ្ឋាភិបាល ដើម្បីអាចអនុវត្តការពិនិត្យឡើងវិញនូវកិច្ចប្រតិបត្តិការនេះដោយខ្លួនឯង ។

៤៣- ចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាលលើប្រព័ន្ធបៀវត្សមន្ត្រីរាជការ រាជរដ្ឋាភិបាលបានកំណត់គោលការណ៍ជាមូលដ្ឋានពីរ ។ ទី១ គឺ បំរែបំរួលទាំងអស់ត្រូវគោរពគោលការណ៍សាបេក្ខភាព (Relativity) រវាងចំណាត់ថ្នាក់មន្ត្រី(មន្ត្រីនយោបាយ មន្ត្រីរាជការស៊ីវិល និងកងកំលាំងប្រដាប់អាវុធ) ។ ទី២ គឺត្រូវធានាចីរភាពក្នុងក្របខ័ណ្ឌសារពើពន្ធ ។ ក្នុងន័យនេះ ការតំលើងប្រាក់បៀវត្សត្រូវតែគិតគូរដល់ធនធាន ដែលមាន និងចំណូលថវិការបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលប្តេជ្ញានឹងតំលើងប្រាក់បៀវត្សជូនមន្ត្រីរាជការ អោយបាន ១០%-១៥% ក្នុងមួយឆ្នាំ ។ ធនធានដែលយើងមាននឹងត្រូវផ្តោតទៅលើតំរូវការជាអាទិភាព តាមរយៈឧបករណ៍ផ្សេងៗ ដូចជាកម្មវិធីកន្សោមអាទិភាព និងប្រព័ន្ធប្រាក់បំណាច់សំរាប់បង្គ្រប់បៀវត្សមូលដ្ឋាន ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានរៀបចំ និងអនុវត្តសាកល្បង ដើម្បីវាយតំលៃអំពីជំរើសដែលបានលើកឡើង ។ ការសិក្សាពីគោលនយោបាយស្តីពីលាភការនឹងរៀបចំឡើង ជាមួយការពិនិត្យកិច្ចប្រតិបត្តិការឡើងវិញ ដែលនឹងចាប់ផ្តើមនៅដើមឆ្នាំ២០០៥ ផ្អែកលើលក្ខខ័ណ្ឌយោងដែលបានកែតំរូវថ្មី ។

៤៤- ការសិក្សាពីក្របខ័ណ្ឌការងារនឹងគ្រោងដំណើរការនាដើមឆ្នាំ២០០៥ ដើម្បីផ្តល់ពត៌មានបន្ថែមអំពីតំរូវការការងារ និងសំរាប់រៀបចំយន្តការផ្លាស់ប្តូរដែលចាំបាច់ នៅក្នុងការរៀបចំក្របខ័ណ្ឌរដ្ឋបាលសាធារណៈ ។ ការសិក្សាពីការគ្រប់គ្រងមន្ត្រីរាជការ នឹងត្រូវផ្អែកតាមលទ្ធផលនៃការសិក្សាដទៃទៀតដែលបានអនុវត្តកន្លងមក ។

៤៥- នៅក្នុងដំណាក់កាលទី១ នៃការអនុវត្តន៍កម្មវិធីជាតិស្តីពីកំណែទំរង់រដ្ឋបាល រាជរដ្ឋាភិបាលបានយកចិត្តដាក់ទៅលើសកម្មភាពសំខាន់ៗចំនួន ៥ គឺ÷ ១-កត់ត្រា និងត្រួតពិនិត្យសមាសធាតុ និងការបែងចែកមន្ត្រី រាជការ ។ ២-រៀបចំឧបករណ៍សំខាន់ៗសំរាប់គ្រប់គ្រង និងលើកទឹកចិត្តមន្ត្រីរាជការ ។ ៣-វាយតំលៃតំរូវការរបស់ក្រសួង ដែលពាក់ព័ន្ធនឹងការផ្តល់សេវា ។ ៤-បញ្ចប់ការត្រៀមរៀបចំការងារ ដើម្បីអោយរដ្ឋបាលបាននៅជិតប្រជាជន ។ និង ៥-ពង្រឹងសមត្ថភាពសំរាប់រៀបចំផែនការ និងគ្រប់គ្រងកំណែទំរង់ ។ នៅក្នុងកម្មវិធីជាតិស្តីពីកំណែទំរង់រដ្ឋបាល សមិទ្ធផលដែលបានសំរេច មានដូចខាងក្រោម÷

- បានប្រមូលនិងវិភាគពត៌មានស្តីពីសមាសធាតុ និងលក្ខណៈពិសេសនៃរដ្ឋបាលស៊ីវិល ។ ជាលទ្ធផលយើងមានការយល់ដឹងយ៉ាងច្បាស់អំពីសមាសធាតុ និងលក្ខណៈពិសេសនៃរដ្ឋបាលស៊ីវិល ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ខេត្ត- ក្រុង ។
- បានរៀបចំ និងដាក់អោយអនុវត្ត នូវក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិនានា ។

- បានរៀបចំ និងដាក់អោយអនុវត្តនូវប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស រួមទាំងប្រព័ន្ធពត៌មានស្តីពីការគ្រប់គ្រងធនធានមនុស្ស សំរាប់រៀបចំផែនការ និងគ្រប់គ្រងមន្ត្រីរដ្ឋបាលស៊ីវិល ។
- បានរៀបចំ និងដាក់អោយអនុវត្តនូវរបបផ្តល់ប្រាក់បៀវត្ស និងប្រព័ន្ធការងារ សំរាប់វាយតំលៃប្រសិទ្ធភាពការងារ ។
- បានរៀបចំគោលនយោបាយថ្មីៗ សំរាប់បង្វែរធនធានហិរញ្ញវត្ថុដែលមានទៅក្នុងផ្នែកអាទិភាព ដើម្បីបង្កើនប្រសិទ្ធភាពការងាររបស់មន្ត្រីរាជការ ដូចជា កន្សោមអាទិភាព ការផ្តល់ប្រាក់ឧបត្ថម្ភដល់មន្ត្រីមួយចំនួន (Targeted Allowances) និងការិយាល័យតែមួយនៅថ្នាក់ខេត្ត- ស្រុក (One Window Office) ។

៤៦- **ការប្រមូលចំណូលនាំអោយចំណូលថវិកាកើនដល់ ១២,៧៥% នៃផ.ស.ស** : ដូចដែលបានលើកឡើងពីខាងដើម បន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់លើកទី៦ ដោយមានការជួយឧបត្ថម្ភពីមូលនិធិរូបិយវត្ថុអន្តរជាតិ វិទ្យាស្ថានជាតិស្ថិតិបានធ្វើបច្ចុប្បន្នភាពបញ្ចប់នាចុងឆ្នាំ២០០២ អំពីទិន្នន័យផ. ស. ស ដែលមានចាប់ពីឆ្នាំ១៩៩៣មក ។ ដោយសារការកែសំរួលលើការប៉ាន់ស្មានតួលេខ ផ. ស. ស បានកើនឡើង គោលដៅប្រមូលចំណូល១២,៧៥% ដែលគិតតាមតួលេខ ផ. ស. ស ចាស់ ត្រូវបានកែសំរួលអោយទាបជាងមុន ។ របាយការណ៍ស្តីពីវឌ្ឍនភាពនៅក្នុងឯកសារនេះ គឺផ្អែកលើតួលេខ ផ. ស. សដែលត្រូវបានកែសំរួលឡើងវិញ ។

៤៧- នៅក្នុងនីតិកាលទី២ រាជរដ្ឋាភិបាលបានប្រឹងប្រែងអនុវត្តប្រកបដោយវឌ្ឍនភាពល្អ ក្នុងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ដោយរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ពង្រឹងស្ថាប័នធនាគារនិងហិរញ្ញវត្ថុ និងអនុវត្តបណ្តាវិធានការកំណែទំរង់ហិរញ្ញវត្ថុ ។ ទន្ទឹមនេះ កម្ពុជាបានខិតខំបំពេញកិច្ចការជាច្រើន ក្នុងការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងសហគមន៍អន្តរជាតិ ។ ក្នុងរយៈពេល៥ឆ្នាំកន្លងមក ផ. ស. ស បានកើនឡើងជាមធ្យម ៦,៨% ក្នុងមួយឆ្នាំ ។ លើសពីនេះ ការអភិវឌ្ឍន៍ខាងរូបិយវត្ថុបានឆ្លុះបញ្ចាំងអំពីស្ថានភាពល្អប្រសើរនៃការងារ ហិរញ្ញវត្ថុ ។ ការអនុវត្តន៍គោលនយោបាយរូបិយវត្ថុ និងសារពើពន្ធដោយប្រយ័ត្នប្រយែងរបស់រាជរដ្ឋាភិបាលបាននាំមកនូវកំរិតអតិផរណាទាប និងស្ថិរភាពនៃអត្រាប្តូរប្រាក់ ។ អតិផរណាត្រូវបានរក្សាអោយនៅកំរិត មធ្យម ១,៦% ប្រចាំឆ្នាំ នៅក្នុងរយៈពេលនេះ ។ ទុនបំរុងអន្តរជាតិក៏ត្រូវបានរក្សាក្នុងកំរិតសមរម្យផងដែរ ។

៤៨- ទោះបីជារាជរដ្ឋាភិបាលបានជួបប្រទះនឹងបញ្ហាប្រឈមជាច្រើនក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ដូចជាការកែទំរង់ប្រព័ន្ធពន្ធគយ ដោយបន្ទាបអតិបរមាអត្រាពន្ធគយ ព្រមទាំងបញ្ហាប្រឈមក្នុងការត្រួតពិនិត្យការរត់ពន្ធ និងការគេចពន្ធក៏ដោយ ក៏រាជរដ្ឋាភិបាលបានជំរុញអោយមានវឌ្ឍនភាពក្នុងការបង្កើនការប្រមូលចំណូល ។ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ការអនុវត្តន៍យ៉ាងម៉ឺងម៉ាត់នូវកំណែទំរង់សារពើពន្ធ និងការអនុវត្តន៍វិធានការបង្កើនចំណូល បានស្តែងចេញជាលទ្ធផលគួរជាទីពេញចិត្ត ។ ចំណូលគិតជាភាគរយនៃការប៉ាន់ស្មានកែសំរួលនៃ ផ. ស. ស បានកើនឡើងពី ៨,១% ក្នុងឆ្នាំ១៩៩៨ ដល់ ១១,១% ក្នុងឆ្នាំ២០០២ ។ នៅក្នុង ឆ្នាំ២០០៣ ការប្រមូលចំណូលមិនត្រឹមតែជួបការលំបាកដោយសារការលេចឡើងនៃជំងឺ SARS នៅក្នុងតំបន់ បាតុកម្មហិង្សាប្រឆាំងស្ថានទូតថៃកាលពីដើមឆ្នាំ ២០០៣ សង្គ្រាមនៅអ៊ីរ៉ាក់ រួមផ្សំជាមួយនឹងការបន្ត

នៃអប្រសិទ្ធភាពក្នុងការប្រមូលពន្ធតែប៉ុណ្ណោះទេ ប៉ុន្តែក៏ជួបការលំបាកផងដែរ ដោយសារភាពមិនច្បាស់លាស់ដែលពាក់ព័ន្ធនឹងការបោះឆ្នោតនៅក្នុងឆមាសទីមួយឆ្នាំ២០០៣ និងការពន្យារពេលក្នុងការបង្កើតរាជរដ្ឋាភិបាលថ្មី បន្ទាប់ពីការបោះឆ្នោតនាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣ ។

៤៩- ស្ថានភាពមិនច្បាស់លាស់ដែលកើតមាននៅក្នុងឆ្នាំ២០០៣ បានជះឥទ្ធិពលមិនល្អដល់ការប្រមូលចំណូលពីការបង់ថ្លៃជួលទ្រព្យសម្បត្តិសាធារណៈ ការប្រមូលពន្ធជំពាក់ និងការអនុវត្តន៍អធិការកិច្ចមុនពេលផ្ទុក (Pre-Shipment Inspection Program) ។

៥០- **ការពង្រឹងសវនកម្មនិងការគ្រប់គ្រងពន្ធដារ** : អាជ្ញាធរសវនកម្មជាតិ ដែលត្រូវបានបង្កើតឡើងនាដើមឆ្នាំ២០០០ បាននិងកំពុងដំណើរការ ហើយកំពុងពង្រឹងសមត្ថភាពរបស់ខ្លួន ។ អាជ្ញាធរសវនកម្មជាតិបាន បញ្ចប់របាយការណ៍សវនកម្មសំរាប់ឆ្នាំ២០០០ ឆ្នាំ២០០១ និង២០០២ ហើយបានស្នើស្ថាប័ននីតិបញ្ញត្តិពិនិត្យ ។ មុខងារនៃសវនកម្មផ្ទៃក្នុងនៅតាមក្រសួងជំនាញនានា ក៏កំពុងត្រូវបានពង្រឹងផងដែរ ។ អាជ្ញាធរសវនកម្មជាតិកំពុងសហការជាមួយអង្គភាពសវនកម្មផ្ទៃក្នុង នៅតាមក្រសួងជំនាញនានា ដើម្បីបង្កើនតំលាភាព និងគណនេយ្យភាព ។

៥១- **ការបង្កើនតំលាភាពក្នុងកិច្ចសន្យារបស់រាជរដ្ឋាភិបាល** : ដើម្បីបង្កើនតំលាភាព និងដើម្បីកាត់បន្ថយការរំលោភច្បាប់អោយបានអប្បបរមា អនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈត្រូវបានពង្រីកវិសាលភាពនៃការអនុវត្តន៍ទៅក្រសួងទាំងអស់របស់រាជរដ្ឋាភិបាល លើកលែងតែក្រសួងព្រះបរមរាជវាំង ។

៥២- ការពង្រឹងខាងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគឺជាការងារសំខាន់ ក្នុងការពង្រឹងអភិបាលកិច្ចល្អ ។ រាជរដ្ឋាភិបាលបានរៀបចំចក្ខុវិស័យច្បាស់លាស់សំរាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Financial Management-PFM) និងបណ្តាជំហានការងារចាំបាច់នានាសំរាប់អនុវត្ត ដើម្បីឈានទៅសំរេចអោយបាននូវចក្ខុវិស័យនេះ ។ កម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានរៀបចំឡើង ដោយផ្អែកតាមគោលការណ៍អាទិភាព៤ដូចតទៅ ÷ ១) ថវិកាដែលកាន់តែមានជំនឿទុកចិត្ត ។ ២) គណនេយ្យភាពប្រកបដោយប្រសិទ្ធភាពនៃកិច្ចការហិរញ្ញវត្ថុ ។ ៣) កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលគឺជាអាទិភាព និងត្រូវបានយកចិត្តទុកដាក់ ។ ៤) អ្នកគ្រប់គ្រងនៃរាជរដ្ឋាភិបាលត្រូវមានគណនេយ្យភាពចំពោះលទ្ធផលនៃការអនុវត្តន៍កម្មវិធី ។ នៅក្នុងផ្នែកមួយនៃកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលនឹងអនុវត្តសាកល្បងនូវគំនិតផ្តួចផ្តើមមួយចំនួន ដោយផ្តោតទៅលើការប្រែប្រួលខាងរចនាសម្ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសំរាប់គាំទ្រដល់កិច្ចប្រឹងប្រែងនៃកំណែទំរង់នេះ ។ រាជរដ្ឋាភិបាលសូមស្វាគមន៍ចំពោះអភិក្រមគ្រប់គ្រងទូទាំងវិស័យ (Sector Wide Approach-SWAP) ដែលបានពិភាក្សា និងឯកភាពជាមួយដៃគូអភិវឌ្ឍន៍សំរាប់អនុវត្តកម្មវិធីកំណែទំរង់នេះ ។ កិច្ចការនេះបានផ្តល់កាលានុវត្តភាពអោយកម្ពុជាដើរតួជាដៃគូស្មើភាព ហើយជាពិសេស អាចអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដកស្រង់យុទ្ធសាស្ត្រ និងបទពិសោធន៍ល្អពីកម្មវិធី

អភិវឌ្ឍន៍ និងកិច្ចប្រឹងប្រែងកែលំអកំណែទំរង់ ដើម្បីរៀបចំឡើងវិញនូវកម្មវិធីកំណែទំរង់ខាងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយបច្ចុប្បន្នភាព និងប្រសិទ្ធភាពខ្ពស់ ។

## អាទិភាពសំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ

៥៣- ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣នៃរដ្ឋសភា គឺការកសាងសង្គមមួយ ដែលមានសាមគ្គីភាពរឹងមាំ មានប្រព័ន្ធអប់រំនិងវប្បធម៌ជឿនលឿន ដើម្បីរំដោះកម្ពុជាអោយរួចផុតពីខ្នោះឃ្នាងនៃភាពក្រីក្រ គ្មានអនក្ខរភាព និងជម្ងឺដម្កាត់ផ្សេងៗ ។ ដើម្បីសំរេចអោយបានទស្សនៈវិស័យនេះ យើងត្រូវប្រកាន់ខ្ជាប់នូវតំលៃនៃយុត្តិធម៌សង្គម សុខមាលភាព ការផ្តល់សិទ្ធិអំណាច ការរៀបចំនិងការអនុវត្តន៍គោលនយោបាយកាត់បន្ថយភាពក្រីក្រ ដោយជំរុញអោយមានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងអភិបាលកិច្ចល្អ ។

៥៤- **យុទ្ធសាស្ត្រចតុកោណ** របស់រាជរដ្ឋាភិបាលនីតិកាលទី ៣ នៃរដ្ឋសភា ត្រូវបានរៀបចំឡើង ដើម្បីធ្វើអោយបានសំរេចនូវចក្ខុវិស័យនេះ ។ ក្នុងរយៈពេលដ៏ខ្លី បន្ទាប់ពីការបង្កើតរាជរដ្ឋាភិបាលថ្មីក្នុងខែកក្កដា ឆ្នាំ២០០៤ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានធ្វើការណែនាំដល់ក្រសួងនិងស្ថាប័នរបស់រដ្ឋាភិបាលទាំងអស់ អោយរៀបចំផែនការសកម្មភាពសំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ ។ នាកិច្ចប្រជុំត្រៀមនៃកិច្ចប្រជុំពិគ្រោះយោបល់ ដែលបានប្រារព្ធឡើងកាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០២ នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្តេចនាយករដ្ឋមន្ត្រីបានអំពាវនាវដល់ដៃគូអភិវឌ្ឍន៍ទាំងឡាយ អោយធ្វើការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់អាទិភាពនានា តាមរយៈដំណើរការមួយដែលមានកិច្ចសហការគ្នា និងរៀបចំផែនការសកម្មភាពសំរាប់អនុវត្តបណ្តាគោលនយោបាយដែលបានលើកឡើងនៅក្នុងយុទ្ធសាស្ត្រចតុកោណ ។ ក្រុមការងារ បច្ចេកទេសរួមរវាងរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយទាំង១៧ មានភារកិច្ចបញ្ចប់ការងារនេះ អោយបានមុនកិច្ចប្រជុំពិគ្រោះយោបល់ ដែលបានគ្រោងនាដើមខែធ្នូ ឆ្នាំ២០០៤ ។ ដូច្នេះ អាទិភាពសំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណដែលបានកំណត់នេះ គឺជាការងារដែលកំពុងវិវត្តទៅមុខ និងដែលបានឆ្លុះបញ្ចាំងអំពីបណ្តាការងារអាទិភាពដំបូងរបស់ក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាល ។ នៅពេលដែលឯកសារនេះកំពុងត្រូវបានរៀបចំឡើង ក្រុមការងារបច្ចេកទេសចំរុះកំពុងតែពិនិត្យពីអាទិភាពទាំងនេះ ។ យើងសង្ឃឹមថាដំណើរការនេះនឹងបញ្ចប់នាដំណាច់ខែវិច្ឆិកា ឆ្នាំ ២០០៤ ដែលនៅពេលនោះ ក្រុមការងារបច្ចេកទេសចំរុះនឹងមាន ផែនការសកម្មភាពអាទិភាព និងការធានាខាងធនធាន សំរាប់អនុវត្តផែនការសកម្មភាពនេះ ។ ក្នុងន័យនេះ អាទិភាពសំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ គឺជាការងារមួយដែលកំពុងតែមានវឌ្ឍនភាពនៅឡើយ ។

៥៥- ចំពោះរាជរដ្ឋាភិបាល **អភិបាលកិច្ចល្អ** គឺជាបុរេលក្ខខ័ណ្ឌសំខាន់បំផុតមួយ ដើម្បីធានាកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាព សមធម៌ និង យុត្តិធម៌សង្គម ។ អភិបាលកិច្ចល្អតំរូវអោយមាននូវការចូលរួមយ៉ាងទូលំទូលាយ មានការលើកកំពស់ការចែករំលែកពត៌មាន មានគណនេយ្យភាព និងតំលាភាព មានលក្ខណៈស្មើភាព និងការមិនបោះបង់ចោលនូវបុគ្គលណាម្នាក់ និងការប្រតិបត្តិតាមវិធាននៃច្បាប់ ។ នៅក្នុងនីតិកាល

ទី៣នេះ ដើម្បីសំរេចគោលបំណងនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ទៅលើការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព នូវផែនការសកម្មភាពអភិបាលកិច្ចរបស់ខ្លួន ដែលគ្របដណ្តប់លើកំណែទំរង់៤យ៉ាង ដែលមានការពាក់ព័ន្ធគ្នាទៅវិញទៅមក ក្នុងនោះរួមមាន÷

ទី១- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។

ទី២- កំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

ទី៣- កំណែទំរង់រដ្ឋបាលសាធារណៈ រួមមានទាំងកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការផង ។

ទី៤- កំណែទំរង់កងកំលាំងប្រដាប់អាវុធ ពិសេសគឺកម្មវិធីកាត់បន្ថយកងទ័ព ។

៥៦- ក្នុងការ**ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ** រាជរដ្ឋាភិបាលបានប្តេជ្ញាបន្តអនុវត្តតាមអភិក្រម ដែលមានលក្ខណៈសន្តនិយម (Holistic) មានការចូលរួមអនុវត្តជាបណ្តើរៗ និងមានចីរភាព ដើម្បីលុបបំបាត់ឫសគល់នៃបញ្ហាដែលមាននាំអោយកើតអំពើពុករលួយ ។ ទោះបីយើងបានសំរេចនូវវឌ្ឍនភាពនៅក្នុងកិច្ចការមួយចំនួនក៏ដោយ ក៏កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកំពុងជួបប្រទះនូវបញ្ហាប្រឈមជាច្រើន ។ ដើម្បីប្រឆាំងនឹងអំពើពុករលួយ រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្តន៍ច្បាប់ប្រឆាំងនឹងអំពើពុករលួយអោយបានខ្លាំងក្លាបំផុត បន្ទាប់ពីច្បាប់នេះត្រូវបានស្ថាប័ននីតិបញ្ញត្តិអនុម័តរួច ហើយបង្កើតអង្គភាពអព្យាក្រឹត្យប្រឆាំងអំពើពុក រលួយ ។ រាជរដ្ឋាភិបាលនឹងជំរុញប្រសិទ្ធភាព តំលាភាព គណនេយ្យភាព នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ ពិសេសតាមរយៈការពង្រឹងសវនកម្ម និងលទ្ធកម្មសាធារណៈ ។ រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្តន៍កំណែទំរង់អភិបាលកិច្ចតាមវិស័យ និងពហុវិស័យ ក្នុងក្របខ័ណ្ឌនៃផែនការសកម្មភាពស្តីពីអភិបាលកិច្ចដែលបានរៀបចំរួចហើយ តាមរយៈការចូលរួមយ៉ាងទូលំទូលាយពីបណ្តាក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាល សង្គមស៊ីវិល និងបណ្តាដៃគូអភិវឌ្ឍន៍ ។

៥៧- រាជរដ្ឋាភិបាលគោរព និងលើកស្ទួយឯករាជ្យ និងអព្យាក្រឹតភាពនៃប្រព័ន្ធតុលាការ ដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ ក្នុងគោលដៅនេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវមានដំណើរការប្រព្រឹត្តិទៅក្នុងឯករាជ្យពិតប្រាកដ ។ រាជរដ្ឋាភិបាលខិតខំជំរុញ **កំណែទំរង់ច្បាប់ និង ប្រព័ន្ធតុលាការ** និងធានាឯករាជ្យភាពរបស់ប្រព័ន្ធតុលាការ តាមរយៈការអនុវត្តន៍ឯកសារគោលនយោបាយនិងយុទ្ធសាស្ត្រដែលក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការបានរៀបចំឡើង ។ រាជរដ្ឋាភិបាលសំរេចបាននូវលទ្ធផលគួរអោយកត់សំគាល់ក្នុងរយៈកាលកន្លងទៅ ។ យើងបានរៀបចំរួចនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពក្នុងការកែទំរង់ច្បាប់និងប្រព័ន្ធតុលាការ ។ អាទិភាពរយៈពេលខ្លី និងមធ្យម ក្នុងការអនុវត្តន៍ផែនការសកម្មភាពក៏ត្រូវបានរៀបចំ រួចដោយមានការចូលរួមយ៉ាងទូលំទូលាយពីភាគីដែលពាក់ព័ន្ធ ។ រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងមុតមាំថាក្នុងស្មារតីសហប្រតិបត្តិការរវាងក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធតុលាការ សហគមន៍អ្នកផ្តល់ជំនួយ និងភាគីពាក់ព័ន្ធទាំងអស់ យើងនឹងសំរេចបានដោយជោគជ័យក្នុងកាអនុវត្តន៍កម្មវិធីកំណែទំរង់ច្បាប់ និងប្រព័ន្ធតុលាការ ។

៥៨- កម្មវិធីជាតិស្តីពី**កំណែទំរង់រដ្ឋបាល**របស់រាជរដ្ឋាភិបាលបានគូសរំលេចពីយុទ្ធសាស្ត្រ និងគោលនយោបាយដែលត្រូវអនុវត្ត ដើម្បីកែប្រែរដ្ឋបាលសាធារណៈអោយមានប្រសិទ្ធភាព ដើម្បីអនុវត្តកម្មវិធីនយោបាយ និងរបៀបវារៈសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ។ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានរៀបចំផែនការសកម្មភាព ដោយផ្អែកលើការសិក្សាថ្មីៗកន្លងមក ដោយធ្វើការពិភាក្សាជាមួយក្រសួង និងដៃគូអភិវឌ្ឍន៍ ។ ផែនការនេះត្រូវបានលើកបង្ហាញជូនអ្នកផ្តល់ជំនួយ ក្នុងសិក្ខាសាលាជាតិនាខែសីហា ឆ្នាំ២០០៤ ។ សកម្មភាពជាក់ស្តែងដែលត្រូវអនុវត្តក្នុងក្របខ័ណ្ឌនៃកម្មវិធីជាតិស្តីពីកំណែទំរង់រដ្ឋបាល ត្រូវបានចងក្រងជាអាទិភាពចំនួន ៧ ដូចតទៅ ÷ ទី១-កែលំអការផ្តល់សេវា ។ ទី២-បង្កើនលាភការ ។ ទី៣-ការដាក់ពង្រាយមន្ត្រីរាជការឡើងវិញ ។ ទី៤-ពង្រឹងការគ្រប់គ្រង និងការត្រួតពិនិត្យធនធានមនុស្ស ។ ទី៥-អនុវត្តកម្មវិធីកន្សោមអាទិភាព ។ ទី៦-អភិវឌ្ឍសមត្ថភាពមនុស្ស និងស្ថាប័ន ។ និង ទី៧-ជំរុញប្រព័ន្ធបច្ចេកវិទ្យាពត៌មាន និងទំនាក់ទំនង ។

៥៩- នៅក្នុងរាជរដ្ឋាភិបាល យើងកំពុងស្វែងរកក៏រិតសមស្របមួយ ស្តីពីតួនាទី និងភារកិច្ចរបស់បណ្តាថ្នាក់រដ្ឋបាលក្នុងក្របខ័ណ្ឌ **វិមជ្ឈការនិងវិសហមជ្ឈការ** ។ សំរាប់រាជរដ្ឋាភិបាលកម្ពុជា បញ្ហាទាំងនេះបានចាក់ស្រេះគ្នាបន្ថែមទៀតដោយព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រថ្មីៗរបស់កម្ពុជា ។ រាជរដ្ឋាភិបាលបានកំណត់ច្បាស់ថាការអនុវត្តវិមជ្ឈការនៅថ្នាក់ឃុំ- សង្កាត់ មិនគ្រាន់តែដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែវាអាចពង្រឹង និងលើកកំពស់គុណភាពសេវាសាធារណៈ និងសំរាប់ជំរុញកិច្ចអភិវឌ្ឍន៍ដោយមានការចូលរួមនៅថ្នាក់មូលដ្ឋាន ។ ដើម្បីពង្រឹងអភិបាលកិច្ចមូលដ្ឋាន អាទិភាពចំបង គឺការកសាងសមត្ថភាពគ្រប់គ្រងនៅថ្នាក់មូលដ្ឋាន និងការផ្តល់ប្រភពធនធានហិរញ្ញវត្ថុសមស្រប ព្រមទាំងការលើកស្ទួយវប្បធម៌ចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងកិច្ចការទាំងអស់នេះ ។ ការងារអាទិភាពមួយទៀត គឺការអនុវត្តវិមជ្ឈការត្រូវអនុវត្តទន្ទឹមគ្នានឹងវិសហមជ្ឈការ និងការកសាងសមត្ថភាពថ្នាក់ខេត្ត- ក្រុង និងស្រុក- ខ័ណ្ឌ ដើម្បីធានាអោយមានភាពរលូនក្នុងការជួយទ្រទ្រង់ និងបំពេញអោយគ្នាទៅវិញទៅមកនៅថ្នាក់មូលដ្ឋាន ។

៦០- ដើម្បីជំរុញដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ ការងារជាអាទិភាពរបស់រាជរដ្ឋាភិបាលមានដូចជា ÷ ទី១- រៀបចំច្បាប់អង្គការ (Organic Law) ដើម្បីកំណត់តួនាទីរបស់រចនាសម្ព័ន្ធថ្នាក់ខេត្តនិងស្រុក ដើម្បីពន្លឿនដំណើរការនៃការធ្វើប្រតិភូកម្មអំណាចពីក្រសួងទៅអោយថ្នាក់ខេត្ត- ក្រុង ។ ទី២- រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ។ ទី៣- ធានាការផ្តល់មូលនិធិអោយបានទាន់ពេលវេលា ព្រមទាំងពិនិត្យលទ្ធភាពដើម្បីអនុញ្ញាតអោយឃុំអាចប្រមូលធនធានផ្ទាល់ ។ និងទី៤- ពង្រឹងទំនាក់ទំនង និងកិច្ចសំរបសំរួលរវាងរាជរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយ និងរវាងអ្នកផ្តល់ជំនួយទាំងអស់ ដើម្បីសំរេចនូវយុទ្ធសាស្ត្រ និងសកម្មភាពដើម្បីអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល និងដើម្បីលើកកំពស់ប្រសិទ្ធភាពជំនួយ ។

៦១- រាជរដ្ឋាភិបាលបន្តអនុវត្តគោលនយោបាយដែលបានលើកឡើងក្នុងសៀវភៅ «**ស**» របស់ **គណបក្សប្រជាជនកម្ពុជា** រួមបញ្ចូលទាំងការចែកដីសម្បទានដើម្បីគោលដៅសង្គមកិច្ចដល់យោធិនរំសាយដែលខ្វះខាតដី និងមានបំណងសុំដីសំរាប់សាងសង់លំនៅដ្ឋាន ឬ/និងធ្វើកសិកម្មជាលក្ខណៈគ្រួសារ តាមតំរូវការសមស្រប

ស្របតាមស្មារតីនៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ។ ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាលនឹងបន្តកំណែទំរង់ដើម្បីកសាង និងពង្រឹងកងកម្លាំងនគរបាលជាតិ អោយទៅជាកងកម្លាំងមានវិជ្ជាជីវៈ ជំនាញ និងមាន បច្ចេកវិទ្យាទំនើប មានស្មារតីទទួលខុសត្រូវ គោរពប្រតិបត្តិច្បាប់មុឹងម៉ាត់ គោរពសិទ្ធិមនុស្ស បំរើប្រជាជនដោយស្មោះត្រង់ មានសមត្ថភាពសំរេចបានល្អនូវភារកិច្ចគ្រប់គ្រង និងថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ការពារអាយុជីវិត និងទ្រព្យសម្បត្តិរបស់ប្រជាជន ព្រមទាំងរក្សាបាននូវភាពសុខុដុមរមនានៅក្នុងសង្គម ។

៦២- **សន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម** គឺជាលក្ខខ័ណ្ឌមិនអាចខ្វះបានសំរាប់ការពង្រឹងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ ។ រាជរដ្ឋាភិបាលនឹងបន្តការងាររបស់ខ្លួន ក្នុងគោលដៅបន្តពង្រឹងថែមទៀតនូវសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម ជូនដល់ប្រជាពលរដ្ឋ ដើម្បីឆ្លុះបញ្ចាំងពីការបោះជំហានរបស់កម្ពុជាឆ្ពោះទៅរកការអភិវឌ្ឍន៍ និងភាពកាន់តែចំរើនរុងរឿង ដោយប្តេជ្ញាដោះស្រាយអោយអស់នូវផលវិបាកនៃសង្គ្រាម របបប្រល័យពូជសាសន៍ និងជំលោះផ្ទៃក្នុង ដែលបានបំផ្លិចបំផ្លាញ និងញាំញីកម្ពុជា ក្នុងរយៈពេលជិតបីទសវត្សរ៍កន្លងទៅនេះ ។ ក្នុងន័យនេះ សុខសន្តិភាព ស្ថិរភាពនយោបាយ និង សណ្តាប់ធ្នាប់សង្គម គឺជាមូលដ្ឋានគ្រឹះនៃការងារកសាង និងកំណែទំរង់រដ្ឋ ។ ភារកិច្ចចំបងរបស់រាជរដ្ឋាភិបាល គឺត្រូវពង្រឹងកោសិកាសន្តិភាពអោយផ្សារភ្ជាប់គ្នាល្អដោយប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ ។ ការពង្រឹងសុខសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គមនឹងបង្កើតនូវ«រូបភាពជាក់ស្តែង» មួយរបស់កម្ពុជា ក្នុងការបង្កើនជំនឿទុកចិត្តពីសំណាក់វិនិយោគិន និងអ្នកទេសចរណ៍ ក៏ដូចជាក្នុងការបង្កលក្ខណៈអោយប្រជាពលរដ្ឋអាចរស់នៅប្រកបរបរអាជីវកម្មតាមធម្មតា និងចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចយ៉ាងសកម្មតាមសមត្ថភាពរៀងៗខ្លួន ។

៦៣- ការប្រកាន់ខ្ជាប់នូវវិន័យនៅក្នុង **ការគ្រប់គ្រងថវិកា**មានសារៈសំខាន់ខ្លាំងណាស់ សំរាប់ការបង្កើតឡើងនូវបរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានលក្ខណៈអនុគ្រោះចំពោះការខិតខំកសាងមូលដ្ឋានគ្រឹះ ដ៏រឹងប៉ឹង និងមាំមួននៃសេដ្ឋកិច្ចជាតិ ដើម្បីធានាកំណើនមួយប្រកបទៅដោយចីរភាព និងមានសមធម៌ ។ អាទិភាពរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នៃរដ្ឋសភា មានដូចជា ÷ ទី១- ពង្រឹងការប្រមូលចំណូលពន្ធ និងមិនមែនពន្ធ រួមទាំងអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវច្បាប់ពន្ធដារ និងច្បាប់ដទៃទៀត ដូចជាច្បាប់វិនិយោគជាដើម ។ ទី២- កាត់បន្ថយអំពើពុករលួយ និងការគេចវេះពន្ធ ។ ទី៣- បន្តប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវការមិនអនុញ្ញាតអោយមាន «វប្បធម៌រួចពន្ធនិងលើកលែងពន្ធ» នៅក្នុងប្រទេសកម្ពុជា ។ ទី៤- ពង្រីកមូលដ្ឋានយកពន្ធ ។ ទី៥- ពង្រឹងរដ្ឋបាលគយ និងពន្ធដារ ។ ទី៦- ពង្រឹងគ្រប់គ្រងអោយបានម៉ត់ចត់បំផុតនូវទ្រព្យសម្បត្តិរបស់រដ្ឋគ្រប់ប្រភេទ ។ ទី៧- កែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេសធ្វើវិចារណកម្មចំណាយសាធារណៈដោយផ្អែកលើគោលការណ៍ "តំលាភាព គណនេយ្យភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច" ។ ទី៨- កែលំអប្រព័ន្ធសវនកម្ម និងលទ្ធកម្មសាធារណៈ ដោយផ្តល់អាទិភាពទៅលើចំណាយសាធារណៈសំរាប់កិច្ចអភិវឌ្ឍន៍ និងការវិនិយោគសាធារណៈ ពិសេសលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ។

៦៤- ដើម្បីអនុវត្តបណ្តាអាទិភាពខាងលើ ក្នុងនាមជាប្រមុខនៃរាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នៃរដ្ឋសភា សម្តេច នាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានដាក់ចេញនូវវិន័យដប់យ៉ាងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលគ្រប់សមាជិកសមាជិកានៃរាជរដ្ឋាភិបាល មានកាតព្វកិច្ចត្រូវគោរពយ៉ាងខ្ជាប់ខ្ជួន និងដោយម៉ឺងម៉ាត់ បំផុត និងគ្រប់ពេលវេលា គឺ ÷ ទី១-ត្រូវបន្តប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវការមិនអនុញ្ញាតឱ្យមាន «វប្បធម៌រួចពន្ធ និងលើកលែងពន្ធ» នៅក្នុងប្រទេសកម្ពុជា ។ ទី២- ត្រូវខិតខំប្រមូលចំណូលគ្រប់ប្រភេទអោយបានគ្រប់តាមផែនការ ឬលើសផែនការ ។ ទី៣-ត្រូវបង់ចំណូលទាំងអស់ចូលរតនាគារជាតិភ្លាមៗអោយបានទាន់ពេល និងហាមដាច់ខាតនូវការរក្សាទុកចំណូលសំរាប់ចំណាយនៅក្រៅក្របខ័ណ្ឌថវិកាជាតិ ទោះជាតាមរយៈយន្តការចំណូលព្រម- ចំណាយព្រមក្តី ឬតាមរយៈការខ្ចីក្រុមហ៊ុនប្រើមុន ហើយចាំកាត់ចំណូលសងតាមក្រោយក្តី ។ ទី៤-ត្រូវក្លាហាន និងដាច់ខាតក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើរត់គេចពន្ធគ្រប់ប្រភេទ និងក្នុងការតឹងទារបំណុលពីអ្នកដែលជំពាក់បំណុលរដ្ឋ ពិសេសពីអ្នកជំពាក់បំណុលពន្ធ ។ ទី៥-ត្រូវតម្រង់ចំណាយអោយចំទិសដៅអាទិភាពនៃការអភិវឌ្ឍន៍ ហើយម៉ឺងម៉ាត់ក្នុងការត្បិតត្បៀតចំណាយដែលមិនចាំបាច់ ឬមិនទាន់ ចាំបាច់ និងត្រូវសន្សំសំចៃក្នុងការចាយវាយ ហើយត្រូវលើកកំពស់ស្មារតីប្រឆាំងនឹងភាពខ្ជះខ្ជាយ ។ ទី៦-ត្រូវ ពង្រឹង និងអនុវត្តអោយបានខ្ជាប់ខ្ជួននូវបទបញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។ ទី៧-ត្រូវពង្រឹងសវនកម្មក្នុងការគ្រប់គ្រងថវិកា (ទាំងចំណូល- ទាំងចំណាយ) ទាំងអធិការកិច្ចហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទាំងសវនកម្មផ្ទៃក្នុងក្រសួង- ស្ថាប័ននីមួយៗ ទាំងសវនកម្មឯករាជ្យផ្ទៃក្រៅ ។ ទី៨-ហាមដាច់ខាតនូវការចុះកិច្ចសន្យានានាជាមួយក្រុមហ៊ុនឯកជន ដែលមានកាតព្វកិច្ចពន្ធដារ និងកិច្ចសន្យាណាដែលជះឥទ្ធិពលដល់ចំណូល- ចំណាយរបស់រដ្ឋ ដោយគ្មានការចូលរួម និងការឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ទី៩-ហាមដាច់ខាតនូវការ ខ្ចីឥណទានដែលមានលក្ខណៈពាណិជ្ជកម្ម ។ និងទី១០-ត្រូវពង្រឹងគ្រប់គ្រងអោយបានម៉ត់ចត់បំផុតនូវទ្រព្យសម្បត្តិរដ្ឋគ្រប់ប្រភេទ ដោយគោរពយ៉ាងម៉ឺងម៉ាត់តាមច្បាប់ និងបទបញ្ញត្តិទាំងឡាយស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

៦៥- រាជរដ្ឋាភិបាលនឹងបន្តជំរុញការធ្វើសមាហរណកម្មប្រទេសកម្ពុជាទៅក្នុងសហគមន៍តំបន់ និងពិភពលោក ដោយផ្តោតអាទិភាពជាពិសេស ទៅលើការខិតខំដើម្បីកាត់បន្ថយគំលាតនៃការអភិវឌ្ឍន៍នៅក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ។ ដើម្បីកម្ពុជាអាចទាញយកផលចំណេញពីសមាហរណកម្មអន្តរជាតិ យើងត្រូវពង្រឹងសមត្ថភាពស្ថាប័ន និងដាក់អោយអនុវត្តយុទ្ធសាស្ត្រសហប្រតិបត្តិការ ជាមួយប្រទេសជិតខាង ដូចជាការអនុវត្តន៍ទស្សនាទាន*«ប្រទេសបួន- សេដ្ឋកិច្ចមួយ»* ការបង្កើតនូវតំបន់ត្រីកោណនៃកំណើនសេដ្ឋកិច្ច និងការបង្កើតនូវតំបន់សេរីសំរាប់ដំណើរការនាំចេញ (EPZs) ។ រាជរដ្ឋាភិបាលនឹងបន្តដំណើរទៅមុខយ៉ាងស្វាហាប់ នៅលើមាគ៌ានៃការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម សំដៅធានាអោយទំនិញ និងសេវាគ្រប់ប្រភេទ អាចចរាចរបានដោយសេរីនៅក្នុងទូទាំងប្រទេស និងរវាងប្រទេសកម្ពុជា និងប្រទេសជាដៃគូសំខាន់ៗ នៅក្នុង តំបន់ និងលើសកលលោក ។ រាជរដ្ឋាភិបាលនឹងប្រឹងប្រែងអនុវត្តយ៉ាងម៉ត់ចត់នូវកាតព្វកិច្ចរបស់កម្ពុជា ជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ដោយទទួលស្គាល់ថាសមាជិកភាពនៅក្នុង WTO តំរូវអោយ មានការងារជាច្រើន ដូចជាការអនុម័ត និងការអនុវត្តន៍ច្បាប់ និងបទដ្ឋានពាក់ព័ន្ធនានា ។

៦៦- ការអភិវឌ្ឍន៍វិស័យកសិកម្ម ដែលអាចទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជាងបីភាគបួន គឺជាអាទិភាពខ្ពស់បំផុតមួយរបស់រាជរដ្ឋាភិបាល ។ ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាព ការកាត់បន្ថយភាពក្រីក្រ និងសំរេចអោយបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា នឹងមិនធ្វើទៅបានឡើយ ប្រសិនបើគ្មានការរីកលូតលាស់របស់វិស័យកសិកម្ម ។ ដើម្បីធ្វើទំនើបកម្មវិស័យកសិកម្ម រាជរដ្ឋាភិបាលនឹងចាត់វិធានការដូចតទៅ ÷ **ទីមួយ** បង្កើនវិនិយោគសាធារណៈសំរាប់វិស័យកសិកម្ម និងការអភិវឌ្ឍន៍ជនបទ ជាពិសេសនៅតាមបណ្តាខេត្ត ស្រុក និងឃុំ ដោយសាងសង់ប្រព័ន្ធប្រឡាយ ផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធជនបទផ្សេងៗទៀត ដោយមានក្រុមប្រឹក្សាឃុំជាអ្នកចុះកិច្ចសន្យាស្ថាបនា និងទទួលខុសត្រូវដោយផ្ទាល់ ។ **ទីពីរ** ជំរុញវិនិយោគឯកជនតាមអនុវិស័យសំខាន់ៗនៅថ្នាក់មូលដ្ឋាន ដូចជា វារីវប្បកម្ម ទីផ្សារខ្នាតតូច ផលិតកម្មកសិផល និងសត្វពាហនៈ កសិសហគ្រាស ដូចជាការកែច្នៃផលិតផល ការប្រមូលផលនិងយន្តូបនីយកម្ម ។ **ទីបី** ពន្លឿន និងរក្សាស្ថិរភាពកំណើនវិស័យកសិកម្ម ដោយឈរលើមូលដ្ឋានទូលំទូលាយ តាមរយៈការអភិវឌ្ឍន៍ប្រកបដោយចីរភាពនូវផលិតផលដែលមានតំលៃខ្ពស់ ។ និង **ទីបួន** បង្កើនចំណាយ និងវិនិយោគនៅថ្នាក់មូលដ្ឋានលើផ្នែក ÷ ១-សេវាផ្សព្វផ្សាយសំដៅបង្កើនផលិតភាពកសិកម្ម ។ ២-ធារាសាស្ត្រដែលគ្រប់គ្រង និងដំណើរការដោយកសិករ ។ ៣- សហគ្រាសជនបទ ។ ៤-ជំនាញនិងសមត្ថភាពផ្នែកឥណទានដល់សហគ្រាសដែលវិនិយោគផ្នែកកសិកម្ម ។ ៥-វិនិយោគសាធារណៈបែបរិមជ្ឈការ ជាមួយនឹងការផ្តល់ហិរញ្ញប្បទាន និងសេវាតាមបែបវិសហមជ្ឈការ ក្នុងវិស័យកសិកម្ម ។ និង ៦-ផ្តល់មូលនិធិសំរាប់ក្រុមកសិករដោយផ្អែកតាម គោលការណ៍នៃការផ្តល់ហិរញ្ញប្បទានទ្រង់ទ្រាយតូច ។

៦៧- ក្នុងការគាំទ្រ**កិច្ចអភិវឌ្ឍន៍ជនបទ** ក្រសួងអភិវឌ្ឍន៍ជនបទនឹងបន្តតួនាទីជាអ្នកសំរបសំរួលការងារ ជាមួយបណ្តាក្រសួង អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងជាមួយផ្នែកឯកជន តាមរយៈការសំរបសំរួលការអនុវត្តន៍គំរោងនៅតាមតំបន់ជនបទ ព្រមទាំងផ្តល់ការគាំទ្រដល់បណ្តាកម្មវិធីនានា ដែលជាជំនួយឧបត្ថម្ភរបស់សហគមន៍អន្តរជាតិ និងអនុវត្តដោយផ្ទាល់ នូវបណ្តាគំរោង និងកម្មវិធីនានា ដើម្បីបង្កើតសេដ្ឋកិច្ចទីផ្សារនៅសហគមន៍ជនបទ ។ ក្រសួងនឹងបន្តជំរុញការអភិវឌ្ឍន៍ធនធានមនុស្ស ការបង្កើតរចនាសម្ព័ន្ធជនបទ ពិសេសការបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ឃុំ និងការគ្រប់គ្រងពត៌មាន និងទំនាក់ទំនង ។ ក្រសួងក៏បន្តអនុវត្តកម្មវិធីនានា ដូចជាគំរោងស្ពារ និងកសាងផ្លូវ ការផ្គត់ផ្គង់ទឹកស្អាត ការជំរុញវិស័យសុខាភិបាល ការពង្រីកធារាសាស្ត្រខ្នាតតូច ការជំរុញសន្តិសុខស្បៀងនៅតាមគ្រួសារ ការជំរុញឥណទានជនបទ និងការអភិវឌ្ឍន៍ឃុំ ។

៦៨- **ដីនិងទឹក** គឺជាធនធានធម្មជាតិជាមូលដ្ឋានដ៏សំខាន់ ២យ៉ាង សំរាប់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច- សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រ ពិសេសតំបន់ជនបទ ។ ពង្រឹងសិទ្ធិកាន់កាប់ដីធ្លីជូនប្រជាពលរដ្ឋ ដែលត្រូវការដីសំរាប់សង់លំនៅដ្ឋាន និងធ្វើអាជីវកម្មកសិកម្មជាលក្ខណៈគ្រួសារក្នុងក្របខ័ណ្ឌដីសម្បទានសង្គមកិច្ច ដោយឈរលើគោលការណ៍ជួយគ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះ ។ ដើម្បីបង្កើនសមត្ថភាពរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងការបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ក្រសួងនឹង

រៀបចំរចនាសម្ព័ន្ធក្រសួងឡើងវិញ ប្រសិនបើចាំបាច់ ហើយព្រមជាមួយគ្នានេះ ក្រសួងនឹងបណ្តុះបណ្តាលធនធានមនុស្សបន្ថែមទៀតផង ។ ក្រសួងនឹងរៀបចំយុទ្ធសាស្ត្រស្តីពីតំលាភាព និងគណនេយ្យភាពចំពោះគ្រប់មុខងារទាំងអស់ដែលក្រសួងទទួលខុសត្រូវ ។ ក្រសួងនឹងពន្លឿនដំណើរការចុះបញ្ជីដីធ្លី ដើម្បីកាត់បន្ថយជំលោះដីធ្លី និងបង្កលទ្ធភាពដល់អ្នកចុះបញ្ជីដីធ្លីក្នុងការស្វែងរកឥណទាន ព្រមជាមួយនេះ ក្រសួងនឹងបង្កើនការប្រមូលចំណូលដែលបានមកពីពន្ធដី ពន្ធលើដីដែលមិនប្រើប្រាស់ ថ្លៃចុះបញ្ជីសុរិយោដី និងកំរៃផ្សេងៗទៀតដែលបានមកពីដីធ្លី ។

៦៩- កម្ពុជានៅតែជាប្រទេសមួយដែលនៅមានមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (UXO) ច្រើនជាងគេនៅលើពិភពលោក ។ **គ្រាប់មីននិងសារធាតុ** UXO ទាំងនេះ ត្រូវបានបន្សល់ទុកតាំងពីសង្គ្រាមវៀតណាម និងជំលោះផ្ទៃក្នុងក្នុងរយៈកាលក្រោយៗមកទៀត ហើយបានបន្តសម្លាប់ជីវិតជនស្លូតត្រង់ រាប់រយនាក់ក្នុងមួយឆ្នាំៗ ។ គោលដៅរបស់រាជរដ្ឋាភិបាលគឺបោសសំអាតគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ នៅតាមតំបន់មានគ្រោះថ្នាក់កំរិតខ្ពស់ អោយបានអស់ ត្រឹមឆ្នាំ២០១២ និងរំដោះមីននៅទូទាំងប្រទេសអោយអស់នៅត្រឹមឆ្នាំ ២០២០ ។

៧០- **នេសាទនិងជលផល** មានសារៈសំខាន់ជាអាយុជីវិតដល់ប្រជាជនកម្ពុជារាប់លាននាក់ ដោយផ្តល់ជាស្បៀងអាហារ ជាចំណូល និងការរស់នៅ ។ អាទិភាពរបស់រាជរដ្ឋាភិបាលសំរាប់វិស័យនេះរួមមាន ÷ ទី១- បង្កើតសហគមន៍អភិវឌ្ឍន៍វិស័យជលផល ដោយប្រគល់សិទ្ធិអំណាចទៅអោយសហគមន៍ជនបទដើម្បីអោយប្រជាកសិករអាចចូលរួមបានយ៉ាងសកម្មក្នុងការរៀបចំផែនការ និងទទួលខុសត្រូវគ្រប់គ្រងដោយខ្លួនឯង ។ ទី២- បង្វែរឡូតិ៍នេសាទចប់កិច្ចសន្យាមួយចំនួនទុកជាកន្លែងអភិរក្សពូជត្រី សំរាប់បង្កើនផលស្តុកធម្មជាតិផង និងរក្សាពូជត្រី ដែលស្ទើរផុតពូជអោយសំបូរឡើងវិញផង ។ ទី៣- ជំរុញបង្កើនទំហំដែននេសាទសំរាប់ជូនប្រជាពលរដ្ឋប្រើប្រាស់ និងជំរុញការអភិវឌ្ឍន៍ផ្នែកវារីវប្បកម្ម ដើម្បីឆ្លើយតបទៅនឹងតំរូវការសាច់ត្រីកើនឡើងផង ព្រមទាំងបន្ថយសម្ពាធលើធនធានជលផលធម្មជាតិផងដែរ ។

៧១- គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនៅក្នុង **វិស័យព្រៃឈើ** គឺការធានាអោយមានការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ដោយផ្អែកលើសសរទ្រូងជាយុទ្ធសាស្ត្របីសំខាន់ គឺ ÷ ទី១- គោលនយោបាយគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ដោយមានការត្រួតពិនិត្យអាជីវកម្មព្រៃឈើយ៉ាងម៉ឺងម៉ាត់ និងសមស្របតាមនិយាមនៃការគ្រប់គ្រងព្រៃឈើជាអន្តរជាតិ ដែលតំរូវអោយមានទំហំព្រៃឈើបំរុងទុកគ្រប់គ្រាន់ សំរាប់ទប់ទល់ការប្រើប្រាស់របស់ប្រជាពលរដ្ឋ ការពារភាពរាំងស្ងួត និងទឹកជំនន់ ព្រមទាំងព្រៃលិចទឹកសំរាប់ទុកជាជម្រកមច្ឆាជាតិ ។ ទី២- ប្រព័ន្ធការពារធនធានធម្មជាតិ ដើម្បីធ្វើការអភិរក្សជីវសាស្ត្រចំរុះ និងប្រភេទដែលកម្រ ។ ទី៣- ការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍សហគមន៍ព្រៃឈើមួយដែលរឹងមាំ មានតំលាភាព និងមានការគ្រប់គ្រងដោយប្រជាពលរដ្ឋដោយផ្ទាល់នៅក្នុងតំបន់នោះ ។ ដើម្បីសំរេចបានការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយចីរភាព អាទិភាពរបស់រាជរដ្ឋាភិបាលគឺ÷ទី១- ពង្រឹងការគ្រប់គ្រងនិងអភិរក្សធនធានព្រៃឈើ ។ ទី២- បង្កើនការចូលរួមរបសវិស័យជំរុញព្រៃឈើនៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ។ ទី៣- បង្កើនការ

ចូលរួមរបស់វិស័យជំរុញព្រៃឈើនៅក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ ។ និង ទី៤- ពង្រឹងសមត្ថភាព និងអភិបាលកិច្ចល្អក្នុងវិស័យព្រៃឈើ ។

៧២ **ការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធ**ដែលជាបុរេលក្ខខ័ណ្ឌសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ នៅតែជាបញ្ហាអាទិភាពដ៏ខ្ពស់បំផុតរបស់រាជរដ្ឋាភិបាល ។ បណ្តាញគមនាគមន៍គឺជាសរសៃឈាមសំរាប់តភ្ជាប់គ្រប់ច្រកល្ហកនៃព្រះរាជាណាចក្រកម្ពុជា អោយក្លាយទៅជាសរីរាង្គកាយសេដ្ឋកិច្ចមួយ ។ ប្រព័ន្ធដឹកជញ្ជូនគឺជាឧបករណ៍សំរាប់អភិវឌ្ឍទីផ្សារក្នុងស្រុក ព្រមទាំងធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជា ទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក ។ អាទិភាពចំបងរបស់រាជរដ្ឋាភិបាលគឺបន្តស្តារ និងកសាងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនគ្រប់ប្រភេទ រួមមានថ្នល់ ស្ពាន ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងអាកាសយានដ្ឋាន សំរាប់តភ្ជាប់តំបន់នានាជាមួយគ្នានៅទូទាំងប្រទេស និងសំរាប់តភ្ជាប់ជាមួយបណ្តាប្រទេសជិតខាង និងជាមួយពិភពលោក ។ បញ្ហាប្រឈមជាចំបងក្នុងការស្តារឡើងវិញនូវបណ្តាញផ្លូវគមនាគមន៍គឺ ទន្លេមួយចំនួនមិនត្រឹមតែហូរកាត់តំបន់ជនបទប៉ុណ្ណោះទេ តែវាហូរកាត់ផ្លូវជាតិសំខាន់ៗទៀតផង ។ លើសពីនេះស្ពានមួយចំនួនធំមានលទ្ធភាពទ្រទំងន់បានត្រឹមតែ២០តោនប៉ុណ្ណោះ ហើយទទួលរងការបាក់ស្រុតជាញឹកញាប់ ។ ដូចនេះ រាជរដ្ឋាភិបាលនីតិកាលទី ៣ បានផ្តល់អាទិភាពចំបងដល់ការថែទាំជាប្រចាំនូវបណ្តាញផ្លូវទាំងនេះ ។ នៅក្នុងនីតិកាលទី៣នេះ រាជរដ្ឋាភិបាលបានគ្រោងស្តារ និងជួសជុលឡើងវិញផ្លូវជាតិសំខាន់ៗប្រវែងជាង ២.០០០គម និងផ្លូវខេត្ត ប្រមាណ១.០០០ គម ។

៧៣- អាទិភាពសំរាប់ **កំពង់ផែនិងការដឹកជញ្ជូនតាមផ្លូវទឹក** រួមមាន ÷ ការស្តារឡើងវិញនូវម៉ាស៊ីនបូមដីដើម្បីបូមដីបាតទន្លេ ដែលជាផ្លូវទឹកសំខាន់ៗអោយជាប់ជាប្រចាំ ការលើកកំពស់គុណភាពកំពង់ផែភ្នំពេញក៏ដូចជាការកែលំអកំពង់ផែតូចៗតាមដងទន្លេ និងបឹង ព្រមជាមួយនឹងការជួសជុលកំពង់ចំឡង ដែលមានស្រាប់ ។ រាជរដ្ឋាភិបាលជំរុញអោយមានការចូលរួមពីផ្នែកឯកជន ក្នុងការគ្រប់គ្រងនិងការថែទាំកំពង់ផែអន្តរជាតិភ្នំពេញ ក្រុងព្រះសីហនុ និងកោះកុង ហើយដែលអាចជួយខេត្ត បង្កើតយន្តការស្វ័យហិរញ្ញប្បទានដើម្បីថែទាំ និងអភិវឌ្ឍកំពង់ផែនៅក្នុងខេត្តរបស់ខ្លួនដោយខ្លួនឯង ។ **បណ្តាញផ្លូវដែក** ជាផ្នែកមួយយ៉ាងសំខាន់ក្នុងប្រព័ន្ធដឹកជញ្ជូន ។ នាពេលបច្ចុប្បន្ននេះ បណ្តាញផ្លូវដែកទទួលរងការខូចខាតយ៉ាងខ្លាំង និងក៏មិនទាន់ត្រូវបានប្រើប្រាស់អោយអស់លទ្ធភាពនៅឡើយដែរ ។ អាទិភាពជាចំបងរបស់រាជរដ្ឋាភិបាល គឺស្តារឡើងវិញនូវបណ្តាញផ្លូវដែកដែលបាត់បង់ប្រមាណ ៤៨ គម តភ្ជាប់កម្ពុជាទៅកាន់តំបន់ព្រំដែនកម្ពុជា- ថៃ ។ បណ្តាញផ្លូវដែកភាគខាងត្បូងប្រទេស ដែលតភ្ជាប់ពីភ្នំពេញទៅកំពង់ផែក្រុងព្រះសីហនុ ក៏ត្រូវស្តារឡើងវិញផងដែរ ដើម្បីកាត់បន្ថយតំលៃប្រតិបត្តិការ និងដើម្បីបង្កើនលទ្ធភាពប្រកួតប្រជែងជាមួយនឹងការដឹកជញ្ជូនតាមផ្លូវគោក ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងពិនិត្យផងដែរ អំពីលទ្ធភាពស្តារឡើងវិញ នូវបណ្តាញផ្លូវដែកភាគខាងជើងប្រទេស ។

៧៤ ការផ្តល់សេវាក្នុងក្របខ័ណ្ឌ**អាកាសចរណ៍ស៊ីវិល** គឺជាបុរេលក្ខខ័ណ្ឌនៃការអភិវឌ្ឍន៍វិស័យទេសចរណ៍ ដែលអាចជះឥទ្ធិពលជាដុំកំភួនដល់ការរីកចំរើននៃសេដ្ឋកិច្ចជាតិ ។ ព្រលានយន្តហោះអន្តរជាតិភ្នំពេញ (ពោធិ

ចិនតុង) នឹងបន្តកែលំអទៀតតាមកិច្ចព្រមព្រៀង BOT។ រាជរដ្ឋាភិបាលនឹងបន្តកែលំអព្រលានយន្តហោះអន្តរជាតិក្រុងព្រះសីហនុ និងខេត្តសៀមរាប អោយបានស្របនឹងស្តង់ដារអន្តរជាតិ ដើម្បីបំពេញតំរូវការនៃការកើនឡើងនៃទេសចរណ៍ ដែលធ្វើដំណើរទៅកាន់តំបន់ទាំងនោះ ព្រមទាំងអាកាសយានដ្ឋានក្នុងស្រុកមួយចំនួននៅភាគខាងជើងប្រទេស ដូចជាព្រលានយន្តហោះនៅខេត្តស្ទឹងត្រែង ខេត្តរតនៈគីរី និងខេត្តមណ្ឌលគីរីជាដើម ។ ដើម្បីឆ្លើយតបនឹងស្តង់ដារអន្តរជាតិស្តីពីសុវត្ថិភាព យើងត្រូវការបន្ទាន់នូវប្រព័ន្ធគ្រប់គ្រងចរាចរណ៍តាមផ្លូវអាកាស (ATM) និងប្រព័ន្ធទំនាក់ទំនងតាមផ្លូវអាកាស (Communication-Navigation-Surveillance) ។

៧៥- គោលនយោបាយជាតិស្តីពី **ធនធានទឹក** គឺជាផ្នែកមួយនៃកម្មវិធីទូលំទូលាយរបស់រាជរដ្ឋាភិបាល ក្នុងការការពារ គ្រប់គ្រង និងធានាការប្រើប្រាស់ទឹកសាប ទឹកប្រៃ និងធនធានសមុទ្រប្រកបដោយចីរភាព ព្រមទាំងអភិរក្សជីវសាស្ត្រចំរុះ ។ នៅក្នុងនីតិកាលទី៣ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តការងារអាទិភាពដូចតទៅ ÷ ទី១- អភិវឌ្ឍ និងពង្រីកប្រព័ន្ធស្រោចស្រពផ្ទៃដី ។ ទី២- គ្រប់គ្រងធនធានទឹក ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការបង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ។ ទី៣- បន្តបង្កើត និងពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ទឹករបស់សហគមន៍អ្នកប្រើប្រាស់ទឹក ។ និងទី៤- កាត់បន្ថយភាពងាយរងគ្រោះពីគ្រោះធម្មជាតិ និងការពឹងផ្អែកទាំងស្រុងលើលក្ខខ័ណ្ឌធម្មជាតិ ។

៧៦- ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍន៍**វិស័យថាមពល** គឺធានាការផលិត និងការផ្គត់ផ្គង់ថាមពលអគ្គិសនី ដែលអាចឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងក្នុងតំលៃថោកសមរម្យ នឹងតំរូវការនៃការប្រើប្រាស់ដែលចេះតែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃរបស់ប្រជាពលរដ្ឋ ។ ការអភិវឌ្ឍន៍វិស័យ នេះទាមទារនូវថវិកាមូលធនយ៉ាងច្រើន ព្រមជាមួយនឹងការពង្រឹងសមត្ថភាពខាងស្ថាប័នទទួលខុសត្រូវនៅថ្នាក់ជាតិក្នុងការរៀបចំគំរោង ក្នុងកិច្ចប្រតិបត្តិការ និងក្នុងការថែទាំប្រព័ន្ធចែកចាយថាមពលទាំងនេះ ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលផ្តល់អាទិភាពខ្ពស់ ទៅលើការចូលរួមរបស់ផ្នែកឯកជននៅក្នុងផ្នែកផលិត និងនៅក្នុងប្រព័ន្ធចែកចាយថាមពលអគ្គិសនី ។ ដោយសារមូលធនរបស់រដ្ឋនៅមានកំរិតនៅឡើយ ក្នុងការអនុវត្តន៍អោយបានសំរេចនូវទស្សនៈវិស័យនេះ រាជរដ្ឋាភិបាលបានកំណត់នូវយុទ្ធសាស្ត្ររយៈពេលខ្លី និងមធ្យមរបស់ខ្លួនដូចតទៅ ÷ ទី១- បន្តស្តារ និងសាងសង់បន្ថែមរោងចក្រផលិតថាមពលអគ្គិសនី ផ្អែកលើធនធានដែលមានស្រាប់ ។ ទី២- បន្តជាវថាមពលអគ្គិសនីពីប្រទេសជិតខាង តាមរយៈការចុះកិច្ចព្រមព្រៀងទ្វេភាគី ។ ទី៣- បន្តពង្រីកប្រព័ន្ធចែកចាយថាមពលអគ្គិសនីឱ្យដល់បណ្តាតំបន់ឆ្ងាយៗ តាមរយៈការសាងសង់រោងចក្រអគ្គិសនីបន្ថែម និងការជាវថាមពលពីប្រទេសជិតខាង ។

៧៧- ចក្ខុវិស័យជាយុទ្ធសាស្ត្ររយៈពេលវែងរបស់រាជរដ្ឋាភិបាល គឺអភិវឌ្ឍ**ប្រព័ន្ធប្រៃសណីយ៍ និងទូរគមនាគមន៍** ដែលមានគុណភាពខ្ពស់ ថ្លៃថោកសមរម្យ ស្របតាមស្តង់ដារអន្តរជាតិ និងមានសេវាកម្មទំនើបគ្របដណ្តប់ទូទាំងប្រទេស ។ ការសំរេចអោយបាននូវចក្ខុវិស័យនេះទាមទារអោយមានការវិនិយោគនៅលើបណ្តាញហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ សំរាប់បំរើអោយផ្នែកបច្ចេកវិទ្យាពត៌មាន និងទូរគមនាគមន៍ ពិសេសបណ្តាញ

ខ្សែកាបអុបទិចដែលមានសមត្ថភាពខ្ពស់ ដែលអាចចូលរួមអភិវឌ្ឍន៍បណ្តាញទូរគមនាគមន៍ជនបទ ប្រកបដោយប្រសិទ្ធភាពផងដែរ ។ ក្នុងនីតិកាលទី៣នេះ រាជរដ្ឋាភិបាលនឹងបន្តពង្រីកបណ្តាញទូរគមនាគមន៍ពីក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងខេត្តសៀមរាប ទៅកាន់បណ្តាទីប្រជុំជនដទៃទៀត ។ រាជរដ្ឋាភិបាលនឹងបង្កើតអោយមានទំនាក់ទំនងតាមរលកធាតុអាកាសក៏រឹតទាប ឬទំនាក់ទំនងតាមខ្សែកាបអុបទិច ដើម្បីតភ្ជាប់ ÷ ទី១-កំពង់ចាម- ភ្នំពេញ- តាកែវ- កំពត- ក្រុងព្រះសីហនុ ។ ទី២ កំពង់ចាម- កំពង់ធំ- សៀមរាប- ស៊ីសុផុន ។ ទី៣-កំពង់ចាម- ក្រចេះ- ស្ទឹងត្រែង ។ និងទី៤-មណ្ឌលគីរី- ប៉ៃលិន- ព្រះវិហារ- ឧត្តរមានជ័យ ។ រីឯរចនាសម្ព័ន្ធប្រៃសណីយ៍ ព្រមទាំងសមត្ថភាពខាងផ្នែកស្ថាប័ន ក៏ត្រូវពង្រឹងអោយបានរឹងមាំដែរ ដើម្បីបង្កើនគុណភាពសេវានេះអោយកាន់តែប្រសើរឡើង ។ ព្រមជាមួយគ្នានេះ បណ្តាញផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ក៏ត្រូវពង្រឹងផងដែរក្នុងគោលដៅបង្កើនប្រសិទ្ធភាព ។ រាជរដ្ឋាភិបាលនឹងដាក់ចេញនូវបទដ្ឋានថ្នាក់ជាតិ សំរាប់រៀបចំផែនការវិនិយោគ និងកិច្ចប្រតិបត្តិការនៅក្នុងគ្រប់សេវាទូរគមនាគមន៍ និងបច្ចេកវិទ្យាពត៌មាន រួមមានប្រព័ន្ធស្តង់ដារ និងបទដ្ឋានសំរាប់ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាពត៌មាន និងអ៊ិនទែរណិតផងដែរ ។

៧៨- រាជរដ្ឋាភិបាលចាត់ទុក**វិស័យឯកជន**ជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច ។ រាជរដ្ឋាភិបាលនឹងបន្តតួនាទីជាយុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីបង្កើតបរិស្ថានធុរកិច្ចអោយកាន់តែប្រសើរសំរាប់វិស័យឯកជន និងការគ្រប់គ្រងការអភិវឌ្ឍន៍ ។ ក្នុងការរៀបចំអោយកាន់តែប្រសើរឡើងនូវបរិស្ថានរួមសំរាប់ការអភិវឌ្ឍន៍របស់វិស័យឯកជនអាទិភាពចំបង របស់រាជរដ្ឋាភិបាលនៅក្នុងនីតិកាលទី ៣ នេះ គឺប្រកាន់យកនូវវិធានការជាក់ស្តែង នានាដែលសំដៅ ទី១-ពង្រឹងអភិបាលកិច្ចទាំងនៅក្នុងវិស័យសាធារណៈ ទាំងនៅក្នុងវិស័យឯកជន ។ ទី២-សំរួលពាណិជ្ជកម្ម និងកែលំអបរិយាកាសវិនិយោគ ។ ទី៣-ជំរុញការអភិវឌ្ឍន៍ធនធានមនុស្ស អោយឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងតំរូវការទីផ្សារ ។ រាជរដ្ឋាភិបាលនឹងបន្តគាំទ្រការវិនិយោគពីសំណាក់ផ្នែកឯកជន នៅតាមវិស័យអាទិភាព ទាំង ៦ គឺ ÷

- ទី១- ការអភិវឌ្ឍន៍វិស័យកសិកម្ម និងកសិឧស្សាហកម្ម ក្នុងនោះផ្តល់អាទិភាពលើការដោះស្រាយទឹកសំរាប់កសិកម្ម ។
- ទី២- ការអភិវឌ្ឍន៍ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដឹកជញ្ជូន និងទូរគមនាគមន៍ ។
- ទី៣- ការអភិវឌ្ឍន៍វិស័យថាមពល និងអគ្គិសនី ។
- ទី៤- វិស័យឧស្សាហកម្មអតិពលកម្ម និងឧស្សាហកម្មកែច្នៃសំរាប់ការនាំចេញ ។
- ទី៥- វិស័យឧស្សាហកម្មទេសចរណ៍ ។
- ទី៦- ការអភិវឌ្ឍន៍ធនធានមនុស្ស ។

៧៩- រាជរដ្ឋាភិបាលបានកំណត់ថា ការកែលំអបរិស្ថានសំរាប់ធុរកិច្ច និងការបង្កើតបរិស្ថានអំណោយផល សំរាប់កិច្ចអភិវឌ្ឍន៍វិស័យឯកជន គឺជាបុរេលក្ខខ័ណ្ឌសំរាប់ជំរុញកំណើនសេដ្ឋកិច្ច បង្កើតការងារ កាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ។ ដើម្បីលុបបំបាត់កត្តារាំងស្ទះដល់ការអភិវឌ្ឍន៍វិស័យ

ឯកជន និងក្នុងដំណើរការកំណែទំរង់រដ្ឋបាល និងគតិយុត្តិ រាជរដ្ឋាភិបាលបានបង្កើតវេទិការវាងរាជរដ្ឋាភិបាល និងឯកជនចាប់តាំងពីឆ្នាំ១៩៩៩ ហើយមានការជួបប្រជុំទៀងទាត់រាល់៦ខែម្តង ដោយមានការគាំទ្រពីក្រុមការងារទាំង៧ ។ ក្រុមការងារទាំងនេះបានជួបប្រជុំរៀងរាល់ខែ ដើម្បីដោះស្រាយបញ្ហាទាំងឡាយ ។ លើសពីនេះទៅទៀត ដើម្បីបន្តពង្រឹងយន្តការខាងស្ថាប័នសំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ នៅក្នុងវេទិការវាងរាជរដ្ឋាភិបាល និងផ្នែកឯកជន នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៤ កន្លងមក សម្តេច នាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានប្រកាសអំពីការបង្កើតគណៈកម្មាធិការដឹកនាំការងារសំរាប់ការអភិវឌ្ឍន៍ផ្នែកឯកជន ។ គណៈកម្មាធិការនេះដឹកនាំដោយទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជាអនុប្រធាន ។ រីឯសមាជិករួមមានអគ្គទេសាភិបាលធនាគារជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងទេសចរណ៍ ដោយមានអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអគ្គលេខាធិការ ។ គណៈកម្មាធិការដឹកនាំការងារនេះមានអនុគណៈកម្មាធិការចំនួន ៣ គឺ ÷ ១) អនុគណៈកម្មាធិការបរិស្ថានវិនិយោគ និងការចូលរួមរបស់ផ្នែកឯកជនក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ (PPI) ដឹកនាំដោយទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ២) អនុគណៈកម្មាធិការសំរួលពាណិជ្ជកម្ម ដឹកនាំដោយទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។ និង៣) អនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ គណៈកម្មាធិការដឹកនាំការងារ និងអនុគណៈកម្មាធិការទាំង៣នឹងបំពេញការងាររបស់ខ្លួនជាមួយដៃគូអភិវឌ្ឍន៍នានាដែលមានបំណងជួយកម្ពុជា ក្នុងការអភិវឌ្ឍន៍ផ្នែកឯកជន តាមរយៈអភិក្រមនៃការគ្រប់គ្រងទូទាំងផ្ទៃវិស័យសំរាប់អភិវឌ្ឍផ្នែកឯកជន ។

៨០- **វិស័យទេសចរណ៍**បានទាក់ទាញវិនិយោគឯកជនជាច្រើន ។ រាជរដ្ឋាភិបាលបន្តគាំទ្រវិស័យឯកជន ក្នុងការជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសំរាប់ពង្រីកវិស័យទេចរណ៍ ។

៨១- រាជរដ្ឋាភិបាលបានលើកទិសដៅជំរុញការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម (SME) នៅក្នុងនីតិកាលទីបីនេះ ។ អាទិភាពចំបងៗមាន ÷ ទី១-លើកទឹកចិត្តដល់ការរីកលូតលាស់ផ្នែក SME ជាពិសេសតាមរយៈការផ្តល់ឥណទានរយៈពេលមធ្យម និងរយៈពេលវែង ។ ទី២-ទប់ស្កាត់ការរត់ពន្ធគ្រប់ប្រភេទ ។ ទី៣-កាត់បន្ថយបែបបទសំរាប់ការចុះបញ្ជី និងការរៀបចំដំណើរការក្រុមហ៊ុន ។ ទី៤-សំរួលការនាំចេញ-នាំចូលតាមរយៈការកាត់បន្ថយបែបបទស្មុគ្រស្មាញ មានដូចជាអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតផ្សេងៗ ។ ទី៥-ផ្តល់ការគាំពារដល់ឧស្សាហកម្មក្មេងខ្ចីមួយចំនួនក្នុងរយៈពេលសមស្របមួយ ។ ទី៦-ជំរុញសម្ព័ន្ធភាពរវាងសហគ្រាសខ្នាតតូចនិងមធ្យម ជាមួយនឹងឧស្សាហកម្មធុនធំ ។ ទី៧-ជំរុញបង្កើតមជ្ឈមណ្ឌលផលិតភាពជាតិ ដែលជួយដល់ឧស្សាសហកម្មធុនតូច និងមធ្យម តាមរយៈការលើកកំពស់ផលិតភាព និង ការកាត់បន្ថយថ្លៃដើមនៃផលិតកម្ម ។ ទី៨-បង្កើតវិទ្យាស្ថានស្តង់ដារជាតិ ដែលនឹងជួយធានាអោយគុណភាពផលិតផលក្នុងប្រទេសអាចឆ្លើយតបបានទៅនឹងស្តង់ដារតំបន់ និងអន្តរជាតិ ។ ទី៩-បង្កើតមន្ទីរពិសោធន៍ជាតិផ្នែករូបគីមី មីក្រូជីវៈមេកានិច និងការធ្វើតេស្ត ដែលអាចកំណត់បានលើគុណភាព និងលក្ខណៈវិនិច្ឆ័យរបស់ផលិតផល ។

ទី១០-ពង្រឹងយន្តការការពារកម្មសិទ្ធិបញ្ញាឧស្សាហកម្ម ដែលការពារដល់ការលួចចម្លងដោយខុសច្បាប់ ក្នុងការរិះរក និងប្រើប្រាស់បច្ចេកទេស និងបច្ចេកវិទ្យាថ្មី ព្រមទាំងផលិតផលថ្មី ។ ទី១១-ជំរុញដល់ការបណ្តុះបណ្តាលមុខវិជ្ជាជំនាញ ទាំងនៅក្នុង និងក្រៅប្រទេស ។ ទី១២-បង្កើនចលនា «ភូមិមួយ- ផលិតមួយ »។ ទី១៣-ពង្រឹងប្រព័ន្ធច្បាប់ដោយបង្កើតច្បាប់រោងចក្រ ច្បាប់តំបន់ឧស្សាហកម្ម ច្បាប់ប៉ាតង់ និងតក្កកម្មឧស្សាហកម្ម ច្បាប់រង្វាស់រង្វាល់ ច្បាប់សុវត្ថិភាពឧស្សាហកម្ម ។

៨២ រាជរដ្ឋាភិបាលនឹងបន្តជំរុញផ្នែក**ឥណទានជនបទ** ដើម្បីប្រជាជនក្រីក្រអាចទទួលឥណទានបាន តាមកំរិតការប្រាក់សមស្រប ពិសេសប្រជាជនដែលរស់នៅតំបន់ជនបទ និងនៅតាមតំបន់ព្រំដែន និងប្រជាជនដែលប្រកបអាជីវកម្មក្នុងសហគ្រាសតូច និងមធ្យម ។

៨៣- ដើម្បី**បង្កើតការងារនិងធានាលក្ខខ័ណ្ឌការងារល្អប្រសើរជូនកម្មករ និងនិយោជិត** អាទិភាពរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី៣ នៃរដ្ឋសភាគឺ ÷ ទី១- ដាក់ចេញនូវវិធានការនានា ដែលលើកទឹកចិត្តដល់ការវិនិយោគក្នុងស្រុក និងដែលទាក់ទាញវិនិយោគផ្ទាល់ពីបរទេស នៅតាមបណ្តាវិស័យជាអាទិភាពទាំងឡាយ ពិសេសវិស័យកសិកម្ម កសិ-ឧស្សាហកម្ម ឧស្សាហកម្មអតិពលកម្ម និងទេសចរណ៍ ។ ទី២- បង្កើតស្ថាប័នបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជូនជនក្រីក្រដែលផ្សាភ្ជាប់ជាមួយនឹងមជ្ឈមណ្ឌល សំរាប់ជួយរកការងារធ្វើអោយយុវជន ជាពិសេសយុវជនដែលទើបចេញពីសាលាអោយបានស្របតាមតំរូវការទីផ្សារពលកម្ម ។ និងទី៣- រៀបចំប្រព័ន្ធស្ថិតិការងារ ។

៨៤- ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិនានា រាជរដ្ឋាភិបាលនឹងបង្កើនកិច្ចអន្តរាគមន៍ក្នុង**វិស័យសង្គមកិច្ច** ក្នុងទិសដៅលើកស្ទួយកាលានុវត្តភាពការងារ កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋក្រីក្រ បង្កើនសកម្មភាពសង្គ្រោះបន្ទាន់ ដើម្បីជួយដល់អ្នករងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗ និងពង្រីកកម្មវិធីស្តារលទ្ធភាពពលកម្មសំរាប់ជនពិការ ព្រមទាំងកម្មវិធីលើកកំពស់សុខុមាលភាពរបស់ជនចាស់ជរា កុមារកំព្រា ស្ត្រីរងគ្រោះ ជនអនាថាគ្មានទីពឹង អតីតយុទ្ធជន និងគ្រួសារ ។ រាជរដ្ឋាភិបាលបន្តជួយឧបត្ថម្ភអោយបានជិតដល់ចំពោះជនពិការ និងគ្រួសារយុទ្ធជន ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ព្រមទាំងជំរុញអោយម្ចាស់សហគ្រាស រោងចក្រ ឧបត្ថម្ភប្រាក់បៀវត្ស រួមជាមួយកំរៃបេឡាសន្តិសុខសង្គមដល់កម្មករជាជំហានៗ អោយបានសមស្របតាមកំរិតលក្ខខ័ណ្ឌទីផ្សារការងារ ។

៨៥- ពលករដែលមានសុខភាពល្អ និងមានជំនាញច្បាស់លាស់ ដែលអាចឆ្លើយតបនឹងតំរូវការទីផ្សារពលកម្ម គឺជាបុរេលក្ខខ័ណ្ឌមួយដែលមិនអាចខ្វះបាន សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាព ។ អាទិភាពរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទីបីនេះគឺ **ការពង្រឹងគុណភាពអប់រំ** កែលំអការផ្តល់សេវាសុខភាព លុបបំបាត់អសមភាពផ្លូវភេទ និងអនុវត្តនូវគោលនយោបាយប្រជាសាស្ត្រ ។ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងបន្ថែមទៀតនូវសមិទ្ធផលនៃការអប់រំសំរាប់ទាំងអស់គ្នា នៅក្នុងការអប់រំមូលដ្ឋាន ។ រាជរដ្ឋាភិបាលនឹងបន្តខិតខំបង្កើនចំណាយថវិកា និងកៀងគរជំនួយបរទេសអោយបានច្រើនថែមទៀត សំរាប់លើកទឹកចិត្តគ្រូបង្រៀន ធានា

គុណភាពបណ្តុះបណ្តាល បង្កើនការផ្គត់ផ្គង់សំភារៈសិក្សា បណ្ណាល័យ និងមន្ទីរពិសោធន៍ បង្កើតអន្តេវាសិកដ្ឋានសំរាប់សិស្ស- និស្សិត ពិសេសសំរាប់សិស្ស- និស្សិតជានារីភេទ បន្តជំរុញកំណែទំរង់កម្មវិធីសិក្សា ផ្តល់អាហារូបករណ៍ដល់សិស្សនិងនិស្សិតក្រីក្រ ជំរុញកម្មវិធីអក្ខរកម្ម និងការអប់រំក្រៅប្រព័ន្ធ និងផ្តល់ថវិកាសំរាប់កសាងសាលារៀននៅតាមជនបទ ព្រមទាំងធានាការចំណាយប្រតិបត្តិការរបស់សាលារៀន ។ ព្រមជាមួយនេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន ព្រមទាំងសហគមន៍ជាតិ និងអន្តរជាតិ ដើម្បីបង្កើននិងលើកកំពស់គុណភាពសេវាអប់រំ ទាំងក្នុងកំរិតមធ្យមសិក្សា បណ្តុះបណ្តាលវិជ្ជាជីវៈ និង បច្ចេកទេសទាំងក្នុងកំរិតឧត្តមសិក្សា ក្នុងគោលដៅឆ្លើយតបបានយ៉ាងសមស្របទៅនឹងស្តង់ដារអន្តរជាតិ និងតំរូវការអភិវឌ្ឍន៍របស់ប្រទេស ។

៨៦- រាជរដ្ឋាភិបាលបានប្តេជ្ញាអនុវត្តប្រកបដោយប្រសិទ្ធភាពនូវច្បាប់ និងបទបញ្ញត្តិនានាស្តីពីសុខាភិបាល ដើម្បីធានាគុណភាពនៃការផ្តល់**សេវាសុខាភិបាល**និងឱសថរួមទាំងឱសថបូរាណតាមរយៈការផ្តល់ពត៌មាន និងការត្រួតពិនិត្យដោយផ្សារភ្ជាប់ជាមួយនឹងការប្រើប្រាស់ឱសថសម័យ ។ រាជរដ្ឋាភិបាលបានផ្តល់អាទិភាពទៅលើការបង្កើនការវិភាជន៍ធនធានសាធារណៈសំរាប់វិស័យសុខាភិបាល និងត្រូវបន្តលើកទឹកចិត្តការចូលរួមរបស់សហគមន៍អន្តរជាតិ និងផ្នែកឯកជន ដើម្បីបង្កើនការវិនិយោគបន្ថែមទៀតនៅក្នុងវិស័យសុខាភិបាល សំដៅលើកកំពស់ស្ថានភាពសុខភាពរបស់ប្រជាជន ។ អាទិភាពនឹងត្រូវផ្តល់ទៅលើការសាងសង់មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ដែលអាចផ្តល់សេវាសុខាភិបាលតាមរូបភាពមួយដែលមានប្រសិទ្ធភាព សមធម៌ និរភាព សំរាប់ប្រជាពលរដ្ឋទូទាំងប្រទេស ពិសេសប្រជាជនក្រីក្រនិងក្រុមជនងាយរងគ្រោះ ។ រាជរដ្ឋាភិបាលនឹងបន្តយកចិត្តទុកដាក់អនុវត្តកម្មវិធីការពារ និងប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងនានា ព្រមទាំងជំរុញលើកទឹកចិត្តអោយមានការថែទាំសុខភាពមាតានិងកុមារ សំដៅកាត់បន្ថយមរណភាពមាតា និងកុមារ និងកែលំអសេវាសង្គ្រោះបន្ទាន់ និងផ្តល់ការអប់រំ និងពត៌មានស្តីពីសុខភាព និងអនាម័យ ពិសេសនៅតាមតំបន់ជនបទ ។ ជនក្រីក្រនឹងទទួលការថែទាំសុខភាពដោយឥតបង់ថ្លៃ នៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ។ មូលនិធិប្រកបដោយសមធម៌នឹងត្រូវបានពង្រឹងនិងពង្រីកបន្ថែមទៀត ដើម្បីអោយជនក្រីក្រអាចទទួលសេវាសុខាភិបាលប្រកបដោយគុណភាព ។ រាជរដ្ឋាភិបាលនឹងទទួលយក និងជំរុញការអនុវត្តន៍ច្បាប់ និងបទបញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យសុខាភិបាល ដើម្បីធានាសេវាសុខាភិបាល ឱសថ និងអាហារប្រកបដោយគុណភាព ។ រាជរដ្ឋភិបាលនឹងបន្តលើកទឹកចិត្តការប្រើប្រាស់ឱសថបូរាណ គួបផ្សំជាមួយឱសថសម័យដោយផ្តល់ពត៌មាន និងមានការត្រួតពិនិត្យត្រឹមត្រូវ ។

៨៧- ដើម្បីឆ្លើយតបទាន់ពេលវេលា និងមានប្រសិទ្ធភាពចំពោះការរាលដាលនៃជំងឺ **អេដស៍** រាជរដ្ឋាភិបាលនឹងប្រកាន់យកនូវវិធានការចាំបាច់នានា សំដៅ ទី១-ទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺនេះ ទី២-កែលំអ និងលើកកំពស់ការផ្តល់ការគាំពារ និងព្យាបាលដល់អ្នកផ្ទុកមេរោគអេដស៍ និងទី៣-កាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីការឆ្លងមេរោគអេដស៍ ។

៨៨- រាជរដ្ឋាភិបាលនឹងបន្តអនុវត្តផែនការយុទ្ធសាស្ត្រ *«នារីរតនៈ»* ឬ ស្ត្រីគឺជាត្បូងមានតំលៃ ក្នុងគោលបំណងផ្តល់ជូនស្ត្រីខ្មែរនូវតម្លៃ និងក្តីសង្ឃឹមក្នុងជីវិត និងដែលផ្តោតលើបញ្ហាយេនឌ័រ ។ គោលបំណងចំបងនៃកម្មវិធីនេះ គឺការកសាងសមត្ថភាពរបស់ស្ត្រី និងការកែប្រែអាកប្បកិរិយាក្នុងសង្គម ដែលមានការរើសអើងចំពោះស្ត្រី ។ រាជរដ្ឋាភិបាលផ្តល់អាទិភាពខ្ពស់ ទៅការលើកកំពស់តួនាទី និងស្ថានភាពសង្គមរបស់ស្ត្រីកម្ពុជា ដោយយកចិត្តទុកដាក់ជំរុញការអនុវត្តន៍ **យុទ្ធសាស្ត្រយេនឌ័រ** ការកសាងសមត្ថភាពស្ត្រីលើគ្រប់ផ្នែក ការកែប្រែឥរិយាបថក្នុងសង្គមដែលមានការរើសអើងចំពោះស្ត្រីភេទ និងការធានាសិទ្ធិដើម្បីអោយស្ត្រីភេទមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចូលរួមយ៉ាងសកម្ម និងដោយស្មើភាពក្នុងដំណើរការកសាងប្រទេស ។ កម្មវិធី *«នារីរតនៈ»* បានបង្ហាញអំពីបំណងប្រាថ្នាចង់ឃើញប្រជាពលរដ្ឋស្ត្រី និងបុរសរួបរួមគ្នាធ្វើដំណើរឆ្ពោះទៅមុខ ដើម្បីស្ថាបនាប្រទេសជាតិមួយប្រកបដោយសុខសន្តិភាព អភិវឌ្ឍន៍ លើកស្ទួយការគោរពច្បាប់ និងវិន័យ តាមរយៈប្រព័ន្ធមួយដែលមានយុត្តិធម៌ តំលាភាព ព្រមជាមួយនឹងអភិបាលកិច្ចល្អ ដែលដឹកនាំសង្គម សេដ្ឋកិច្ច និងនយោបាយ អោយមានស្ថិរភាពតរៀងទៅ ។ *«នារីរតនៈ»* មានគោលដៅកែប្រែជីវភាព និងស្ថានភាពរស់នៅរបស់ស្ត្រីអោយរួចផុតពីភាពក្រីក្រ តាមរយៈការកសាងសមត្ថភាព ដើម្បីផ្តល់លទ្ធភាពអោយស្ត្រីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច និងកម្មវិធីជាអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងវិស័យអប់រំសុខភាព ការអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការពារតាមផ្លូវច្បាប់ និងភាពជាអ្នកដឹកនាំ ។

៨៩- អត្រាកំណើនប្រជាជនពេលបច្ចុប្បន្ន ជាបន្ទុកដ៏ធ្ងន់ធ្ងរមិនត្រឹមតែសំរាប់សេវាសាធារណៈប៉ុណ្ណោះទេ ថែមទាំងមានផលប៉ះពាល់ជាអវិជ្ជមាន ទៅលើភាពក្រីក្រផងដែរ ។ រាជរដ្ឋាភិបាលយល់យ៉ាងច្បាស់ពីផលវិបាកទាំងនេះសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ។ ក្នុងន័យនេះ**គោលនយោបាយប្រជាជន**របស់រាជរដ្ឋាភិបាល គឺសំដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងសំរេចអោយបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា ។

## ភាពជាដៃគូនៅក្នុងការអភិវឌ្ឍន៍

៩០- ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ការពង្រឹងភាពជាដៃគូជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ក្នុងនោះរួមមាន ភាពជាដៃគូជាមួយនឹងសហគមន៍អ្នកផ្តល់ជំនួយ វិស័យឯកជន និងសង្គមស៊ីវិល គឺជាអាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាល ។ គោលការណ៍ជាមូលដ្ឋានសំរាប់ពង្រឹងភាពជាដៃគូជាមួយសហគមន៍អ្នកផ្តល់ជំនួយ ត្រូវបានរៀបចំឡើង ដោយឈរលើមូលដ្ឋាននៃសេចក្តីសំរេចចិត្តរបស់មហាសន្និបាតនៃអង្គការសហប្រជាជាតិ គោលការណ៍របស់គណកម្មការជំនួយដើម្បីអភិវឌ្ឍន៍ (DAC) នៃអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (OECD) ក៏ដូចជាការផ្តួចផ្តើមគំនិតនានារបស់ធនាគារពិភពលោក និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ។ រាជរដ្ឋាភិបាលនឹងបន្តពង្រឹង «វេទិកាព្រជរដ្ឋាភិបាល– ផ្នែកឯកជន» អោយក្លាយទៅជាយន្តការនៃភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន ប្រកបដោយប្រសិទ្ធភាពកាន់តែខ្ពស់ជាងមុន ។ រាជរដ្ឋាភិបាលបន្តពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋ និងសង្គមស៊ីវិល ដោយឈរលើគោលការណ៍នីតិរដ្ឋ ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ សិទ្ធិសេរីភាព សណ្តាប់ធ្នាប់សង្គម និងការគោរព

ច្បាប់ ។ រាជរដ្ឋាភិបាលបានចាត់ទុកថាសង្គមស៊ីវិលត្រូវមានតួនាទីជាដៃគូមួយដ៏មានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល ក្នុងការកសាងប្រទេសជាតិ ។ ក្នុងទស្សនៈនេះ រាជរដ្ឋាភិបាលលើកទឹកចិត្តតាមគ្រប់រូបភាពចំពោះអង្គការក្រៅរដ្ឋាភិបាល និងសមាគមស្របច្បាប់នានា ដែលកំពុងធ្វើសកម្មភាពបំរើផលប្រយោជន៍ប្រជាពលរដ្ឋនៅទូទាំងប្រទេស ។ រាជរដ្ឋាភិបាលស្វាគមន៍ការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល ក្នុងដំណើរការស្តារ និងអភិវឌ្ឍន៍សេដ្ឋកិច្ច- សង្គមកិច្ច និងការគាំពារលើកស្ទួយការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញការបង្កើត និងអនុវត្តច្បាប់ស្តីពីអង្គការក្រៅរដ្ឋាភិបាលនិងសមាគម ដោយមានការពិគ្រោះយោបល់ជាមួយនឹងស្ថាប័ននិងអង្គការពាក់ព័ន្ធ ។

៩១- នៅក្នុងនីតិកាលទី៣នេះ បញ្ហាប្រឈមសំខាន់របស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ គឺការកំណត់អោយបាននូវអភិក្រមសំរាប់អនុវត្ត ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ជំនួយ ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ និងដើម្បីឈានទៅសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលស្នើអោយដៃគូអភិវឌ្ឍន៍ទាំងអស់តំរឹមកម្មវិធីផ្តល់ជំនួយរបស់ខ្លួន ជាមួយនឹងបណ្តាអាទិភាពអភិវឌ្ឍន៍របស់កម្ពុជា និងធ្វើសុខដុមនីយកម្មនៃការអនុវត្តន៍ដោយផ្អែកតាមបណ្តាគោលការណ៍ និងការណែនាំទាំងឡាយដែលបានឯកភាពក្នុងកិច្ចប្រជុំអន្តរជាតិ ពិសេស កិច្ចប្រជុំរបស់អង្គការសំរាប់សហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (OECD/DAC) ។ រាជរដ្ឋាភិបាលយល់ថា ការប្រើប្រាស់យុទ្ធសាស្ត្រជាតិសំរាប់រៀបចំផែនការ និងគ្រប់គ្រងជំនួយ និងការបង្កើនសុខដុមនីយកម្មក្នុងការអនុវត្តន៍របស់អ្នកផ្តល់ជំនួយ មិនត្រឹមតែអាចពង្រឹងភាពជាម្ចាស់ក្នុងកិច្ចអភិវឌ្ឍន៍របស់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែ វាក៏ជាមធ្យោបាយមួយសំរាប់បង្កើនការងារសំរបសំរួល និងប្រសិទ្ធភាពនៃជំនួយផងដែរ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏ជំរុញអោយដៃគូអភិវឌ្ឍន៍រៀបចំការផ្តល់ជំនួយតាមអភិក្រមគ្រប់គ្រងតាមកម្មវិធីឬតាមវិស័យ (Program/Sector Based Approach) ដែលមិនត្រឹមតែអាចកាត់បន្ថយចំនួនគំរោងទោល (Stand-Alone Project) ដែលនេះជាអំរែកយ៉ាងធ្ងន់ មកលើសមត្ថភាពខាងស្ថាប័នប៉ុណ្ណោះទេ ប៉ុន្តែវាអាចជួយតំរង់ការប្រើប្រាស់ជំនួយអោយចំគោលដៅផងដែរ ។

៩២ យន្តការនៃក្រុមការងារត្រូវបានបង្កើតឡើងក្នុងកិច្ចប្រជុំពិគ្រោះយោបល់ឆ្នាំ១៩៩៩ ដើម្បីតាមដានការអនុវត្តន៍កម្មវិធីកំណែទំរង់របស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បានឯកភាពគ្នាកែសំរួលឡើងវិញនូវរចនាសម្ព័ន្ធរបស់ក្រុមការងារទាំងនេះ សំដៅបង្កើនប្រសិទ្ធភាពនៃក្រុមការងារទាំងនេះ និងដើម្បីធានាអោយមានសង្គតិភាពជាងមុន ក្នុងរាល់សកម្មភាពប្រតិបត្តិការរបស់ជំនួយ ។ គោលការណ៍សំខាន់ៗនៃដំណើរការកែសំរួលនេះ ត្រូវបានអនុម័តយកដោយសម្តេច នាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក្នុងកិច្ចប្រជុំត្រៀមពិគ្រោះយោបល់ កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ ។ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បានឯកភាពបង្កើតក្រុមការងារចំរុះចំនួន១៧នៅតាមវិស័យនានា ។ នៅក្នុងកិច្ចប្រជុំត្រៀម នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានកំណត់ភារកិច្ចបន្ទាន់មួយចំនួន ដែលក្រុមការងារនិមួយៗត្រូវអនុវត្តចាប់ពីពេលនេះរហូតដល់កិច្ចប្រជុំពិគ្រោះយោបល់នាដើមខែធ្នូ ឆ្នាំ ២០០៤ ។

១- ដៃគូទាំងសងខាងត្រូវសហការគ្នាជំរុញការរៀបចំបញ្ចប់ជាបន្ទាន់ អំពីសមាជិកភាពរបស់ក្រុមការងារនីមួយៗ និងលក្ខខ័ណ្ឌយោងសំរាប់ក្រុមការងារបច្ចេកទេសចំរុះនីមួយៗ ។

២- ក្រុមការងារនីមួយៗត្រូវវាយតំលៃអំពីវឌ្ឍនភាពនៃការអនុវត្តន៍លក្ខខ័ណ្ឌទាំង៩ដែលរាជរដ្ឋាភិបាលបានប្តេជ្ញាអនុវត្ត ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ នាខែមិថុនា ឆ្នាំ ២០០២ កន្លងមក ព្រមទាំងបញ្ហាប្រឈម និងបញ្ហាសេសសល់ដែលត្រូវអនុវត្តបន្ត ។ របាយការណ៍របស់ក្រុមការងារនីមួយៗនឹងត្រូវច្របាច់បញ្ចូលគ្នាជាឯកសារតែមួយ ដែលត្រូវលើកបង្ហាញក្នុងកិច្ចប្រជុំពិគ្រោះយោបល់ នាខែធ្នូ ឆ្នាំ ២០០៤ ខាងមុខនេះ ។

៣- ក្រុមការងារបច្ចេកទេសនីមួយៗត្រូវរៀបចំផែនការសកម្មភាពរបស់ខ្លួន ព្រមទាំងលក្ខខ័ណ្ឌវិនិច្ឆ័យនានា (Benchmarks) សំរាប់កិច្ចប្រជុំពិគ្រោះយោបល់ នាខែធ្នូ ឆ្នាំ ២០០៤ ខាងមុខនេះ ពិនិត្យនិងអនុម័ត ។

៩៣- ទន្ទឹមនឹងនេះ ដើម្បីធានាអោយមានការសំរបសំរួលរវាងក្រុមការងារបច្ចេកទេសបច្ចេកទេសចំរុះទាំងនេះ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍បានឯកភាពគ្នាបង្កើត «គណៈកម្មាធិការសំរបសំរួលរវាងរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ» (Government-Donor Coordination Committee-GDCC) ដែលមានភារកិច្ចផ្តល់ការណែនាំក្នុងកំរិតគោលនយោបាយ (Policy Guidance) កំណត់អាទិភាព និងស្នើវិធានការសំរាប់ដោះស្រាយបញ្ហានានាដែលក្រុមការងារបច្ចេកទេសបានលើកឡើង ។ «គណៈកម្មាធិការសំរបសំរួលរវាងរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ» មានលេខាធិការដ្ឋានមួយសំរាប់ជួយការងាររបស់ខ្លួន ។ លេខាធិ-ការដ្ឋាននេះ មានទីតាំងនៅគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

៩៤- ចំពោះសុខដុមនីយកម្ម និងការតំរឹមសកម្មភាពផ្តល់ជំនួយដើម្បីលើកកំពស់ប្រសិទ្ធភាពជំនួយ កម្ពុជាបានសំរេចវឌ្ឍនភាពសំខាន់ៗមួយចំនួនក្នុងឆ្នាំកន្លងមក ទាំងលើឆាកអន្តរជាតិ និងនៅក្នុងប្រទេស ។ នៅលើវេទិកាអន្តរជាតិ ក្រុមដឹកនាំការងារស្តីអំពីសុខដុមនីយកម្មរបស់ OECD/DAC បានចេញផ្សាយកំរងឯកសារស្តីពីការអនុវត្តន៍ល្អរបស់អ្នកផ្តល់ជំនួយ (Good Donor Practices Papers) ដែលឯកសារទាំងនេះត្រូវបានអនុម័តយល់ព្រមនៅក្នុងវេទិកាជាន់ខ្ពស់ (High Level Forum) ដោយមានការចូលរួមពីតំណាងប្រទេសនិងស្ថាប័នផ្តល់ជំនួយពហុភាគី និងទ្វេភាគី តំណាងមកពី IMF និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងពីបណ្តាប្រទេសជាដៃគូដទៃទៀត នៅក្រុងរ៉ូមនៃប្រទេសអ៊ីតាលី កាលពីខែកុម្ភៈ ឆ្នាំ២០០៣ ។ វេទិកាជាន់ខ្ពស់នេះបានថ្លែងសេចក្តីប្រកាសមួយ ដែលមានឈ្មោះថាសេចក្តីប្រកាសក្រុងរ៉ូម (Rome Declaration) ក្នុងនោះ ដៃគូអភិវឌ្ឍន៍ទាំងអស់បានប្តេជ្ញាគាំទ្រកិច្ចប្រឹងប្រែងក្នុងការធ្វើសុខដុមនីយកម្ម ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់ជំនួយ ។

៩៥- រាជរដ្ឋាភិបាលបានរៀបចំផែនការសកម្មភាព សំរាប់អនុវត្តការប្តេជ្ញាចិត្ត ដែលបានចែងនៅក្នុងសេចក្តីប្រកាសក្រុងរ៉ូម ។ ផែនការសកម្មភាពនេះនឹងបង្ហាញជូននៅក្នុងរបាយការណ៍របស់រាជរដ្ឋាភិបាលស្តីពី «ការកសាងភាពជាដៃគូដើម្បីអភិវឌ្ឍន៍- បច្ចុប្បន្នភាព» ។ ក្នុងការអនុវត្តន៍ផែនការសកម្មភាពនេះ រាជរដ្ឋាភិបាលទទួល

ស្គាល់នូវបញ្ហាប្រឈមជាច្រើន ។ បញ្ហាប្រឈមដ៏ធ្ងន់ធ្ងរមួយគឺ គម្លាតរវាងគោលនយោបាយសុខដុមនីយកម្ម ដែលបានព្រមព្រៀងនៅក្នុងកំរិតអន្តរជាតិ និងសកម្មភាពចាំបាច់ដែលត្រូវអនុវត្តដើម្បីផ្លាស់ប្តូរបែបបទអនុវត្តន៍ និងឥរិយាបថរបស់អ្នកផ្តល់ជំនួយដែលកំពុងបំពេញភារកិច្ចនៅក្នុងប្រទេសដែលជាដៃគូរបស់ខ្លួន ។ ស្ថាប័នកណ្តាលនៃប្រទេសផ្តល់ជំនួយមួយចំនួនបានរៀបចំរួចហើយ នូវផែនការសកម្មភាពដើម្បីធ្វើសុខដុមនីយកម្មនៃការផ្តល់ជំនួយរបស់ពួកគេ ស្របតាមគោលការណ៍របស់ OECD/DAC ។ តាងនាមអោយរាជរដ្ឋាភិបាល ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានស្នើអោយក្រុមដឹកនាំការងាររបស់OECD/DAC ចែករំលែកមិនត្រឹមតែផែនការសកម្មភាពជាមួយប្រទេសជាដៃគូរបស់ខ្លួនប៉ុណ្ណោះទេ ថែមទាំងស្នើសុំអោយធ្វើការតាមដានយ៉ាងម៉ត់ចត់ និងរាយការណ៍ជាទៀងទាត់ដល់ប្រទេសជាដៃគូថែមទៀតផង ពិសេសលើបញ្ហាដូចជា ÷

- កំរិតនៃការចែកផ្សព្វផ្សាយនូវផែនការសកម្មភាព ដែលបានរៀបចំឡើងដោយស្ថាប័នកណ្តាលរបស់ប្រទេសផ្តល់ជំនួយ និងទីស្នាក់ការកណ្តាលនៃស្ថាប័នផ្តល់ជំនួយពហុភាគី ជាមួយនឹងការិយាល័យរបស់ខ្លួននៅតាមប្រទេសទទួលជំនួយ ។
- ការណែនាំច្បាស់លាស់ស្តីពីការអនុវត្តន៍ផែនការសកម្មភាព ពីស្ថាប័នកណ្តាលរបស់ប្រទេសផ្តល់ជំនួយ និងស្ថាប័នផ្តល់ជំនួយពហុភាគី មកដល់ការិយាល័យរបស់ខ្លួននៅតាមប្រទេសទទួលជំនួយ ។
- ការប្រតិភូកម្មអំណាចក្នុងការអនុវត្តន៍ផែនការសកម្មភាព ពីស្ថាប័នកណ្តាលរបស់ប្រទេស ឬស្ថាប័នកណ្តាលការិយាល័យរបស់ខ្លួននៅតាមប្រទេសទទួលជំនួយ ។

៩៦- នៅថ្នាក់ជាតិ ក្រុមការងារដើម្បីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយដែលត្រូវបានបង្កើតតាមសំណើរបស់រាជរដ្ឋាភិបាល កាលពីកិច្ចប្រជុំពិគ្រោះយោបល់លើកទី ៦ខែមិថុនា ឆ្នាំ ២០០២ បានប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួន ដោយផ្តល់ការគាំទ្រដល់ការងាររបស់ OECD/DAC ផង និងពិនិត្យមើលពីបញ្ហាសុខដុមនីយកម្ម នៅក្នុងបរិការប្រទេសកម្ពុជាផង ។ ក្រុមការងារដើម្បីភាពជាដៃគូបានធ្វើការសិក្សាពដើម្បីប្រមូលពតិមានចាំបាច់នានា សំរាប់ស្វែងរកដំណោះស្រាយលើបញ្ហាសុខដុមនីយកម្មនៅកម្ពុជា ។ ការសិក្សាទាំងនេះផ្តោតជាសំខាន់លើបញ្ហាបី គឺ÷ទី១- ការប្រតិបត្តិស្តីពីការកសាងសមត្ថភាពរបស់ដៃគូអភិវឌ្ឍន៍កម្ពុជា ។ ទី២- ការអនុវត្តន៍និងបទពិសោធន៍ដែលទទួលបានក្នុងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ និងទី៣- ការរៀបចំគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ ការសិក្សាទី១ និងទី២ ត្រូវបានបញ្ចប់ជាស្ថាពរ ។ ចំណែកសេចក្តីព្រាងការសិក្សាទីបី ក៏ត្រូវបានបញ្ចប់ផងដែរ ។ ការសិក្សាអំពីការកសាងសមត្ថភាពកំពុងត្រូវបានពិភាក្សា រវាងក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលនិងដៃគូអភិវឌ្ឍន៍របស់កម្ពុជា ដើម្បីឯកភាពគ្នាក្នុងការផ្តល់អនុសាសន៍សំរាប់រៀបចំផែនការសកម្មភាព ដើម្បីអនុវត្តអនុសាសន៍ទាំងនោះ ។

៩៧- ដើម្បីជំរុញបន្ថែមភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងវិស័យឯកជន វេទិការាជរដ្ឋាភិបាលនិងវិស័យឯកជនត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៩៩ ។ ដូចបានជំរាបខាងដើម យន្តការពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលនិងវិស័យឯកជនត្រូវបានពង្រឹងបន្តបន្ថែមទៀត តាមរយៈការបង្កើតឡើងនូវគណៈកម្មាធិការដឹកនាំការងារសំរាប់ការអភិវឌ្ឍន៍ផ្នែកឯកជន ដែលគាំទ្រដោយអនុគណៈកម្មការបី ។ គណៈកម្មាធិការដឹកនាំការងារសំរាប់

ការអភិវឌ្ឍន៍ផ្នែកឯកជន រួមជាមួយនឹងអនុគណៈកម្មការទាំងបីនេះ នឹងបំពេញភារកិច្ចរបស់ខ្លួន ដោយមានកិច្ចសហការជាមួយនឹងបណ្តាដៃគូអភិវឌ្ឍន៍ ដែលមានបំណងជួយកម្ពុជាអភិវឌ្ឍន៍វិស័យនេះ ដោយឈរលើគោលការណ៍អភិក្រមតាមវិស័យ ។

៩៨- រាជរដ្ឋាភិបាលមានជំនឿថា សង្គមស៊ីវិលមានតួនាទីយ៉ាងសំខាន់ ក្នុងការតាមដានពីវឌ្ឍនភាពនៃការអនុវត្តន៍គោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។ អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា ជាផ្នែកមួយនៃសង្គមស៊ីវិល ចំណែកឯអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិជាផ្នែកមួយនៃសង្គមស៊ីវិលអន្តរជាតិដែរ ។ អង្គការមិនមែនរដ្ឋាភិបាលអាចរួមចំណែកយ៉ាងធំធេងដល់ការកាត់បន្ថយភាពក្រីក្រ តាមរយៈបទពិសោធន៍ក្នុងកិច្ចការអភិវឌ្ឍន៍របស់ពួកគេ ។ ហេតុដូចនេះ អង្គការមិនមែនរដ្ឋាភិបាលមានតួនាទីយ៉ាងសំខាន់ក្នុងការសំដែងអំពីតំរូវការរបស់ក្រុមជនងាយរងគ្រោះអោយដល់អ្នករៀបចំគោលនយោបាយ ។ រាជរដ្ឋាភិបាលបានលើកទឹកចិត្តអោយសមាគមពាណិជ្ជករ សមាគមជនជាតិភាគតិច សមាគមកសិករ ក្នុងការចូលរួមត្រួតពិនិត្យការអនុវត្តន៍គំនិតផ្តួចផ្តើមនានាសំរាប់កាត់បន្ថយភាពក្រីក្រ ។ ដើម្បីផ្តួចផ្តើមគំនិតអោយបាន ចំទិស យើងក៏ត្រូវពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋក្រីក្រ និងក្រុមជនងាយរងគ្រោះ ចូលរួមក្នុងដំណើរការទាំងនេះ ។ ព្រមជាមួយគ្នានេះ ការពង្រឹងសមត្ថភាពរបស់សភាជាតិក្នុងដំណើរការតាមដាន ក៏ជាតំរូវការចាំបាច់ផងដែរ ។

## តំរូវការហិរញ្ញវត្ថុប្បទាន និងទិសដៅកៀងគរជំនួយអភិវឌ្ឍន៍ផ្លូវការ

៩៩- ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជាតាមរយៈការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ច គឺជាអាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាល ។ **យុទ្ធសាស្ត្រចតុកោណ** របស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទីបីនៃរដ្ឋសភាមានគោលដៅចំបង ជំរុញលើកកំពស់កំណើនសេដ្ឋកិច្ច ការដោះស្រាយការងារសំរាប់ពលករកម្ពុជា ការធានាសមធម៌ និងយុត្តិធម៌សង្គម និងការលើកស្ទួយប្រសិទ្ធភាពនៃវិស័យសាធារណៈ តាមរយៈផែនការសកម្មភាពអភិបាលកិច្ច និងកំណែទំរង់ស៊ីជំរៅនិងប្រទាក់ក្រឡាគ្នាក្នុងគ្រប់ផ្នែក- គ្រប់វិស័យ ។ **យុទ្ធសាស្ត្រចតុកោណ** ជ្រើសរើសចេញនូវសមាសធាតុសំខាន់ៗពី «គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDGs)» «ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ ឆ្នាំ ២០០១-២០០៥» ពី *«យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រឆ្នាំ ២០០៣-២០០៥»* និងពីគោលនយោបាយ យុទ្ធសាស្ត្រ ផែនការនិងកម្មវិធីកំណែទំរង់សំខាន់ៗជាច្រើនទៀត ។ យុទ្ធសាស្ត្រ និងគោលនយោបាយទាំងនេះនឹងត្រូវសំរេចអោយបាន តាមរយៈការអនុវត្តន៍កម្មវិធីវិនិយោគសាធារណៈអាទិភាព (PIP) ដែលជាឧបករណ៍មួយក្នុងការអនុវត្តន៍អោយបានសំរេចនូវយុទ្ធសាស្ត្រ និងគោលនយោបាយទាំងនេះ ។ កម្មវិធីវិនិយោគសាធារណៈត្រូវបានរៀបចំសំរាប់រយៈពេល៣ឆ្នាំ ដើម្បីឆ្លុះបញ្ចាំងអំពីតំរូវការជាអាទិភាពជាក់ស្តែង ។ បណ្តាកម្មវិធីនិងគំរោងនៃកម្មវិធីវិនិយោគសាធារណៈនឹងទទួលការគាំទ្រហិរញ្ញប្បទានពីថវិការដ្ឋ និងពីដៃគូអភិវឌ្ឍន៍របស់កម្ពុជា ។ កម្មវិធីវិនិយោគសាធារណៈនេះរួមមានបណ្តាកម្មវិធីនិងគំរោងអាទិភាពរបស់រាជរដ្ឋាភិបាល ដែលកំពុងអនុវត្ត និង/ឬដែលនឹងត្រូវអនុវត្តនៅតាម

វិស័យនិមួយៗ ព្រមទាំងជាប្រភពពត៌មានដ៏សំខាន់ សំរាប់វិភាជន៍ថវិការដ្ឋ ក៏ដូចជាសំរាប់កៀងគរជំនួយពីដៃគូអភិវឌ្ឍន៍របស់កម្ពុជា ។

១០០- បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកំពុងអនុវត្តនូវវិធានការនានា សំដៅពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ ។ លទ្ធផលជាក់ស្តែងដែលបានមកពីការចរចាកំណត់ពេលសងបំណុល ដែលកម្ពុជាបានខ្ចីពីសហរដ្ឋអាមេរិក និងសហភាពរុស្ស៊ីកាលពីទសវត្សរ៍ទី ៧០ និង៨០ នឹងបង្កើនបន្ទុកការប្រាក់បំណុលមកលើការគ្រប់គ្រងចំណូលក្នុងស្រុករបស់រាជរដ្ឋាភិបាល ។ ដើម្បីលើកកំពស់ប្រសិទ្ធភាពនៃជំនួយអភិវឌ្ឍន៍ផ្លូវការ និងកាត់បន្ថយបន្ទុកដល់ប្រជាពលរដ្ឋស្រុករក្រោយៗទៀត រាជរដ្ឋាភិបាលសូមស្នើអោយបណ្តាដៃគូអភិវឌ្ឍន៍របស់កម្ពុជាពិចារណាពីលទ្ធភាពផ្តល់ជំនួយឥតសំណងដើម្បីអភិវឌ្ឍវិស័យសង្គមកិច្ច ដោយរួមទាំងវិស័យសុខាភិបាល និងអប់រំ ការអភិវឌ្ឍន៍ធនធានមនុស្ស និងបច្ចេកវិទ្យាពត៌មាន ។ រាជរដ្ឋាភិបាលនឹងដាក់ក៏រិតការប្រើប្រាស់កំចីសម្បទាន សំរាប់សកម្មភាពអភិវឌ្ឍន៍ណាដែលអាចផ្តល់លទ្ធផលសេដ្ឋកិច្ចមកវិញភ្លាមៗ សំរាប់សង ការប្រាក់ និងកាតព្វកិច្ចបំណុល ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងមិនលើកទឹកចិត្តដល់ការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍ទាំងឡាយណា ដែលប្រើប្រាស់ហិរញ្ញប្បទានជាកំចីគ្មានលក្ខណៈសម្បទានឡើយ ។

១០១- ក្នុងបណ្តាឆ្នាំកន្លងមក ដៃគូអភិវឌ្ឍន៍បរទេសបានគាំទ្រដល់កម្មវិធីវិនិយោគសាធារណៈនេះ ។ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ទាំង៦លើកកន្លងមក រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងកៀងគរជំនួយបរទេស ប្រមាណ ៥០០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ សំរាប់អនុវត្តគំរោងកំពុងដំណើរការនិងគំរោងថ្មីៗ ។ ដោយសារការងារអាទិភាពដែលស្នើឡើងដោយបណ្តាក្រសួងនានា មានចំនួនច្រើនសន្ធឹកសន្ធាប់ រាជរដ្ឋាភិបាលជួបប្រទះនឹងការលំបាកក្នុងការក៏រិតតំរូវការហិរញ្ញប្បទានរបស់ខ្លួនអោយស្ថិតក្នុងក៏រិតដូចមុនៗបានឡើយ ។ តំរូវការហិរញ្ញប្បទានសរុបសំរាប់អនុវត្តកម្មវិធីកំពុងដំណើរការ និងកម្មវិធីថ្មី ក្នុងរយៈពេល៣ឆ្នាំ២០០៥-២០០៧ មានប្រមាណ១.៩៣៧,៦លានដុល្លារអាមេរិក ។ រាជរដ្ឋាភិបាលបានប្តេជ្ញាផ្តល់ប្រភពធនធានផ្ទាល់ចំនួន ២៩០,៤លានដុល្លារអាមេរិក សំរាប់កម្មវិធីអភិវឌ្ឍន៍ទាំងនេះ ។ ទន្ទឹមនេះ យើងក៏ត្រូវការហិរញ្ញប្បទានចំនួន ១៥០លានដុល្លារអាមេរិក សំរាប់ទ្រទ្រង់ថវិកា និងចំនួន៦៦លានដុល្លារអាមេរិកទៀត សំរាប់ទ្រទ្រង់ជញ្ជីងទូទាត់ផងដែរ ។ ដូចនេះ **តំរូវការជំនួយហិរញ្ញប្បទានសរុបមានចំនួន ១.៨៦៣,២លានដុល្លារអាមេរិក** ពី ដៃគូអភិវឌ្ឍន៍ សំរាប់រយៈពេល៣ឆ្នាំខាងមុខ ពោលគឺ ៦២១,១លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ។ ដៃគូអភិវឌ្ឍន៍មួយចំនួនបានសន្យាផ្តល់ហិរញ្ញប្បទានរួចហើយ ចំនួន១.០៦២,៦លានដុល្លារអាមេរិក សំរាប់អនុវត្តកម្មវិធីអាទិភាពទាំងនេះ ។ ដូចនេះ **រាជរដ្ឋាភិបាលត្រូវស្វះស្វែងរកការគាំទ្របន្ថែមទៀតចំនួន ៨០០,៦ លានដុល្លារអាមេរិក ពីដៃគូអភិវឌ្ឍន៍របស់ខ្លួន** ។

## ជំពូកទី១
## សេចក្តីផ្តើម

១- ក្នុងរយៈពេលជាច្រើនទសវត្សរ៍កន្លងមក កម្ពុជាបានចំណាយពេលវេលា និងបានខិតខំប្រឹងប្រែងយ៉ាងពេញទំហឹង ដើម្បីស្តារ និងកសាងប្រទេសឡើងវិញ ពីការបំផ្លិចបំផ្លាញនៃរបបប្រល័យពូជសាសន៍ និងសង្គ្រាមរ៉ាំរ៉ៃ ទម្រាំសម្រេចបាននូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម លទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធមនុស្ស និងស្ថិរភាពសេដ្ឋកិច្ចរឹងមាំ ចាប់ពីឆ្នាំ១៩៩៩មក ។ កន្លងមក យើងបានអនុវត្តកម្មវិធីកំណែទំរង់គ្រប់វិស័យ ដោយបានឆ្លងកាត់ការលំបាក និងឧបសគ្គធំតូចច្រើនរាប់មិនអស់ ។ យើងបន្តសំរេចបាននូវវឌ្ឍនភាពក្នុងការឆ្លងកាត់អន្តរកាលពីសេដ្ឋកិច្ចបែបផែនការចាប់ពីទសវត្សរ៍ឆ្នាំទី៨០ មកបង្កើតបាននូវប្រព័ន្ធសេដ្ឋកិច្ចទីផ្សារដ៏រស់រវើក ព្រមទាំងបង្កើតបានលក្ខខ័ណ្ឌល្អប្រសើរ សំរាប់ស្តារនិងអភិវឌ្ឍប្រទេសនៅលើគ្រប់វិស័យ សំដៅដឹកនាំកម្ពុជាលើមាគ៌ាដ៏វែងមួយ ឈានទៅសំរេចគោលដៅក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។

២- តាមការអនុវត្តន៍យ៉ាងប្តូរផ្តាច់ឥតរាថយនូវ *«យុទ្ធសាស្ត្រត្រីកោណ»* រាជរដ្ឋាភិបាលសំរាប់នីតិកាលទី២ នៃរដ្ឋសភាកន្លងមកនេះ បានបង្កើតឡើងនូវបរិស្ថានអនុគ្រោះ និងលក្ខខ័ណ្ឌចាំបាច់ និងគ្រប់គ្រាន់ ទាំងក្នុង និងក្រៅប្រទេស សំរាប់អោយកម្ពុជាអាចបោះជំហានទៅមុខប្រកបដោយក្តីសង្ឃឹម និងជំនឿទុកចិត្តយ៉ាងមុតមាំនៅលើមាគ៌ានៃកំណែទំរង់ និងការអភិវឌ្ឍន៍ ។ ជោគជ័យនៃការអនុវត្តន៍យុទ្ធសាស្ត្រនេះ បានធ្វើអោយកម្ពុជាឆ្លងកាត់ដំណាក់កាលប្រែប្រួលយ៉ាងធំធេង ពីចំណុចមួយនៃផែនទីពិភពលោក ដែលប្រកបដោយភាពមិនច្បាស់លាស់ ដោយសារកលយុគសង្គ្រាម ជម្លោះផ្ទៃក្នុង អស្ថិរភាព និងភាពអន់ថយ ហើយក្លាយទៅជាប្រទេសមួយដែលមានសុខសន្តិភាពពេញលេញ មានសុវត្ថិភាពនិងសណ្តាប់ធ្នាប់សង្គម មានការគោរពលទ្ធិប្រជាធិបតេយ្យ គោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងមានកិច្ចសហប្រតិបត្តិការនិងការអភិវឌ្ឍន៍ ។ ឆ្លងកាត់រយៈពេលដ៏ខ្លីបំផុត ប្រសិនបើប្រៀបធៀបទៅនឹងប្រវត្តិសាស្ត្រនៃប្រទេសជឿនលឿននានា រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញដោយគ្មានការសង្ស័យថា កម្ពុជាពិតជាមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីចូលប្រឡូកដោយស្មើភាព និងស្មើសិទ្ធិក្នុងកិច្ចការតំបន់ និងពិភពលោក ។ ប្រការទាំងនេះបានប្រែក្លាយទៅជាការកើនឡើងនៃជំនឿទុកចិត្តមកលើប្រទេសកម្ពុជា ហើយផ្តល់ជាផលប្រយោជន៍មកវិញ តាមរយៈការកើនឡើងនៃពាណិជ្ជកម្ម និងលំហូរនៃការវិនិយោគ និងភ្ញៀវទេសចរចូលមកក្នុងប្រទេសកម្ពុជា ដែលជាកត្តាយ៉ាងសំខាន់សំរាប់ជួយបង្កើតការងារ និងបង្កើនចំណូលដល់ពលករកម្ពុជា ។

៣- ចំពោះវឌ្ឍនភាពដ៏គួរអោយកត់សំគាល់ក្នុងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច រយៈពេល៥ឆ្នាំកន្លងមកនេះ រួមមាន÷ ការអនុវត្តន៍បណ្តាគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមដោយផ្តោតទៅលើអ្នកក្រីក្រ ការរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច កំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ការបន្តអនុវត្តលទ្ធិប្រជាធិបតេយ្យ ពង្រឹងនីតិរដ្ឋ និងអភិបាលកិច្ចល្អ ការកែលំអការផ្តល់សេវាសាធារណៈ ដើម្បីឆ្លើយតបទៅនឹងតំរូវការនិងសំណូមពររបស់

ប្រជាជន ។ កិច្ចប្រឹងប្រែងទាំងអស់នេះត្រូវបានអនុវត្ត ក្នុងគោលដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងដើម្បីឈានទៅសំរេចគោលដៅអភិវឌ្ឍន៍របស់កម្ពុជា ។ ទោះបីមានការខិតខំប្រឹងប្រែង ហើយទទួលជោគជ័យក្នុងជំហានដំបូងយ៉ាងណាក្តី ក៏រាជរដ្ឋាភិបាលមិនអាចជៀសផុតពីការខ្វះខាតបានឡើយ ។ ជាក់ស្តែងរចនាសម្ព័ន្ធផលិតកម្មរបស់ជាតិយើងដែលនៅមានទំហំតូច ហើយច្រើនប្រមូលផ្តុំនៅតាមតំបន់មួយចំនួនត្រូវតែពង្រីក និងធ្វើពិពិធកម្ម ដើម្បីធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ។ ទោះបីជាយើងបានអនុវត្តយន្តការ និងនីតិវិធីមួយចំនួនសំរាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈចាប់ពីឆ្នាំ១៩៩៤ ដើម្បីបង្កើនចំណូលរដ្ឋក៏ដោយ ក៏យន្តការនិងទំរង់ការមួយចំនួននៅពុំទាន់ចាប់ដំណើរការអោយបានពេញលេញនៅឡើយ ព្រោះការប្រើឥទ្ធិពលមិនស្របគ្នាបានប៉ះពាល់យ៉ាងខ្លាំងដល់ទិសដៅបង្កើនចំណូល និងកែលំអរវិភាជន៍ចំណាយសាធារណៈ ។ ក្រសួងជំនាញមួយចំនួននៅពុំទាន់មានយន្តការទំនាក់ទំនង និងសំរបសំរួលនៅឡើយ ។ ទន្ទឹមនេះដើម្បីពង្រឹងនីតិរដ្ឋ រាជរដ្ឋាភិបាលកំពុងរៀបចំសេចក្តីព្រាងច្បាប់ថ្មីៗ ហើយកំពុងរង់ចាំការផ្តល់ សច្ចាប័នពីស្ថាប័ននីតិបញ្ញត្តិ ។ លើសពីនេះ ការរៀបចំ និងកែទំរង់ឡើងវិញនូវបរិធានតុលាការមួយអោយ រឹងមាំគឺជាការចាំបាច់ ។ ចំពោះការផ្តល់ជំនួយអន្តរជាតិ ទោះបីអ្នកផ្តល់ជំនួយភាគច្រើនបានផ្តល់ជំនួយ យ៉ាងថ្លៃថ្លាដែលមានខ្លះជាលក្ខណៈមនុស្សធម៌ក្តី ក៏នៅមានប្រទេសផ្តល់ជំនួយមួយចំនួនបានភ្ជាប់ការផ្តល់ជំនួយទៅនឹងលក្ខខ័ណ្ឌខ្លះៗ មិនសមហេតុសមផល ទាំងទិដ្ឋភាពបច្ចេកទេស ទាំងទិដ្ឋភាពនយោបាយ ។ សរុបមក ទន្ទឹមនឹងសមិទ្ធផលដែលសំរេចបានកន្លងមក រាជរដ្ឋាភិបាលសំរាប់នីតិកាលទី៣នៃរដ្ឋសភាមានភារកិច្ចដោះស្រាយបណ្តាបញ្ហាប្រឈមជាច្រើន ។

៤- សំរាប់រយៈពេលវែងខាងមុខ បញ្ហាប្រឈមចំបងបំផុតចំពោះកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីអភិវឌ្ឍគឺការកាត់បន្ថយភាពក្រីក្រ និងការធ្វើអោយប្រសើរឡើងនូវគុណភាពនៃជីវភាពរស់នៅរបស់ប្រជាជនដែលមានកំណើនខ្ពស់ ។ រាជរដ្ឋាភិបាលយល់ច្បាស់ និងបានចាត់ទុកភាពក្រីក្រថាជាការខាតបង់ខាងសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ និងជាការដែលមិនអាចទទួលយកបានខាងសីលធម៌ ដែលអាចនាំទៅដល់ការបែកបាក់សង្គមជាតិ ។ ដើម្បីសំរេចគោលដៅកាត់បន្ថយភាពក្រីក្រដែលបានដាក់ចេញ រាជរដ្ឋាភិបាលបានប្រកាសយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ដែលមានគោលដៅជាចំបងដូចខាងក្រោម ÷

- ទី១- ការពង្រឹងសន្តិភាព សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម តាមរយៈវិធានការជាក់ស្តែងនានាសំដៅលើកស្ទួយនីតិរដ្ឋ ការពារសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ដើម្បីបង្កើតឡើងនូវបរិស្ថាននយោបាយ និងសន្តិសុខ ដែលអនុគ្រោះសំរាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងរយៈពេលវែង ។
- ទី២- ការធានាអោយបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ក្នុងរយៈពេលវែង ក្នុងអត្រាខ្ពស់ ពី ៦ ទៅ ៧% ក្នុងមួយឆ្នាំ ។
- ទី៣- ការបែងចែកផ្លែផ្កានៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ រវាងអ្នកមាន និងអ្នកគ្មាន រវាងទីក្រុង និងជនបទ និងរវាងស្ត្រីនិងបុរស ។
- ទី៤- ការធានាការគ្រប់គ្រង និងប្រើប្រាស់ប្រកបដោយចីរភាព បរិស្ថាននិងធនធានធម្មជាតិ ។

៥- ការបោះឆ្នោតនាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣ កន្លងមក ត្រូវបានបណ្តាអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ទទួលស្គាល់ថា ជាការបោះឆ្នោតមួយសេរី យុត្តិធម៌និងត្រឹមត្រូវ មានតំលាភាព និងអាចទទួលយកបាន ហើយរដ្ឋសភានិងរាជរដ្ឋាភិបាលថ្មីត្រូវបានប្រសូតឡើង ស្របតាមឆន្ទៈរបស់ប្រជាជន ។ រាជរដ្ឋាភិបាលកម្ពុជាបានឈានចូលកាន់អំណាចក្នុងនីតិកាលទី៣នៃរដ្ឋសភា ស្របទៅតាមឆន្ទៈរបស់ប្រជារាស្ត្រ ជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងពេញទំហឹង ដើម្បីបំរើនូវឧត្តមប្រយោជន៍របស់ប្រទេសជាតិមាតុភូមិ និងឆ្លើយតបទៅនឹងសំណូមពរ និងសេចក្តីត្រូវការទាំងឡាយរបស់ប្រជាពលរដ្ឋកម្ពុជា ដែលរាជរដ្ឋាភិបាលបានទទួលតាមរយៈសម្លេងឆ្នោតផ្តល់ការទុកចិត្តនៅក្នុងកិច្ចដំណើរការបោះឆ្នោតប្រជាធិបតេយ្យ ដោយសេរី និងយុត្តិធម៌ ។ បន្ទាប់ពីឡើងកាន់កាប់ការងារភ្លាមមក រាជរដ្ឋាភិបាលបានរៀបចំ «**យុទ្ធសាស្ត្រចតុកោណ**» **ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា** ដែលនឹងដើរតួជាឧបករណ៍ដ៏សំខាន់សំរាប់ទ្រទ្រង់ការអនុវត្តន៍ «**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នៃរដ្ឋសភា**» ។ **សម្តេច ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានឧទ្ទេសនាម «**យុទ្ធសាស្ត្រចតុកោណ**» នេះ នៅក្នុងឱកាសបើក កិច្ចប្រជុំលើកទី១របស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០០៤ ។

៦- «***យុទ្ធសាស្ត្រចតុកោណ***» នេះ គឺជារបៀបវារៈសេដ្ឋកិច្ច ដែលជាការបន្តសកម្មភាព និងការបន្តពង្រឹងនូវសមិទ្ធផលនានា ដែលរាជរដ្ឋាភិបាលកម្ពុជាសំរេចបានក្នុងនីតិកាលទី ២ តាមរយៈការអនុវត្តន៍ **យុទ្ធសាស្ត្រត្រីកោណ** និងការជ្រើសរើសចេញនូវសមាសធាតុសំខាន់ៗពី *«គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs)»* *«ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ ឆ្នាំ ២០០១-២០០៥»* របស់កម្ពុជាបច្ចុប្បន្ន ពី *«យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រឆ្នាំ ២០០៣-២០០៥»* និងពីគោលនយោបាយ យុទ្ធសាស្ត្រ ផែនការនិងកម្មវិធីកំណែទំរង់សំខាន់ៗជាច្រើនទៀត ។ គោលដៅចំបងនៃរបៀបវារៈសេដ្ឋកិច្ច គឺការកែលំអ និងការបង្កើនសមត្ថភាពរបស់ស្ថាប័នសាធារណៈ លើកស្ទួយអភិបាលកិច្ចល្អ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិ ដើម្បីគោលដៅជំរុញលើកកំពស់កំណើនសេដ្ឋកិច្ច បង្កើតការងារជូនប្រជាពលរដ្ឋ ធានាសមធម៌ក្នុងសង្គម និងបង្កើនប្រសិទ្ធភាពនៃវិស័យសាធារណៈ ព្រមទាំងរក្សាការពារសម្បត្តិធម្មជាតិ និងសម្បត្តិវប្បធម៌ជាតិ ។ យុទ្ធសាស្ត្រចតុកោណគឺជាឧបករណ៍សំរាប់ទ្រទ្រង់ការអនុវត្តន៍ «**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី៣ នៃរដ្ឋសភា**» ដែលបានឯកភាពមតិជាឯកឆន្ទៈរវាងគណបក្សដៃគូទាំងពីរក្នុងរាជរដ្ឋាភិបាល ។

៧- រាជរដ្ឋាភិបាលទទួលស្គាល់ថា កម្ពុជានៅមានផ្លូវដ៏វែងអន្លាយសំរាប់ធ្វើដំណើរទៅមុខ ហើយត្រូវពុះពារឆ្លងកាត់ឧបសគ្គរាប់មិនអស់ថែមទៀត ដើម្បីសំរេចបាននូវវឌ្ឍនភាពប្រកបដោយចីរភាព និងវិបុលភាពដ៏រុងរឿងថ្កើងថ្កានជូនប្រទេសជាតិ និងប្រជាជន ។ ក្នុងន័យនេះ ការខិតខំដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនតាមកិច្ចប្រឹងប្រែងប្រកបដោយសុខដុមនីយកម្ម នៅតែជាគោលដៅដ៏ចំបងបំផុតរបស់រាជរដ្ឋាភិបាលនីតិកាលទី៣នៃរដ្ឋសភា ។ ពិតណាស់ រាជរដ្ឋាភិបាលទទួលស្គាល់ថា គ្រប់បញ្ហានៃភាពក្រីក្រ ពុំអាចនឹងត្រូវបានដោះស្រាយរួចស្រេចបាច់អស់ ក្នុងរយៈពេលតែមួយថ្ងៃ ឬមួយខែ ឬមួយឆ្នាំនោះឡើយ ។ ក៏ប៉ុន្តែ

ដោយមានកម្មវិធីច្បាស់លាស់ និងដោយមានការខិតខំប្រឹងប្រែងរួមគ្នាយ៉ាងឥតសំចៃពីបណ្តាភាគីពាក់ព័ន្ធ រាជរដ្ឋាភិបាលប្រាកដជាអាចធ្វើអោយមានការផ្លាស់ប្តូរជាវិជ្ជមានយ៉ាងច្រើន ក្នុងការលើកស្ទួយកំរិតជីវភាព របស់ប្រជាជនក្នុងរយៈពេល៤ឆ្នាំខាងមុខ ។ តាមរយៈការអនុវត្តន៍នូវយុទ្ធសាស្ត្រចតុកោណ រាជរដ្ឋាភិបាល នឹងបន្តជំរុញអនុវត្តយ៉ាងម៉ឺងម៉ាត់ និងមធ្យ័តបំផុត នូវកម្មវិធីកំណែទំរង់ទាំងឡាយ ដែលមានលក្ខណៈកាន់ តែទូលំទូលាយ និងកាន់តែស៊ីជំរៅឡើង ពីព្រោះកំណែទំរង់គឺជាកិច្ចការស្លាប់រស់របស់កម្ពុជា ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលអាចកំណត់បាវចនានៃការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលនីតិកាលទី៣នៃរដ្ឋសភានេះ ថាជា **«រាជរដ្ឋាភិបាលដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព»** ។

៨- ឯកសារជំហរនេះគឺជាលទ្ធផលនៃកិច្ចដំណើរការមួយយ៉ាងវែងនៃកិច្ចពិគ្រោះយោបល់ និងការសំរបសំរួល អន្តរក្រសួងជាច្រើនលើកច្រើនសារ ចាប់ពីខែមេសាដល់ខែវិច្ឆិកា ឆ្នាំ២០០៤ ។ បន្ថែមលើការវិភាគ និងសំណើ ដែលបានវែកញែកក្នុងឯកសារជំហរនេះ ក្រសួងនិងស្ថាប័នពាក់ព័ន្ធបានរៀបចំឯកសារដោយឡែកបន្ថែមទៀត ផងដែរ ។ ឯកសារជំហរនេះបានបង្ហាញអំពីបណ្តាអាទិភាពនិងប្រភពធនធាន ដែលរាជរដ្ឋាភិបាលនឹងប្តេជ្ញា សំរាប់រយៈពេលខ្លី និងរយៈពេលមធ្យមដើម្បីអនុវត្តអោយបានសំរេចដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលនឹងបំពេញកាតព្វកិច្ច និងបុរេលក្ខខ័ណ្ឌទាំងឡាយសំរាប់កំណែទំរង់ ដើម្បី ជំនះអោយបាននូវបញ្ហាប្រឈមនាពេលអនាគត ។

៩- ឯកសារជំហរនេះនឹងបង្ហាញអំពីបណ្តាសមិទ្ធផលដែលរាជរដ្ឋាភិបាលសំរេចបាន បន្ទាប់ពីកិច្ចប្រជុំពិគ្រោះ យោបល់ នៅរាជធានីភ្នំពេញ នាខែមិថុនា ឆ្នាំ២០០២ កន្លងមក ។ ឯកសារនេះបានផ្តល់ពត៌មានដែលមាន លក្ខណៈបច្ចុប្បន្នភាពស្តីពីលទ្ធផលនៃការអនុវត្តន៍គោលនយោបាយ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច រូបិយវត្ថុ និង សារពើពន្ធ និងការអភិវឌ្ឍន៍តាមវិស័យ ។ ជំពូកបន្ទាប់នៃឯកសារជំហរនេះនឹងបង្ហាញអំពីពត៌មានសំខាន់ៗ ស្តីពីយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។ ជំពូកទី៤ នឹងលើកអំពីវិធានការលំអិតជាក់ស្តែងមួយចំនួន ដែលត្រូវអនុវត្តតាមការដ្ឋានកំណែទំរង់នីមួយៗ ដើម្បីសំរេចគោលដៅនៃយុទ្ធសាស្ត្រនេះ ។ នៅជំពូកចុង ក្រោយ ឯកសារនេះនឹងបញ្ជាក់អំពីតំរូវការជំនួយបរទេស សំរាប់បំពេញបន្ថែមលើប្រភពធនធានក្នុងប្រទេស ដែលកម្ពុជាត្រូវការសំរាប់គាំទ្រដល់ការអនុវត្តន៍គំរោងវិនិយោគ និងគំនិតផ្តួចផ្តើមថ្មីៗរបស់រាជរដ្ឋាភិបាល និងសេចក្តីសន្និដ្ឋាន ។

១០- រាជរដ្ឋាភិបាលសូមបញ្ជាក់ជូនសហគមន៍អ្នកផ្តល់ជំនួយថា ប្រសិនបើគ្មានជំនួយទាំងនេះទេ កម្ពុជាមិនអាច សំរេចកំរិតរីកចំរើន និងសមិទ្ធផលទាំងនេះបានឡើយ ហើយប្រាកដជាមិនអាចជំនះរាល់ការលំបាកទាំងឡាយ ដែលកម្ពុជាបានជួបប្រទះក្នុងពេលអនុវត្តកម្មវិធីកំណែទំរង់នានាក្នុងបណ្តាឆ្នាំខាងមុខឡើយ ។

## ជំពូកទី២

## សមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាលចាប់ពី កិច្ចប្រជុំពិគ្រោះយោបល់លើកទី៦ ខែមិថុនា ឆ្នាំ២០០២

> **សមិទ្ធផលសំខាន់ៗ**
>
> ២.១- ការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល
> ២.២- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច
> ២.៣- ស្ថានភាពរូបិយវត្ថុ និងសារពើពន្ធ
> ២.៤- ការអភិវឌ្ឍន៍តាមវិស័យ
> ២.៥- កម្មវិធីអន្តរវិស័យ

១១- ចាប់តាំងពីកិច្ចប្រជុំពិគ្រោះយោបល់លើកទី៦ ដែលបានប្រារព្ធជាលើកទី១ នៅរាជធានីភ្នំពេញ នាខែមិថុនា ឆ្នាំ ២០០២កន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងច្រើន សំដៅឈានទៅសំរេចអោយបាននូវគោលដៅជាយុទ្ធសាស្ត្រនានា ដែលមានចែងនៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ របស់កម្ពុជា ។ រាជរដ្ឋាភិបាលបានប្តេជ្ញាយកអស់កំលាំងកាយចិត្ត អនុវត្តតាមអនុសាសន៍ដ៏មានសារៈប្រយោជន៍របស់ដៃគូអភិវឌ្ឍន៍របស់កម្ពុជា ដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកមុន ។ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រត្រូវបានរៀបចំ និងប្រកាសអោយអនុវត្តនាខែមិនា ឆ្នាំ២០០៣ កំណែទំរង់ក្នុងវិស័យសារពើពន្ធ និងធនាគារត្រូវបានអនុវត្តកាន់តែស៊ីជំរៅ យុទ្ធសាស្ត្រស្តីពីកំណែទំរង់រដ្ឋបាលសាធារណៈត្រូវបានរៀបចំបញ្ចប់ និងកំពុងដាក់អោយអនុវត្ត យន្តការបែងចែកអំណាចដល់ថ្នាក់មូលដ្ឋានឃុំ- សង្កាត់ តាមរយៈការបោះឆ្នោតក្រុមប្រឹក្សាឃុំ- សង្កាត់ ក្នុងឆ្នាំ២០០២ កំពុងតែដំណើរការ និងពង្រឹងបន្ថែម យុទ្ធសាស្ត្រស្តីពីកំណែទំរង់ច្បាប់ និងតុលាការត្រូវបានរៀបចំ និងអនុវត្ត ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាពត្រូវបានពង្រឹងបន្ថែមតាមរយៈការអនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រងដីធ្លី ច្បាប់ព្រៃឈើ និងច្បាប់ស្តីពីសហគមន៍ព្រៃឈើ និងការបង្កើនលទ្ធភាពរបស់ជនក្រីក្រក្នុងការនេសាទ អនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈត្រូវបានពង្រីកគ្របដណ្តប់លើចំណាយគ្រប់ក្រសួងនិងស្ថាប័នទាំងអស់ លើកលែងតែក្រសួងព្រះបរមរាជវាំង ។ ច្បាប់វិនិយោគត្រូវបានធ្វើវិសោធនកម្មបន្ថែម ហើយអាជ្ញាធរសវនកម្មជាតិបានចាប់ដំណើរការ ។ ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុសំរាប់រយៈពេល១០ឆ្នាំ២០០១- ២០១០ត្រូវបានអនុម័ត និងកំពុងអនុវត្ត ។ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម៥ឆ្នាំ២០០១- ២០០៥ ត្រូវបានរៀបចំ និងដាក់អោយអនុវត្ត ។

១២- នៅក្នុងនីតិកាលទី២ របស់រាជរដ្ឋាភិបាល ឆ្នាំ១៩៩៨- ២០០៣ ប្រទេសកម្ពុជាបានទទួលនូវសុខសន្តិភាព និងសុវត្ថិភាព ដែលពុំធ្លាប់មានក្នុងរយៈពេលកន្លងមក ។ សមិទ្ធផលដ៏ធំធេងមួយនៅក្នុងរយៈពេលនោះ គឺការបោះឆ្នោតឃុំ- សង្កាត់ ដែលជាជំហានថ្មីមួយទៀតសំរាប់ពង្រឹងលទ្ធិប្រជាធិបតេយ្យ និងបានបង្ហាញអោយឃើញផងដែរអំពីការប្តេជ្ញាចិត្តយ៉ាងម៉ោះមុត ក្នុងការអនុវត្តន៍ស៊ីជំរៅនូវកិច្ចដំណើរការកំណែទំរង់ ក្នុងគ្រប់វិស័យនៅកម្ពុជា ។ ក្រុមប្រឹក្សាឃុំ- សង្កាត់ថ្មីដែលត្រូវបានបង្កើតនេះ គឺជាការផ្តល់អំណាចដល់សហគមន៍មូលដ្ឋាន ដែលជាសមាសភាគដ៏សំខាន់មួយនៃអភិបាលកិច្ចនៅតាមមូលដ្ឋាន ។ ការប្រគល់អំណាច និងការផ្ទេរប្រភពធនធានដល់សហគមន៍មូលដ្ឋាន គឺជាដំណើរការប្រែប្រួលមួយដ៏សំខាន់សំរាប់ប្រជាជនកម្ពុជា ។

ដំណើរការនេះនឹងមិនត្រឹមតែបញ្ចេញនូវថាមពលដ៏ខ្លាំងក្លានៃការអនុវត្តន៍វិមជ្ឈការខាងហិរញ្ញវត្ថុ និងជំរុញយ៉ាងខ្លាំងក្លានូវការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅតាមមូលដ្ឋានប៉ុណ្ណោះទេ ក៏ប៉ុន្តែវានឹងជួយពង្រឹងមូលធនសង្គមនៅតាមសហគមន៍មូលដ្ឋានទៀតផង ។ លើសពីនេះ វាជួយពង្រឹងបន្ថែមទៀតនូវស្ថិរភាពនយោបាយ និងសន្តិសុខ ដែលសុទ្ធតែជាប្រការមានសារៈសំខាន់បំផុត សំរាប់ការបោះជំហានទៅមុខរបស់កម្ពុជាឆ្ពោះទៅកាន់ការលើកកំពស់កំរិតជីវភាពរបស់ប្រជាជន ការគោរពសិទ្ធិមនុស្ស និងការសំរេចអោយបាននូវការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។

១៣- សមិទ្ធផលមួយទៀតក្នុងការពង្រឹងបរិស្ថានសន្តិភាព និងសន្តិសុខរបស់ប្រទេស គឺជោគជ័យនៃការបោះឆ្នោតសកលប្រកបដោយសេរី និងយុត្តិធម៌ នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣ កន្លងមក ព្រមទាំងការបញ្ចប់ដោយជោគជ័យក្នុងការចរចាបង្កើតរាជរដ្ឋាភិបាលថ្មី ។ ដំណើរការបោះឆ្នោតទាំងពីរលើកនេះនៅក្នុងរយៈពេល ៥ឆ្នាំកន្លងមក បានពង្រឹងបន្ថែមនូវប្រពៃណីលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។

## ២.១- លទ្ធផលការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល

១៤- នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ នាខែមិថុនា ឆ្នាំ២០០២ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បានឯកភាពកំណត់វិស័យអាទិភាពមួយចំនួន ភ្ជាប់ជាមួយនឹងលក្ខខ័ណ្ឌវិនិច្ឆ័យសំរាប់ការត្រួតពិនិត្យរួមគ្នា ។ កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកន្លងមក បានស្តែងចេញជាវឌ្ឍនភាព គួរអោយកត់សំគាល់នៅក្នុងវិស័យជាច្រើន ។ គួរកត់សំគាល់ដែរថា បន្ទាប់ពីការបោះឆ្នោតសកលនាខែកក្កដា ឆ្នាំ២០០៣មកការពន្យារពេលក្នុងការបង្កើតរាជរដ្ឋាភិបាល រួមជាមួយនិងភាពមិនប្រាកដប្រជាមួយចំនួន បាននាំអោយមានការយឺតយ៉ាវជាបណ្តោះអាសន្ន ក្នុងការបន្តពង្រឹងចលនការ ដែលបានបង្កើតឡើងក្នុងរាជរដ្ឋាភិបាលសំរាប់នីតិកាលទី២ នៃរដ្ឋសភា ។ បន្ទាប់ពីការបង្កើតរាជរដ្ឋាភិបាលសំរាប់នីតិកាលទី៣ នៃរដ្ឋសភា នាខែកក្កដា ឆ្នាំ២០០៤រួចមក រាជរដ្ឋាភិបាលនៅតែបន្តអនុវត្តការប្តេជ្ញាយ៉ាងហ្មត់ចត់ ក្នុងការដ្ឋានកំណែទំរង់របស់ខ្លួន ។ ខាងក្រោមនេះ គឺជាការសង្ខេបអំពីវឌ្ឍនភាពតាមវិស័យអាទិភាព ចាប់ពីកិច្ចប្រជុំពិគ្រោះយោបល់ខែមិថុនា ឆ្នាំ២០០២ ទោះបីរាជរដ្ឋាភិបាលត្រូវជួបប្រទះបញ្ហាប្រឈមជាច្រើនក៏ដោយ ។

| **ការអនុវត្តន៍គោលនយោបាយ** |
|---|
| - កំណែទំរង់ច្បាប់ និងតុលាការ និងអភិបាលកិច្ច |
| - ការគ្រប់គ្រងធនធានធម្មជាតិ |
| -វិស័យសង្គមកិច្ច |
| - ការគ្រប់គ្រងហិរញ្ញវត្ថុ និងកំណែទំរង់រដ្ឋបាលសាធារណៈ |

### ២.១.១ កំណែទំរង់ច្បាប់ និងតុលាការ និងអភិបាលកិច្ច

#### កំណែទំរង់ច្បាប់ និងតុលាការ

១៥- នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ខែមិថុនា ឆ្នាំ២០០២ លក្ខខ័ណ្ឌវិនិច្ឆ័យមួយចំនួនត្រូវបានកំណត់ដូចតទៅ÷

ទី១- កាលបរិច្ឆេទច្បាស់លាស់ក្នុងការរៀបចំបញ្ចប់ យុទ្ធសាស្ត្រស្តីពីកំណែទំរង់ច្បាប់និងតុលាការ ។

ទី២-ការកែសំរួលរចនាសម្ព័ន្ធនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ទី៣-ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម ។

១៦- **កាលបរិច្ឆេទច្បាស់លាស់ក្នុងការរៀបចំបញ្ចប់យុទ្ធសាស្ត្រស្តីពីកំណែទំរង់ច្បាប់និងតុលាការ** ៖ រាជរដ្ឋាភិបាលបានអនុវត្តប្រកបដោយវឌ្ឍនភាពមួយចំនួនគួរអោយកត់សំគាល់ ក្នុងកំណែទំរង់វិស័យច្បាប់ និងតុលាការ ។ រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងតុលាការ កាលពីខែមិថុនា ឆ្នាំ២០០២ ដែលសហដឹកនាំដោយអតីតទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងចៅក្រមប្រធានតុលាការកំពូល ។ កាលពីខែសីហា ឆ្នាំ២០០២ អង្គភាពសំរបសំរួលអចិន្ត្រៃយ៍ត្រូវបានបង្កើតឡើង ដោយមានការចូលរួមពីតំណាងមកពីស្ថាប័នសំខាន់ៗដែលពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល បន្ទាប់មកក្នុងខែធ្នូ ឆ្នាំ ២០០២ អង្គភាពគ្រប់គ្រងគំរោងមួយក៏ត្រូវបានបង្កើតឡើង ដើម្បីជួយការងារអង្គភាពសំរបសំរួលអចិន្ត្រៃយ៍ និងក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធតុលាការ ។ ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធតុលាការ យុទ្ធសាស្ត្រស្តីពីកំណែទំរង់ច្បាប់និងតុលាការត្រូវបានរៀបចំបញ្ចប់ និងអនុម័តយល់ព្រមដោយគណៈរដ្ឋមន្ត្រី កាលពីខែ មិថុនា ឆ្នាំ២០០៣ ។ យុទ្ធសាស្ត្រនេះមានគោលដៅជាសារវន្ត ៧ ខាងក្រោម÷

ទី១-លើកកំពស់ការការពារសិទ្ធិនិងសេរីភាពជាមូលដ្ឋានរបស់បុគ្គល ។

ទី២-កែលំអដំណើរការតាក់តែងច្បាប់ ។

ទី៣-កែលំអការផ្តល់ពតិមានលើបញ្ហាពាក់ព័ន្ធនឹងវិស័យច្បាប់ និងតុលាការ ។

ទី៤-កែលំអគុណភាពដំណើរការយុត្តិធម៌ និងសេវាតុលាការ ។

ទី៥-ពង្រឹងការផ្តល់សេវាយុត្តិធម៌ ដូចជាអំណាចតុលាការ និងព្រះរាជអាជ្ញា ។

ទី៦-ជំរុញអោយមានយន្តការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ ។

ទី៧-ពង្រឹងសមត្ថភាពស្ថាប័នដែលគាំទ្រវិស័យតុលាការនិងយុត្តិធម៌ ។

១៧- ព្រមជាមួយគ្នានេះ សេចក្តីព្រាងផែនការសកម្មភាពសំរាប់អនុវត្តយុទ្ធសាស្ត្រកំណែទំរង់ច្បាប់និងតុលាការក៏ត្រូវបានរៀបចំ ។ ផែនការសកម្មភាពនេះបានក្លាយជាមូលដ្ឋានសំរាប់ការជជែកពិភាក្សា នៅក្នុងសិក្ខាសាលាថ្នាក់ជាតិមួយ ដែលត្រូវបានរៀបចំឡើងក្រោមការដឹកនាំរបស់អង្គភាពសំរបសំរួលអចិន្ត្រៃយ៍ ដោយមានការចូលរួមពីក្រសួងនិងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកផ្តល់ជំនួយ ។ បន្ទាប់ពីសិក្ខាសាលាត្រូវបានបញ្ចប់ ការពិគ្រោះយោបល់ដ៏ទូលំទូលាយត្រូវបានធ្វើឡើង ដែលនាំទៅដល់ការរៀបចំផែនការអាទិភាពសំរាប់រយៈពេលខ្លី និងមធ្យម ។ ផែនការសកម្មភាពរយៈពេលខ្លី ២០០៤-២០០៦ រួមមានចំណុចជាអាទិភាព ៣៣ ដែលគ្របដណ្តប់គោលដៅយុទ្ធសាស្ត្រទាំង៧ខាងលើ ។ ផែនការសកម្មភាពរយៈពេលមធ្យមបានកំណត់អាទិភាព ២៧បន្ថែមទៀត ដែលត្រូវសំរេចអោយបានត្រឹមដំណាច់ឆ្នាំ២០០៨ ។ ផែនការសកម្មភាពទាំងនេះបានទទួលស្គាល់នូវដំណើរការដ៏រស់រវើកមួយ សំដៅសំរេចអោយបាននូវគោលដៅជាយុទ្ធសាស្ត្រដែលបានកំណត់ឡើងនៅក្នុងយុទ្ធសាស្ត្រកំណែទំរង់ច្បាប់និងតុលាការ ។

១៨- **ការកែសំរួលរចនាសម្ព័ន្ធនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម** : វិសោធនកម្មលើច្បាប់ស្តីពីអង្គការ ចាត់តាំង និងការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី ហើយ បច្ចុប្បន្ន កំពុងរង់ចាំការអនុម័តពីស្ថាប័ននីតិបញ្ញត្តិ ។ ទន្ទឹមនេះដែរ ការកែសំរួលរចនាសម្ព័ន្ធនៃឧត្តម ក្រុមប្រឹក្សានៃអង្គចៅក្រមកំពុងត្រូវបានដំណើរការ ជាមួយនឹងការបង្កើតអគ្គលេខាធិការដ្ឋានមួយ ដែល បច្ចុប្បន្នកំពុងពិនិត្យមើលពីតំរូវការនានា សំរាប់ការប្រព្រឹត្តិទៅដោយពេញលេញរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ នាខែមករា ឆ្នាំ២០០៣ រាជរដ្ឋាភិបាលបានសំរេចតំលើងប្រាក់បំណាច់ជូនចៅក្រម និងអយ្យការតុលាការ ។ សាលាភូមិន្ទនៃអង្គចៅក្រម និងមជ្ឈមណ្ឌលបណ្តុះបណ្តាលអ្នកច្បាប់បាន និងកំពុងដំណើរការ ។ «តុលាការគំរូ» មួយត្រូវបានបង្កើតឡើងនៅខេត្តកណ្តាល ដើម្បីសាកល្បងអនុវត្តនូវគំរូប្រតិបត្តិល្អៗក្នុងការ ដោះស្រាយរឿងក្តី ព្រមជាមួយគ្នានេះ ទព្វសំភារៈតុលាការសំរាប់បំរើការចាំបាច់ដល់ការប្រព្រឹត្តិទៅរបស់តុលាការគំរូ នឹងត្រូវបញ្ចប់ត្រឹមដំណាច់ឆ្នាំ ២០០៦ ។ យើងកំពុងដំណើរការបង្កើតតុលាការឯកទេសមួយចំនួនផងដែរ ដូចជាតុលាការពាណិជ្ជកម្ម តុលាការអនីតិជន និងតុលាការរដ្ឋបាល ។ ស្ថាប័នគាំទ្រស្នូល ដូចជាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រុមប្រឹក្សាអ្នកច្បាប់ ក្រសួងយុត្តិធម៌ និងយន្តការគាំទ្រកម្មវិធីកំណែទំរង់ច្បាប់ និងតុលាការ ដូចជាអង្គភាពសំរបសំរួលអចិន្ត្រៃយ៍ និងអង្គភាពគ្រប់គ្រងគំរោងកំពុងត្រូវបានពិនិត្យមើលឡើងវិញ និងពង្រឹងបន្ថែមទៀត ។ រាជរដ្ឋាភិបាលកំពុងតំរែតំរង់ធនធានសំរាប់អនុវត្តកម្មវិធីកំណែទំរង់ទាំងនេះ ។ ប៉ុន្តែមកទល់ពេលនេះ ថវិកាសំរាប់ការងារនេះភាគច្រើនបានមកតែពីថវិការបស់រាជរដ្ឋាភិបាលប៉ុណ្ណោះ ។

១៩- **ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម** : រាជរដ្ឋាភិបាលកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈរបស់ចៅក្រម និងច្បាប់អង្គការស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់អង្គតុលាការ ។ ពង្រាងច្បាប់ទាំងនេះគ្រោងនឹងដាក់ជូនស្ថាប័ននីតិបញ្ញត្តិអនុម័តក្នុងឆ្នាំ២០០៥ ស្របតាមអាទិភាពការងារដែលមានចែងក្នុងផែនការសកម្មភាពរយៈពេលខ្លី ។

២០- **សមិទ្ធផលផ្សេងៗទៀត** រួមមានការអនុម័តច្បាប់ស្តីពីការការពារសិទ្ធិមនុស្ស ច្បាប់ស្តីពីការវិនិយោគ ច្បាប់ពាណិជ្ជកម្ម និងច្បាប់ស្តីពីការគ្រប់គ្រងធនធានធម្មជាតិ ។ លើសពីនេះ ក្រម និងនីតិវិធីរដ្ឋប្បវេណី ព្រមទាំងក្រម និងនីតិវិធីព្រហ្មទណ្ឌត្រូវបានរៀបចំ ហើយកំពុងពិនិត្យឡើងវិញដោយក្រុមប្រឹក្សាអ្នកច្បាប់ ដើម្បីដាក់ស្នើជូនគណៈរដ្ឋមន្ត្រី រដ្ឋសភាជាតិ និងព្រឹទ្ធសភាពិនិត្យ និងអនុម័ត នាឆ្នាំ២០០៥ ។

២១- ទោះបីដៃគូអភិវឌ្ឍន៍របស់កម្ពុជាបានយល់អំពីសារៈសំខាន់នៃការកែទំរង់ប្រព័ន្ធតុលាការក៏ដោយ ក៏រហូតមកដល់ពេលនេះ កំណែទំរង់នេះបានទទួលការជួយឧបត្ថម្ភតិចតួចបំផុតពីដៃគូអភិវឌ្ឍន៍ ។ កំណែទំរង់វិស័យតុលាការត្រូវបានកំណត់ដោយ«ការអង្កេតបរិយាកាសវិនិយោគ» ថាជាការងារសំខាន់បំផុតមួយ សំរាប់ផ្តល់នូវបរិយាកាសអំណោយផលដល់ការអភិវឌ្ឍន៍វិស័យឯកជន ។ ការបង្កើនលទ្ធភាពរបស់ជនក្រីក្រក្នុងការទទួលបានយុត្តិធម៌ និងសេវាតុលាការជាកត្តាសំខាន់មួយក្នុងការដោះស្រាយភាពអយុត្តិធម៌ លើកកំពស់ទំនុកចិត្តរបស់ប្រជាពលរដ្ឋលើច្បាប់ កែលំអស្ថានភាពរស់នៅ និងកាត់បន្ថយភាពក្រីក្រលំបាកតោកយ៉ាក ។

២២- ភាពស្មុគស្មាញនៃកំណែទំរង់ច្បាប់និងតុលាការ ក៏បណ្តាលមកពីបរិស្ថានសង្គមរបស់កម្ពុជាផងដែរ ។ សង្គ្រាមរ៉ាំរ៉ៃ និងជំលោះផ្ទៃក្នុងជាងបីទសវត្សរ៍ បានបន្សល់នូវស្លាកស្នាមអតីតកាលមួយដ៏តានតឹង ។ កំណើនយ៉ាងឆាប់រហ័សនៃចំនួនប្រជាជនដែលមានវ័យក្មេង និងបំរែបំរួលដ៏ឆាប់រហ័សនៃសង្គម ដែលបណ្តាលមកពីការរីកចំរើននៃបច្ចេកវិទ្យា និងការចូលរួមក្នុងតំបន់និងពិភពលោក បាននាំអោយមានការប្រែប្រួលនូវតំលៃ និងសេចក្តីថ្លៃថ្នូរសង្គម ។ សង្គមកម្ពុជាកំពុងឆ្លងកាត់ការផ្លាស់ប្តូរ ។ ព្រមជាមួយនេះ យើងមានអ្នកឯកទេសច្បាប់កម្ពុជាមួយចំនួនតូចប៉ុណ្ណោះ ដែលធ្វើអោយក្របខ័ណ្ឌច្បាប់កម្ពុជាបច្ចុប្បន្នងាយទទួលរងនូវឥទ្ធិពលពីសំណាក់អ្នកឯកទេសបរទេសដែលមកបំរើការនៅកម្ពុជា ។ នេះបណ្តាលអោយមានភាពមិនស៊ីសង្វាក់គ្នា ដែលធ្វើអោយការអនុវត្តន៍ច្បាប់ជួបប្រទះនឹងឧបសគ្គយ៉ាងធំធេង ។ លើសពីនេះ ការអនុវត្តន៍ច្បាប់នៅតែជាបញ្ហាប្រឈមមួយ ពិសេសដោយសារកំរិតប្រាក់បៀវត្សទាប ។ ប្រការនេះពិតជាការលំបាកណាស់ក្នុងការអនុវត្តន៍ច្បាប់អោយបានត្រឹមត្រូវ ច្បាស់លាស់ និងមានតំលាភាព នៅពេលដែលប្រាក់បៀវត្សរបស់មន្ត្រីអនុវត្តច្បាប់មានកំរិតទាបជាងកំរិតអប្បបរមាដែលអាចរស់បាន ។

២៣- រាជរដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់ទៅលើការរៀបចំក្របខ័ណ្ឌគតិយុត្តិសំរាប់ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចទីផ្សារ និងសំរាប់ជំរុញការរីកចំរើនខាងផ្នែកពាណិជ្ជកម្មនិងការវិនិយោគ ដោយបានរៀបចំក្របខ័ណ្ឌគតិយុត្តិស្តីពីកម្មសិទ្ធិ ការបង្កើតអត្តសញ្ញាណធុរៈកិច្ច ប្រព័ន្ធធនាគារ ប្រព័ន្ធពន្ធដារនិងគណនេយ្យ ការធានារ៉ាប់រង សន្តិសុខអន្តរកម្ម ច្បាប់សហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីក្ស័យធន ច្បាប់ស្តីពីកិច្ចសន្យានិងឥណទានពាណិជ្ជកម្ម ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ដើម្បីធានាកិច្ចដំណើរការក្នុងវិស័យហិរញ្ញវត្ថុអោយមានប្រសិទ្ធភាព ។

## ការប្រឆាំងអំពើពុករលួយ

២៥- នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ នាខែមិថុនា ឆ្នាំ២០០២ លក្ខខ័ណ្ឌវិនិច្ឆ័យដែលពាក់ព័ន្ធនឹងផ្នែកនេះ ត្រូវបានកំណត់ដូចតទៅ÷

ទី១- សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយស្នើជូនសភាជាតិ ។

ទី២- រាយការណ៍ករណីមានអំពើពុករលួយដែលបានរកឃើញ និងផ្តន្ទាទោសសមស្របទៅតាមក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ ។

២៦- សេចក្តីព្រាងច្បាប់ប្រឆាំងនឹងអំពើពុករលួយត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣ កន្លងមក ហើយក៏បានស្នើជូនសភាជាតិអនុម័ត នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៣ ។ សភាជាតិបានបញ្ជូនសេចក្តីព្រាងច្បាប់នេះត្រឡប់មករាជរដ្ឋាភិបាល ដើម្បីពិនិត្យឡើងវិញ ។ ការពិនិត្យសេចក្តីព្រាងច្បាប់ឡើងវិញត្រូវបានដំណើរការយឺតៗ ដោយសារការពន្យារពេលក្នុងការបង្កើតរាជរដ្ឋាភិបាល ។ ផ្អែកតាមធាតុចូលដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ក្នុងកិច្ចប្រជុំត្រៀម នាខែកញ្ញា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលនឹងពិនិត្យ បញ្ចប់ ហើយសេចក្តីព្រាងច្បាប់នឹងត្រូវបញ្ជូនទៅសភាជាតិក្នុងពេលឆាប់ៗខាងមុខនេះ ។ រាជរដ្ឋាភិបាលបាន

ឯកភាពជាមួយដៃគូអភិវឌ្ឍន៍ថា យើងត្រូវអនុវត្តតាមអភិក្រមប្រកបដោយលក្ខណៈសន្តនិយម (Holistic Approach) ក្នុងការប្រឆាំនឹងអំពើពុករលួយ ។ ទន្ទឹមនឹងការអនុម័តច្បាប់ដែលជាជំហានសំខាន់មួយ ការកសាងសមត្ថភាពសំរាប់អនុវត្តច្បាប់ក៏ជាកត្តាសំខាន់ស្មើគ្នាដែរ ។ ក្នុងការប្រឆាំងនឹងអំពើពុករលួយដែលជះឥទ្ធិពលដល់ស្ថានភាពសេដ្ឋកិច្ចជាទូទៅ និងការកាត់បន្ថយភាពក្រីក្រ យើងក៏ត្រូវយកចិត្តទុកដាក់ដល់វិធានការមួយចំនួនផ្សេងទៀតដែរ ។ វិធានការទាំងនោះរួមមាន ÷ កែលំអទំរង់ការបែបបទរដ្ឋបាល ការធ្វើអោយសាមញ្ញ និងទំនើបកម្មប្រព័ន្ធពន្ធដារ ការកាត់បន្ថយលិខិតបទដ្ឋានច្រើនហួសហេតុ ការលើកទឹកចិត្តមន្ត្រីរាជការតាមរយៈប្រាក់បៀវត្ស ដើម្បីកាត់បន្ថយកាលានុវត្តភាពនៃអំពើពុករលួយ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏យល់ថា ការកែប្រែឥរិយាបថរបស់ប្រជាជនទាមទារនូវពេលវេលាសមស្របដែរ ។

២៧- **ករណីអំពើពុករលួយដែលបានរកឃើញ និងផ្តន្ទាទោស** : ទោះជាមានការលំបាក និងស្មុគ្រស្មាញយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលបានសំរេចលទ្ធផលគួរអោយកត់សំគាល់មួយចំនួន ក្នុងការប្រយុទ្ធប្រឆាំងដល់ឫសគល់នៃអំពើពុករលួយ ។ ការប្រយុទ្ធនឹងអំពើកាប់ឈើខុសច្បាប់ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវចំណូល- ចំណាយរដ្ឋ ការកាត់បន្ថយចំនួនខ្មោចចេញពីបញ្ជីមន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធ ការរឹបអូសដីដែលលក់ ឬកាន់កាប់ខុសច្បាប់ គឺជាបណ្តាវិធានការប្រឆាំងនឹងអំពើពុករលួយ ។ ទន្ទឹមនេះ អាជ្ញាធរជាតិសវនកម្មត្រូវបានបង្កើត និងកំពុងដំណើរការ សំរាប់ជាយន្តការត្រួតពិនិត្យ (Check and Balance Mechanism) សំរាប់ត្រួតពិនិត្យការប្រមូលចំណូល និងការគ្រប់គ្រងចំណាយ ។ អង្គភាពសវនកម្មផ្ទៃក្នុងតាមក្រសួងត្រូវបានបង្កើត និងកំពុងពង្រឹងសមត្ថភាព ។ អាជ្ញាធរជាតិសវនកម្មបាននិងកំពុងធ្វើការជាមួយបណ្តាអង្គភាពសវនកម្មផ្ទៃក្នុងទាំងនេះ ដើម្បីពង្រឹងតំលាភាព និងគណនេយ្យភាព ។

**លទ្ធកម្មសាធារណៈ**

២៨- នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ នាខែមិថុនា ឆ្នាំ២០០២ លក្ខខ័ណ្ឌវិនិច្ឆ័យដែលពាក់ព័ន្ធនឹងផ្នែកនេះ ត្រូវបានកំណត់ដូចតទៅ ÷

ទី១- ពង្រីកវិសាលភាពនៃការអនុវត្តន៍អនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈចំពោះគ្រប់ក្រសួងសេដ្ឋកិច្ច និងសង្គមកិច្ច សំរាប់រាល់ចំណាយក្នុងជំពូកទី១១ និង១៣នៃថវិការដ្ឋ ។

ទី២- កំណត់កាលបរិច្ឆេទក្នុងការអនុវត្តន៍លទ្ធកម្មលើគ្រប់ប្រភេទចំណាយរបស់គ្រប់ក្រសួង ។

២៩- ការអនុវត្តន៍អនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈ ត្រូវបានពង្រីកលើគ្រប់ប្រភេទចំណាយទាំងអស់របស់គ្រប់ក្រសួង លើកលែងតែក្រសួងព្រះបរមរាជវាំង ។

## ២.១.២ ការគ្រប់គ្រងប្រភពធនធានធម្មជាតិ

### សុន្ទនាកម្មនៃប្រព័ន្ធសម្បទានព្រៃឈើ

៣០- នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ នាខែមិថុនា ឆ្នាំ២០០២ លក្ខខ័ណ្ឌវិនិច្ឆ័យដែលពាក់ព័ន្ធនឹងផ្នែកនេះ ត្រូវ

បានកំណត់ដូចតទៅ ÷

ទី១- មិនអនុញ្ញាតអោយធ្វើអាជីវកម្មក្នុងតំបន់ព្រៃសម្បទានណាមួយជារៀងរហូត លុះត្រាណាមិនទាន់មានផែនការយុទ្ធសាស្រ្តស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព រួមទាំងការវាយតំលៃពីផលប៉ះពាល់បរិស្ថាននិងសង្គម ស្របតាមខ្លឹមសារនៃអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន ។

ទី២- បោះផ្សាយជាសាធារណៈ និងអនុញ្ញាតអោយអ្នកជំនាញការឯករាជ្យ រួមមានទាំងអ្នកសង្កេតការណ៍ពីក្រុមការងារគ្រប់គ្រងធនធានធម្មជាតិផ្តល់យោបល់ជាមុន មុនការពិនិត្យជាស្ថាពររបស់រាជរដ្ឋាភិបាល លើផែនការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងការវាយតំលៃពីផលប៉ះពាល់បរិស្ថាននិងសង្គម ។

ទី៣- ដកហូតព្រៃសម្បទានពីសម្បទានិកណា ដែលមិនបានស្នើផែនការយុទ្ធសាស្រ្តស្តីពីការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ។

៣១- ដោយរក្សាបាននូវការប្តេជ្ញាចិត្តដែលមានកន្លងមក រាជរដ្ឋាភិបាលមិនបានផ្តល់សម្បទានព្រៃឈើថ្មីណាមួយឡើយ ចាប់តាំងពីថ្ងៃទី១ ខែមករា ឆ្នាំ២០០២ ។ ប៉ុន្តែ រាជរដ្ឋាភិបាលបានអនុញ្ញាតិអោយមានប្រតិបត្តិការទ្រង់ទ្រាយតូចលើសំណល់ព្រៃឈើ (ដូចជា ការកាប់គាស់ប្រមូលគល់ឈើ) និងការងារមួយចំនួនទៀតដែលត្រូវបានអនុញ្ញាតក្រោមបញ្ញត្តិ និងច្បាប់របស់កម្ពុជា ។ សម្បទានិកត្រូវស្នើផែនការយុទ្ធសាស្រ្តស្តីពីការគ្រប់គ្រងព្រៃឈើ (Strategic Forest Management Plan-SFMP) ដោយភ្ជាប់ជាមួយនឹងការវាយតំលៃផលប៉ះពាល់សង្គមនិងបរិស្ថាន (Environment and Social Impact Assessments-ESIA) ក្នុងខែកញ្ញា ឆ្នាំ ២០០២ ។ សម្បទានិកចំនួន ១៣ បានស្នើឯកសារទាំងនេះ នាខែវិច្ឆិកា ឆ្នាំ២០០២ ហើយដែលឯកសារទាំងនេះត្រូវបានប្រើប្រាស់សំរាប់ពិគ្រោះយោបល់ជាមួយនឹងសហគមន៍ដែលទទួលផលប៉ះពាល់ ។

៣២- ចំពោះការផ្សព្វផ្សាយជាសាធារណៈ និងការផ្តល់កាលានុវត្តភាពអោយអ្នកជំនាញឯករាជ្យផ្តល់អនុសាសន៍មុនការសំរេចរបស់រាជរដ្ឋាភិបាលលើផែនការយុទ្ធសាស្រ្តស្តីពីការគ្រប់គ្រងព្រៃឈើ និងការវាយតំលៃផលប៉ះពាល់សង្គមនិងបរិស្ថាន ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីធនាគារពិភពលោក រាជរដ្ឋាភិបាលបានពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្រ្តស្តីពីការគ្រប់គ្រងព្រៃឈើ និងការវាយតំលៃផលប៉ះពាល់ ដែលបានស្នើឡើងដោយសម្បទានិក ។ រាជរដ្ឋាភិបាលបានធ្វើការផ្សព្វផ្សាយឯកសារទាំងនេះ ជូនដល់សហគមន៍ ពាក់ព័ន្ធ ។ ដោយសារភាពស្មុគ្រស្មាញផ្នែកបច្ចេកទេសនៃផែនការយុទ្ធសាស្រ្តស្តីពីការគ្រប់គ្រងព្រៃឈើ និងការវាយតំលៃផលប៉ះពាល់ សហគមន៍មូលដ្ឋានមិនអាចផ្តល់យោបល់ភ្លាមៗបានទេ ។ ដូចនេះ រដ្ឋបាលព្រៃឈើបានផ្តល់ពេលវេលាដោយគ្មានកំណត់សំរាប់បញ្ចប់ដំណើរការពិគ្រោះយោបល់របស់ពួកគេ ។ រដ្ឋបាលព្រៃឈើបានផ្សព្វផ្សាយឯកសារទាំងនេះ ដល់សហគមន៍មូលដ្ឋាន ២៤៥ភូមិ ដែលមានទីតាំងនៅក្នុង ឬនៅជុំវិញតំបន់ព្រៃសម្បទាន ។ ក្រុមការងាររបស់រដ្ឋបាលព្រៃឈើបានពិភាក្សាជាមួយសហគមន៍មូលដ្ឋាន ហើយបានកត់ត្រាបណ្តាកង្វល់ទាំងឡាយដែលសហគមន៍បានលើកឡើង ។ លើសពីនេះ រដ្ឋបាលព្រៃឈើបានតំរូវ

អោយសម្បទានិកស្វែងរកដំណោះស្រាយ អំពីកង្វល់ដែលបានលើកឡើង និងបញ្ចូលដំណោះស្រាយទាំងនេះទៅក្នុងផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងព្រៃឈើ និងការវាយតំលៃផលប៉ះពាល់ ។ នៅត្រឹមដំណាច់ខែកក្កដា ឆ្នាំ២០០៣ ក្រុមការងារត្រួតពិនិត្យផ្នែកបច្ចេកទេសរបស់រដ្ឋបាលព្រៃឈើ ដោយមានជំនួយឧបត្ថម្ភ បច្ចេកទេសពីធនាគារពិភពលោក បានបញ្ចប់ការពិនិត្យដំបូងរបស់ខ្លួន លើផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងព្រៃឈើចំនួន១២ ។ ផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងព្រៃឈើ ដែលបានពិនិត្យឡើងវិញនេះកំពុងត្រូវបានត្រួតពិនិត្យមើលបន្ថែមទៀត ដោយក្រុមការងារឯករាជ្យស្តីពីការគ្រប់គ្រងធនធានធម្មជាតិរបស់សហគមន៍អ្នកផ្តល់ជំនួយ ។ ដើម្បីធានាតំលាភាពក្នុងដំណើរការវាយតំលៃ និងដើម្បីកាត់បន្ថយ " ការមិនជឿទុកចិត្ត និងការមន្ទិលសង្ស័យ " ដែលអាចកើតមាន ហើយដែលក្នុងករណីខ្លះ អាចបំភ្លៃមតិសាធារណៈ រដ្ឋបាលព្រៃឈើបានផ្តួចផ្តើមគំនិតបង្កើតការិយាល័យកិច្ចការសាធារណៈ ដើម្បីពង្រឹងការប្រាស្រ័យទាក់ទងជាមួយភាគីពាក់ព័ន្ធ ។

៣៣- រាជរដ្ឋាភិបាលបានលុបអាជ្ញាប័ណ្ណរបស់សម្បទានិក ដែលមិនបានស្នើផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងព្រៃឈើ និងការវាយតំលៃផលប៉ះពាល់ ។ ចាប់ពីឆ្នាំ១៩៩៩ រហូតមកដល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលបានប្រកាសលុបកិច្ចព្រមព្រៀង និងដកហូតអាជ្ញាប័ណ្ណពីក្រុមហ៊ុនចំនួន១៧ លើផ្ទៃដីចំនួន២៨កន្លែង ដែលមានផ្ទៃដីប្រមាណ ៣,៥លានហិកតា ។ រាជរដ្ឋាភិបាលបានលុបចោលកិច្ចព្រមព្រៀងសម្បទានចំនួន៥ (ក្រុមហ៊ុន Hero Taiwan, Wood Tee Peanich, GAT International, Mieng LY Heng និង Kignwood) ក្នុងពេលដំណើរការពិនិត្យមើលពីផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងព្រៃឈើ ។ រហូតមកដល់ពេលនេះ ក្រុមហ៊ុនសម្បទានព្រៃឈើចំនួន ១២ កំពុងរៀបចំកិច្ចព្រមព្រៀងសម្បទានឡើងវិញ ដើម្បីធានាចីរភាពនៃព្រៃឈើស្របតាមស្តង់ដារអន្តរជាតិ ។ ក្រុមហ៊ុនទាំង១២ នេះទទួលសម្បទានផ្ទៃដីព្រៃតិចជាង ៤,៤លានហិកតា ។ លើសពីនេះ រាជរដ្ឋាភិបាលបានផ្អាកការធ្វើអាជីវកម្មឈើរបស់សម្បទានិកទាំងអស់ រហូតដល់ពេលណាដែលផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងព្រៃឈើ និងការវាយតំលៃផលប៉ះពាល់ខាងបរិស្ថាន និងសង្គម ត្រូវបានពិនិត្យ វាយតំលៃ និងអនុម័តជាផ្លូវការពីរាជរដ្ឋាភិបាល ។

៣៤- រាជរដ្ឋាភិបាលបានប្រឹងប្រែងយ៉ាងសកម្មក្នុងការទប់ស្កាត់ការធ្វើអាជីវកម្មឈើខុសច្បាប់ ។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីរដ្ឋបាលព្រៃឈើ ៧ រូបត្រូវស្លាប់ និង៣៤ រូបទៀត ត្រូវរងរបួស ។ រោងចក្រអារឈើខុសច្បាប់ប្រមាណ ១.៣៨៦ សិប្បកម្មកែច្នៃឈើ ៦៥៣ សិប្បកម្មកែច្នៃវល្លិ៍ ៣៩ សិប្បកម្មកែច្នៃជ័រឈើ ២៤ និងឧបករណ៍កែច្នៃ១៥៩ត្រូវបានរឹបអូស បំផ្លាញចោល និងបិទជាស្ថាពរ ។ អ្នកការពារអំពើខុសច្បាប់ចំនួន ៣៣២ នាក់ ត្រូវបានឃាត់ខ្លួន ហើយរៀបចំសំណុំបែបបទបញ្ជូនទៅតុលាការ ។

៣៥- ការកាប់ព្រៃឈើខុសច្បាប់ ការរត់ពន្ធសត្វព្រៃ ការទន្ទ្រានដីព្រៃ ត្រូវកាត់បន្ថយមកនៅត្រឹមកំរិតអាចគ្រប់គ្រងបាន ។ វិធានការដែលរាជរដ្ឋាភិបាលប្រកាន់យកក្នុងការបង្ក្រាបបទល្មើសព្រៃឈើ មាន ÷ ការរឹតបន្តឹងក្នុងការអនុវត្តន៍ច្បាប់ព្រៃឈើ បង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើស ។ អភិក្រមដែលរាជរដ្ឋាភិបាលប្រកាន់យកក្នុងការគ្រប់គ្រងធនធានធម្មជាតិ ដែលរួមមានកំណែទំរង់ក្នុងការគ្រប់គ្រងសម្បទាន សហគមន៍ព្រៃឈើ និង

ការគ្រប់គ្រងតំបន់ព្រៃការពារ គឺសំដៅកាត់បន្ថយបទល្មើសព្រៃឈើនានា ។ ក្នុងពេលថ្មីៗនេះ រាជរដ្ឋាភិបាល បានចេញសារាចរណែនាំលេខ ០១ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៤ ដើម្បីទប់ស្កាត់ និងលុបបំបាត់ការទន្ទ្រាន និងការរំលោភដីព្រៃ ហើយក៏បានបង្កើតគណៈកម្មាធិការថ្នាក់ជាតិ និងអនុគណៈកម្មាធិការថ្នាក់ខេត្ត ដើម្បី អនុវត្តសារាចរនេះ ។

## ក្របខ័ណ្ឌច្បាប់សំរាប់ការគ្រប់គ្រងធនធានធម្មជាតិនៅមូលដ្ឋាន

៣៦- នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ នាខែមិថុនា ឆ្នាំ២០០២ លក្ខខ័ណ្ឌវិនិច្ឆ័យដែលពាក់ព័ន្ធនឹងផ្នែកនេះ ត្រូវ បានកំណត់ដូចតទៅ÷

ទី១- អនុវត្តទាំងស្រុងនូវការវាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គមទៅលើព្រៃសម្បទានថ្មី លើឡូតិ៍ នេសាទសម្បទានថ្មី និងលើដីធ្លីសម្បទានថ្មី ។

ទី២- រៀបចំបញ្ចប់និងអនុម័តអនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើ ដោយផ្អែកលើការពិគ្រោះយោបល់ជាមួយ សហគមន៍ដែលទទួលរងការប៉ះពាល់ ។

ទី៣- រៀបចំបញ្ចប់ និងអនុម័តអនុក្រឹត្យស្តីពីសម្បទានសង្គម ដោយផ្អែកលើការពិគ្រោះយោបល់ជាមួយ សហគមន៍ដែលទទួលរងការប៉ះពាល់ ។

ទី៤- រៀបចំបញ្ចប់ និងអនុម័តអនុក្រឹត្យស្តីពីសហគមន៍នេសាទ ដោយផ្អែកលើការពិគ្រោះយោបល់ជាមួយ សហគមន៍ដែលទទួលរងការប៉ះពាល់ ។

៣៧- ដូចបានជំរាបជូនខាងដើម ការអនុវត្តន៍អោយបានស្របនឹងគំរូវការនៃការវាយតំលៃអំពីផលប៉ះពាល់ខាង បរិស្ថាន និងសង្គមកិច្ច គឺជាផ្នែកមួយនៃការពិនិត្យឡើងវិញអំពីព្រៃសម្បទាន ។

៣៨- នៅខែធ្នូ ឆ្នាំ២០០៣ រាជរដ្ឋាភិបាលបានអនុម័តអនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើ ។ អនុក្រឹត្យនេះបានអនុញ្ញាត អោយរាជរដ្ឋាភិបាលប្រគល់ទ្រព្យសម្បត្តិព្រៃឈើសាធារណៈ អោយស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ សហគមន៍មូលដ្ឋាន ក្នុងក្របខ័ណ្ឌផែនការគ្រប់គ្រង និងការរៀបចំបែងចែកផលប្រយោជន៍ ។ អនុក្រឹត្យនេះ គឺជាលទ្ធផលនៃការពិគ្រោះយោបល់រយៈពេលជាង ៦ឆ្នាំ ជាមួយនឹងភាគីពាក់ព័ន្ធ និងទីប្រឹក្សាជាច្រើន ហើយ នេះក៏ជាការបំពេញបន្ថែមលើវិធានការផ្សេងទៀត ដូចជា អនុក្រឹត្យស្តីពីការផ្តល់សម្បទានដីសង្គមកិច្ច ដែល រាជរដ្ឋាភិបាលកំពុងបន្តអនុវត្ត ដើម្បីធានាការគ្រប់គ្រងធនធានដីធ្លីមានភាពប្រសើរ និងមានប្រយោជន៍ជាង មុន ។ រាជរដ្ឋាភិបាលបានធ្វើការក្នុងភាពជាដៃគូជាមួយអ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលជាច្រើន ក្នុងការសាកល្បងអនុវត្តគំរោងសហគមន៍ព្រៃឈើនៅតាមតំបន់នានា ។ ផ្ទៃដីប្រមាណ ១១០.០០០ហិកតា ត្រូវបានអភិវឌ្ឍតាមយន្តការ «សហគមន៍ព្រៃឈើ» ។

៣៩- រាជរដ្ឋាភិបាលបានអនុម័តអនុក្រឹត្យស្តីពីសម្បទានដីសង្គម នាខែមិនា ឆ្នាំ២០០៣ ។ ដោយអនុវត្តស្មារតីនៃ អនុក្រឹត្យនេះទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ខេត្ត- ក្រុង និងថ្នាក់ស្រុក- ខ័ណ្ឌ គំរោងសាកល្បងត្រូវបាន អនុវត្តនៅក្នុងឃុំ ៣ និង សង្កាត់ ១ ក្នុងខេត្តបាត់ដំបង កំពត កំពង់ស្ពឺ និងក្រុងភ្នំពេញ ។ ផ្អែកតាមលទ្ធផល

នៃគំរោងសាកល្បង និងការវាយតំលៃផលប៉ះពាល់សង្គមនៃភាពក្រីក្រ (Poverty Social Impact Assessment) នៃគំរោងសម្បទានដីសង្គមកិច្ច ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដោយបានសហការជាមួយ បណ្តាដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា បាននិងកំពុងរៀបចំកម្មវិធីបែងចែកដីធ្លី សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកិច្ច (Program for Land Allocation for Social and Economic Development-LASED) ។

៤០- ព្រះរាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទត្រូវបាន ពិភាក្សាបញ្ចប់រួចជាស្ថាពរ ហើយកំពុងរង់ចាំការអនុម័តរបស់គណៈរដ្ឋមន្ត្រី នាពេលឆាប់ៗខាងមុខនេះ ។ បច្ចុប្បន្ន ទោះបីជារាជរដ្ឋាភិបាលពុំទាន់បានអនុម័តលិខិតបទដ្ឋានទាំងនេះក្តី ក៏សហគមន៍នេសាទចំនួន ៣៦០ ត្រូវបានបង្កើតនៅទូទាំងប្រទេស ក្រោមជំនួយឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍ ។ រីឯច្បាប់ជលផលក៏ត្រូវបានពិនិត្យ ឡើងវិញដោយគណៈរដ្ឋមន្ត្រី ហើយនឹងត្រូវដាក់ជូនរដ្ឋសភា និងព្រឹទ្ធសភាពិនិត្យអនុម័ត ក្នុងពេលដ៏ខ្លីខាង មុខនេះ ។

## ២.១.៣ វិស័យសង្គមកិច្ច

### ការចំណាយថវិកាសំរាប់វិស័យសង្គមកិច្ច

៤១- នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ នាខែមិថុនា ឆ្នាំ២០០២ លក្ខខ័ណ្ឌវិនិច្ឆ័យដែលពាក់ព័ន្ធនឹងផ្នែកនេះ ត្រូវ បានកំណត់ដូចតទៅ ÷

ទី១- ថវិកាចំណាយសំរាប់ក្រសួងអាទិភាពទាំងបួន បានកើនឡើងដល់ ៣,៦% នៃផ. ស. ស ។

ទី២- ចំណាយថវិការបស់ក្រសួងសុខាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត មានយ៉ាងតិច ៣៥% នៃថវិកា ក្នុងជំពូក ១១ និង ៤០% នៃថវិកាជំពូក ១៣ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ។

ទី៣- ចំណាយថវិការបស់ក្រសួងអប់រំ មានយ៉ាងតិច ៤០% នៃថវិកាជំពូក ១១ និង ៥០% នៃថវិកាជំពូក ១៣ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ។

ទី៤- ចំណាយថវិកាសំរាប់ក្រសួងអប់រំ និងសុខាភិបាលមានប្រមាណ១០០% នៃថវិកាជំពូក ១១ និង ១៣។

៤២- **ថវិកាចំណាយសំរាប់ក្រសួងអាទិភាពទាំងបួន បានកើនឡើងដល់ ៣,៦% នៃផ.ស.ស** : បន្ទាប់ពី កិច្ចប្រជុំពិគ្រោះយោបល់លើកទី៦ វិទ្យាស្ថានជាតិស្ថិតិបានធ្វើបច្ចុប្បន្នភាពបញ្ចប់នាចុងឆ្នាំ២០០២ អំពីទិន្នន័យ ផ. ស. ស ចាប់ពីឆ្នាំ ១៩៩៣មក ដោយមានការជួយឧបត្ថម្ភពីមូលនិធិរូបិយវត្ថុអន្តរជាតិ ។ វិទ្យាស្ថានស្ថិតិ បានផ្លាស់ប្តូរទិន្នន័យផ. ស. សខ្លះ ដោយផ្អែកតាមតួលេខកែសំរួលរបស់ក្រសួងជំនាញ និងស្ថាប័នរបស់រាជ-រដ្ឋាភិបាល ព្រមជាមួយនឹងការកែសំរួលវិធីសាស្ត្រប្រមូលទិន្នន័យ ។ ជាលទ្ធផល យើងកត់សំគាល់ឃើញមាន កំណើនផ. ស. ស ចាប់ពីឆ្នាំ១៩៩៣មក ។ ក្នុងដំណាក់កាលឆ្នាំ១៩៩៨- ២០០២ តាមតំលៃចរន្ត ផ. ស. សបាន កើនឡើងខ្ពស់ជាងមុនបន្តិច ជាក់ស្តែង១០,១% សំរាប់ឆ្នាំ១៩៩៨ និង១៥,៨% សំរាប់ឆ្នាំ២០០២ ។ ដោយសារ មានការកែតំរូវបែបនេះ លក្ខខ័ណ្ឌវិនិច្ឆ័យដែលបានកំណត់នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ កាលពីខែមិថុនា ឆ្នាំ២០០២ មានការរឹតទាបបន្តិច ។ បើផ្អែកតាមតួលេខកែតំរូវនេះ ចំណាយថវិកាសំរាប់បណ្តាក្រសួងអាទិភាព

មាន ៣,៣% នៃ ផ.ស.ស ក្នុងឆ្នាំ២០០២ ។ តាមច្បាប់ហិរញ្ញវត្ថុសំរាប់គ្រប់គ្រងថវិកាឆ្នាំ ២០០៣ ថវិកាវិភាជន៍សំរាប់ក្រសួងអាទិភាពស្មើ ៣,៦% នៃផ.ស.ស ។ ប៉ុន្តែ ដោយសារការប្រមូលចំណូលមានកំរិតទាបព្រោះបណ្តាលមកពីកត្តាក្នុងស្រុក (បាតុកម្មហិង្សានៅភ្នំពេញកាលពីដើមឆ្នាំ ២០០៣ និងភាពមិនប្រាកដប្រជានៅពេលមុន និងក្រោយបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ) និងកត្តាក្រៅស្រុក (ជំងឺសារស៍ក្នុងតំបន់ និងសង្គ្រាមនៅអ៊ីរ៉ាក់) ចំណាយថវិកាត្រូវបានកាត់បន្ថយនៅតាមផ្នែកជាច្រើន ដោយរួមទាំងក្រសួងអាទិភាពផងដែរ ។ ចំណាយថវិកាសំរាប់ក្រសួងអាទិភាពមានរហូតដល់ ៣,៣% នៃផ.ស.ស ក្នុងឆ្នាំ ២០០៣ ។ នៅក្នុងឆ្នាំ២០០២ ចំណាយទូទាត់សំរាប់ក្រសួងអាទិភាពមានចំនួន ៥១២,១ពាន់លានរៀល ធៀបនឹងឆ្នាំ ២០០៣ មាន ៥២៩,៤ពាន់លានរៀល ។

៤៣- **ចំណាយថវិការបស់ក្រសួងសុខាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត មានយ៉ាងតិច ៣៥% នៃ ថវិកាក្នុងជំពូក ១១ និង ៤០% នៃថវិកាជំពូក ១៣ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ហើយចំណាយថវិការបស់ក្រសួងអប់រំ មានយ៉ាងតិច ៤០% នៃថវិកាជំពូក ១១ និង ៥០% នៃថវិកាជំពូក ១៣ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត** ៖ ការអនុវត្តន៍លក្ខខ័ណ្ឌវិនិច្ឆ័យទាំងពីរនេះ តំរូវអោយវិភាជន៍ ៧៥% នៃថវិកាជំពូក ១១ និង៩០% នៃថវិកាជំពូក១៣ អោយដល់ក្រសួងអប់រំ និងក្រសួងសុខាភិបាល ។ ការវិភាជន៍ថវិកាបែបនេះមិនអាចអនុវត្តទៅកើតឡើយ ។ ប៉ុន្តែ វិភាជន៍ថវិកាជំពូក ១១ និង ១៣ អោយក្រសួងសុខាភិបាល បានកើនឡើងពី១៥២,៤ពាន់លានរៀល សំរាប់ឆ្នាំ២០០២ ដល់១៦៦,៥ពាន់លានរៀល ក្នុងឆ្នាំ ២០០៣ ។ ចំពោះក្រសួងអប់រំ ការវិភាជន៍ថវិកាជំពូក១១ និង ១៣ ត្រូវបានបង្កើនពី ១៣០,១ពាន់លានរៀល ក្នុងឆ្នាំ២០០២ ដល់ ១៣៦,១ពាន់លានរៀលក្នុងឆ្នាំ២០០៣ ។

៤៤- **ចំណាយថវិកាសំរាប់ក្រសួងអប់រំ និងសុខាភិបាល មានប្រមាណ ១០០% នៃថវិកាជំពូក ១១ និង ១៣** ៖ ចំណាយថវិកាសំរាប់ក្រសួងសុខាភិបាលក្នុងឆ្នាំ២០០២ មាន ៨៨,១% នៃថវិកាក្រោមជំពូក ១១ និង ៩៩,៩% សំរាប់ជំពូក ១៣ ។ សំរាប់ឆ្នាំ ២០០៣ ចំណាយថវិកាក្រោមជំពូក ១១ មាន ៨៤,៦% និង ក្រោមជំពូក ១៣ មាន ៩៣,៥% ។ រីឯចំណាយថវិកាសំរាប់ក្រសួងអប់រំក្នុងឆ្នាំ ២០០២ មាន ៨៧,១% នៃថវិកាសំរាប់ជំពូក ១១ និង ១០៧,២% សំរាប់ជំពូក ១៣ ។ ចំណែកក្នុងឆ្នាំ ២០០៣ ចំណាយថវិកាក្រោមជំពូក ១១ មាន ៩៥,១% និងក្រោមជំពូក ១៣ មាន ៨៥,១% ។

**ការទប់ស្កាត់ការរាលដាលជំងឺអេដស៍**

៤៥- នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ នាខែមិថុនា ឆ្នាំ២០០២ លក្ខខ័ណ្ឌវិនិច្ឆ័យដែលពាក់ព័ន្ធនឹងផ្នែកនេះ ត្រូវបានកំណត់ដូចតទៅ ÷

ទី១- ការអនុម័តច្បាប់អេដស៍ ។

ទី២- កម្មវិធីផ្សព្វផ្សាយពីជំងឺអេដស៍តាមវិទ្យុ និងទូរទស្សន៍ ។

៤៦- **ការអនុម័តច្បាប់អេដស៍** : ច្បាប់ស្តីពីការទប់ស្កាត់ និងបង្ការការឆ្លងរាលដាលនៃជំងឺអេដស៍ ត្រូវបានអនុម័តដោយសភាជាតិ កាលពីខែមិថុនា ឆ្នាំ២០០២ ។ ការបង្ការជំងឺអេដស៍ ការផ្តល់សេវាថែទាំ និងព្យាបាលដល់អ្នកឆ្លងមេរោគអេដស៍ គឺជាសកម្មភាពអាទិភាពមួយរបស់រាជរដ្ឋាភិបាល ។ ច្បាប់ស្តីពីការទប់ស្កាត់ និងបង្ការការឆ្លងមេរោគអេដស៍ គឺជាក្របខ័ណ្ឌសំរាប់រាជរដ្ឋាភិបាលអនុវត្តគោលនយោបាយបង្ការ ព្យាបាល និងកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីការឆ្លងមេរោគនេះ ។

៤៧- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបានបង្កើតឡើងក្នុងខែមករា ឆ្នាំ១៩៩៩ មានតួនាទីសំរបសំរួលការអនុវត្តន៍វិធានការបង្ការ ព្យាបាល និងកាត់បន្ថយផលប៉ះពាល់ ដែលបណ្តាលមកពីការឆ្លងមេរោគនេះ ។ ក្នុងឆ្នាំ២០០១ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានប្រកាស «ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យ ក្នុងការទប់ទល់នឹងការឆ្លងរាលដាលជំងឺអេដស៍ ឆ្នាំ២០០១-២០០៥» ។ បន្ទាប់មក ក្រសួងសុខាភិបាល ក្រសួងការពារជាតិ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ សង្គមកិច្ច និងយុវនីតិសម្បទា និងក្រសួងអភិវឌ្ឍន៍ជនបទ ក៏បានរៀបចំផែនការយុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីទប់ទល់នឹងបញ្ហាជំងឺអេដស៍នេះផងដែរ ។ ខេត្តបាត់ដំបង និងសៀមរាបក៏បានរៀបចំផែនការយុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីទប់ទល់នឹងការរីករាលដាលនៃជំងឺអេដស៍ផងដែរ ។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានក្រសួង ២៦ និង ២៤ខេត្ត- ក្រុងជាសមាជិក ។ គណៈកម្មការសំរបសំរួលនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបានបង្កើតឡើងកាលពីខែមិនា ឆ្នាំ២០០៣ ដោយជួបប្រជុំគ្នាជាទៀងទាត់រៀងរាល់ខែ ដើម្បីសំរបសំរួលទំនាក់ទំនងជាមួយនឹងអង្គការសហប្រជាជាតិ ដៃគូផ្តល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ។ ដើម្បីសំរួលការរៀបចំយុទ្ធនាការផ្សព្វផ្សាយសំរាប់ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ពិធីបុណ្យអុំទូក និងទិវារំលឹកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ដោយសារមេរោគអេដស៍ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក៏បានបង្កើតនូវយន្តការសំរាប់សំរបសំរួលទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលផងដែរ ។

៤៨- កិច្ចខិតប្រឹងប្រែងរួមគ្នាជាមួយនឹងដៃគូអភិវឌ្ឍន៍ទាំងអស់ បានផ្តល់លទ្ធផលគួរជាទីពេញចិត្ត ។ អ្នកផ្ទុកមេរោគអេដស៍បានថយចុះពី ១៧៥.០០០នាក់ ក្នុងឆ្នាំ១៩៩៨ មកនៅត្រឹម ១៥៧.៥០០នាក់ ក្នុងឆ្នាំ២០០៣ ។ ការឆ្លងជំងឺអេដស៍ក្នុងចំណោមអ្នកមានវ័យ ១៥ ដល់ ៤៩ឆ្នាំ បានថយចុះពី ៣,៣% កាលពីឆ្នាំ១៩៩៨ មកនៅត្រឹម ២,៦% នៅឆ្នាំ២០០៣ ។ មនុស្សប្រមាណ ១០០.០០០នាក់បានមកពិនិត្យឈាម ។ សេវាពិនិត្យឈាម និងពិគ្រោះយោបល់ត្រូវបានអនុវត្តនៅតាម ១៣ខេត្ត- ក្រុង តាមរយៈមជ្ឈមណ្ឌលផ្តល់សេវាចំនួន ៤៩ ដែលក្នុងនោះ ១៨កន្លែងបានដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាល ។ អ្នកជំងឺអេដស៍ ២.០០០នាក់បានទទួលថ្នាំប្រឆាំងនឹងវីរុស ។ ការអនុវត្តន៍កម្មវិធីប្រើប្រាស់ស្រោមអនាម័យអោយបាន ១០០% នៅទូទាំងប្រទេស បានជួយកាត់បន្ថយអត្រាឆ្លងមេរោគអេដស៍របស់ស្ត្រីរកស៊ីផ្លូវភេទ ពី ៥៤% ក្នុងឆ្នាំ១៩៩៨ មកនៅត្រឹម ៣៧% ក្នុងឆ្នាំ២០០៣ ។ កម្មវិធីមិត្តអប់រំមិត្តកំពុងត្រូវបានអនុវត្តដោយជោគជ័យ នៅក្នុងមជ្ឈដ្ឋានមន្ត្រីរាជការស៊ីវិល និងកងកំលាំងប្រដាប់អាវុធ ។ ព្រះសង្ឃប្រមាណ ៥០.០០០អង្គ បានបញ្ចូលបញ្ហាអេដស៍ ទៅក្នុងកម្មវិធី

ទេសនាដល់ពុទ្ធបរិស័ទ ។ ព្រមជាមួយនេះ ការអប់រំពីជំងឺអេដស៍ក៏កំពុងត្រូវបានដំណើរការក្នុងវិស័យឯកជនផងដែរ ។

៤៩- **កម្មវិធីផ្សព្វផ្សាយពីជំងឺអេដស៍តាមវិទ្យុ និងទូរទស្សន៍** ៖ ការផ្សព្វផ្សាយពីជំងឺអេដស៍តាមកម្មវិធីវិទ្យុ និងទូរទស្សន៍ដោយមិនគិតថ្លៃ មានការជឿនលឿនគួរអោយកត់សំគាល់ ។ ស្ថានីយ៍ទូរទស្សន៍មួយចំនួនបានចែករំលែកពេលវេលាដល់ការផ្សព្វផ្សាយកម្មវិធីបង្ការជំងឺអេដស៍ ដោយមិនយកកំរៃ ។ ចំណែកឯផ្នែកឯកជនក៏បានជួយផ្សព្វផ្សាយកម្មវិធីជំងឺអេដស៍ផងដែរ ដូចជាក្រុមហ៊ុន Cambrew បានបញ្ចូលកម្មវិធីខ្លីៗពីជំងឺអេដស៍ ក្នុងកម្មវិធីខារ៉ាអូខេតាមទូរទស្សន៍ប្រចាំសប្តាហ៍របស់ខ្លួន ។ យើងក៏គួរអោយកត់សំគាល់នូវចំនួនកើនឡើងនៃការជួយគាំទ្រពីសំណាក់ប្រទេសអ្នកផ្តល់ជំនួយ សំរាប់ការផលិតកម្មវិធីផ្សព្វផ្សាយ ដូចជាការគាំទ្ររបស់ DFID ដល់វិទ្យុ BBC ក្នុងការផលិតរឿងខ្លីតាមវិទ្យុនិងទូរទស្សន៍ ។ ចំណែកឯ UNDP UNESCO និង UNICEF ក៏បានផលិតកម្មវិធីខ្លីៗរបស់ខ្លួនផងដែរ ។ ព្រមជាមួយនេះ អ្នកផ្តល់ជំនួយក៏បានបង្កើនការគាំទ្រដល់ការផ្សព្វផ្សាយដំណឹងស្តីពីមេរោគអេដស៍តាមទូរទស្សន៍ផងដែរ ដូចជា DFID បាននិងកំពុងឧបត្ថម្ភការផ្សព្វផ្សាយតាមទូរទស្សន៍ប៉ុស្តិ៍លេខ ៥ ។ ចំណែកឯ UNICEF ក៏បានឧបត្ថម្ភការផ្សាយតាមស្ថានីយ៍ផ្សេងៗទៀត ។

## ២.១.៤ ការគ្រប់គ្រងហិរញ្ញវត្ថុ និងកំណែទំរង់រដ្ឋបាលសាធារណៈ

### កំណែទំរង់រដ្ឋបាលស៊ីវិល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

៥០- នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់នាខែមិថុនា ឆ្នាំ២០០២ លក្ខខ័ណ្ឌវិនិច្ឆ័យដែលពាក់ព័ន្ធនឹងផ្នែកនេះ ត្រូវបានកំណត់ដូចតទៅ ÷ ដោយផ្អែកលើការសិក្សារបស់ធនាគារពិភពលោក រាជរដ្ឋាភិបាលត្រូវរៀបចំផែនការកំណែទំរង់សំរាប់មន្ត្រីរាជការរយៈពេលមធ្យម ដើម្បីកែលំអប្រាក់បៀវត្សមន្ត្រីរាជការ ដែលអាចប្រកួតប្រជែងជាមួយនឹងទីផ្សារពលកម្មឯកជន រួមទាំងការផ្តល់ការឧបត្ថម្ភសំរាប់សុវត្ថិភាពមន្ត្រីដែលត្រូវរំសាយ និងផ្តល់ជំរើសហិរញ្ញវត្ថុដែលមានសង្គតិភាពជាមួយក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។

៥១- រាជរដ្ឋាភិបាលបានអនុម័តកម្មវិធីជាតិកំណែទំរង់រដ្ឋបាល នាពាក់កណ្តាលឆ្នាំ ១៩៩៩ ។ នៅខែតុលា ឆ្នាំ២០០១ រាជរដ្ឋាភិបាលបានអនុម័តយុទ្ធសាស្ត្រស្តីពីសនិទានកម្មនៃមន្ត្រីរាជការ ។ ក្នុងផ្នែកមួយនៃយុទ្ធសាស្ត្រនេះ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានស្នើអំពីជំរើសនានា សំរាប់ពន្លឿនកំណែទំរង់ក្នុងការបើកប្រាក់បៀវត្ស និងក្របខ័ណ្ឌការងារ ។ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលក៏បានធ្វើការសិក្សាចំនួន ៦ ដើម្បីប្រមូលពត៌មាន និងធ្វើការវិភាគ សំរាប់ជាមូលដ្ឋានក្នុងការជំរុញល្បឿនកំណែទំរង់បៀវត្ស និងក្របខ័ណ្ឌការងារ ព្រមទាំងពង្រឹងការគ្រប់គ្រងរដ្ឋបាលស៊ីវិល ។

ទី១- ការកែលំអការផ្តល់សេវាសាធារណៈ ។

ទី២- ការធ្វើលក្ខខ័ណ្ឌវិនិច្ឆ័យទីផ្សារពលកម្ម ។

ទី៣- ការពិនិត្យឡើងវិញអំពីកិច្ចប្រតិបត្តិការ ។

ទី៤-បង្កើនប្រាក់បៀវត្ស និងលាភការ ដើម្បីប្រសិទ្ធភាពការងារ ។

ទី៥-កែលំអការងារដើម្បីគាំទ្រការផ្តល់សេវាសាធារណៈ ។

ទី៦-ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ។

៥២- កាលពីខែមេសា ឆ្នាំ២០០២ ធនាគារពិភពលោកបានយល់ព្រមផ្តល់ហិរញ្ញប្បទានសំរាប់ការសិក្សាចំនួន ៥ ក្នុងគំរោងសិក្សាទាំង ៦ ។ លក្ខខ័ណ្ឌយោងសំរាប់ការសិក្សាទាំងនេះ ត្រូវបានអនុម័តយល់ព្រមកាលពី ខែមិនា ឆ្នាំ២០០៣ ហើយទទួលហិរញ្ញប្បទាន ចាប់ពីខែឧសភា ឆ្នាំ២០០៣ ។ ចាប់ពីពេលនោះមក ការសិក្សាស្តីអំពីការកែលំអការផ្តល់សេវាសាធារណៈ ត្រូវបានបញ្ចប់កាលពីខែកញ្ញា ឆ្នាំ២០០៣ ។ ការអង្កេតអំពីទីផ្សារពលកម្មនៃបៀវត្សរ៍ និងប្រាក់បំណាច់ ក៏ត្រូវបានបញ្ចប់កាលពីខែកញ្ញា ឆ្នាំ២០០៤ ផងដែរ ។ ដោយមានជំនួយបច្ចេកទេសពីប្រទេសប្រ៊ុយណេ ការពង្រឹងការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស កំពុងដំណើរការ ។ ដោយមានការជួយគាំទ្រពីសហភាពអឺរ៉ុប ការគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធពតិមានវិទ្យាត្រូវបានពង្រឹងសំរាប់ជាឧបករណ៍ក្នុងការត្រួតពិនិត្យបែបបទជ្រើសរើសបុគ្គលិក និងជំរុញការអភិវឌ្ឍន៍ធនធានមនុស្ស ។

៥៣- ការពិនិត្យឡើងវិញនូវកិច្ចប្រតិបត្តិការ (Operations Review) នឹងចាប់ផ្តើមអនុវត្តក្នុងពេលឆាប់ៗខាងមុខនៅក្នុងក្រសួងអាទិភាព (អប់រំ សុខាភិបាល កសិកម្ម និងយុត្តិធម៌ ) ។ ការសិក្សានេះនឹងពិនិត្យមើលពីវឌ្ឍនភាពដែលសំរេចបានកន្លងមក និងរៀបចំវិធីសាស្ត្រ និងក្របខ័ណ្ឌសំរាប់ការពិនិត្យឡើងវិញនូវកិច្ចប្រតិបត្តិការទាំងនេះ ។ ការពិនិត្យឡើងវិញនូវកិច្ចប្រតិបត្តិការនឹងអនុវត្តសាកល្បង សំដៅដាក់អោយដំណើរការ នូវវិធីសាស្ត្រដែលបានរៀបចំឡើង ព្រមទាំងបណ្តុះបណ្តាលសមត្ថភាពរបស់រាជរដ្ឋាភិបាល ដើម្បីអាចអនុវត្តការពិនិត្យឡើងវិញនូវកិច្ចប្រតិបត្តិការនេះដោយខ្លួនឯង ។

៥៤- ចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាលលើប្រព័ន្ធបៀវត្សរ៍មន្ត្រីរាជការ រាជរដ្ឋាភិបាលបានកំណត់គោលការណ៍ជាមូលដ្ឋានពីរ ។ ទីមួយគឺ បំរែបំរួលទាំងអស់ត្រូវគោរពគោលការណ៍សាបេក្ខភាពរវាងចំណាត់ថ្នាក់មន្ត្រី (មន្ត្រីនយោបាយ មន្ត្រីរាជការស៊ីវិល និងកងកំលាំងប្រដាប់អាវុធ) ។ ទីពីរគឺត្រូវធានាចីរភាពក្នុងក្របខ័ណ្ឌសារពើពន្ធ ។ ក្នុងន័យនេះ ការតំលើងប្រាក់បៀវត្សរ៍ត្រូវតែគិតគូរដល់ធនធានដែលមាន និងចំណូលចរិការរបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលប្តេជ្ញានឹងតំលើងប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការ អោយបានពី១០ ទៅ១៥ភាគរយក្នុងមួយឆ្នាំ ។ ធនធានដែលយើងមាននឹងត្រូវផ្តោតទៅលើតំរូវការជាអាទិភាព តាមរយៈឧបករណ៍ផ្សេងៗ ដូចជាកម្មវិធីកន្សោមអាទិភាព និងប្រព័ន្ធប្រាក់បំណាច់សំរាប់បង្គ្រប់បៀវត្សរ៍ជាមូលដ្ឋាន ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានរៀបចំ និងអនុវត្តសាកល្បង ដើម្បីវាយតំលៃអំពីជំរើសដែលបានលើកឡើង ។ ការសិក្សាពីគោលនយោបាយស្តីពីលាភការ នឹងធ្វើឡើងជាមួយការពិនិត្យកិច្ចប្រតិបត្តិការឡើងវិញ ដែលនឹងចាប់ផ្តើមនៅដើមឆ្នាំ២០០៥ ផ្អែកលើលក្ខខ័ណ្ឌយោងដែលបានកែតំរូវថ្មី ។

៥៥- ការសិក្សាពីក្របខ័ណ្ឌការងារនឹងគ្រោងដំណើរការនាដើមឆ្នាំ២០០៥ ដើម្បីផ្តល់ពត៌មានបន្ថែមអំពីតួនាទីការ ការងារ និងសំរាប់រៀបចំយន្តការផ្លាស់ប្តូរដែលចាំបាច់ នៅក្នុងការរៀបចំក្របខ័ណ្ឌរដ្ឋបាលសាធារណៈ ។ ការសិក្សាពីការគ្រប់គ្រងមន្ត្រីរាជការ នឹងត្រូវផ្អែកតាមលទ្ធផលនៃការសិក្សាដទៃទៀតដែលបានធ្វើកន្លងមក ។

៥៦- នៅក្នុងដំណាក់កាលទី១ នៃការអនុវត្តន៍កម្មវិធីជាតិស្តីពីកំណែទំរង់រដ្ឋបាល រាជរដ្ឋាភិបាលបានយកចិត្តដាក់ទៅលើសកម្មភាពសំខាន់ៗ ចំនួន ៥ គឺ÷ ១-កត់ត្រា និងត្រួតពិនិត្យសមាសធាតុ និងការបែងចែកមន្ត្រី រាជការ ។ ២-រៀបចំឧបករណ៍សំខាន់ៗសំរាប់គ្រប់គ្រង និងលើកទឹកចិត្តមន្ត្រីរាជការ ។ ៣-វាយតំលៃតួនាទីការរបស់ក្រសួង ដែលពាក់ព័ន្ធនឹងការផ្តល់សេវា ។ ៤-បញ្ចប់ការត្រៀមរៀបចំការងារ ដើម្បីអោយរដ្ឋបាលបាននៅជិតប្រជាជន ។ និង ៥-ពង្រឹងសមត្ថភាពសំរាប់រៀបចំផែនការ និងគ្រប់គ្រងកំណែទំរង់ ។ នៅក្នុងកម្មវិធីជាតិស្តីពីកំណែទំរង់រដ្ឋបាល សមិទ្ធផលដែលបានសំរេច មានដូចខាងក្រោម÷

- បានប្រមូលនិងវិភាគពត៌មានស្តីពីសមាសធាតុ និងលក្ខណៈពិសេសនៃរដ្ឋបាលស៊ីវិល ។ ជាលទ្ធផលយើងមានការយល់ដឹងយ៉ាងច្បាស់អំពីសមាសធាតុ និងលក្ខណៈពិសេសនៃរដ្ឋបាលស៊ីវិល ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ខេត្ត- ក្រុង ។
- បានរៀបចំ និងដាក់អោយអនុវត្ត នូវក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិនានា ។
- បានរៀបចំ និងដាក់អោយអនុវត្តនូវប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស រួមទាំងប្រព័ន្ធពត៌មានស្តីពីការគ្រប់គ្រងធនធានមនុស្ស សំរាប់រៀបចំផែនការ និងគ្រប់គ្រងមន្ត្រីរដ្ឋបាលស៊ីវិល ។
- បានរៀបចំ និងដាក់អោយអនុវត្តនូវរបបផ្តល់ប្រាក់បៀវត្ស និងប្រព័ន្ធការងារ សំរាប់វាយតំលៃប្រសិទ្ធភាពការងារ ។
- បានរៀបចំគោលនយោបាយថ្មីៗ សំរាប់បង្វែរធនធានហិរញ្ញវត្ថុដែលមានទៅក្នុងផ្នែកអាទិភាព ដើម្បីបង្កើនប្រសិទ្ធភាពការងាររបស់មន្ត្រីរាជការ ដូចជា កន្សោមអាទិភាព ការផ្តល់ប្រាក់ឧបត្ថម្ភដល់មន្ត្រីមួយចំនួន (Targeted Allowances) និងការិយាល័យតែមួយនៅថ្នាក់ខេត្ត- ស្រុក (One Window Office) ។

## ការប្រមូលចំណូល

៥៧- នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ នាខែមិថុនា ឆ្នាំ២០០២ លក្ខខ័ណ្ឌវិនិច្ឆ័យដែលពាក់ព័ន្ធនឹងផ្នែកនេះ ត្រូវបានកំណត់ដូចតទៅ÷

ទី១- បង្កើនចំណូលរដ្ឋអោយដល់ ១២,៧៥%នៃ ផ.ស.ស ។

ទី២- បង្កើនចំណូលដែលបានមកពីការជួលទ្រព្យសម្បត្តិរដ្ឋ ការប្រមូលពន្ធយឺតយ៉ាវ និងស្ថានភាពនៃការអនុវត្តន៍យន្តការត្រួតពិនិត្យមុនពេលផ្ទុក ។

ទី៣- ពង្រឹងសវនកម្មពន្ធ និងការគ្រប់គ្រងរដ្ឋបាលពន្ធ ។

ទី៤- បង្កើនតំលាភាពក្នុងការកំណត់លក្ខខ័ណ្ឌនៃកិច្ចសន្យារបស់រដ្ឋាភិបាល ។

៥៨- **ចំណូលថវិកាបង្កើនដល់ ១២,៧៥% នៃ ផ.ស.ស** ៖ ដូចដែលបានលើកឡើងពីខាងដើម បន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់លើកទី៦ វិទ្យាស្ថានជាតិស្ថិតិបានធ្វើការកែសំរួលទិន្នន័យផ. ស. សចាប់ពីឆ្នាំ១៩៩៣ ដោយមានការជួយឧបត្ថម្ភពីមូលនិធិរូបិយវត្ថុអន្តរជាតិ ។ ដោយសារការកែសំរួលលើទិន្នន័យផ. ស. សបានកើនឡើង គោលដៅកំណើន១២,៧៥%ផ្អែកតាមតួលេខផ. ស. សចាស់ មានកំរិតទាបបើផ្អែកតាមតួលេខ ផ. ស. សដែលបានកែសំរួល ។ ការពិនិត្យពីវឌ្ឍនភាពនៅក្នុងឯកសារនេះ គឺផ្អែកតាមតួលេខផ. ស. ស ដែលត្រូវបានកែសំរួល ។

៥៩- ទោះបីជារាជរដ្ឋាភិបាលបានជួបប្រទះនឹងបញ្ហាប្រឈមជាច្រើនក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ដូចជាការកែទំរង់ប្រព័ន្ធពន្ធគយ ដោយបន្ទាបអតិបរមាអត្រាពន្ធគយ ព្រមទាំងបញ្ហាប្រឈមក្នុងការត្រួតពិនិត្យការរត់ពន្ធ និងការគេចពន្ធក៏ដោយ ក៏រាជរដ្ឋាភិបាលបានជំរុញអោយមានវឌ្ឍនភាពក្នុងការបង្កើនការប្រមូលចំណូល ។ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ការអនុវត្តន៍យ៉ាងម៉ឺងម៉ាត់នូវកំណែទំរង់សារពើពន្ធ និងការអនុវត្តន៏វិធានការបង្កើនចំណូល បានស្តែងចេញជាលទ្ធផលគួរជាទីពេញចិត្ត ។ ចំណូលគិតជាភាគរយនៃ ផ. ស. ស បានកើនឡើងពី ៨,១% ក្នុងឆ្នាំ១៩៩៨ ដល់១១,១% ក្នុងឆ្នាំ២០០២ ។ នៅក្នុងឆ្នាំ២០០៣ ការប្រមូលចំណូលមិនត្រឹមតែជួបការលំបាកដោយសារការលេចឡើងនៃជំងឺSARS នៅក្នុងតំបន់ បាតុកម្មហិង្សាប្រឆាំងស្ថានទូតថៃកាលពីដើមឆ្នាំ២០០៣ សង្គ្រាមនៅអ៊ីរ៉ាក់ រួមផ្សំជាមួយនឹងការបន្តនៃអប្រសិទ្ធភាពក្នុងការប្រមូលពន្ធតែប៉ុណ្ណោះទេ ប៉ុន្តែក៏ជួបការលំបាកផងដែរដោយសារភាពមិនច្បាស់លាស់ដែលពាក់ព័ន្ធនឹងការបោះឆ្នោតនៅក្នុងឆមាសទីមួយឆ្នាំ២០០៣ និងការពន្យារពេលក្នុងការបង្កើតរាជរដ្ឋាភិបាលថ្មីបន្ទាប់ពីការបោះឆ្នោតនាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣ ។

៦០- ស្ថានភាពមិនច្បាស់លាស់ដែលកើតមាននៅក្នុងឆ្នាំ២០០៣ បានជះឥទ្ធិពលមិនល្អដល់ការប្រមូលចំណូលពីការបង់ថ្លៃជួលទ្រព្យសម្បត្តិសាធារណៈ ការប្រមូលពន្ធជំពាក់ និងការអនុវត្តន៍អធិការកិច្ចមុនពេលផ្ទុក (Pre-Shipment Inspection Program) ។

៦១- **ការពង្រឹងសវនកម្មនិងការគ្រប់គ្រងពន្ធដារ** ៖ អាជ្ញាធរសវនកម្មជាតិ ដែលត្រូវបានបង្កើតឡើងកាលពីឆ្នាំ២០០០ បានដំណើរការ និងកំពុងពង្រឹងសមត្ថភាពរបស់ខ្លួន ។ អាជ្ញាធរសវនកម្មជាតិបានបញ្ចប់របាយការណ៍ស្តីពីសវនកម្មសំរាប់ឆ្នាំ២០០០ ឆ្នាំ២០០១ និង២០០២ ហើយបានដាក់ជូនសភាជាតិដើម្បីពិនិត្យ ។ មុខងារនៃសវនកម្មផ្ទៃក្នុងនៅតាមក្រសួងជំនាញនានា ក៏កំពុងត្រូវបានពង្រឹងផងដែរ ។ អាជ្ញាធរសវនកម្មជាតិកំពុងធ្វើការជាមួយអង្គភាពសវនកម្មផ្ទៃក្នុងនៅតាមក្រសួងជំនាញដើម្បីបង្កើនតំលាភាពនិងគណនេយ្យភាព ។

៦២- **ការបង្កើនតំលាភាពក្នុងកិច្ចសន្យារបស់រាជរដ្ឋាភិបាល** ៖ ដើម្បីបង្កើនតំលាភាព និងកាត់បន្ថយការរំលោភច្បាប់អោយបានជាអតិបរមា អនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈត្រូវបានពង្រីកវិសាលភាពនៃការអនុវត្តន៍គ្របដណ្តប់គ្រប់ក្រសួងទាំងអស់ លើកលែងតែក្រសួងព្រះបរមរាជវាំង ។

## ២.២- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

៦៣- រាជរដ្ឋាភិបាលនីតិកាលទី២ នៃរដ្ឋសភា ឆ្នាំ១៩៩៨-២០០៣ បានអនុវត្តក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ហើយទទួលបានវឌ្ឍនភាពគួរអោយកត់សំគាល់ ក្នុងគោលបំណងសំរេចអោយបាននូវសមធម៌កំណើនសេដ្ឋកិច្ចរយៈពេលយូរអង្វែង និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ ក្របខ័ណ្ឌការងារនេះបានផ្តោតការយកចិត្តទុកដាក់ទៅលើការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការពង្រឹងស្ថាប័នហិរញ្ញវត្ថុនិងធនាគារ ការអនុវត្តន៍វិធានការកំណែទំរង់សារពើពន្ធ ធានាអោយបាននូវការគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ និងការបង្កើនវិនិយោគសាធារណៈដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តសង្គម និងការអភិវឌ្ឍន៍ធនធានមនុស្សរបស់ប្រទេស ។ ទន្ទឹមនេះ ក្នុងរយៈពេល ៥ឆ្នាំកន្លងមក កម្ពុជាបានបោះជំហានយ៉ាងរឹងមាំ ក្នុងការពង្រឹងស្ថិរភាពនយោបាយ សេដ្ឋកិច្ច និងការធ្វើសមារណកម្មទៅក្នុងសហគមន៍អន្តរជាតិ ។

៦៤- ចំពោះរាជរដ្ឋាភិបាល កំណើនគឺជាអាវុធដ៏ខ្លាំងក្លាក្នុងការប្រឆាំងនឹងភាពក្រីក្រ និងជាការប្តេជ្ញាចិត្តនៅក្នុងសកម្មភាពនយោបាយលើកកំពស់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច បង្វែរប្រភពធនធានទៅវិស័យដែលមានប្រសិទ្ធិភាពជាង និងសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចសកលលោក ។ ការបន្តពង្រឹងស្ថិរភាពនយោបាយសន្តិសុខក្នុងប្រទេស និងការរើបឡើងវិញនៃសេដ្ឋកិច្ចក្នុងតំបន់ បានជួយកម្ពុជាក្នុងការពង្រឹងដំណើរកែទំរង់អោយកាន់តែទូលំទូលាយ និងស៊ីជំរៅថែមទៀត ព្រមទាំងរក្សាបាននូវចលនាការសំរាប់អភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចប្រកបដោយចីរភាព ។

៦៥- កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងការងារគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងការអនុវត្តន៍កំណែទំរង់សារពើពន្ធយ៉ាងហ្មត់ចត់ បាននាំអោយផលិតផលក្នុងស្រុកសរុប (ផ.ស.ស) ប្រចាំឆ្នាំ កើនឡើងជាមធ្យម ៦,៨% ក្នុងចន្លោះឆ្នាំ ១៩៩៩-២០០៣ ដែលជានីតិកាលទី២ របស់រាជរដ្ឋាភិបាល ។ អតិផរណាប្រចាំឆ្នាំក្នុងរយៈកាលនេះមានអត្រាមធ្យមប្រមាណ ១,៦% ទាបជាងច្រើន បើធៀបនឹងអត្រា ៧,៥% ក្នុងចន្លោះឆ្នាំ ១៩៩៤-១៩៩៨ ដែលជានីតិកាលទី១របស់រាជរដ្ឋាភិបាល ។ ស្ថានភាពរូបិយវត្ថុ ក្នុងកំឡុង ៥ឆ្នាំកន្លងមក បានឆ្លុះបញ្ចាំងពីស្ថានភាពសារពើពន្ធ ដែលមានលក្ខណៈល្អប្រសើរ ។ ទុនបំរុងអន្តរជាតិជារូបិយវត្ថុបរទេសមានតំលៃស្មើនឹង ៣ ខែនៃការនាំចូល ។ អត្រាប្តូរប្រាក់មានស្ថិរភាព ធៀបនឹងដុល្លារអាមេរិក គឺប្រែប្រួលនៅក្នុងរង្វង់ប្រមាណ៣.៩០០រៀល ក្នុង១ដុល្លារអាមេរិក ពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០៣ ។

៦៦- **ក្នុងឆ្នាំ ២០០២** នៅពេលដែលកិច្ចប្រជុំពិគ្រោះយោបល់លើកទី ៦ ត្រូវបានរៀបចំឡើង ស្ថានភាពសេដ្ឋកិច្ចកម្ពុជាបានបង្ហាញអោយឃើញពីលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការបន្ត និងជំរុញចលនាករនៃការអនុវត្តន៍កម្មវិធីកំណែទំរង់ និងរបៀបវារៈនៃកិច្ចអភិវឌ្ឍន៍សង្គម ។ នៅក្នុងឆ្នាំ២០០២ ទោះបីជាកម្ពុជាជួបប្រទះនូវគ្រោះមហន្តរាយទឹកជំនន់ និងសេដ្ឋកិច្ចពិភពលោកមានការធ្លាក់ចុះ កម្ពុជានៅតែសំរេចបាននូវកំណើនសេដ្ឋកិច្ច ៧,៧% គិតតាមថ្លៃចរន្ត និង៥,៥% គិតតាមថ្លៃស្ថិរឆ្នាំ២០០០ ។ ក្នុងរយៈពេល២ឆ្នាំកន្លងទៅនេះ កំណើនផ.ស.សមានប្រមាណ ៥,៧% ក្នុងឆ្នាំ២០០១ និង៧%ក្នុងឆ្នាំ២០០០ ។ នៅក្នុងឆ្នាំ២០០២

អត្រាអតិផរណាបានរក្សានៅក្រោម៥% ។ អត្រាប្តូរប្រាក់មានស្ថិរភាពក្នុងកំរិត ៣.៩៥០រៀលក្នុងមួយដុល្លារអាមេរិក ។ ទុនបំរុងធនាគារសរុបមានការកើនឡើងពី៥៨៨លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០០១ ដល់៦៦៣លានដុល្លារអាមេរិកក្នុងឆ្នាំ២០០២ ដែលអាចធានាបានការនាំចូលចំនួន ៣,១ ខែ ។

៦៧- **នៅក្នុងឆ្នាំ ២០០៣** ទោះបីជាមានការលេចឡើងនៃជំងឺសារស៍នៅក្នុងតំបន់ បាតុកម្មហិង្សាប្រឆាំងស្ថានទូតថៃនៅក្រុងភ្នំពេញ សង្គ្រាមនៅអ៊ីរ៉ាក់ និងភាពមិនប្រាកដប្រជាក្នុងការបង្កើតរាជរដ្ឋាភិបាលថ្មី បន្ទាប់ពីការបោះឆ្នោតសាកល នាខែកក្កដា ឆ្នាំ២០០៣ កំណើនសេដ្ឋកិច្ចក្នុងឆ្នាំ២០០៣ បានបង្ហាញពីការរីកចំរើនលើសពីការប៉ាន់ស្មានទុក ។ ក្នុងឆ្នាំ២០០៣ សេដ្ឋកិច្ចកម្ពុជាមានកំណើន ៥,២% បើធៀបនឹងកំណើន ៥,៥% ក្នុងឆ្នាំ២០០២ ដោយសារកំណើននៃការនាំចេញសំលៀកបំពាក់ ការងើបឡើងវិញនៃការវិនិយោគទូទៅ និងទំនោរនៃកំណើនក្នុងវិស័យកសិកម្ម ។ ដោយឡែក វិស័យទេសចរណ៍បានធ្លាក់ចុះ ១០% ដោយសារផលប៉ះពាល់នៃបាតុកម្មនៅទីក្រុងភ្នំពេញ នាដើមឆ្នាំ២០០៣ សង្គ្រាមនៅអ៊ីរ៉ាក់ និងការទទួលរងឥទ្ធិពលពីការរីករាលដាលនៃជំងឺសារស៍ ដែលបានរាតត្បាតក្នុងតំបន់នាពេលនោះ ។ ការធ្លាក់ចុះនៃវិនិយោគផ្ទាល់ពីបរទេស ដោយសារភាពមិនប្រាកដប្រជាផ្នែកនយោបាយ ត្រូវបានប៉ះប៉ូវឡើងវិញដោយកំណើននៃវិនិយោគឯកជនក្នុងស្រុក និងចំណាយប្រើប្រាស់ក្នុងស្រុកខ្ពស់ ដែលជំរុញដោយកំណើននៃចំណាយសាធារណៈ ។ លើសពីនេះទៀត ភាពទន់ខ្សោយខាងផ្នែកសេវាកម្ម ត្រូវបានប៉ះប៉ូវដោយកំណើនខ្ពស់ក្នុងការនាំចេញរបស់វិស័យឧស្សាហកម្ម កាត់ដេរ ។ នៅក្នុងកំឡុងពេលនៃភាពមិនប្រាកដប្រជាបែបនេះ តំលៃទំនិញមានស្ថិរភាព ហើយអតិផរណា មានកំរិតត្រឹម ១,២% ដែលខុសគ្នាយ៉ាងខ្លាំង បើធៀបនឹងបទពិសោធន៍ក្នុងរយៈពេលបោះឆ្នោតឆ្នាំ១៩៩៨ ដែលនាពេលនោះអតិផរណាមានរហូតដល់ទៅ ១២% ។

៦៨- សមាសភាពនៃ ផ.ស.ស តាមវិស័យមានការប្រែប្រួលជាច្រើនក្នុងរយៈពេល៥ឆ្នាំកន្លងមក ដែលឆ្លុះបញ្ចាំងអំពីពិពិធកម្មនៃសេដ្ឋកិច្ចរបស់កម្ពុជា ។ វិស័យកសិកម្មក្នុងផ.ស.សបានថយចុះបន្តិច ទន្ទឹមនឹងការកើនឡើងរបស់ផ្នែកកម្មន្តសាល ។ គិតតាមថ្លៃបច្ចុប្បន្ន វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានប្រមាណ ៣៨,៨% នៃផ.ស.ស ក្នុងឆ្នាំ២០០៣ បើធៀបទៅនឹង៤៥,២% ក្នុងឆ្នាំ១៩៩៨ ។ ដោយសារគ្រោះរាំងស្ងួត ទឹកជំនន់អូសបន្លាយ និងការធ្លាក់ចុះផលិតផលព្រៃឈើ វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទធ្លាក់ចុះ ២,៧% នៅក្នុងឆ្នាំ២០០២ ដែលនៅក្នុងឆ្នាំ២០០១ វិស័យនេះមានកំណើនប្រមាណ២,២% ។ កសិផលថយចុះ ៥,៨% នៅពេលដែលផលិតផលបសុសត្វនិងត្រីបានកើនឡើងចំនួន១,២% និង ១,៣% ។ វិស័យរុក្ខកម្មបន្តធ្លាក់ចុះជាលំដាប់ ហើយបានធ្លាក់ចុះប្រមាណ៩,៣%ដោយសារការបង្ក្រាបការកាប់ព្រៃឈើខុសច្បាប់ ពោលគឺមានកំរិតទាបបំផុតគិតចាប់ពីឆ្នាំ១៩៩៣ ។ ប៉ុន្តែផលិតផលកសិកម្មចាប់ផ្តើមមានកំណើនឡើងវិញ ៩,៣% ក្នុងឆ្នាំ២០០៣ (គិតតាមថ្លៃបច្ចុប្បន្ន) ដែលនាំមុខដោយកំណើនកសិផល២៥,៣% បន្ទាប់ពីថយចុះកាលពីឆ្នាំ២០០២ ។ កំណើនកសិផលបានធ្វើអោយកម្ពុជាអាចរក្សាបាននូវភាពម្ចាស់ការក្នុងការផ្គត់ផ្គង់ស្រូវ និងរក្សាតំលៃម្ហូបអាហារអោយនៅកំរិតទាបបាន ។ បសុសត្វថយចុះបន្តិច ចំណែកការនេសាទថយចុះ ៦% ។

៦៩- ចំណែកជាវិស័យឧស្សាហកម្ម នៅតែបន្តស្ទុះឡើងយ៉ាងខ្លាំងពី ១៧,២% ក្នុងឆ្នាំ១៩៩៨ រហូតដល់ ២៦,៧% ក្នុងឆ្នាំ២០០៣ អាស្រ័យដោយ មានការរីកចំរើនខាងឧស្សាហកម្មវាយនភ័ណ្ឌ សំលៀកបំពាក់ និងស្បែកជើង ព្រមទាំងសកម្មភាពសំណង់ ។ វិស័យឧស្សាហកម្មមានកំណើន១៧,៧% ក្នុងឆ្នាំ២០០២ ដែលកាលពីឆ្នាំ២០០១ មានត្រឹម១២,៩% ។ វិស័យនេះគ្របដណ្តប់ដោយកម្មន្តសាលចំនួន ៧២,៧% និងសំណង់ ២៥,១% ។ តំលៃបន្ថែមខាងផ្នែកវាយនភ័ណ្ឌ សំលៀកបំពាក់ និងស្បែកជើងបានកើនឡើង ២៧% នៅក្នុងឆ្នាំ២០០២ ។ កំណើននេះទាបជាងកំណើននៅក្នុងឆ្នាំ២០០០ដែលមាន៦៣,៤% និងក្នុងឆ្នាំ២០០១ ដែលមាន២២,៧% ។ ការនាំចេញផលិតផលក្នុងប្រព័ន្ធអនុគ្រោះទូទៅ GSP ដែលភាគច្រើនជាសំលៀកបំពាក់ មានកំណើនឡើងពីកំរិតតិចតួចបំផុតនៅឆ្នាំ១៩៩៣ រហូតដល់៨៣,១% នៃការនាំចេញសរុបរបស់កម្ពុជាក្នុងឆ្នាំ២០០២ ។ ការបន្តកើនឡើងនៃការនាំចេញសំលៀកបំពាក់ ស្តែងឡើងតាមរយៈកំណើន១៥% ក្នុងឆ្នាំ២០០៣ ដែលជាមូលដ្ឋានសំរាប់ការកើនឡើងពីរខ្ទង់សំរាប់ផ្នែកកម្មន្តសាល ។ វិស័យសំណង់ក៏បានចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ចឆ្នាំ២០០២ ផងដែរ ដោយមានកំណើន ២៦,៨% បន្ទាប់ពីកំណើន ៩,៦% នៅឆ្នាំ២០០១ និង៣៦,៨% នៅឆ្នាំ២០០០ ។

៧០- ទោះបីជាសេវាកម្មទេសចរណ៍មានការរីកចំរើនគួរអោយកត់សំគាល់ ដោយសារការរីកលូតលាស់នៃវិស័យឧស្សាហកម្ម ភាគរយនៃវិស័យទេសចរណ៍ក្នុងផ.ស.ស បានធ្លាក់ចុះពី ៣៣,៦% នៅក្នុងឆ្នាំ១៩៩៨ មកនៅត្រឹម ៣៣,២% ប៉ុណ្ណោះក្នុងឆ្នាំ២០០៣ ។ វិស័យសេវាកម្មមានកំណើន ៤,៥% នៅឆ្នាំ២០០២ បើធៀបទៅនឹងកំណើន៤,២% ក្នុងឆ្នាំ២០០១ ។ វិស័យទេសចរណ៍បានរួមចំណែកគួរអោយកត់សំគាល់នៅក្នុងវិស័យសេវាកម្ម ដោយមានកំណើនភ្ញៀវបរទេសចំនួន ២៧,៩% ក្នុងឆ្នាំ២០០២ ។ តាមទិន្នន័យដែលទទួលបានពីក្រសួងទេសចរណ៍ ភ្ញៀវទេសចរណ៍អន្តរជាតិដែលមកទស្សនាកម្ពុជាក្នុងឆ្នាំ២០០២ មានចំនួន ៧៨៦.៥២៤នាក់ កើនឡើង៣០% ធៀបនឹងឆ្នាំ ២០០១ ។ កំណើនភ្ញៀវទេសចរណ៍បរទេសបានចូលរួមចំណែកដល់កំណើនឧស្សាហកម្មសណ្ឋាគារ និងភោជនីយដ្ឋាន (១១,៤%) ដឹកជញ្ជូននិងទូរគមនាគមន៍ (០,៨%) និងសេវាកម្មផ្សេងៗទៀត (១៦,៨ %) ។ ទោះបីជាមានភាពមិនប្រាកដប្រជាផ្នែកនយោបាយ សង្គ្រាមនៅអ៊ីរ៉ាក់ និងការរាតត្បាតនៃជំងឺសារស៍ក៏ដោយ វិស័យសេវាកម្មកើនឡើង១,៦% នៅឆ្នាំ២០០៣ ។ សណ្ឋាគារនិងភោជនីយដ្ឋានបានធ្លាក់ចុះ១០% ។ ទោះបីជាវិស័យទេសចរណ៍បានងើបឡើងវិញចាប់ពីពាក់កណ្តាលឆ្នាំ២០០៣មកក៏ដោយ ក៏គេសង្កេតឃើញថាចំនួនភ្ញៀវទេសចរណ៍បានថយចុះពី៧៨៦.៥២៤នាក់ក្នុងឆ្នាំ២០០២ មកនៅត្រឹម ៧០១.០១៤ នាក់ ក្នុងឆ្នាំ២០០៣ គឺធ្លាក់ចុះប្រមាណ១១% ។

## ២.៣- ស្ថានភាពរូបិយវត្ថុ និងសារពើពន្ធ

៧១- នៅក្នុងនីតិកាលទី២ ឆ្នាំ១៩៩៨-២០០៣ រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយរូបិយវត្ថុ និងសារពើពន្ធដោយជោគជ័យ ដោយរក្សាបានអតិផរណាមានកំរិតទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព ដើម្បីជាកិច្ចគាំទ្រដល់កំណើនសេដ្ឋកិច្ច ។ ស្ថានភាពរូបិយវត្ថុនៅក្នុងឆ្នាំ២០០៣ បានឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការរក្សាលំនឹងសារពើពន្ធ ទោះបីមានភាពមិនប្រាកដប្រជាខាងផ្នែកនយោបាយ ។ ការទូទាត់សាច់ប្រាក់របស់ធនាគារក្នុងឆ្នាំ២០០៣ ដែលវាស់ដោយ M2 បង្ហាញកំណើន១៥% បន្ទាប់ពីកំណើន ៣១%

នៅឆ្នាំ២០០២ ។ ប្រភពសំខាន់ៗនៃកំណើនរូបិយវត្ថុរួមមានកំណើន១៥% នៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសរបស់ប្រជាជនក្នុងប្រទេស និងកំណើន១៨%នៃរូបិយប័ណ្ណនៅក្រៅប្រព័ន្ធធនាគារ ។ ទ្រព្យសកម្មបរទេសសុទ្ធមានការកើនឡើងជាមធ្យម នៅពេលដែលទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ប្រព័ន្ធធនាគារបានកើនឡើងគួរអោយកត់សំគាល់ ។ កំណើនទ្រព្យសកម្មក្នុងស្រុកសុទ្ធ គឺដោយសារការស្ទុះឡើងនៃការផ្តល់ឥណទានដល់វិស័យឯកជន ដែលមានកំណើន ២៧% នៅក្នុងឆ្នាំ២០០៣ ស្មើនឹង៧២លានដុល្លារអាមេរិក ។

៧២- ស្ថិរភាពរូបិយវត្ថុត្រូវបានរំខានជាបណ្តោះអាសន្ន ក្នុងខែមេសា ឆ្នាំ២០០៣ ដោយសារការចេញផ្សាយប័ណ្ណរតនាគារ និងការបញ្ចេញប្រាក់រៀលនៅលើទីផ្សារ ដែលបណ្តាលអោយតម្លៃប្រាក់រៀលកម្ពុជា ធៀបនឹងប្រាក់ដុល្លារត្រូវធ្លាក់ចុះ ។ តំលៃប្រាក់រៀលបានថយចុះប្រមាណ២% ធៀបនឹងប្រាក់ដុល្លារ ហើយបន្ទាប់ ភ្លាមមកក៏មានស្ថិរភាពឡើងវិញត្រឹមកំរិត៤.០០០រៀលក្នុងមួយដុល្លារ ។ ស្ថិរភាពរូបិយវត្ថុបានមានលំនឹងឡើងវិញយ៉ាងឆាប់រហ័ស ហើយជាទូទៅអត្រាប្តូរប្រាក់មានកំរិតស្ថិរក្នុងឆ្នាំ២០០៣ គឺពី៣.៩៩៥ទៅ៤.០៥០រៀលក្នុងមួយដុល្លារអាមេរិក ។

៧៣- **ជញ្ជីងទូទាត់ :** សមតុល្យជញ្ជីងទូទាត់ជារួមមានលក្ខណៈមិនល្អប្រសើរនៅក្នុងឆ្នាំ ២០០៣ ដែលស្តែងតាមរយៈឱនភាពគណនីចរន្ត ដែលមានកំរិតកើនឡើងដល់១០,២%នៃផ. ស. ស ដោយសារផលប៉ះពាល់នៃតំលៃប្រេងខ្ពស់ ការថយចុះនៃភ្ញៀវទេសចរណ៍ និងវិនិយោគផ្ទាល់ពីបរទេសដែលបណ្តាលមកពីការីករាលដាលជម្ងឺសារស៍ និងភាពមិនប្រាកដប្រជាខាងផ្នែកនយោបាយ ។ កំណើនអតុល្យភាពសារពើពន្ធក៏មានការពាក់ព័ន្ធនឹងការធ្លាក់ចុះតំលៃរូបិយវត្ថុជាតិធៀបនឹងប្រាក់ដុល្លា២% ក្នុងចន្លោះខែមេសា- ឧសភា ឆ្នាំ២០០៣ផងដែរ ដោយទុនបំរុងផ្លូវការបានថយចុះ ១០% នៅខែកក្កដា ឆ្នាំ២០០៣ បន្ទាប់ពីមានអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជាដើម្បីគាំទ្ររូបិយវត្ថុជាតិ ។ ក្រោយពីការបោះឆ្នោតនៅខែកក្កដា ឆ្នាំ២០០៣ ការគ្រប់គ្រងស្ថានភាពសារពើពន្ធដែលមានលក្ខណៈល្អប្រសើរឡើងវិញ បានជំរុញអោយមានការហូរចូលឡើងវិញជាបណ្តើរៗនូវប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសពី៦៦៣លានដុល្លារអាមេរិកក្នុងឆ្នាំ២០០២ ដល់៧៣៧លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៣ ។ ដែលនាំអោយទុនបំរុងផ្លូវការដុល អាចរក្សាបាននៅក្នុងកំរិតប្រហាក់ប្រហែលនឹងឆ្នាំ២០០២ ។

៧៤- សមតុល្យក្រៅប្រទេសនឹងមានលក្ខណៈមិនសូវគាប់ប្រសើរខ្លះដែរក្នុងឆ្នាំ២០០៤ ដោយសារកំណើនថ្លៃប្រេងឆៅដែលបានកើនឡើងដល់ជាង៥០ដុល្លារអាមេរិកក្នុងមួយធុង ។ ប្រការនេះអាចនាំអោយឱនភាពគណនីចរន្តកើនឡើងពី១០,២%នៃផ. ស. សក្នុងឆ្នាំ២០០៣ ដល់១០,៨%នៃផ. ស. សក្នុងឆ្នាំ២០០៤ ។ ប៉ុន្តែជាមួយនឹងការរំពឹងទុកនៃកំណើនវិនិយោគផ្ទាល់ពីបរទេសដោយសារស្ថិរភាពនយោបាយល្អប្រសើរ ទុនបំរុងបរទេសដុលអាចនឹងកើនឡើងរហូតដល់៧៨២លានដុល្លារអាមេរិក ស្មើនឹង២,៨ខែនៃការនាំចូល នាចុងឆ្នាំ២០០៤នេះ ។

## តារាងទី ១ : សូចនាករសំខាន់ៗនៃម៉ាក្រូសេដ្ឋកិច្ច

| សូចនាករ | ១៩៩៨ | ១៩៩៩ | ២០០០ | ២០០១ | ២០០២ | ២០០៣ តួលេខបឋម |
|---|---|---|---|---|---|---|
| **<u>ផលិតផលក្នុងស្រុកសរុប</u>** (ពាន់លានរៀល គិតតាមថ្លៃបច្ចុប្បន្ន) | **១១.៦០៩** | **១៣,១៣១** | **១៣.៨១០** | **១៤.៥៤៤** | **១៥.៦៦៧** | **១៦.៧៤៨** |
| ផលិតផលក្នុងស្រុកសរុប (លានដុល្លារ គិតតាមថ្លៃបច្ចុប្បន្ន) | ៣.០៥៥ | ៣.៤៤៣ | ៣.៥៧៩ | ៣.៧០៧ | ៣.៩៩៦ | ៤.២០៤ |
| **<u>កំណើនផលិតផលក្នុងស្រុកសរុប</u>** (%) | **៣,៧%** | **១០,៨%** | **៧%** | **៥,៧%** | **៥,៥%** | **៥,២%** |
| **<u>អត្រានៃផលិតផលក្នុងស្រុកសរុប</u>** (គិតតាមថ្លៃបច្ចុប្បន្ន) | | | | | | |
| -កសិកម្ម (%) | ៤៥,២% | ៤២,៣% | ៣៧,៦% | ៣៥,៥% | ៣៣,៤% | ៣៤,៨% |
| -ឧស្សាហកម្ម (%) | ១៧,២% | ១៨,១% | ២២,១% | ២៤,២% | ២៦,៣% | ២៦,៧% |
| -សេវាកម្ម (%) | ៣៣,៦% | ៣៣,៩% | ៣៥,២% | ៣៤,៨% | ៣៤,២% | ៣៣,២% |
| ផលិតផលក្នុងស្រុកសរុបក្នុងប្រជាជនម្នាក់ (គិតជាដុល្លារ) | ២៥២ | ២៧៥ | ២៧៩ | ២៨២ | ២៩៦ | ៣០៦ |
| ចំនួនប្រជាជនសរុប (លាននាក់) | ១២,២ | ១២,៥ | ១២,៨ | ១៣,១ | ១៣,៥ | ១៣,៨ |
| អតិផរណាប្រាក់រៀល_(មធ្យមភាគប្រចាំឆ្នាំ%) | ១៤,៧០% | ៤% | -០,៨% | -០,៩% | -០,១% | ១,២% |
| អតិផរណាប្រាក់រៀល (ប្រៀបធៀបតាមត្រីមាស) | ១៤,៨% | ៤% | -០,៨% | ០,២% | ៣% | ១,២% |
| ទុនបំរុងអន្តរជាតិ (គិតជាលានដុល្លារ) | ៣២៣ | ៣៤៩ | ៤១១ | ៤៦៧ | ៥៦៧ | ៦៣៣ |
| ទុនបំរុងអន្តរជាតិ (គិតជាលានដុល្លារ) | ៣៩០ | ៤២២ | ៤៨៤ | ៥៤៨ | ៦៦៣ | ៧៣៧ |
| ទុនបំរុងអន្តរជាតិ (ចំនួនខែនាំចូល) | ៣,៦ | ២,៧ | ២,៦ | ២,៧ | ៣ | ២,៩ |
| សរុបថវិការបំរុង (គិតជា %នៃផ.ស.ស) | ២១,៣៥% | ២០,៨៦% | ១៨,០៣% | ១៨,៩៧% | ២០,១៧% | ១៧,៣៨% |
| អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំ | ៣.៧៧៤ | ៣.៨១៣ | ៣.៨៥៩ | ៣.៩២៤ | ៣.៩២១ | ៣.៩៨០ |
| អត្រាប្តូរប្រាក់មធ្យមចុងឆ្នាំ | ៣.៧៨០ | ៣.៧៧៥ | ៣.៨១០ | ៣.៩០០ | ៣.៩៣៥ | ៣.៩៨០ |
| វិនិយោគសរុប (លានដុល្លា) | ៦៥២,២ | ៧១៧,១ | ៦៤៥,៤ | ៧០៣,៣ | ៨០៦,៧ | ៧៣០,៧ |
| **វិនិយោគសាធារណៈ** | **១៦៥,២** | **១៩០,៥** | **២១៣,៦** | **២៨០,៧** | **៣៥៤,៤** | **២៩៨,៣** |
| -ហិរញ្ញប្បទានក្នុងប្រទេស | ៣០,២ | ៥៧,៤ | ៤៩,៤ | ៥៨,៣ | ៤០,៩ | ៤៨,៨ |
| -ហិរញ្ញប្បទានក្រៅប្រទេស | ១៣៥ | ១៣៣,១ | ១៦៤,២ | ២២២,៤ | ៣១៣,៥ | ២៤៩,៥ |
| **វិនិយោគឯកជន** | **៤៨៧** | **៥២៦,៦** | **៤៣១,៨** | **៤២២,៦** | **៤៥២,៣** | **៤៣២,៤** |
| -ហិរញ្ញប្បទានក្នុងប្រទេស | ២៦៤ | ៣០៥,៦ | ២៨៩,៨ | ២៨០,៦ | ៣១៣,៣ | ៣៥៥,១ |
| -ហិរញ្ញប្បទានក្រៅប្រទេស | ២២៣ | ២២១ | ១៤២ | ១៤២ | ១៣៩ | ៧៧,៣ |
| **<u>សរុបការវិនិយោគគិតជាភាគរយនៃផ.ស.ស</u>** | **២១,៣៥%** | **២០,៨៦%** | **១៨,០៣%** | **១៨,៩៧%** | **២០,១៧%** | **១៧,៣៨%** |
| - វិនិយោគសាធារណៈ | ៥,៤១% | ៥,៥៤% | ៥,៩៧% | ៧,៥៧% | ៨,៨៦% | ៧,១% |
| - វិនិយោគឯកជន | ១៥,៩៤% | ១៥,៣២% | ១២,០៦% | ១១,៤០% | ១១,៣១% | ១០,២៩% |

<u>ប្រភពពត៌មាន</u> : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ -ធនាគារជាតិនៃកម្ពុជា -វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ

៧៥- កិច្ចព្រមព្រៀងស្តីពីការកំណត់ពេលសងបំណុលជាមួយសហរដ្ឋអាមេរិកនិងរុស្ស៊ី អាចកាត់បន្ថយការទូទាត់សងរំលោះ ប៉ុន្តែក៏អាចបង្កើនកាតព្វកិច្ចសងការប្រាក់ដែរ ។ ការសងបំណុលបរទេសរបស់កម្ពុជានឹងមានផលប៉ះពាល់យ៉ាងខ្លាំងដល់ការអនុវត្តន៍ថវិកា និងគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ។ បន្ទាប់ពីបានកំណត់ពេលឡើងវិញអំពីកាតព្វកិច្ចសងបំណុលដែលបានខ្ចីមុនឆ្នាំ១៩៩៣ បំណុលបរទេសរបស់កម្ពុជាពីពេលបច្ចុប្បន្នរហូតឆ្នាំ២០០៨ អាចមានទំហំប្រហែលនឹង៤៨,៩%នៃផ.ស.ស ហើយសេវាបំណុលអាចស្មើនឹង ២,៦%នៃការនាំចេញទំនិញនិងសេវា ។ បន្ទុកសារពើពន្ធនៃបំណុលមានសភាពធូរធ្ងរ ដោយសារអនុបាតចំណូលធៀបនឹងផ.ស.សនៅមានកំរិតទាបនៅឡើយ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលត្រូវអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលបរទេសអោយបានប្រយ័ត្នប្រយែងបំផុត និងជៀសវាងដាច់ខាតនូវការទទួលហិរញ្ញប្បទានណាដែលគ្មានលក្ខណៈសម្បទាន ។

**ចំណូលថវិកា**

៧៦- នៅក្នុងនីតិកាលទី២ ឆ្នាំ១៩៩៨-២០០៣ រាជរដ្ឋាភិបាលទទួលបាននូវវឌ្ឍនភាពគួរអោយកត់សំគាល់ ក្នុងការអនុវត្តន៍កំណែទំរង់រចនាសម្ព័ន្ធ ពិសេសខាងផ្នែកគ្រប់គ្រងចំណូលនិងចំណាយសាធារណៈ ។ ចំណូលក្នុងស្រុកបានកើនឡើងពី៨,១%នៃផ.ស.សក្នុងឆ្នាំ១៩៩៨ រហូតដល់១០,៥%ក្នុងឆ្នាំ២០០១ និង១១,១%ក្នុងឆ្នាំ២០០២ ។ ក្នុងឆ្នាំ២០០២ ចំណូលក្នុងស្រុកបានកើនឡើងរហូតដល់១.៧៤៤,១ពាន់លានរៀល (៤៤៥,២លានដុល្លារអាមេរិក) ពី១.៥២៩,៤ពាន់លានរៀល(៣៨៩,៨លានដុល្លារអាមេរិក)ក្នុងឆ្នាំ២០០១ ដែលជាកំណើន១៤% ។ ចំណូលក្នុងស្រុកសំរាប់ឆ្នាំ២០០២រួមមានចំណូលពន្ធដារ១.២២៧,២ពាន់លានរៀល (៣១៣,២លានដុល្លារ) ចំណូលមិនមែនពន្ធ ៥០០,៦ពាន់លានរៀល (១២៧,៨លានដុល្លារ) និងចំណូលមូលធន១៦,៣ពាន់លានរៀល (៤,២លានដុល្លារ) ដែលបានមកពីឯកជនភាវូបនីយកម្ម និងប្រភពផ្សេងៗទៀត ។

៧៧- ក្នុងឆ្នាំ២០០៣ ចំណូលមិនមានកំណើនខ្លាំងដូចឆ្នាំមុនៗ ដោយសារតែភាពមិនប្រាកដប្រជាក្នុងកំឡុងពេលបោះឆ្នោត ការរាតត្បាតនៃជំងឺសារស៍ សង្គ្រាមនៅអ៊ីរ៉ាក់ និងអប្រសិទ្ធភាពនៃការប្រមូលចំណូល ។ ក្នុងឆ្នាំ ២០០៣ ចំណូលក្នុងស្រុកដែលប្រមូលបានមាន ១.៧៦៤,៦ពាន់លានរៀល (៤៤២,៩ លានដុល្លារ) ក្នុងនោះរួមមានចំណូលពន្ធដារ ១.២២០,១ពាន់លានរៀល (៣០៦,៣លានដុល្លារ) ចំណូលមិនមែនពន្ធ ៥១៣,១ពាន់លានរៀល (១២៨,៨លានដុល្លារ) និងចំណូលមូលធន ៣១,៤ពាន់លានរៀល (៧,៩លានដុល្លារ) ។

## តារាងទី ២ : សូចនាករនៃថវិការដ្ឋ

| | ១៩៩៨ ផែនការថវិកា | | ១៩៩៩ ផែនការថវិកា | | ២០០០ ផែនការថវិការ | | | ២០០១ ផែនការថវិកា | | | ២០០២ ផែនការថវិកា | | | ២០០៣ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | %ផសស | ពាន់លានរៀល | %ផសស | ពាន់លានរៀល | លានដុល្លា | %ផសស | ពាន់លានរៀល | លានដុល្លា | %ផសស | ពាន់លានរៀល | លានដុល្លា | %ផសស | ពាន់លានរៀល | លានដុល្លា | %ផសស |
| **ចំណូលក្នុងប្រទេស** | **៩៣៨,៥** | **៨,១%** | **១.៣២៩,៨** | **១០,១%** | **១.៤២២,៩** | **៣៦៨,៧** | **១០,៣%** | **១.៥២៩,៤** | **៣៨៩,៨** | **១០,៥%** | **១.៧៤៤,១** | **៤៤៥,២** | **១១,១%** | **១.៧៦៤,៦** | **៤៤២,៩** | **១០,៥%** |
| **១. <u>ចំណូលពន្ធដារ</u>** | ៦៧៩,៤ | ៥,៩% | ៩៦២,៧ | ៧,៣% | ១.០៤០,៣ | ២៦៩,៦ | ៧,៥% | ១.០៩៦,៦ | ២៧៩,៥ | ៧,៥% | ១.២២៧,២ | ៣១៣,២ | ៧,៨% | ១.២២០,១ | ៣០៦,៣ | ៧,៣% |
| ពន្ធចំពោះ | ៥៩ | ០,៥% | ៨២,៧ | ០, ៦% | ១៣៥, ៦ | ៣៥,១ | ១% | ១៤០,៤ | ៣៥,៨ | ១% | ១៣១,៧ | ៣៣,៦ | ០,៨% | ១៥០,៤ | ៣៧,៨ | ០,៩% |
| ពន្ធមិនចំពោះ | ២៤៤,១ | ២,១% | ៤៤៦,៦ | ៣,៤% | ៥១៤,២ | ១៣៣,២ | ៣,៧% | ៥៨០,៥ | ១៤៧,៩ | ៤% | ៦៧១,៧ | ១៧១,៤ | ៤,៣% | ៦៧៤,៥ | ១៦៩,៥ | ៤% |
| ចំណូលពន្ធគយ | ៣៧៦,៣ | ៣,២% | ៤៣៣,៤ | ៣,៣% | ៣៩០,៥ | ១០១,២ | ២,៨% | ៣៧៥,៧ | ៩៥,៧ | ២,៦% | ៤២៣,៨ | ១០៨,២ | ២,៧% | ៣៩៥,២ | ៩៩,២ | ២,៤% |
| **២. <u>ចំណូលមិនមែនពន្ធដារ</u>** | ២២៥,៩ | ១,៩% | ៣៥៣,៤ | ២,៧% | ៣៥៣,៣ | ៩១,៦ | ២,៦% | ៤២៣,៨ | ១០៨ | ២,៩% | ៥០០,៦ | ១២៧,៨ | ៣,២% | ៥១៣,១ | ១២៨,៨ | ៣,១% |
| ចំណូលព្រៃឈើ | ២២,៨ | ០,២% | ៣៦,៣ | ០,៣% | ៤១ | ១០,៦ | ០,៣% | ២៩,៣ | ៧,៥ | ០,២% | ១៤,៩ | ៣,៨ | ០,១% | ៦,៧ | ១,៧ | ០,០៤% |
| **៣. <u>ចំណូលមូលធន</u>** | ៣៣,២ | ០,៣% | ១៣,៧ | ០,១% | ២៩,៣ | ៧,៦ | ០,២% | ៩ | ២,៣ | ០,១% | ១ ៦,៣ | ៤,២ | ០,១% | ៣១,៤ | ៧,៩ | ០,២% |
| រចនាសម្ព័ន្ធពន្ធដារ : % នៃសរុបពន្ធ | | | | | | | | | | | | | | | | |
| - ពន្ធដារ | ៣០៣,១ | ៤៤,៦% | ៥២៩,៣ | ៥៥% | ៦៤៩,៨ | | ៦២,៥% | ៧២០,៩ | | ៦៥,៧% | ៨០៣,៤ | | ៦៥,៥% | ៨២៤,៩ | | ៦៧,៦% |
| - ពន្ធគយ | ៣៧៦,៣ | ៥៥,៤% | ៤៣៣,៤ | ៤៥% | ៣៩០,៥ | | ៣៧,៥% | ៣៧៥,៧ | | ៣៤,៣% | ៤២៣,៨ | | ៣៤,៥% | ៣៩៥,២ | | ៣២,៤% |
| **ចំណាយ** | **១.៥៥៧,១** | **១៣,៤១%** | **១.៨២៣,៨** | **១៣,៨៩%** | **២.០៣៩,៧** | **៥២៨,៦** | **១៤,៧៧%** | **២.៥១៦,៩** | **៦៤១,៤** | **១៧,៣១%** | **២.៩៦៣,២** | **៧៥៦,៣** | **១៨,៩១%** | **២.៩៤៦,៥** | **៧៣៩,៦** | **១៧,៤៩%** |
| **១. <u>ចំណាយចរន្ត</u>** | ៩២៩,៤ | ៨,០១% | ១.០៩៦ | ៨,៣៥% | ១.២១៥,៥ | ៣១៥ | ៨,៨% | ១.៤១៥,៦ | ៣៦០,៨ | ៩,៧៣% | ១,៥៧៤,៩ | ៤០២ | ១០,០៥% | ១.៧៥៨,១ | ៤៤១,៣ | ១០,៥% |
| - ការពារប្រទេសនិងសន្តិសុខ | ៤៥៣,៨ | ៣,៩១% | ៤៦៨,១ | ៣,៥៦% | ៤៥០,៧ | ១១ ៦,៨ | ៣,២៦% | ៤១៧,៣ | ១០៦,៣ | ២,៨៧% | ៤០៦,៧ | ១០៣,៨ | ២,៦% | ៤១១ | ១០៣,២ | ២,៤៥ % |
| - រដ្ឋបាលស៊ីវិល | ៤៧៥,៦ | ៤,១% | ៦២៧,៩ | ៤,៧៨% | ៧៦៤,៨ | ១៩៨,២ | ៥,៥៤% | ៩៩៨,៣ | ២៥៤,៤ | ៦,៨៦% | ១.១ ៦ ៨៩,២ | ២៩៨,២ | ៧,៤៦% | ១.៣៤៧,១ | ៣៣៨,១ | ៨,០៤% |
| **២. <u>ចំណាយមូលធន</u>** | **៦២៧,៧** | **៥,៤១%** | **៧២៧,៨** | **៥,៥៤%** | **៨២៤,២** | **២១៣,៦** | **៥,៩៧%** | **១.១០១,៣** | **២៨០,៧** | **៧,៥៧%** | **១.៣៨៨,៣** | **៣៥៤,៣** | **៨,៨៦%** | **១.១៨៨,៤** | **៨៣,៧** | **១,៩៩%** |
| - ហិរញ្ញប្បទានវិនិយោគក្នុងស្រុក | ១១៦,២ | ១% | ២២៣,៦ | ១,៧% | ៣០៣,៤ | ៧៨,៦ | ២,២% | ២៨៣,០ | ៧២,១ | ១,៩៥% | ៣៣៨,៤ | ៨៦,៤ | ២,១៦% | ៣៣៣,៦ | ៨៣,៧ | ១,៩៩% |
| - ហិរញ្ញប្បទានវិនិយោគក្រៅប្រទេស | ៥១១,៥ | ៤,៤១% | ៥០៤,២ | ៣,៨៤% | ៥២០,៨ | ១៣៥ | ៣,៧៧% | ៨១៨,៣ | ២០៨,៥ | ៥,៦៣% | ១.០៤៩,៩ | ២៦៨ | ៦,៧% | ៨៥៤,៨ | ២១៤,៦ | ៥,១% |
| **ឱនភាព/អតិរេក** | | | | | | | | | | | | | | | | |
| **- សរុប** | **៦១៨,៦** | **៥,៣%** | **៤៩៤** | **៣,៨%** | **៦១៦,៨** | **១៥៩,៨** | **៤,៥%** | **៩៨៧,៥** | **២៥១,៧** | **៦,៨%** | **១.២១៩,១** | **៣១១,២** | **៧,៨%** | **១.១៨១,៩** | **២៩៦,៧** | **៧%** |
| **- ក្នុងនោះ ចរន្ត** | ៩,១ | ០,០៨% | ២៣៣,៨ | ១,៧៨% | ២០៧,៤ | ៥៣,៧៤ | ១,៥% | ១១៣,៨ | ២៩ | ០,៧៨% | ១ ៦៩,២ | ៤៣,១៩ | ១,០៨% | ៦,៥ | ១,៦៣ | ០,០៤% |
| **ផ.ស.ស/ពាន់លានរៀល** | **១១.៦០៩** | | **១៣.១៣១** | | **១៣.៨១០** | | | **១៤.៥៤៤** | | | **១៥.៦៦៧** | | | **១៦.៧៤៨** | | |
| **ផ.ស.សលានដុល្លាអាមេរិក** | **៣.០៥៥** | | **៣.៤៣៧,៤** | | **៣.៥៧៨,៦** | | | **៣.៧០៦,៤** | | | **៣.៩៩៨,៧** | | | **៤.២០៣,៨** | | |

<u>ប្រភព</u> :ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៧៨- ក្នុងពេលដែលចំណូលក្នុងស្រុកបានកើនឡើងពី១.៧៤៤,១ពាន់លានរៀលក្នុងឆ្នាំ២០០២ ដល់១.៧៦៤,៦ ពាន់លានរៀលក្នុងឆ្នាំ២០០៣ (កំណើនប្រមាណ១%) ចំណូលក្នុងស្រុកគិតជាភាគរយនៃផ.ស.សថយចុះពី១១,១% ក្នុងឆ្នាំ២០០២ មកនៅត្រឹមតែ១០,៥%ប៉ុណ្ណោះក្នុងឆ្នាំ២០០៣ ។ ចំណូលពន្ធដារបានថយចុះពី ៧,៨%នៃផ.ស.សក្នុងឆ្នាំ២០០២ មកនៅត្រឹម៧,៣%ក្នុងឆ្នាំ២០០៣ នៅពេលដែលចំណូលមិនមែនពន្ធដារក៏ថយចុះពី ៣,២%នៃផ.ស.ស ក្នុងឆ្នាំ២០០២ មកនៅត្រឹម៣,១% ក្នុងឆ្នាំ២០០៣ផងដែរ (តារាងទី២) ។

៧៩- ក្នុងរយៈពេល៥ឆ្នាំកន្លងមក រាជរដ្ឋាភិបាលបានចាត់វិធានការមួយចំនួន ដើម្បីបង្កើនចំណូល និងពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ វិធានការទាំងនេះរួមមាន ÷

- ពង្រឹងការអនុវត្តន៍អាករ ១០% លើសេវាកំសាន្ត ។
- អនុវត្តប្រព័ន្ធតែមប្រើសំរាប់ពន្ធលើបារី ។
- បង្កើតការិយាល័យអ្នកបង់ពន្ធទំហំធំ ដោយអនុញ្ញាតិអោយក្រុមហ៊ុនធំៗអាចបង់ពន្ធជាមូលប្បទានប័ត្រ ឬដោយបង្វែរចូលគណនីរតនាគារជាតិនៅធនាគារជាតិកម្ពុជា ។
- កាត់បន្ថយចំនួនអត្រាពន្ធគយពី ១២% មក ៤% ហើយកាត់បន្ថយអត្រាពន្ធគយអតិបរមា មកត្រឹម ៣៥% ដោយតំលើងអត្រាអាករពិសេស ក្នុងក្របខ័ណ្ឌនៃកំណែទំរង់អត្រាពន្ធគយ ។
- ចាត់ទុករាល់ការលក់ប្រេងម៉ាហ្សូតជាការលក់ចុងក្រោយសំរាប់អាករលើតំលៃបន្ថែម ។
- ពង្រីកមូលដ្ឋានអាករលើតំលៃបន្ថែមតាមរយៈការបញ្ចូលសហគ្រាសចំនួន ១៥០ទៀត សំរាប់ប្រមូលពន្ធតាមរបបពិត ។
- ពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នដែលពាក់ព័ន្ធ ដើម្បីបង្ក្រាបអំពើរត់ពន្ធ ។
- ពង្រឹងនិងជំរុញនីតិវិធីប្រមូលបំណុលពន្ធ និងមិនមែនសារពើពន្ធ ដែលមិនបានបង់តាមកាលកំណត់ ជាពិសេស បំណុលទូរគមនាគមន៍ និងបំណុលពីការជួលទ្រព្យសម្បត្តិរដ្ឋ ។
- ពង្រឹងការប្រមូលចំណូលទិដ្ឋាការ និងការដាក់អោយអនុវត្តទិដ្ឋាការស្អិត ។
- ពិនិត្យឡើងវិញនូវកិច្ចសន្យាលើការលក់សំបុត្រចូលទស្សនាប្រាង្គប្រាសាទអង្គរ ។
- បង្កើតក្រុមការងារមួយរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបណ្តាក្រសួងពាក់ព័ន្ធ ដើម្បីរៀបចំនូវយន្តការត្រួតពិនិត្យ និងតាមដានការជួលទ្រព្យសម្បត្តិរដ្ឋ និងបង្កើនការខិតខំប្រឹងប្រែងក្នុងការប្រមូលថ្លៃឈ្នួលអោយបានទាន់ពេលវេលា ជាពិសេសថ្លៃឈ្នួលដែលនៅមិនទាន់បង់កន្លងមក ។
- រៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ។

**ចំណាយសាធារណៈ**

៨០- ក្នុងនីតិកាលទី២ រាជរដ្ឋាភិបាលបានអនុវត្តកម្មវិធីកំណែទំរង់សារពើពន្ធ និងការគ្រប់គ្រងថវិកាយ៉ាងហ្មត់ចត់ ដោយរក្សាចំណាយនៅក្នុងក៏រិតចំណូលដែលប្រមូលបាន ដើម្បីធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។ ការអនុវត្តន៍

គោលនយោបាយសារពើពន្ធជាគន្លឹះយ៉ាងសំខាន់ដើម្បីធានាស្ថិរភាពថ្លៃ ។ វិធានការខាងក្រោមនេះត្រូវបានអនុវត្តដោយរាជរដ្ឋាភិបាល ដើម្បីកែលំអការគ្រប់គ្រងចំណាយសាធារណៈ÷

- បន្តលុបឈ្មោះមន្ត្រីខ្មោច និងទាហានខ្មោចចេញពីបញ្ជីបើកប្រាក់បៀវត្សរ៍របស់មន្ត្រីរាជការស៊ីវិល និងបញ្ជីបើកប្រាក់បៀវត្សរ៍យោធា និងសន្តិសុខ ។
- ចាត់វិធានការនានា ដើម្បីធានាអោយការបើកផ្តល់ថវិកាបានគ្រប់គ្រាន់ទៅតាមគំរោងថវិកាសំរាប់ចំណាយក្នុងវិស័យសង្គមកិច្ចនិងសេដ្ឋកិច្ច ដូចជា សុខាភិបាល អប់រំ កសិកម្ម និងអភិវឌ្ឍន៍ជនបទ ស្របតាមការវិភាជន៍ថវិកា ។
- អនុវត្តកម្មវិធីសកម្មភាពអាទិភាពដើម្បីបង្កើនការបើកផ្តល់សាច់ប្រាក់សំរាប់វិស័យអាទិភាព ។
- បង្កើនការវិភាជន៍ចំណាយសំរាប់ការវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធជនបទ ។
- ជួសជុល ថែទាំ ផ្លូវជាតិ និងស្ពាន ព្រមទាំងពង្រឹងសមត្ថភាពស្ថាប័ន ។

៨១- ក្នុងកំឡុងពេលប្រាំឆ្នាំកន្លងមក រាជរដ្ឋាភិបាលបានប្រឹងប្រែងកំរិតចំណាយអោយនៅក្រោមគោលដៅដែលអាចជួយកាត់បន្ថយហិរញ្ញប្បទានពីប្រភពក្នុងស្រុក ។ ក្នុងកំឡុងពេលនោះ ចំណាយចរន្តសរុបមានកំរិតទាបជាងចំណូលដែលប្រមូលបាន គិតទាំងន័យនាមករណ៍ និងជាភាគរយនៃផ.ស.ស ។ ចំណាយចរន្តសរុបមាន ៨% នៃផ.ស.ស នៅក្នុងឆ្នាំ ១៩៩៨ មាន៨,៤% ក្នុងឆ្នាំ១៩៩៩ មាន៨,៨% ក្នុងឆ្នាំ២០០០ មាន៩,៧% ក្នុងឆ្នាំ២០០១ មាន ១០,១% ក្នុងឆ្នាំ២០០២ និងមាន ១០,៥% ក្នុងឆ្នាំ២០០៣ ។ ចំណែកឯចំណូលប្រមូលបានមាន ៨,១% នៃផ.ស.ស ក្នុងឆ្នាំ ១៩៩៨ មាន១០,១% ក្នុងឆ្នាំ១៩៩៩ មាន ១០,៣% ក្នុងឆ្នាំ ២០០០ មាន ១០,៥% ក្នុងឆ្នាំ២០០១ មាន ១១,១% ក្នុងឆ្នាំ២០០២ និង ១០,៥% ក្នុងឆ្នាំ២០០៣ ។

៨២- សមាសធាតុនៃចំណាយសំរាប់កិច្ចការពារប្រទេស សន្តិសុខ និងរដ្ឋបាលស៊ីវិល មានការប្រែប្រួលជាច្រើនក្នុងរយៈពេល៥ឆ្នាំ ១៩៩៨-២០០៣ ។ ចំណាយសាធារណៈសំរាប់កិច្ចការពារប្រទេស និងសន្តិសុខ បានថយចុះពី៣,៩% នៃ ផ.ស.ស ក្នុងឆ្នាំ១៩៩៨ មកត្រឹម ២,៤៥% នៃផ.ស.ស ក្នុងឆ្នាំ២០០៣ រីឯចំណាយសំរាប់រដ្ឋបាលស៊ីវិលត្រូវបានកើនឡើងពី៤,១% នៃផ.ស.សក្នុងឆ្នាំ១៩៩៨ ដល់៨% ក្នុងឆ្នាំ២០០៣ ។

៨៣- ក្នុងឆ្នាំ២០០២ ចំណាយសរុបមានប្រមាណ ២.៩៦៣,២ពាន់លានរៀល (៧៥៦,៣លានដុល្លារអាមេរិក) ដែលរួមមានចំណាយចរន្ត ១.៥៧៤,៩ពាន់លានរៀល (៤០២លានដុល្លារអាមេរិក) និងចំណាយមូលធន ១.៣៨៨,៣ពាន់លានរៀល (៣៥៤,៣លានដុល្លារអាមេរិក) ។

៨៤- ក្នុងឆ្នាំ២០០២ ចំណាយចរន្ត១.៥៧៤,៩ពាន់លានរៀលសំរាប់រដ្ឋបាលស៊ីវិល ការពារនិងសន្តិសុខ និងការប្រាក់លើកំចី មានសមាសភាគដូចខាងក្រោម÷

- ចំណាយសំរាប់រដ្ឋបាលស៊ីវិលសរុបមាន ១.១៤០,៥ពាន់លានរៀល (២៩០,១លានដុល្លារអាមេរិក) ត្រូវជា៧២,៤%នៃចំណាយចរន្តសរុប ។

- ចំណាយការពារប្រទេស និងសន្តិសុខសរុប ៤០៦,៧ពាន់លានរៀល (១០៣,៨លានដុល្លារអាមេរិក) ស្មើនឹង ២៥,៨%នៃចំណាយចរន្តសរុប ។
- ការប្រាក់លើកំចីស្មើ ២៧,៦ពាន់លានរៀល (៧លានដុល្លារអាមេរិក) ត្រូវជា ១,៨% នៃចំណាយចរន្តសរុប ។

៨៥- បំរែបំរួលនៃសមាសភាគចំណាយចរន្តសរុបសំរាប់ឆ្នាំ២០០២ មានដូចខាងក្រោម ÷
- ចំណាយលើការពារជាតិនិងសន្តិសុខថយចុះ ២,៥% ពីកំរិតឆ្នាំ២០០១ ។
- ចំណាយសំរាប់រដ្ឋបាលទូទៅថយចុះ ៧,៥% ពីកំរិតឆ្នាំ២០០១ ។
- ចំណាយសំរាបវិស័យសង្គមកិច្ចបានកើនឡើង ២៧,២% លើសឆ្នាំ២០០១ ។ ក្រសួងដែលត្រូវបញ្ចូលក្នុងវិស័យនេះមានក្រសួងពត៌មាន សុខាភិបាល អប់រំ វប្បធម៌និងវិចិត្រសិល្បៈ បរិស្ថាន សង្គមកិច្ចការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ធម្មការនិងកិច្ចការសាសនា និង ក្រសួងកិច្ចការនារីនិងអតីត យុទ្ធជន ។ ចំណាយសំរាប់ក្រសួងអប់រំ យុវជន និងកីឡាបានកើនឡើង ៣៦,៥% ។ ចំណែកចំណាយសំរាប់ក្រសួងសុខាភិបាលបានកើនឡើង ២៦,២% ពីកំរិតឆ្នាំ ២០០១ ។
- ចំណាយសំរាបវិស័យសេដ្ឋកិច្ចបានកើនឡើង ៦,៦% លើសកំរិតឆ្នាំ២០០១ ។

៨៦- ក្នុងឆ្នាំ២០០៣ ចំណាយសរុបមានប្រមាណ ២.៩៤៦,៥ពាន់លានរៀល ស្មើនឹង ៧៣៩,៦លានដុល្លាអាមេរិក ដែលរួមមានចំណាយចរន្ត ១.៧៥៨,១ពាន់លានរៀល (៤៤១,៣លានដុល្លារអាមេរិក) និងចំណាយមូលធន ១.១៨៨,៤ពាន់លានរៀល (២៩៨,៣លានដុល្លារអាមេរិក) ។

៨៧- សមាសភាគនៃចំណាយចរន្ត ១.៧៥៨,២ពាន់លានរៀល សំរាប់រដ្ឋបាលស៊ីវិល ការពារនិងសន្តិសុខ និងការប្រាក់លើកំចី មានសមាសភាគដូចខាងក្រោម ÷
- ចំណាយសំរាប់រដ្ឋបាលស៊ីវិលសរុបមាន ១.៣៤៧,១ពាន់លានរៀល (៣៣៨,១លានដុល្លារអាមេរិក) ត្រូវជា៧៤,៧%នៃចំណាយចរន្តសរុប ។
- ចំណាយការពារប្រទេស និងសន្តិសុខសរុប ៤១១ពាន់លានរៀល (១០៣,២លានដុល្លារអាមេរិក) ស្មើនឹង ២៣,៤% នៃចំណាយចរន្តសរុប ។
- ការប្រាក់លើកំចីស្មើ ៣៤,១ពាន់លានរៀល (៨,៦លានដុល្លារអាមេរិក) ត្រូវជា ១,៩%នៃចំណាយចរន្តសរុប ។

៨៨- បំរែបំរួលនៃសមាសភាគចំណាយចរន្តសរុបសំរាប់ឆ្នាំ២០០៣ មានដូចខាងក្រោម ÷
- ចំណាយលើការពារជាតិនិងសន្តិសុខកើនឡើងចំនួ ១,១% ពីកំរិតឆ្នាំ ២០០២ ។
- ចំណាយសំរាប់រដ្ឋបាលទូទៅកើនឡើង ៣៣,៧% ពីកំរិតឆ្នាំ ២០០២ ។

- ចំណាយសំរាប់វិស័យសង្គមកិច្ចបានកើនឡើងចំនួន៥,៦% ពីកំរិតឆ្នាំ ២០០២ ។ ចំណាយសំរាប់ក្រសួងអប់រំ យុវជន និងកីឡាបានកើន ៣,៧% ចំណែកចំណាយសំរាប់ក្រសួងសុខាភិបាលកើន ៥,២%។
- ចំណាយសំរាប់វិស័យសេដ្ឋកិច្ចកើន ៤,៩% ពីកំរិតឆ្នាំ ២០០២ ។

៨៩- ចំណាយសាធារណៈសំរាប់ឆ្នាំ ២០០៣ កើនឡើងដោយសារចំណាយសំរាប់ការបោះឆ្នោតសាកលមានកំរិតខ្ពស់លើសផែនការគ្រោងទុក និងត្រូវបង់សំណងអំពីការខូចខាតដល់សហគ្រាសថៃ ដែលបណ្តាលមកពីបាតុកម្មហិង្សាកាលពីដើមឆ្នាំ២០០៣ ។ ចំណាយខ្ពស់នៅពេលដែលចំណូលប្រមូលបានទាបជាងគំរោងបានធ្វើអោយឱនភាពសារពើពន្ធ (មិនគិតប្រាក់កំចី) កាន់តែមានគម្លាតធំរហូតដល់៧%នៃផ. ស. សក្នុងឆ្នាំ ២០០៣ ។ ក្នុងជំហានកែលំអអតុល្យភាពនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងចាត់វិធានការដូចខាង ក្រោម ÷

- ពង្រឹងតួនាទីនៃគណៈកម្មការគ្រប់គ្រងសាច់ប្រាក់ ។
- បង្កើតក្រុមដឹកនាំការងារសំរាប់ការប្រមូលចំណូលមិនមែនសារពើពន្ធ ដើម្បីធានាការបង់ចំណូលនេះអោយបានពេញលេញចូលថវិកាជាតិ ។
- បង្កើនការប្រមូលចំណូល ដោយពង្រឹងរដ្ឋបាលពន្ធគយ និងពន្ធដារ ប្រយុទ្ធប្រឆាំងនឹងការរត់ពន្ធ និងស្ការ ឬរឹតបន្តឹងការទារបំណុលពន្ធ ។
- រឹតត្បិតចំណាយថវិកាជាមូលធន និងចរន្តរបស់រាជរដ្ឋាភិបាល តាមការកំណត់ក្នុងថវិកាជាតិ ។
- ការបង្កើនតំលាភាពក្នុងការចុះហត្ថលេខាលើកិច្ចសន្យា ។
- ការកំហិតចំណាយជាមូលធន ដែលត្រូវធ្វើហិរញ្ញប្បទានក្នុងស្រុក ។
- អនុវត្តដោយប្រសិទ្ធភាពនូវកំណែទំរង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

៩០- ការសំរេចនូវស្ថិរភាពសារពើពន្ធតាមរយៈការកាត់បន្ថយឱនភាពបឋមអោយស្ថិតនៅក្រោម២%នៃផ. ស. ស គឺជាបញ្ហាប្រឈមរបស់រាជរដ្ឋាភិបាលកម្ពុជា ។ រាជរដ្ឋាភិបាលបានពិចារណាឃើញថាការបន្ថយចំណាយក្នុងផ្នែកដែលមិនមែនជាអាទិភាព និងការស្វែងរកចំណូលបន្ថែមគឺជាប្រការចាំបាច់ ជាពិសេសប្រសិនបើចង់អោយបំណុលក្នុងស្រុកថយចុះក្នុងរយៈពេលមធ្យម ។ ដើម្បីកាត់បន្ថយឱនភាពថវិកា រាជរដ្ឋាភិបាលនឹងខិតខំកំហិតចំណាយអោយនៅត្រឹមកំរិតទាប ក្នុងខណៈដែលចំណូលត្រូវបង្កើនអោយបានយ៉ាងហោចណាស់ដល់១១,៩%នៃផ. ស. សក្នុងឆ្នាំ២០០៤ ។ ប្រការនេះទាមទារការអនុវត្តន៍វិធានការពន្ធថ្មីទៀត ដើម្បីរកចំណូលបន្ថែមអោយបានសមមូលនឹង០,៨%នៃផ. ស. ស ។

## ២.៤- ការអភិវឌ្ឍន៍តាមវិស័យ

### ២.៤.១ វិស័យសង្គមកិច្ច

| វិស័យសង្គមកិច្ច |
|---|
| - អប់រំ |
| - សុខាភិបាល |

**វិស័យអប់រំ**

៩១- នៅក្នុងនីតិកាលទី២ ឆ្នាំ១៩៩៨-២០០៣ រាជរដ្ឋាភិបាលនៅតែប្តេជ្ញាចិត្ត បង្កើនការវិនិយោគនៅលើវិស័យអប់រំនិងបណ្តុះបណ្តាល ដែលមានសារៈសំខាន់សំរាប់ធ្វើអោយសំរេចបាន នូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងការលើកកំពស់ផលិតភាព ។ រាជរដ្ឋាភិបាលបានបង្កើនការ ធ្វើវិភាជន៍ថវិកាចរន្តសំរាប់វិស័យ អប់រំក្នុងកំរិតមួយគួរអោយកត់សំគាល់ក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ គឺកើនពី១៣,៦%នៃចំណាយចរន្តសរុបរបស់រាជរដ្ឋាភិបាលក្នុងឆ្នាំ២០០០ ដល់១៨,៣%ក្នុងឆ្នាំ២០០៣ ហើយ មានទិសដៅបង្កើនដល់២០%នាឆ្នាំ២០០៥ ។ ទន្ទឹមនេះ ជាង៦០%នៃថវិកាវិភាជន៍សំរាបវិស័យអប់រំត្រូវបាន សំរេចផ្តល់អោយទៅការអប់រំមូលដ្ឋាន ដោយមានការយកចិត្តទុកដាក់លើចំណាយទាំងឡាយដែលមាន ប្រយោជន៍ដល់ការកាត់បន្ថយភាពក្រីក្រ ។ វិស័យអប់រំសំរេចបាននូវវឌ្ឍនភាពគួរអោយកត់សំគាល់ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ដោយបានពង្រីកនូវលទ្ធភាពទទួលសេវាអប់រំមូលដ្ឋានបានស្មើៗគ្នា និងការលើកកំពស់គុណភាពអប់រំ មូលដ្ឋាន ព្រមទាំងការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានដែលបានវិភាជន៍សំរាបវិស័យអប់រំ ។

៩២- កំណែទំរង់វិស័យអប់រំរបស់រាជរដ្ឋាភិបាលដែលបានចាប់ផ្តើមនាពាក់កណ្តាលឆ្នាំ១៩៩៩ បាននាំទៅដល់ការរៀបចំគោលនយោបាយអប់រំ និងក្របខ័ណ្ឌយុទ្ធសាស្ត្រដែលកំណត់នូវអាទិភាពនៃការអភិវឌ្ឍន៍ជារួមរបសវិស័យ គោលដៅសំរាប់អនុវិស័យ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបសវិស័យអប់រំសំរាប់ដំណាក់កាលឆ្នាំ២០០១-២០០៥ ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០១-២០០៥ ត្រូវបានរៀបចំឡើងដោយមានការពិគ្រោះយោបល់ជាមួយសហគមន៍អ្នកផ្តល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ហើយផែនការនេះត្រូវបានអនុម័តនៅក្នុងខែមេសា ឆ្នាំ២០០១ ។ ផែនការនេះបានលើកឡើងអំពីការកំណត់ដំណាក់កាលនៃគោលនយោបាយជាអាទិភាពក្នុងវិស័យអប់រំ និងកំណែទំរង់ជាយុទ្ធសាស្ត្រ សំរាប់រយៈពេល៥ឆ្នាំខាងមុខ ។ កម្មវិធីគាំទ្រវិស័យអប់រំ ២០០១-២០០៥ ត្រូវបានរៀបចំឡើង ក្នុងគោលបំណងដាក់បញ្ចូលគ្នានូវកម្មវិធីអាទិភាពនៃចំណាយមូលធននិងចំណាយចរន្ត ដើម្បីធ្វើអោយសំរេចបាននូវទិសដៅរយៈពេលមធ្យមរបស់គោលនយោបាយនិងយុទ្ធសាស្ត្រ ដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ។ ក្រុមការងារចំនួន១៤នៅក្នុងក្រសួងអប់រំ យុវជន និងកីឡា បានចូលរួមពាក់ព័ន្ធនៅក្នុងដំណើរការរៀបចំកម្មវិធីគាំទ្រវិស័យអប់រំ ។ ការពិនិត្យមើលឡើងវិញនិងការវាយតម្លៃរួមគ្នាលើផែនការយុទ្ធសាស្ត្រវិស័យអប់រំ/កម្មវិធីគាំទ្រវិស័យអប់រំ ២០០១-២០០៥ ត្រូវបានធ្វើឡើងនៅក្នុងខែមិថុនា ឆ្នាំ២០០១ ។ លទ្ធផលនៃការវាយតំលៃត្រូវបានដាក់បញ្ចូលទៅក្នុងឯកសារសំរេចរបស់កម្មវិធីគាំទ្រវិស័យអប់រំ ២០០១-២០០៥ ហើយត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការធ្វើផែនការលំអិតរបស់ក្រសួងអប់រំ យុវជន និងកីឡា សំរាប់អនុវត្តក្នុងឆ្នាំ២០០២ ។ បន្ទាប់ពីនេះ ក្រសួងអប់រំ យុវជន និងកីឡា ដោយមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ បាន

ធ្វើការពិនិត្យមើលឡើងវិញរួមគ្នាចំនួន២ដង នូវកម្មវិធីគាំទ្រវិស័យអប់រំ ក្នុងខែកញ្ញា ឆ្នាំ២០០២ និងក្នុងខែឧសភា ឆ្នាំ២០០៣ ។

៩៣- ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីទ្រទ្រង់វិស័យអប់រំ បានផ្តល់ផងដែរនូវគោលនយោបាយដ៏មានសារៈសំខាន់ និងក្របខ័ណ្ឌអនុវត្តន៍មួយសំរាប់លើកស្ទួយជីវភាពជនក្រីក្រ ដោយប្រើប្រាស់ការអប់រំជាកត្តាសំខាន់ ក្នុងការលើកកំពស់ការអភិវឌ្ឍន៍សង្គមកិច្ច និងកំណើនសេដ្ឋកិច្ច ។ យុទ្ធសាស្ត្រសំខាន់ៗបានផ្តោតលើការកាត់បន្ថយ«អន្ទាក់»នៃភាពក្រីក្រក្នុងការទទួលបានការអប់រំ តាមរយៈការកាត់បន្ថយបន្ទុកចំណាយលើគ្រួសារក្រីក្រ ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំបានទទួលស្គាល់តួនាទីសំខាន់នៃការបណ្តុះបណ្តាលក្មេងស្រីក្នុងការលើកស្ទួយសុខភាពគ្រួសារនិងអាហារូបត្ថម្ភ និងក្នុងការរួមវិភាគទានដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ រាជរដ្ឋាភិបាលបន្តប្រឹងប្រែងសំរេចទិសដៅ«អប់រំសំរាប់ទាំងអស់គ្នា» តាមរយៈការធានាសមធម៌ក្នុងការអប់រំមូលដ្ឋានរយៈពេល៩ឆ្នាំសំរាប់កុមារគ្រប់រូប និងការបង្កលក្ខណៈសម្បត្តិអនុគ្រោះនានាដើម្បីអោយកូនចៅប្រជាពលរដ្ឋក្រីក្រមានលទ្ធភាពចូលសិក្សា ជាពិសេសតាមរយៈការពង្រឹង និងពង្រីកគ្រឹះស្ថានសិក្សាសាធារណៈ និងការផ្តល់អាហារូបករណ៍សំរាប់សិស្សនិងនិស្សិតក្រីក្រ ។ អាហារូបករណ៍ត្រូវបានផ្តល់អោយនិស្សិតមកពីគ្រួសារក្រីក្រ កុមារពិការ កុមារមកពីក្រុមជនជាតិភាគតិច កុមារនៃក្រុមជនងាយរងគ្រោះ ពិសេសសិស្សស្រីដែលងាយរងគ្រោះនិងរស់នៅតំបន់ដាច់ស្រយាល ។ ក្នុងពេលដែលលទ្ធភាពសិក្សានៅបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិបានកើនឡើង តំរូវការសិក្សាថ្នាក់ក្រោយការអប់រំមូលដ្ឋានបានកើនឡើងដែរ ។ ការផ្តល់កាលានុវត្តភាពដល់ជនក្រីក្រអោយចូលរៀននៅមធ្យមសិក្សាទុតិយភូមិ ការសិក្សានិងបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេស និងថ្នាក់ឧត្តមសិក្សា គឺជាអាទិភាពនៃគោលនយោបាយអភិវឌ្ឍន៍វិស័យអប់រំ ។

៩៤- តាមរយៈការអនុវត្តន៍ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០១-២០០៥ វឌ្ឍនភាពត្រូវបានកត់សំគាល់នៅក្នុងការកែលំអលទ្ធភាពក្នុងការទទួលសេវាអប់រំបានស្មើៗគ្នា ការលើកកំពស់គុណភាព និងប្រសិទ្ធភាពនៃវិស័យអប់រំ ការពង្រឹងនិងការអភិវឌ្ឍន៍សមត្ថភាពស្ថាប័នសំរាប់ការធ្វើវិមជ្ឈការប្រព័ន្ធអប់រំ និងការពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីកៀងគរធនធានសំរាប់វិស័យអប់រំ ។

៩៥- នៅក្នុងឆ្នាំ២០០០ រាជរដ្ឋាភិបាលបានចាប់ផ្តើមកម្មវិធីសកម្មភាពអាទិភាព ដើម្បីវិភាជន៍ថវិកាជូនក្រសួងបួន គឺ÷ ក្រសួងអប់រំ សុខាភិបាល កសិកម្ម និងអភិវឌ្ឍន៍ជនបទ ។ ក្នុងករណីវិស័យអប់រំ កម្មវិធីសកម្មភាពអាទិភាពត្រូវបានផ្តោតជាដំបូងនៅលើកំរិតបឋមសិក្សានៅក្នុងខេត្ត-ក្រុងចំនួន១០ ហើយបន្ទាប់មកទៀតត្រូវបានអនុវត្តនៅគ្រប់ភូមិសិក្សាទាំងអស់ក្នុងទូទាំងប្រទេស ។ គំនិតផ្តួចផ្តើមនេះបានសំរេចលទ្ធផលគួរជាទីកត់សំគាល់ ។ ជាលទ្ធផល ការចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សាបានកើនឡើងពី ២,១លាននាក់ នៅឆ្នាំសិក្សា១៩៩៨-៩៩ ដល់ ២,៧លាននាក់ នៅឆ្នាំសិក្សា២០០២-២០០៣ ។ ចំនួនសិស្សនៅមធ្យមសិក្សាបឋមភូមិបានកើនឡើងពី ២២៦.០៥៧នាក់ នៅឆ្នាំសិក្សា១៩៩៨-១៩៩៩ ដល់ ៤១៦.០០០នាក់ ក្នុងឆ្នាំ

សិក្សា២០០២-២០០៣ កើនឡើង ៨៤% ។ ចំនួនសិស្សមធ្យមសិក្សាទុតិយភូមិវិញ កើនឡើងបាន ៥៦% ក្នុងរយៈពេលដូចគ្នា ។ អត្រាឆ្លងពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ បានកើនឡើងពី ៧៤,៣% ក្នុងឆ្នាំ ១៩៩៨-១៩៩៩ ដល់ ៨៣,២% ក្នុងឆ្នាំ ២០០២-២០០៣ ហើយអត្រាឆ្លងពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិ បានកើនឡើងពី ៣៩,៤% ក្នុងឆ្នាំសិក្សា១៩៩៨-១៩៩៩ ដល់ ៥៩,២% ក្នុងឆ្នាំសិក្សា ២០០២-២០០៣ ។

៩៦- ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តរបស់សាលារៀន បានរីកដុះដាលយ៉ាងខ្លាំងនៅក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ គឺចំនួនសាលារៀនបានកើនឡើងពី ១៣.០១១ខ្នង ដោយមានថ្នាក់រៀនចំនួន ៤៧.៨២៣បន្ទប់ ក្នុងឆ្នាំសិក្សា ១៩៩៨-១៩៩៩ ដល់ ១៤.៧១៧ខ្នង ដោយមានថ្នាក់រៀន ៥៦.៨០៤បន្ទប់ ក្នុងឆ្នាំសិក្សា២០០២-២០០៣ ។

៩៧- **បឋមសិក្សា** : ដូចដែលបានលើកឡើងពីខាងលើ ការចុះឈ្មោះចូលរៀននៅបឋមសិក្សា បានបន្តកើន ឡើងពី ២,១លាននាក់ ក្នុងឆ្នាំសិក្សា១៩៩៨-១៩៩៩ ដល់ ២,៧លាននាក់ ក្នុងឆ្នាំសិក្សា២០០២-២០០៣ ។ នៅក្នុងដំណាក់កាលនេះ ការកើនឡើងនៃចំនួនកូនសិស្សចូលរៀនបឋមសិក្សាក្នុងឃុំក្រីក្របំផុត ត្រូវបានចាត់ទុកថាមានកំរិតខ្ពស់ជាងនៅក្នុងឃុំដែលមានជាង ។ ការចុះឈ្មោះរបស់ក្មេងស្រីនៅបឋមសិក្សាមានកំណើនខ្ពស់ជាងក្មេងប្រុស (ក្មេងស្រី២៧% ក្មេងប្រុស២២% ចាប់តាំងពីឆ្នាំ១៩៩៩) ដែលជួយកាត់បន្ថយគំលាតយេនឌ័រនៅក្នុងអត្រាចុះឈ្មោះចូលរៀន ។ និយាយសរុបមក គំលាតនៃភាពក្រីក្រ/ការអប់រំក្នុងកំរិតបឋមសិក្សាបានថយចុះ ចំណែកផែនការយុទ្ធសាស្ត្រវិស័យអប់រំមានឥទ្ធិពលយ៉ាងខ្លាំងក្នុងការកែលំអសមធម៌ក្នុងការទទួលបានការអប់រំសំរាប់ជនក្រីក្រ ។ កត្តាមួយចំនួនដែលបានរួមចំណែកធ្វើអោយមានជោគជ័យនេះរួមមាន÷ការលុបបំបាត់ការបង់ប្រាក់វិភាគទានរបស់អាណាព្យាបាលនៅដើមឆ្នាំសិក្សា និមួយៗ និងការផ្តល់សំភារៈឧបទេសសិក្សាបន្ថែម និងការឧបត្ថម្ភលើកទឹកចិត្តដោយផ្តោតទៅលើភាពក្រីក្រ (និងយេនឌ័រ) ដូចជាកម្មវិធីផ្តល់ចំណីអាហារនៅតាមសាលាក្នុងបណ្តាឃុំដែលក្រីក្របំផុត ។ ទោះបីជាអត្រាត្រួតថ្នាក់ និងអត្រាបោះបង់សាលាបានថយចុះ ដែលធ្វើអោយចំណាយសាធារណៈ និងចំណាយរបស់អាណាព្យាបាលសិស្សថយចុះ វឌ្ឍនភាពនៅមានកំរិតនៅឡើយ ។ ដំណោះស្រាយអំពីបញ្ហាទាំងនេះគឺនៅតែជាអាទិភាពមួយ ដោយប្រើប្រាស់យុទ្ធសាស្ត្ររួមផ្សំដូចជា បន្តកាត់បន្ថយបន្ទុកចំណាយ ការបង្កើនទព្វសំភារៈនិងបរិក្ខារឧបទេសសំរាប់តំបន់ខ្វះខាត លើកកំពស់គុណភាព និងវិធានការបង្កើនប្រសិទ្ធភាព ។ លើសពីនេះ សាលាបឋមសិក្សានៅតាមឃុំក្រីក្របំផុត នៅតែមិនទាន់មានបុគ្គលិកគ្រប់គ្រាន់នៅឡើយ ។

៩៨- **មធ្យមសិក្សា** : អាគារមធ្យមសិក្សាបឋមភូមិកើនឡើងពី៣៦៧ខ្នងដល់៤៨៦ខ្នង ចំណែកសិស្សានុសិស្សបានកើនឡើងពី២៨៣.៥៧៨នាក់ក្នុងឆ្នាំសិក្សា២០០០-២០០១ ដល់៤៥៩.៩៨៦នាក់ក្នុងឆ្នាំសិក្សា២០០៣-២០០៤ ដែលជាកំណើន៦២% ។ ក្នុងរយៈពេលដូចគ្នានេះ ចំនួនសិស្សស្រីបានកើនឡើងពី១០៤.៨១៦នាក់ ដល់ ១៩២.៧៣០នាក់ ដែលជាកំណើន៨៤% ។ បើទោះបីជាអត្រាចុះឈ្មោះចូលរៀនសរុបបានកើនឡើងពី២៧% ដល់៣៩% អត្រាចុះឈ្មោះចូលរៀនសរុបកើនឡើងយឺតៗពី១៧%ដល់២១% ។ អត្រាចុះឈ្មោះចូលរៀន

នៅតាមតំបន់ដាច់ស្រយាលនៅមានកំរិតទាបនៅឡើយ ដោយមានសិស្សតែ២.៨០០នាក់ប៉ុណ្ណោះដែលចូលរៀនថ្នាក់ទី៧ដល់ទី៩ ។ អាគារសិក្សាសំរាប់មធ្យមសិក្សាទុតិយភូមិបានកើនឡើងពី១៥១ខ្នង ក្នុងឆ្នាំសិក្សា ២០០០-២០០១ ដល់២១២ខ្នង ក្នុងឆ្នាំសិក្សា២០០៣-២០០៤ ។ អត្រាចុះឈ្មោះសំរាប់មធ្យមសិក្សាទុតិយភូមិកើនឡើងពី១០៥.០៨៦នាក់ ក្នុងឆ្នាំសិក្សា ២០០០-២០០១ ដល់១៥៣.៧៥៨នាក់ ក្នុងឆ្នាំសិក្សា ២០០៣-២០០៤ ។ អត្រាចុះឈ្មោះចូលរៀនសរុបមានលក្ខណៈស្ថេរប្រមាណ៧-៨% ក្នុងកំឡុងពេលបួនឆ្នាំកន្លងមកនេះ ។ សិស្សស្រី និងសិស្សជនជាតិភាគតិចមាន៣៧%នៃចំនួនសិស្សសរុប ។ ឧបសគ្គសំខាន់មួយគឺកង្វះសាលាមធ្យមសិក្សានៅតាមស្រុកនិងឃុំក្រីក្រទាំងនោះ ។ មានឃុំប្រមាណ១.០០០ឃុំ ខ្វះខាតអាគារសិក្សាសំរាប់ថ្នាក់ទី៧-៩ និងសាលាមធ្យមសិក្សាទុតិយភូមិសំរាប់ថ្នាក់ទី១០-១២ ។ អាទិភាពសំខាន់មួយគឺត្រូវពង្រីកការសាងសង់សាលាមធ្យមសិក្សាអោយបានឆាប់ និងជាបន្ទាន់នៅតាមតំបន់ខ្វះខាត (ជាពិសេសសាលាមធ្យមសិក្សាបឋមភូមិ) ។ យុទ្ធសាស្រ្តគួបផ្សំនានាត្រូវផ្តោតលើការផ្តល់ការលើកទឹកចិត្តតាមរយៈអាហារូបករណ៍ដោយផ្តោតជាសំខាន់ទៅលើអ្នកក្រីក្រ (ព្រមទាំងអាហារូបករណ៍ដល់សិស្សស្រី) ។

៩៩- **ឧត្តមសិក្សា** : រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់បន្ថែមទៀតទៅលើការគ្រប់គ្រងគុណភាពនៃការបណ្តុះបណ្តាលនៅឧត្តមសិក្សា ។ គណៈកម្មាធិការវាយតម្លៃសំរាប់ឧត្តមសិក្សាត្រូវបានបង្កើតឡើង ដើម្បីត្រួតពិនិត្យមើលគុណភាពនៃការបណ្តុះបណ្តាល សំដៅធានានិសិត្សបញ្ចប់ការសិក្សាថ្នាក់ឧត្តមប្រកបដោយគុណភាព និងមានគុណភាពគ្រប់គ្រាន់សំរាប់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចរបស់ប្រទេស ។ ចំនួននិសិត្សឧបត្ថម្ភខ្លួនឯង បានកើនឡើងពី ៣២.០០០នាក់ ក្នុងឆ្នាំសិក្សា២០០១-២០០២ ដល់ ៤៣.០០០នាក់ ក្នុងឆ្នាំសិក្សា២០០២-២០០៣ ។

១០០- **ការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ**: ការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈរបស់ផ្នែកសាធារណៈនិងឯកជននៅក្នុងគ្រប់ខេត្ត-ក្រុង ក៏បានកើនឡើងផងដែរ ។ ការកើនឡើងនេះគឺបណ្តាលមកពីការជំរុញលើកទឹកចិត្តអោយមានការចូលរួមពីផ្នែកឯកជន នៅក្នុងការគ្រប់គ្រង និងការផ្តល់សេវាអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ប្រកបដោយ គុណភាព និងប្រសិទ្ធភាព ។ ការចុះឈ្មោះចូលរៀននៅគ្រឹះស្ថានសិក្សានានារបស់ក្រសួង មានប្រមាណ ៥.៥០០-៦.០០០នាក់ ហើយការចុះឈ្មោះនៅក្នុងប្រព័ន្ធបណ្តុះបណ្តាលឯកជន និងអង្គការ ក្រៅរដ្ឋាភិបាល មានប្រមាណ ៨.០០០នាក់ ។ និសិត្សបញ្ចប់ការសិក្សាពីការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបណ្តុះបណ្តាលមុខវិជ្ជាឯកទេសនៅក្នុងឆ្នាំសិក្សា១៩៩៨-១៩៩៩ មានចំនួន ១.០៥៦នាក់ ក្នុងកំរិតមធ្យម និង៧.៦៨៧នាក់ ក្នុងកំរិតបឋម ។ នៅក្នុងឆ្នាំសិក្សា២០០២-២០០៣ ចំនួនទាំងនេះមាន ÷ ២.២០២នាក់ នៅកំរិតមធ្យម និង ១.៣៨៨នាក់ នៅកំរិតបឋម ។

**វិស័យសុខាភិបាល**

១០១- **ការផ្តល់សេវាសុខាភិបាលសាធារណៈ** : ចាប់តាំងពីឆ្នាំ១៩៩៨មក វិស័យសុខាភិបាលមានការរីកចំរើនយ៉ាងច្រើនគួរអោយចាប់អារម្មណ៍ ទាំងការផ្តល់សេវាសុខាភិបាលជាមូលដ្ឋាន ទាំងកម្មវិធីប្រយុទ្ធនឹងជំងឺឆ្លងនិងការលើកកំពស់សុខភាពស្ត្រី និងកុមារ ។ ចំនួនមណ្ឌលសុខភាព (ម.ស.) ដែលមានធនធាន និងសមត្ថភាពអាចផ្តល់សេវាសំណុំសកម្មភាពអប្បបរមា (Minimun Package of Activities-MPA) បានកើនឡើងពី៣៨៦កន្លែងនាឆ្នាំ១៩៩៨ ដល់៨២៣កន្លែងនាឆ្នាំ២០០៣ ។ ចំនួនមន្ទីរពេទ្យបង្អែក (ម.ប.)នៅតាមស្រុកដែលអាចធ្វើការវះកាត់ធំបន្ទាន់ បានកើនពី៣កន្លែងកាលពីឆ្នាំ១៩៩៨ ដល់១៥កន្លែងក្នុងឆ្នាំ ២០០៣ ។ ជោគជ័យរបស់កម្មវិធីប្រយុទ្ធនឹងជំងឺឆ្លងនានា មានជាអាទិ៍ការកើនឡើងនៃអត្រាព្យាបាលជាសះស្បើយ និងអត្រាស្រាវជ្រាវរបស់ជំងឺរបេង ការថយចុះនៃអត្រាមនុស្សពេញវ័យផ្ទុកមេរោគហ៊ីវ និងការថយចុះរបស់អត្រាឈឺ-ស្លាប់នៃជំងឺគ្រុនចាញ់ គ្រុនឈាម កញ្ជ្រិល អាសន្នរោគ ។ ជំងឺគ្រុនស្វិតដៃជើងត្រូវបានបំបាត់ពីប្រទេសកម្ពុជាតាំងពីឆ្នាំ២០០០មក ។ នារីមានផ្ទៃពោះដែលបានទទួលការពិនិត្យផ្ទៃមុនសំរាលយ៉ាងតិចពីរដងបានកើនពី១៩%នាឆ្នាំ១៩៩៨ ដល់៣៧%នាឆ្នាំ២០០៣ ។ អត្រាស្ត្រីរៀបការកំពុងប្រើប្រាស់វិធីពន្យារកំណើតទំនើបរបស់វិស័យសាធារណៈ បានកើនពី៩,៧% នាឆ្នាំ១៩៩៨ ដល់ ១៩,៩% នាឆ្នាំ២០០៣ ។ កុមារអាយុ១២-៥៩ខែចំនួន ៧០% បានទទួលវីតាមីនអា យ៉ាងតិច១ដង នៅក្នុងឆ្នាំ២០០៣ ។

១០២- កម្មវិធីសាកល្បងសំរាប់ពង្រីកសេវាសុខភាពបឋមនៅក្នុងស្រុកប្រតិបត្តិសេវាសុខាភិបាលចំនួន៥ ក្នុងភាពជាដៃគូជាមួយផ្នែកឯកជន (អង្គការក្រៅរដ្ឋាភិបាល) តាមរយៈការចុះកិច្ចសន្យា បានបង្ហាញអំពីជោគជ័យដ៏ធំធេង ។ ការវាយតំលៃលើកម្មវិធីសាកល្បងបានបង្ហាញថា ការចុះកិច្ចសន្យាបានធ្វើអោយការផ្តល់សេវាសុខភាពបឋមមានការកើនឡើងពី២ទៅ៣ដង ហើយនៅក្នុងស្រុកប្រតិបត្តិ សេវាសុខាភិបាលមួយចំនួន ចំណាយខាងសុខភាពរបស់គ្រួសារក្រីក្របានថយចុះ៦០-៧០% នៅក្នុងរយៈពេល៣ឆ្នាំនៃគំរោងសាកល្បង (១៩៩៨-២០០១) ។ លើសពីនេះទៀត ចំណាយចរន្តប្រចាំឆ្នាំជាមធ្យមក្នុងការចុះកិច្ចសន្យា ស្ថិតនៅក្នុងរង្វង់ដែលបានរំពឹងទុក ។ កម្មវិធីនេះត្រូវបានគ្រោងពង្រីកដល់ស្រុកប្រតិបត្តិសេវាសុខាភិបាល ចំនួន១១ នៅក្នុងដំណាក់កាលឆ្នាំ២០០៤-២០០៧ ដោយមានជំនួយឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍មួយចំនួន ។

១០៣- ក្នុងការជំរុញការអនុវត្តន៍លិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យសុខាភិបាល អនុក្រឹត្យស្តីពីសីលធម៌របស់គ្រូពេទ្យត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០០៣ ។ ក្រុមប្រឹក្សាគ្រូពេទ្យជាតិកម្ពុជា និងក្រុមប្រឹក្សាគ្រូពេទ្យថ្នាក់តំបន់ចំនួនប្រាំ ដែលបានបង្កើតឡើងក្នុងពេលថ្មីៗនេះ បានចាប់ផ្តើមផ្សព្វផ្សាយ និងអនុវត្តក្របខ័ណ្ឌច្បាប់ និងនីតិវិធីជាច្រើន ។ សេចក្តីព្រាងក្របខ័ណ្ឌច្បាប់ស្តីពីការត្រួតពិនិត្យថ្នាំជក់ត្រូវបានដាក់ជូនគណៈរដ្ឋមន្ត្រីនៅក្នុងខែមិថុនា ឆ្នាំ២០០៣ ។ ការណែនាំស្តីពីទីកន្លែងហាមជក់បារី ត្រូវបានរៀបចំឡើង និងចែកចាយដល់គ្រប់ទីភ្នាក់ងារផ្តល់សេវាសុខាភិបាលទាំងអស់ ។ ទន្ទឹមនេះ ក៏កំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការផ្សព្វផ្សាយការចិញ្ចឹមទារកជំនួសទឹកដោះ ។

១០៤- **ការផ្លាស់ប្តូរឥរិយាបថនិង ការទ្រាំទ្រទំនាក់ទំនង** : ដើម្បីបង្កើនការយល់ដឹងអំពីការអនុវត្តន៍ល្អផ្នែកសុខភាព និងអាហារូបត្ថម្ភ ការរៀបចំយុទ្ធនាការមហាជនត្រូវបានអនុវត្តតាមរយៈការផ្សព្វផ្សាយតាមទូរទស្សន៍និងវិទ្យុ គួបផ្សំនឹងការផ្សព្វផ្សាយតាមផ្ទាំងរូបភាពតាមទីកន្លែងសាធារណៈ និងក្រដាសបិទ-បត់ ។ កូនសៀវភៅស្តីពីការការពារសុខភាពក្នុងគ្រាទឹកជំនន់ និងកូនសៀវភៅស្តីពីច្បាប់និងនីតិក្រមសីលធម៌វិជ្ជាជីវៈត្រូវបានផ្សព្វផ្សាយនៅគ្រប់ខេត្ត-ក្រុង។

១០៥- **ការលើកកំពស់គុណភាព** : ការបង្កើតនូវការិយាល័យធានាគុណភាព ដែលមានទស្សនៈវិស័យច្បាស់លាស់អំពីបេសកកម្ម និងតួនាទីរបស់ក្រសួងសុខាភិបាល បានបង្កើតនូវមូលដ្ឋានគ្រឹះសំរាប់បង្កើនគុណភាពនៃការផ្តល់សេវា ។ សមិទ្ធផលគួរអោយកត់សំគាល់ក្នុងឆ្នាំ២០០៣ រួមមានការចាប់ផ្តើមអនុវត្តវប្បធម៌គុណភាពនៅក្រសួងសុខាភិបាល និងការបង្កើតឡើងនូវក្រុមការងារសំរាប់ការលើកកំពស់គុណភាព ។ ផែនការសកម្មភាពសំរាប់ឆ្នាំ២០០៤-២០០៥ ត្រូវបានរៀបចំឡើង រួមមានការកំណត់នូវឧបករណ៍សំរាប់វាយតម្លៃការពេញចិត្តរបស់អតិថិជន ការវាយតម្លៃអំពីគុណភាពរបស់មន្ទីរពេទ្យ និងគោលការណ៍ណែនាំសំរាប់ការទទួលស្គាល់/ការចេញអាជ្ញាប័ណ្ណដល់សេវាសុខាភិបាលសាធារណៈ និងឯកជន ។ ខេត្តចំនួនពីរកំពុងអនុវត្តសាកល្បងជាមួយក្រុមធានាគុណភាព នៅកំរិតមន្ទីរសុខាភិបាលខេត្ត ។

១០៦- **ការអភិវឌ្ឍន៍ធនធានមនុស្ស** : អាទិភាពខ្ពស់បំផុតនៃការអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យសុខាភិបាល គឺការបណ្តុះបណ្តាលសំរាប់ទ្រទ្រង់ការអភិវឌ្ឍន៍និងដំណើរការរបស់មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ដើម្បីផ្តល់សេវាសុខាភិបាលជាមូលដ្ឋាន ។ ចំនួននិស្សិតដែលបញ្ចប់ការបណ្តុះបណ្តាលនៅសាលា បច្ចេកទេសសុខាភិបាលទាំង៥(គិលានុបដ្ឋាក ឆ្មប អ្នកបច្ចេកទេសមន្ទីរពិសោធន៍)បានកើនឡើងពី១០៩នាក់ក្នុងឆ្នាំ១៩៩៨ ដល់៥៥៩នាក់ ក្នុងឆ្នាំ២០០៣ ។ តាមរយៈកម្មវិធីបណ្តុះបណ្តាលផ្នែកវះកាត់បឋម វេជ្ជបណ្ឌិតទូទៅចំនួន៣៦នាក់ ត្រូវបានបណ្តុះបណ្តាលជាគ្រូពេទ្យវះកាត់ ដើម្បីទៅធ្វើការនៅតាមមន្ទីរពេទ្យបង្អែកជនបទនៅក្នុងដំណាក់កាលឆ្នាំ១៩៩៨-២០០៣ ។ សិក្ខាកាមចំនួន១២.០០០នាក់ ដែលមកពីមណ្ឌលសុខភាពបានចូលរួមវគ្គវិក្រឹតការស្តីពីសំណុំសកម្មភាពអប្បបរមា នៅក្នុងដំណាក់កាលដូចគ្នានេះដែរ ។ ការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងដល់មន្ត្រីថ្នាក់ខេត្ត-ស្រុក បានសំរេចតាមគោលដៅឆ្នាំ២០០៣ គឺ៨៤%នៃការិយាល័យប្រតិបត្តិការ និង ៧៥%នៃមន្ទីរសុខាភិបាលខេត្ត-ក្រុង ។

១០៧- **ហិរញ្ញប្បទានវិស័យសុខាភិបាល** : រាជរដ្ឋាភិបាលបានបង្កើនការធ្វើវិភាជន៍ថវិកាសំរាប់វិស័យសុខាភិបាលដល់២២៤%នៅក្នុងដំណាក់កាលឆ្នាំ១៩៩៨-២០០៣ ។ ទោះបីជាមានកំណើនគួរអោយកត់សំគាល់ក៏ការធ្វើវិភាជន៍ថវិកាចរន្តមានត្រឹមតែ២-៣ដុល្លារអាមេរិកសំរាប់ចំណាយក្នុងមនុស្សម្នាក់តែប៉ុណ្ណោះ ។ គេបានប៉ាន់ស្មានថា កំរិត១២ដុល្លារអាមេរិកក្នុងមនុស្សម្នាក់ គឺជាចំណាយចាំបាច់សំរាប់ការផ្តល់សេវាសុខាភិបាលបឋម ។ ដោយសារតម្លាតក្នុងការធ្វើហិរញ្ញប្បទាននេះ វិស័យសុខាភិបាលនៅតែពឹងផ្អែកលើជំនួយ

បរទេស ទាំងក្នុងរយៈពេលខ្លីទាំងក្នុងរយៈពេលមធ្យម ដើម្បីអភិវឌ្ឍន៍សមត្ថភាពសមស្របក្នុងការផ្តល់សេវាចាំបាច់ ។

១០៨- **ការអភិវឌ្ឍន៍ស្ថាប័ន** : ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល២០០៣-២០០៧ ត្រូវបានរៀបចំឡើងដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយនឹងដៃគូអភិវឌ្ឍន៍ ។ ផែនការនេះត្រូវបានដាក់ចេញអោយអនុវត្តដោយសម្តេចនាយករដ្ឋមន្ត្រី ក្នុងខែសីហា ឆ្នាំ២០០២ ។ នៅក្នុងខែមេសា ឆ្នាំ២០០៣ ការវាយតំលៃលើការអនុវត្តន៍ក្នុងវិស័យសុខាភិបាលលើកទី១ ត្រូវបានរៀបចំរួមគ្នាឡើងដោយរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ក្នុងគោលដៅពិនិត្យឡើងវិញអំពីវឌ្ឍនភាពក្នុងវិស័យសុខាភិបាល កំណត់នូវសមិទ្ធផល បញ្ហា និងការលំបាកនានានៅក្នុងវិស័យគន្លឹះទាំង៦ នៃផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល និងកំណត់សូចនាករ និងអាទិភាពសំរាប់អនុវត្តក្នុងឆ្នាំ២០០៣-២០០៤ ។ មន្ត្រីថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុកប្រតិបត្តិរបស់រាជរដ្ឋាភិបាល អ្នកផ្តល់ជំនួយ អង្គការក្រៅរដ្ឋាភិបាល ក៏ដូចជាក្រុមប្រឹក្សាឃុំដែលតំណាងអោយក្រុមអ្នក ប្រើប្រាស់ បានចូលរួមក្នុងការវាយតំលៃនេះដែរ ។ ការវាយតំលៃនេះបានផ្តល់របាយការណ៍មួយស្តីពីការអនុវត្តន៍វិស័យសុខាភិបាលឆ្នាំ២០០៣ កិច្ចព្រមព្រៀងលើសកម្មភាពអាទិភាពសំរាប់ឆ្នាំ២០០៤-២០០៥ ក៏ដូចជាគោលដៅដែលអាចវាស់វែងបានសំរាប់ឆ្នាំ ២០០៤ ។ ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសសំខាន់ៗបានសន្យាផ្តល់ការគាំទ្រដល់សកម្មភាពអាទិភាពឆ្នាំ២០០៤-២០០៥ ដោយផ្តោតការយកចិត្តទុកដាក់លើសុខភាពកុមារ និងម្តាយ និងលើការបង្កើនលទ្ធភាពផ្តល់សេវាសុខាភិបាលប្រកបដោយគុណភាពដល់អ្នកក្រីក្រ ។ បច្ចុប្បន្ននេះ ក្រសួងសុខាភិបាលកំពុងរៀបចំផែនការដើម្បីអនុវត្តសកម្មភាពអាទិភាពទាំងនេះ ។ បច្ចុប្បន្ននេះ ក្រសួងសុខាភិបាលក៏កំពុងរៀបចំធ្វើការវាយតំលៃ ដើម្បីបង្កើនប្រសិទ្ធភាពនៃនីតិវិធី និងកិច្ចដំណើរការរៀបចំផែនការរបស់ខ្លួនដែរ ។

១០៩- នៅក្នុងដំណាក់កាលដំបូងនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលឆ្នាំ២០០៣-២០០៧ ក្រសួងសុខាភិបាលជួបនឹងបញ្ហាប្រឈមជាច្រើន ដូចជាការធានាតុល្យភាពជាជំហាននៃការធ្វើហិរញ្ញប្បទានរវាងធនធានក្រៅប្រទេសជាមួយនឹងធនធានថវិកាជាតិ ក្នុងការធ្វើអន្តរាគមន៍សុខាភិបាលសាធារណៈ ។ បញ្ហាប្រឈមផ្សេងៗទៀតក្នុងអភិក្រមនៃការគ្រប់គ្រងទូទាំងវិស័យ (Sector Wide Management) រួមមាន ÷ ក- លទ្ធភាពប្រសើរជាងមុនក្នុងការទទួលពត៌មានស្តីពីការសន្យារបស់អ្នកផ្តល់ជំនួយ សំរាប់រៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម កម្មវិធីវិនិយោគសាធារណៈ និងផែនការប្រតិបត្តិការប្រចាំឆ្នាំ ។ ខ- សុខដុមនីយកម្មនូវយន្តការជាច្រើនសំរាប់រៀបចំផែនការ និងការត្រួតពិនិត្យតាមដាន និងវាយតំលៃ ដែលទាមទារអោយមានការចូលរួមរបស់ភ្នាក់ងារផ្តល់ជំនួយ ក៏ដូចជាស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។ និង គ- ការកំណត់នូវការលើកទឹកចិត្តសមស្របសំរាប់មន្ត្រី ដែលធ្វើការផ្នែកសំរបសំរួល ការងារផែនការ និងការងារពិនិត្យតាមដាន និងគ្រប់គ្រងគំរោង ។

១១០- ក្នុងជំហានដំបូងនៃការអនុវត្តន៍អោយសំរេចកំណែទំរង់ខាងរចនាសម្ព័ន្ធ ប្រព័ន្ធនិងនីតិវិធីរបស់ក្រសួងសុខាភិបាល ការវិភាគមុខងារសំរាប់ខេត្តពីរ និងអង្គភាពនៅថ្នាក់ជាតិចំនួន ៥ របស់ក្រសួងសុខាភិបាលត្រូវបានបញ្ចប់នៅក្នុងឆ្នាំ២០០៣ ។

## ២.៤.២ វិស័យសេដ្ឋកិច្ច

**វិស័យសេដ្ឋកិច្ច**

- កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- កម្មន្តសាល និងរ៉ែ
- ទេសចរណ៍
- ពាណិជ្ជកម្ម

### កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១១១- ក្នុងនីតិកាលទី២ ឆ្នាំ ១៩៩៨-២០០៣ ការអភិវឌ្ឍន៍វិស័យកសិកម្មគឺជាយុទ្ធសាស្ត្រមួយដ៏សំខាន់របស់រាជ រដ្ឋាភិបាល ដើម្បីកាត់បន្ថយភាពក្រីក្រនៅតាមសហគមន៍ជនបទ ធានាសន្តិសុខស្បៀង និងជំរុញកំណើន សេដ្ឋកិច្ចប្រកបដោយចីរភាពនិងសមធម៌ ។ ទោះបីជាវិស័យ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកើនឡើងខ្លាំងគួរអោយកត់សំគាល់ក្នុងចន្លោះឆ្នាំ១៩៩៨-២០០៣ ក៏ដោយ ក៏ការរួមចំណែករបស់វិស័យនេះក្នុង ផ.ស.ស បានថយចុះពី៤៣,៧%ក្នុងឆ្នាំ១៩៩៨ មកនៅត្រឹមជាងមួយភាគបីប៉ុណ្ណោះនៅក្នុងឆ្នាំ២០០២ ។ នេះបណ្តាលមកពីការរីកចំរើនខ្លាំងនៃវិស័យឧស្សាហកម្មក្នុងកំឡុងពេលដូចគ្នា ។ វិស័យកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទនៅតែជាប្រភពការងារនៃកំលាំងពលកម្មជាង៨០% ។ ដោយសារ៨៥%នៃប្រជាជនសរុបរស់នៅតាមសហគមន៍ជនបទ ហើយ៧៥%នៃប្រជាជនក្រីក្រគឺជាគ្រួសារដែលមានមេគ្រួសារជាកសិករ ការអភិវឌ្ឍន៍វិស័យកសិកម្មនៅតែជាកត្តាគន្លឹះសំរាប់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពសំរាប់កាត់បន្ថយភាពក្រីក្រ និងសំរាប់អភិវឌ្ឍសេដ្ឋកិច្ចជនបទ ។ ក្នុងកំឡុងពេល៥ឆ្នាំកន្លងមក ការអភិវឌ្ឍន៍វិស័យនេះបានទទួលផលប៉ះពាល់ពីអាកាសធាតុមិនស្លូវអំណោយផល ដូចជាគ្រោះទឹកជំនន់ និងភាពរាំងស្ងួតជាដើម ។ ប៉ុន្តែ ការខិតខំប្រឹងប្រែងបង្កើនផលិតភាពកសិកម្មបានទទួលលទ្ធផលគាប់ប្រសើរខ្លះដែរ ។ ទិន្នផលស្រូវកើនឡើងពី១,៧៩តោនក្នុងមួយហិកតានៅក្នុងឆ្នាំ១៩៩៨ ដល់២,១តោនក្នុងមួយហិកតាក្នុងឆ្នាំ២០០២ និងឆ្នាំ២០០៣ ។

១១២- ទោះជាមានវឌ្ឍនភាពជាដុំកំភួនក៏ដោយ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រដែលមិន សមស្រប កង្វះសំភារះកសិកម្ម ទីផ្សារដែលមិនសូវមានប្រសិទ្ធភាព និងកង្វះការគាំទ្រខាងផ្នែកស្ថាប័ន គឺជាកត្តាទប់បង្អាក់ដល់កិច្ចអភិវឌ្ឍន៍វិស័យកសិកម្ម ។ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងអនុវត្តកម្មវិធីកំណែទំរង់មួយចំនួន ក្នុងគោលដៅបង្កើតប្រព័ន្ធទីផ្សារមួយដែលសង្កត់ធ្ងន់លើការកែទំរង់ដីធ្លី សេរីភាវូបនីយកម្មថ្លៃ និងការអនុម័តបទបញ្ញត្តិអោយមានសហគ្រាសចំរុះរវាងរដ្ឋ និងវិនិយោគិនបរទេស ។ រចនាសម្ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទត្រូវបានរៀបចំឡើងវិញ ក្រោមកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍នានា ។ សេវាផ្សព្វផ្សាយកសិកម្មត្រូវបានពង្រីកអោយទូលំទូលាយ ដើម្បីសិក្សាស្រាវជ្រាវបណ្តាពូជស្រូវ និងផ្ទេរបច្ចេកវិទ្យាដល់កសិករ ។ ទន្ទឹមនេះដែរ កំណែទំរង់ខាងគោលនយោបាយ និងខាង

ស្ថាប័ន កំពុងត្រូវបានអនុវត្តតាមរយៈកម្មវិធីវិនិយោគសាធារណៈ ដែលរួមមានការផ្គត់ផ្គង់ទឹកតាមភូមិ ការស្តារហេដ្ឋារចនាសម្ព័ន្ធជនបទសំខាន់ៗឡើងវិញ និងការបង្កើតការងារ ។

១១៣- ផ.ស.សសរុបរបស់វិស័យកសិកម្ម (ស្រូវ បសុសត្វ នេសាទនិងអាជីវកម្មឈើ) មានកំណើន៧,៩% ក្នុងរយៈពេល ៥ឆ្នាំ ១៩៩៨-២០០៣ ពី ៥.០៩៤ពាន់លានរៀល ក្នុងឆ្នាំ១៩៩៨ ដល់៥.៤៩៦ពាន់លានរៀល ក្នុងឆ្នាំ២០០៣ ។ លក្ខខ័ណ្ឌអាកាសធាតុមិនអំណោយផល និងគ្រោះទឹកជំនន់យ៉ាងធ្ងន់ធ្ងរ ក្នុងចន្លោះឆ្នាំ ១៩៩៩-២០០០ និងឆ្នាំ២០០១-២០០២ បានបណ្តាលអោយទិន្នផលថយចុះ ។ សមាសភាគផ្សេងនៃស្រូវ និងការចិញ្ចឹមសត្វក្នុងផ.ស.សសំរាប់វិស័យកសិកម្មមិនមានការប្រែប្រួលធំដុំគួរអោយកត់សំគាល់ឡើយ ក្នុងកំឡុងពេល៥ឆ្នាំនេះ ។ ផលិតផលនេសាទមានការកើនឡើង ហើយរួមចំណែកប្រមាណមួយភាគបីនៃ ផ.ស.សកសិកម្មសំរាប់ឆ្នាំ២០០៣ ។ ចំណែកអាជីវកម្មព្រៃឈើថយចុះគួរអោយកត់សំគាល់ ក្នុងកំឡុងពេលដូចគ្នានេះដែរ ពី៧២៤ពាន់លានរៀលក្នុងឆ្នាំ១៩៩៨ ឬ ១៤,២%នៃផលិតផលកសិកម្ម មកនៅត្រឹម៣៤២ពាន់លានរៀល ឬ ៦,៦%ក្នុងឆ្នាំ២០០៣ ។

១១៤- ក្នុងឆ្នាំ២០០៣ លើដីកសិកម្ម ២,៧លានហិកតា ស្រូវស្រូបយកអស់ ២,១លានហិកតា ត្រូវជា ៧៨% ។ ក្រៅពីនោះ ដំណាំអាហាររួមផ្សំមាន ៦% ដំណាំឧស្សាហកម្មមាន ៤% និងដំណាំប្រើប្រាស់ប្រចាំថ្ងៃ និងបន្លែបង្កាមាន ៦% ។ ផ្ទៃដីស្រោចស្រពសំរាប់ដំណាំស្រូវមានប្រមាណ៤៣០.០០០ហិកតា (ប្រហែល ២៣% នៃផ្ទៃដីសរុប២,១លានហិកតា)។ ក្នុងឆ្នាំ២០០៣ ផលិតផលស្រូវបានកើនឡើង២៣% ពី ៣,៨លានតោន នៅឆ្នាំ២០០២ ដល់៤,៧លានតោន នៅឆ្នាំ២០០៣ លើសតំរូវការប្រមាណ៦៨៦.០០០តោន ។ កំណើនផលិតផលស្រូវនេះគឺជាលទ្ធផលនៃការប្រើប្រាស់ពូជស្រូវដែលផ្តល់ទិន្នផលខ្ពស់ រួមផ្សំនឹងបច្ចេកវិទ្យាដាំដុះថ្មីដែលបានផ្សព្វផ្សាយដោយវិទ្យាស្ថានស្រាវជ្រាវកសិកម្មកម្ពុជា (CARDI) តាមរយៈសេវាផ្សព្វផ្សាយកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។ ប៉ុន្តែ នាពេលបច្ចុប្បន្ននេះ ទិន្នផលស្រូវស្ថិតក្នុងកំរិតទាបនៅឡើយ គឺប្រហែល២តោនក្នុងមួយហិកតា បើប្រៀបធៀបជាមួយប្រទេសជិតខាងដែលមានប្រព័ន្ធអេកូសាស្ត្រប្រហាក់ប្រហែលគ្នា គឺប្រហែល៥-៨តោនក្នុងមួយហិកតា ។

១១៥- ទោះបីជាការរាលដាលនៃជំងឺគ្រុនផ្តាសាយបក្សី កាលពីឆ្នាំ២០០៣កន្លងទៅ មានផលប៉ះពាល់ជាអវិជ្ជមានដល់វិស័យចិញ្ចឹមសត្វទាំងមូល ការចិញ្ចឹមសត្វនិងបសុសត្វមានសន្ទុះកើនឡើងចំនួន២,៦%ដែរ ។ ក្នុងឆ្នាំ ២០០៣ រាជរដ្ឋាភិបាលបានពង្រីកចំនួនភ្នាក់ងារសុខភាពសត្វភូមិទូទាំងប្រទេស ដើម្បី កាត់បន្ថយអត្រាស្លាប់និងឈឺរបស់បសុសត្វ ។ លើសពីនេះ រាជរដ្ឋាភិបាលក៏បានចាត់វិធានការប្រឆាំងនឹងជំងឺរាតត្បាត ដើម្បីលើកកំពស់គុណភាពផលិតផលបសុសត្វ សំរាប់ការប្រើប្រាស់របស់ប្រជាជនផងដែរ ។

១១៦- កៅស៊ូជាផលិតផលនាំចេញយ៉ាងសំខាន់របស់រដ្ឋ ដែលអាចប្រមូលចំណូលថវិកាបានយ៉ាងច្រើន ។ កៅស៊ូជាដំណាំដែលប្រើប្រាស់ពលកម្មច្រើន និងមានសក្តានុពលក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតការងារនៅជនបទ ។ ក្នុងកំឡុងឆ្នាំ១៩៩៨-២០០៣ ចំការកៅស៊ូពិសោធន៍ចំនួន៥៧ចំការ ត្រូវបានបង្កើត

នៅលើដីកសិករនៅក្នុងខេត្តរតនគីរី មណ្ឌលគីរី ក្រចេះ កំពង់ចាម និងកំពង់ធំ ក្រោមជំនួយឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍ ។ គំរោងអភិវឌ្ឍន៍កៅស៊ូខ្នាតតូចដែលគាំទ្រដោយទីភ្នាក់ងារអភិវឌ្ឍន៍បារាំងកំពុងដំណើរការទៅយ៉ាងល្អប្រសើរ ដោយមានការចូលរួមយ៉ាងច្រើនពីប្រជាពលរដ្ឋដែលនៅទីនោះ ។

១១៧- **ការគ្រប់គ្រងវិស័យជលផល** : យើងសំរេចបានសមិទ្ធផលសំខាន់ៗមួយចំនួនក្នុងការគ្រប់គ្រងអនុវិស័យ នេះ ។ ជំហានទី២នៃការកែទំរង់ឡូតិ៍នេសាទកំពុងត្រូវបានអនុវត្តនៅតាមបណ្តាខេត្តមួយចំនួន ។ ឡូតិ៍នេសាទជាង៥៦% ត្រូវបានរក្សាទុកសំរាប់ការធ្វើនេសាទរបស់សហគមន៍ និងសំរាប់បង្កើតប្រព័ន្ធគ្រប់គ្រងធនធានជលផលសំរាប់សហគមន៍ ។ ព្រះរាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទត្រូវបានបញ្ចប់ការពិភាក្សា ហើយកំពុងរង់ចាំការអនុម័តពីគណៈរដ្ឋមន្ត្រីនៅពេលឆាប់ៗខាងមុខនេះ ។ បច្ចុប្បន្ន ទោះបីជារាជរដ្ឋាភិបាលពុំទាន់បានអនុម័តលិខិតបទដ្ឋានទាំងនេះក្តី ក៏យើងសង្កេតឃើញមានសហគមន៍នេសាទចំនួន៣៦០ ត្រូវបានបង្កើតនៅទូទាំងប្រទេស ក្រោមជំនួយឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍របស់យើង ។ រីឯច្បាប់ជលផលក៏ត្រូវបានពិនិត្យឡើងវិញដោយគណៈរដ្ឋមន្ត្រី ហើយនឹងត្រូវដាក់ជូនរដ្ឋសភានិងព្រឹទ្ធសភាពិភាក្សានិងអនុម័តក្នុងពេលដ៏ខ្លីខាងមុខ ។ កាលពីខែកុម្ភៈ ឆ្នាំ២០០៣ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍នេសាទទឹកសាប ត្រូវបានបង្កើតឡើងជាផ្លូវការ ។ វិទ្យាស្ថាននេះបានក្លាយជាស្ថាប័នមួយយ៉ាងសំខាន់ ក្នុងការសិក្សាស្រាវជ្រាវពីការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានជលផល ដោយផ្តោតការយកចិត្តទុកដាក់ជាចំបង ទៅលើការស្រាវជ្រាវពីគំនិតវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទំនើបៗ និងផ្តល់ជាប្រភពពត៌មាន និងឯកសារនានាដល់សាធារណជន ពិសេសអ្នកនេសាទ និងសហគមន៍នេសាទ ។

១១៨- រាជរដ្ឋាភិបាលកំពុងរៀបចំផែនការមេក្នុងការអភិវឌ្ឍន៍វិស័យជលផល រយៈពេល ១០ឆ្នាំ ២០០១-២០១១ ។ ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានផ្តួចផ្តើមគំនិតអំពីការអភិរក្ស និងការគ្រប់គ្រងធនធានជលផលផងដែរ រួមមាន ÷ ការទប់ស្កាត់បទល្មើសនេសាទ ការកំណត់ព្រំប្រទល់ឡូតិ៍នេសាទ និងការកំណត់តំបន់បំរុងទុក និងការកែលំអជំរកត្រី ។

១១៩- ការអភិវឌ្ឍន៍វារីវប្បកម្មជនបទគឺជាផ្នែកមួយនៃគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។ ផលិតផលវារីវប្បកម្មបានចូលរួមចំណែកលើកកំពស់ស្ថានភាពរស់នៅរបស់ប្រជាកសិករ ហើយក៏ជាប្រភពចំណូលក្រៅពីកសិផលរបស់ប្រជាកសិករផងដែរ ។ ការគាំទ្រដល់ការអភិវឌ្ឍន៍វារីវប្បកម្មជនបទ កំពុងដំណើរការបានល្អនៅក្នុងខេត្តស្វាយរៀង តាកែវ និងកំពង់ស្ពឺ ។

១២០- **សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ** : រាជរដ្ឋាភិបាលសំរេចបានវឌ្ឍភាពជាច្រើន ក្នុងការកែលំអស្ថានភាពអាហារូបត្ថម្ភ និងសន្តិសុខស្បៀងក្នុងឆ្នាំ២០០៣ ដែលបានឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃផលិតផលកសិកម្ម ស្ថានភាពផ្លូវល្អប្រសើរជាងមុន និងការអភិវឌ្ឍន៍ទីផ្សារ ។ ប៉ុន្តែ នៅមានល្បាយមិនស្មើរវាងបណ្តាស្រុកដែលមានអតិរេក និងឱនភាពផលស្រូវ ។ ដើម្បីសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដោយកាត់បន្ថយអោយបានពាក់កណ្តាលចំនួនមនុស្សរងគ្រោះទុរ្ភិក្ស ត្រឹមឆ្នាំ២០១៥ ចំណុចខ្លាំងបំផុតមួយរបស់កម្ពុជា

គឺសក្តានុពលក្នុងការផលិតស្រូវបន្ថែមអោយបាន១លានតោនបន្ថែមទៀត ដោយមិនចាំបាច់កាប់ឆ្ការ ឬបំផ្លាញព្រៃឈើឡើយ ពីព្រោះផ្ទៃដីដាំដុះនៅតិចនៅឡើយ ធៀបនឹងកំរិតមុនសម័យសង្គ្រាម ។ លើសពីនេះ ការបង្កើនទិន្នផលស្រូវពី២តោនទៅ៣តោនក្នុងមួយហិកតា នឹងមានឥទ្ធិពលធំធេងដល់ការធានាសន្តិសុខស្បៀង ។

១២១- នៅក្នុងកំរិតគោលនយោបាយ ការយកចិត្តទុកដាក់ត្រូវបានផ្តោតទៅលើការលើកកំពស់ការយល់ដឹងអំពីភាពកង្វះចំណីអាហារ កង្វះជាតិដែក ការផ្តល់ចំណីអាហារ ឬ ការចិញ្ចឹមកុមារ ការបញ្ចូលជាតិអ៊ីយ៉ូតទៅក្នុងអំបិល តាមរយៈសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងការតស៊ូមតិ ។ ប៉ុន្តែ យើងនៅមានកិច្ចការជាច្រើនទៀតដែលត្រូវអនុវត្តនៅក្នុងវិស័យនេះ ពីព្រោះសមត្ថភាពផលិតអំបិលអ៊ីយ៉ូតក្នុងស្រុក អាចរ៉ាប់រងបានតែ២០%នៃតំរូវការរបស់ប្រទេស ហើយវីតាមីនអាទទួលបានតែ៣៤%នៃកុមារអាយុចន្លោះ៦-៥៩ខែ ។ ចំនួនមាតាទទួលជីវជាតិដែកបន្ថែមនៅមានកំរិតទាបនៅឡើយដែរ ។ រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការសំរបសំរួលអាហារូបត្ថម្ភនៅតាមខេត្ត-ក្រុងមួយចំនួន និងបានប្រគល់ភារកិច្ចអោយរៀបចំផែនការសកម្មភាពថ្នាក់ខេត្តស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។

១២២- ការសំរេចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតសហគមន៍ព្រៃឈើនិងនេសាទ បានធ្វើអោយប្រជាជនក្រីក្រមានលទ្ធភាពប្រសើរឡើង ក្នុងការរកស៊ីចិញ្ចឹមជីវិត ហើយផ្តល់ប្រយោជន៍ជាច្រើនជូនប្រជាជននៅតាមជនបទ ។ សកម្មភាពអាទិភាពក្នុងឆ្នាំ២០០៣បានជួយសហគមន៍អ្នកនេសាទ ក្នុងការកែលំអការ គ្រប់គ្រង និងកាត់បន្ថយការនេសាទខុសច្បាប់ ។ បន្ទាប់ពីការកែទំរង់ឡូតិ៍នេសាទនៅចុងឆ្នាំ២០០០ ឡូតិ៍នេសាទត្រូវបានកាត់បន្ថយពី២៣៥ឡូតិ៍ ដែលគ្របដណ្តប់លើផ្ទៃទឹកប្រហែល១លានហិកតា មកនៅត្រឹម១៦៤ឡូតិ៍ គ្របដណ្តប់លើផ្ទៃទឹកប្រមាណ៤២០.០០០ហិកតាប៉ុណ្ណោះ ។ ការកាត់បន្ថយឡូតិ៍នេសាទបានកាត់បន្ថយជំលោះរវាងកសិករដែលរស់នៅក្នុងតំបន់ឡូតិ៍នេសាទ និងតំបន់ជិតខាង ។ ប៉ុន្តែ ក៏នៅមានការរីកចំរើនតិចតួចណាស់ក្នុងការផ្តល់ឥណទានខ្នាតតូច ហើយតំលៃឥណទានសំរាប់គ្រួសារជនក្រីក្រក៏នៅមានខ្ពស់ដដែល ។

១២៣- **ការគ្រប់គ្រងវិស័យព្រៃឈើ** : ចាប់តាំងពីកិច្ចប្រជុំពិគ្រោះយោបល់លើកទី៦ ឆ្នាំ២០០២ កន្លងមក រាជរដ្ឋាភិបាលសំរេចបានលទ្ធផលគួរអោយកត់សំគាល់ក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួន ដើម្បីធានាអោយបានការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយចីរភាព ។ ការអនុវត្តន៍កំណែទំរង់ក្នុងវិស័យព្រៃឈើបានឈានដល់ដំណាក់កាលសំខាន់មួយ ដែលភាគីពាក់ព័ន្ធទាំងអស់ត្រូវយកចិត្តទុកដាក់ដល់ការពង្រឹងសមត្ថភាពខាងស្ថាប័ន និងកែលំអកិច្ចការសំរបសំរួលដើម្បីធានាភាពរលូនក្នុងការអនុវត្តន៍គោលនយោបាយនេះ ។ ខាងក្រោមគឺជាការពិនិត្យឡើងវិញលើសមិទ្ធផលសំខាន់ៗដែលរាជរដ្ឋាភិបាលសំរេចបានក្នុងការគ្រប់គ្រងវិស័យព្រៃឈើ ។

១២៤- ដោយប្រកាន់ខ្ជាប់នូវការប្តេជ្ញាកន្លងមក រាជរដ្ឋាភិបាលមិនបានផ្តល់សម្បទានព្រៃឈើថ្មីណាមួយឡើយ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានអនុញ្ញាតអោយមានកិច្ចប្រតិបត្តិការទ្រង់ទ្រាយតូចលើសំណល់ព្រៃឈើ និងការងារមួយចំនួនទៀតដែលត្រូវបានអនុញ្ញាតក្រោមបញ្ញត្តិ និងច្បាប់របស់កម្ពុជា ។ រាជរដ្ឋាភិបាលបានប្រឹងប្រែងយ៉ាងសកម្មក្នុងការទប់ស្កាត់ការធ្វើអាជីវកម្មឈើខុសច្បាប់ ។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីរដ្ឋបាលព្រៃឈើ ៧រូបត្រូវស្លាប់ និង៣៨រូបទៀតត្រូវរងរបួស ។ រោងចក្រអារឈើខុសច្បាប់ប្រមាណ ១.៣៨៦ សិប្បកម្មកែច្នៃឈើ ៦៥៣ សិប្បកម្មកែច្នៃវល្លិ៍ ៣៩ សិប្បកម្មកែច្នៃជ័រឈើ ២៤ និងឧបករណ៍កែច្នៃមួយចំនួនទៀត ត្រូវបានរឹបអូស បំផ្លាញចោល និងបិទជាស្ថាពរ ។ ជនល្មើស៣៣២នាក់ត្រូវបានចាប់ឃាត់ខ្លួន ហើយបានរៀបចំសំណុំបែបបទបញ្ជូនទៅតុលាការ ។

១២៥- ការកាប់ព្រៃឈើខុសច្បាប់ ការរត់ពន្ធសត្វព្រៃ ការទន្ទ្រានដីព្រៃ ត្រូវកាត់បន្ថយមកនៅត្រឹមកំរិតអាចគ្រប់គ្រងបាន ។ វិធានការដែលរាជរដ្ឋាភិបាលប្រកាន់យកក្នុងការបង្ក្រាបបទល្មើសព្រៃឈើរួមមាន ការរឹតបន្តឹងក្នុងការអនុវត្តន៍ច្បាប់ព្រៃឈើ បង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើស ។ អភិក្រមដែលរាជរដ្ឋាភិបាលប្រកាន់យកក្នុងការគ្រប់គ្រងធនធានធម្មជាតិ ដែលរួមមានកំណែទំរង់ក្នុងការគ្រប់គ្រងសម្បទាន សហគមន៍ព្រៃឈើ និងការគ្រប់គ្រងតំបន់ព្រៃការពារ គឺសំដៅកាត់បន្ថយបទល្មើសព្រៃឈើនានា ។ ក្នុងពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានចេញសារាចរណែនាំលេខ០១ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៤ ដើម្បីទប់ស្កាត់ និងលុបបំបាត់ការទន្ទ្រាន និងការរំលោភដីព្រៃ ហើយក៏បានបង្កើតគណៈកម្មាធិការថ្នាក់ជាតិ និងអនុគណៈកម្មាធិការថ្នាក់ខេត្ត ដើម្បីអនុវត្តសារាចរនេះ ។

១២៦- ការត្រួតពិនិត្យនិងរបាយការណ៍ស្តីបទល្មើសព្រៃឈើនៅតែបន្ត ទោះបីជាមានជំលោះជាមួយនឹងអង្គការ Global Witness ក៏ដោយ ។ រាជរដ្ឋាភិបាលយល់ឃើញនូវភាពចាំបាច់ក្នុងការបន្តពង្រឹង និងលើកកំពស់ការត្រួតពិនិត្យ និងរបាយការណ៍ស្តីពីបទល្មើសព្រៃឈើ ដើម្បីពង្រឹងការអនុវត្តន៍ច្បាប់ និងដើម្បីអោយរាជរដ្ឋាភិបាលអាចប្រើប្រាស់ធនធានដ៏តិចតួចស្តួចស្តើងអោយចំទិសដៅអាទិភាព និងមានប្រសិទ្ធភាព ។ រាជរដ្ឋាភិបាលបានកំណត់យក Société Génerale de Surveillance (SGS) ជាអ្នកត្រួតពិនិត្យបទល្មើសព្រៃឈើឯករាជ្យ ។ អង្គការ Wildlife Conservation Society, Conservation International, WildAid និងអង្គការមួយចំនួនទៀតក៏បានដើរតួនាទីជាដៃគូសំខាន់ដែរ ក្នុងការជួយតាមដានបទល្មើសព្រៃឈើនៅ កម្ពុជា ។ រាជរដ្ឋាភិបាលយល់ឃើញនូវភាពចាំបាច់ក្នុងការទទួលយកនូវប្រឹក្សាបច្ចេកទេសស្តីពីការអនុវត្តន៍ច្បាប់ព្រៃឈើពីដៃគូអភិវឌ្ឍន៍របស់កម្ពុជា ។

១២៧- ប្រព័ន្ធផ្តល់ព្រៃឈើសម្បទាន និងព្រៃសម្បទាននីមួយៗ ត្រូវបានរៀបចំកែប្រែឡើងវិញដើម្បីធានាអោយមានការទទួលខុសត្រូវច្បាស់លាស់ និងអាចឆ្លើយតបនឹងសំណូមពរ និងផលប្រយោជន៍ជាសាធារណៈ ផងដែរ ។ រាជរដ្ឋាភិបាលនឹងបន្តកំណែទំរង់គ្រប់គ្រងព្រៃឈើផ្សេងៗទៀត រួមមានការសំរេចកែប្រែកិច្ចសន្យាផ្តល់សម្បទានដែលនៅសេសសល់ឡើងវិញ វិធានការអនុវត្តបន្តដើម្បីលើកកំពស់ការពិគ្រោះយោបល់

ក្នុងមជ្ឈដ្ឋានសហគមន៍ និងការចៀសវាងបញ្ហាសង្គម និងផលប៉ះពាល់បរិស្ថានជាអវិជ្ជមាន ព្រមទាំងលើក កំពស់ស្តង់ដារបច្ចេកទេសនៃកិច្ចប្រតិបត្តិការរបស់ក្រុមហ៊ុនព្រៃសម្បទាន និងស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងការងារគ្រប់គ្រងព្រៃសម្បទានផងដែរ ។

១២៨- លើទិដ្ឋភាពច្បាប់ រាជរដ្ឋាភិបាលបានអនុម័តបន្ថែមនូវឧបករណ៍និយ័តកម្ម និងបទបញ្ញាណែនាំបន្ថែម សំរាប់អនុវត្តច្បាប់ព្រៃឈើឆ្នាំ២០០២។ កាលពីខែធ្នូ ឆ្នាំ២០០៣ អនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើត្រូវបាន អនុម័ត ។ អនុក្រឹត្យនេះអនុញ្ញាតអោយរាជរដ្ឋាភិបាលប្រគល់សម្បត្តិព្រៃឈើសាធារណៈអោយស្ថិតនៅ ក្រោមការទទួលខុសត្រូវរបស់សហគមន៍មូលដ្ឋាន ក្នុងក្របខ័ណ្ឌផែនការគ្រប់គ្រង និងការរៀបចំបែងចែក ផលប្រយោជន៍ ។ អនុក្រឹត្យនេះគឺជាលទ្ធផលនៃការពិគ្រោះយោបល់រយះពេលជាង៦ឆ្នាំ ជាមួយនឹងភាគី ពាក់ព័ន្ធ និងទីប្រឹក្សាជាច្រើន ហើយនេះក៏ជាការបំពេញបន្ថែមលើវិធានការផ្សេងទៀត ដូចជាអនុក្រឹត្យ ស្តីពីការផ្តល់សម្បទានដីសង្គមកិច្ច ដែលរាជរដ្ឋាភិបាលកំពុងបន្តអនុវត្ត ដើម្បីអោយការគ្រប់គ្រងធនធាន ដីធ្លីមានភាពប្រសើរ និងមានប្រយោជន៍ជាងមុន ។

១២៩- រាជរដ្ឋាភិបាលបានធ្វើការក្នុងភាពជាដៃគូជាមួយទីភ្នាក់ងារអ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាល ជាច្រើន ក្នុងការសាកល្បងអនុវត្តគំរោងសហគមន៍ព្រៃឈើនៅតាមតំបន់នានារបស់ប្រទេស ។ ផ្ទៃដី ប្រមាណ១១០ពាន់ហិកតា ត្រូវបានអភិវឌ្ឍនៅក្រោមយន្តការ«សហគមន៍ព្រៃឈើ» ។ នៅក្នុងក្របខ័ណ្ឌ អនុក្រឹត្យថ្មីនេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងភាពជាដៃគូនេះបន្ថែមទៀត ។

**វិស័យកម្មន្តសាល និងរ៉ែ**

១៣០- កិច្ចខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលនីតិកាលទី២(១៩៩៨-២០០៣)សំរេចបានលទ្ធផលគួរអោយកត់សំគាល់ ក្នុងការជំរុញសេដ្ឋកិច្ចទីផ្សារសេរី ដោយបើកចំហទីផ្សារក្នុងស្រុក លើកទឹកចិត្តដល់វិនិយោគផ្ទាល់ពីក្រៅ ប្រទេស និងស្វះស្វែងរកទីផ្សារបរទេសសំរាប់ផលិតផលក្នុងស្រុកតាមរយៈសិទ្ធិពាណិជ្ជកម្មពិសេសដូចជាMFN និង GSP ដែលប្រទេសឧស្សាហកម្មលើពិភពលោកបានផ្តល់អោយកម្ពុជា ។ ក្នុងឆ្នាំ ២០០៣ វិស័យ ឧស្សាហកម្មបានរួមចំណែកប្រមាណ១៩,៥%ដល់ផលិតផលក្នុងស្រុកសរុប ដែលកាលពីឆ្នាំ១៩៩៨ មាន ប្រមាណតែ១២,៧%ប៉ុណ្ណោះ ។

១៣១- ផែនការអភិវឌ្ឍន៍ឧស្សាហកម្ម ១៩៩៨-២០០៣ របស់រាជរដ្ឋាភិបាលមានគោលដៅចំបងពីរគឺ ទីមួយ ជំរុញការលូតលាស់នៃឧស្សហកម្មសំរាប់នាំចេញ និងទីពីរការលូតលាស់នៃផលិតកម្មក្នុងស្រុកសំរាប់ជំនួស ទំនិញនាំចូលមួយចំនួន។ គោលដៅទាំងពីរនេះនឹងត្រូវសំរេចអោយបានតាមរយៈការជំរុញកិច្ចអភិវឌ្ឍន៍ ÷ ១-ឧស្សាហកម្មអគ្គិពលកម្ម ។ ២-ឧស្សាហកម្មកែច្នៃធនធានធម្មជាតិ ។ ៣-សហគ្រាសធុនតូចនិងមធ្យម ។ ៤-កសិឧស្សាហកម្ម ។ ៥-ការផ្ទេរបច្ចេកវិទ្យានិងលើកកំពស់គុណភាពទំនិញ ។ ៦-ការបង្កើតតំបន់ឧស្សា ហកម្ម ។ និង ៧-ផលិតទំនិញក្នុងស្រុកដើម្បីជំនួសការនាំចូល ។

១៣២- ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ ការជំរុញការលូតលាស់នៃកម្មន្តសាលអតិពលកម្ម ផ្តោតជាសំខាន់លើវាយនភ័ណ្ឌនិងផលិតសំលៀកបំពាក់ ។ រាជរដ្ឋាភិបាលនៅតែបន្តគាំទ្រការរីកចំរើននៃវិស័យឧស្សាហកម្មតាមរយៈ ÷ ១- ការលើកទឹកចិត្តសហគ្រាសខ្នាតតូចនិងមធ្យម ។ ២- កែលំអដំណើរការសហគ្រាសរដ្ឋតាមរយៈការបង្កើតសាជីវកម្មនិងតាមរយៈការធ្វើឯកជនភាវូបនីយកម្ម ។ ៣- ទប់ស្កាត់ការហូរចូលទំនិញខុសច្បាប់ ។ ៤- កាត់បន្ថយរបាំងដែលជាឧបសគ្គដល់ការនាំចេញ ដូចជាពន្ធនាំចេញ និងសេវាសំរួលពាណិជ្ជកម្មដែលមិនចាំបាច់ ដូចជាអាជ្ញាបណ្ណ ។ ៥- បន្ថយរបាំងក្នុងការនាំចូលសំភារៈសំរាប់ពាណិជ្ជកម្ម ។ ៦- ពង្រឹងទំនាក់ទំនងរវាងបណ្តាសហគ្រាសខ្នាតតូចនិងមធ្យម និងរវាងសហគ្រាសទាំងនេះជាមួយនឹងរោងចក្រធំៗ ។ ៧- បង្កើតមជ្ឈមណ្ឌលជាតិស្តីពីផលិតភាព ដែលអាចជួយសហគ្រាសខ្នាតតូចនិងមធ្យមបង្កើនផលិតភាពរបស់ខ្លួន និងកាត់បន្ថយចំណាយផលិតកម្ម ។ ៨- បង្កើតវិទ្យាស្ថានជាតិស្តង់ដារដើម្បីបញ្ជាក់គុណភាពទំនិញអោយស្របនឹងស្តង់ដារតំបន់និងអន្តរជាតិ ។ ៩- បង្កើតមន្ទីរពិសោធន៍ជាតិ ដែលបំពាក់ដោយបច្ចេកវិទ្យាគ្រប់គ្រាន់ក្នុងការវិភាគរូបវន្ត វិភាគគីមី មីក្រូជីវសាស្ត្រ និងវិភាគមេកានិច ដើម្បីធានាគុណភាព និងសមាសភាគរបស់ផលិតផល ។ ១០- បង្កើតការិយាល័យការពារកម្មសិទ្ធិឧស្សាហកម្មដើម្បីការពារផលិតផលបង្កើតថ្មីពីការលួចចំលងដោយខុសច្បាប់ ។ ១១- ជំរុញការបណ្តុះ បណ្តាលវិជ្ជាជីវៈទាំងក្នុងនិងក្រៅប្រទេស ។ និង១២- កែលំអក្របខ័ណ្ឌច្បាប់ ជាពិសេសច្បាប់ស្តីពីរោងចក្រ ច្បាប់ស្តីពីតំបន់ឧស្សាហកម្ម ច្បាប់ប៉ាតង់ ច្បាប់ស្តីពីគំរូឧស្សាហកម្ម ទំងន់និងរង្វាស់ និងសុវត្ថិភាពឧស្សាហកម្ម ។

១៣៣- ពីឆ្នាំ១៩៩៨ ដល់ ២០០៣ គណៈកម្មាធិការវិនិយោគកម្ពុជាបានអនុម័តគំរោងវិនិយោគ៤៩៧គំរោង ដែលមានទឹកប្រាក់ប្រមាណ ២,៤ពាន់លានដុល្លារអាមេរិក និងបង្កើតការងារសំរាប់មនុស្ស៣៧៤.០០០នាក់ ។ ក្នុងចំណោមគំរោងទាំងនេះ ៣៥៩គំរោងត្រូវបានអនុវត្តដែលមានមូលធនវិនិយោគជិត១,៦ពាន់លានដុល្លារ ហើយបានបង្កើតការងារសំរាប់មនុស្ស១៦៤.០០០នាក់ ។ ក្នុងចំណោមគំរោងវិនិយោគដែលបានអនុវត្ត១៨៧គំរោងជាគំរោងវិនិយោគក្នុងផ្នែកវាយនភ័ណ្ឌនិងសំលៀកបំពាក់ ចំណែកគំរោងដែលមិនវិនិយោគលើវាយនភ័ណ្ឌមាន៧៤គំរោង ។ ចំណែកវិស័យទេសចរណ៍មាន៣៦គំរោង ផ្នែកសាងសង់មាន៣២គំរោង កសិកម្មនិងកសិឧស្សាហកម្ម៣០គំរោង ។ ក្នុងចំណោមគំរោងវិនិយោគ៣៥៩គំរោងដែលបានអនុវត្ត៧២គំរោងកំពុងបន្តពង្រីក ដោយបានវិនិយោគបន្ថែមប្រមាណ១៣៥លានដុល្លារអាមេរិក ក្នុងនោះ គំរោងចំនួន៥៦គំរោង ជាគំរោងវិនិយោគដែលកំពុងពង្រីកនៅក្នុងវិស័យកាត់ដេរ ។

១៣៤- ច្បាប់ស្តីពីវិនិយោគត្រូវបានធ្វើវិសោធនកម្មឡើងវិញក្នុងឆ្នាំ២០០៣ ដើម្បីសំរួលនិងកាត់បន្ថយបែបបទរដ្ឋបាលក្នុងការស្នើសុំ និងអនុម័តសំណើវិនិយោគ និងកាត់បន្ថយពេលវេលាដែលត្រូវរង់ចាំការអនុម័តគំរោងវិនិយោគនិមួយៗ។

១៣៥- នៅក្នុងអនុវិស័យកម្មន្តសាលដែលមានប្រមាណ១/៥នៃផ.ស.សឆ្នាំ២០០៣ វាយនភ័ណ្ឌនិងសំលៀកបំពាក់រួមចំណែកប្រហែល២/៣នៃផលិតផលកម្មន្តសាលក្នុងឆ្នាំ២០០៣ ។ ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ជា

សកម្មភាពគួរអោយកត់សំគាល់ផងដែរ ដោយបានរួមចំណែកប្រមាណ១៥,១% នៅក្នុងផ. ស. សកម្មន្តសាល ឆ្នាំ២០០៣ ។ តំលៃផលិតកម្មសរុបនៃផលិតផលសំលៀកបំពាក់ បានកើនឡើងពី៤៥៧លានដុល្លារអាមេរិក ក្នុងឆ្នាំ១៩៩៨ ដល់១.៦៦៥លានដុល្លារអាមេរិកនាឆ្នាំ២០០៣ ។

១៣៦- **វិស័យរ៉ែ** : បន្ទាប់ពីច្បាប់ស្តីពីការគ្រប់គ្រងនិងធ្វើអាជីវកម្មធនធានរ៉ែត្រូវបានប្រកាសអោយប្រើក្នុងឆ្នាំ ២០០១ រាជរដ្ឋាភិបាលបានចាប់ផ្តើមផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនក្នុងស្រុកនិងក្រៅស្រុក ដើម្បីធ្វើអាជីវកម្មរុករករ៉ែនៅតាមតំបន់នានាដូចខាងក្រោម :

-អាជ្ញាបណ្ណត្រូវបានផ្តល់អោយក្រុមហ៊ុនក្នុងស្រុកមួយនិងក្រុមហ៊ុនបរទេសប្រាំ ដើម្បីធ្វើសកម្មភាពរុករកមាសនៅក្នុងខេត្តកំពង់ចាម កំពង់ធំ បាត់ដំបង ឧត្តរមានជ័យ ព្រះវិហារ មណ្ឌលគីរី និងរតនៈគីរី ។

-ក្រុមហ៊ុនមួយបានទទួលអាជ្ញាបណ្ណអោយរុករករ៉ែត្បូង និងរែងត្បូងនៅតំបន់សំឡូតខេត្តបាត់ដំបង ។

-រាជរដ្ឋាភិបាលអនុញ្ញាតអោយក្រុមហ៊ុនមួយរុករករ៉ែផូស្វាតនៅខេត្តកំពត ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ដើម្បីផ្គត់ផ្គង់អោយរោងចក្រផលិតជី ។

-ក្រុមហ៊ុនក្នុងស្រុកបី និងក្រុមហ៊ុនបរទេសពីរទទួលការអនុញ្ញាតអោយជីករកថ្មកំបោរនៅក្នុងខេត្តកំពត ដើម្បីជាវត្ថុធាតុដើមផលិតស៊ីម៉ង់ត៍ ។

-អាជ្ញាបណ្ណបានផ្តល់អោយក្រុមហ៊ុនមួយ ដើម្បីរុករកធ្យូងថ្មនៅតំបន់រ៉ុនញ៉ុង- តាឡាត ខេត្តស្ទឹងត្រែង ។

-រាជរដ្ឋាភិបាលបានអនុញ្ញាតអោយក្រុមហ៊ុនក្នុងស្រុក៣៨ និងក្រុមហ៊ុនបរទេស១១ ដើម្បីរុករកសារធាតុសំរាប់ផលិតសំភារៈសំណង់ (មានដូចជា ថ្ម ថ្មបាយក្រៀម ក្រួស ខ្សាច់ និង ឥដ្ឋ) ដើម្បីផ្គត់ផ្គង់តំរូវការទីផ្សារក្នុងស្រុក។

១៣៧- សមាសភាគរបស់វិស័យរ៉ែក្នុងផ. ស. សមានទំហំតូច ប៉ុន្តែបានកើនឡើងបន្តិច ពី ០,២% ក្នុងឆ្នាំ ១៩៩៨ ទៅ ០,៣% នៃផ. ស. សក្នុងឆ្នាំ២០០៣ ។

## វិស័យទេសចរណ៍

១៣៨- វិស័យទេសចរណ៍បានបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការស្តារបនាសេដ្ឋកិច្ចជាតិឡើងវិញ ។ ប្រទេសកម្ពុជាមានរមណីយដ្ឋានយ៉ាងច្រើនដែលមានឈ្មោះល្បីល្បាញនៅលើពិភពលោក រួមមានទាំងប្រាង្គប្រាសាទបុរាណអង្គរវត្ត ព្រមទាំងសណ្ឋាគារថ្នាក់អន្តរជាតិនៅទីក្រុងភ្នំពេញ និងនៅខេត្តសៀមរាប ។ កម្ពុជាសំបូរទៅដោយសម្បត្តិវប្បធម៌ និងប្រវត្តិសាស្ត្របុរាណ ដែលកសាងតាំងពីរាប់ពាន់ឆ្នាំមុនម្ល៉េះ ។ ចំនួនអ្នកទេសចរណ៍មកកាន់ប្រទេសកម្ពុជាបន្តកើនឡើងជាប់ជាលំដាប់ គឺពី២២៨.៥២៤នាក់ក្នុងឆ្នាំ១៩៩៨ ដល់៧៨៦.៥២៤នាក់ ក្នុងឆ្នាំ២០០២ ដែលគិតជាអត្រាមធ្យមប្រចាំឆ្នាំប្រមាណ២៨,៧% ក្នុងចន្លោះឆ្នាំ១៩៩៨ និង២០០២ ។ ដោយសារបញ្ហាប៉ះពាល់មួយចំនួន ដូចជាបាតុកម្មហិង្សានៅក្នុងភ្នំពេញកាលពីដើមឆ្នាំ២០០៣ សង្គ្រាមនៅអ៊ីរ៉ាក់ ការសាយភាយនៃជម្ងឺសារស៍ក្នុងតំបន់ និងភាពមិនច្បាស់លាស់មួយចំនួនដែលពាក់ពន្ធ័ទៅនឹងការបោះឆ្នោតជាទូទៅ បានបណ្តាលអោយចំនួនអ្នកទេសចរណ៍ធ្លាក់ចុះជាលើកដំបូង នាដើមឆ្នាំ

២០០៣ ។ ទោះបីជានៅពាក់កណ្តាលឆ្នាំ២០០៣ សកម្មភាពទេសចរណ៍មានលក្ខណៈប្រសើរឡើងវិញខ្លះៗក៏ដោយ ក៏ជារួម ចំនួនអ្នកទេសចរណ៍នៅតែមានការធ្លាក់ចុះដដែល គឺថយចុះពី៧៨៦.៥២៤នាក់ ក្នុងឆ្នាំ ២០០២ មកត្រឹម៧០១.០១៤នាក់ក្នុងឆ្នាំ២០០៣ ពោលគឺថយចុះប្រមាណ ១១% ។

១៣៩- រាជរដ្ឋាភិបាលក៏បានកំណត់គោលនយោបាយ សំរាប់វិស័យទេសចរណ៍ដោយផ្អែកលើគោលការណ៍គ្រឹះចំបងចំនួនពីរ ÷ ទី១- ការអភិវឌ្ឍន៍វិស័យទេសចរណ៍ដែលមានលក្ខណៈប្រកបដោយចីរភាព និងផ្តោតទៅលើប្រវត្តិសាស្រ្ត កេរ្តិ៍ដំណែលវប្បធម៌ ធនធានធម្មជាតិដ៏ល្អឆើតឆាយ ជាពិសេសគឺការអភិវឌ្ឍន៍ ដែលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ។ ទី២- ការអភិវឌ្ឍន៍វិស័យទេសចរណ៍មួយដែលធ្វើអោយកម្ពុជាក្លាយទៅជាគោលដៅទេសចរណ៍វប្បធម៌ធម្មជាតិដ៏ចំបងមួយក្នុងតំបន់ ដែលរួមចំណែកដល់ការធ្វើអោយអាស៊ានក្លាយទៅជាគោលដៅទេសចរណ៍តែមួយ (ASEAN as a Single Destination) ។ ដើម្បីជំរុញការអភិវឌ្ឍន៍វិស័យទេសចរណ៍នេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយគន្លឹះមួយចំនួន ដូចខាងក្រោម÷

- គោលនយោបាយបើកចំហជើងមេឃ ដែលនឹងបើកចំហផ្លូវគោក និងផ្លូវទឹក ។
- គោលនយោបាយស្តីពីលទ្ធភាពផ្តល់ទិដ្ឋាការពេលមកដល់ ។
- គោលនយោបាយលើកលែងទិដ្ឋាការចំពោះពលរដ្ឋកម្ពុជាដែលរស់នៅបរទេស (Visa K) ដែលជាគោលនយោបាយដ៏ត្រឹមត្រូវ និងបានទទួលការកោតសរសើរពីមតិជាតិ និងអន្តរជាតិ ។
- គោលនយោបាយពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទេសចរណ៍ក្នុងតំបន់អាស៊ាន ដោយបានក្លាយជាហត្ថលេខីមួយនៃកិច្ចព្រមព្រៀងទេសចរណ៍អាស៊ាន(ATA) កិច្ចសហប្រតិបត្តិការអាស៊ាន +៣ អាស៊ាន +៣+ ឥណ្ឌា កិច្ចសហប្រតិបត្តិការក្នុងមហាអនុតំបន់ទន្លេមេគង្គ (GMS) កិច្ចសហប្រតិបត្តិការបួនប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងថៃ (CLMT) និងកិច្ចសហប្រតិបត្តិការអន្តរជាតិទ្វេភាគី ។ល។
- ពង្រឹងសមត្ថភាពស៊ើបអង្កេត និងដាក់ទោសដល់ជនប្រព្រឹត្តិបទល្មើស ដែលទាក់ទងទៅនឹងទេសចរណ៍ផ្លូវភេទ អាជីវកម្មផ្លូវភេទលើកុមារ និងការជួញដូរគ្រឿងញៀន ។

១៤០- ក្នុងទិសដៅលើកស្ទួយដល់វិស័យទេសចរណ៍ កាលពីខែធ្នូ ឆ្នាំ២០០២ កន្លងមក ក្រសួងទេសចរណ៍បានសហការជាមួយក្រុមហ៊ុន Raffles International Resort បានរៀបចំការប្រគុំតន្រ្តីសប្បុរសធម៌ (Charity Concert) ដ៏ធំមួយនៅក្នុងបរិវេណអង្គរ ដោយមានការចូលរួមរបស់លោក José Carreras អ្នកចំរៀង Opera ដ៏ល្បីល្បាញលើពិភពលោក និងមានភ្ញៀវទេសចរណ៍អន្តរជាតិចូលរួមទស្សនាប្រមាណជាងមួយពាន់នាក់ ។ ព្រឹត្តិការណ៍សំខាន់ៗដទៃទៀត រួមមានការរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៨នៃវេទិកាទេសចរណ៍អាស៊ាន (ATF 2003) នៅក្រុងភ្នំពេញកាលពីខែមករា ឆ្នាំ២០០៣ ការរៀបចំទិវាសប្តាហ៍វប្បធម៌អាស៊ាន (ASEAN Cultural Week) ការរៀបចំសន្និសីទព្រះពុទ្ធសាសនាពិភពលោក ការរៀបចំកិច្ចប្រជុំកំពូលលើកទី៦នៃមហាអនុតំបន់ទន្លេមេគង្គ (GMS Summit) និងការរៀបចំមហោស្រព

សិល្បៈតន្ត្រីបូរាណកម្ពុជា-ជប៉ុន នៅខេត្តសៀមរាប កាលពីខែវិច្ឆិកា ឆ្នាំ២០០៣ ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៥០ នៃកំណើតទំនាក់ទំនងការទូតរវាងកម្ពុជា-ជប៉ុន ។ ប្រទេសមួយចំនួនក៏បានចូលរួមជួយផ្សព្វផ្សាយកម្មវិធីស្តីពីតំបន់ទេសចរណ៍នានានៅកម្ពុជា តាមបណ្តាញផ្សាយពត៌មានរបស់ខ្លួនផងដែរ ។ បណ្តាញពត៌មានទាំងនោះមានជាអាទិ៍ ទូរទស្សន៍ NHK របស់ជប៉ុន ទូរទស្សន៍ NBC របស់សហរដ្ឋ អាមេរិក ទូរទស្សន៍ TV5 របស់បារាំង ទូរទស្សន៍ Geographic Channel, Discovery, BBC, និង CNN ។

**វិស័យពាណិជ្ជកម្ម**

១៤១- វិស័យពាណិជ្ជកម្មនៅកម្ពុជានៅតែមានសារៈសំខាន់ជាមូលដ្ឋានសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងជាកាលានុវត្តភាពសំរាប់បង្កើតការងារ ។ ពាក់កណ្តាលនៃកំណើន ផ.ស.ស ក្នុងចន្លោះឆ្នាំ១៩៩៩ និង២០០៣ បានមកពីវិស័យឧស្សាហកម្មកាត់ដេរ ដែលនៅតែជាវិស័យចំបងរបស់ពាណិជ្ជកម្មកម្ពុជា ។ រហូតមកដល់បច្ចុប្បន្ននេះ សកម្មភាពពាណិជ្ជកម្មនៅកម្ពុជាបានទទួលអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្ម អនុគ្រោះដូចជាប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មទូទៅ (GSP) និងកម្មវិធីគ្រប់បែបយ៉ាងលើកលែងតែអាវុធ (EBA) ។

១៤២- **ការចូលជាសមាជិកក្នុងអង្គការពាណិជ្ជកម្មពិភពលោក** (WTO) : កម្ពុជាបានក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៣ នៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី៥ នាទីក្រុងកិនគុណ ប្រទេសម៉ិចស៊ិចកូ ក្នុងឋានៈជាប្រទេសក្រីក្របំផុតដំបូង ក្នុងចំណោមប្រទេសក្រីក្របំផុតពីរជាមួយនឹងប្រទេសនេប៉ាល់ ដែលបានចូលជាសមាជិកអង្គការនេះ ។ ការចូលជាសមាជិកអង្គការ WTO ជាជំហានចុងក្រោយ ក្នុងការនាំកម្ពុជាចូលទៅក្នុងអង្គការតំបន់ និងពិភពលោក ដែលគ្រប់គ្រងទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិ ។ គុណប្រយោជន៍ដែលបានមកពីការចូលរួមរបស់កម្ពុជានៅក្នុង WTO នឹងអាចកំណត់បានតាមរយៈទំហំទីផ្សារដែលកម្ពុជាអាចជ្រៀតចូលបាន និងការធ្វើអោយប្រសើរឡើងនូវប្រព័ន្ធអភិបាលកិច្ចដែលជាសញ្ញាវិជ្ជមានមួយសំរាប់ដៃគូពាណិជ្ជកម្ម និងវិនិយោគ ។ ការចូលជាសមាជិកអង្គការ WTO មិនត្រឹមតែជាបញ្ហាប្រឈមសំរាប់វិស័យឧស្សាហកម្មកាត់ដេរនៅកម្ពុជា ដែលត្រូវប្រកួតប្រជែងអោយកាន់តែមានភាពខ្លាំងក្លាជាងមុននៅក្នុងទីផ្សារតំបន់និងទីផ្សារពិភពលោកប៉ុណ្ណោះទេ ប៉ុន្តែវាជាកាលានុវត្តភាពសំរាប់ពង្រីកវិស័យនេះថែមទៀត តាមរយៈការលុបបំបាត់កូតាក្នុងការនាំចេញសំលៀកបំពាក់ពីកម្ពុជាទៅកាន់ប្រទេស១៤៧ទៀត ដែលជាសមាជិករបស់ WTO ដោយឈរលើគោលការណ៍ MFN និងការមិនរើសអើង ។ ក្នុងឋានៈជាសមាជិករបស់អង្គការ WTO និងសមាគម ASEAN កម្ពុជានឹងមានលទ្ធភាពចូលរួមក្នុងតំបន់ពាណិជ្ជកម្មសេរីទ្វេភាគីជាមួយសហរដ្ឋអាមេរិក ក្រោមគំនិតផ្តួចផ្តើមសហគ្រាសសំរាប់អាស៊ាន (EAI) របស់សហរដ្ឋអាមេរិក ។

១៤៣- **សមាហរណកម្មចូលទៅក្នុងតំបន់** : កម្ពុជាបានក្លាយជាសមាជិករបស់អាស៊ានក្នុងឆ្នាំ ១៩៩៩ ។ ក្នុងនាមជាសមាជិកថ្មី កម្ពុជាបានទទួលអត្ថប្រយោជន៍ពីគំនិតផ្តួចផ្តើមថ្មីៗជាច្រើនពីប្រទេសដែលជាសមាជិកជឿនលឿននៃអាស៊ាន ដូចជាប្រព័ន្ធអនុគ្រោះសមាហរណកម្មអាស៊ាន AISP (៣៤៩ មុខទំនិញ) ជាដើម។ ជាមួយគ្នានេះដែរ កម្ពុជាក៏នៅបានទទួលអត្ថប្រយោជន៍ពីកិច្ចសហប្រតិបត្តិការផ្នែកក្របខ័ណ្ឌជាមួយនឹងដៃគូពាណិជ្ជកម្មមួយចំនួនរបស់អាស៊ាន ដូចជាប្រព័ន្ធពន្ធគយអនុគ្រោះ SPT ពីប្រទេសចិន (ទំនិញ ២៩៧ មុខ) ប្រព័ន្ធអនុគ្រោះទូទៅGSPពីប្រទេសជប៉ុន (ទំនិញ២២៦មុខ) និងសាធារណរដ្ឋកូរ៉េ (៧៨មុខទំនិញ) ។ កម្ពុជាបានបន្តកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការចាប់យកឱកាសពង្រីកការធ្វើពាណិជ្ជកម្មក្នុងក្របខ័ណ្ឌ "ត្បូង-ត្បូង" ជាមួយនិងបណ្តាប្រទេសដែលជាសមាជិកនិងមិនមែនសមាជិកអាស៊ាន ។ រាជរដ្ឋាភិបាលកំពុងពិចារណាអំពីលទ្ធភាពក្នុងការចូលរួមក្នុងប្រព័ន្ធនៃការអនុគ្រោះពន្ធគយសកល ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីជាបច្ច័យក្នុងការជំរុញបន្ថែមទៀតការរីកចំរើននៃពាណិជ្ជកម្ម ។ គំនិតផ្តួចផ្តើមដែលមានលក្ខណៈគួរអោយកត់សំគាល់របស់អាស៊ាន មានដូចជាកិច្ចព្រមព្រៀងផ្នែកក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការអាស៊ាន-ចិន ក្របខ័ណ្ឌស្តីពីភាពជាដៃគូផ្នែកសេដ្ឋកិច្ចអាស៊ាន-ជប៉ុន កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចឥណ្ឌា-អាស៊ាន តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េខាងត្បូង និងក្នុងពេលឆាប់ៗខាងមុខនេះមានតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ទំនាក់ទំនងសេដ្ឋកិច្ចជិតស្និទ្ធអូស្ត្រាលីនូវែលសេឡង់ (AFTA-CER) ។ ជាមួយនឹងកំណើនវិនិយោគផលិតកម្មនិងការប្រើប្រាស់នៅក្នុងប្រទេសជាដៃគូអាស៊ាន តំរូវការនៃធាតុចូលសំរាប់ផលិតកម្ម និងទំនិញដែលផលិតចេញពីប្រទេសដែលជា សមាជិកអាស៊ាននឹងមានតំរូវការកាន់តែខ្លាំងឡើង ដោយក្នុងនោះមានរាប់ទាំងប្រទេសកម្ពុជាផងដែរ ។ ការទទួលបានទីផ្សារនៅក្នុងប្រទេសដែលជាដៃគូអាស៊ាននឹងក្លាយជាគន្លឹះមួយ សំរាប់ការលូតលាស់របស់សេដ្ឋកិច្ចកម្ពុជា ។

១៤៤- នាកិច្ចប្រជុំកំពូលអាស៊ានទីក្រុងបាលីថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០០៣ ថ្នាក់ដឹកនាំអាស៊ានទាំងអស់បានមូលមតិគ្នាបង្កើតអោយមានសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) មួយត្រឹមដំណាច់ឆ្នាំ ២០២០ ។ គោលដៅគឺបង្កើតអោយមានទីផ្សារ និងទំហំផលិតកម្មរួមមួយ ដែលមានតំលៃជាអ្នកប្រើប្រាស់៥០០លាននាក់ និងមាន ផ.ស.សប្រមាណជាង៦.០០០លានដុល្លារអាមេរិក នាឆ្នាំ២០០២ ។

១៤៥- **សមាហរណកម្មសេដ្ឋកិច្ចអនុតំបន់** : គំនិតផ្តួចផ្តើមអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម នៅតាមអនុតំបន់ ដែលគួរអោយកត់សំគាល់ មានដូចជា មហាអនុតំបន់ទន្លេមេគង្គ ការអភិវឌ្ឍន៍រួមគ្នារវាងកម្ពុជា-ថៃនៅក្នុងក្របខ័ណ្ឌសហប្រតិបត្តិការសេដ្ឋកិច្ច Ayeyawady Chao Phraya Mekong (ACMECS) តំបន់ត្រីកោណកម្ពុជា-ឡាវ-ថៃ និងតំបន់អភិវឌ្ឍន៍ត្រីកោណវៀតណាម-ឡាវ-កម្ពុជា ។

១៤៦- **កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មទ្វេភាគី** : ទំនាក់ទំនងពាណិជ្ជកម្មទ្វេភាគីជាមួយថៃ មានភាពប្រសើរឡើងជាប្រចាំ ។ ក្រៅពីពាណិជ្ជកម្ម កម្ពុជាបានក្តាប់យកនូវឱកាសដទៃទៀតដើម្បីពង្រីកប្រតិបត្តិការពាណិជ្ជកម្មជាមួយប្រទេសថៃ ។ រាជរដ្ឋាភិបាលបាននិងកំពុងពិចារណាបង្កើតអោយមានយន្តការគណនី

ពាណិជ្ជកម្មជាមួយប្រទេសថៃ សំដៅកែលំអប្រតិបត្តិការពាណិជ្ជកម្ម និងប្រតិបត្តិការធុរកិច្ចអន្តរជាតិ ដូចជា ការធានារបស់រដ្ឋាភិបាលចំពោះការទូទាត់ពាណិជ្ជកម្ម និងកាត់បន្ថយការពឹងផ្អែកលើប្រតិបត្តិការផ្ទេរជារូបិយវត្ថុ និងកំរែធនាគារនៅក្នុងពាណិជ្ជកម្មអន្តរជាតិ ។ ប្រទេសថៃបានយល់ព្រមអោយនាំចូលទំនិញ ៣១០មុខពីប្រទេសកម្ពុជា នៅក្រោមប្រព័ន្ធអនុគ្រោះសមាហរណកម្មអាស៊ាន AISP ។ តាមរយៈគោលនយោបាយពាណិជ្ជកម្មសេរី ឬ ការនាំចូលដោយមិនជាប់ពន្ធរបស់ ACMECS ប្រទេសថៃបានបញ្ជាក់ពីគោលជំហររបស់ខ្លួនម្តងទៀតក្នុងការទិញផលិតផលកសិកម្មពីកម្ពុជា ដូចជា សណ្តែកសៀង ពោត គ្រាប់ល្ហុង ដំឡូង ពោតផ្អែម គ្រាប់ស្វាយចន្ទី និងសណ្តែកដី ។ គំនិតផ្តួចផ្តើមក្នុងក្របខ័ណ្ឌ ACMECS ផ្សេងទៀតមានដូចជា ការសិក្សាពីលទ្ធភាពក្នុងការបង្កើតអោយមានទីផ្សារលក់ដុំ/នាំចេញនៅក្នុងប្រទេសកម្ពុជា និងការសិក្សាពីលទ្ធភាពក្នុងការបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅខេត្តកោះកុង ប៉ោយប៉ែត និងក្រុងប៉ៃលិន ។

១៤៧- ទំនាក់ទំនងពាណិជ្ជកម្មទ្វេភាគីជាមួយប្រទេសចិន បានកើនឡើងគួរអោយកត់សំគាល់ មានតំលៃ ៣២០ លានដុល្លាអាមេរិក ក្នុងឆ្នាំ២០០៣ ។ ចិនបានផ្តល់ពន្ធអនុគ្រោះដល់ទំនិញ ២៧៩មុខពីកម្ពុជា ដែលភាគច្រើនជាផលិតផលកសិកម្ម និងកំពុងគិតគូរបង្កើនបញ្ជីមុខទំនិញនេះអោយដល់ ៤៣៩មុខ ។ នៅក្នុងផ្នែកវាយនភ័ណ្ឌ ប្រទេសចិនបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាមួយ ក្នុងការបង្កើតរោងចក្រតម្បាញមួយដែលមានជុំរហាត់ ៥០០.០០០ជុំ នៅតំបន់ឧស្សាហកម្មវាយនភ័ណ្ឌក្រុងព្រះសីហនុ ។ បន្ថែមពីនេះទៀត សភាពាណិជ្ជកម្មកម្ពុជាក៏បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាផងដែរជាមួយក្រុមប្រឹក្សាជំរុញពាណិជ្ជកម្មអន្តរជាតិចិន សំដៅជំរុញទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការបច្ចេកវិទ្យា ។

១៤៨- ក្នុងឆ្នាំ ២០០៣ ប្រទេសកាណាដាបានផ្តល់ភាពអនុគ្រោះដោយមិនអោយជាប់ពន្ធគយ និងកូតាសំរាប់ផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់ដែលនាំចេញពីប្រទេសកម្ពុជា ។

១៤៩- ក្នុងឆ្នាំ ២០០២ កម្ពុជានិងវៀតណាមបានចុះហត្ថលេខាឡើងវិញលើកិច្ចព្រមព្រៀងស្តីពីទំនិញឆ្លងកាត់ព្រំដែន ដើម្បីជាការជួយសំរួលដល់ការនាំចេញទំនិញពីកម្ពុជាឆ្ពោះទៅកាន់ប្រទេសទីបី ដោយឆ្លងកាត់ប្រទេសវៀតណាម ។ នៅក្នុងឆ្នាំ ២០០១ កម្ពុជា និងវៀតណាមបានចុះហត្ថលេខារួចមកហើយលើកិច្ចព្រមព្រៀងពាណិជ្ជកម្មតាមព្រំដែន ដើម្បីពង្រីកការផ្លាស់ប្តូរទំនិញជាប្រពៃណីរវាងប្រជាជននៃប្រទេសទាំងពីរ ។

១៥០- កម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយសហភាពអឺរ៉ុប ក្នុងការនាំចេញទំនិញវាយនភ័ណ្ឌ ដោយគ្មានជាប់កូតានិងពន្ធគយចាប់តាំងពីឆ្នាំ១៩៩៩មក ។ ចាប់ពីឆ្នាំ២០០១ សហភាពអឺរ៉ុបបានអនុវត្តគោលនយោបាយអ្វីៗទាំងអស់ដែលមិនមែនអាវុធ (EBA) ដល់ប្រទេសក្រីក្របំផុតទាំងអស់ដែលរួមមានកម្ពុជាផងដែរ ដោយអនុញ្ញាតអោយនាំទំនិញទាំងអស់ចូលទៅកាន់សហភាពអឺរ៉ុបដោយមិនកំណត់កូតា និង ពន្ធគយ លើកលែងតែគ្រឿងសព្វាវុធ ។

១៥១- កម្ពុជាបានចុះហត្ថលេខាជាមួយសហរដ្ឋអាមេរិកក្នុងឆ្នាំ ១៩៩៦ លើកិច្ចព្រមព្រៀងពាណិជ្ជកម្ម ដែលផ្តល់អោយកម្ពុជានូវឋានៈ MFN ក្នុងការនាំចេញទំនិញទៅកាន់សហរដ្ឋអាមេរិក ។ កិច្ចព្រមព្រៀងនេះបានផ្តល់លទ្ធភាពអោយកម្ពុជានាំចេញទំនិញទៅសហរដ្ឋអាមេរិក ដោយបង់ពន្ធស្មើនឹងប្រទេសដែលជាសមាជិក WTO ។ សហរដ្ឋអាមេរិកបានផ្តល់GPSដល់កម្ពុជាក្នុងឆ្នាំ១៩៩៧ផងដែរ។ នៅក្នុងឆ្នាំ១៩៩៩ កម្ពុជា និងសហរដ្ឋអាមេរិកក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងវាយនភ័ណ្ឌ ដែលអនុញ្ញាតអោយកម្ពុជានាំចូលដោយកំណត់កូតាលើមុខទំនិញវាយនភ័ណ្ឌចំនួន ១១មុខ ។

១៥២- **ការរួមចំណែកកាត់បន្ថយភាពក្រីក្រ** : យុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រដែលរាជរដ្ឋាភិបាលបានអនុម័តនៅខែមិនា ឆ្នាំ២០០៣ បានបញ្ចូលផងដែរ ការរួមចំណែករបស់វិស័យពាណិជ្ជកម្មក្នុងការកាត់បន្ថយភាពក្រីក្រ ។ ម៉ាទ្រីសគោលនយោបាយអំពីវិស័យពាណិជ្ជកម្មបានគូសបញ្ជាក់នូវគោលដៅ និងយុទ្ធសាស្រ្តក្នុងការកាត់បន្ថយភាពក្រីក្រ ដោយរួមមានទាំងវិធានការសំរាប់ធ្វើការតាមដានលទ្ធផលវាយតំលៃផល ប៉ះពាល់ និងការកែសំរួលនូវដំណើរការទាំងនេះ ។ គោលបំណងជាចំបងគឺការពារ និងរក្សាអោយបាននូវការងារជូនកម្មករកាត់ដេរ ២៥០.០០០នាក់ និងប្រជាពលរដ្ឋប្រមាណ ១,៥ លាននាក់ទៀតដែលជីវភាពរបស់ពួកគេកំពុងពឹងផ្អែកលើអ្នកទាំងនេះ ហើយព្រមជាមួយគ្នានេះ ពង្រឹង និងពង្រីកមូលដ្ឋាននៃការនាំចេញសំរាប់ប្រទេសកម្ពុជាផងដែរ ។

១៥៣- រាជរដ្ឋាភិបាលនឹងផ្តល់ការយកចិត្តទុកដាក់ជាពិសេសដល់ការបង្កើនតំលៃបន្ថែមក្នុងស្រុក នៃសមាសភាគដែលត្រូវធ្វើការនាំចេញ និងខិតខំអភិវឌ្ឍវិស័យដែលត្រូវធ្វើការនាំចេញបន្ថែមទៀត ដើម្បីបង្កើនការរួមចំណែករបស់វិស័យពាណិជ្ជកម្មដល់ការកាត់បន្ថយភាពក្រីក្រ។ រុក្ខជាតិ ជាពិសេសគ្រាប់ធញ្ញជាតិ ការកែច្នៃកសិកម្ម ការចិញ្ចឹមនិងកែច្នៃត្រី ការបំរើសេវាតាមជំនាញ (ឧទាហរណ៍ ការបង្កើត Software) ជាវិស័យដែលអាចផ្តល់ជាកាលានុវត្តភាពដល់កម្ពុជា ។ ក្រៅពីខិតខំបង្កើនតំលៃបន្ថែមនៃផលិតផលដែលត្រូវនាំ ចេញកម្ពុជាត្រូវរៀបចំធ្វើវិមជ្ឈការផលិតកម្មបន្ថែមទៀត ដើម្បីទាញយកផលប្រយោជន៍ពីសកលភាវូបនីយកម្មបែងចែកអោយបានទូលំទូលាយដល់ប្រជាជនក្នុងស្រុក ។

១៥៤- ក្នុងរយៈពេលប្រាំឆ្នាំកន្លងទៅនេះ មានការសិក្សាស្រាវជ្រាវមួយចំនួនធំដែលបានទទួលការឧបត្ថម្ភពីប្រទេសដែលជាដៃគូអភិវឌ្ឍន៍ ដែលរួមមានការសិក្សាស្តីពីការអភិវឌ្ឍន៍តំបន់ច្រករបៀងភ្នំពេញ- ក្រុងព្រះសីហនុ ការធ្វើអោយប្រសើរនូវប្រព័ន្ធស្វែងរកទីផ្សារ និងការគ្រប់គ្រងគុណភាពស្រូវក្រោយពេលប្រមូលផល ការសិក្សាស្តីពីការបង្កើតទីផ្សារស្រូវ ការវាយតំលៃវិស័យឯកជននិងការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និង មធ្យម ការសិក្សាពីស្ថានភាពកសិឧស្សាហកម្មនៅកម្ពុជា កម្មវិធីកាត់បន្ថយភាពក្រីក្រតាមរយៈការនាំចេញ ការសិក្សាស្តីអំពីពិពិធកម្មកសិកម្មនិងសមត្ថភាពផ្គត់ផ្គង់កសិឧស្សាហកម្ម និងការសិក្សាពីឥទ្ធិពលការកាត់បន្ថយភាពក្រីក្រ តាមរយៈតំបន់ជុំវិញការនាំចេញ ។

១៥៥- វិស័យពាណិជ្ជកម្មនៅកម្ពុជា ក៏នៅបានទទួលអត្ថប្រយោជន៍ពីក្របខ័ណ្ឌសមាហរណកម្មសំរាប់ជំនួយ បច្ចេកទេសពាក់ព័ន្ធពាណិជ្ជកម្មចំពោះប្រទេសក្រីក្រ (Integrated Framework for Trade Related Technical Assistance to Least Developed Countries-IF) ក្នុងការកំណត់យុទ្ធសាស្រ្តពាណិជ្ជកម្មដែលផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋក្រីក្ររបស់កម្ពុជា ។ ក្របខ័ណ្ឌ IF នៅកម្ពុជា គឺជាការសំរេចបានប្រកបដោយប្រសិទ្ធភាព ដែលគួរតែចាត់ជាករណីគំរូមួយបើប្រៀបធៀបនឹងប្រទេសដទៃទៀតដែលបានប្រើប្រាស់វិធីសាស្រ្តនិងដំណើរការប្រហាក់ប្រហែលនឹងប្រទេសកម្ពុជា ។

## ២.៤.៣ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

| ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត |
|---|
| - ការដឹកជញ្ជូន |
| - ធនធានទឹក និងឧតុនិយម |
| - ទឹកស្អាត |
| - ការផលិតថាមពលអគ្គិសនី និងចែកចាយ |
| - ប្រៃសណីយ៍ ទូរគមនាគមន៍ និងសេវាពត៌មាន |

### ការដឹកជញ្ជូន

១៥៦- ទោះបីជាកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល នៅក្នុងនីតិកាលទី២នៃរដ្ឋសភា (១៩៩៨-២០០៣) ក្នុងការស្តារ និងកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនបានសំរេចលទ្ធផលប្រកបដោយជោគជ័យជាច្រើនគួរកត់សំគាល់ ក៏ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនាបច្ចុប្បន្ននៅមិនទាន់អាចឆ្លើយតបទៅនឹងតំរូវការនៃកំណើនសេដ្ឋកិច្ច ទាំងក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគតបាននៅឡើយ ។ កង្វះខាតថវិការដ្ឋបានកំហិតការងារស្តារ និងកសាងឡើងវិញ ពិសេសការថែរក្សាហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ។ ក្នុងរយៈពេល៥ឆ្នាំកន្លងមក រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងដល់ការស្តារ និងកសាងឡើងវិញនូវបណ្តាញផ្លូវថ្នល់ និងពង្រីកបន្ថែមកំពង់ផែទឹកជ្រៅអន្តរជាតិក្រុងព្រះសីហនុ ព្រមទាំងព្រលានយន្តហោះអន្តរជាតិនៅរាជធានីភ្នំពេញ និងសៀមរាប ។

១៥៧- **ការដឹកជញ្ជូនតាមផ្លូវគោក**មានតួនាទីសំខាន់ ក្នុងការដឹកទំនិញចុះឡើងក្នុងទូទាំងផ្ទៃប្រទេស ។ ប្រព័ន្ធផ្លូវថ្នល់ ពិសេសផ្លូវជាតិតភ្ជាប់ទៅបណ្តាប្រទេសជិតខាង ដូចជា វៀតណាម ឡាវ និងថៃ មិនទាន់ត្រូវបានស្តារចប់រួចរាល់នៅឡើយ ។ ការស្តារឡើងវិញ ការកែលំអ និងការតភ្ជាប់ផ្លូវជាតិសំខាន់ៗ គឺជាអាទិភាពខ្ពស់មួយរបស់រាជរដ្ឋាភិបាល ។

១៥៨- ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ដោយមានជំនួយឧបត្ថម្ភពីប្រទេសជប៉ុន ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក និងបណ្តាភ្នាក់ងារទ្វេភាគីដទៃទៀត ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលនានា រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ទៅលើការស្តារឡើងវិញនូវបណ្តាញផ្លូវជាតិ រួមទាំងស្ពាន និងសាឡាងដើម្បីជួយសំរួលដល់ការដឹកជញ្ជូនទំនិញ និងសមាហរណកម្មទីផ្សារ ។ ក្នុងចន្លោះឆ្នាំ ១៩៩៨-២០០៣ ផ្លូវគមនាគមន៍ប្រវែងសរុបប្រមាណ២.៣៥០គម ត្រូវបានស្តារនិងកសាងឡើងវិញ ដោយជំនួយឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍ និងពីថវិការដ្ឋ ។ គំរោងសំខាន់ៗនៅក្នុងផ្នែកនេះរួមមាន ÷ ស្ពានឆ្លងកាត់ទន្លេមេគង្គនៅទីរួម

ខេត្តកំពង់ចាម (ខែកុម្ភៈ ឆ្នាំ២០០២) ស្ពាននៅខេត្តកោះកុង (ឆ្នាំ ២០០១) ការកែលំអឡើងវិញនូវកំណាត់ផ្លូវជាតិលេខ៦ និងលេខ៧ ពីភ្នំពេញទៅកំពង់ចាម ហើយនឹងការស្តារឡើងវិញនូវកំណាត់ផ្លូវជាតិលេខ១ លេខ២ លេខ៣ លេខ៥ លេខ១១ លេខ២១ លេខ៣១ លេខ៣៣ លេខ៦១ លេខ៦៣ លេខ៦៦ និងលេខ៧២ ព្រមទាំងការស្តារ និងការសាងសង់ថ្មីស្ពានមួយចំនួន ជាពិសេសស្ពាននៅតាមផ្លូវជាតិលេខ១ លេខ៥ លេខ៦ និងលេខ៧ ។

១៥៩- ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានផ្តល់ថវិការដ្ឋមួយចំនួន សំរាប់ជួសជុលនិងស្តារឡើងវិញ នូវផ្លូវគមនាគមន៍ប្រវែង២.០៩៦គម ដែលជាផ្លូវក្រាលគ្រួសក្រហម និងកំណាត់ផ្លូវជាតិសំខាន់ៗ និងផ្លូវខេត្តមួយចំនួនដែរ ដូចជាផ្លូវជាតិលេខ៤៨ លេខ៥៦ លេខ៥៧ លេខ ៥៨ លេខ ៥៩ លេខ ៦៧ លេខ ៦៩អា លេខ៧៣ លេខ៧៦ លេខ៧៨ ។ល។ ដើម្បីតភ្ជាប់ជាមួយនឹងតំបន់ដាច់ស្រយាល សំដៅជួយជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ចនៅតាមតំបន់ជនបទ ។ រាជរដ្ឋាភិបាលមានផែនការជំរុញល្បឿននៃការស្តារបណ្តាញផ្លូវ ដោយអនុវត្តតាមគោលនយោបាយ "សាងសង់តាមដំណាក់កាល " តាមការសំរួលនីតិវិធីចុះកិច្ចសន្យា និងតាមការអនុវត្តន៍បច្ចេកទេសស្តារផ្លូវសំរាប់អាយុកាលខ្លីៗ (៥ឆ្នាំ) ។

១៦០- ជារួម រាជរដ្ឋាភិបាលគ្រោងនឹងបញ្ចប់ការស្តារឡើងវិញនូវបណ្តាញផ្លូវជាតិសំខាន់ៗ (ផ្លូវជាតិលេខ១ ដល់លេខ៧) ដែលមានប្រវែងសរុប១.៩៨៨គម នាចុងឆ្នាំ ២០០៧ ខាងមុខនេះ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលគ្រោងស្តារឡើងវិញ និងសាងសង់ជាថ្មី នូវផ្លូវថ្នល់ប្រវែង១.៨៥០គម ដោយអនុវត្តបច្ចេកទេសស្តារសំរាប់អាយុកាលខ្លី ។ អាទិភាពទី១ គឺការស្តារបណ្តាញផ្លូវជាតិលំដាប់ទី២ ដែលតភ្ជាប់ពីភ្នំពេញទៅទីរួមខេត្ត នានា ។ ចំណែកអាទិភាពទី២ គឺផ្តោតទៅលើការស្តារបណ្តាញផ្លូវជាតិនិងផ្លូវខេត្ត ដែលតភ្ជាប់ពីខេត្តមួយ ទៅខេត្តមួយ ។

១៦១- ការងារថែទាំផ្លូវគឺជាអាទិភាពចំបងរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី២ ។ រាជរដ្ឋាភិបាលបានចំណាយថវិការដ្ឋប្រមាណ៥-១០លានដុល្លាអាមេរិកក្នុងមួយឆ្នាំសំរាប់ចំណាយថែទាំផ្លូវ ។

១៦២- **ផ្លូវដែក** : បច្ចុប្បន្ន កម្ពុជាមានផ្លូវដែកតែពីរខ្សែប៉ុណ្ណោះ ហើយមានសភាពអន់ថយទៀតផង ដោយសារការបំផ្លិចបំផ្លាញ និងកង្វះការថែរក្សា ។ ផ្លូវដែកដែលស្ថិតនៅភាគខាងជើង ដែលតភ្ជាប់ពីភ្នំពេញទៅប៉ោយប៉ែត មានប្រវែង៣៨៥គ.ម ហើយកំណាត់ផ្លូវពីស៊ីសុផុន-ប៉ោយប៉ែតបានផ្អាកដំណើរការចាប់តាំងពីដើមទស្សវត្សទី៧០មកម្ល៉េះ ។ ផ្លូវដែកដែលស្ថិតនៅភាគខាងត្បូងតភ្ជាប់ពីភ្នំពេញទៅក្រុងព្រះសីហនុ មានប្រវែង២៦៣គ.ម ។ ការជួសជុលបន្ទាន់នូវកំណាត់ផ្លូវដែកសំខាន់ៗ រួមទាំងស្ពាននានានៅលើផ្លូវដែក ទាំងពីរខ្សែនេះ ត្រូវបានអនុវត្តក្រោមគំរោងស្តារបន្ទាន់ក្រោយគ្រោះទឹកជំនន់ ដែលផ្តល់ហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី និងថវិការដ្ឋ ។

១៦៣- **ការដឹកជញ្ជូនតាមផ្លូវទឹក** គឺជាមធ្យោបាយដ៏សំខាន់មួយនៃការធ្វើដំណើរកាលពីអតីតកាលមក ។ កំពង់ផែ និងផ្លូវទឹកបានដើរតួនាទីយ៉ាងសំខាន់បំផុតនៅក្នុងប្រទេស ។ ផលិតផលកសិកម្ម និងព្រៃឈើ ប្រេង និងការផ្ទុកទំនិញធំៗ ព្រមទាំងគ្រឿងចក្រធុនធ្ងន់ ត្រូវបានដឹកជញ្ជូនតាមនាវា ។ ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវទឹកមានសារៈសំខាន់ផងដែរ ក្នុងការជួយបំពេញបន្ថែមអោយសេវាកម្មដឹកជញ្ជូនតាមផ្លូវគោក ដែលពុំទាន់មានលក្ខណៈល្អប្រសើរទាំងស្រុងនៅឡើយ ។ បច្ចុប្បន្ន ចរាចរផ្លូវទឹកភាគច្រើនគឺស្ថិតនៅលើទន្លេមេគង្គ រវាងទីក្រុងភ្នំពេញ និងទីក្រុងហូជីមិញ និងពីទីក្រុងភ្នំពេញឡើងទៅខេត្តក្រចេះ ។ នាវាចំណុះ ៥.០០០តោន អាចចរាចរស្ទើរពេញមួយឆ្នាំ តាមបណ្តោយទន្លេមេគង្គរហូតដល់ភ្នំពេញ ។ នាវាតូចៗ និងមានចំណុះទាបអាចធ្វើចរាចរលើដងទន្លេដទៃទៀត ។ ទោះបីរាជរដ្ឋាភិបាលបានរៀបចំគំរោងអភិវឌ្ឍន៍កំពង់ផែនិងផ្លូវទឹកក៏ដោយ ក៏គំរោងមួយចំនួនតូចប៉ុណ្ណោះត្រូវបានអនុវត្ត ។ ក្នុងរយៈពេលថ្មីៗកន្លងមកនេះ យើងសង្កេតឃើញមាននិន្នាការកើនឡើងនៃការដឹកជញ្ជូនតាមផ្លូវគោកច្រើនជាងការដឹកជញ្ជូនតាមផ្លូវទឹក ។

១៦៤- **កំពង់ផែអន្តរជាតិនិងការដឹកជញ្ជូន** : កំពង់ផែសំខាន់ៗទាំងពីរ ដែលបំរើអោយការងារពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជារួមមាន កំពង់ផែភ្នំពេញ និងកំពង់ផែក្រុងព្រះសីហនុ ។ កំពង់ផែភ្នំពេញ គឺជាកំពង់ផែអន្តរជាតិ ដែលស្ថិតនៅលើដងទន្លេសាបត្រើយខាងលិច មានចំងាយប្រមាណ ៣៣២គម ពីសមុទ្រ ហើយដែលស្ថិតនៅលើចំណុចយុទ្ធសាស្ត្រនៃតំបន់ពាណិជ្ជកម្ម និងឧស្សាហកម្មរបស់ប្រទេស ព្រមទាំងជាចំណុចដែលតភ្ជាប់បណ្តាញផ្លូវទឹកនានា ។ ក្នុងឆ្នាំ ១៩៩៥ កំពង់ផែភ្នំពេញត្រូវបានស្តារ និងបានសាងសង់ទីលានផែសារជាថ្មីឡើងវិញ ដែលមានបណ្តោយ ៣០០ម និងទទឹង ២០ម ។ ផែថ្មីនេះមានសមត្ថភាពផ្ទុក និងលើកដាក់ទំនិញ ពី ២.៥០០តោន ទៅ ៥.០០០តោន ទាំងក្នុងរដូវប្រាំង និងរដូវវស្សា ។ ក្នុងឆ្នាំ២០០២ និង ២០០៣ ការលើកដាក់ទំនិញនៅកំពង់ផែនេះ មានប្រមាណ ៤២៧.៣៦៨ តោន និង៥៣៣.៦៥៩តោន ។ គេរំពឹងថា ការលើកដាក់កុងតែន័រនៅកំពង់ផែភ្នំពេញនឹងបន្តកើនឡើងបន្ថែមទៀត ដោយសារឧត្តមភាពប្រៀបធៀបរបស់កំពង់ផែនេះ ។

១៦៥- **កំពង់ផែក្រុងព្រះសីហនុ** ស្ថិតនៅចំងាយ២៣០គ.ម ផ្នែកខាងត្បូងឈៀងខាងលិចរាជធានីភ្នំពេញ ។ កំពង់ផែនេះជាកំពង់ផែទឹកជ្រៅតែមួយគត់របស់កម្ពុជា ដែលមានសមត្ថភាពផ្ទុកកុងតែន័រទំនិញបានច្រើនជាងគេ ។ ប្រមាណ៧០%នៃទំនិញនាំចូលមកកម្ពុជា ត្រូវបានឆ្លងកាត់កំពង់ផែក្រុងព្រះសីហនុ រួចទើបធ្វើការដឹកជញ្ជូនតាមផ្លូវដែកនិងផ្លូវថ្នល់ ។ កំពង់ផែក្រុងព្រះសីហនុមានឧបករណ៍ស្ទូចប្រវែងរហូតដល់ ៧,៥ ទៅ ៨,៥ម ព្រមទាំងមានសមត្ថភាព១១.០០០GTR ។ ការផ្ទុកលើកដាក់ទំនិញមានទំហំលើស ១,៥លានតានក្នុងមួយឆ្នាំ (១,៧៧ តោនលានតោន ក្នុងឆ្នាំ២០០៣)។ បច្ចុប្បន្ន លទ្ធភាពកំពង់ផែក្នុង ការទទួលការផ្ទុក និងការលើកដាក់ទំនិញនៅមានកំរិតនៅឡើយ ។ ការងារស្តារឡើងវិញនៅកំពង់ផែបានចាប់ផ្តើមតាំងពីខែកក្កដា ឆ្នាំ២០០០ ក្រោមកម្ចីសម្បទានប្រមាណ៤១លានដុល្លាអាមេរិក ដែលរួមមានការសាងសង់ផែផ្ទុកថ្មីមួយប្រវែង ៤០០ម និងចំណតសំរាប់កប៉ាល់ចំនួន១១កន្លែង ប្រវែង២៤០ម ការសាងសង់ទីលានសំរាប់ផ្ទុកកុងតែន័រទំហំ៦០.០០០ម៉ែត្រទ្វេគុណ និង ៥០.៨០០ម៉ែត្រទ្វេគុណ ដែលមានជំរៅ

៨,៥-៩ម ។ ការសាងសង់គ្រោងនឹងបញ្ចប់នៅក្នុងឆ្នាំ២០០៥ ។ ការសាងសង់ដំណាក់ការទីពីរ ដែលនឹងគ្រោងចាប់ផ្តើមពីឆ្នាំ ២០០៤-២០០៧ ក្រោមកម្ចីសម្បទាន៣៥លានដុល្លាអាមេរិក រួមមានការសាងសង់ចំណតសំរាប់កប៉ាល់ធំៗចំនួន៣កន្លែង ប្រវែង៤៥០ម ជំរៅ ១០ម និងទីលានសំរាប់ផ្ទុកកុងតែន័រ ប្រវែង ៣០០ម និងជំរៅ ៨,៥ម ព្រមទាំងគ្រឿងចក្រស្ទូច និងលើកដាក់ទំនិញចំនួន ៤គ្រឿង ។

១៦៦- គោលនយោបាយរបស់រាជរដ្ឋាភិបាល គឺលើកទឹកចិត្តអោយមានការចូលរួមរបស់ផ្នែកឯកជនអោយកាន់តែច្រើនឡើង នៅក្នុងការផ្តល់សេវាដឹកជញ្ជូនផ្លូវគោក និងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ។ ក្រោមទំរង់ការ " សាងសង់- ដំណើរការ- និងផ្ទេរ (BOT) " ស្ពានខេត្តកោះកុង និងផ្លូវជាតិលេខ៤ ត្រូវបានផ្ទេរអោយក្រុមហ៊ុនឯកជនថែរក្សា ។ ផ្លូវពីបន្ទាយស្រីទៅកោះកែ ដែលមានចំងាយផ្លូវ១៣គម ពីផ្លូវជាតិលេខ៥ (ប៉ោយប៉ែត) ទៅព្រំដែនកម្ពុជា- ថៃ ត្រូវបាន និងកំពុងសាងសង់ដោយក្រុមហ៊ុនឯកជន ។ បណ្តាគំរោងផ្សេងៗទៀត ក្នុងវិស័យដឹកជញ្ជូន រួមមាន ការកែលំអកំពង់ផែភ្នំពេញ និងក្រុងព្រះសីហនុ កំពង់ផែកែវផុស ព្រលានយន្តហោះអន្តរជាតិភ្នំពេញ ដោយបំពាក់នូវប្រព័ន្ធត្រួតពិនិត្យចរាចរផ្លូវអាកាស និងអគាររង់ចាំសំរាប់អ្នកដំណើរ ព្រមទាំងការកែលំអព្រលានយន្តហោះសៀមរាប ត្រូវបានដាក់អោយដំណើរការតាមទំរង់ការ " សាងសង់- ដំណើរការ- និងផ្ទេរ (BOT)" ដែរ ។

**ធនធានទឹក និងឧតុនិយម**

១៦៧- តាមលក្ខណៈភូមិសាស្ត្រ ព្រះរាជាណាចក្រកម្ពុជាគឺជាប្រទេសមួយសម្បូរទៅដោយធនធានទឹក ។ ទន្លេ ស្ទឹង បឹងបួរ ល្អាងទឹកធម្មជាតិក្រោមដី និងសមុទ្រជាដើម គឺជាប្រភពធនធានទឹកដ៏សំខាន់សំរាប់បំរើការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។ ប្រព័ន្ធទន្លេមេគង្គកម្ពុជា រួមបញ្ចូលទាំងប្រព័ន្ធបឹងទន្លេសាបផង មានតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សា និងទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី ហើយគឺជាធនធានជាមូលដ្ឋាន សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។

១៦៨- ផ្នែកមួយនៃអាងទន្លេមេគង្គដែលស្ថិតនៅក្នុងប្រទេសកម្ពុជា បង្កើតអោយមានទឹកលើផ្ទៃដីប្រមាណ ៧៥.០០០លានម៣ ក្នុងមួយឆ្នាំ ដោយមិនគិតពីបរិមាណទឹក ដែលស្ថិតក្នុងតំបន់ផ្ទេរងទឹកភ្លៀង និងទឹក ក្រោមដី ដែលមានចំនួនប្រមាណ១៧.៦០០លានម៣ ។ បរិមាណទឹកនេះមានទំហំ១០០ដង ច្រើនជាងបរិមាណទឹកដែលបានប្រើប្រាស់នាពេលបច្ចុប្បន្ននេះ ។ កម្ពុជាបានទទួលទឹកភ្លៀងជាមធ្យមប្រមាណពី ១.៤០០មម ទៅ៣.៥០០មម ក្នុងមួយឆ្នាំ ។ ជារៀងរាល់ឆ្នាំ បរិមាណទឹកទន្លេមេគង្គប្រមាណ ៤៧៥.០០០លានម៣ បានហូរកាត់កម្ពុជាចាក់ទៅក្នុងសមុទ្រចិនភាគខាងត្បូង ។ ទោះបីកម្ពុជាជាប្រទេសមួយសំបូរដោយធនធានទឹកក៏ដោយ ក៏ប្រជាជនកម្ពុជាភាគច្រើនជួបប្រទះនឹងភាពខ្វះខាតទឹកនៅក្នុងរដូវប្រាំង ។ នៅក្នុងរដូវវស្សា តំបន់ខ្លះមានទឹកបរិបូរណ៍ រីឯតំបន់ខ្លះទៀតនៅជួបប្រទះកង្វះខាតទឹក ដោយសារពុំមានហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពគ្រប់គ្រាន់ ។ ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពនៅតែខ្វះខាត ហើយដែលទាមទារអោយមានការកែលំអជាបន្ទាន់ ។

១៦៩- ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ រាជរដ្ឋាភិបាលនីតិកាលទី ២នៃរដ្ឋសភា បានបង្កើតក្រសួងធនធាន ទឹក និងឧតុនិយម នាឆ្នាំ ១៩៩៩ ។ ក្រសួងមានភារកិច្ចសំខាន់ៗ ក្នុងការស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រ ទំនប់ការពារទឹកជំនន់ និងទំនប់ការពារទឹកប្រៃ ដើម្បីធានាផ្តល់ទឹកគ្រប់គ្រាន់ សំរាប់ដំណាំកសិកម្ម និង ប្រពន្ធ័ត្រួតពិនិត្យទឹកជំនន់ ដើម្បីការពារទ្រព្យសម្បត្តិសាធារណៈ និងការពារផ្ទៃដីកសិកម្ម និងដើម្បីកាត់ បន្ថយគ្រោះមហន្តរាយធម្មជាតិ ។ ក្រសួងបាន និងកំពុងធ្វើការជាមួយដៃគូអភិវឌ្ឍន៍ជាច្រើន ដើម្បីអនុវត្ត កម្មវិធី និងគំរោងអាទិភាពរបស់ខ្លួន ។ ដៃគូអភិវឌ្ឍន៍ទាំងនោះរួមមាន ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ជប៉ុន ភ្នាក់ងារអភិវឌ្ឍន៍បារាំង សហគមន៍អឺរ៉ុប កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ អង្គការស្បៀង អាហារនិងកសិកម្ម ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក មូលនិធិអន្តរជាតិសំរាប់អភិវឌ្ឍន៍កសិកម្ម ប្រទេសបារាំង ឥណ្ឌា និងអ៊ីតាលី ។

១៧០- **ការរៀបចំក្របខ័ណ្ឌច្បាប់** : ក្រសួងបានសហការជាមួយស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូ អភិវឌ្ឍន៍ ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ហើយបានដាក់ជូនសភាជាតិពិនិត្យ ក្នុងខែមេសា ឆ្នាំ២០០២ កន្លងមក ដើម្បីសុំការអនុម័ត ។ ជាការងារបន្តទៀត ក្រសួងបានរៀបចំ គោលនយោបាយជាតិស្តីពីការគ្រប់គ្រងធនធានទឹក ហើយត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី នាខែមករា ឆ្នាំ២០០៤ ។

១៧១- **ការស្តារឡើងវិញហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព ការអន្តរាគមន៍ទប់ទល់នឹងភាពរាំងស្ងួត និង ការការពារច្រាំងទន្លេ** : ក្រសួងធនធានទឹក និងឧតុនិយមបានស្តារប្រព័ន្ធធារាសាស្ត្រ ៣១៥គំរោង ដែល អាចស្រោចស្រពផ្ទៃដីកសិកម្មសរុបចំនួន ១៥៣.១៤៩ហិកតា (ស្រូវវស្សាចំនួន ៨៩.៣៨៣ហិកតា និង ស្រូវប្រាំង ចំនួន ៦៣.៧៦៦ហិកតា) ។ ទំនប់ការពារទឹកជំនន់នាពេលបច្ចុប្បន្ន អាចរំដោះផ្ទៃដីពីទឹកជំនន់ សរុប ១១៣.៥០០ហិកតា និងការពារការជ្រាបចូលនៃទឹកប្រៃលើផ្ទៃដីសរុប១៦.៦៨០ហិកតា ។ តំលៃសរុបនៃ ការស្តារប្រព័ន្ធធារាសាស្ត្រនេះ មានចំនួន ៥,២លានរៀល និង៨៦,៥លានដុល្លាអាមេរិក ។ បាតុភូតគ្រោះ រាំងស្ងួតតែងតែកើតមានឡើងជាប្រចាំនៅក្នុងកម្ពុជា ។ ដើម្បីសំរាលផលប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់ផលិតកម្ម កសិកម្ម ក្រសួងបានជួយអន្តរាគមន៍ម៉ាស៊ីនបូមទឹកដល់តំបន់ណាដែលរងគ្រោះដោយសារគ្រោះរាំងស្ងួត ។ រាជរដ្ឋាភិបាលបានចាត់ទុកថា ការកែលំអការហូរច្រោះច្រាំងទន្លេ គឺជាការងារអាទិភាពខ្ពស់ ។ ការជួស ជុលច្រាំងបាក់នៅទីរួមខេត្តកំពង់ចាម ប្រវែង៥,២ គម ត្រូវបានអនុវត្តដោយប្រើប្រាស់ថវិការដ្ឋ ។

១៧២- **ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រកាសភាពអាសន្ន** : ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ គ្រោះរាំងស្ងួត និងទឹកជំនន់ គឺជាគ្រោះធម្មជាតិដ៏ធំ ដែលបានបណ្តាលអោយខូចខាតដល់អាយុជីវិតមនុស្ស ទ្រព្យសម្បត្តិឯកជននិងសាធារណៈ និងការបាត់បង់សកម្មភាពសេដ្ឋកិច្ច ។ ការបង្កើតអោយមានប្រព័ន្ធ គ្រប់គ្រងគ្រោះមហន្តរាយ និងការប្រកាសភាពអាសន្នជាមុន គឺជាបណ្តាការងារអាទិភាពខ្ពស់របស់រាជ រដ្ឋាភិបាល ។ ក្រសួងបាន និងកំពុងពង្រឹងឧបករណ៍ឧតុនិយម និងបង្កើតទិន្នន័យឧតុនិយម និងជលសាស្ត្រ

ដើម្បីឆ្លើយតបអោយបានទាន់ពេលវេលា ទៅនឹងគ្រោះមហន្តរាយធម្មជាតិ ។ រហូតមកដល់ពេលបច្ចុប្បន្ន ក្រសួងបានបំពាក់ និងកែលំអឧបករណ៍ឧតុនិយមនៅក្នុងខេត្ត ៥ និងបានតំឡើងប៉ុស្តិ៍តំរងទឹកភ្លៀង ចំនួន ១០២កន្លែង នៅគ្រប់ខេត្ត- ក្រុង ព្រមទាំងបានជួសជុល និងតំឡើងស្ថានីយ៍ជលសាស្ត្រចំនួន ២០កន្លែង នៅតាមបណ្តោយទន្លេមេគង្គ និងទន្លេបាសាក់ ហើយក៏បានតម្លើងក្តារវាស់កំពស់ទឹកចំនួន ៧៧កន្លែង នៅតាមចំណុចត្រួតពិនិត្យសំខាន់ៗ តាមដងទន្លេ និងស្ទឹងសំខាន់ៗផងដែរ ។

១៧៣- **ការអភិវឌ្ឍន៍ធនធានមនុស្ស** : ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ក្រសួងធនធានទឹក និងឧតុនិយម បានបណ្តុះបណ្តាលមុខវិជ្ជាស្តីពីកិច្ចអភិវឌ្ឍន៍វិស័យធនធានទឹកនិងឧតុនិយម ដល់មន្ត្រីរាជការចំនួន ៤៨៤នាក់ ។

**ទឹកស្អាត**

១៧៤- គោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីអំពីការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យបានកំណត់គោលដៅក្នុងការពង្រីកការផ្គត់ផ្គង់ទឹកស្អាតសំរាប់លើកកំពស់ជីវភាពរស់នៅ និងសុខមាលភាពរបស់ប្រជាជន ដើម្បីឈានទៅសំរេចអោយបាននូវទិសដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា ។ រាជរដ្ឋាភិបាលបានស្វែងរកការគាំទ្រពីបណ្តាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងប្រទេសដែលជាដៃគូអភិវឌ្ឍន៍ទាំងអស់ ក្នុងការស្តារ និងកសាងប្រព័ន្ធចែកចាយទឹកដើម្បីឆ្លើយតបអោយទាន់តំរូវការរបស់ប្រជាពលរដ្ឋ ។ ការចូលរួមពីសំណាក់វិស័យឯកជនក៏ជាគោលដៅមួយដែលរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ផងដែរ ។ បច្ចុប្បន្ននេះ ៨៥% នៃប្រជាពលរដ្ឋដែលរស់នៅទីក្រុងភ្នំពេញ និង១៥%នៃប្រជាពលរដ្ឋដែលរស់នៅតាមទីរួមខេត្ត អាចប្រើប្រាស់ទឹកម៉ាស៊ីន ។ ក្នុងចំណោម ២៤ខេត្ត- ក្រុង ខេត្តឧត្តរមានជ័យ មណ្ឌលគីរី ព្រះវិហារ ក្រុងប៉ៃលិន និង ក្រុងកែបនៅពុំទាន់មានប្រព័ន្ធចែកចាយទឹកស្អាតនៅឡើយទេ ។

១៧៥- ក្នុងកំឡុងពេលប្រាំឆ្នាំកន្លងទៅនេះ រាជរដ្ឋាភិបាលសំរេចបាននូវលទ្ធផលគួរអោយកត់សំគាល់ក្នុងការស្តារប្រព័ន្ធចែកចាយទឹកស្អាតឡើងវិញ ។ ក្រោមគំរោងហិរញ្ញប្បទានរបស់ធនាគារពិភពលោក ប្រព័ន្ធចែកចាយទឹកស្អាតនៅក្រុងព្រះសីហនុត្រូវបានស្តារឡើងវិញ ដោយបានពង្រីកសមត្ថភាពផលិតទឹកបានពី២.០០០ម$^{៣}$ ក្នុងមួយថ្ងៃ រហូតដល់៨.០០០ម$^{៣}$ ក្នុងមួយថ្ងៃ ដែលអាចចែកចាយដល់១.៣២០គ្រួសារបន្ថែមទៀត ។ ក្រោមកំចីពីធនាគារអភិវឌ្ឍន៍អាស៊ី ប្រព័ន្ធចែកចាយទឹកស្អាត៦កន្លែង នៅតាមទីរួមខេត្តបាត់ដំបង ពោធិ៍សាត់ កំពង់ធំ កំពង់ចាម កំពត និងស្វាយរៀង កំពុងត្រូវបានស្ថាបនាឡើងវិញ ហើយគ្រោងនឹងបញ្ចប់នៅក្នុងឆ្នាំ២០០៥ ។ គំរោងនេះនឹងអាចផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋចំនួន ១០.០០០គ្រួសារ ។ ក្រោមជំនួយឥតសំណងពីរាជរដ្ឋាភិបាលជប៉ុន ប្រព័ន្ធចែកចាយទឹកស្អាតនៅក្នុងខេត្តសៀមរាបកំពុងត្រូវបានសាងសង់ ។ ជាមួយគ្នានេះដែរ គំរោងអនាម័យទឹកជុំវិញក្រុងនិងខេត្ត កំពុងត្រូវបានអនុវត្តនៅ ៤៣ កន្លែងនៅតាមទីប្រជុំជននានា តាមរយៈកម្មវិធីរបស់ធនាគារពិភពលោក ។

**ការផលិតថាមពលអគ្គិសនី និងប្រព័ន្ធចែកចាយ**

១៧៦- ការអភិវឌ្ឍន៍បណ្តាញអគ្គិសនីដែលអាចផ្គត់ផ្គង់ក្នុងតំលៃទាប នៅតែជាផ្នែកមួយសំខាន់នៃគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ការទាក់ទាញវិនិយោគពីវិស័យឯកជន ក្នុងការផលិតនិងចែកចាយអគ្គិសនីអោយដល់ទីប្រជុំជនសំខាន់ៗនៅតាមបណ្តាខេត្ត-ក្រុង និងតំបន់ដាច់ស្រយាល ព្រមជាមួយនឹងការតំឡើងបណ្តាញថាមពលដែលអាចភ្ជាប់កម្ពុជាជាមួយនឹងប្រទេសជិតខាង គឺជាសកម្មភាពអាទិភាពរបស់រាជរដ្ឋាភិបាលនៅក្នុងនីតិកាលទី ២ ។ ជាក់ស្តែង សមត្ថភាពផ្គត់ផ្គង់អគ្គិសនីនៅក្នុងក្រុងភ្នំពេញ និងតាមបណ្តាខេត្ត-ក្រុង បានកើនឡើងពី៤១៤.៩៥៣.000kWh ក្នុងឆ្នាំ១៩៩៨ រហូតដល់ ៧៤២.៣៦៩.៧00kWh ក្នុងឆ្នាំ២00៣ ពោលគឺបានកើនឡើង១៥,៨% ក្នុងមួយឆ្នាំ ។

១៧៧- ក្រោមការជួយឧបត្ថម្ភពីប្រទេសដែលជាដៃគូអភិវឌ្ឍន៍របស់កម្ពុជា និងពីវិស័យឯកជន រោងចក្រថាមពលមួយចំនួនកំពុងដំណើរការសាងសង់ ។ គំរោងខ្លះបានបញ្ចប់ការសាងសង់ជាស្ថាពរ ទន្ទឹមនឹងការពិនិត្យលទ្ធភាពសាងសង់លើគំរោងថ្មីមួយចំនួន ។ គំរោងដែលបានបញ្ចប់ជាស្ថាពររួមមាន ÷

- ការពង្រីកបន្ថែមប្រព័ន្ធថាមពលនៅតាមតំបន់ជាយក្រុងភ្នំពេញចំនួនបួនកន្លែង ដែលបានបញ្ចប់នៅក្នុងឆ្នាំ២00១ ហើយដែលបច្ចុប្បន្នអាចបំរើអតិថិជនបាន ១0.000នាក់ថែមទៀត ។ គំរោងនេះទទួលការគាំទ្រពីរាជរដ្ឋាភិបាលជប៉ុន ដែលមានតំលៃ ២៦,៨លានដុល្លារអាមេរិក ។
- ការស្តារឡើងវិញវារីអគ្គិសនីគីរីរម្យទី១ ដែលមានសមត្ថភាពផលិត ១២MW រួមជាមួយបណ្តាញចែកចាយមកកាន់រាជធានីភ្នំពេញ នៅក្រោមទំរង់ការ " សាងសង់-ដំណើការ-ផ្ទេរ (BOT) " ដែលបានបញ្ចប់ក្នុងឆ្នាំ២00២ ។ បណ្តាញនេះត្រូវបានសាងសង់ដោយក្រុមហ៊ុនមួយពីសាធារណរដ្ឋប្រជាមានិតចិន (CETIC) ។
- ការសាងសង់រោងចក្រអគ្គិសនីថ្មីមួយ ដែលមានសមត្ថភាពផលិត ១0MW នៅក្នុងខេត្តសៀមរាប ដែលបានបញ្ចប់រួចរាល់នៅខែមិនា ឆ្នាំ២00៤ មានតំលៃ ១៧,0៤លានដុល្លារអាមេរិក ។

១៧៨- ការស្តាបនាឡើងវិញនូវប្រព័ន្ធថាមពលនៅតាមទីរួមខេត្ត ៨ ផ្សេងទៀតគ្រោងនឹងបញ្ចប់រួចរាល់នៅត្រឹម ដើមឆ្នាំ២00៥ ។ ស្ថានីយ៍ ៧កន្លែងដែលស្ថិតក្នុងខេត្តកំពត ព្រៃវែង បន្ទាយមានជ័យ រតនៈគីរី កំពង់ស្ពឺ តាកែវ និងស្វាយរៀង កំពុងសាងសង់ ដោយគំរោងកំចីពីធនាគារអភិវឌ្ឍន៍អាស៊ី ។ ទីតាំងទី ៨ ដែលស្ថិតនៅក្នុងទីរួមខេត្តស្ទឹងត្រែង គឺជាគំរោងឧបត្ថម្ភរបស់ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង AFD ដែលមានតំលៃ ៣,៧៥ លានអឺរ៉ូ ។

១៧៩- ការសិក្សាពីសក្តានុពលភាពក្នុងការសាងសង់រោងចក្រអគ្គិសនីដែលមានកំលាំង ២ x ៩0MW នៅក្រុងព្រះសីហនុ បានបញ្ចប់ជាស្ថាពរក្នុងឆ្នាំ ២00២ ក្រោមជំនួយឧបត្ថម្ភពីជប៉ុន ។ ការសាងសង់រោងចក្រនេះនឹងដំណើរការក្នុងកំឡុងឆ្នាំ ២00៧-២0១0 ។ ការសិក្សាពីសក្តានុពលភាពក្នុងការសាងសង់វារីអគ្គិសនីនៅតំបន់កំចាយក៏ត្រូវបានបញ្ចប់នាឆ្នាំ ២00២ ក្រោមការជួយឧបត្ថម្ភពីរដ្ឋាភិបាលកាណាដាតាមរយៈ

CIDA ។ គំរោងនេះកំពុងស្ថិតក្នុងដំណាក់កាលដេញថ្លៃពីផ្នែកឯកជន ។ ការសិក្សាពីសក្តានុពលភាពក្នុងការសាងសង់វារីអគ្គិសនីបាត់ដំបងទី១ និងទី២ វារីអគ្គិសនីអាទៃ ឫស្សីជ្រុំ ស្ទឹងពោធិ៍សាត់ ក៏កំពុងដំណើរការផងដែរ ។ ជាមួយគ្នានេះ របាយការណ៍ស្តីអំពីស្តង់ដារបច្ចេកទេសថាមពលអគ្គិសនីរបស់កម្ពុជាត្រូវបានរៀបចំរួចរាល់នាខែមិនា ឆ្នាំ២០០៤ ។ រាជរដ្ឋាភិបាលបានកំណត់ថា ការសាងសង់ទំនប់វារីអគ្គិសនីនៅកម្ពុជាទាមទារអោយមានការពិចារណាដិតដល់អំពីផលប្រយោជន៍នៃកំណើន និងផលប៉ះពាល់សង្គមនិងបរិស្ថានដែលអាចកើតឡើងផងដែរ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងប្រកាន់យកវិធានការទាំងឡាយណាដែលចាំបាច់ដើម្បីបញ្ចៀសគ្រោះមហន្តរាយដែលប្រទេសជិតខាងធ្លាប់បានជួបប្រទះ ដែលមិនត្រឹមតែបង្កផលវិបាកដល់សង្គមនិងបរិស្ថានប៉ុណ្ណោះទេ ថែមទាំងប៉ះពាល់ដល់សេដ្ឋកិច្ចថែមទៀតផង ។ បន្ថែមពីនេះ ក្នុងការអនុម័តគំរោងផលិតថាមពលអគ្គិសនីនីមួយៗ រាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់ផងដែរដល់ការបង្កើតការងារនៅតាមទីជនបទ ដែលអាចជាប្រភពចំណូលបន្ថែមសំរាប់ប្រជាពលរដ្ឋក្រីក្រ ។

១៨០- ក្នុងទិសដៅលើកកំពស់ការចែកចាយថាមពល រវាងប្រទេសដែលជាសមាជិកមហាអនុតំបន់ទន្លេមេគង្គ កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលស្តីពីពាណិជ្ជកម្មថាមពលក្នុងតំបន់ (Inter-Governmental Agreement on Regional Power Trade) ត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការថាមពលទាំង ៦ប្រទេស កាលពីថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០២ ។ កិច្ចព្រមព្រៀងនេះបានត្រួសត្រាយផ្លូវសំរាប់ការផលិតថាមពលអគ្គិសនីក្នុងទ្រង់ទ្រាយធំ និងការចែកចាយថាមពលទាំងនេះ រវាងបណ្តាប្រទេសនៃមហាអនុតំបន់ទន្លេ មេគង្គ ។

១៨១- ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការថាមពលអគ្គិសនីជាមួយប្រទេសវៀតណាម (ខែមិថុនា ១៩៩៩) និងជាមួយប្រទេសថៃ (ខែកុម្ភៈ ២០០០) បានជួយសំរួលដល់ការផ្គត់ផ្គង់ថាមពលអគ្គិសនីតាមតំបន់ដែលនៅជិតព្រំប្រទល់ជាមួយប្រទេសទាំង២ ។ ក្រោមកិច្ចព្រមព្រៀងជាមួយអាជ្ញាធរអគ្គិសនីខេត្តរបស់ប្រទេសថៃ ថាមពលអគ្គិសនីត្រូវបានផ្គត់ផ្គង់អោយខេត្តកោះកុង ប៉ោយប៉ែត ប៉ៃលិន អូរស្មាច់ ខេត្ត ឧត្តរមានជ័យ កំរៀង ភ្នំព្រឹក និងសំពៅលូន។ ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ទាំងនោះអាចប្រើប្រាស់ ថាមពលអគ្គិសនីដែលមានតំលៃថោកគឺ ៦០០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង ដែលកាលពីមុន ពួកគេត្រូវបង់ ដល់ ២.៥០០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង ។ កិច្ចព្រមព្រៀងទិញថាមពលអគ្គិសនីមួយផ្សេងទៀតត្រូវបាន ចុះហត្ថលេខានាខែកក្កដា ឆ្នាំ២០០២ ដើម្បីផ្គត់ផ្គង់អគ្គិសនីអោយខេត្តបន្ទាយមានជ័យ បាត់ដំបង និង សៀមរាប ។ ប្រព័ន្ធបែងចែកអគ្គិសនីពីប្រទេសថៃមកដល់ខេត្តទាំងនេះនឹងតំលើងដោយវិនិយោគឯកជន ដោយរំពឹងថានឹងត្រូវបញ្ចប់ក្នុងកំឡុងឆ្នាំ២០០៧ ។ បន្ទាប់ពីការចុះហត្ថលេខាជាមួយប្រទេសវៀតណាម លើកិច្ចព្រមព្រៀងសហប្រតិបត្តិការវិស័យថាមពល រាជរដ្ឋាភិបាលបានចុះហត្ថលេខាកិច្ចព្រមព្រៀងទិញ ថាមពលដើម្បីភ្ជាប់ថាមពលអគ្គិសនីដែលមានកំលាំង ២២០kv មកកាន់រាជធានីភ្នំពេញ និងដើម្បីផ្តល់ថាមពលអោយតំបន់នៃភាគខាងត្បូងប្រទេស ។ ការសាងសង់ប្រព័ន្ធចែកចាយថាមពលអគ្គិសនីបាននិងកំពុងទទួលហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិរបស់អង្គការ NORDIC ។ ក្រោមកិច្ច

ព្រមព្រៀងជាមួយក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីរបស់វៀតណាម តំបន់នៅក្បែរព្រំប្រទល់ជាមួយវៀតណាម ក៏បានទទួលការផ្គត់ផ្គង់អគ្គិសនីផងដែរ រួមមានពញាក្រែក មេមត់ បាវិត កំពង់ត្រាច កំពង់រោទិ៍ និងទីរួម ខេត្តស្វាយរៀង ។ រាជរដ្ឋាភិបាលកំពុងជំរុញអោយមានការចូលរួមពីវិស័យឯកជនក្នុងការតបណ្តាញ ថាមពលអគ្គិសនីពីប្រទេសវៀតណាមមកដល់ស្រុកស្នួលខេត្តក្រចេះ គីរីវង្សខេត្តតាកែវ ជ្រៃធំ និងក្អមសំណ ខេត្តកណ្តាល ។

១៨២- ក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយគម្លាតនៃការអភិវឌ្ឍន៍រវាងប្រទេសដែលជាសមាជិកអាស៊ានថ្មី (កម្ពុជា លាវ និងភូមា) និងប្រទេសដែលជាសមាជិកអាស៊ានចាស់ អាស៊ានបានរៀបចំនូវផែនការសមាហរណកម្ម ថាមពលតំបន់មួយ ដែលក្នុងនោះថាមពលអគ្គិសនីនឹងត្រូវបានផ្គត់ផ្គង់ដល់តំបន់ទាំងឡាយណាដែលទទួល រងការខ្វះខាត តាមរយៈកិច្ចព្រមព្រៀងចែករំលែកថាមពលអគ្គិសនីទ្វេភាគី (រវាងប្រទេសថៃ-កម្ពុជា និង រវាងវៀតណាម-កម្ពុជា) តាមរយៈការកសាងភាពជាដៃគូរវាងវិស័យឯកជននិងសាធារណៈដើម្បីស្ថាបនា បណ្តាញចែកចាយថាមពល (រវាងលាវ-វៀតណាម ថៃ-ភូមា លាវ-ថៃ និង លាវ-កម្ពុជា) និងតាម រយៈគំរោងសាកល្បងនានា សំដៅកែលំអការផ្គត់ផ្គង់ថាមពលនៅតាមតំបន់ដាច់ស្រយាលក្នុងប្រទេស កម្ពុជា វៀតណាម លាវ និងភូមា ។

១៨៣- រាជរដ្ឋាភិបាលកម្ពុជាបានជំរុញផងដែរការអភិវឌ្ឍន៍ថាមពលប្រើកំដៅព្រះអាទិត្យ ខ្យល់ ឧស្ម័នជីវសាស្ត្រ (Biogas) ជីវម៉ាស់ (Biomass) វារីអគ្គិសនីខ្នាតតូច Hydrid Biogas និងថាមពលកំដៅ (Geothermal Energy) ។ ដោយមានការសហការជាមួយទីភ្នាក់ងារ និងអង្គការអន្តរជាតិ ប្រព័ន្ធថាមពលអគ្គិសនី មួយចំនួនត្រូវបានតំឡើងនៅតាមតំបន់មួយចំនួនក្នុងក្រុងព្រះសីហនុ ពោធិ៍សាត់ តាកែវ កំពង់ចាម កំពង់ឆ្នាំង ព្រះវិហារ សៀមរាប និងកំពត ។ អង្គការ NEDO ជប៉ុនបានតំឡើងប្រព័ន្ធចំរុះថាមពលអគ្គិសនី វារីអគ្គិសនី ដែលមានកំលាំង ១00kW នៅក្នុងខេត្តកំពង់ចាម និងប្រព័ន្ធចំរុះថាមពលព្រះអាទិត្យ ឧស្ម័នជីវសាស្ត្រដែលមានកំលាំង ១00kW នៅក្រុងព្រះសីហនុ ។

១៨៤- **មូលនិធិអគ្គិសនីជនបទ** : កត្តាចំបងមួយក្នុងការឈានទៅលុបបំបាត់ភាពក្រីក្រនៅតាមតំបន់ជនបទគឺ ការប្រើប្រាស់ថាមពលអគ្គិសនីដែលមានតំលៃថោក សំរាប់សកម្មភាពគ្រួសារ និងសេដ្ឋកិច្ច ។ ក្នុងការ គិតគូរពីបញ្ហានេះ រាជរដ្ឋាភិបាលបានបង្កើតឡើងនូវមូលនិធិអគ្គិសនីជនបទសំរាប់ទ្រទ្រង់ដល់ការផ្គត់ផ្គង់ អគ្គិសនីអោយដល់តំបន់ទាំងនេះក្នុងតំលៃថោក ។ មូលនិធិនេះនឹងប្រើប្រាស់ហិរញ្ញប្បទានពីឥណទាន និងកំចីពីប្រភពផ្សេងៗទៀត ។ តាមរយៈឧបត្ថម្ភធនពិសេស រាជរដ្ឋាភិបាលលើកទឹកចិត្តអោយវិនិយោគ ឯកជនចូលរួមក្នុងការផលិត និងចែកចាយថាមពលអគ្គិសនីនៅតាមតំបន់ដាច់ស្រយាល ជាពិសេស វិនិយោគទាំងឡាយណាដែលប្រើប្រាស់ថាមពលដែលអាចប្រើប្រាស់សាជាថ្មីបាន ។

**វិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងសេវាកម្មពត៌មាន**

១៨៥- នៅដើមនីតិកាលទីពីរនៃរាជរដ្ឋាភិបាល វិស័យទូរគមនាគមន៍ដែលភ្ជាប់តាមបណ្តាខេត្តនានាមានលក្ខណៈ

ទ្រុឌទ្រោម និងហួសសម័យ ។ អ្នកជាវប្រើប្រាស់ប្រព័ន្ធនេះមានប្រមាណជាង៤-៥ពាន់នាក់ប៉ុណ្ណោះនៅទូទាំងខេត្ត និងស្រុក ។ នៅក្នុងបណ្តាប្រាំឆ្នាំចុងក្រោយ វិស័យនេះមានការរីកចម្រើនគួរអោយកត់សំគាល់ ។ នៅចុងឆ្នាំ១៩៩៨ សន្ទភាពវិស័យទូរគមនាគមន៍ជាតិគិតជាមធ្យមមានប្រមាណ០,៦៩ក្នុងចំណោមប្រជាជន ១០០នាក់ និង២,១៧សំរាប់ប្រជាពលរដ្ឋនៅក្រុងភ្នំពេញ ។ នៅចុងឆ្នាំ២០០៣ មធ្យមភាគនេះបានកើនឡើងដល់៣,៨២ និង ៣៣,០០ នៅក្នុងក្រុងភ្នំពេញ ។ គិតមកទល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ មានអ្នកប្រើប្រាស់ប្រមាណ ៥២៦.៦៩៨នាក់ ដែលប្រើប្រាស់សេវាផ្តល់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រុមហ៊ុនទូរស័ព្ទឯទៀតដែលកំពុងដំណើរការនៅកម្ពុជា ។ បណ្តាញទូរស័ព្ទអន្តរជាតិ ០០១ របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានទទួលការហៅចូលប្រមាណ២៨.៧លាននាទី និង៨.៧លាននាទីសំរាប់ការហៅចេញទៅក្រៅប្រទេសក្នុងមួយឆ្នាំ ។ ប្រព័ន្ធទូរស័ព្ទអន្តរជាតិមួយផ្សេងទៀតរបស់ក្រុមហ៊ុន RTI ដែលបានដំណើរការកាលពីឆ្នាំ២០០១ បានទទួលការហៅចេញប្រមាណ៣,៦លាននាទី និងទទួលការហៅចូលប្រមាណ៧,៩លាននាទី ។

១៨៦- បច្ចុប្បន្ននេះ យើងមានបណ្តាញផ្តល់សេវាកម្មអ៊ិនធើណែតបួន ដែលមានអ្នកជាវប្រើប្រាស់សរុបចំនួន ៧.១៥២នាក់ ។ ចំនួនអ្នកជាវសរុបតាមប្រព័ន្ធក្រុមហ៊ុនផ្តល់សេវាកម្មនិមួយៗមានដូចខាងក្រោម ÷

- ប្រព័ន្ធ Camnet (MPTC) មានអ្នកជាវ ១.៥២៦
- ប្រព័ន្ធ Online មានអ្នកជាវ ៣.២៤៤
- ប្រព័ន្ធ CamGSM (Telesurf) មានអ្នកជាវ ១.៧៤៧
- ប្រព័ន្ធ Camintel មានអ្នកជាវ ៦៣៥

១៨៧- ក្នុងរយៈពេលប៉ុន្មានឆ្នាំមុននេះ យើងពុំមានសេវាកម្មប្រៃសណីយ៍ដែលគួរអោយទុកចិត្តបានឡើយ ។ ប៉ុន្តែក្នុងកំឡុងពេល៥ឆ្នាំចុងក្រោយនេះ សេវាកម្មប្រៃសណីយ៍មានការរីកលូតលាស់យ៉ាងខ្លាំង ថែមទាំងបានទទួលនូវទំនុកចិត្តពីអតិថិជនទៀតផង ។ បច្ចុប្បន្ន ការចែកចាយសំបុត្រមានភាពប្រក្រតីនិងទៀងទាត់ ចំនួន៤ដងក្នុងមួយខែ ទៅកាន់ប៉ោយប៉ែតព្រំដែនថៃ និងបាវិតព្រំដែនវៀតណាម ។ សេវាកម្ម EMS បានបំរើការនៅតាម២១ខេត្ត-ក្រុង និង១៦ស្រុក នាពេលបច្ចុប្បន្ននេះ ។ ប្រព័ន្ធសេវាកម្មផ្ញើសំបុត្រ EMS ទៅបរទេសមានចំនួន២ដងក្នុង១ថ្ងៃ និងទៅកាន់៩០ប្រទេសលើពិភពលោក ។ ប្រព័ន្ធផ្ទេរប្រាក់ទៅកាន់បរទេសតាមរយៈការបញ្ជាផ្ទេរពីក្នុងស្រុកក៏បានដាក់អោយប្រើប្រាស់ដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ផងដែរ ។

១៨៨- ចំពោះវិស័យពត៌មាន ក្រសួងពត៌មានបានដើរតួនាទីយ៉ាងពេញលេញក្នុងផ្តល់ពត៌មានជូនប្រជាជន នៅទូទាំងប្រទេស នូវពត៌មានជាតិ តំបន់ និងអន្តរជាតិ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ដូចជា ទូរទស្សន៍ វិទ្យុ និងឯកសារបោះពុម្ពផ្សេងៗ ក្នុងគោលបំណងដើម្បីលើកស្ទួយដល់ចំណេះដឹងទូទៅផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស ដល់ប្រជាពលរដ្ឋ ។

១៨៩- ក្រសួងពត៌មានបានផ្សព្វផ្សាយព្រះរាជសារ និងសេចក្តីថ្លែងការណ៍នានា របស់ព្រះមហាក្សត្រ ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រសួង និងស្ថាប័ននានា ដល់មហាជន អន្តរជាតិ តាមរយៈព្រឹត្តិប័ត្រ ទស្សនាវដ្តី រូបថត និងប្រព័ន្ធផ្សព្វផ្សាយតាមអេឡិចត្រូនិច ។ សមត្ថភាពផ្សាយរបស់ទូរទស្សន៍ជាតិបានបង្កើនដល់ ១០ គីឡូវ៉ាត់ ហើយដែលបច្ចុប្បន្ននេះគ្របដណ្តប់ប្រមាណ ១៤៥ពាន់គីឡូម៉ែត្រក្រឡា និងបានបំរើប្រជាពលរដ្ឋ បានជាង ១០លាននាក់ ។ ដោយមានការសហការជាមួយ Thaicom-3 កម្មវិធីទូរទស្សន៍ជាតិកម្ពុជា បច្ចុប្បន្ន អាចផ្សាយទៅកាន់ ១២៦ប្រទេសនៅក្នុងទ្វីបទាំង ៤ លើពិភពលោក ។ ទូរទស្សន៍តាមខេត្ត-ក្រុង ដូចជា ក្រុងព្រះសីហនុ ខេត្តកោះកុង ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តសៀមរាប ខេត្តរតនៈគីរី ខេត្ត មណ្ឌលគីរី បានផ្សាយនូវកម្មវិធីរបស់ខ្លួន ព្រមជាមួយនឹងកម្មវិធីរបស់ទូរទស្សន៍ជាតិផងដែរ ។ ការផ្សាយ របស់វិទ្យុជាតិគ្របដណ្តប់ជាង ៧០% នៃផ្ទៃប្រទេស ។ ការផ្សាយកម្មវិធីមាន ១៧ម៉ោង ក្នុងមួយថ្ងៃ ដែល ជាភាសាខ្មែរ ចាប់ពីម៉ោង៥និង៣០នាទីព្រឹក ដល់ម៉ោង២២និង៣០នាទី រួមទាំងភាសាបរទេស ៥ផ្សេងទៀត ដូចជាភាសាអង់គ្លេស បារាំង ថៃ ឡាវ និងវៀតណាម ពីរដងក្នុងមួយថ្ងៃ ។ ស្ថានីយ៍វិទ្យុ FM ដំណើរការ រៀងរាល់ថ្ងៃ ចាប់ពីម៉ោង៥ព្រឹក ដល់ម៉ោង២៤ ដោយមានពត៌មានជាតិនិងអន្តរជាតិ ព្រមទាំងកម្មវិធីកំសាន្ត ផ្សេងៗទៀតផង ។ ទន្ទឹមនេះ យើងក៏មានស្ថានីយ៍វិទ្យុ AM នៅតាមបណ្តាខេត្ត-ក្រុងមួយចំនួនទៀតដែរ ដូចជាខេត្តបាត់ដំបង ស្ទឹងត្រែង ក្រុងព្រះសីហនុ ព្រមទាំងស្ថានីយ៍វិទ្យុ FM នៅខេត្តពោធិ៍សាត់ កំពង់ចាម និងបាត់ដំបង ។

## ២.៥- កម្មវិធីអន្តរវិស័យ

**កម្មវិធីអន្តរវិស័យ**
- ការអភិវឌ្ឍន៍ជនបទ
- ការងារបរិស្ថាន និងអភិរក្ស
- ការគ្រប់គ្រងដែនដី និងនគរូបនីយកម្ម
- ការបោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ
- ការងារ និងសេវាសង្គម
- យេនឌ័រ និងការអភិវឌ្ឍន៍

### ការអភិវឌ្ឍន៍ជនបទ

១៩០- ប្រជាជនកម្ពុជាប្រមាណ ៨០% កំពុងរស់នៅតាមទីជនបទ ។ ការអភិវឌ្ឍន៍ជនបទបានក្លាយជាអាទិភាពខ្ពស់បំផុតមួយ របស់រាជរដ្ឋាភិបាល ក្នុងនិតិកាលទី២របស់ខ្លួន ។ រាជរដ្ឋាភិបាលបានរៀបចំទស្សនទានពហុផ្នែកសំរាប់ជំរុញកិច្ចអភិវឌ្ឍន៍ជនបទ និងពង្រឹងអំណាចរបស់សហគមន៍មូលដ្ឋានក្នុងការងារផែនការ និងកិច្ចអភិវឌ្ឍន៍របស់សហគមន៍ ។ វិមជ្ឈការ និងវិសហមជ្ឈការក្នុងការផ្តល់សេវាសាធារណៈ ការគាំទ្រដល់ការចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍តាមបែបវិមជ្ឈការ និងការផ្តល់ឥណទានដល់គ្រួសារ និងធុរៈជនតូចតាចនៅតាមតំបន់ជនបទ គឺជាកិច្ចប្រឹងប្រែងកន្លងមករបស់រាជរដ្ឋាភិបាល ។ នៅក្នុងរាជរដ្ឋាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទមានភារកិច្ចដូចតទៅ ÷ ១- សំរបសំរួល សហការ អនុវត្ត តាមដាន និងវាយតម្លៃកម្មវិធី និងគំរោងអភិវឌ្ឍន៍ជនបទ ដើម្បីស្តារនិងអភិវឌ្ឍតំបន់ជនបទកម្ពុជា ។ ២- សំរបសំរួលកិច្ចប្រឹងប្រែងរបស់បណ្តាក្រសួងជំនាញ និង

កម្មវិធីជំនួយនានា ។ ៣- អនុវត្តយ៉ាងសកម្មនូវគំនិតផ្តួចផ្តើមក្នុងការស្រាវជ្រាវ ដើម្បីអភិវឌ្ឍតំបន់ជនបទ ដោយធ្វើទំនាក់ទំនងអោយបានទូលំទូលាយដើម្បីវាយតំលៃអំពីតំរូវការ ព្រមទាំងស្វែងរកដំណោះស្រាយ ។

១៩១- ក្នុងរយៈពេល ៥ឆ្នាំ១៩៩៨-២០០៣ ក្រសួងអភិវឌ្ឍន៍ជនបទបានសំរេបសំរួលការងារស្តារ និងសាងសង់ដូចតទៅ ÷

- ផ្លូវជនបទប្រវែង ១៤.២៣០ គម ក្នុងនោះ ចាក់គ្រួសក្រហម ប្រវែង ៥.២៣០គម ។
- ស្ពាន ១.៨៨៧កន្លែង ប្រវែង ២៣.៣១១ម ។
- លូបង្ហូរទឹក ៥.៦១៩ ។
- អណ្តូងទឹក ចំនួន ៤០.៥០០ ។
- ទំនប់ ប្រវែង ៦៧៩គម ។
- ប្រឡាយទឹក ប្រវែង ៤៥២គម ។
- អាងស្តុកទឹក ១.៨៤៨កន្លែង ។
- ស្រះទឹក ចំនួន ៦.៤១២ ។
- ថ្នាក់រៀន ចំនួន ១.៤១៤ ។
- ទីផ្សារជនបទ ចំនួន ១៦ ។

១៩២- ក្រសួងអភិវឌ្ឍន៍ជនបទក៏បានរៀបចំផែនការរួមស្តីពីលទ្ធភាពទទួលសេវានៅជនបទ (IRAP) ដែលជាមធ្យោបាយក្នុងការរៀបចំផែនការថ្មី ដើម្បីពិនិត្យមើលលទ្ធភាពអាទិភាព និងរៀបចំសំណើសំរាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងគាំទ្រកម្មវិធីវិនិយោគ ដូចជា ផ្លូវថ្នល់ សាលារៀន អណ្តូងទឹកនៅថ្នាក់ស្រុក ។ ផែនការ IRAP នេះ កំណត់លំដាប់ថ្នាក់នៃលទ្ធភាពទទួលសេវារបស់ភូមិ និងឃុំ ទៅតាមកំរិតលទ្ធភាព ទទួលសេវាប្រៀបធៀបនឹងសេចក្តីត្រូវការអប្បបរមា ។

១៩៣- ក្នុងរយៈពេល ៥ឆ្នាំកន្លងមក យើងបានកែលំអជាច្រើនក្នុងការផ្តល់សេវាជនបទ ដល់សហគមន៍ក្រីក្រ ។ ក្នុងឆ្នាំ២០០៣ ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំស្តង់ដារបច្ចេកទេសសំរាប់ការសាងសង់ផ្លូវជនបទ ផ្តល់តួនាទីអោយក្រុមប្រឹក្សាឃុំ- សង្កាត់ ក្នុងការថែរក្សាផ្លូវលំជនបទ បានរៀបចំធ្វើសារពើភ័ណ្ឌផ្លូវជនបទ កសាង និងថែទាំផ្លូវលំប្រវែង ១.០០០គម និងជីកអណ្តូងទឹកប្រមាណជាង៧០០ ។ ក្រសួងអភិវឌ្ឍន៍ជនបទកំពុងបោះជំហានពីការអនុវត្តន៍ផ្អែកលើគំរោង ឆ្ពោះទៅរកអភិក្រមផ្អែកលើកម្មវិធី និងវិស័យ ។ អាទិភាពបានផ្តោតលើតំបន់អភិវឌ្ឍន៍មួយចំនួន ដើម្បីសំរេចការកាត់បន្ថយភាពក្រីក្រ តាមរយៈការពង្រីកកាលានុវត្តភាពសេដ្ឋកិច្ច គឺ ÷ ១- តំបន់នៅជុំវិញបឹងទន្លេសាប ដើម្បីធានាចីរភាពជីវសាស្ត្រចំរុះ ពីព្រោះជាកន្លែងដែលមានប្រជាជនប្រមាណ៣លាននាក់រស់នៅ ។ ២- ការអភិវឌ្ឍន៍តំបន់ព្រំដែន ពិសេសក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ ខេត្តសៀមរាប និងខេត្តស្វាយរៀង ។ និង៣- បណ្តាខេត្តភូមិភាគ

ឥសាន្ត ដូចជាខេត្តរតនៈគីរី និងខេត្តមណ្ឌលគីរី ដើម្បីធានាការការពារបរិស្ថាន និងជំរុញការអភិវឌ្ឍន៍របស់ជនជាតិភាគតិច ។

១៩៤- ការអនុវត្តន៍គំរោងសំរាប់ស្តារនិងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ បានបង្កើតការងារប្រមាណ ៣០លាននាក់/ថ្ងៃ ។ ក្រសួងអភិវឌ្ឍន៍ជនបទក៏បានរួមចំណែកយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍន៍សហគមន៍ ការបង្កើតនិងការបណ្តុះបណ្តាលសមាជិកនៃគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ សកម្មភាពស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ការបណ្តុះបណ្តាលដល់អ្នកម៉ៅការឯកជន និងឥណទានជនបទផងដែរ (ឥណទានជាស្រូវជារបស់របរ គុងទីន និងឥណទានសន្សំ) ។

១៩៥- ក្នុងរយៈពេលស្តារ និងកសាងផ្លូវលំជនបទប្រវែងជាង ១៤.០០០គម សេវាសង្គមមួយចំនួន ដូចជាសេវាសុខាភិបាល ការផ្តល់ឥណទាន ការបណ្តុះបណ្តាលមុខជំនាញ កម្មវិធីអក្ខរកម្ម និងសេវាផ្សព្វផ្សាយក៏ត្រូវបានផ្តល់ជូនទាំងតំបន់ជនបទ និងទាំងតំបន់ដាច់ស្រយាល ។ ការផ្លាស់ប្តូរទីកន្លែងរបស់ប្រជាជនតាមជនបទត្រូវបានកែលំអជាច្រើន ហើយបច្ចុប្បន្ន ពួកគេអាចចូលរួមយ៉ាងសកម្មក្នុងកិច្ចការអភិវឌ្ឍន៍សហគមន៍របស់ពួកគេ ។

១៩៦- កម្មវិធីសំខាន់ៗដែលផ្តល់ការគាំទ្រដល់សហគមន៍មូលដ្ឋាន រួមមាន ÷ កម្មវិធីសិលា មូលនិធិសង្គម កម្មវិធីឥណទានតូចៗនៅជនបទ ។ កម្មវិធីទាំងនេះត្រូវបានទទួលការគាំទ្រពីដៃគូអភិវឌ្ឍន៍បរទេស ។ យើងសង្ឃឹម ថាដៃគូបរទេសនឹងបន្តការគាំទ្របន្ថែមទៀត សំរាប់កម្មវិធីទាំងអស់នេះ ដើម្បីប្រឈមដោះស្រាយបញ្ហាជាឬសគល់នៃភាពក្រីក្រ និងដើម្បីរួមចំណែកអនុវត្តអោយបានសំរេច នូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រព្រមទាំងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា ។

១៩៧- **កម្មវិធីសិលា** : កម្មវិធីសិលារបស់រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមអនុវត្តដំបូងនៅឆ្នាំ១៩៩៦ ដើម្បីរៀបចំបង្កើតសាកល្បងអនុវត្ត និងពង្រឹងប្រព័ន្ធវិមជ្ឈការនិងវិសហមជ្ឈការក្នុងការកសាងផែនការហិរញ្ញវត្ថុនិងអនុវត្តកិច្ចអភិវឌ្ឍន៍មូលដ្ឋាននៅថ្នាក់ខេត្ត និងឃុំ ។ ដោយចាប់ផ្តើមអនុវត្តដំបូងនាឆ្នាំ ១៩៩៦ ក្នុងខេត្ត៥និងឃុំសាកល្បងមួយចំនួន គិតត្រឹមដំណាច់ឆ្នាំ២០០១មុនពេលបោះឆ្នោតឃុំ/សង្កាត់ កម្មវិធីសិលាបានពង្រីកតំបន់គ្របដណ្តប់របស់ខ្លួន រហូតដល់១២ខេត្ត និង៥០៩ឃុំ ហើយបានពង្រីកវិសាលភាពរបស់ខ្លួនពេញទូទាំងប្រទេសចាប់ពីឆ្នាំ២០០៣មក ។ ក្នុងរយៈពេល៥ឆ្នាំ ១៩៩៨-២០០៣ ដោយគួបផ្សំរវាងការបណ្តុះបណ្តាលក្នុងថ្នាក់ ជាមួយនឹងអភិក្រម «រៀនផង-ធ្វើផង» មន្ត្រីរាជការប្រមាណ៣.០០០នាក់ ព្រមទាំងអ្នកតំណាងភូមិ៧៥.០០០នាក់ បានទទួលវគ្គបណ្តុះបណ្តាលជំនាញក្នុងផ្នែកកសាងផែនការ ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងកិច្ចសន្យា ការដេញថ្លៃនិងលទ្ធកម្ម និងការតាមដាន និងវាយតំលៃ ។ ក្នុងកំឡុងពេលនោះ កម្មវិធីសិលាបានផ្តល់ហិរញ្ញប្បទានប្រមាណ៤៣លានដុល្លារអាមេរិក សំរាប់ការវិនិយោគដោយផ្ទាល់តាមរបៀបចុះកិច្ចសន្យា រវាងអភិបាលខេត្តជាមួយនឹងមន្ទីរជំនាញ និងផ្នែកឯកជននៅថ្នាក់ខេត្ត ។ ចំណែកឯហិរញ្ញប្បទានប្រមាណ៤២លានដុល្លារអាមេរិកត្រូវបានផ្តល់ជូនថ្នាក់ឃុំដើម្បីអោយគណៈកម្មាធិការ

អភិវឌ្ឍន៍ឃុំ ចុះកិច្ចសន្យាការងារជាមួយអ្នកម៉ៅការឯកជន ។ ដោយអនុវត្តភាពជាដៃគូជាមួយសហគមន៍អន្តរជាតិនៅថ្នាក់ជាតិ ក៏ដូចជាការរៀបចំក្របខ័ណ្ឌកម្មវិធីចំរុះប្រចាំឆ្នាំជាមួយភ្នាក់ងារអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានានៅថ្នាក់ខេត្ត រាជរដ្ឋាភិបាលបានកៀងគរប្រភពធនធានបន្ថែមមួយចំនួនទៀតសំរាប់គាំទ្រកិច្ចអភិវឌ្ឍន៍នៅថ្នាក់ខេត្ត និងថ្នាក់ឃុំ ។ ការវាយតំលៃរបស់អ្នកឯកទេសអន្តរជាតិ បានបញ្ជាក់ថាកម្មវិធីសិលាបានផ្តល់អត្ថប្រយោជន៍ ទាំងផ្នែកសេដ្ឋកិច្ច ទាំងផ្នែកសង្គមកិច្ច តាមរយៈការអនុវត្តន៍គំរោងសំណង់ស៊ីវិល ដែលភាគច្រើនត្រូវបានអនុវត្តដោយផ្នែកឯកជន ព្រមទាំងបានជួយពង្រឹងសមត្ថភាពខេត្ត ស្រុក និងឃុំ ដើម្បីគ្រប់គ្រងប្រព័ន្ធវិមជ្ឈការ ។

១៩៨- ការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/ សង្កាត់នាឆ្នាំ២០០១ និងការបោះឆ្នោតឃុំ/ សង្កាត់នាខែកុម្ភៈឆ្នាំ២០០២ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររបស់ កម្ពុជា ក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ។ គណៈកម្មាធិការជាតិគាំទ្រឃុំ- សង្កាត់ និង នាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ មានតួនាទីទទួលខុសត្រូវក្នុងការរៀបចំក្របខ័ណ្ឌការងារលិខិតបទដ្ឋានស្តីពីវិមជ្ឈការ និងសំរបសំរួលការងារគាំទ្រគណៈកម្មាធិការជាតិគាំទ្រឃុំ- សង្កាត់ ។ ដោយបានប្រមើលមើលពីការផ្លាស់ប្តូរទាំងនេះ កម្មវិធីសិលាជំហានទី២ ឆ្នាំ២០០១- ២០០៥ បានរៀបចំគោលគំនិតដើមរបស់ខ្លួនឡើងវិញ ដើម្បីប្រែក្លាយជាក្របខ័ណ្ឌការងារមួយសំរាប់កៀងគរ និងសំរបសំរួលជំនួយក្នុងគោលដៅបន្តគាំទ្រកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ។ ឯកសារកម្មវិធីសិលារយៈពេល ៥ ឆ្នាំ ដែលមានតំលៃ ៩៥លានដុល្លារអាមេរិក ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល ក្នុងអង្គប្រជុំរបស់គណៈរដ្ឋមន្ត្រី នា ថ្ងៃទី៥ ខែមករា ឆ្នាំ២០០១ ហើយឆ្នាំនេះគឺជាឆ្នាំទី៤ នៃអាណត្តិរបស់ខ្លួន ។

១៩៩- **មូលនិធិសង្គម** : មូលនិធិសង្គមដែលបានបង្កើតឡើងនាឆ្នាំ ១៩៩៤ ដែលមានសម្តេចនាយករដ្ឋមន្ត្រី ជាប្រធាន គឺជាស្ថាប័នសាធារណៈស្វ័យត ។ មូលនិធិសង្គមបានចាប់ដំណើរការទូទាំងប្រទេសនៅចុងឆ្នាំ ១៩៩៥ ដើម្បីទ្រទ្រង់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល សំដៅកាត់បន្ថយភាពក្រីក្រ តាមរយៈការផ្តល់ហិរញ្ញប្បទាន ដល់គំរោងការស្តារ និងស្ថាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គមកិច្ច និងសកម្មភាពផ្សេងៗទៀត ដែលមានផលប្រយោជន៍ដល់សង្គម និងតាមរយៈការបង្កើតកាលានុវត្តភាពការងារក្នុងរយៈពេលខ្លី ព្រមទាំងជួយពង្រឹងសមត្ថភាពសហគមន៍ក្នុងការកំណត់អំពីតំរូវការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន និងក្នុងការគ្រប់គ្រងគំរោងការអភិវឌ្ឍន៍ទំហំតូចៗ ។

២០០- ស្ថាប័នមូលនិធិសង្គមនៃព្រះរាជាណាចក្រកម្ពុជា គឺជាស្ថាប័នផ្តល់ហិរញ្ញប្បទានដល់គំរោងដែលស្នើឡើងដោយសហគមន៍ អាជ្ញាធរមូលដ្ឋាន ស្ថាប័នសាធារណៈ និងអង្គការនានានៅទូទាំងកម្ពុជា ។ មូលនិធិសង្គមមិនអនុវត្តគំរោងដោយខ្លួនឯងផ្ទាល់ទេ ដោយគ្រាន់តែជាអ្នកផ្តល់ហិរញ្ញប្បទាន និងត្រួតពិនិត្យគំរោងអោយសមស្របនឹងលក្ខខ័ណ្ឌវិនិច្ឆ័យ ។ គន្លឹះសំខាន់របស់មូលនិធិសង្គមគឺការពង្រឹង និងបង្កើនការចូលរួមរបស់

សហគមន៍ក្នុងការអនុវត្តន៍ និងធានាចីរភាពគំរោង ព្រមទាំងលើកកំពស់ភាពជាម្ចាស់របស់សហគមន៍ក្នុងការធ្វើលទ្ធកម្ម ការចុះកិច្ចសន្យា និងគ្រប់គ្រងសមិទ្ធផលនៃគំរោង ។

២០១- ក្នុងរយៈពេល ១៩៩៨-២០០៣ មូលនិធិសង្គមបានទទួលពាក្យស្នើគំរោងពីសហគមន៍មូលដ្ឋានសរុបចំនួន ៣.២៣២គំរោង ស្មើនឹងទឹកប្រាក់ប្រមាណ៩៥,៨លានដុល្លារអាមេរិក ដែលក្នុងនោះ ៥៩% ជាគំរោងខាងផ្នែកសេដ្ឋកិច្ច និង ៤១%ជាគំរោងខាងផ្នែកសង្គមកិច្ច ។ ក្នុងនោះ មានសាលារៀនចំនួន១.១៧៨កន្លែង ធារាសាស្ត្រចំនួន៧ មជ្ឈមណ្ឌលសុខាភិបាលឃុំ-ស្រុកចំនួន៥៤ អណ្តូងទឹក ៤១៥ ស្ពាន-លូតាមផ្លូវជនបទ ១.០៩៣ ប្រព័ន្ធលូបង្ហូរទឹកភ្លៀងនិងទឹកស្អុយ២៦ អនុវិទ្យាល័យចំនួន៩១អាគារ ។ ទាំងអស់នេះបង្ហាញពីសេចក្តីត្រូវការយ៉ាងធំធេងខាងផ្នែកហេដ្ឋារចនាសម្ព័ន្ធគំរោងខ្នាតតូច ពិសេសនៅតំបន់ជនបទនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

២០២- ក្នុងនីតិកាលទី ២ ឆ្នាំ១៩៩៨-២០០៣ មូលនិធិសង្គមបានអនុម័តគំរោងចំនួន ១.៩២៨ ដែលមានតំលៃសរុប ៣៨,៨លានដុល្លាអាមេរិក ក្នុងគំរោងសាងសង់ទាំងអស់ខាងលើនេះ ១៥,២% ជាគំរោងនៅតំបន់ក្រោយជំលោះ ៩០,៨%ជាគំរោងនៅតាមជនបទ និង៩,២% ជាគំរោងនៅទីប្រជុំជន ។ ក្នុងតំលៃសរុបខាងលើតំលៃពលកម្មស្មើនឹង ១៣,២% ដោយបង្កើតការងារបានចំនួនជាង ៩៨.៦៦០នាក់/ខែ ។

២០៣- **ឥណទានជនបទ** : រាជរដ្ឋាភិបាលបានគាំទ្រ និងលើកទឹកចិត្តយ៉ាងពេញទំហឹង ដើម្បីអោយស្ថាប័នមីក្រូហិរញ្ញវត្ថុ ធនាគារពាណិជ្ជ ធនាគារឯកទេស និងពិសេសធនាគារអភិវឌ្ឍន៍ជនបទ (ធ.អ.ជ ) ផ្តល់ឥណទានដល់សហគមន៍មូលដ្ឋាន ។ នាពេលបច្ចុប្បន្ននេះ ធនាគារពាណិជ្ជភាគច្រើនពុំទាន់មានសាខារបស់ខ្លួននៅតាមខេត្ត-ក្រុងនៅឡើយ ។ ម៉្យាងវិញទៀត ទោះបីមានសាខានៅតាមខេត្តខ្លះៗក៏ដោយ ក៏ធនាគារទាំងនោះ មានសាខានៅតែតាមទីប្រជុំជនធំៗ ហើយក៏មិនទាន់មានសាខារបស់ខ្លួននៅតាមស្រុក ឃុំ និងភូមិនៅឡើយ ។ ប៉ុន្តែ ស្ថាប័នមីក្រូហិរញ្ញវត្ថុ អង្គការមិនមែនរដ្ឋាភិបាល និងធនាគារឯកទេសមួយចំនួនបានប្រឹងប្រែងពង្រីកសេវាឥណទានរបស់ខ្លួន ដើម្បីឆ្លើយតបនឹងតំរូវការរបស់ប្រជាជនតាមជនបទ ។ ទន្ទឹមនេះ ធនាគារអភិវឌ្ឍន៍ជនបទបានដើរតួនាទីសំខាន់ ក្នុងការផ្តល់ហិរញ្ញប្បទាន និងជំនួយបច្ចេកទេសដល់ស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងអស់ ព្រមជាមួយនឹងការកៀងគរធនធានហិរញ្ញវត្ថុ ទាំងក្នុង និងក្រៅប្រទេស សំរាប់គាំទ្រសកម្មភាពរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុផងដែរ ។

២០៤- លទ្ធភាពក្នុងការទទួលឥណទាននៅតាមតំបន់ជនបទ គឺជាគន្លឹះសំខាន់នៃការពង្រីកសកម្មភាពសេដ្ឋកិច្ចទូលំទូលាយមួយ ។ រាជរដ្ឋាភិបាលមានវិធានការជាក់ស្តែងជាច្រើន ក្នុងការបង្កើនលទ្ធភាពផ្តល់ឥណទាន ដល់តំបន់ជនបទ ដែលរួមមាន ÷ ១-ប្រែក្លាយអង្គការមិនមែនរដ្ឋាភិបាលអោយទៅជាស្ថាប័នមីក្រូហិរញ្ញវត្ថុស្របច្បាប់ ឬជាភ្នាក់ងារផ្តល់មីក្រូហិរញ្ញវត្ថុមានការចុះបញ្ជី ។ ២-លើកកំពស់ការគ្រប់គ្រង និងត្រួតពិនិត្យ និងការកៀងគរប្រភពធនធាន ។ និង៣-កាត់បន្ថយអត្រាការប្រាក់ ដើម្បីបង្កើនលើកកំពស់ការប្រើប្រាស់ឥណទានដោយប្រជាជនក្រីក្រ ។ ក្នុងរយៈពេល ៩ ខែដំបូងនៃឆ្នាំ២០០៣ ធនាគារជាតិកម្ពុជាបានផ្តល់

អាជ្ញាប័ណ្ណដល់ស្ថាប័នផ្តល់មីក្រូហិរញ្ញវត្ថុខ្នាតតូចចំនួន ៥ និងចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាលចំនួន ៤ ជាភ្នាក់ងារផ្តល់ឥណទានជនបទ ។ បច្ចុប្បន្ន មានភ្នាក់ងារផ្តល់ឥណទានជនបទជាង ១០០ រួមមាន ÷ ស្ថាប័នផ្តល់ហិរញ្ញវត្ថុខ្នាតតូច ដែលមានអាជ្ញាប័ណ្ណ និងអង្គការមិនមែនរដ្ឋាភិបាល ដែលមិនទាន់ចុះបញ្ជី និងចុះបញ្ជីរួច ហើយភាគច្រើនមានទ្រង់ទ្រាយតូចៗ ។

២០៥- ការដាក់ចេញដោយរាជរដ្ឋាភិបាល នូវនីតិវិធីស្តីពីការណែនាំអនុវត្តការត្រួតពិនិត្យផ្ទៃក្នុង និងពីក្រៅចំពោះស្ថាប័នផ្តល់ហិរញ្ញវត្ថុខ្នាតតូច នាដើមឆ្នាំ២០០៣ បានរួមចំណែកកែលំអប្រព័ន្ធគ្រប់គ្រងស្ថាប័នផ្តល់ហិរញ្ញវត្ថុខ្នាតតូចទាំងនោះ ។ ដើម្បីពង្រឹងការត្រួតពិនិត្យពីក្រៅប្រកបដោយគុណភាព និងសង្គតិភាពនៃពត៌មានហិរញ្ញវត្ថុ ដែលបានរាយការណ៍ដោយស្ថាប័នហិរញ្ញវត្ថុទាំងអស់នោះ ធនាគារជាតិកម្ពុជាក៏បានរៀបចំប្លង់គណនេយ្យថ្មីករិតស្តង់ដារអន្តរជាតិ ។ ប្លង់គណនេយ្យថ្មីនេះ នឹងត្រូវអនុវត្តជាបណ្តើរៗដល់ស្ថាប័នផ្តល់ហិរញ្ញវត្ថុខ្នាតតូច ដែលមានអាជ្ញាប័ណ្ណ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលមានបំណងដាក់ពាក្យសុំអាជ្ញាប័ណ្ណ ក្នុងពេលអនាគត ។ ដូចគ្នានេះដែរ ធនាគារជាតិបានបង្កើតទំរង់ធ្វើរបាយការណ៍សាមញ្ញមួយសំរាប់ស្ថាប័នដែលមានអាជ្ញាប័ណ្ណ និងភ្នាក់ងារចុះបញ្ជីការនានា ។ ក្នុងគោលបំណងអោយមានភាពច្បាស់លាស់ ការត្រួតពិនិត្យនៅនឹងកន្លែង ត្រូវធ្វើឡើងមុនពេលផ្តល់អាជ្ញាប័ណ្ណ និងលិខិតបញ្ជាក់ពីការចុះបញ្ជីការជាភ្នាក់ងារផ្តល់ឥណទានជនបទ ។

២០៦- កន្លងមក ស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងអស់មានឯករាជ្យភាព ក្នុងការកំណត់អត្រាការប្រាក់ដោយខ្លួនឯង ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏ស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងនេះពុំទាន់មានលទ្ធភាពក្នុងការគិតគូរហានិភ័យអោយបានត្រឹមត្រូវនៅឡើយ ដែលជាកត្តានេះបាននាំអោយដល់ការកំណត់អត្រាការប្រាក់ខ្ពស់ ។ ធនាគារជាតិកម្ពុជាបានចេញសេចក្តីប្រកាសណែនាំមួយ អំពីវិធីសាស្ត្រសំរាប់ជាមូលដ្ឋាន ក្នុងការគិតគូរអត្រា ការប្រាក់ដោយផ្អែកតាមលក្ខខ័ណ្ឌទីផ្សារ ។ វិធីសាស្ត្រគិតគូរនេះត្រូវបានរៀបចំ សំរាប់កែលំអការវិភាគ ហិរញ្ញវត្ថុដែលអាចនាំដល់ការបន្ទាបអត្រាការប្រាក់ សំរាប់ជនក្រីក្រនៅតាមតំបន់ជនបទ ។ ប៉ុន្តែធនាគារជាតិកម្ពុជាក៏មានកង្វល់ផងដែរ ក្នុងការធ្វើអន្តរាគមន៍គ្រង់ក្នុងកិច្ចការនេះ ដែលអាចនាំដល់សភាពការណ៍អស្ថិរភាពនៃស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងនេះ ។

២០៧- គំលាតយ៉ាងធំរវាងតំរូវការ និងការផ្គត់ផ្គង់មូលនិធិគឺជាឧបសគ្គជាចំបងមួយ ក្នុងការផ្តល់ឥណទានដោយយកការប្រាក់ទាបរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុ ។ ដូច្នេះ លិខិតបទដ្ឋានស្តីពីការផ្តល់អាជ្ញាប័ណ្ណ និងការចុះបញ្ជីភ្នាក់ងារមីក្រូហិរញ្ញវត្ថុ ត្រូវផ្តោតលើការលើកស្ទួយស្ថានភាព/ឋានៈច្បាប់ និងការពង្រឹងប្រតិបត្តិការរបស់ភ្នាក់ងារទាំងអស់នោះ ដើម្បីអោយស្ថាប័នទាំងនោះអាចមានលទ្ធភាពកៀងគរធនធានថែមទៀតតាមរយៈការទទួលហិរញ្ញប្បទានបន្ថែមពីធនាគារអភិវឌ្ឍន៍ជនបទ និងការចូលរួមជាភាគហ៊ុន ។ ការកសាងសមត្ថភាពស្ថាប័នរបស់អង្គការមិនមែនរដ្ឋាភិបាលដែលបានក្លាយជាស្ថាប័នមីក្រូហិរញ្ញវត្ថុ គឺពិតជាមានសារៈសំខាន់ណាស់ សំរាប់ចីរភាពរបស់ស្ថាប័នទាំងនោះ ។

## ការងារបរិស្ថាន និងអភិរក្ស

២០៨- បន្ទាប់ពីច្បាប់ស្តីពីកិច្ចការពារបរិស្ថានត្រូវបានអនុម័តនៅឆ្នាំ១៩៩៦ សេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារ ធម្មជាតិក៏ត្រូវបានរៀបចំឡើងក្នុងឆ្នាំ២០០១ ។ ក្រសួងបរិស្ថានជាស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្តន៍ ច្បាប់នេះ ។ សេចក្តីព្រាងច្បាប់នេះបានផ្តល់នូវនីតិវិធី គោលការណ៍ និងវិធានបញ្ញត្តិ សំរាប់គ្រប់គ្រងអោយកាន់តែប្រសើរឡើងនូវតំបន់ការពារធម្មជាតិ ដូចជាធានានូវសិទ្ធិ ទំនៀមទំលាប់ប្រពៃណីរបស់ជនជាតិដើមភាគតិច និងសិទ្ធិបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ដោយមានការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រង ការប្រើប្រាស់ធនធានធម្មជាតិ និងជីវចំរុះ ប្រកបដោយចីរភាព ។ ព្រមជាមួយនេះ សេចក្តីព្រាងច្បាប់ស្តីពីជីវសុវត្ថិភាព និងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវចំរុះ ក៏ត្រូវបានរៀបចំឡើងផងដែរ ។

២០៩- ក្រសួងបរិស្ថានបានចូលរួមយ៉ាងសកម្មផងដែរ ក្នុងការអនុវត្តន៍អនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីការអភិរក្ស ដូចជា អនុសញ្ញាជីវចំរុះ ពិធីសារជីវសុវត្ថិភាព អនុសញ្ញារ៉ាមសា (RAMSAR) អនុសញ្ញាសាយតេស្ត (CITES) និងថាយហ្គ័រហ្វរុម (Tiger Forum)។

២១០- **ការគ្រប់គ្រងតំបន់ការពារ** : រាជរដ្ឋាភិបាលបានកំណត់តំបន់ការពារធម្មជាតិចំនួន២៣កន្លែង ដែលត្រូវគ្រប់គ្រងតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ។ តំបន់ការពារនីមួយៗត្រូវបែងចែកជា៤តំបន់សំរាប់គ្រប់គ្រង រួមមានតំបន់ស្នូល តំបន់អភិរក្ស តំបន់អភិវឌ្ឍន៍ដោយចីរភាព និងតំបន់សហគមន៍ ។ ដើម្បីការពារតំបន់ទាំងនេះ ក្រសួងបរិស្ថានបានធ្វើផែនទីផ្លូវការ និងបោះបង្គោលព្រំប្រទល់តំបន់ការពារចំនួន១១តំបន់ បោះបង្គោលព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ ចំនួន២៨០បង្គោល សង់ទីចាត់ការ ស្នាក់ការ និងស្នាក់រងបានចំនួន៦៨ស្នាក់ការ ជួសជុលផ្លូវក្នុងតំបន់ការពារធម្មជាតិបានប្រវែង១១០គម និងបានធ្វើផ្លូវការពារភ្លើងឆេះព្រៃ ព្រមទាំងបំពាក់រថយន្តពន្លត់អគ្គីភ័យ៦គ្រឿង និងមធ្យោបាយធ្វើដំណើរដូចជាម៉ូតូ និងឧបករណ៍ប្រើប្រាស់មួយចំនួន ។

២១១- ក្រសួងបរិស្ថាន បានធ្វើការសិក្សាស្រាវជ្រាវ និងប្រមូលពត៌មានស្តីពីរុក្ខជាតិទូទៅ រុក្ខជាតិឱសថ ប្រភេទថនិកសត្វ សត្វល្មូន សត្វស្លាប អំបូរពានរ ប្រភេទមេអំបៅ ប្រភេទសត្វល្អិតមួយចំនួនទៀត ព្រមទាំងធ្វើការសិក្សាពីការទំនាស់រវាងមនុស្សនិងសត្វដំរី ។ យើងអាចកត់សំគាល់ការកើនឡើងនូវប្រភេទសត្វព្រៃនៅតាមតំបន់ការពារធម្មជាតិមួយចំនួន ឧទាហរណ៍ ហ្វូងសត្វខ្ទីងក្នុងដែនជំរកសត្វព្រៃភ្នំសំកុស កើនឡើងពី ៣០ ទៅ ៥០ ក្បាល ហ្វូងសត្វដំរី ក្នុងដែនជំរកសត្វព្រៃភ្នំព្រេច កើនឡើងពី ១០ ទៅ ២០ក្បាល សត្វក្ងោកក្នុងដែនជំរកសត្វព្រៃគូលែន-ព្រហ្មទេព កើនពី ៥០ ទៅ ១០០ក្បាល និងសត្វស្មោញក្នុងតំបន់ស្នូលព្រែក ទាល់ នៃតំបន់ឋបនីយជីវមណ្ឌលបឹងទន្លេសាប កើនឡើងដល់ទៅ ១.៥០០គូ ។ល។

២១២- ដើម្បីចូលរួមដល់គោលនយោបាយវិមជ្ឈការ និងលើកទឹកចិត្តការចូលរួមរបស់សហគមន៍មូលដ្ឋាន ក្រសួងបរិស្ថាន បានបង្កើតសហគមន៍តំបន់ការពារធម្មជាតិបាន ៧០ សហគមន៍ ក្នុងនោះ ១៤សហគមន៍ត្រូវបានប្រកាសទទួលស្គាល់ជាផ្លូវការពីក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថាន បានកសាងភាពជាដៃគូ ក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ជាមួយអង្គការជាតិ និងអន្តរជាតិមួយចំនួន ដូចជា WB, ADB, GEF, UNDP, UNESCO, FAO, DANIDA, WI, UNEP, Capacity 21, WWF, WCS, FFI, IUCN, WildAid, US Fish and Wildlife, IDRC, CWHC, Mlup Baitong, SCW, RECOFTC, LWS, Oxfam GB និងកម្មវិធីសិលា ។ ជាលទ្ធផលនៃកិច្ចប្រឹងប្រែងទាំងនេះ សកម្មភាពខុសច្បាប់ត្រូវបានកាត់បន្ថយ ប្រភេទសត្វកំរមានចំនួនកើនឡើង ដូចជាសត្វទឹក និងផ្សោត ។

២១៣- **ការគ្រប់គ្រងថបនីយជីវមណ្ឌលបឹងទន្លេសាប និងបរិស្ថានតំបន់ឆ្នេរ** : ក្រសួងបរិស្ថានបានជំរុញការអភិរក្សជីវចំរុះនៅក្នុងតំបន់ស្នូលទាំងបី នៃថបនីយជីវមណ្ឌលបឹងទន្លេសាប ដោយរៀបចំស្ថានីយ៍ស្រាវជ្រាវជីវចំរុះ រៀបចំក្រុមអភិរក្ស អនុវត្តកម្មវិធីអប់រំ និងផ្សព្វផ្សាយបរិស្ថាន ព្រមទាំងពង្រឹងសមត្ថភាពឧទ្យានុរក្ស ។ យន្តការសហប្រតិបត្តិការរវាងស្ថាប័នពាក់ពន្ធ័ដើម្បីធានាចីរភាពនៃធនធានធម្មជាតិ និង ជីវចំរុះត្រូវបានបង្កើតឡើង ដើម្បីបង្កើនប្រសិទ្ធភាពក្នុងកំណែទំរង់ដីធ្លី ព្រៃឈើ ជលផល និងបង្កើតសហគមន៍គ្រប់គ្រងធនធានធម្មជាតិ ។

២១៤- ក្រសួងបរិស្ថានបានបង្កើតគណៈកម្មាធិការជាតិសំរាប់គ្រប់គ្រងតំបន់ឆ្នេរ និងក្រុមការងារបច្ចេកទេស ដើម្បីជំរុញការចូលរួមរបស់អាជ្ញាធរថ្នាក់ខេត្ត និងក្រុមប្រឹក្សាឃុំ ក្នុងការគ្រប់គ្រងបរិស្ថានតំបន់ឆ្នេរ ។ ក្រោមការជួយឧបត្ថម្ភពី DANIDA គោលការណ៍ណែនាំ និងឧបករណ៍ផែនការកម្មវប្ប័ត្តនិងយុទ្ធសាស្ត្រសំរាប់បណ្តាខេត្តនៅតាមតំបន់ឆ្នេរ ត្រូវបានរៀបចំឡើង ជាមួយនឹងការបង្កើតមជ្ឈមណ្ឌលធនធានសមុទ្របឹកន្លែង ។ ក្រសួងបានបង្កើតសហគមន៍គ្រប់គ្រងតំបន់ឆ្នេរ ៣០ សហគមន៍ ដាំព្រៃកោងកាងបាន ៥៤ ហិកតា សិក្សាស្រាវជ្រាវពីស្មៅសមុទ្របាន ៩ ប្រភេទ ផ្កាថ្ម ៨៤ ប្រភេទ និងព្រៃកោងកាងបាន ៧៤ ប្រភេទ ។

២១៥- **កិច្ចការពារគុណភាពបរិស្ថាន** : ក្រសួងបរិស្ថានបានរៀបចំលិខិតបទដ្ឋាននានា ដែលស្តីអំពីកិច្ចការពារគុណភាពបរិស្ថាន ក្នុងទិសដៅសំរេចអោយបាននូវបេសកកម្មរបស់ខ្លួន ក្នុងការទប់ស្កាត់ និងកាត់បន្ថយផលប៉ះពាល់បរិស្ថានទៅលើសុខភាពសាធារណៈ និងដើម្បីធានាគុណភាពបរិស្ថាន ។ លិខិតបទដ្ឋានទាំងនេះរួមមាន អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក ការគ្រប់គ្រងសំណល់រឹង ការត្រួតពិនិត្យ ការបំពុលខ្យល់ និងការរំខានដោយសំលេង និងបានបញ្ចប់ពង្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូហ្សូន ។ ក្រសួងបរិស្ថានបានចូលរួមផងដែរ ជាមួយសហគមន៍អន្តរជាតិ ក្នុងការអនុវត្តន៍អនុសញ្ញា និងពិធីសារអន្តរជាតិស្តីពីបរិស្ថាន ដូចជា អនុសញ្ញាប្រែប្រួលអាកាសធាតុនិងពិធីសារក្យូតូ អនុសញ្ញាវីយែននិងពិធីសារម៉ុងរ៉េអាល់ អនុសញ្ញាបាសែល (Basel Convention) អនុសញ្ញាស្តុកខូម (Stockholm Convention) ការបង្កើតឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍ដោយចីរភាពសំរាប់សមុទ្រអាស៊ីបូព៌ា និងសេចក្តីប្រកាសស្តីពីកិច្ចសហប្រតិបត្តិការតំបន់សំរាប់ការអភិវឌ្ឍន៍ដោយចីរភាព (PEMSEA/IMO)។

២១៦- ដើម្បីទប់ស្កាត់ការបំពុលទឹក សហគ្រាសឯកជនធំៗចំនួន៤៨ ដែលបង្កអោយមានផលប៉ះពាល់ដល់គុណភាពទឹក ត្រូវបានជំរុញអោយបំពាក់នូវអាងប្រព្រឹត្តកម្មសំណល់រាវ ។ ជាមួយគ្នាផងដែរ ប្រព័ន្ធប្រឡាយមេ និងបណ្តាញលូសាធារណៈនៅក្នុងក្រុងភ្នំពេញ ក៏ត្រូវបានស្តារនិងជួសជុលឡើងវិញផងដែរ ក្រោមជំនួយពី JICA ។ អាងប្រព្រឹត្តកម្មសំណល់រាវ ត្រូវបានសាងសង់នៅក្រុងព្រះសីហនុ ក្រោមកម្ចីរបស់ ADB និងខេត្តបាត់ដំបង ក្រោមជំនួយឧបត្ថម្ភពី SAWA/EU ។

២១៧- **ការគ្រប់គ្រងកាកសំណល់រឹង** : ការគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់ គឺជាបញ្ហាអាទិភាព ដែលរាជរដ្ឋាភិបាលត្រូវដោះស្រាយជាបន្ទាន់ ។ ដោយបានការសហការគាំទ្រពីផ្នែកឯកជន ក្រសួងបរិស្ថានបានសាងសង់នូវទីលានចាក់សំណល់ប្រកបដោយសុវត្ថិភាពមួយកន្លែង ដែលបច្ចុប្បន្នកំពុងដាក់អោយប្រើប្រាស់ សំរាប់សំណល់រោងចក្រ និងផលិតផលខូចគុណភាព ដែលមានផ្ទុកជាតិពុល ឬសារធាតុគ្រោះថ្នាក់ ។ ដោយឡែក ការគ្រប់គ្រងសំណល់រឹងនៅតាមបណ្តាខេត្ត- ក្រុង ក៏ត្រូវបានកែលំអអោយកាន់តែប្រសើរផងដែរ ។ ការកែច្នៃសំណល់សំរាមពីលំនៅស្ថាន ក្នុងតំបន់ខ្លះៗនៃរាជធានីភ្នំពេញ បាន និងកំពុងអនុវត្ត ដោយមានការចូលរួមពីសំណាក់ប្រជាជនក្រីក្រដែលមានប្រាក់ចំណូលទាប ។ កម្មវិធីនេះ ត្រូវបានរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដូចជា SCARO និង CAMPED/EU ។

២១៨- **ការយល់ដឹងពីបរិស្ថាន និងការគ្រប់គ្រងដោយមានការចូលរួមពីសហគមន៍** : ការអប់រំពីបរិស្ថានជាអាទិភាពចំបងមួយរបស់រាជរដ្ឋាភិបាល ក្នុងការសាងសមត្ថភាព ហើយត្រូវបានបញ្ចូលទៅក្នុងកម្មវិធីអប់រំតាំងពីបឋមសិក្សារហូតដល់ឧត្តមសិក្សា ។ ដោយផ្អែកលើបទពិសោធន៍ដែលបានទទួលកន្លងមកពីការសាកល្បងគំរោងមួយចំនួន ការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងការថែរក្សាបរិស្ថាននឹងត្រូវជំរុញអោយបានកាន់តែខ្លាំងក្លាបន្ថែមទៀត ។

**ការរៀបចំដែនដី និងនគរូបនីយកម្ម**

២១៩- ផ្អែកតាមសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលលើគោលនយោបាយដីធ្លីកាលពីខែឧសភា ឆ្នាំ២០០១ គណៈរដ្ឋមន្ត្រីបានអនុម័តឯកសារបឋមស្តីពីយុទ្ធសាស្ត្រក្របខ័ណ្ឌគោលនយោបាយដីធ្លី នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០២ ។ គោលនយោបាយដីធ្លីទូលំទូលាយមួយត្រូវបានរៀបចំឡើង ។ ដើម្បីអនុវត្តច្បាប់ភូមិបាលឆ្នាំ ២០០១ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី រួមជាមួយនឹងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានរៀបចំឯកសារយុទ្ធសាស្ត្រគោលនយោបាយដីធ្លី និងសេចក្តីព្រាងអនុក្រឹត្យចំនួន៤ដាក់ជូនគណៈរដ្ឋមន្ត្រី ដើម្បីអនុម័ត ។ សេចក្តីព្រាងអនុក្រឹត្យទាំង៤នេះរួមមាន អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច (ខែមិនា ឆ្នាំ២០០៣) អនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងសៀវភៅគល់បញ្ជីដីធ្លី និងការចុះបញ្ជីដីធ្លី (ខែឧសភា ឆ្នាំ២០០២) អនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយឡែក (ខែឧសភា ឆ្នាំ២០០២) និងអនុក្រឹត្យស្តីពីតួនាទីនិងភារកិច្ចរបស់គណៈកម្មការសុរិយោដី ។ ដើម្បីអនុវត្តអនុក្រឹត្យទាំងនេះ ក្រសួងបានដាក់ចេញគោលការណ៍ណែនាំអនុវត្តន៍បួន ។ ដើម្បីជួយដល់ការងារឃុំ- សង្កាត់ ដោយមានការគាំទ្រពីក្រសួង

មហាផ្ទៃ ក្រសួងបានរៀបចំឯកសារជំនួយស្មារតីស្តីពីនិតិវិធីនិងដំណើរការនៃការកំណត់ព្រំប្រទល់របស់ឃុំសង្កាត់ ហើយគំរោងសាកល្បងមួយត្រូវបានអនុវត្ត ដែលក្រោយមកត្រូវបានពង្រីកនៅទូទាំងប្រទេស ។ ផែនទីឃុំ-សង្កាត់ត្រូវបានរៀបចំ និងបោះពុម្ព ។ ក្រសួងក៏បានរៀបចំសេចក្តីព្រាងរួមគ្នាមួយស្តីពីតួនាទីនិងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ-សង្កាត់ក្នុងការចុះបញ្ជីដីធ្លី សំរាប់ដាក់ជូនក្រសួងមហាផ្ទៃ ។ ក្រសួងក៏បានបានរៀបចំសេចក្តីព្រាងការណែនាំស្តីពីរដ្ឋបាលមូលដ្ឋានលើការងារដីធ្លី រៀបចំដែនដី និងសំណង់ ។ គោលនយោបាយនិងក្របខ័ណ្ឌគតិយុត្តិទាំងនេះ ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយសំរាប់អនុវត្ត ។

២២០- ដើម្បីអនុវត្តគោលនយោបាយវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ដោយផ្អែកលើការវាយតម្លៃសមត្ថភាពជំនាញ និងវិសាលភាពនៃការទទួលខុសត្រូវទាក់ទងនឹងកិច្ចការសុរិយោដី ក្រសួងបានធ្វើប្រតិភូកម្មអំណាចទៅអោយខេត្ត-ក្រុងចំនួន៨ ដើម្បីចុះហត្ថលេខាលើឯកសារសុរិយោដី ។ ក្នុងឆ្នាំ ២០០៤-២០០៥ មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តចំនួន៣បន្ថែមទៀត នឹងត្រៀមទទួលការងារនេះ ។

២២១- ក្រសួងបានរៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន ហើយបានកំពុងកែសំរួលរចនាសម្ព័ន្ធ ដើម្បីឆ្លើយតបទៅនឹងទំហំការងារ ។ ដើម្បីបង្កើនសមត្ថភាពដល់មន្ត្រីរាជការ ក្រសួងបានរៀបចំចងក្រងឯកសារបណ្តុះបណ្តាល និងបានផ្តល់ការបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេសដល់មន្ត្រីខាងផ្នែកបច្ចេកទេសច្បាប់ ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ ។ ដើម្បីលើកកំពស់ប្រសិទ្ធភាពនៃការផ្តល់សេវា ក្រសួងបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី " ការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំ " ដល់មន្ត្រី ជាន់ខ្ពស់តាមនាយកដ្ឋាននៅថ្នាក់ជាតិ ថ្នាក់ខេត្ត-ក្រុងចំនួនជាង ១០០នាក់ ។

២២២- ក្រសួងបានផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីរាជការ ដើម្បីធានាប្រសិទ្ធភាព និងតំលាភាពក្នុងការអនុវត្តន៍គោលនយោបាយដីធ្លី និងអនុក្រឹត្យដែលពាក់ព័ន្ធនឹងវិស័យនេះ ។ ក្រសួងបានរៀបចំ និងចងក្រងសៀវភៅសំរាប់បណ្តុះបណ្តាលស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងបានបណ្តុះបណ្តាលមន្ត្រីបានចំនួនជាង៧០០នាក់ ក្នុងនោះគ្រូបង្គោលចំនួន៥៨នាក់ មន្ត្រីត្រួតពិនិត្យគុណភាពចំនួនជាង១២០នាក់ និងមន្ត្រីផលិតអ័រតូហ្វូតូ (Orthophoto) ចំនួន៦នាក់ ។ ទន្ទឹមនេះ ក្រសួងបានផ្តល់ការបណ្តុះបណ្តាលដល់គណៈកម្មការរដ្ឋបាលខេត្ត-ក្រុងចំនួន៨ ដែលមានមន្ត្រីរាជការចូលរួមចំនួនប្រមាណជិត៣.០០០នាក់ស្តីអំពីតួនាទី និងភារកិច្ចក្នុងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ។ ក្រសួងក៏បានរៀបចំចងក្រងសៀវភៅអនុទ្ទេសនីតិវិធីសំរាប់គណៈកម្មការសុរិយោដី និងបានបណ្តុះបណ្តាលដល់មន្ត្រីគណៈកម្មការសុរិយោដីសរុបចំនួន៦៤៤នាក់ អំពីច្បាប់ភូមិបាល នីតិវិធី និងសេចក្តីណែនាំអំពីវិធីសាស្ត្រដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ ។ ដើម្បីធានាការយល់ដឹងច្បាប់ភូមិបាលឆ្នាំ២០០១ អោយកាន់តែស៊ីជំរៅ ក្រសួងបានបណ្តុះបណ្តាលគ្រូបង្គោលចំនួន៣០នាក់ និងមន្ត្រីជំនាញ១.៧៦៧នាក់ ដែលជាមន្ត្រីរបស់ក្រសួង និងមន្ត្រីមកពីស្ថាប័នពាក់ព័ន្ធនៅគ្រប់ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌទូទាំងប្រទេស ។ ក្រសួងបានរៀបចំឯកសារ

និងបានបណ្តុះបណ្តាលអំពីការងាររៀបចំផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម ដល់គ្រូបង្គោលថ្នាក់ជាតិចំនួន២៩នាក់ និងមន្ត្រីសិរបសិរូលថ្នាក់ខេត្តក្រុងចំនួន ៣៧០នាក់ ។ ក្រសួងក៏បានរៀបចំឯកសារ និងបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ ស្តីពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ស្រុកបានចំនួន ៥នាក់ និងថ្នាក់ខេត្ត- ក្រុង ចំនួន ៣០នាក់ផងដែរ ។

២២៣- ដើម្បីជំរុញការបណ្តុះបណ្តាលមន្ត្រីជំនាញរដ្ឋបាលដីធ្លី ក្រសួងបានបង្កើតមហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី នៅក្នុងសកលវិទ្យាល័យភូមិន្ទកសិកម្ម ចាប់ពីខែតុលា ឆ្នាំ ២០០២ ដែលមកដល់បច្ចុប្បន្ននេះមាននិស្សិតសរុបជាង ១០០នាក់ បានទទួលការសិក្សាក្នុងកម្មវិធីនេះ ។ មហាវិទ្យាល័យនឹងស្វែងរកការទទួលស្គាល់ជាលក្ខណៈអន្តរជាតិពីសកលវិទ្យាល័យមុយនិក (Munich) នៃប្រទេសអាល្លឺម៉ង់ ។

២២៤- មកដល់ពេលបច្ចុប្បន្ននេះ ក្រសួងបានចេញប័ណ្ណកម្មសិទ្ធិដីធ្លីសរុបចំនួន ២៩៣.៥០០ តាមរយៈគំរោងសាកល្បង និងគំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ។ ប័ណ្ណកម្មសិទ្ធិដីធ្លី២៨០.០០០ ត្រូវបានផ្តល់តាមរយៈការចុះបញ្ជីដីធ្លីជាប្រព័ន្ធ ក្នុងខេត្តគោលដៅរបស់គំរោងចំនួន ១១ និងការចុះបញ្ជីដីធ្លីទូទាំងប្រទេសចំនួន ១៣.៥០០ក្បាលដី និងផ្ទះល្វែង ។ ក្រសួងបានកសាងបណ្តាញប្រថពីវិភាគរយៈបណ្តោយបាន១.៣១៣ បង្គោល និងផលិតអ័រតូហ្វូតូបាន ២២.១០៨ គម២ ។

២២៥- កន្លងមក នៅទូទាំងប្រទេស មានករណីជំលោះដីធ្លីសរុបចំនួន ១.៩៦១ករណី ដែលក្នុងនោះបានដោះស្រាយបញ្ចប់ចំនួន៤៩៣ករណី បញ្ជូនទៅតុលាការ១៦១ករណី និងកំពុងដោះស្រាយ ១.៣០៧ករណី ។

២២៦- **ការគ្រប់គ្រងដីធ្លី** : ដើម្បីធានាការអភិវឌ្ឍន៍ដីធ្លី ផែនការប្រើប្រាស់ដីធ្លីត្រូវបានរៀបចំនៅតាមតំបន់មួយចំនួន ។ ឯកសារទាំងនេះរួមមាន ផែនការអភិវឌ្ឍន៍នៅក្នុងស្រុកកំរៀងក្នុងខេត្តបាត់ដំបង ប្លង់កំណត់តំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង ប្លង់តំបន់អភិរក្សភ្នំព្រះរាជទ្រព្យ ប្លង់គោលទីរួមខេត្តកំពត (កំពុងរៀបចំអនុក្រឹត្យ) ប្លង់គោលក្រុងប៉ៃលិន (រង់ចាំការផ្តល់យោបល់ពីអជ្ញាធរដែនដី) ប្លង់គោលស្រុកឆ្លូងខេត្តក្រចេះ (រង់ចាំការផ្តល់យោបល់ពីអាជ្ញាធរដែនដី) ក៏ដូចជាប្លង់គោលអភិរក្ស អាគារបេតិកភ័ណ្ឌវប្បធម៌នៅខេត្តបាត់ដំបង (កំពុងរៀបចំអនុក្រឹត្យ) និងប្លង់តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង (កំពុងរៀបចំអនុក្រឹត្យ) ។ សកម្មភាពដទៃទៀតដែលកំពុងដំណើរការនាបច្ចុប្បន្ន គឺការរៀបចំប្លង់គោលសំរាប់ទីរួមខេត្តកំពង់ចាម ទីរួមខេត្តមណ្ឌលគីរី និងរាជធានីភ្នំពេញ ។

២២៧- **សម្បទានដីសង្គមកិច្ច** : ដោយអនុវត្តតាមស្មារតីនៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ខេត្ត- ក្រុង និង ថ្នាក់ស្រុក- ខ័ណ្ឌ គំរោងសាកល្បងត្រូវបានអនុវត្តនៅក្នុងឃុំ ៣ និងសង្កាត់ ១ ក្នុងខេត្តបាត់ដំបង កំពត កំពង់ស្ពឺ និងក្រុងភ្នំពេញ ។ ផ្អែកលើលទ្ធផលនៃគំរោងសាកល្បង និងការវាយតម្លៃផលប៉ះពាល់សង្គមនៃភាពក្រីក្រនៃគំរោងសម្បទានដីសង្គមកិច្ច ក្រុមប្រឹក្សាគោលនយោបាយដីធ្លី

ដោយបានសហការជាមួយបណ្តាដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា កំពុងរៀបចំកម្មវិធីបែងចែកដីធ្លីសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច (LASED) ។

២២៨- **ការគ្រប់គ្រងការសាងសង់** : ក្រសួងបានដាក់ចេញនូវបទបញ្ញត្តិមួយចំនួន ដែលទាក់ទងនឹងការគ្រប់គ្រងការបើកបិទការដ្ឋានសាងសង់ ការគ្រប់គ្រងក្រុមហ៊ុនធ្វើអាជីវកម្មសាងសង់ និងគូរប្លង់ ។ ហើយក៏កំពុងបន្តរៀបចំសេចក្តីព្រាងប្រកាសស្តីពីការកំណត់ថ្លៃសំរាប់ការអនុញ្ញាតសាងសង់ផងដែរ ។ ក្រសួងបានចេញលិខិតអនុញ្ញាតិសាងសង់ដល់សណ្ឋាគារចំនួន៤២ រោងចក្រ- សហគ្រាសចំនួន៣១ ស្ថានីយ៍ប្រេងឥន្ធនៈ១៧ និងបូរីលំនៅដ្ឋាន៤២ ។ ទន្ទឹមនឹងនេះក្រសួងក៏បានចេញលិខិតអនុញ្ញាតដល់ក្រុមហ៊ុនធ្វើអាជីវកម្មសាងសង់ និងគូរប្លង់ចំនួន១៩០ផងដែរ ។

## ការបោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

២២៩- ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសមួយក្នុងចំណោមប្រទេសដែលទទួលផលប៉ះពាល់ដោយគ្រាប់មីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះធ្ងន់ធ្ងរជាងគេនៅលើពិភពលោក ។ ការទំលាក់គ្រាប់បែកពីលើអាកាសក្នុងកំឡុងសង្គ្រាមវៀតណាម និងការជីកកប់ដាក់មីនដោយភាគីជំលោះនានានៅកម្ពុជា ក្នុងរយៈពេលរាប់ទសវត្សរ៍កន្លងមកនេះ បានបណ្តាលអោយមានផលប៉ះពាល់ដល់អាយុជីវិតរបស់ប្រជាជនស្លូតត្រង់រយនាក់ក្នុងមួយឆ្នាំៗ ។ ការទំលាក់គ្រាប់បែក និងការប្រើប្រាស់គ្រាប់មីនរយៈពេលរាប់សិបឆ្នាំកន្លងមក បានជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងដល់ប្រទេសជាតិទាំងមូល ។ បញ្ហានេះបានចោទកាន់តែធ្ងន់ធ្ងរឡើងចំពោះប្រជាពលរដ្ឋដែលរស់នៅតំបន់ជនបទដាច់ស្រយាល និងពោរពេញដោយគ្រោះថ្នាក់ខ្លាំង ដូចជាការខ្វះ ខាតទឹក ផ្លូវ ស្ពាន និងដីសំរាប់បង្កបង្កើនផល ។

២៣០- ការស្រាវជ្រាវចំការមីនកំរិត ១ ដែលបានបញ្ចប់នៅខែមេសា ឆ្នាំ២០០២ បានបង្ហាញថា តំបន់ដែលសង្ស័យថាមានមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ មានចំនួន ៣.០៣៧ ដែលគ្របដណ្តប់លើផ្ទៃដីប្រមាណ ៤.៤៦៦ គម២ ស្មើនឹង ២,៥% នៃផ្ទៃដីទូទាំងប្រទេស ហើយមានភូមិប្រមាណ ១.៦៤០ភូមិ ស្មើប្រហែល ១២% នៃចំនួនភូមិទាំងអស់នៅក្នុងប្រទេសកម្ពុជា ។ ទន្ទឹមនេះ ក៏មានភូមិចំនួន ៥.៥០០ភូមិដែរ ដែលមានគ្រាប់ និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅរាយប៉ាយ ។

២៣១- រាជរដ្ឋាភិបាលបានចាត់ទុកថាការដោះមីន និងសកម្មភាពកំចាត់មីននានា គឺជាបុរេលក្ខខ័ណ្ឌចាំបាច់សំរាប់ កិច្ចអភិវឌ្ឍន៍ប្រទេស ។ ក្នុងន័យនេះ នាខែធ្នូ ឆ្នាំ២០០២ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (CMAA) បានរៀបចំបញ្ចប់ នូវយុទ្ធសាស្ត្រជាតិស្តីពីសកម្មភាពមីន និងផែនការសកម្មភាព៥ឆ្នាំ ២០០៣-២០០៧ ។ រហូតមកដល់បច្ចុប្បន្ន យើងមានប្រតិបត្តិករជាច្រើនដែលកំពុងធ្វើសកម្មភាពដោះមីន ។ ទន្ទឹមនេះ យើងបានរៀបចំបញ្ចប់នាចុងឆ្នាំ២០០៣កន្លងមក នូវឯកសារស្តីពីស្តង់ដារជាតិសំរាប់សកម្មភាពដោះមីន (National Mine Action Standard-NMAS) ដើម្បីបង្កើត

ស្តង់ដារក្នុងការចេញអាជ្ញាប័ណ្ណទទួលស្គាល់ ការត្រួតពិនិត្យ និងដំណើរការធានាគុណភាពលើគ្រប់ក្នាក់ងារបោសសំអាតមីនដែលកំពុងប្រតិបត្តិការនៅកម្ពុជា ។ អាជ្ញាធរមីនបានជ្រើសរើសក្រុមត្រួតពិនិត្យគុណភាពសំរាប់ចុះត្រួតពិនិត្យការអនុវត្តន៍តាមស្តង់ដារពីសំណាក់ភ្នាក់ងារដោះមីនទាំងអស់ ។

២៣២- ចាប់ពីឆ្នាំ១៩៩៨ ដល់២០០៣ ប្រតិបត្តិករដោះមីនធំៗចំនួនបួន ៖ មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា កងវិស្វកម្មនៃកងយោធពលខេមរភូមិន្ទ អង្គការ HALO Trust និង អង្គការ MAG បានបោសសំអាតផ្ទៃដីប្រមាណ១៦៣គម[២] ស្មើនឹង៣,៦%នៃផ្ទៃដីដែលសង្ស័យថាមានមីន ក្នុងនោះបានរំដោះ និងកំទេចគ្រាប់មីនប្រឆាំងមនុស្សចំនួន២៣៥.៩៧១គ្រាប់ និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះចំនួន៩១៣.៣៨៨គ្រាប់ ។ ជាលទ្ធផលចំនួនអ្នករងគ្រោះដោយសារគ្រាប់មីនបានថយចុះពី១.១៥៨នាក់ក្នុងឆ្នាំ១៩៩៩ មកត្រឹម៧៥៥នាក់ ក្នុងឆ្នាំ២០០៣នេះ ។

## ការងារ និងការផ្តល់សេវាសង្គម

២៣៣- នៅក្នុងនីតិកាលទី២នៃរដ្ឋសភា ឆ្នាំ១៩៩៨-២០០៣ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាបានប្រឹងប្រែងអនុវត្ត និងសំរេចបានវឌ្ឍនភាពជាច្រើនគួរអោយកត់សំគាល់ក្នុងការអនុវត្តន៍ច្បាប់ការងារ និងការផ្តល់សេវាសង្គមកិច្ចដល់អតីតយុទ្ធជន និងក្រុមជនងាយរងគ្រោះ ។ អង្គការពលកម្មអន្តរជាតិ (ILO) នៃអង្គការសហប្រជាជាតិ ដែលជាអង្គភាពតាមដានលក្ខខ័ណ្ឌការងារ បានប្រកាសថាពុំមានករណីបង្ខំក្នុងប្រើប្រាស់ពលកម្មកុមារ និងការរើសអើងក្នុងឧស្សាហកម្មកាត់ដេរ និងស្បែកជើងនៅក្នុងប្រទេសកម្ពុជាឡើយ ។

២៣៤- បន្ទាប់ពីការបង្កើតរាជរដ្ឋាភិបាលសំរាប់នីតិកាលទី៣ នាខែកក្កដា ឆ្នាំ២០០៤មក ក្រសួងត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងវិញ ហើយក៏បានប្តូរឈ្មោះទៅជាក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ក្រសួងថ្មីនេះនឹងត្រូវទទួលខុសត្រូវលើកិច្ចការការងារ ក៏ដូចជាការងារបណ្តុះបណ្តាលវិជ្ជាជីវៈ យុវជន និងកីឡាផងដែរដែលកាលពីមុនស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

២៣៥- ក្នុងការអនុវត្តន៍ច្បាប់ការងារក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានរៀបចំនិងអនុម័តនូវលិខិតគតិយុត្តិចំនួន៥១ រួមមាន អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានផ្សេងៗទៀត ។ ដោយអនុលោមតាមច្បាប់ការងារ គណៈកម្មាធិការប្រឹក្សាការងារ និងក្រុមប្រឹក្សាមជ្ឈត្តកម្ម ត្រូវបានបង្កើតឡើង ។ ក្នុងឆ្នាំ២០០២ ប្រាក់បៀវត្សរ៍អប្បបរមាប្រចាំខែរបស់និយោជិតនៅក្នុងឧស្សាហកម្មកាត់ដេរនិងស្បែកជើង ត្រូវបានតំលើងពី៤០ ទៅ៤៥ដុល្លារអាមេរិក ដោយរាប់បញ្ចូលទាំងប្រាក់បន្ថែម និងអត្ថប្រយោជន៍ផ្សេងៗទៀត ។ និយោជិកនៅក្នុងវិស័យឯកជនមានសិទ្ធិទទួលប្រាក់បៀវត្សរ៍សំរាប់រយៈពេលឈប់សំរាកប្រចាំឆ្នាំរបស់ខ្លួន ដូចគ្នានឹងវិស័យសាធារណៈដែរ ។

២៣៦- ក្រសួងបានធ្វើអធិការកិច្ចលក្ខខ័ណ្ឌការងារ សុខភាព និងសុវត្ថិភាព ព្រមទាំងអនុវត្តការគ្រប់គ្រងពលករបរទេស ។ ក្រសួងបានធ្វើអធិការកិច្ចទៅលើសហគ្រាសចំនួន ៥.៤៩៥ ដែលក្នុងនោះ យើងបានដាក់វិន័យលើសហគ្រាសចំនួន៤.០៦២ ដែលបានរំលោភលើច្បាប់ការងារ ។ ក្រសួងបានចេញសេចក្តីណែនាំដល់សហគ្រាសចំនួន៣.២៤៩ ដែលបានរំលោភលើច្បាប់ការងារ ដែលក្នុងនោះបានផាក ពិន័យដល់សហគ្រាសចំនួន៤៤០ ។ ដោយសារការពង្រឹងអធិការកិច្ច ជំលោះដែលពាក់ព័ន្ធនឹងការងារមានការថយចុះគួរអោយកត់សំគាល់ ។

២៣៧- ក្រសួងបានចុះបញ្ជីសហជីពកំរិតសហគ្រាសចំនួនជាង៥០០ សហព័ន្ធសហជីព១៦ និងសម្ព័ន្ធសហជីព១ ដែលមានសមាជិកសរុប២០០.៥៧២នាក់ ។ បច្ចុប្បន្ន យើងមានសមាគមនិយោជកប្រាំមួយ ដែលតំណាងដោយសម្ព័ន្ធសមាគមនិយោជកមួយ ។ សិទ្ធិធ្វើកូដកម្មរបស់និយោជិត និងសិទ្ធិឡុកអៅរបស់និយោជកអនុលោមតាមច្បាប់ការងារ ត្រូវបានគោរពផងដែរ ។

២៣៨- ក្រសួងបានចុះបញ្ជីអ្នករកការងារធ្វើចំនួន ១៣៨.១៤៨នាក់ ក្នុងនោះ១៣៤.៧៩១នាក់ត្រូវបានជ្រើសរើសអោយបំរើការងារនៅតាមសហគ្រាសឯកជន ។ ក្រសួងបានផ្តល់សេវាការងារក្រៅប្រទេសដល់ពលករចំនួន៣.៤៣៧នាក់ អោយទៅធ្វើការនៅប្រទេសម៉ាឡេស៊ី និងសាធារណរដ្ឋកូរ៉េ ។ ផ្អែកតាមអនុស្សារណៈនៃការយោគយល់រវាងកម្ពុជានិងថៃ ពលករដែលធ្វើការខុសច្បាប់ចំនួន១៨១.៥៧៩នាក់ នឹងត្រូវបានចុះបញ្ជីអោយធ្វើការស្របច្បាប់នៅក្នុងប្រទេសថៃ ។

២៣៩- នៅក្នុងខែកញ្ញា ឆ្នាំ២០០២ ច្បាប់ស្តីពីរបបសន្តិសុខសង្គម សំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបញ្ញត្តិនៃច្បាប់ការងារត្រូវបានអនុម័តអោយប្រើប្រាស់ ។ អនុលោមតាមច្បាប់នេះ កម្មករ/និយោជិកនឹងទទួលបានប្រាក់សោធននិវត្តន៍ សោធនទុព្វលភាព ឬ និងសោធនបាត់បង់សមត្ថភាពការងារ និងតាវកាលិកសំរាប់ប៉ះប៉ូវគ្រោះថ្នាក់ក្នុងការងារ ។ មូលនិធិជាតិសុវត្ថិភាពសង្គមមិនទាន់ត្រូវបានបង្កើតនៅឡើយ ដើម្បីអនុវត្តច្បាប់នេះ ដោយសារកង្វះខាតទាំងខាងបច្ចេកទេស និងខាងធនធានហិរញ្ញវត្ថុ ។

២៤០- **ការផ្តល់សេវាសង្គមកិច្ច**ដល់អតីតយុទ្ធជន រួមទាំងប្រាក់បៀវត្សរ៍ប្រចាំខែ ត្រូវបានបង្កើន៣០% លើកទីមួយ និង១០%ទៀតសំរាប់លើកទីពីរ។ អ្នកគ្មានទីលំនៅ៤.៦០០នាក់ និងជនពិការចរិក១៤៧នាក់ បានទទួលការបណ្តុះបណ្តាល និងប្រាក់ទុនដើម្បីអោយពួកគេបានតាំងទីលំនៅនៅក្នុងសហគមន៍ ។ ស្បៀងនិងសំភារៈសង្គ្រោះបន្ទាន់ត្រូវបានផ្តល់ដល់គ្រួសារដែលរងគ្រោះដោយអគ្គីភ័យចំនួន២.៧០១គ្រួសារ និងគ្រួសាររងគ្រោះដោយគ្រោះរាំងស្ងួតចំនួន ៩៦៥គ្រួសារ គ្រួសាររងគ្រោះដោយសារទឹកជំនន់ ៤១៩.១៨១គ្រួសារ និងប្រជាជនទុរភិក្សចំនួន១០.៥៩៦នាក់ ដើម្បីជួយកាត់បន្ថយចំនួននៃអ្នកគ្មានផ្ទះសម្បែង ។ អនីតិជនដែលប្រព្រឹត្តិបទល្មើសប្រមាណ ១.២០០នាក់ ត្រូវបានទទួលសេវាថែទាំសុខភាព និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយក៏បានធ្វើសមាហរណកម្មពួកគេចូលទៅក្នុងសហគមន៍វិញ ។ អនីតិជនដែលប្រព្រឹត្តិបទល្មើសចំនួន ១.១០០នាក់ បានទទួលការអប់រំស្តីពីផលប៉ះពាល់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន ។

២៤១- ក្រសួងបានធ្វើយុទ្ធនាការប្រឆាំងនឹងសកម្មភាពពេស្យាចារ ដោយមិនគ្រាន់តែផ្តន្ទាទោសដល់អ្នកប្រព្រឹត្តិបទល្មើសប៉ុណ្ណោះទេ ថែមទាំងផ្តល់នូវការអប់រំ និងដំបូន្មាន អំពីការថែទាំសុខភាពដល់អ្នកពាក់ព័ន្ធទាំងនោះផងដែរ ។ ជារៀងរាល់ឆ្នាំ ទិវាមនុស្សចាស់ត្រូវបានប្រារព្ធឡើង ដើម្បីលើកកំពស់ការយល់ដឹងអំពីវិភាគទានរបស់មនុស្សចាស់ទៅក្នុងសង្គម និងដើម្បីលើកទឹកចិត្តដល់ការបង្កើតសមាគមមនុស្សចាស់ទៀតផង ។ ផែនការជាតិ៥ឆ្នាំស្តីពីការប្រយុទ្ធប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ត្រូវបានអនុវត្តដោយជោគជ័យ ។ កម្មវិធីលុបបំបាត់ពលកម្មកុមារ និងកម្មវិធីស្តីពីបណ្តាញការពារកុមារនៅក្នុងសហគមន៍ត្រូវបានអនុវត្តយ៉ាងហ្មត់ចត់ ។ ក្រសួងបានគ្រប់គ្រងមជ្ឈមណ្ឌលថែទាំកុមារកំព្រាចំនួន២១កន្លែង ដែលមានកុមារកំព្រាចំនួន២.២១៨នាក់ ។ ក្រសួងបានធ្វើសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបង្កើតអោយមានមជ្ឈមណ្ឌលថែទាំកុមារកំព្រាចំនួន៧៨កន្លែងទៀត សំរាប់ថែទាំកុមារកំព្រាចំនួន១.៨៦៤នាក់ ។ កុមារកំព្រាទាំងនេះបានទទួលអាហារ ទីកន្លែងស្នាក់នៅ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេវាថែទាំសុខភាព ។

២៤២- ប្រទេសកម្ពុជាមានជនពិការប្រមាណ ១៦៩.០០០នាក់ ក្នុងនោះ ៩៣% ជាបុរស ហើយប្រមាណ ៦០% គឺជាជនរងគ្រោះដោយសារសង្គ្រាម ។ កម្មវិធីស្តីពីសិទ្ធិរបស់ជនពិការ ត្រូវបានដាក់អោយអនុវត្ត ប្រកបដោយជោគជ័យតាមរយៈការផ្តល់ការឧបត្ថម្ភចាំបាច់ដល់ក្រុមជនទាំងនេះ ។ លើសពីនេះ ក្រសួងបានធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ១០កន្លែង ដើម្បីផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនពិការ ។

## យេនឌ័រ និងការអភិវឌ្ឍន៍

២៤៣- រយៈពេល៥ឆ្នាំកន្លងមកនេះ ក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន ដោយសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នរដ្ឋនានា និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ បានខិតខំប្រឹងប្រែងបំពេញការងារយ៉ាងសកម្ម ក្នុងការអនុវត្តន៍កម្មវិធី " **នារីរតនៈ** " ។ កម្មវិធី " **នារីរតនៈ** "បានបង្ហាញអំពីទស្សនៈវិស័យនៃប្រជាពលរដ្ឋស្ត្រីនិងបុរស រួបរួមគ្នានិងធ្វើដំណើរឆ្ពោះទៅមុខ ដើម្បីស្ថាបនាប្រទេសជាតិមួយ ដែលប្រកបដោយសន្តិភាព អភិវឌ្ឍន៍ លើកស្ទួយការគោរពច្បាប់ និងសណ្តាប់ធ្នាប់ តាមរយៈប្រព័ន្ធមួយប្រកបដោយយុត្តិធម៌តម្លាភាព ក្នុងបរិការអភិបាលកិច្ចល្អ ដើម្បីសំរេចអោយបានស្ថេរភាពខាងសង្គម សេដ្ឋកិច្ច និងនយោបាយ ។ គោលដៅចំបងគឺការកែលំអជីវភាព និងស្ថានភាពរស់នៅរបស់ស្ត្រីអោយរួចផុតពីភាពក្រីក្រ តាមរយៈការបង្កើនសមត្ថភាព ក្នុងការចូលរួមរាល់សកម្មភាពសេដ្ឋកិច្ច និងអភិវឌ្ឍន៍សង្គម ។ កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលគឺផ្តោតលើការបញ្ជ្រាបបញ្ហាយេនឌ័រ ស្ត្រីក្នុងការសំរេចចិត្ត ការយល់ដឹងជាសាធារណៈ ការទទួលការអប់រំនិងសេវាសុខាភិបាល ការបង្កើនសមត្ថភាពសេដ្ឋកិច្ច ការការពារខាងផ្លូវច្បាប់ និងអភិបាលកិច្ចល្អសំរាប់ស្ត្រី ។

២៤៤- **ការបញ្ជ្រាបបញ្ហាយេនឌ័រ** : នៅកំរិតជាតិ បញ្ហាយេនឌ័រត្រូវបានបញ្ចូលទៅក្នុងឯកសារយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដូចជាគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមលើកទី២ និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ។ ការជំរុញសមភាពយេនឌ័រ និងលើកកំពស់ការអភិវឌ្ឍន៍ធនធានមនុស្សជាគោលនយោបាយជាអាទិភាពមួយក្នុងចំណោមគោលនយោបាយជាអាទិភាពទាំង៧ ស្តីពីគោលនយោបាយប្រជាជន ។ ដើម្បីតាមដានពីបញ្ហាយេនឌ័រ រាជរដ្ឋាភិបាលបានកំណត់អោយវិទ្យាស្ថានជាតិស្ថិតិធ្វើការប្រមូលសូចនាករទាំងឡាយណាដែលពាក់ព័ន្ធនឹងបញ្ហាយេនឌ័រ ដើម្បីធ្វើការវិភាគពីបញ្ហាគំលាតយេនឌ័រនេះ ។ ក្រសួងខ្លះបានត្រៀមថវិកាសំរាប់ដោះស្រាយបញ្ហាយេនឌ័រនេះផងដែរ ជាពិសេសក្នុងកិច្ចការអប់រំ ។ ក្រសួងកិច្ចការនារីត្រូវបានកំណត់ជាក្រសួងអាទិភាពនៅក្នុងក្របខ័ណ្ឌចំណាយមធ្យមសំរាប់ឆ្នាំ២០០៥-២០០៧ ។ ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី ដែលជាស្ថាប័នអន្តរក្រសួងមួយត្រូវបានបង្កើតឡើងក្នុងខែកុម្ភៈឆ្នាំ២០០១ ។ កម្ពុជាក៏កំពុងឈានទៅមុខក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅក្រោមសន្ធិសញ្ញាដើម្បីលុបបំបាត់គ្រប់រូបភាពនៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW) ។ ក្រុមការងារស្តីពីយេនឌ័រពីរក្រុមនៅតាមក្រសួងនានា បានទទួលការបណ្តុះបណ្តាលពីក្រសួងកិច្ចការនារី ក្នុងឆ្នាំ២០០០-២០០១។ ក្រុមការងារស្តីពីយេនឌ័រត្រូវបានបង្កើតឡើងក្នុងក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងមហាផ្ទៃ ដោយមានការគាំទ្រពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃស្ថាប័នទាំងនេះ ។ ដើម្បីជំរុញការបញ្ជ្រាបបញ្ហាយេនឌ័រនៅតាមថ្នាក់មូលដ្ឋាន រាជរដ្ឋាភិបាលទទួលស្គាល់ថា ចាំបាច់ត្រូវមានការគាំទ្រពីមហាជនដើម្បីលើកទឹកចិត្តអោយស្ត្រីមានទំនុកចិត្តលើខ្លួនឯង សំរាប់ចូលរួមអោយសកម្ម និងខ្លាំងក្លាថែមទៀត ។ យុទ្ធសាស្ត្របញ្ជ្រាបបញ្ហាយេនឌ័ររបស់កម្មវិធីសីលា ២០០១-២០០៥ ត្រូវបានរៀបចំ និងអនុវត្តដោយក្រសួងកិច្ចការនារី ដោយបានផ្តោតការយកចិត្តទុកដាក់ទៅលើការលើកស្ទួយការយល់ដឹងអំពីបញ្ហាយេនឌ័រពីអាជ្ញាធរនិងសហគមន៍មូលដ្ឋាន តាមរយៈ÷ ទី១- កសាងការប្តេជ្ញាចិត្ត និងសមត្ថភាព ។ ទី២- លើកកំពស់ការចូលរួមរបស់ស្ត្រីក្នុងការងាររៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋាន និងអភិបាលកិច្ច ។ និងទី៣- លើកកំពស់សមត្ថភាពត្រួតពិនិត្យ វាយតំលៃ និងគ្រប់គ្រងស្ថិតិយេនឌ័រ ។ ស្ត្រីដែលជាមន្ត្រីបង្គោលនៅក្នុងក្រុមប្រឹក្សាឃុំបានទទួលការបណ្តុះបណ្តាល ដើម្បីអោយពួកគេមានសមត្ថភាពឆ្លើយតបនឹងបញ្ហាយេនឌ័រ នៅក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន ។

២៤៥- **ស្ត្រីក្នុងការសំរេចចិត្ត** : ក្នុងរយៈពេល៥ឆ្នាំកន្លងមក ចំនួនស្ត្រីក្នុងដំណែងធ្វើការសំរេចចិត្តបានកើនឡើងយ៉ាងច្រើន ។ នៅក្នុងផ្នែកនយោបាយ ស្ត្រីមួយចំនួនធំត្រូវបានជ្រើសរើសជាសមាជិកក្រុមប្រឹក្សាឃុំ- សង្កាត់ ពីព្រោះគណបក្សនយោបាយបានតែងតាំងអោយឈរឈ្មោះបោះឆ្នោត ។ ក្រសួងកិច្ចការនារី បានធ្វើការក្នុងឋានៈជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាលដើម្បីបណ្តុះបណ្តាលសមត្ថភាពរបស់ស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ- សង្កាត់ ។ គណៈកម្មការថវិកានិងផែនការឃុំ- សង្កាត់ មានសមាសភាពជាស្ត្រីម្នាក់ និងបុរសម្នាក់ដែលតំណាងអោយភូមិនីមួយៗក្នុងឃុំ ឬសង្កាត់ផងដែរ ។ នៅក្នុងក្រុមប្រឹក្សាអភិវឌ្ឍន៍ភូមិ សមាជិក៤០ភាគរយត្រូវតែជាស្ត្រី ។ ប៉ុន្តែភាគរយស្ត្រីដែលត្រូវជ្រើសតាំងជាតំណាងរាស្ត្រថ្មីនៅមិនទាន់មានកំណើន

ខ្លាំងប៉ុន្មានទេ ។ ដើម្បីបង្កើនបន្ថែមទៀតការចូលរួមរបស់ស្ត្រីក្នុងជីវភាពនយោបាយ យើងចាំបាច់ត្រូវផ្លាស់ប្តូរនូវឥរិយាបទនិងទស្សនៈក្នុងចំណោមស្ត្រី និងលើកកំពស់វប្បធម៌នយោបាយទូទៅនៅកម្ពុជា ។ រាជរដ្ឋាភិបាលបន្តគាំទ្រកម្មវិធីមគ្គុទ្ទេសសំរាប់ស្ត្រីជាមន្ត្រីរាជការជាន់ខ្ពស់ ដើម្បីជំរុញការចូលរួមដោយស្មើភាពរបស់ពួកគេ នៅក្នុងការសម្រេចចិត្តលើបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ។

២៤៦- **ការលើកកំពស់ការយល់ដឹងជាសាធារណៈ** : បច្ចុប្បន្ន ការយល់ដឹងពីបញ្ហាសមភាពយេនឌ័រកាន់តែមានភាពទូលំទូលាយឡើង ។ ទិវានារីអន្តរជាតិត្រូវបានប្រើប្រាស់ដើម្បីផ្សព្វផ្សាយប្រធានបទសំខាន់ៗមួយចំនួនដូចជាការបំបាត់អំពើហឹង្សាក្នុងគ្រួសារ និងការរួមចំណែករបស់ស្ត្រីក្នុងសេដ្ឋកិច្ចជាតិ ។ កម្មវិធីនារីរតនៈដែលផ្សាយតាមវិទ្យុជាតិ ផ្សាយពតិមានទាក់ទងនឹងបញ្ហាយេនឌ័រ អាទិភាពនិងយុទ្ធសាស្ត្ររបស់ក្រសួង កិច្ចការនារី ។ ប្រព័ន្ធផ្សព្វផ្សាយត្រូវបានប្រើប្រាស់កាន់តែខ្លាំងឡើង ក្នុងយុទ្ធនាការប្រឆាំងការជួញដូរលើស្ត្រីនិងកុមារ ។

២៤៧- **ការទទួលបានការអប់រំ** : ការអប់រំមិនគ្រាន់តែចូលរួមកាត់បន្ថយភាពក្រីក្រនិងអនក្ខរភាពប៉ុណ្ណោះទេ ថែមទាំងជួយកាត់បន្ថយភាពងាយរងគ្រោះ អស្ថិរភាពសង្គម អត្រាមរណៈមាតានិងទារក ការឆ្លងជំងឺអេដស៍ អំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រីភេទ និងការរើសអើងគ្រប់ប្រភេទក្នុងគ្រួសារនិងសង្គម ។ ក្រសួងកិច្ចការនារីកំពុងសហប្រតិបត្តិការជាមួយក្រសួងអប់រំយុវជន និងកីឡា ដើម្បីចាតវិធានការសំដៅជំរុញសមភាពយេនឌ័រនៅក្នុងការចុះឈ្មោះចូលរៀននៅគ្រប់កំរិត និងការបញ្ចូលបញ្ហាយេនឌ័រទៅក្នុងកម្មវិធីសិក្សា ។ អាទិភាពកំពុងផ្តោតលើការកៀងគរធនធានសំរាប់អន្តរាគមន៍លើកកំពស់ការទទួលបានការអប់រំរបស់ស្ត្រីនិងកុមារ ដើម្បីអោយពួកគេអាចបន្តការសិក្សាផុតថ្នាក់ទី៩ ដូចជាការសាងសង់អន្តេវាសិកដ្ឋាន ការផ្តល់អាហារូបករណ៍ និងការបញ្ជូនទៅរៀននៅបរទេស ។ ក្រសួងកិច្ចការនារីបានអនុវត្តកម្មវិធីអក្ខរកម្ម និងការថែទាំកុមារ នៅតាមបណ្តាខេត្ត-ក្រុង ១៦ ។ មន្ត្រីថ្នាក់ខេត្តបានធ្វើការបណ្តុះបណ្តាលដល់ក្រុមការងារលើការថែទាំកុមារ និងការអប់រំយុវវ័យ ព្រមទាំងអ្នកបណ្តុះបណ្តាលទាំងនោះ ។ កម្មវិធីអក្ខរកម្មទាំងនេះបានទទួលការយល់ព្រមពីក្រសួងអប់រំ និងត្រូវបានអនុវត្តនៅទូទាំងប្រទេស ។

២៤៨- **បង្កើនការទទួលពតិមាននិងសេវាសុខាភិបាលដែលជួយកាត់បន្ថយភាពងាយរងគ្រោះពីការឆ្លងជំងឺអេដស៍** : ដោយមានកិច្ចសហប្រតិបត្តិការជាមួយក្រសួងសុខាភិបាល ក្រសួងកិច្ចការនារីបានរៀបចំនិងអនុវត្តគំរោងសាកល្បងមួយចំនួនដើម្បីពង្រីកការអប់រំពីសុខភាពបន្តពូជ និងការពន្យារកំណើតនៅតាមសហគមន៍មូលដ្ឋាន ។ ក្នុងគំរោងសាកល្បងដំបូងៗ អ្នកស្ម័គ្រចិត្តធ្វើការផ្នែកសុខភាពបន្តពូជនៅក្នុងខេត្តពីរបានទទួលការបណ្តុះបណ្តាលពីបញ្ហានេះ ជាមួយនិងការអប់រំផ្លូវភេទ ។ ក្រុមអ្នកស្ម័គ្រចិត្តទាំងនេះបានធ្វើការផ្សព្វផ្សាយពតិមានអោយដល់សហគមន៍តាមមូលដ្ឋាន ។ យោងលើបទពិសោធន៍ទាំងនេះ នាយកដ្ឋានសុខាភិបាលរបស់ក្រសួងកិច្ចការនារី បានរៀបចំនូវកម្មវិធីចែកចាយថ្នាំពន្យារកំណើតនៅតាមសហគមន៍មូលដ្ឋាន ហើយបានអនុវត្តនៅក្នុងខេត្ត៦ ។ ភ្នាក់ងារចែកចាយក៏បានទទួលការបណ្តុះបណ្តាលផងដែរ ។

សំភារៈបរិក្ខារនិងបែបបទនានា ត្រូវបានសំរេចឡើងដើម្បីធានាការអនុវត្តន៍កម្មវិធីនេះអោយបានសំរេចជោគជ័យ ព្រមទាំងធ្វើការវាយតំលៃ និងតាមដានទៀតផង ។ គំរោងសាកល្បងក្នុងការទប់ស្កាត់ការឆ្លងជំងឺគ្រុនចាញ់ ក៏ត្រូវបានអនុវត្តនៅក្នុងខេត្តមួយផងដែរ ។ ភ្នាក់ងារដែលបំពេញភារកិច្ចទាំងនេះបានទទួលការហ្វឹកហ្វឺន ដើម្បីអោយពួកគេបណ្តុះបណ្តាលបន្តដល់អ្នកភូមិ ប្រធានភូមិ និងអ្នកសំរបសំរួលនៅតាមស្រុក ។ លទ្ធភាពរបស់ក្រសួងកិច្ចការនារីក្នុងការបំពេញភារកិច្ចតាមរយៈបណ្តាញនៅតាមសហគមន៍ មូលដ្ឋានជាកត្តាមួយដែលនាំអោយការអនុវត្តន៍គំរោងប្រភេទនេះបានទទួលជោគជ័យ ។ ក្រសួងកិច្ចការនារីបានដឹកនាំការរៀបចំតាក់តែងគោលនយោបាយជាតិស្តីពីស្ត្រីនិងកុមារ និងការឆ្លងជំងឺសង្គមដូចជា អេដស៍ ហើយថែមទាំងបានចូលរួមគាំទ្រយ៉ាងសកម្មក្នុងការគណៈកម្មាធិការអចិន្ត្រៃយ៍និងបច្ចេកទេសនានារបស់អជ្ញាធរអេដស៍ ក្នុងការតាក់តែងយុទ្ធសាស្ត្រឆ្លើយតបពហុវិស័យទៅនឹងការឆ្លងមេរោគអេដស៍ ជាពិសេសភាពងាយរងគ្រោះរបស់ស្ត្រី និងកុមារ ។

២៤៩- **ការបង្កើនសមត្ថភាពសេដ្ឋកិច្ច** : រាជរដ្ឋាភិបាលបានប្រឹងប្រែងយ៉ាងខ្លាំងដើម្បីធានាការចូលរួមដោយស្មើភាពរបស់ស្ត្រីទៅក្នុងសកម្មភាពសេដ្ឋកិច្ច ។ ក្រសួងកិច្ចការនារីបានសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការរៀបចំគោលនយោបាយទីផ្សារបន្លែនិងផ្លែឈើ អនុវត្តគំរោងសាកល្បងជាមួយក្រុមកសិករនិងអ្នកប្រើប្រាស់ទឹក កសាងសាលាកសិករ បណ្តុះបណ្តាលកសិករស្ត្រី និងរៀបចំផែនការដើម្បីបញ្ជ្រាបបញ្ហាយេនឌ័រក្នុងវិស័យកសិកម្ម ។ សហគ្រាសខ្នាតតូចមានសារៈសំខាន់ដល់ស្ត្រី ។ ក្រសួងកិច្ចការនារីបានផ្តល់ការបណ្តុះបណ្តាលជំនាញមូលដ្ឋានដល់ស្ត្រី ដូចជាការដេរប៉ាក់ ត្បាញ និងអ៊ុតសក់ ព្រមទាំងផ្តល់ឥណទានខ្នាតតូចតាមរយៈមជ្ឈមណ្ឌលស្ត្រីក្នុងការអភិវឌ្ឍន៍ និងតាមមន្ទីរនៅតាមខេត្តនានា ។ យុទ្ធសាស្ត្រទូលំទូលាយមួយត្រូវបានរៀបចំឡើងដើម្បីជំរុញនិងគាំទ្រស្ត្រីក្នុងសហគ្រាស ។ កម្មវិធី ភូមិមួយផលិតផលមួយ ត្រូវបានបញ្ចូលតាមរយៈសិក្ខាសាលា ស្ត្រីនិងការលើកកំពស់ការអភិវឌ្ឍន៍សហគ្រាសខ្នាតតូចនិងមធ្យម កាលពីឆ្នាំ២០០១ ។ សកម្មភាពសាកល្បងត្រូវបានអនុវត្តដើម្បីណែនាំបច្ចេកវិទ្យាកែច្នៃម្ហូបនៅតាមភូមិ រៀបចំសាកល្បងវិធីសាស្ត្រដើម្បីកែលំអការចូលទៅកាន់ទីផ្សាររបស់ក្រុមជនងាយរងគ្រោះ និងប្រែក្លាយមជ្ឈមណ្ឌលស្ត្រីក្នុងការអភិវឌ្ឍន៍អោយទៅជាមជ្ឈមណ្ឌលស្ត្រីមានអំណាចតាមរយៈការគាំទ្រដូចជាជំនាញ និងការទទួលបានឥណទាន ។ ឧស្សាហកម្មវាយនភ័ណ្ឌជាប្រភពចំណូលមួយសំរាប់ស្ត្រី ។ ការលុបបំបាត់ប្រព័ន្ធកូតាចាប់ពីឆ្នាំ២០០៥ នឹងបើកផ្លូវដល់ការប្រកួតប្រជែងក្នុងវិស័យនេះ ។ ដើម្បីបង្កើនកាលានុវត្តភាពរបស់ស្ត្រីក្នុងផ្នែកនេះ រាជរដ្ឋាភិបាលនឹងប្រឹងប្រែងរក្សាកេរ្តិ៍ឈ្មោះថាជាប្រទេសមួយដែលមានលក្ខខ័ណ្ឌការងារស្អាតស្អំ ដើម្បីទាក់ទាញវិនិយោគ ។ សកម្មភាពសាកល្បងមួយចំនួនកំពុងត្រូវបានអនុវត្តដើម្បីការពារស្ត្រីអោយរួចផុតពីការរំលោភសិទ្ធិការងារ ។

២៥០- **ពង្រឹងសិទ្ធិនិងការការពារតាមផ្លូវច្បាប់** : រាជរដ្ឋាភិបាលបានរៀបចំក្របខ័ណ្ឌគតិយុត្តិមួយដែលមានការគិតគូរដល់បញ្ហាយេនឌ័រ ។ ក្រៅពីរៀបចំពង្រាងច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ និងចូលរួមក្នុងការតាក់តែងច្បាប់ប្រឆាំងការជួញដូរមនុស្សរបស់ក្រសួងយុត្តិធម៌ ក្រសួងក៏បានចូលរួមផងដែរក្នុងការរៀបចំច្បាប់

ស្តីពីកម្មសិទ្ធិ ក្រមព្រហ្មទណ្ឌ ច្បាប់គ្រួសារនិងអាពាហ៍ពិពាហ៍ និងបទបញ្ញត្តិនានាសំរាប់ការអនុវត្តន៍ច្បាប់ការងារ ។ ការពិគ្រោះយោបល់ត្រូវបានរៀបចំឡើងក្នុងការរៀបចំច្បាប់ស្តីពីការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ ។ ច្បាប់នេះត្រូវបានបញ្ជូនទៅសភាជាតិកាលពីរាជរដ្ឋាភិបាលនិតិកាលមុន តែការអនុម័តច្បាប់នេះត្រូវពន្យារពេលដោយសារតែព្រឹត្តិការណ៍នយោបាយនៅមុននិងក្រោយការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រកាលពីឆ្នាំ២០០៣ ។ រាជរដ្ឋាភិបាលនៅបន្តប្តេជ្ញាប្រឆាំងការជួញដូរមនុស្ស ។ វិធានការមួយចំនួនត្រូវបានប្រកាន់យក ដូចជា ÷ ទី១- ចរចាជាមួយថៃនិងវៀតណាមស្តីពីកិច្ចសហប្រតិបត្តិការលុបបំបាត់ការជួញដូរមនុស្ស ។ ទី២- រៀបចំច្បាប់ប្រឆាំងនឹងការជួញដូរមនុស្សដែលនឹងត្រូវដាក់ជូនសភាជាតិអនុម័តក្នុងពេលឆាប់ៗ ។ ទី៣- បណ្តុះបណ្តាលមន្ត្រីប៉ូលីស ទាហាន និងមន្ត្រីតុលាការលើការទប់ស្កាត់ការជួញដូរ ។ ទី៤- ធ្វើយុទ្ធនាការផ្សព្វផ្សាយពតិមាន និងអប់រំអំពីការជួញដូរស្ត្រីនិងកុមារ ។ ទី៥- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធដើម្បីចាប់ជនឧក្រិដ្ឋផ្តន្ទាទោស ។ ក្រសួងកិច្ចការនារីក៏ត្រូវបានស្នើអោយមានអន្តរាគមន៍ផងដែរក្នុងបញ្ហាដែលទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ ការជួញដូរផ្លូវភេទលើកុមារ និងស្ត្រី ។ តួនាទីរបស់ក្រសួងកិច្ចការនារីគឺជួយស្ត្រីអោយទទួលបាននូវការការពារផ្នែកផ្លូវច្បាប់ ។ វិទ្យាស្ថានកិច្ចការសង្គមត្រូវបានបង្កើតឡើង ដើម្បីផ្តល់ការបណ្តុះបណ្តាលដល់អង្គការមិនមែនរដ្ឋាភិបាលដែលបំរើការផ្នែក ច្បាប់ និងសេវាអោយដល់ជនរងគ្រោះដោយអំពើហិង្សាដែលកើតពីបញ្ហាយេនឌ័រ ។

២៥១- **អភិបាលកិច្ចល្អ** : ក្រសួងកិច្ចការនារីត្រូវបានបង្កើតក្នុងឆ្នាំ១៩៩៩ ដើម្បីជំរុញសមភាពផ្លូវភេទ និងលើកកំពស់តួនាទីនិងឋានៈរបស់ស្ត្រីនៅក្នុងសង្គមជាតិ ។ ក្រសួងបានផ្តោតការយកចិត្តទុកដាក់របស់ខ្លួនលើកិច្ចការបញ្ជ្រាបបញ្ហាយេនឌ័រ ព្រមទាំងរៀបចំយុទ្ធសាស្ត្រដែលពាក់ព័ន្ធនឹងបញ្ហានេះ ។ ក្រសួងកិច្ចការនារីជាក្រសួងថ្មី ដែលបានប្តូរតួនាទីពីការផ្តល់សេវាដោយផ្ទាល់ ទៅជាអ្នកសំរបសំរួលសកម្មភាពដែលឆ្លើយតបនឹងបញ្ហាយេនឌ័រនៅក្នុងកម្មវិធី និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល ។ ការយកចិត្តទុកដាក់ត្រូវផ្តោតលើការកសាងសមត្ថភាពរបស់ក្រសួង ដើម្បីអាចមានសមត្ថភាពអនុវត្តតួនាទីរបស់ខ្លួន ។ យើងត្រូវរៀបចំសកម្មភាព និងយុទ្ធសាស្ត្រថ្មីៗមួយចំនួនទៀត ដោយរួមទាំងការបណ្តុះបណ្តាលមន្ត្រី ។ យើងត្រូវបន្តអនុវត្តទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ។

## ជំពូកទី ៣

## កម្មវិធីនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល : យុទ្ធសាស្ត្រចតុកោណ

២៥២- បន្ទាប់ពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣ ដែលអ្នកសង្កេតការណ៍ជាតិនិងអន្តជាតិបានវាយតម្លៃថា ជាការបោះឆ្នោតមួយដោយសេរី យុត្តិធម៌ ត្រឹមត្រូវ និងមានតំលាភាព រាជរដ្ឋាភិបាល ដែលមានគណបក្សចូលរួម ត្រូវបានបង្កើតឡើង នាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤ ដើម្បីអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សំរាប់នីតិកាលទី ៣ នៃរដ្ឋសភា ។ ស្របទៅតាមឆន្ទៈរបស់ប្រជារាស្ត្រ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តយ៉ាងពេញទំហឹង ចំពោះបុព្វហេតុនៃសុខសន្តិភាព ការបង្រួបបង្រួមជាតិ ស្ថេរភាព សណ្តាប់ធ្នាប់សង្គម ការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ឯករាជ្យជាតិ អធិបតេយ្យភាព និងបូរណភាពទឹកដី និងការអភិវឌ្ឍន៍ប្រកបដោយចិរភាព ដែលនឹងផ្តល់ជូនដល់ប្រទេសជាតិ និងប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់ នូវវឌ្ឍនភាព វិបុលភាព សុខដុមរមនា និងជីវភាពសមរម្យថ្លៃថ្នូរ ។

២៥៣- រាជរដ្ឋាភិបាល នៅក្នុងនីតិកាលទី៣នេះ នឹងបន្តអនុវត្តកម្មវិធីកំណែទំរង់អោយកាន់តែស៊ីជំរៅបន្ថែមទៀត ដើម្បីឈានទៅអនុវត្តអោយបានសំរេច នូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា (Cambodia's Millenium Development Goals-CMDGs) ។ សំរាប់រាជរដ្ឋាភិបាលកម្ពុជា ការរក្សាអោយបាន និងការបង្កើនល្បឿននៃកំណែទំរង់ គឺជាបញ្ហា " ស្លាប់-រស់ " របស់កម្ពុជា ។ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ទាំងអស់ យើងត្រូវសំរេចអោយបាននូវវឌ្ឍនភាពក្នុងកម្មវិធីកំណែទំរង់របស់យើង ដើម្បីអោយកម្ពុជាអាចរំដោះខ្លួនចេញពីវដ្តសង្សារនៃភាពក្រីក្រតោកយ៉ាក ហើយស្តារឡើងវិញបាននូវភាពថ្លៃថ្នូររបស់ប្រជាជាតិមួយដែលធ្លាប់តែរឹងមាំ និងមានមោទនភាព ។ ផ្ទុយទៅវិញ ការមិនសំរេចបាននូវវឌ្ឍនភាពក្នុងកម្មវិធីកំណែទំរង់ ដោយឈរលើមូលដ្ឋានចលនករ (Momentum) កន្លងមកទេនោះ យើងមិនត្រឹមតែបាត់បង់នូវសំណាងនិងកាលានុវត្តភាពប៉ុណ្ណោះទេ ប៉ុន្តែយើងនឹងបន្តស្ថិតក្នុងភាពក្រីក្ររ៉ាំរ៉ៃ ជម្លោះ និងអស្ថិរភាពមិនចេះចប់ ។

២៥៤- ទិសដៅជាសារវន្តរបស់រាជរដ្ឋាភិបាលនីតិកាលទី៣នៃរដ្ឋសភា គឺកសាងជាជំហានៗនូវសង្គមកម្ពុជាមួយ ដែលមានសន្តិភាព ស្ថិរភាព សណ្តាប់ធ្នាប់សង្គម មានការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ ប្រជាធិបតេយ្យ ព្រមទាំងសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស ។ រាជរដ្ឋាភិបាលនឹងជំរុញកិច្ចអភិវឌ្ឍន៍ប្រកបចិរភាព និងសមធម៌ មានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់និងវប្បធម៌ជ្រៅជ្រះ មានសេចក្តីថ្លៃថ្នូរក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ព្រមទាំងមានសុខដុមរមនាក្នុងគ្រួសារ និងក្នុងសង្គម ។ របៀបវារៈនយោបាយដ៏ខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី៣នៃរដ្ឋសភា គឺ÷

ទី១- ការជំរុញលើកកំពស់កំណើនសេដ្ឋកិច្ច ។

ទី២- ការដោះស្រាយការងារសំរាប់ពលករកម្ពុជាគ្រប់រូប ។

ទី៣- ការអនុវត្តន៍ផែនការសកម្មភាពអភិបាលកិច្ច ដើម្បីធានាសមធម៌ និងយុត្តិធម៌ក្នុងសង្គម និងការធានាប្រសិទ្ធភាពការងាររបស់រាជរដ្ឋាភិបាល ។

ទី៤- ការបង្កើនល្បឿនក្នុងការអនុវត្តន៍កម្មវិធីកំណែទំរង់ទូលំទូលាយ ក្នុងគ្រប់ផ្នែក- គ្រប់វិស័យ ក្នុងទិសដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងការអភិវឌ្ឍន៍ប្រកបដោយចិរភាព ។

២៥៥- បន្ទាប់ពីការបង្កើតរាជរដ្ឋាភិបាលសំរាប់នីតិកាលទី៣ នៃរដ្ឋសភា រួចភ្លាមមក រាជរដ្ឋាភិបាលបានឧទ្ទេសនាមជូនប្រជាជន និងដៃគូអភិវឌ្ឍន៍របស់ខ្លួននូវ «**យុទ្ធសាស្ត្រចតុកោណ**» ដែលជារបៀបវារៈនយោបាយសេដ្ឋកិច្ច សំរាប់អនុវត្តកម្មវិធីនយោបាយ ។ «**យុទ្ធសាស្ត្រចតុកោណ**» ត្រូវបានរៀបចំកសាងឡើងដោយផ្អែកលើជោគជ័យនៃការអនុវត្តន៍ «**យុទ្ធសាស្ត្រត្រីកោណ**» ដែលត្រូវបានអនុវត្តក្នុងនីតិកាលទី២កន្លងមកនេះ ។ ជោគជ័យនៃការអនុវត្តន៍ «យុទ្ធសាស្ត្រត្រីកោណ» បានធ្វើអោយប្រទេសកម្ពុជាឆ្លងកាត់នូវដំណាក់កាលប្រែប្រួលយ៉ាងធំធេងពីចំណុចមួយនៃផែនទីពិភពលោកដែលប្រកបដោយភាពមិនច្បាស់លាស់ ដោយសារកលយុគសង្គ្រាម ជម្លោះផ្ទៃក្នុង អស្ថេរភាព និងភាពអន់ថយ ហើយក្លាយទៅជាប្រទេសមួយដែលមានសុខសន្តិភាពពេញលេញ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម មានការគោរពនូវលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ ។ ឆ្លងកាត់រយៈពេលដ៏ខ្លីបំផុត ប្រសិនបើប្រៀបធៀបទៅនឹងប្រវត្តិសាស្ត្រនៃប្រទេសជឿនលឿននានា យើងបានបង្ហាញអោយដៃគូអន្តរជាតិទាំងឡាយមើលឃើញដោយគ្មានការសង្ស័យថា កម្ពុជាពិតជាមានសមត្ថភាពគ្រប់គ្រាន់ដើម្បីចូលប្រឡូកដោយស្មើភាពនិងស្មើសិទ្ធិក្នុងកិច្ចការតំបន់ និងកិច្ចការពិភពលោក ។ ប្រការទាំងអស់នេះបានប្រែក្លាយទៅជាការកើនឡើងនូវជំនឿទុកចិត្តមកលើប្រទេសកម្ពុជា ហើយផ្តល់ជាផលប្រយោជន៍មកវិញតាមរយៈការកើនឡើងនៃពាណិជ្ជកម្ម លំហូរវិនិយោគ និងទេសចរណ៍ចូលមកក្នុងប្រទេសកម្ពុជា ដែលជាកត្តាយ៉ាងសំខាន់សំរាប់ជួយបង្កើតការងារ និងបង្កើនចំណូលដល់ពលករកម្ពុជា ដែលកើតចេញជាលទ្ធផលចុងក្រោយ គឺការកាត់បន្ថយភាពក្រីក្រ និងការបង្កើនសុខុមាលភាពរបស់ប្រជាជន ។

២៥៦- «**យុទ្ធសាស្ត្រចតុកោណ**» នេះ ជារបៀបវារៈនយោបាយសេដ្ឋកិច្ចនៃនីតិកាលទី ៣ របស់រាជរដ្ឋាភិបាល ។ យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើង ដោយផ្អែកលើសមាសធាតុសំខាន់ៗនៃ «គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា» «ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច៥ឆ្នាំ លើកទី២ ឆ្នាំ២០០១-២០០៥» «យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រឆ្នាំ២០០៣-២០០៥» និងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍តាមវិស័យជាផ្លូវការនានា ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រទាំងអស់នេះ ត្រូវបានរៀបចំឡើង ដោយឆ្លងកាត់ការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយបណ្តាភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិ រួមទាំងសង្គមស៊ីវិល និងសហគមន៍អ្នកផ្តល់ជំនួយទៀតផង ។

២៥៧- «**យុទ្ធសាស្ត្រចតុកោណ**» គឺជា «របៀបវារៈគោលនយោបាយសេដ្ឋកិច្ច» នៃ «កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នៃរដ្ឋសភា» ។ យុទ្ធសាស្ត្រត្រូវបានយកមករៀបចំលំអិតបន្ថែមទៀត ហើយបានសំរិតសំរាំង សម្រួច និងរំលេចអោយចេញជាកញ្ចប់អាទិភាពទៅតាមបណ្តាវិស័យសំខាន់ៗនានា ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងជាប្រព័ន្ធស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា និងយោងគ្នាទៅវិញទៅមក ហើយងាយយល់ និងងាយគ្រប់គ្រង ដែលអនុញ្ញាតិអោយរាជរដ្ឋាភិបាលអាចប្រើប្រាស់បានជា «ឧបករណ៍គ្រប់គ្រង» (Managemnet Tool) សំរាប់ការអនុវត្តន៍ និងគ្រប់គ្រងរបៀបវារៈគោលនយោបាយសេដ្ឋកិច្ចរបស់កម្ពុជា ។ គោលដៅចំបងរបស់យុទ្ធសាស្ត្រចតុកោណគឺ ÷ ការជំរុញលើកកំពស់កំណើនសេដ្ឋកិច្ច ការដោះស្រាយការងារសំរាប់ពលករកម្ពុជា ការធានាសមធម៌និងយុត្តិធម៌សង្គម និងការលើកស្ទួយប្រសិទ្ធភាពនៃវិស័យសាធារណៈ តាមរយៈផែនការសកម្មភាពអភិបាលកិច្ច និងកំណែទំរង់ស៊ីជំរៅ និងប្រទាក់ក្រឡាគ្នាក្នុងគ្រប់ផ្នែក- គ្រប់វិស័យ ។ តាមខ្លឹមសារនេះ រាជរដ្ឋាភិបាលនីតិកាលទី ៣ នៃរដ្ឋសភាត្រូវបានប្រសិទ្ធនាមថាជា «រាជរដ្ឋាភិបាលដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព» ។

២៥៨- យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងតាមរចនាសម្ព័ន្ធ ដែលបានប្រទាក់ក្រឡាជាប់គ្នា គ្រប់ជ្រុងជ្រោយទាំងអស់ ។ ជារួម សមាសធាតុនៃ «**យុទ្ធសាស្ត្រចតុកោណ**» មានដូចតទៅ ÷

ទី១- <u>ស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺ អភិបាលកិច្ចល្អ</u> ដែលផ្តោតការយកចិត្តទុកដាក់ទៅលើកំណែទំរង់បួនយ៉ាង គឺ ÷ ទី១- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ ទី២- កំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ។ ទី៣- កំណែទំរង់រដ្ឋបាលសាធារណៈ រួមមានទាំងកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការផង ។ និងទី៤- កំណែទំរង់កងកំលាំងប្រដាប់អាវុធ ពិសេសគឺកម្មវិធីកាត់វិសាយទ័ព ។

ទី២- <u>បរិស្ថានគ្របដណ្តប់សំរាប់ការអនុវត្តន៍យុទ្ធសាស្ត្រទាំងមូល</u> ដែលមានបួនដែរ គឺ ÷ ទី១- សុខសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម ។ ទី២- ភាពជាដៃគូនៅក្នុងការអភិវឌ្ឍន៍ រួមមាន ភាពជាដៃគូជាមួយវិស័យឯកជន និងសហគមន៍អ្នកផ្តល់ជំនួយ ព្រមទាំងភាពជាដៃគូជាមួយនឹងសង្គមស៊ីវិល ។ ទី៣- បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ ។ និងទី៤- សមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក ។

ទី៣- <u>ចតុកោណយុទ្ធសាស្ត្រទាំង៤ សំរាប់ជំរុញកំណើន</u>រួមមាន ÷ ទី១- ការលើកស្ទួយវិស័យកសិកម្ម ។ ទី២- ការអភិវឌ្ឍន៍ផ្នែកឯកជននិងការងារ ។ ទី៣- ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងទី៤- ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស ។

ទី៤- <u>ចតុកោណយុទ្ធសាស្ត្រនីមួយៗមានមុំយុទ្ធសាស្ត្របួន</u> គឺ ÷

<u>ចតុកោណទី១</u> - ការលើកស្ទួយវិស័យកសិកម្ម មាន ÷ ទី១- ការលើកកំពស់ផលិតភាព និងពិពិធកម្មវិស័យកសិកម្ម ។ ទី២- កំណែទំរង់ដីធ្លី និងការបោសសំអាតមីន ។ ទី៣- កំណែទំរង់វិស័យនេសាទ និងជលផល ។ និងទី៤- កំណែទំរង់ព្រៃឈើ ។

ចតុកោណទី២ - ការអភិវឌ្ឍន៍ផ្នែកឯកជន និងការងារ មាន ÷ ទី១- ការពង្រឹងវិស័យឯកជន និងការទាក់ទាញទុនវិនិយោគ ។ ទី២- ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម ។ ទី៣- ការបង្កើតការងារ និងការធានាលក្ខខ័ណ្ឌការងារល្អប្រសើរជូនដល់កម្មករ និងនិយោជិត ។ និងទី៤- ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គមសំរាប់មន្ត្រីបុគ្គលិក និងកម្មករ ។

ចតុកោណទី៣ - ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មាន ÷ ទី១- ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ (ផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស) ។ ទី២- ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ ។ ទី៣- ការអភិវឌ្ឍន៍វិស័យថាមពល និងបណ្តាញអគ្គិសនី ។ និងទី៤- ការអភិវឌ្ឍន៍បច្ចេកវិទ្យាពតិមាន និងទូរគមនាគមន៍ ។

ចតុកោណទី ៤ - ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស រួមមាន ÷ ទី១- ការលើកកំពស់ និងពង្រឹងគុណភាពនៃវិស័យអប់រំ ។ ទី២- ការលើកកំពស់សេវាសុខាភិបាល ។ ទី៣- ការអនុវត្តន៍គោលនយោបាយយេនឌ័រ ។ និងទី៤- ការអនុវត្តន៍គោលនយោបាយប្រជាជន ។

២៥៩- រាជរដ្ឋាភិបាលកម្ពុជាបានចំណាយពេលវេលា និងបានខិតខំប្រឹងប្រែងយ៉ាងពេញទំហឹង អស់រយៈពេលរាប់ទសវត្សរ៍ ដើម្បីស្តារ និងកសាងប្រទេសឡើងវិញពីការបំផ្លិចបំផ្លាញនៃរបបប្រល័យពូជសាសន៍ និងសង្គ្រាម រាំរ៉ៃ ទម្រាំសំរេចបាននូវសុខសន្តិភាពពេញលេញ ស្ថេរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម លទ្ធិប្រជាធិប តេយ្យ ការគោរពសិទ្ធិមនុស្ស និងស្ថិរភាពសេដ្ឋកិច្ចរឹងមាំ ។ កន្លងមក រាជរដ្ឋាភិបាលបានអនុវត្តកម្មវិធីកំណែទំរង់គ្រប់វិស័យដោយបានឆ្លងកាត់ការលំបាក និងឧបសគ្គធំតូចច្រើនរាប់មិនអស់ ។ កម្ពុជាបានអនុវត្តប្រកបដោយជោគជ័យចាប់ពីទសវត្សរ៍ទី៨០ ក្នុងកិច្ចដំណើរការឆ្លងអន្តរកាលពីសេដ្ឋកិច្ចបែបផែនការ មកបង្កើតបាននូវប្រព័ន្ធសេដ្ឋកិច្ចទីផ្សារដ៏រស់រវើក ។

២៦០- ភាពប្រឈមចំបងបំផុតចំពោះកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ គឺការកាត់បន្ថយនូវភាពក្រីក្រ និងការធ្វើអោយប្រសើរឡើងនូវគុណភាពនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាដែលកំពុងតែមានកំណើនយ៉ាងលឿន ។ យុទ្ធសាស្ត្រចតុកោណគឺជាឧបករណ៍ខាងគោលនយោបាយ សំរាប់អោយរាជរដ្ឋាភិបាលអនុវត្ត ដើម្បីកាត់បន្ថយភាពក្រីក្រ ក្នុងនីតិកាលរបស់ខ្លួន ក្នុងគោលដៅឈានទៅសំរេចនូវបណ្តាគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់កម្ពុជា ។ រាជរដ្ឋាភិបាលទទួលស្គាល់ថា កម្ពុជានៅមានផ្លូវដ៏វែងអន្លាយសំរាប់ធ្វើដំណើរទៅមុខ ហើយត្រូវពុះពារឆ្លងកាត់ឧបសគ្គរាប់មិនអស់ថែមទៀត ដើម្បីសំរេចបាននូវវឌ្ឍនភាព និងវិបុលភាពដ៏រុងរឿងថ្កើងថ្កានជូនប្រទេសជាតិ និងប្រជាជន ។ ក្នុងន័យនេះ ការខិតខំប្រកបដោយសុខដុមនីយកម្មក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា នៅតែជាគោលដៅដ៏ចំបងបំផុតរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី៣នៃរដ្ឋសភានេះ ។

២៦១- ក្នុងន័យនេះ រាជរដ្ឋាភិបាលសូមអំពាវនាវដល់គ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ រួមមានសហគមន៍អ្នកផ្តល់ជំនួយវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការនៅគ្រប់ក្រសួង-

ស្ថាប័ន ទាំងស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ព្រមទាំងតុលាការ កងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋគ្រប់រូប សូមផ្តល់ការគាំទ្រគ្រប់បែបយ៉ាង និងសូមយកចិត្តទុកដាក់ចូលរួមអោយបានសកម្មជាមួយនឹងរាជរដ្ឋាភិបាល ដើម្បីអនុវត្តអោយបានជោគជ័យនូវ «កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នៃរដ្ឋសភា» ពិសេសគឺយុទ្ធសាស្រ្តចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដែលជារបៀបវារៈគោលនយោបាយសេដ្ឋកិច្ចនៃកម្មវិធីនយោបាយនេះ ។

## ជំពូកទី ៤
## អាទិភាពសំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ

២៦២- ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣នៃរដ្ឋសភា គឺការកសាងសង្គមមួយ ដែលមានសាមគ្គីភាពរឹងមាំ មានប្រព័ន្ធអប់រំនិងវប្បធម៌ជឿនលឿន ដើម្បីរំដោះកម្ពុជាអោយរួចផុតពីខ្នោះឃ្នាងនៃភាពក្រីក្រ គ្មានអនក្ខរភាព និងជម្ងឺដម្កាត់ផ្សេងៗ ។ ដើម្បីសំរេចអោយបានទស្សនៈវិស័យនេះ យើងត្រូវប្រកាន់ខ្ជាប់នូវតំលៃនៃយុត្តិធម៌សង្គម សុខមាលភាព ការផ្តល់សិទ្ធិអំណាច ការរៀបចំនិងការអនុវត្តន៍គោលនយោបាយកាត់បន្ថយភាពក្រីក្រ ដោយជំរុញអោយមានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងអភិបាលកិច្ចល្អ ។

| **អាទិភាពសំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ** |
|---|
| ៤.១- អភិបាលកិច្ចល្អ |
| ៤.២- បរិស្ថានសំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ |
| ៤.៣- កំណើន |

២៦៣- **យុទ្ធសាស្ត្រចតុកោណ** របស់រាជរដ្ឋាភិបាលនីតិកាលទី៣ នៃរដ្ឋសភា ត្រូវបានរៀបចំឡើង ដើម្បីធ្វើអោយបានសំរេចនូវចក្ខុវិស័យនេះ ។ ក្នុងរយៈពេលដ៏ខ្លី បន្ទាប់ពីការបង្កើតរាជរដ្ឋាភិបាលថ្មីក្នុងខែកក្កដា ឆ្នាំ២០០៤ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានធ្វើការណែនាំដល់ក្រសួងនិងស្ថាប័នរបស់រដ្ឋាភិបាលទាំងអស់ អោយរៀបចំផែនការសកម្មភាពសំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ ។ នាកិច្ចប្រជុំត្រៀមនៃកិច្ចប្រជុំពិគ្រោះយោបល់ ដែលបានប្រារព្ធឡើងកាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០២ នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្តេចនាយករដ្ឋមន្ត្រីបានអំពាវនាវដល់ដៃគូអភិវឌ្ឍន៍ទាំងឡាយ អោយធ្វើការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់អាទិភាពនានា តាមរយៈដំណើរការមួយដែលមានកិច្ចសហការគ្នា និងរៀបចំផែនការសកម្មភាព សំរាប់អនុវត្តបណ្តាគោលនយោបាយដែលបានលើកឡើងនៅក្នុងយុទ្ធសាស្ត្រចតុកោណ ។ ក្រុមការងារបច្ចេកទេសរួមរវាងរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយទាំង១៧ មានភារកិច្ចបញ្ចប់ការងារនេះ អោយបានមុនកិច្ចប្រជុំពិគ្រោះយោបល់ ដែលបានគ្រោងនាដើមខែធ្នូ ឆ្នាំ២០០៤ ។ ដូច្នេះ អាទិភាពសំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ ដែលត្រូវលើកនៅក្នុងផ្នែកបន្តបន្ទាប់ទៀត គឺជាការងារដែលកំពុងវិវត្តទៅមុខ និងដែលបានឆ្លុះបញ្ចាំងអំពីបណ្តាការងារអាទិភាពដំបូងរបស់ក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាល ។

### ៤.១- អភិបាលកិច្ចល្អ

២៦៤- ចំពោះរាជរដ្ឋាភិបាល អភិបាលកិច្ចល្អ គឺជាបុរេលក្ខណៈវិនិច្ឆ័យសំខាន់បំផុតមួយ ដើម្បីធានាអោយមានការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាព សមធម៌ និងយុត្តិធម៌សង្គម ។ អភិបាលកិច្ចល្អត្រូវអោយមាននូវការចូលរួមយ៉ាងទូលំទូលាយ មានការលើកកំពស់ការចែក

| **អភិបាលកិច្ចល្អ** |
|---|
| - ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ |
| - កំណែទំរង់ច្បាប់និងប្រព័ន្ធតុលាការ |
| - កំណែទំរង់រដ្ឋបាលសាធារណៈ រួមទាំង វិមជ្ឈការ និងវិសហមជ្ឈការ |
| - កំណែទំរង់កងកំលាំងប្រដាប់អាវុធ ពិសេស ការរំសាយកងទ័ព |

វិលែកពតិមាន មានគណនេយ្យភាព និងតំលាភាព មានលក្ខណៈស្មើភាព និងការមិនបោះបង់ចោលនូវបុគ្គលណាម្នាក់ និងការប្រតិបត្តិតាមវិធាននៃច្បាប់ ។ ក្នុងនីតិកាលទី៣នេះ ដើម្បីសំរេចគោលបំណងនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ទៅលើការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព នូវផែនការសកម្មភាពអភិបាលកិច្ចរបស់ខ្លួន ដែលគ្របដណ្តប់លើកំណែទំរង់៤យ៉ាង ដែលមានការពាក់ព័ន្ធគ្នាទៅវិញទៅមក ក្នុងនោះរួមមាន ÷

ទី១- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។

ទី២- កំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

ទី៣- កំណែទំរង់រដ្ឋបាលសាធារណៈ រួមមានទាំងកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការផង ។

ទី៤- កំណែទំរង់កងកំលាំងប្រដាប់អាវុធ ពិសេសគឺកម្មវិធីកាត់វិសាយទ័ព ។

## ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

២៦៥- ដូចមានចែងក្នុងយុទ្ធសាស្រ្តចតុកោណ ស្នូលនៃយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាលក្នុងការប្រឆាំងនឹងអំពើពុករលួយ គឺការអនុវត្តន៍សកម្មភាពជាក់ស្តែង ដើម្បីរំលើងឫសគល់នៃអំពើពុករលួយ ។ ការអនុវត្តន៍យុទ្ធសាស្រ្តប្រឆាំងនឹងអំពើពុករលួយត្រូវគាំទ្រដោយមធ្យោបាយ និងធនធានគ្រប់គ្រាន់ ដើម្បីបង្ការ និងបំបាត់សមាសភាពពុករលួយ ។ ការអនុវត្តន៍គឺពិតជាមានសារៈសំខាន់ ពីព្រោះច្បាប់ បទបញ្ញត្តិ និងលិខិតបទដ្ឋានសំរាប់ណែនាំនៅមិនទាន់គ្រប់គ្រាន់ ដើម្បីប្រឆាំងនឹងអំពើពុករលួយឡើយ ។ ជាការពិត យើងត្រូវប្រឹងប្រែងទាំងអស់គ្នា និងត្រូវមានយន្តការដើម្បីពង្រឹងការអនុវត្តន៍ច្បាប់អោយមានប្រសិទ្ធភាព ។

២៦៦- ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ រាជរដ្ឋាភិបាលបានប្តេជ្ញាបន្តអនុវត្តតាមអភិក្រម ដែលមានលក្ខណៈសន្តនិយម (Holistic) មានការចូលរួមអនុវត្តជាបណ្តើរៗ និងមានចីរភាព ដើម្បីលុបបំបាត់ឫសគល់នៃបញ្ហាដែលមាននាំអោយកើតអំពើពុករលួយ ។ ទោះបីយើងបានសំរេចនូវវឌ្ឍនភាព នៅក្នុងកិច្ចការមួយចំនួន កិច្ចការមួយចំនួនទៀតនៅទ្រឹង ។ ដើម្បីប្រឆាំងនឹងអំពើពុករលួយ រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្តន៍ច្បាប់ប្រឆាំងនឹងអំពើពុករលួយអោយបានខ្លាំងក្លាបំផុតបន្ទាប់ពីច្បាប់នេះត្រូវបានសភាអនុម័ត រួចព្រមទាំងបង្កើតនូវអង្គភាពអព្យាក្រឹត្យប្រឆាំងអំពើពុករលួយ ។ រាជរដ្ឋាភិបាលនឹងជំរុញប្រសិទ្ធភាព តំលាភាព គណនេយ្យភាព នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេស តាមរយៈការពង្រឹងសវនកម្ម និងលទ្ធកម្មសាធារណៈ ។ រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្តន៍កំណែទំរង់អភិបាលកិច្ចតាមវិស័យ និងពហុវិស័យ ក្នុងក្របខ័ណ្ឌនៃផែនការសកម្មភាពស្តីពីអភិបាលកិច្ចដែលបានរៀបចំរួចហើយ តាមរយៈការចូលរួមយ៉ាងទូលំទូលាយពីបណ្តាក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាល សង្គមស៊ីវិល និងបណ្តាដៃគូអភិវឌ្ឍន៍ ។ ចាប់ពីនីតិកាលទី៣នេះទៅ រាជរដ្ឋាភិបាលនឹងណែនាំអោយក្រសួង និងស្ថាប័នពិនិត្យ និងផ្ទៀងផ្ទាត់កិច្ចសន្យាពាណិជ្ជកម្មនីមួយៗ និងកិច្ចព្រមព្រៀងសម្បទានលើធនធានធម្មជាតិ និងទ្រព្យសម្បត្តិរដ្ឋ ។

២៦៧- អាទិភាពរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នេះ រួមមាន ÷
- ពិនិត្យសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ហើយស្នើជូនរដ្ឋសភា និងព្រឹទ្ធសភា ដើម្បីអនុម័តអោយបានឆាប់រហ័ស ។
- ពង្រឹងសមត្ថភាពនៃបណ្តាស្ថាប័នពាក់ព័ន្ធ ដើម្បីគ្រប់គ្រងការអនុវត្តន៍ច្បាប់នេះអោយមានប្រសិទ្ធភាព ។
- កែលំអការផ្តល់សេវាសាធារណៈ ដោយទប់ស្កាត់ឱកាសប្រព្រឹត្តិអំពើពុករលួយ ជាពិសេសនៅក្នុងវិស័យពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងវិនិយោគ ។
- ជំរុញយន្តការត្រួតពិនិត្យនិងតុល្យភាព (Check and Balance Mechanism) តាមរយៈការ បង្កើត «ការិយាល័យប្រជាពលរដ្ឋ» ។
- បង្កើត និង ជំរុញអនុវត្តក្រមសីលធម៌ សំរាប់វិស័យសាធារណៈ ។
- ក្នុងការដោះស្រាយជាមួយវិស័យឯកជន រាជរដ្ឋាភិបាល នឹងលើកកំពស់តម្លាភាពក្នុងការដេញថ្លៃ និង ចុះកិច្ចសន្យាលទ្ធកម្មសាធារណៈ ។
- បន្តពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
- ចូលរួមពេញលេញ នៅក្នុងឆាកអន្តរជាតិ សំដៅប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដូចជា នៅក្នុង «ផែនការសកម្មភាពប្រឆាំងនឹងអំពើពុករលួយ សំរាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក» ។

## កំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

២៦៨- ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ រាជរដ្ឋាភិបាលគោរព និងលើកស្ទួយឯករាជ្យ និងអព្យាក្រឹតភាពនៃប្រព័ន្ធតុលាការ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ ក្នុងគោលដៅនេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវមានដំណើរការប្រព្រឹត្តិទៅក្នុងឯករាជ្យពិតប្រាកដ ។ រាជរដ្ឋាភិបាលខិតខំជំរុញការកែប្រែប្រព័ន្ធច្បាប់ និងតុលាការ ដើម្បីបង្កើនជំនឿទុកចិត្តរបស់សាធារណជន ។ រាជរដ្ឋាភិបាលបន្តសហការយ៉ាងជិតស្និទ្ធជាមួយនឹងដៃគូអភិវឌ្ឍន៍ទាំងអស់ សំដៅពង្រឹងនីតិរដ្ឋ បង្កើនយុត្តិធម៌សង្គម កាត់បន្ថយអំពើពុករលួយ ឈានទៅបង្កើតលក្ខខ័ណ្ឌពង្រឹងសន្តិភាព និងស្ថេរភាពសង្គម ។

២៦៩- អាទិភាពរបស់រាជរដ្ឋាភិបាលដូចដែលមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ មាន ÷

ទី១- បញ្ចប់ការតាក់តែង ដើម្បីដាក់ឆ្លងសភាជាតិ នូវបណ្តាច្បាប់ដែលមានលក្ខណៈជាមូលដ្ឋាន មានជា អាទិ៍ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ច្បាប់ស្តីពីការរៀបចំអង្គតុលាការ ក្រមនិងនីតិវិធីព្រហ្មទណ្ឌ ក្រមនិងនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃសារការី និងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់អាជ្ញាសាលា ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានមួយចំនួនទៀត ដើម្បីបំពេញបន្ថែមទៅលើក្របខ័ណ្ឌគតិយុត្តិបច្ចុប្បន្ន ដែលជាលក្ខខ័ណ្ឌចាំបាច់ ក្នុងក្របខ័ណ្ឌអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក ។

ទី២- រៀបចំឱ្យមានតុលាការឯកទេសមួយចំនួនតាមតម្រូវការចាំបាច់ មានជាអាទិ៍ តុលាការពាណិជ្ជកម្ម តុលាការអនីតិជន តុលាការការងារ និង តុលាការរដ្ឋបាល ។

ទី៣- រៀបចំបង្កើតឡើងតុលាការគំរូ ក្នុងទិសដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាយុត្តិធម៌ ។

ទី៤- ពង្រឹងសមត្ថភាព និងការទទួលខុសត្រូវរបស់ចៅក្រម តាមរយៈការបង្កើតលក្ខន្តិកៈចៅក្រម ការពង្រឹងវិន័យតាមក្រមសីលធម៌ និងតាមការបណ្តុះបណ្តាល ។

ទី៥- បង្កើតសាលាបណ្តុះបណ្តាលក្រឡាបញ្ជី និង សាលាបណ្តុះបណ្តាលអាជ្ញាសាលា និងសារការី ។

ទី៦- ធ្វើការបណ្តុះបណ្តាល និង លើកកំពស់ការគ្រប់គ្រង នគរបាលយុត្តិធម៌ ។

ទី៧- ផ្តល់ជំនួយគតិយុត្តិ (ដូចជាតាមរយៈការផ្តល់មេធាវី) ដល់ជនក្រីក្រ ដើម្បីស្វះស្វែងរកយុត្តិធម៌ និងការពារផលប្រយោជន៍របស់ពួកគេ ។

ទី៨- លើកកំពស់យន្តការដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជូនប្រជាពលរដ្ឋ ជាពិសេស ចំពោះបញ្ហាដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដី ។

២៧០- រាជរដ្ឋាភិបាលសំរេចបាននូវលទ្ធផលគួរអោយកត់សំគាល់ ក្នុងរយៈកាលកន្លងទៅ ។ យើងបានរៀបចំរួចនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពក្នុងការកែទំរង់ច្បាប់ និងប្រព័ន្ធតុលាការ ។ អាទិភាពរយៈពេលខ្លី និងមធ្យម ក្នុងការអនុវត្តន៍ផែនការសកម្មភាព ក៏ត្រូវបានរៀបចំរួច ដោយមានការចូលរួមយ៉ាងទូលំទូលាយពីភាគីដែលពាក់ព័ន្ធ ។ រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងមុតមាំថា ស្មារតីសហប្រតិបត្តិការរវាងក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធតុលាការ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល នឹងនាំអោយយើងសំរេចបានដោយជោគជ័យការអនុវត្តន៍កម្មវិធីកំណែទំរង់ច្បាប់ និងប្រព័ន្ធតុលាការ ។

**កំណែទំរង់រដ្ឋបាលស៊ីវិល**

២៧១- រាជរដ្ឋាភិបាលបានផ្តល់សារៈសំខាន់ទៅលើការបង្កើតប្រព័ន្ធរដ្ឋបាលសាធារណៈដែលមានអព្យាក្រឹតភាព តំលាភាព មានវិជ្ជាជីវៈ មានការឆ្លើយតប និងមានការទទួលខុសត្រូវ ដើម្បីសំរេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ កម្មវិធីជាតិស្តីពីកំណែទំរង់រដ្ឋបាលរបស់រាជរដ្ឋាភិបាលបានគូសរំលេចពីយុទ្ធសាស្ត្រ និងគោលនយោបាយដែលត្រូវអនុវត្ត ដើម្បីកែប្រែរដ្ឋបាលសាធារណៈអោយមានប្រសិទ្ធភាព ដើម្បីអនុវត្តកម្មវិធីនយោបាយ និងរបៀបវារៈសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ។ ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ កម្មវិធីជាតិស្តីពីកំណែទំរង់រដ្ឋបាលនឹងផ្តោតអាទិភាពទៅលើការងារដូចតទៅ÷

ទី១- សេវាដែលពាក់ព័ន្ធនឹងអធិបតេយ្យភាពរបស់ជាតិ ។

ទី២- សេវាដែលពាក់ព័ន្ធនឹងការវិនិយោគ ។

ទី៣- សេវាមូលដ្ឋាន ដូចជាសេវាអប់រំ និងសុខាភិបាល ។

ទី៤- សេវាដែលទាន់ទងនឹងការប្រមូលចំណូល និងការគ្រប់គ្រងចំណាយរបស់រដ្ឋ ។

២៧២- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលបានរៀបចំផែនការសកម្មភាពកំណែទំរង់រដ្ឋបាល ដោយផ្អែកលើការសិក្សាថ្មីៗកន្លងមក និងដោយបានធ្វើការពិភាក្សាជាមួយបណ្តាក្រសួងដែលពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ។ ផែនការនេះត្រូវបានលើកបង្ហាញជូនអ្នកផ្តល់ជំនួយ ក្នុងសិក្ខាសាលាជាតិនាខែសីហា ឆ្នាំ២០០៤ ។ សកម្មភាពជាក់ស្តែងដែលត្រូវអនុវត្តក្នុងក្របខ័ណ្ឌនៃកម្មវិធីជាតិស្តីពីកំណែទំរង់រដ្ឋបាល ត្រូវបានចងក្រងជាអាទិភាពចំនួន ៧ ដូចតទៅ ÷

ទី១- កែលំអការផ្តល់សេវា ។

ទី២- បង្កើនលាភការ ។

ទី៣- ការដាក់ពង្រាយមន្ត្រីរាជការឡើងវិញ ។

ទី៤- ពង្រឹងការគ្រប់គ្រង និងការត្រួតពិនិត្យធនធានមនុស្ស ។

ទី៥- អនុវត្តកម្មវិធីកន្សោមអាទិភាព ។

ទី៦- អភិវឌ្ឍសមត្ថភាព និងស្ថាប័ន ។

ទី៧- ជំរុញប្រព័ន្ធបច្ចេកវិទ្យាពត៌មាន និងទំនាក់ទំនង ។

**វិមជ្ឈការ និងវិសហមជ្ឈការ**

២៧៣- នៅក្នុងរាជរដ្ឋាភិបាល យើងកំពុងស្វែងរកក៏រិតសមស្របមួយស្តីពីតួនាទី និងភារកិច្ចរបស់បណ្តាថ្នាក់រដ្ឋបាលក្នុងក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ ។ សំរាប់រាជរដ្ឋាភិបាល បញ្ហាទាំងនេះបានចាក់ស្រេះគ្នាបន្ថែមទៀត ដោយព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រថ្មីៗរបស់កម្ពុជា ។ រាជរដ្ឋាភិបាលបានកំណត់ច្បាស់ថាការអនុវត្តន៍វិមជ្ឈការនៅថ្នាក់ឃុំ- សង្កាត់មិនគ្រាន់តែដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋានប៉ុណ្ណោះ ទេ ប៉ុន្តែវាអាចពង្រឹង និងលើកកំពស់គុណភាពសេវាសាធារណៈ និងសំរាប់ជំរុញកិច្ចអភិវឌ្ឍន៍ដោយមានការចូលរួមនៅថ្នាក់មូលដ្ឋាន ។ ដើម្បីពង្រឹងអភិបាលកិច្ចមូលដ្ឋាន អាទិភាពចំបង គឺការកសាងសមត្ថភាពគ្រប់គ្រងនៅថ្នាក់មូលដ្ឋាន និងការផ្តល់ប្រភពធនធានហិរញ្ញវត្ថុសមស្រប ព្រមទាំងការលើកស្ទួយវប្បធម៌ចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងកិច្ចការទាំងអស់នេះ ។ ការងារអាទិភាពមួយទៀតគឺការអនុវត្តន៍វិមជ្ឈការត្រូវអនុវត្តទន្ទឹមគ្នានឹងវិសហមជ្ឈការ និងការកសាងសមត្ថភាពថ្នាក់ខេត្ត- ក្រុង និងស្រុក- ខ័ណ្ឌ ដើម្បីធានាអោយមានភាពរលូនក្នុងការជួយទ្រទ្រង់ និងបំពេញអោយគ្នាទៅវិញទៅមកនៅថ្នាក់មូលដ្ឋាន ។

២៧៤- ដើម្បីជំរុញដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ ការងារជាអាទិភាពរបស់រាជរដ្ឋាភិបាលមានដូចខាង ក្រោម ÷

- រៀបចំច្បាប់អង្គការ (Organic Law) ដើម្បីកំណត់តួនាទីរបស់រចនាសម្ព័ន្ធថ្នាក់ខេត្តនិងស្រុក ដើម្បីពន្លឿនដំណើរការនៃការធ្វើប្រតិភូកម្មអំណាចពីក្រសួង ទៅអោយថ្នាក់ខេត្ត- ក្រុង ។
- រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ។ ក្រុមការងារអន្តរក្រសួងកំពុងដំណើរការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសំរាប់អនុវត្តយុទ្ធសាស្ត្រនេះ ។

- ធានាការផ្តល់មូលនិធិអោយបានទាន់ពេលវេលា ព្រមទាំងពិនិត្យលទ្ធភាពដើម្បីអនុញ្ញាតអោយឃុំអាចប្រមូលធនធានផ្ទាល់ តាមរយៈវិធានការដូចតទៅ ÷ ១-ផ្ទេរមូលនិធិសំរាប់ថវិកាឃុំ ។ ២-ពិនិត្យ និងកែសំរួលឡើងវិញក្នុងករណីចាំបាច់ នូវលិខិតបទដ្ឋានបច្ចុប្បន្ន ដែលពាក់ព័ន្ធនឹងប្រព័ន្ធហិរញ្ញវត្ថុឃុំ ការផ្តល់លទ្ធភាពអោយឃុំកៀងគរប្រភពចំណូលដោយខ្លួនឯង ការចូលរួមរបស់មូលដ្ឋាន និងការបែងចែកចំណូលពន្ធសំរាប់ថវិកាឃុំ ។ ៣-អនុវត្តសាកល្បងប្រព័ន្ធគណនេយ្យវិមជ្ឈការនៅថ្នាក់ឃុំ នៅរតនាគារខេត្តចំនួន ២ ។ ៤-ពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ- សង្កាត់ ។
- ពង្រឹងទំនាក់ទំនង និងកិច្ចសំរបសំរួលរវាងរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ និងរវាងអ្នកផ្តល់ជំនួយទាំងអស់ ដើម្បីសំរេចនូវយុទ្ធសាស្ត្រ និងសកម្មភាពដើម្បីអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល និងដើម្បីលើកកំពស់ប្រសិទ្ធភាពជំនួយ ។

### កំណែទំរង់កងកំលាំងប្រដាប់អាវុធ

២៧៥- ដើម្បីសម្រេចកិច្ចការនេះ រាជរដ្ឋាភិបាលបន្តអនុវត្តគោលនយោបាយដែលបានលើកឡើងក្នុងសៀវភៅ«ស» របស់កងយោធពលខេមរភូមិន្ទ រួមបញ្ចូលទាំងការចែកដីសម្បទានដើម្បីគោលដៅសង្គមកិច្ចដល់យោធិនរំសាយ ដែលខ្វះខាតដី និងមានបំណងសុំដីសំរាប់សាងសង់លំនៅដ្ឋានឬ/និងធ្វើកសិកម្មជាលក្ខណៈគ្រួសារតាមតំរូវការសមស្រប ស្របតាមស្មារតីនៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ។ ទន្ទឹម នឹងនោះ រាជរដ្ឋាភិបាលនឹងបន្តកំណែទំរង់ ដើម្បីកសាង និងពង្រឹងកងកម្លាំងនគរបាលជាតិ អោយទៅជាកងកម្លាំងមានវិជ្ជាជីវៈជំនាញ និងមានបច្ចេកវិទ្យាទំនើប មានស្មារតីទទួលខុសត្រូវ គោរពប្រតិបត្តិច្បាប់ម៉ឺងម៉ាត់ គោរពសិទ្ធិមនុស្ស បំរើប្រជាជនដោយស្មោះត្រង់ មានសមត្ថភាព សំរេចបានល្អនូវភារកិច្ចគ្រប់គ្រង និងថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការពារអាយុជីវិត និងទ្រព្យសម្បត្តិរបស់ប្រជាជន ព្រមទាំងរក្សាបាននូវភាពសុខុដុមរមនានៅក្នុងសង្គម ។

## ៤.២- បរិស្ថានគ្របដណ្តប់សំរាប់ការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ

២៧៦- សមាសធាតុទី២នៃយុទ្ធសាស្ត្រចតុកោណ បង្ហាញពីកត្តាខាងផ្នែកបរិស្ថានដែលជះឥទ្ធិពលដល់ការអនុវត្តន៍យុទ្ធសាស្ត្រទាំងមូល ។ កត្តាខាងផ្នែកបរិស្ថានទាំងនោះមាន ÷ ទី១- សុខសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម ។ ទី២- ភាពជាដៃគូសំរាប់កិច្ចអភិវឌ្ឍន៍ ។ ទី៣- បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលអនុគ្រោះ ។ និងទី៤- សមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក ។

| **បរិស្ថានសំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ** |
| --- |
| - សន្តិភាព ស្ថិរភាពនយោបាយនិងសណ្តាប់ធ្នាប់សង្គម |
| - ភាពជាដៃគូសំរាប់កិច្ចអភិវឌ្ឍន៍ |
| - បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអនុគ្រោះ |
| - សមាហរណកម្មទៅក្នុងតំបន់ និងពិភពលោក |

## សុខសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម

២៧៧- ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ សន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម គឺជាលក្ខខ័ណ្ឌមិនអាចខ្វះបាន សំរាប់ការពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងការកាត់បន្ថយភាពក្រីក្រ ។ ដូច្នេះ រាជរដ្ឋាភិបាលនឹងបន្តការងាររបស់ខ្លួន ក្នុងគោលដៅបន្តពង្រឹងថែមទៀតនូវសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម ជូនដល់ប្រជាពលរដ្ឋ ដើម្បីឆ្លុះបញ្ចាំងពីការបោះជំហានរបស់កម្ពុជា ឆ្ពោះទៅរកការអភិវឌ្ឍន៍ និងភាពកាន់តែចំរើនរុងរឿង ដោយប្តេជ្ញាដោះស្រាយអោយអស់នូវផលវិបាកនៃសង្គ្រាម របបប្រល័យពូជសាសន៍ និងជំលោះផ្ទៃក្នុង ដែលបានបំផ្លិចបំផ្លាញនិងញាំញីកម្ពុជា ក្នុងរយៈពេលជិតបីទសវត្សរ៍កន្លងទៅនេះ ។

២៧៨- ក្នុងន័យនេះ សុខសន្តិភាព ស្ថិរភាពនយោបាយ និង សណ្តាប់ធ្នាប់សង្គម គឺជាមូលដ្ឋានគ្រឹះនៃការងារកសាងនិងកំណែទំរង់រដ្ឋ ។ ដូច្នេះ ភារកិច្ចចំបងរបស់រាជរដ្ឋាភិបាល គឺត្រូវពង្រឹងកោសិកាសន្តិភាពអោយភ្ជាប់ គ្នាល្អដោយប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ ។ ការពង្រឹងសុខសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គមនឹងបង្កើតនូវ «រូបភាពជាក់ស្តែង» មួយរបស់កម្ពុជា ក្នុងការបង្កើនជំនឿទុកចិត្តពីសំណាក់វិនិយោគិន និងអ្នកទេសចរណ៍ ក៏ដូចជាក្នុងការបង្កលក្ខណៈអោយប្រជាពលរដ្ឋអាចរស់នៅប្រកបរបរអាជីវកម្មតាមធម្មតា និងចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចយ៉ាងសកម្មតាមសមត្ថភាពរៀងៗ ខ្លួន ។

## ភាពជាដៃគូនៅក្នុងការអភិវឌ្ឍន៍

២៧៩- ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ការពង្រឹងភាពជាដៃគូជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ក្នុងនោះ រួមមានភាពជាដៃគូជាមួយនឹងសហគមន៍អ្នកផ្តល់ជំនួយ វិស័យឯកជន និងសង្គមស៊ីវិល គឺជាអាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាល ។ គោលការណ៍ជាមូលដ្ឋានសំរាប់ពង្រឹងភាពជាដៃគូជាមួយសហគមន៍អ្នកផ្តល់ជំនួយ ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋាននៃសេចក្តីសំរេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ គោលការណ៍របស់គណៈកម្មការជំនួយដើម្បីអភិវឌ្ឍន៍ (DAC) នៃអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (OECD) ក៏ដូចជាការផ្តួចផ្តើមគំនិតនានារបស់ធនាគារពិភពលោក និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ។ រាជរដ្ឋាភិបាលនឹងបន្តពង្រឹង «វេទិការាជរដ្ឋាភិបាល- ផ្នែកឯកជន» អោយក្លាយទៅជាយន្តការនៃភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន ប្រកបដោយប្រសិទ្ធភាពកាន់តែខ្ពស់ជាងមុន ។ រាជរដ្ឋាភិបាលបន្តពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋ និងសង្គមស៊ីវិល ដោយឈរលើគោលការណ៍នីតិរដ្ឋ ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ សិទ្ធិសេរីភាព សណ្តាប់ធ្នាប់សង្គម និងការគោរពច្បាប់ ។ រាជរដ្ឋាភិបាលបានចាត់ទុកថា សង្គមស៊ីវិលត្រូវមានតួនាទីជាដៃគូមួយដ៏មានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល ក្នុងការកសាងប្រទេសជាតិ ។ ក្នុងទស្សនៈនេះ រាជរដ្ឋាភិបាលលើកទឹកចិត្តតាមគ្រប់រូបភាពចំពោះអង្គការក្រៅរដ្ឋាភិបាល និងសមាគមស្របច្បាប់នានា ដែលកំពុងធ្វើសកម្មភាពបំរើផលប្រយោជន៍

ប្រជាពលរដ្ឋនៅទូទាំងប្រទេស ។ រាជរដ្ឋាភិបាលស្វាគមន៍ការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល ក្នុងដំណើរការស្តារ និងអភិវឌ្ឍន៍សេដ្ឋកិច្ច- សង្គមកិច្ច និងការគាំពារលើកស្ទួយការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញការបង្កើត និងអនុវត្តច្បាប់ស្តីពីអង្គការក្រៅរដ្ឋាភិបាលនិងសមាគម ដោយមានការពិគ្រោះយោបល់ជាមួយនឹងស្ថាប័ននិងអង្គការពាក់ព័ន្ធ ។

២៨០- នៅក្នុងនីតិកាលទី៣ នេះ បញ្ហាប្រឈមសំខាន់របស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ គឺការកំណត់អោយបាននូវអភិក្រមសំរាប់អនុវត្ត ដែលអាចបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ជំនួយ ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ និងដើម្បីឈានទៅសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលស្នើអោយដៃគូអភិវឌ្ឍន៍ទាំងអស់តំរឹមកម្មវិធីផ្តល់ជំនួយរបស់ខ្លួន ជាមួយនឹងបណ្តាអាទិភាពអភិវឌ្ឍន៍របស់កម្ពុជា និងធ្វើសុខដុមនីយកម្មនៃការអនុវត្តន៍ដោយផ្អែកតាមបណ្តាគោលការណ៍ និងការណែនាំទាំងឡាយដែលបានឯកភាពនៅក្នុងវេទិកាអន្តរជាតិ ពិសេសវេទិការបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (OECD/DAC) ។ រាជរដ្ឋាភិបាលយល់ឃើញថាការប្រើប្រាស់យុទ្ធសាស្ត្រជាតិសំរាប់រៀបចំផែនការ និងគ្រប់គ្រងជំនួយ និងការបង្កើនសុខដុមនីយកម្មក្នុងការអនុវត្តន៍របស់អ្នកផ្តល់ជំនួយ មិនត្រឹមតែអាចពង្រឹងភាពជាម្ចាស់ក្នុងកិច្ចអភិវឌ្ឍន៍របស់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែ វាក៏ជាមធ្យោបាយសំរាប់បង្កើនការងារសំរបសំរួល និងប្រសិទ្ធភាពនៃជំនួយផងដែរ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏ជំរុញអោយដៃគូអភិវឌ្ឍន៍ រៀបចំការផ្តល់ជំនួយស្របតាមអភិក្រមតាមកម្មវិធីឬទូទាំងវិស័យ (Program/Sector Based Approach) ដែលមិនត្រឹមតែអាចកាត់បន្ថយចំនួនគំរោងទោល (Stand-Alone Project) ដែលជាអំរែកយ៉ាងធ្ងន់មកលើសមត្ថភាពខាងស្ថាប័នប៉ុណ្ណោះទេ ប៉ុន្តែវាអាចជួយតំរង់ការប្រើប្រាស់ជំនួយអោយកាន់តែចំគោលដៅជាងមុន ។

២៨១- យន្តការនៃក្រុមការងារត្រូវបានបង្កើតឡើងក្នុងកិច្ចប្រជុំពិគ្រោះយោបល់ឆ្នាំ១៩៩៩ ដើម្បីតាមដានការអនុវត្តន៍កម្មវិធីកំណែទំរង់របស់រាជរដ្ឋាភិបាល ។ កន្លងមក សមាជិករបស់ក្រុមការងារទាំងនេះភាគច្រើនមានតែតំណាងរបស់អ្នកផ្តល់ជំនួយ ។ ក្រុមការងារខ្លះបានដំណើរការដោយអន្លើៗ (Ad-hoc) ដោយគ្មានលក្ខខ័ណ្ឌការងារច្បាស់លាស់ ។ នៅក្នុងឆ្នាំកន្លងមក ក្នុងនាមរាជរដ្ឋាភិបាល ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានរិះរកវិធីនិងមធ្យោបាយដើម្បីបង្កើនប្រសិទ្ធភាពនៃក្រុមការងារទាំងនេះ និងដើម្បីធានាអោយមានសង្គតិភាព ជាងមុនក្នុងរាល់សកម្មភាពប្រតិបត្តិការរបស់ជំនួយ ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានលើកស្នើជូនដៃគូ អភិវឌ្ឍន៍អំពីគោលការណ៍ជាមូលដ្ឋានសំខាន់ៗដើម្បីរៀបចំឡើងវិញនូវរចនាសម្ព័ន្ធនៃក្រុមការងារទាំងនេះ កាលពីខែតុលា ឆ្នាំ២០០៣ ។ គោលការណ៍ទាំងនេះបានទទួលការឯកភាពពីរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នៅក្នុងកិច្ចប្រជុំត្រៀមកិច្ចប្រជុំពិគ្រោះយោបល់ កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ ។

២៨២- រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បានឯកភាពគ្នាបង្កើតក្រុមការងារចំរុះចំនួន១៧ នៅតាមវិស័យមួយចំនួន ។ ក្រុមការងារទាំងនេះត្រូវបានបង្កើតឡើងដោយផ្អែកលើគោលការណ៍សំខាន់ៗដូចតទៅ ÷

១- ដើម្បីពង្រឹងភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល ក្រុមការងារបច្ចេកទេសចំរុះ (Joint Technical Working Group) នឹងត្រូវដឹកនាំដោយក្រសួង ឬស្ថាប័នទទួលខុសត្រូវរបស់ រាជរដ្ឋាភិបាល និងមានសមាជិកចូលរួមពីបណ្តាក្រសួង និងពីប្រទេស ឬភ្នាក់ងារផ្តល់ជំនួយនានា ។ ការចាត់តាំងប្រធានក្រុមការងារជាសិទ្ធិសំរេចរបស់រដ្ឋមន្ត្រីនៃក្រសួង- ស្ថាប័ន ដែលត្រូវដឹកនាំក្រុមការងារនោះ ។ យោងតាមបទពិសោធន៍របស់ក្រុមការងារខ្លះៗកន្លងមក ប្រធានក្រុមការងារដែលត្រូវចាត់តាំងថ្មីនេះ ត្រូវតែមានការប្តេជ្ញា និងមានឆន្ទៈនយោបាយមោះមុតបំផុត ហើយហ៊ានចំណាយពេលវេលារបស់ខ្លួនយ៉ាងច្រើន ដើម្បីដឹកនាំកិច្ចការរបស់ក្រុមឆ្ពោះទៅរកវឌ្ឍនភាព ។ ទន្ទឹមនេះដៃគូអភិវឌ្ឍន៍ចាត់តាំងអ្នកសំរបសំរួល (Donor Coordinator) ដើម្បីធានានូវភាពរលូនក្នុងការ ពិភាក្សា និងឯកភាពមតិផ្ទៃក្នុងរបស់ខ្លួន និងចាត់តាំងអ្នកសំរបសំរួលបំរុង (Alternate Coordinator) ដើម្បីធានាចីរភាពនៃកិច្ចដំណើរការរបស់ក្រុមការងារនីមួយៗ ។

២- ក្រុមការងារនីមួយៗត្រូវមានលក្ខខ័ណ្ឌយោងជាក់លាក់ (Terms of Reference-TORs) ដែលត្រូវកំណត់ច្បាស់លាស់អំពីតួនាទីនិងភារកិច្ចដែលត្រូវបំពេញ ។ លក្ខខ័ណ្ឌយោងជាមូលដ្ឋានរបស់ក្រុមការងារនីមួយៗ រួមមានដូចខាងក្រោម ÷

ក- រួមគ្នារៀបចំយុទ្ធសាស្រ្ត ឬ គោលនយោបាយលំអិតសំរាប់វិស័យដែលខ្លួនមានភារកិច្ចទទួលខុសត្រូវ អោយមានតំលាភាព និងសង្គតិភាពជាមួយនឹងយុទ្ធសាស្ត្រចតុកោណ ប្រសិនបើយុទ្ធសាស្រ្ត ឬគោលនយោបាយសំរាប់វិស័យនោះ មិនទាន់ត្រូវបានរៀបចំនៅឡើយ ។ ចំពោះក្រុមការងារណាដែលបានរៀបចំយុទ្ធសាស្រ្ត ឬ គោលនយោបាយលំអិតសំរាប់វិស័យរួចហើយ ក្រុមការងារក៏ត្រូវពិនិត្យ និងកែសំរួលយុទ្ធសាស្រ្តនោះឡើងវិញ ប្រសិនបើចាំបាច់ ។

ខ- ក្រោយពេលយុទ្ធសាស្រ្ត ឬគោលនយោបាយលំអិតត្រូវបានរៀបចំរួច ក្រុមការងារនីមួយៗ ត្រូវរៀបចំផែនការសកម្មភាព និងកំណត់អាទិភាព (Action Plan and Priorities) ព្រមទាំងទំរង់ការ (Modality) សំរាប់គាំទ្រការអនុវត្តន៍ផែនការសកម្មភាព និងអាទិភាពទាំងនោះ ។ ផែនការសកម្មភាពដែលបានរៀបចំរួមគ្នានេះ នឹងត្រូវបានចាត់ទុកជាឯកសាររួមរវាងរាជរដ្ឋាភិបាលនិងសហគមន៍អ្នកផ្តល់ជំនួយ សំរាប់តាមដាន និងត្រួតពិនិត្យអំពីវឌ្ឍនភាពការងាររបស់ក្រុមនីមួយៗ ។

គ- ក្រុមការងារនីមួយៗត្រូវទទួលខុសត្រូវរួមគ្នា ក្នុងការកៀងគរប្រភពធនធានដែលត្រូវការ ចាំបាច់សំរាប់អនុវត្តផែនការសកម្មភាព និងអាទិភាពទាំងនោះ ។ ប្រសិនបើធនធានហិរញ្ញវត្ថុមិនអាចធានាបានគ្រប់គ្រាន់ សំរាប់អនុវត្តផែនការសកម្មភាពនោះទេ ទាំងភាគីរាជរដ្ឋាភិបាល ទាំងភាគីអ្នកផ្តល់ជំនួយ ត្រូវរួមគ្នារៀបចំអាទិភាពសកម្មភាពឡើងវិញអោយស្របតាមធនធានដែលមាន ។

ឃ- ក្រុមការងារនីមួយៗត្រូវរួមគ្នាត្រួតពិនិត្យ និងតាមដានវឌ្ឍនភាព (Joint Monitoring of Progress) ដោយធៀបទៅនឹងគោលដៅដែលបានដាក់ចេញ ដើម្បីលើកកំពស់ប្រសិទ្ធភាពនៃ

ការប្រើប្រាស់ធនធានទាំងនោះ សំដៅអនុវត្តអោយបានសំរេចនូវគោលដៅជាយុទ្ធសាស្រ្ត ដែលមានចែងក្នុងយុទ្ធសាស្រ្តចតុកោណ និងដើម្បីឈានទៅអនុវត្តអោយបានសំរេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (Millennium Development Goals-MDGs)។

២៨៣- ទន្ទឹមនឹងនេះ ដើម្បីធានាអោយមានការសំរបសំរួលរវាងក្រុមការងារបច្ចេកទេសចំរុះទាំងនេះ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បានឯកភាពគ្នាបង្កើត«គណៈកម្មាធិការសំរបសំរួលរវាងរាជរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយ» (Government-Donor Coordination Committee-GDCC) ដែលមានភារកិច្ចផ្តល់ការណែនាំក្នុងកំរិតគោលនយោបាយ (Policy Guidance) កំណត់អាទិភាព និងស្នើវិធានការសំរាប់ដោះស្រាយបញ្ហានានាដែលក្រុមការងារបច្ចេកទេសបានលើកឡើង ។ គណៈកម្មាធិការនេះត្រូវជួបប្រជុំគ្នាជាទៀងទាត់ក្នុងរយៈពេល៣ខែម្តង ។ ក្នុងស្មារតីនេះ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានចាត់តាំងឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អោយធ្វើជាប្រធាននៃគណៈកម្មាធិការនេះ ។ សមាជិកនៃគណៈកម្មាធិការនេះរួមមានប្រធានក្រសួង និងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងឯកអគ្គរដ្ឋទូត ឯកអគ្គរាជទូត តំណាងប្រទេស និងទីភ្នាក់ងារផ្តល់ជំនួយ ។ លើសពីនេះ «គណៈកម្មាធិការសំរបសំរួលរវាងរាជរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយ» ត្រូវមានលេខាធិការដ្ឋានមួយសំរាប់ជួយការងាររបស់ខ្លួន ។ លេខាធិការដ្ឋាននេះមានទីតាំងនៅគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានឯកឧត្តមអគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ជាអគ្គលេខាធិការ ។ លេខាធិការដ្ឋាននេះមានភារកិច្ចទាក់ទងជាមួយក្រុមការងារបច្ចេកទេស និងប្រមូលពត៌មានថ្មីៗស្តីពីវឌ្ឍនភាព ព្រមទាំងបញ្ហានានាដែលក្រុមការងារបច្ចេកទេសបានជួបប្រទះក្នុងពេលអនុវត្តភារកិច្ចរបស់ខ្លួន ។ លេខាធិការដ្ឋានត្រូវរៀបចំរបាយការណ៍ប្រចាំត្រីមាសស្តីពីវឌ្ឍនភាព និងបញ្ហាដែលបានជួបប្រទះ ព្រមទាំងលើកឡើងនូវជំរើសដើម្បីដោះស្រាយបញ្ហាទាំងនោះសំរាប់ស្នើជូន «គណៈកម្មាធិការសំរបសំរួល» ពិនិត្យនិងសំរេច ។ ក្នុងករណីដែល «គណៈកម្មាធិការសំរបសំរួល» មិនអាចសំរេចឬដោះស្រាយបាន ត្រូវធ្វើរបាយការណ៍គ្រង់ជូនមកប្រមុខរាជរដ្ឋាភិបាលដើម្បីសំរេចនិង/ឬចង្អុលទិសអោយអនុវត្តការងារបន្ត ។

២៨៤- នៅក្នុងកិច្ចប្រជុំត្រៀម នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ សម្តេច នាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក៏បានកំណត់ភារកិច្ចបន្ទាន់មួយចំនួន ដែលក្រុមការងារនិមួយៗត្រូវអនុវត្តចាប់ពីពេលនេះរហូតដល់កិច្ចប្រជុំពិគ្រោះយោបល់ ដែលគ្រោងនាដើមខែធ្នូ ឆ្នាំ២០០៤ ។

ទី១- ភាគីទាំងសងខាងត្រូវសហការគ្នាជំរុញការរៀបចំបញ្ចប់ជាបន្ទាន់អំពីសមាជិកភាព និងលក្ខខ័ណ្ឌយោងសំរាប់ក្រុមការងារបច្ចេកទេសចំរុះនិមួយៗ ។

ទី២- ក្រុមការងារនីមួយៗត្រូវវាយតំលៃអំពីវឌ្ឍនភាពនៃការអនុវត្តន៍លក្ខខ័ណ្ឌវិនិច្ឆ័យទាំង៩ ដែលរាជរដ្ឋាភិបាលបានប្តេជ្ញាអនុវត្ត កាលពីកិច្ចប្រជុំពិគ្រោះយោបល់ នាខែមិថុនា ឆ្នាំ ២០០២ កន្លងមក ព្រមទាំងបញ្ហាប្រឈម និងបញ្ហាសេសសល់ដែលត្រូវអនុវត្តបន្ត ។ របាយការណ៍របស់ក្រុមការងារ

ទីមួយៗ នឹងត្រូវច្របាច់បញ្ចូលគ្នាជាឯកសារតែមួយ ដែលត្រូវលើកបង្ហាញក្នុងកិច្ចប្រជុំពិគ្រោះយោបល់ នាខែធ្នូ ឆ្នាំ២០០៤ ខាងមុខនេះ ។

ទី៣- ក្រុមការងារបច្ចេកទេសនីមួយៗត្រូវរៀបចំផែនការសកម្មភាពរបស់ខ្លួន ព្រមទាំងលក្ខខ័ណ្ឌវិនិច្ឆ័យ (Benchmarks) សំរាប់ពិនិត្យនិងអនុម័ត នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ដែលគ្រោងនាខែធ្នូ ឆ្នាំ ២០០៤ ខាងមុខនេះ ។

២៨៥- លើបញ្ហាសុខដុមនីយកម្ម និងការតំរឹមសកម្មភាពផ្តល់ជំនួយសំដៅលើកកំពស់ប្រសិទ្ធភាពជំនួយ កម្ពុជាបានសំរេចវឌ្ឍនភាពសំខាន់ៗមួយចំនួនក្នុងឆ្នាំកន្លងមក ទាំងលើឆាកអន្តរជាតិ និងនៅក្នុងប្រទេស ។ នៅលើវេទិកាអន្តរជាតិ ក្រុមដឹកនាំការងារស្តីអំពីសុខដុមនីយកម្មរបស់ OECD/DAC បានចេញផ្សាយកំរងឯកសារស្តីពីការប្រតិបត្តិល្អរបស់អ្នកផ្តល់ជំនួយ (Good Donor Practices Papers) ដែលឯកសារនេះត្រូវបានអនុម័តយល់ព្រមនៅក្នុងវេទិកាជាន់ខ្ពស់ (High Level Forum) ដោយមានការចូលរួមពីតំណាងប្រទេស និងស្ថាប័នផ្តល់ជំនួយពហុភាគីនិងទ្វេភាគី តំណាងមកពី IMF និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងពីបណ្តាប្រទេសជាដៃគូដទៃទៀត នៅក្រុងរ៉ូម ប្រទេសអ៊ីតាលី កាលពីខែកុម្ភៈ ឆ្នាំ២០០៣ ។ វេទិកាជាន់ខ្ពស់នេះបានថ្លែងសេចក្តីប្រកាសមួយ ដែលហៅថាសេចក្តីប្រកាសក្រុងរ៉ូមស្តីពីសុខដុមនីយកម្ម (Rome Declaration on Harmonisation) ដែលក្នុងនោះប្រទេសជាដៃគូអភិវឌ្ឍន៍ទាំងអស់បានសន្យាគាំទ្រនូវ កិច្ចប្រឹងប្រែងធ្វើសុខដុមនីយកម្មដើម្បីលើកកំពស់ប្រសិទ្ធភាពការផ្តល់ជំនួយ ។ បន្ទាប់ពីវេទិកាជាន់ខ្ពស់ ក្រុងរ៉ូម OECD/DAC បានបន្តតាមដាននូវវឌ្ឍនភាពក្នុងការអនុវត្តន៍ការប្តេជ្ញាចិត្តដែលបានធ្វើនៅក្នុងសេចក្តីប្រកាសទីក្រុងរ៉ូម ។ OECD/DAC បានធ្វើអង្កេតមួយស្តីពីស្ថានភាពនៃការធ្វើសុខដុមនីយកម្ម និងការតំរែតំរង់ជំនួយនៅក្នុងប្រទេសជាដៃគូ ១៤ ដែលរួមមានប្រទេសកម្ពុជាផងដែរ ។ ឯកសារអង្កេតមានសំនួរដែលចែកជាបីផ្នែកធំៗ ។ បន្ទាប់ពីបានពិភាក្សាយ៉ាងទូលំទូលាយក្នុងរង្វង់រាជរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងរវាងរាជរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយ រាជរដ្ឋាភិបាលមិនត្រឹមតែបានបញ្ចប់ការឆ្លើយសំនួរអង្កេតបានទាន់ពេលវេលាដែលកំណត់ប៉ុណ្ណោះទេ ថែមទាំងជាប្រទេសទីមួយដែលបានផ្ញើអង្កេតនោះ ត្រលប់ទៅ OECD/DAC វិញទៀតផង ។

២៨៦- ដោយមានកិច្ចសហប្រតិបត្តិការ និងការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍នានារបស់កម្ពុជា រាជរដ្ឋាភិបាលបានរៀបចំផែនការសកម្មភាព សំរាប់អនុវត្តការប្តេជ្ញាចិត្ត ដែលបានចែងនៅក្នុងសេចក្តីប្រកាសក្រុងរ៉ូម ។ ផែនការសកម្មភាពនេះនឹងបង្ហាញជូននៅក្នុងរបាយការណ៍របស់រាជរដ្ឋាភិបាល ស្តីពី «ការកសាងភាពជាដៃគូដើម្បីអភិវឌ្ឍន៍- បច្ចុប្បន្នភាព» ។ ក្នុងការអនុវត្តន៍ផែនការសកម្មភាពនេះ រាជរដ្ឋាភិបាលទទួលស្គាល់នូវបញ្ហាប្រឈមជាច្រើន ។ បញ្ហាប្រឈមដ៏ធ្ងន់ធ្ងរមួយគឺ គម្លាតរវាងគោលនយោបាយសុខដុមនីយកម្មដែលបានព្រមព្រៀងនៅក្នុងកំរិតអន្តរជាតិ និងការតំរឹម និងការផ្លាស់ប្តូរក្នុងកិច្ចប្រតិបត្តិការ និងឥរិយាបថរបស់អ្នកផ្តល់ជំនួយដែលកំពុងប្រតិបត្តិការនៅកម្ពុជា ។ ស្ថាប័នកណ្តាលនៃប្រទេសផ្តល់ជំនួយមួយចំនួនបានរៀបចំរួចហើយនូវផែនការសកម្មភាពដើម្បីធ្វើសុខដុមនីយកម្មនៃការផ្តល់ជំនួយរបស់ពួកគេ ស្របតាម

គោលការណ៍របស់ OECD/DAC ។ តាងនាមអោយរាជរដ្ឋាភិបាល ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានស្នើអោយក្រុមដឹកនាំការងាររបស់OECD/DAC ចែករំលែកមិនត្រឹមតែផែនការសកម្មភាពជាមួយប្រទេសជាដៃគូរបស់ខ្លួនប៉ុណ្ណោះទេ ថែមទាំងស្នើសុំអោយធ្វើការតាមដានយ៉ាងម៉ត់ចត់ និងរាយការណ៍ជាទៀងទាត់ដល់ប្រទេសជាដៃគូថែមទៀតផង ពិសេសលើបញ្ហាដូចជា÷

- កំរិតនៃការចែកផ្សព្វផ្សាយនូវផែនការសកម្មភាព ដែលបានរៀបចំឡើងដោយស្ថាប័នកណ្តាលរបស់ប្រទេសផ្តល់ជំនួយ និងទីស្នាក់ការកណ្តាលនៃស្ថាប័នផ្តល់ជំនួយពហុភាគី ជាមួយនឹងការិយាល័យរបស់ខ្លួននៅតាមប្រទេសទទួលជំនួយ ។
- ការណែនាំច្បាស់លាស់ស្តីពីការអនុវត្តន៍ផែនការសកម្មភាព ពីស្ថាប័នកណ្តាលរបស់ប្រទេសផ្តល់ ជំនួយ និងស្ថាប័នផ្តល់ជំនួយពហុភាគី មកដល់ការិយាល័យរបស់ខ្លួននៅតាមប្រទេសទទួលជំនួយ ។
- ប្រតិភូកម្មអំណាចក្នុងការអនុវត្តន៍ផែនការសកម្មភាព ពីស្ថាប័នកណ្តាលរបស់ប្រទេសឬស្ថាប័នផ្តល់ជំនួយពហុភាគី មកការិយាល័យរបស់ខ្លួននៅតាមប្រទេសទទួលជំនួយ ។

២៨៧- នៅថ្នាក់ជាតិ ក្រុមការងារដើម្បីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ដែលត្រូវបានបង្កើតតាមសំណើរបស់រាជរដ្ឋាភិបាល កាលពីកិច្ចប្រជុំពិគ្រោះយោបល់លើកទី ៦ ខែមិថុនា ឆ្នាំ ២០០២ បានប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួន ដោយផ្តល់ការគាំទ្រដល់ការងាររបស់ OECD/DAC ផង និងពិនិត្យមើលពីបញ្ហាសុខដុមនីយកម្ម ក្នុងបរិការនៃប្រទេសកម្ពុជាផង ។ ក្រុមការងារដើម្បីភាពជាដៃគូ បានធ្វើការសិក្សា បី ដើម្បីប្រមូលពតិមានចាំបាច់នានា សំរាប់ស្វែងរកដំណោះស្រាយលើបញ្ហាសុខដុមនីយកម្មនៅកម្ពុជា ។ ការសិក្សាទាំងនេះ ផ្តោតជាសំខាន់លើបញ្ហាបី គឺ ÷ ១- ការប្រតិបត្តិស្តីពីការកសាងសមត្ថភាពរបស់ដៃគូអភិវឌ្ឍន៍របស់កម្ពុជា ។ ២- ការអនុវត្តន៍ និងបទពិសោធន៍ដែលទទួលបានក្នុងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ និង ៣- ការរៀបចំគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ ការសិក្សាទី១និងទី២ត្រូវបានបញ្ចប់ជាស្ថាពរ ។ ចំណែកសេចក្តីព្រាងការសិក្សាទីបី ក៏ត្រូវបានបញ្ចប់ផងដែរ ។ ការសិក្សាអំពីការកសាងសមត្ថភាពកំពុងត្រូវបានពិភាក្សារវាងក្រុមប្រឹក្សាកំណែទំរង់ រដ្ឋបាល និងដៃគូអភិវឌ្ឍន៍របស់កម្ពុជា ដើម្បីឯកភាពគ្នាក្នុងការផ្តល់អនុសាសន៍សំរាប់រៀបចំផែនការ សកម្មភាពដើម្បីអនុវត្តអនុសាសន៍ទាំងនោះ ។

២៨៨- រាជរដ្ឋាភិបាលមានជំនឿថា សង្គមស៊ីវិលមានតួនាទីយ៉ាងសំខាន់ ក្នុងការតាមដានពីវឌ្ឍនភាពនៃការអនុវត្តន៍គោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។ អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជាជាផ្នែកមួយនៃសង្គមស៊ីវិល រួមជាមួយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ។ អង្គការមិនមែនរដ្ឋាភិបាលអាចរួមចំណែកយ៉ាងធំធេងដល់ការកាត់បន្ថយភាពក្រីក្រ តាមរយៈបទពិសោធន៍ក្នុងកិច្ចការអភិវឌ្ឍន៍របស់ពួកគេ ។ ហេតុដូចនេះ អង្គការមិនមែនរដ្ឋាភិបាលមានតួនាទីយ៉ាងសំខាន់ ក្នុងការសំដែងអំពីតំរូវការរបស់ក្រុមជនងាយរងគ្រោះអោយដល់អ្នករៀបចំគោលនយោបាយ ។ រាជរដ្ឋាភិបាលលើកទឹកចិត្តសមាគមពាណិជ្ជករ សមាគមជនជាតិភាគតិច សមាគមកសិករ ចូលរួមត្រួតពិនិត្យការអនុវត្តន៍គំនិតផ្តួចផ្តើមនានា

សំរាប់កាត់បន្ថយភាពក្រីក្រ ។ ដើម្បីផ្តួចផ្តើមគំនិតអោយបានចំទិស យើងក៏ត្រូវពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋក្រីក្រ និងក្រុមជនងាយរងគ្រោះក្នុងដំណើរការទាំងនេះផងដែរ ។ ព្រមជាមួយគ្នានេះ ការពង្រឹងសមត្ថភាពរបស់សភាជាតិក្នុងដំណើរការតាមដាន ក៏ជាតំរូវការចាំបាច់ផងដែរ ។

## បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានលក្ខណៈអនុគ្រោះ

២៨៩- ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ និងផ្អែកលើមូលដ្ឋាននៃសមិទ្ធផលការងារដែលសំរេចបានពីមុនមកក្នុងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលនឹងបន្តពុះពារ ដើម្បីសំរេចអោយបាននូវគោលដៅនៃកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រា ៦-៧% ក្នុងមួយឆ្នាំ ក្នុងបរិការនៃអត្រាអតិផរណាទាបក្នុងកំរិតតួលេខតែមួយខ្ទង់ អត្រាប្តូរប្រាក់មានស្ថិរភាពល្អ ហើយទុនបំរុងជាតិក៏មានការកើនឡើងជាប្រចាំ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តគោលនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន ដោយរួមទាំងអត្រាប្តូរប្រាក់ដែលផ្អែកលើគោលការណ៍ទីផ្សារ ។ គោលនយោបាយបដិដុល្លារូបនីយកម្ម នឹងត្រូវបានអនុវត្តបន្តក្នុងជំហានដ៏ប្រុងប្រយ័ត្ន ស្របទៅតាមសភាពការណ៍វិវត្តន៍នៃសេដ្ឋកិច្ចជាតិ និងអន្តរជាតិ ។

២៩០- ការប្រកាន់ខ្ជាប់នូវវិន័យនៅក្នុងការគ្រប់គ្រងថវិកាមានសារៈសំខាន់ខ្លាំងណាស់ សំរាប់ការបង្កើតឡើងនូវបរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានលក្ខណៈអនុគ្រោះចំពោះការខិតខំកសាងមូលដ្ឋានគ្រឹះ ដ៏រឹងប៉ឹង និងមាំមួននៃសេដ្ឋកិច្ចជាតិ ដើម្បីធានាកំណើនមួយប្រកបទៅដោយចីរភាព និងមានសមធម៌ ។ អាទិភាពរបស់រាជរដ្ឋាភិបាលសំរាប់ នីតិកាលទី ៣ នៃរដ្ឋសភា មានដូចខាងក្រោម÷

- ពង្រឹងការប្រមូលចំណូលពន្ធ និងមិនមែនពន្ធ រួមទាំងអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវច្បាប់ពន្ធដារ និង និងច្បាប់ដែលមានការពាក់ព័ន្ធដទៃទៀត ដូចជាច្បាប់វិនិយោគជាដើម ។
- កាត់បន្ថយអំពើពុករលួយ និងការគេចវេះពន្ធ ។
- បន្តប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវការមិនអនុញ្ញាតអោយមាន «វប្បធម៌រួចពន្ធ និងលើកលែងពន្ធ» នៅក្នុងប្រទេសកម្ពុជា ។
- ពង្រីកមូលដ្ឋានយកពន្ធ ។
- ពង្រឹងរដ្ឋបាលគយ និងពន្ធដារ ។
- ពង្រឹងគ្រប់គ្រងអោយបានម៉ត់ចត់បំផុតនូវទ្រព្យសម្បត្តិរបស់រដ្ឋគ្រប់ប្រភេទ ។
- កែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេសធ្វើវិចារណកម្មចំណាយសាធារណៈដោយផ្អែកលើគោលការណ៍" តំលាភាព គណនេយ្យភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច "។
- កែលំអប្រព័ន្ធសវនកម្ម និងលទ្ធកម្មសាធារណៈ ដោយផ្តល់អាទិភាពទៅលើចំណាយសាធារណៈសំរាប់កិច្ចអភិវឌ្ឍន៍ និងវិនិយោគសាធារណៈលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ។

២៩១- ដើម្បីអនុវត្តបណ្តាអាទិភាពដូចពោលខាងលើ ក្នុងនាមជាប្រមុខនៃរាជរដ្ឋាភិបាលសំរាប់នីតិកាលទី ៣ នៃរដ្ឋសភា សម្តេច នាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានដាក់ចេញនូវវិន័យដប់យ៉ាងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ

សាធារណៈ ដែលគ្រប់សមាជិកសមាជិកានៃរាជរដ្ឋាភិបាលមានកាតព្វកិច្ចត្រូវគោរពយ៉ាងខ្ជាប់ខ្ជួន និង ដោយម៉ឺងម៉ាត់បំផុត និងគ្រប់ពេលវេលា គឺ÷

១- ត្រូវបន្តប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវការមិនអនុញ្ញាតអោយមាន «វប្បធម៌រួចពន្ធ និង លើកលែង ពន្ធ» នៅក្នុងប្រទេសកម្ពុជា ។

២- ត្រូវខិតខំប្រមូលចំណូលគ្រប់ប្រភេទអោយបានគ្រប់តាមផែនការ ឬលើសផែនការ ។

៣- ត្រូវបង់ចំណូលទាំងអស់ចូលរតនាគារជាតិភ្លាមៗអោយបានទាន់ពេល ។ ហាមដាច់ខាតនូវការរក្សាទុកចំណូលសំរាប់ចំណាយនៅក្រៅក្របខ័ណ្ឌថវិកាជាតិ ទោះជាតាមរយៈយន្តការចំណូលព្រម- ចំណាយព្រមក្តី តាមរយៈការខ្ចីក្រុមហ៊ុនប្រើមុន ហើយចាំកាត់ចំណូលសងតាមក្រោយក្តី ។

៤- ត្រូវក្លាហាន និងដាច់ខាត ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើរត់គេចពន្ធគ្រប់ប្រភេទ និងក្នុងការតឹងទារបំណុលពីអ្នកដែលជំពាក់បំណុលរដ្ឋ ពិសេសពីអ្នកជំពាក់បំណុលពន្ធ ។

៥- ត្រូវតម្រង់ចំណាយអោយចំទិសដៅអាទិភាពនៃការអភិវឌ្ឍន៍ ហើយម៉ឺងម៉ាត់ក្នុងការត្បិតត្បៀតចំណាយដែលមិនចាំបាច់ ឬ មិនទាន់ចាំបាច់ និងត្រូវសន្សំសំចៃក្នុងការចាយវាយ ហើយត្រូវលើកកំពស់ស្មារតីប្រឆាំងនឹងភាពខ្ជះខ្ជាយ ។

៦- ត្រូវពង្រឹង និងអនុវត្តអោយបានខ្ជាប់ខ្ជួននូវបទបញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

៧- ត្រូវពង្រឹងសវនកម្មក្នុងការគ្រប់គ្រងថវិកា (ទាំងចំណូល- ទាំងចំណាយ) ទាំងអធិការកិច្ចហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទាំងសវនកម្មផ្ទៃក្នុងក្រសួង- ស្ថាប័ននីមួយៗ ទាំងសវនកម្មឯករាជ្យផ្ទៃក្រៅ ។

៨- ហាមដាច់ខាតនូវការចុះកិច្ចសន្យានានាជាមួយក្រុមហ៊ុនឯកជន ដែលពាក់ព័ន្ធដល់កាតព្វកិច្ចពន្ធដារ និងចំណូល- ចំណាយរដ្ឋ ដោយមិនមានការចូលរួម និងការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៩- ហាមដាច់ខាតនូវការខ្ចីឥណទានដែលមានលក្ខណៈពាណិជ្ជកម្ម ។

១០- ត្រូវពង្រឹងគ្រប់គ្រងឱ្យបានម៉ត់ចត់បំផុត នូវទ្រព្យសម្បត្តិរបស់រដ្ឋគ្រប់ប្រភេទ ដោយគោរពយ៉ាងម៉ឺងម៉ាត់តាមច្បាប់ និងបទបញ្ញត្តិទាំងឡាយស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

២៩២- រាជរដ្ឋាភិបាលយល់យ៉ាងច្បាស់ថា ការបង្កើនសញ្ចយធនក្នុងស្រុក គឺជាកិច្ចការមួយដែលមានសារសំខាន់ខ្លាំងណាស់សំរាប់ការអភិវឌ្ឍន៏សេដ្ឋកិច្ចកម្ពុជាក្នុងអនាគតរយៈពេលវែង ។ ដើម្បីគោលដៅនេះ រាជរដ្ឋាភិបាលនឹងបន្តដាក់ចេញវិធានការពង្រឹងប្រព័ន្ធធនាគារនៅក្នុងប្រទេស សំដៅធានាអោយបាននូវការគ្រប់គ្រងល្អប្រសើរ មានការត្រួតពិនិត្យម៉ត់ចត់ សមស្របនិងមានសមត្ថភាព និងប្រសិទ្ធភាពគ្រប់គ្រាន់ក្នុងការកៀងគរប្រាក់សន្សំ យកមកផ្តល់ហិរញ្ញប្បទានសំរាប់ពង្រីកសកម្មភាពវិស័យឯកជន និងលើកកំពស់កំណើនសេដ្ឋកិច្ច ។ ជាចំណែកដ៏សំខាន់មួយនៃកិច្ចការនេះ រាជរដ្ឋាភិបាលនឹងបន្តលើកស្ទួយវិស័យឥណទានជនបទ ដើម្បីជួយផ្តល់សេវាហិរញ្ញវត្ថុ និងប្រាក់កម្ចីធ្វើដើមទុន ដែលមានការប្រាក់ទាបបំផុតតាមដែល

អាចធ្វើបាន នៅក្នុងក្របខ័ណ្ឌនៃគោលការណ៍សេដ្ឋកិច្ចទីផ្សារ ដោយគិតគូរអំពីអត្រាការប្រាក់តាមវិស័យ ដូចគ្នានៃប្រទេសជាសមាជិកអាស៊ាន សំរាប់ជូនដល់ប្រជាពលរដ្ឋក្រីក្រ គ្រួសារដែលមានចំណូលទាប ព្រមទាំងសហគ្រាសធុនតូច និងមធ្យម ក្នុងទិសដៅជំរុញសកម្មភាពសេដ្ឋកិច្ចជនបទ និងរួមចំណែកលើក កំពស់ជីវភាពរបស់ប្រជាពលរដ្ឋ នៅតាមមូលដ្ឋានឆ្ងាយដាច់ស្រយាល ។ បន្ថែមពីលើនេះ រាជរដ្ឋាភិបាល នឹងបង្កើនការយកចិត្តទុកដាក់ដល់ការរៀបចំប្រព័ន្ធច្បាប់ បទបញ្ញា និងយន្តការស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ទៀត សំរាប់ប្រមែប្រមូលធនធានក្នុងស្រុក ដែលកំពុងតែស្ថិតនៅរាយប៉ាយនៅឡើយ តាមរយៈការបន្តធ្វើ កំណែទម្រង់ និងសុក្រឹតកម្មប្រព័ន្ធពន្ធដារ ការពង្រឹងប្រព័ន្ធធនាគារពាណិជ្ជ និងវិស័យធានារ៉ាប់រង ការបង្កើតផ្សារមូលធន ។ល។ ស្របទៅតាម «ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ សំរាប់ឆ្នាំ ២០០១-២០១០» ដែលត្រូវបានរៀបចំឡើង តាមរយៈជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និង ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនៅខែសីហា ឆ្នាំ២០០១ ។

២៩៣- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងអនុវត្តបណ្តាសកម្មភាពជាអាទិភាព ដូចតទៅ÷

ទី១- <u>ការពង្រឹងសមត្ថភាពរួមសំរាប់គ្រប់គ្រង និងប្រមូលចំណូលៈ</u>

- កសាងបណ្តាជំរើសនានាដើម្បីពង្រឹងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការ កសាងគោលនយោបាយ និងយន្តការគ្រប់គ្រងកម្មវិធីសមាហរណកម្មពេញលេញនៃការកៀងគរ ធនធានថវិកា ។
- បង្កើតក្របខ័ណ្ឌសំរាប់កៀងគរ និងបែងចែកចំណូលនៅតាមគ្រប់លំដាប់ថ្នាក់រដ្ឋបាល និងផ្តល់ ការណែនាំដល់ការកសាងវិធានការសំដៅបង្កើនធនធាននៅតាមខេត្ត និងឃុំ ។
- កសាងបណ្តាជំរើសសំរាប់រយៈពេលមធ្យម និងវែង ពាក់ព័ន្ធនឹងកម្មវិធីសមាហរណកម្មនៃការ កៀងគរធនធានថវិកា សំដៅបំរើអោយការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។
- កសាងបណ្តាជំរើសក្នុងការធ្វើសមាហរណកម្មនៃការកៀងគរថវិកា ដើម្បីកំណត់បញ្ចូលទៅក្នុង ដំណើរការកសាងថវិកាជាតិ និងដំណើរការត្រួតពិនិត្យឡើងវិញនៃការអនុវត្តន៍ថវិកាជាតិ ។
- កំណត់អោយបានច្បាស់លាស់នូវបំណុលពន្ធដារ និងបំណុលនៃចំណូលមិនមែនពន្ធដារ ដើម្បី រៀបចំផែនការ និងប្រមូលពន្ធអោយមានប្រសិទ្ធភាព ។
- ពង្រឹងការងារសវនកម្ម ទាំងសវនកម្មផ្ទៃក្នុងរបស់សាមីក្រសួង-ស្ថាប័ននិមួយៗ ទាំងសវនកម្ម ផ្ទៃក្រៅ និងការងារអធិការកិច្ច ទាំងអធិការកិច្ចរបស់រាជរដ្ឋាភិបាល ទាំងអធិការកិច្ចរបស់ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការគ្រប់គ្រងថវិកាជាតិ ជាពិសេសលើការប្រមូលចំណូល ។

ទី២- <u>ការកៀងគរចំណូលផ្នែកគយ និងរដ្ឋាករ</u> :

- ពង្រឹងការប្រមូលពន្ធគយតាមរយៈ ១-ការជំរុញការអនុវត្តន៍ច្បាប់អោយបានម៉ឺងម៉ាត់ចំពោះ អ្នកដែលមានប្រវត្តិមិនគោរពច្បាប់ និងចំពោះប្រភេទទំនិញដែលមានហានិភ័យចំណូលខ្ពស់

និង ២- ការពង្រឹងអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការទប់ស្កាត់ និងបង្ក្រាបអំពើរត់ពន្ធ ។

- អនុវត្តយុទ្ធសាស្រ្តចាប់បង្ខំ និងគោលការណ៍គ្រប់គ្រងហានិភ័យដើម្បីកាត់បន្ថយការរត់ពន្ធ និងបណ្តាសកម្មភាពខុសច្បាប់ផ្សេងៗនៅតាមព្រំដែន ។
- ពង្រឹងក្របខ័ណ្ឌគតិយុត្តិដោយផ្អែកទៅលើច្បាប់គយថ្មី ដោយការអនុវត្តន៍យ៉ាងម៉ឺងម៉ាត់ ក្នុងនោះរួមមានទាំងការកសាងគោលនយោបាយវិស័យគយ និងរដ្ឋាករ ការចងក្រងសេចក្តីណែនាំអនុវត្តនិតិវិធីគយ និងការបណ្តុះបណ្តាលមន្ត្រីផងដែរ ។
- អនុវត្តកម្មវិធីគ្រប់ជ្រុងជ្រោយរបស់គយ នៅក្នុងការវិភាគលើចំណូល និងការផ្តល់តួលេខ ចំណូល និងស្ថិតិពាណិជ្ជកម្ម ប្រកបដោយបច្ចុប្បន្នភាព និងសុក្រិតភាព។
- ជំរុញអនុវត្តគំរោងបំពាក់បច្ចេកវិទ្យាពត៌មានដល់ទីចាត់ការគយ និងរដ្ឋាករ ហើយរៀបចំវិធានការរយៈពេលខ្លី សំរាប់ការអនុវត្តន៍កម្មវិធីស្វ័យប្រវត្តិកម្មគយ រួមទាំងការរៀបចំបង្កើតមូលដ្ឋានច្បាប់ និងនិតិវិធីដែលមានការពាក់ព័ន្ធ និងការបណ្តុះបណ្តាល និងការរៀបចំគំរោងផង ។
- កំណត់ និងអនុវត្តវិធានការពង្រឹងស្ថាប័នគយ រួមទាំងការកែលំអរចនាសម្ព័ន្ធនៃការផ្តល់កំរៃ និងការលើកទឹកចិត្តដល់មន្ត្រីគយ និងការអភិវឌ្ឍន៍កម្មវិធីអភិបាលកិច្ចល្អផង ។

ទី៣- <u>ការកៀងគរចំណូលពន្ធដារ</u> :

- ពង្រឹងការប្រមូលចំណូលពន្ធ តាមរយៈការអនុវត្តន៍ច្បាប់ស្តីពីសារពើពន្ធ និងច្បាប់ដែលមានការពាក់ព័ន្ធ ដូចជាច្បាប់ស្តីពីវិសោធនកម្មលើច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ។
- បន្តពង្រីកមូលដ្ឋានយកពន្ធ តាមរយៈការពង្រីករបបពិតនៅតាមបណ្តាខេត្ត-ក្រុងផ្សេងទៀត និងពង្រឹងការអនុវត្តន៍អាករលើតម្លៃបន្ថែម និងយន្តការបង្វិលសងអាករលើតំលៃបន្ថែម ។
- កែលំអការវិភាគ និងការព្យាករណ៍លើចំណូលពន្ធដារ ក្នុងទិសដៅបង្កើតបណ្តាជំរើសគោលនយោបាយថ្មីៗ ដើម្បីបង្កើនចំណូលពន្ធ ។
- កំណត់និតិវិធីអោយបានច្បាស់លាស់ សំរាប់ពង្រឹងការផ្តល់ពត៌មានទៅវិញទៅមក ជាពិសេសពត៌មានអំពីអ្នកបង់ពន្ធប្រភេទធំ រវាងទីចាត់ការគយ និងរដ្ឋាករ និងនាយកដ្ឋានពន្ធដារ ។
- ការបង្កើនការប្រើប្រាស់ប្រព័ន្ធធនាគារក្នុងកំរិតអតិបរមា ដើម្បីសំរួលដល់ការបង់ពន្ធ ជាពិសេសចំពោះអ្នកជាប់ពន្ធប្រភេទធំ និងមធ្យម ។
- ពង្រឹងរដ្ឋបាលអាករពិសេស នៅនាយកដ្ឋានពន្ធដារ ។
- ពង្រឹងអោយបានសព្វជ្រុងជ្រោយនូវសវនកម្មពន្ធ ជាពិសេសចំពោះអ្នកជាប់ពន្ធប្រភេទធំ និងមធ្យម ។

- ពង្រឹងការគ្រប់គ្រងបំណុលពន្ធ និងអនុវត្តយ៉ាងម៉ឺងម៉ាត់នូវការតឹងទារបំណុលពន្ធដារ ក្នុងនោះ រួមមាន ការអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាពតិមានសំរាប់កិច្ចប្រតិបត្តិការគ្រប់គ្រង និងការធ្វើសវនកម្មពន្ធនៅនឹងកន្លែង ព្រមទាំងការជំរះបញ្ជីអ្នកជាប់ពន្ធផងដែរ ។
- បន្តអនុវត្តវិធានការពង្រឹងនាយកដ្ឋានពន្ធដារ រួមទាំងការរៀបចំរចនាសម្ព័ន្ធឡើងវិញ ការជ្រើសរើសមន្ត្រីថ្មីបន្ថែម ការកែលំអសេវាបំរើអោយអ្នកជាប់ពន្ធ ការអនុវត្តន៍កម្មវិធីបណ្តុះបណ្តាល ការធ្វើសវនកម្មផ្ទៃក្នុង ការបំពាក់នូវទព្វសំភារៈចាំបាច់ផ្សេងៗ ។ ល។
- បង្កើនការផ្ទៀងផ្ទាត់ពតិមាន ដើម្បីស្វែងរកផលរបរនៅក្នុងរបបម៉ៅការដែលត្រូវផ្ទេរទៅរបប ពិត ។

៤- <u>ការពង្រឹងការគ្រប់គ្រង និងការកៀងគរចំណូលមិនមែនសារពើពន្ធ</u> :

- ដាក់ចេញនូវវិធានការជាបន្ទាន់ដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់ និងស្ថាប័នសំរាប់ការគ្រប់គ្រង និងប្រមូលចំណូលមិនមែនសារពើពន្ធ ។
- ពង្រឹងការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ។
- ពង្រឹងការគ្រប់គ្រងឯកជនភាវូបនីយកម្មនៃទ្រព្យសម្បត្តិរដ្ឋអោយស្របតាមច្បាប់និងបទបញ្ញត្តិជាធរមាន ។
- ដាក់ចេញនិងអនុវត្តជាបន្ទាន់អោយមានប្រសិទ្ធិភាពនូវ÷១-វិធានការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធពីការជួល ឬលក់អចលនទ្រព្យ រួមទាំងការពង្រឹងនិតិវិធីនៃការជួល និងចុះ កិច្ចសន្យាផង ។២- វិធានការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធពីសហគ្រាស សាធារណៈតាមរយៈការពង្រឹងក្របខ័ណ្ឌនៃការគ្រប់គ្រងសហគ្រាសទាំងអស់នោះ ។ ៣-វិធានការពង្រឹងការប្រមូល ចំណូលមិនមែនសារពើពន្ធពីការលក់ទំនិញសាធារណៈ និងការផ្តល់សេវាសាធារណៈ ។ និង៤-វិធានការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធពីការគ្រប់គ្រងធនធានធម្មជាតិគ្រប់ប្រភេទ ។
- ពង្រឹងប្រព័ន្ធត្រួតពិនិត្យនិងប្រមូលចំណូលពីអាជីវកម្មឆ្នោត និងល្បែងភ្នាល់ផ្សេងៗ ដោយសិក្សាពីបទពិសោធន៍អន្តរជាតិពាក់ព័ន្ធនឹងជំរើស ដែលអាចបង្កើនចំណូលពីអាជីវកម្មឆ្នោត និងល្បែងភ្នាល់ទាំងអស់នោះ ។
- ពង្រឹងក្របខ័ណ្ឌច្បាប់ក្នុងការត្រួតពិនិត្យសកម្មភាពប្រតិបត្តិការកាស៊ីណូ និងពង្រឹងការប្រមូលចំណូលពីកាស៊ីណូ អោយបានកើនឡើងសមស្របនឹងចំណូលជាក់ស្តែងនៃអាជីវកម្មក្នុងវិស័យ នេះ ក្នុងនោះរួមមានការពង្រឹងសមត្ថភាពរបស់ស្ថាប័ន និងមន្ត្រីដែលទទួលបន្ទុកការងារប្រមូលចំណូលនេះផងដែរ ។
- ដាក់ចេញនិងអនុវត្តនូវប្រព័ន្ធដែលផ្តល់អំណាចដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការអនុម័តជាចុងក្រោយលើរាល់កិច្ចព្រមព្រៀង និងកិច្ចសន្យាសម្បទានគ្រប់ប្រភេទ ដើម្បីបង្កើនចំណូលពីសម្បទានរបស់រដ្ឋ និងដើម្បីការពារផលប៉ះពាល់អាក្រក់ដល់ថវិកាជាតិ ។

- ដាក់ចេញនិងអនុវត្តជាបន្ទាន់អោយបានប្រកបដោយប្រសិទ្ធិភាព នូវវិធានការដាក់វិន័យចំពោះក្រសួង- ស្ថាប័ន ឬមន្ត្រីគ្រប់គ្រងចំណូលមិនមែនពន្ធគ្រប់ប្រភេទ ដែលមិនព្រមបង់ចំណូលចូលរតនាគារជាតិ ឬលួចលាក់ចំណូលទុកចាយនៅក្រៅបរិបថនៃថវិកាជាតិ ឬទុកចាយដោយខុសនិតិវិធីច្បាប់ជាធរមាន ។
- អនុវត្តយ៉ាងម៉ឺងម៉ាត់និងជាប់ជាប្រចាំនូវសវនកម្ម និងអធិការកិច្ចលើការអនុវត្តន៍កាតព្វកិច្ចបង់ចំណូលមិនមែនសារពើពន្ធរបស់គ្រប់ក្រសួង- ស្ថាប័ន និងសហគ្រាសសាធារណៈដែលមានការពាក់ព័ន្ធ ។

២៩៤- ការពង្រឹងខាងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគឺជាការងារសំខាន់ក្នុងការពង្រឹងអភិបាលកិច្ចល្អ ។ រាជ-រដ្ឋាភិបាលបានរៀបចំចក្ខុវិស័យច្បាស់លាស់សំរាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Financial Management-PFM) និងបណ្តាជំហានការងារចាំបាច់នានាសំរាប់អនុវត្ត ដើម្បីឈានទៅសំរេចអោយបាននូវចក្ខុវិស័យនេះ ។ កម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានរៀបចំឡើង ដោយផ្អែកតាមគោលការណ៍អាទិភាព ៤ ដូចតទៅ ÷ ១- ថវិកាដែលកាន់តែមានជំនឿទុកចិត្ត ។ ២- គណនេយ្យភាពប្រកបដោយប្រសិទ្ធភាពនៃកិច្ចការហិរញ្ញវត្ថុ ។ ៣- កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលគឺជាអាទិភាព និងត្រូវបានយកចិត្តទុកដាក់ ។ ៤- អ្នកគ្រប់គ្រងនៃរាជរដ្ឋាភិបាលត្រូវមានគណនេយ្យភាពចំពោះលទ្ធផលនៃការអនុវត្តន៍កម្មវិធី ។ នៅក្នុងផ្នែកមួយនៃកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលនឹងអនុវត្តសាកល្បងនូវគំនិតផ្តួចផ្តើមមួយចំនួន ដោយផ្តោតទៅលើការប្រែរចនាសម្ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសំរាប់គាំទ្រដល់កិច្ចប្រឹងប្រែងនៃកំណែទំរង់នេះ ។ រាជរដ្ឋាភិបាលសូមស្វាគមន៍ចំពោះអភិក្រមទូទាំងវិស័យ (Sector Wide Approach-SWAP) ដែលបានពិភាក្សា និងឯកភាពជាមួយដៃគូអភិវឌ្ឍន៍ សំរាប់អនុវត្តកម្មវិធីកំណែទំរង់នេះ ។ កិច្ចការនេះបានផ្តល់កាលានុវត្តភាពអោយកម្ពុជាដើរតួជាដៃគូស្មើភាព ហើយជាពិសេស អាចអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដកស្រង់យុទ្ធសាស្ត្រ និងបទពិសោធន៍ល្អៗពីកម្មវិធី អភិវឌ្ឍន៍ និងកិច្ចប្រឹងប្រែងកែលំអកំណែទំរង់ ដើម្បីរៀបចំឡើងវិញនូវកម្មវិធីកំណែទំរង់ខាងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយបច្ចុប្បន្នភាព និងប្រសិទ្ធភាពខ្ពស់ ។

## សមាហរណកម្មកម្ពុជានៅក្នុងតំបន់ និងពិភពលោក

២៩៥- ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ រាជរដ្ឋាភិបាលនឹងបន្តជំរុញការធ្វើសមាហរណកម្មប្រទេសកម្ពុជាទៅក្នុងសហគមន៍តំបន់ និងពិភពលោក ដោយផ្តោតអាទិភាពជាពិសេស ទៅលើការខិតខំដើម្បីកាត់បន្ថយគំលាតនៃការអភិវឌ្ឍន៍នៅក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) តាមរយៈការជំរុញភាពជាដៃគូជាមួយប្រទេសជាសមាជិកអាស៊ាន និងប្រទេសជាដៃគូទាំងឡាយអោយចូលរួមយ៉ាងសកម្មក្នុងការអនុវត្តន៍គំរោងការនានានៃគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន ដែលបានអនុម័តក្នុងកិច្ចប្រជុំកំពូលអាស៊ានកន្លងមក ជាពិសេសវិធានការ និងគំរោងនានា ដែលបានអនុម័តនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី ៨

កាលពីខែវិច្ឆិកា ឆ្នាំ២០០២ នៅទីក្រុងភ្នំពេញ ។ ជាមួយគ្នានោះ រាជរដ្ឋាភិបាលនឹងបន្តចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តន៍ *«កម្មវិធីមហាអនុតំបន់មេគង្គ»* ជាពិសេសគំរោងអាទិភាពនានា ដែលបានអនុម័តនៅក្នុង កិច្ចប្រជុំកំពូលមហាអនុតំបន់មេគង្គលើកទី ១ នៅទីក្រុងភ្នំពេញ នាខែវិច្ឆិកា ឆ្នាំ២០០២ និងគំនិតផ្តួចផ្តើម *«តំបន់អភិវឌ្ឍន៍ត្រីកោណ»* កម្ពុជា- វៀតណាម- ឡាវ និងកម្ពុជា- ឡាវ- ថៃ និង *«យុទ្ធសាស្រ្តសហ- ប្រតិបត្តិការសេដ្ឋកិច្ច»* រវាងកម្ពុជា- ឡាវ មីយ៉ាន់ម៉ារ និងថៃ ។ ដើម្បីកម្ពុជាអាចទាញយកផលចំណេញពី សមាហរណកម្មអន្តរជាតិ យើងត្រូវពង្រឹងសមត្ថភាពស្ថាប័ន និងដាក់អោយអនុវត្តយុទ្ធសាស្រ្តសហប្រតិ- បត្តិការជាមួយប្រទេសជិតខាង ដូចជា ការអនុវត្តន៍ទស្សនទាន *«ប្រទេសបួន- សេដ្ឋកិច្ចមួយ»* ការបង្កើត នូវតំបន់ត្រីកោណនៃកំណើនសេដ្ឋកិច្ច និងការបង្កើតនូវតំបន់សេរីសំរាប់ដំណើរការនាំចេញ (EPZs) ។

២៩៦- បច្ចុប្បន្ននេះ ពិភពលោកទាំងមូលបានទទួលស្គាល់ថា ពាណិជ្ជកម្មសេរីអាចចូលរួមផ្តល់វិភាគទានយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រ និងការលើកកំពស់ជីវភាពរបស់ប្រជាជន ។ នៅក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងបន្តដំណើរទៅមុខយ៉ាងស្វាហាប់ នៅលើមាគ៌ានៃការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម សំដៅធានាអោយទំនិញ និងសេវាគ្រប់ប្រភេទ អាចចរាចរបានដោយសេរីនៅក្នុងទូទាំងប្រទេស និងរវាងប្រទេសកម្ពុជា និងប្រទេសជាដៃគូសំខាន់ៗនៅក្នុងតំបន់ និងលើសកលលោក ។ ការបើកច្រកអោយផលិតផលកម្ពុជាអាចឈានចូលដោយគ្មានរបាំង និងឧបស័គ្គនានា ទៅកាន់ទីផ្សារដ៏ធំធេងនៅក្នុងតំបន់ និងក្នុងពិភពលោក នឹងផ្តល់អោយកម្ពុជានូវកាលានុវត្តភាពនៃ «វិមាត្រសេដ្ឋកិច្ច» ដ៏ធំធេង ដែលនឹងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជា ជាកំណើននៃការវិនិយោគ កំណើននៃការងារ កំណើននៃប្រាក់ចំណូល និងកំណើននៃសេដ្ឋកិច្ចជាតិទាំងមូល ដែលសុទ្ធតែជាកត្តាដ៏សំខាន់សំរាប់ការកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាជន ។ ក្នុងន័យនេះ ការចូលរួមរបស់កម្ពុជានៅក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) និងការចូលជាសមាជិកនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO) នាពេលថ្មីៗនេះ គឺសុទ្ធតែជំហានដែលមានអត្ថន័យជាយុទ្ធសាស្រ្ត និងជាប្រវត្តិសាស្រ្ត សំរាប់ការខិតខំប្រឹងប្រែងស្តារ និងអភិវឌ្ឍន៍កម្ពុជា ។

២៩៧- ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងប្រឹងប្រែងអនុវត្តយ៉ាងម៉ត់ចត់នូវកាតព្វកិច្ចរបស់កម្ពុជាជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ។ ជាការពិត សមាជិកភាពនៅក្នុង WTO តំរូវអោយមានការងារជាច្រើន ដូចជា ការអនុម័ត និងការអនុវត្តន៍ច្បាប់ និងបទដ្ឋាន នីតិវិធីប៉ាន់តំលៃ វិធីសាស្រ្តប៉ាន់តំលៃពាណិជ្ជកម្ម និងរបាយការណ៍ដែលប៉ាន់ប្រមាណផលប៉ះពាល់ដល់ការការពារពាណិជ្ជកម្ម ក៏ដូចជាការសិក្សាស្តីពីការផលិតស្រូវ ទីផ្សារកសិកម្មផ្សេងទៀត និង ដំណើក្សេត្រវិទ្យា សិប្បកម្ម ទឹកស្អាត នេសាទ រោងចក្រ ទេសចរណ៍ និងសេវាពលកម្ម ដើម្បីទាញយកផលប្រយោជន៍ពីអង្គការនេះ ។ រាជរដ្ឋាភិបាលប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការប្រើប្រាស់កាលានុវត្តភាពនេះ ដើម្បីធ្វើការកែទំរង់ក្នុងគ្រប់វិស័យ ។

## ៤.៣ កំណើន

២៩៨- សមាសធាតុទីបីនៃយុទ្ធសាស្រ្តចតុកោណ រួមមានចតុកោណយុទ្ធសាស្រ្តបួនសំរាប់ជំរុញកំណើន ។ ចតុកោណទាំងបួននេះ បានកំណត់យុទ្ធសាស្រ្តសំខាន់ៗរបស់រាជរដ្ឋាភិបាល សំដៅជំរុញកំណើនតាមរយៈ ទី១- ការលើកកំពស់វិស័យកសិកម្ម ។ ទី២- ការអភិវឌ្ឍន៍ផ្នែកឯកជន និងការងារ ។ ទី៣- ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ។ និងទី៤- ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស ។ យុទ្ធសាស្រ្ត និងអាទិភាពសំរាប់ចតុកោណនីមួយៗ មានដូចខាងក្រោម ។

**កំណើន**
- វិស័យកសិកម្ម
- ការស្តារ និងកសាងឡើងវិញហេដ្ឋារចនាសម្ព័ន្ធ
- ការអភិវឌ្ឍន៍វិស័យឯកជន និងការងារ
- ការកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្ស

### ៤.៣.១ វិស័យកសិកម្ម

២៩៩- ចតុកោណយុទ្ធសាស្រ្តទីមួយ នៃយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល គឺការលើកស្ទួយវិស័យកសិកម្ម ដែលជាឆ្អឹងខ្នងនៃយុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ប្រកបដោយចីរភាពរបស់រាជរដ្ឋាភិបាល។ យុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្មរបស់រាជរដ្ឋាភិបាលផ្អែកលើយុទ្ធសាស្រ្តបង្គោលបួន គឺ ÷ ទី១- ការលើកកំពស់ផលិតភាព និងពិពិធកម្មវិស័យកសិកម្ម ។ ទី២- កំណែទំរង់ដីធ្លី និងការបោសសំអាតមីន ។ ទី៣- កំណែទំរង់នេសាទ និងជលផល ។ និង ទី៤- កំណែទំរង់ព្រៃឈើ ។

**វិស័យកសិកម្ម**
- លើកកំពស់ផលិតភាព និងពិពិធកម្មវិស័យកសិកម្ម
- កំណែទំរង់ដីធ្លី និងបោសសំអាតមីន
- កំណែទំរង់នេសាទ និងជលផល
- កំណែទំរង់វិស័យព្រៃឈើ

### ការលើកកំពស់ផលិតភាព និងពិពិធកម្មវិស័យកសិកម្ម

៣០០- អាទិភាពជាចំបងបំផុតរបស់រាជរដ្ឋាភិបាលនៅក្នុងកិច្ចអភិវឌ្ឍន៍វិស័យកសិកម្ម គឺការលើកកំពស់ផលិតភាពកសិកម្ម និងពិពិធកម្មវិស័យកសិកម្ម ដើម្បីអោយវិស័យនេះក្លាយជាផ្នែកនាំមុខមួយនៃកំលាំងចលករ សំរាប់កំណើនសេដ្ឋកិច្ច និងសំរាប់កាត់បន្ថយភាពក្រីក្រ ។ គោលនយោបាយដែលបានកំណត់នៅក្នុងយុទ្ធសាស្រ្តចតុកោណ មានដូចជា÷

- ទី១- ការបង្វែរទិសពីការអភិវឌ្ឍន៍តាមបែប «បើកទូលាយ» ឬតាមបែប «វិបុលកម្ម» ទៅកាន់ការអភិវឌ្ឍន៍តាមបែប «ស៊ីជម្រៅ» ឬតាមបែប «ប្រពលកម្ម» ពោលគឺការពង្រឹងសមត្ថភាពចិញ្ចឹមលើផ្ទៃដីដែលមានស្រាប់ ។

ទី២- បង្កើតបរិយាកាសល្អសំរាប់ការចូលរួមរបស់ផ្នែកឯកជន ដើម្បីការលូតលាស់នៃវិស័យកសិកម្ម តាមរយៈការប្រឹងប្រែងពន្លឿនការផ្តល់កម្មសិទ្ធដីធ្លី ក្នុងទិសដៅពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លីកសិកម្ម ក្នុងក្របខ័ណ្ឌដីសម្បទានសង្គមកិច្ច ជាពិសេសនៅតាមតំបន់ជនបទ ។

ទី៣- អភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ និងពង្រឹងការគ្រប់គ្រងធនធានទឹក ដើម្បីបង្កើនប្រសិទ្ធិភាពនៃការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ និងបន្តបង្កើតនិងពង្រឹងគុណភាពសហគមន៍អ្នកប្រើប្រាស់ទឹក និងកាត់បន្ថយភាពងាយរងគ្រោះពីគ្រោះធម្មជាតិ ។

ទី៤- ពង្រីកសេវាកម្មគាំទ្រ ដូចជាការងារស្រាវជ្រាវនិងផ្សព្វផ្សាយកសិកម្ម ការអភិវឌ្ឍន៍ទីផ្សារសំរាប់ផលិតផលកសិកម្ម ការបែងចែកសំភារៈ ពូជ ជី និងបង្កើនលទ្ធភាពផ្តល់ឥណទាននៅតាមតំបន់ជនបទ ។

ទី៥- តំរង់ទិសវិនិយោគសាធារណៈ និងលើកទឹកចិត្តវិនិយោគឯកជននៅក្នុងវិស័យកសិកម្ម សំដៅលើកកំពស់កំណើនកសិផល និងបង្កើនគុណភាពកសិផលកម្ពុជាអោយឆ្លើយតបទៅនឹងស្តង់ដារអន្តរជាតិ ។

ទី៦- អភិវឌ្ឍតំបន់ព្រំដែន និងតំបន់ជនបទដាច់ស្រយាល ដើម្បីកាត់បន្ថយចំនួនប្រជាជនចូលទីក្រុង ។

ទី៧- រៀបចំ និងកសាងតំបន់ទីប្រជុំជន ដោយមានបណ្តាញហេដ្ឋារចនាសម្ព័ន្ធសមស្រប សំរាប់សំរួលដល់ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងសកម្មភាពសេដ្ឋកិច្ចនៅមូលដ្ឋាន ។

ទី៨- ជំរុញចលនា «ភូមិ១- ផលិតផល១» ដើម្បីលើកស្ទួយគំនិតច្នៃប្រឌិត និងជំនឿលើខ្លួនឯងរបស់ប្រជាពលរដ្ឋនៅតាមជនបទ ដោយឈរលើគោលការណ៍សំខាន់ៗបួនយ៉ាង គឺ ÷ ទី១-រិះរកវិធីផលិតដែលសមស្របទៅនឹងស្ថានភាពជាក់ស្តែងនៃបរិស្ថានភូមិស្ថានរបស់ខ្លួន និងស្របទៅតាមសេចក្តីត្រូវការរបស់ទីផ្សារ ។ ទី២- បង្កលក្ខណៈងាយស្រួល និងផ្តល់ការលើកទឹកចិត្តប្រជាពលរដ្ឋក្នុងការផលិត ដូចជាការស្វែងរកទីផ្សារ ការផ្តល់ឥណទាន ការផ្ទេរបច្ចេកវិទ្យា និងការផ្តល់ពូជ ។ ទី៣- បណ្តុះបណ្តាលសមត្ថភាពគ្រប់គ្រង និងធនធានមនុស្ស ។ និងទី៤- ការបង្កលក្ខណៈងាយស្រួលអោយប្រជាពលរដ្ឋបង្កើតសហគមន៍កសិកម្មក្នុងទិសដៅធានាតម្លៃផលិតផល ។

៣០១- ដើម្បីធ្វើទំនើបកម្មវិស័យកសិកម្ម រាជរដ្ឋាភិបាលនឹងចាត់វិធានការ ដូចខាងក្រោម÷

ទី១- បង្កើនវិនិយោគសាធារណៈសំរាបវិស័យកសិកម្ម និងការអភិវឌ្ឍន៍ជនបទ ជាពិសេសនៅតាមបណ្តាខេត្ត ស្រុក និងឃុំ ដោយសាងសង់ប្រព័ន្ធប្រឡាយ ផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធជនបទផ្សេងៗទៀត ដោយមានក្រុមប្រឹក្សាឃុំជាអ្នកចុះកិច្ចសន្យាស្ថាបនា និងទទួលខុសត្រូវដោយផ្ទាល់ ។

ទី២- ជំរុញវិនិយោគឯកជនតាមអនុវិស័យសំខាន់ៗនៅថ្នាក់មូលដ្ឋាន ដូចជា វារីវប្បកម្ម ទីផ្សារខ្នាតតូចផលិតកម្មកសិផល និងសត្វពាហនៈ កសិសហគ្រាស ដូចជាការកែច្នៃផលិតផល ការប្រមូលផល និងយន្តូបនីយកម្ម ។

ទី៣- ពន្លឿន និងរក្សាស្ថិរភាពកំណើនវិស័យកសិកម្ម ដោយឈរលើមូលដ្ឋានទូលំទូលាយ តាមរយៈការអភិវឌ្ឍន៍ប្រកបដោយចីរភាពនូវផលិតផលដែលមានតំលៃខ្ពស់ ។

ទី៤- បង្កើនចំណាយ និងវិនិយោគនៅថ្នាក់មូលដ្ឋាន ក្នុងផ្នែក ÷ ១- សេវាផ្សព្វផ្សាយសំដៅបង្កើនផលិតភាពកសិកម្ម ។ ២- ធារាសាស្ត្រដែលគ្រប់គ្រងនិងដំណើរការដោយកសិករ ។ ៣- សហគ្រាសជនបទ ។ ៤- ជំនាញនិងសមត្ថភាពផ្នែកឥណទានដល់សហគ្រាសដែលវិនិយោគផ្នែកកសិកម្ម ។ ៥-វិនិយោគសាធារណៈបែបវិមជ្ឈការ ជាមួយនឹងការផ្តល់ហិរញ្ញប្បទាន និងសេវាតាមបែបវិសហមជ្ឈការក្នុងវិស័យកសិកម្ម ។ និង៦- ផ្តល់មូលនិធិសំរាប់ក្រុមកសិករ ដោយផ្អែកតាមគោលការណ៍នៃការផ្តល់ហិរញ្ញប្បទានទ្រង់ទ្រាយតូច ។

៣០២- រាជរដ្ឋាភិបាលនឹងអនុវត្តសកម្មភាពជាក់លាក់មួយចំនួន ដូចតទៅ÷

ទី១- បន្តអនុវត្តគោលនយោបាយទឹកកសិកម្ម ដោយស្តារឡើងវិញប្រព័ន្ធស្រោចស្រពដែលមានស្រាប់ និងកសាងប្រព័ន្ធស្រោចស្រពបន្ថែម ព្រមទាំងពង្រឹងការគ្រប់គ្រងប្រព័ន្ធស្រោចស្រពទាំងនេះ ។

ទី២- បង្កើនរដូវដាំដុះអោយបាន២ដងនៅតាមតំបន់ទំនាប និងពង្រីកផ្ទៃដីផលិតកម្មកសិកម្ម បន្ថែមលើផ្ទៃដីដែលបោសសំអាតមីនរួច និងដីបោះបង់ចោលនិងគ្មានជីជាតិ ។

ទី៣- បន្តការយកចិត្តទុកដាក់លើបញ្ហាសន្តិសុខស្បៀង និងបង្កើនផលិតកម្មស្បៀង ពិសេសដំណាំស្រូវ និងដំណាំស្បៀងរួមផ្សំ ។

ទី៤- បង្កើនគុណភាពកសិផល និងជំរុញការអភិវឌ្ឍន៍កសិឧស្សាហកម្មកែច្នៃ ដើម្បីបង្កើនតំលៃបន្ថែម និងចំណូលរបស់កសិករ ។

ទី៥- ជំរុញការរៀបចំប្រព័ន្ធហិរញ្ញវត្ថុជនបទ ដើម្បីផ្តល់ឥណទានដល់កសិករ សំរាប់ប្រើប្រាស់ក្នុងផលិតកម្មកសិកម្ម ។

ទី៦- អនុវត្តពិពិធកម្ម និងប្រពលកម្មកសិកម្ម តាមរយៈការបង្កើនគុណភាពដី ការការពារដំណាំ ការផ្គត់ផ្គង់គ្រាប់ពូជ និងយន្តូបនីយកម្មក្នុងវិស័យកសិកម្ម ទាំងផលិតកម្ម និងទាំងការប្រមូលផល ។

ទី៧- ពង្រឹងសេវាកម្មគាំទ្រកសិកម្មសំខាន់ៗ រួមមានទីផ្សារកសិផល ការផ្សព្វផ្សាយ និងស្រាវជ្រាវ និងពង្រឹងសហគមន៍អភិវឌ្ឍន៍កសិកម្ម ។

ទី៨- កែលំអប្រព័ន្ធដាំដុះ រួមទាំងការបង្កើនមុខដំណាំដាំដុះ និងការចិញ្ចឹមសត្វ តាមគោលការណ៍ «ភូមិ១- ផលិតផល១» ។

ទី៩- ត្រួតពិនិត្យ និងកាត់បន្ថយការឆ្លងរាលដាលជំងឺសត្វ ។

ទី១០- ពង្រឹងការថែរក្សាសុខភាពសាធារណៈលើសត្វ និងផលិតផលមានដើមកំណើតពីសត្វ ។

ទី១១- លើកកំពស់គុណភាព និងសុវត្ថិភាពកសិផល ដើម្បីធានាសុខភាពសាធារណៈ និងដើម្បីឆ្លើយតបតាមតំរូវការទីផ្សារ ។

ទី១២- ពង្រឹងនិងពង្រីកការចិញ្ចឹមសត្វ និងកែច្នៃកាកសំណល់សត្វ ។

ទី១៣- ជំរុញឯកជនភាវូបនីយកម្មលើសហគ្រាសចំការកៅស៊ូរដ្ឋ ។

ទី១៤- ជំរុញដំណាំកៅស៊ូគ្រួសារ ការវិនិយោគលើចំការកៅស៊ូ និងបង្កើនការគ្រប់គ្រងវិស័យកៅស៊ូ ។

៣០៣- ក្នុងការគាំទ្រកិច្ចអភិវឌ្ឍន៍ជនបទ ក្រសួងអភិវឌ្ឍន៍ជនបទនឹង ÷ ១- បន្តតួនាទីជាអ្នកសំរបសំរួលការងារជាមួយបណ្តាក្រសួង អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងជាមួយផ្នែកឯកជន តាមរយៈការសំរបសំរួលការអនុវត្តន៍គំរោងនៅតាមតំបន់ជនបទ ព្រមទាំងផ្តល់ការគាំទ្រដល់បណ្តាកម្មវិធីនានាដែលជាជំនួយឧបត្ថម្ភរបស់សហគមន៍អន្តរជាតិ ។ ២- អនុវត្តដោយផ្ទាល់ នូវបណ្តាគំរោង និងកម្មវិធីនានាដើម្បីបង្កើតសេដ្ឋកិច្ចទីផ្សារនៅសហគមន៍ជនបទ ។ ក្រសួងនឹងបន្តជំរុញការអភិវឌ្ឍន៍ធនធានមនុស្ស ការបង្កើតរចនាសម្ព័ន្ធជនបទ ពិសេសការបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ឃុំ និងការគ្រប់គ្រងពត៌មាន និងទំនាក់ទំនង ។ ក្រសួងក៏បន្តអនុវត្តកម្មវិធីនានា ដូចជាគំរោងស្ពាន និងកសាងផ្លូវ ការផ្គត់ផ្គង់ទឹកស្អាត ការជំរុញវិស័យសុខាភិបាល ការពង្រីកធារាសាស្ត្រខ្នាតតូច ការជំរុញសន្តិសុខស្បៀងនៅតាមគ្រួសារ ការជំរុញឥណទានជនបទ និងការអភិវឌ្ឍន៍ឃុំ ។

**កំណែទំរង់ដីធ្លី និងការបោសសំអាតមីន**

៣០៤- ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ដីនិងទឹកគឺជាធនធានធម្មជាតិជាមូលដ្ឋានដ៏សំខាន់២យ៉ាង សំរាប់ កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច- សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រ ពិសេសតំបន់ជនបទ ។ គោលនយោបាយស្តីពីកំណែទំរង់ដីធ្លី និងការបោសសំអាតមីន ដូចបានលើកឡើងក្នុងយុទ្ធសាស្ត្រចតុកោណ រួមមាន÷

ទី១- ប្តេជ្ញាបន្តអនុវត្តច្បាប់ភូមិបាល និងគោលនយោបាយដីធ្លី ដោយប្រមូលផ្តុំជាសំខាន់លើវិធានការពង្រឹងប្រព័ន្ធគ្រប់គ្រង បែងចែក និងប្រើប្រាស់ដីធ្លីប្រកបដោយសមធម៌ និងដោយធានាបាននូវប្រសិទ្ធភាពសេដ្ឋកិច្ច តាមរយៈការចុះបញ្ជីដីធ្លី ការបែងចែកដីធ្លី ការធានាសុវត្ថិភាពនៃកម្មសិទ្ធិលើដីធ្លី ការលុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ ការដាក់ចេញវិធានការសមស្រប ដើម្បីទប់ស្កាត់ការប្រមូលដីទុកដោយមិនប្រើប្រាស់ ដែលមិនធ្វើផលិតកម្ម ឬមិនធ្វើអាជីវកម្ម ។

ទី២- ពិនិត្យឡើងវិញនូវដីទំនេររបស់រដ្ឋ ឬ ដីរដ្ឋដែលឯកជនកាន់កាប់ដែលផ្ទុយនឹងលិខិតបទដ្ឋាន គតិយុត្តិ និងនីតិវិធីដែលបានកំណត់កន្លងមក ។

ទី៣- ពង្រឹងសិទ្ធិកាន់កាប់ដីធ្លីជូនប្រជាពលរដ្ឋ ដែលត្រូវការដីសំរាប់សង់លំនៅដ្ឋាន និងធ្វើអាជីវកម្មកសិកម្មជាលក្ខណៈគ្រួសារក្នុងក្របខ័ណ្ឌដីសម្បទានសង្គមកិច្ច ដោយឈរលើគោលការណ៍ជួយគ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះ ។

ទី៤- បន្តអនុវត្តការងារតាមនីតិវិធីដែលបានរៀបចំ ដើម្បីធានាអោយសកម្មភាពកំចាត់មីនដែលកំពុងអនុវត្តនៅកម្ពុជាបានដំណើរការទៅប្រកបដោយសុវត្ថិភាព តាមស្តង់ដារជាតិ និងកាតព្វកិច្ចអន្តរជាតិ ព្រមទាំងមានកិច្ចសំរបសំរួលល្អក្នុងការអនុវត្តន៍ផែនការជាតិខាងដោះមីន ។

៣០៥- **កំណែទម្រង់ដីធ្លី** : ដោយមានផែនការសកម្មភាពច្បាស់លាស់ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី រួមជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹង÷

- បន្តរៀបចំគោលនយោបាយដីធ្លីទូលំទូលាយ ដោយផ្អែកលើឯកសារបឋមស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី និងបទពិសោធន៍នៃការអនុវត្តន៍គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ។
- សិក្សាដើម្បីរៀបចំគោលនយោបាយ និងនិតិវិធីលើការចុះបញ្ជីកម្មសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច ។
- រៀបចំគោលនយោបាយ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ និងដីសម្បទានសង្គមកិច្ច ។
- រួមចំណែកអភិវឌ្ឍន៍ប្រព័ន្ធវាយតំលៃដីធ្លី ។
- បន្តរៀបចំគោលនយោបាយ និងសារាចរណែនាំស្តីពីសហកម្មសិទ្ធិ និងដីចំណីផ្លូវ ។
- ស្នើវិសោធនកម្មច្បាប់រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤ ។
- រៀបចំសារាចរណែនាំស្តីពីការអនុវត្តន៍មាត្រា១៨ នៃច្បាប់ភូមិបាល ដើម្បីប្រមូលដីរដ្ឋដែលកាន់កាប់ខុសច្បាប់មកវិញ ។
- ដើម្បីអនុវត្តសម្បទានដីសង្គមកិច្ច បន្តរៀបចំសេចក្តីណែនាំពីការកំណត់ដីសំរាប់ចែក ការកំណត់មុខសញ្ញាអ្នកទទួលដី និងការអភិវឌ្ឍន៍ ។
- កសាងក្រមស្តង់ដារសំណង់- នគរូបនីយកម្ម ។
- បន្តអនុវត្តគោលនយោបាយជាតិស្តីពីលំនៅដ្ឋាន ។
- កសាងក្របខ័ណ្ឌគតិយុត្តិទាក់ទងនឹងការគ្រប់គ្រងទិន្នន័យ NSDI (National Spatial Data Infrastructure) ។
- កសាងស្តង់ដារទាក់ទងនឹងការវាស់វែង និងផែនទី ។
- បន្តសិក្សាស្រាវជ្រាវពីបញ្ហាដីធ្លីដូចជាសេដ្ឋកិច្ចដីធ្លី ការអង្កេតលើបញ្ហាដីធ្លី និងការវាយតំលៃផលប៉ះពាល់សង្គម ។
- រៀបចំសេចក្តីប្រកាសរួមស្តីពីតួនាទីទី និងការទទួលខុសត្រូវរបស់ឃុំ- សង្កាត់ក្នុងការចុះបញ្ជីដីធ្លី ។
- ចងក្រងសៀវភៅណែនាំរបស់រដ្ឋបាលមូលដ្ឋានលើការងារដីធ្លី និងសំណង់ ។
- បន្តរៀបចំនិតិវិធីនៃការកំណត់ព្រំប្រទល់ឃុំ- សង្កាត់ អោយមានលក្ខណៈកាន់តែសុក្រឹត្យ ព្រមទាំងបោះពុម្ព និងផ្សព្វផ្សាយផែនទីឃុំ- សង្កាត់ ។

៣០៦- **ការអភិវឌ្ឍន៍ស្ថាប័ន** :

- កែលំអរចនាសម្ព័ន្ធក្រសួង តាមសកលភាវូបនីយកម្ម ការរីកចំរើនពតិមានវិទ្យា និងការផ្តល់សេវាសាធារណៈអោយកាន់តែប្រសើរជាងមុន ។
- អភិវឌ្ឍធនធានមនុស្ស តាមរយៈ ÷ ១- ការបង្កើនសមត្ថភាពមន្ត្រីរបស់ក្រសួង ដោយធ្វើការបណ្តុះបណ្តាលផ្អែកបច្ចេកទេស ច្បាប់ ការគ្រប់គ្រង និងដឹកនាំ ។ ២- បន្តពង្រឹងគុណភាពអប់រំនៅមហា

វិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី ។ និង ៣- រៀបចំកម្មវិធីបណ្តុះបណ្តាលកំរិតមធ្យម ដើម្បីពង្រឹងសមត្ថភាពបុគ្គលិកនៅថ្នាក់ស្រុក និងខ័ណ្ឌ ។

- ដើម្បីចូលរួមចំណែកពង្រឹងអភិបាលកិច្ចល្អ ក្រសួងនឹងរៀបចំយុទ្ធសាស្រ្តតំលាភាព និងគណនេយ្យ ភាពចំពោះគ្រប់មុខងារទាំងអស់ ។
- បណ្តុះបណ្តាលបន្ថែមក្រុមចុះបញ្ជីដីធ្លីមានលក្ខណៈប្រព័ន្ធ ៣៥០នាក់ មន្រ្តីពិនិត្យគុណភាព ១០០នាក់ មន្រ្តីផលិតអ័រតូហ្វូតូ ៦នាក់ គណៈកម្មការរដ្ឋបាល ២០០០នាក់ បណ្តុះបណ្តាលក្រុមចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ ១០០នាក់ បណ្តុះបណ្តាលស្តីពីការរៀបចំផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួមដល់មន្រ្តីសិរបសិរួលថ្នាក់ខេត្ត- ក្រុង ៣៦៥នាក់ និងបណ្តុះបណ្តាលស្តីពីផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ស្រុក ដល់មន្រ្តីខេត្ត- ក្រុង ៤០នាក់ ។
- ដើម្បីអនុវត្តគោលនយោបាយវិមជ្ឈការ ក្រសួងនឹងប្រតិភូកម្មហត្ថលេខាលើឯកសារសុរិយោដីដល់មន្ទីរខេត្ត ចំនួន៣ទៀត ។
- សាងសង់អាគារក្រសួង មហាវិទ្យាល័យ និងមន្ទីរខេត្ត- ក្រុង ចំនួន១១ និងការិយាល័យស្រុក ៤០ ។
- មហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លីនឹងជ្រើសរើសនិសិត្ស ៣០- ៤០នាក់ ក្នុងឆ្នាំ២០០៤- ២០០៥ ។

៣០៧- **កម្មវិធីចុះបញ្ជីដីធ្លី និងការអភិវឌ្ឍន៍ប្រព័ន្ធចុះបញ្ជីដី និងការដោះស្រាយទំនាស់** :

- ដើម្បីធានាសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី កាត់បន្ថយជំលោះ និងបង្កលទ្ធភាពស្វែងរកឥណទានសំរាប់វិនិយោគ ក្រសួងមានទិសដៅចេញប័ណ្ណចំនួន ៣០០.០០០ក្បាលដី ទាំងលក្ខណៈជាប្រព័ន្ធ និងដាច់ដោយដុំ ជូនប្រជាពលរដ្ឋក្នុងឆ្នាំ ២០០៥ និង ១.០០០.០០០ក្បាលដី ក្នុងឆ្នាំ២០០៧ ។ ក្រសួងបន្តកសាងវប្បធម៌ការចុះបញ្ជីដីធ្លី កាត់បន្ថយការផ្ទេរអចលនវត្ថុក្រៅផ្លូវការ ដោយកសាងការផ្តល់សេវាអោយកាន់តែទំនើប មានប្រសិទ្ធភាព និងមានតំលាភាព ។
- ជួយជំរុញការប្រមូលចំណូលតាមរយៈពន្ធប្រថាប់ត្រា ពន្ធលើដីមិនប្រើប្រាស់ ចំណូលដែលបានមកពីការដូររូបភាពនៃការប្រើប្រាស់ដី និងថ្លៃសុរិយោដី ។
- បន្តកសាងបណ្តាញប្រថពីវិភាគ ទាំងរយៈកំពស់ និងរយៈបណ្តោយ នៅទូទាំងប្រទេស ។
- ចុះបញ្ជីដីរដ្ឋដែលមានលក្ខណៈពិសេស ដូចជាតំបន់អង្គរ ។
- បន្តពង្រឹងការដោះស្រាយទំនាស់ក្រៅតុលាការ (តាមរយៈគណៈកម្មការសុរិយោដី) ចំពោះទំនាស់ដីធ្លីរួមមានការផ្តល់ជំនួយផ្លូវច្បាប់ចំពោះអ្នករងគ្រោះ និងប្រព័ន្ធតាមដាន និងវាយតំលៃ ។

៣០៨- **ការរៀបចំដែនដី** : ក្រសួងនឹងបន្តធ្វើអោយប្រសើរនូវបរិយាកាសវិនិយោគ តាមរយៈការគ្រប់គ្រងដោយប្រសិទ្ធភាពលើដីរដ្ឋ ការបែងចែកតំបន់ និងការធ្វើសមាហរណកម្មផែនការរៀបចំក្រុង និងភូមិភាគ និងការកសាងផែនទីប្រទេស ។ ក្រសួងបន្តផ្តល់សេវារៀបចំ និងសិរបសិរួលផែនការអភិវឌ្ឍន៍ស្រុកចំនួន ២០ រៀង

រាល់ឆ្នាំ និងបន្តរៀបចំប្លង់គោល និងការកំណត់តំបន់នានា ។ ក្រសួងនឹងបន្តផ្តល់ការណែនាំពីការអភិវឌ្ឍន៍ ដីធ្លី និងចូលរួមក្នុងការរៀបចំ កំណត់តំបន់ប្លង់ការពារអង្គរ និងបិតិកភ័ណ្ឌជាតិ ។

៣០៩- **សម្បទានដីសង្គមកិច្ច** : យោងតាមបទពិសោធន៍នៃគំរោងសាកល្បង និងអនុសាសន៍នៃការសិក្សាពីការវាយតំលៃផលប៉ះពាល់សង្គមរបស់គំរោងសម្បទានដីសង្គមកិច្ច ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដោយមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ កំពុងរៀបចំបែងចែកដីធ្លីសង្គមកិច្ច និងការអភិវឌ្ឍន៍សេដ្ឋកិច្ច (LASED) ដែលអាចមានអ្នកទទួលផល ១០.០០០នាក់ ។ គំរោងនេះនឹងអាចជាយុទ្ធសាស្រ្តបង្កើតការងារ ដោយផ្តល់លទ្ធភាពទទួលបានដីធ្លីសំរាប់ប្រជាពលរដ្ឋដែលគ្មានដី ហើយផ្សាភ្ជាប់អ្នកមានដីតូចជាមួយអ្នកមានដីធំ ឬមធ្យមតាមរយៈការជំរុញកសិ- ពាណិជ្ជកម្ម- ឧស្សាហកម្ម ដែលជាឱកាសបង្កើតការងារ ទាំងក្នុងផ្នែកកសិកម្មនិងមិនមែនកសិកម្ម និងក្នុងភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន ។

៣១០- **ការខារសំណង់** : ដើម្បីចូលរួមចំណែកក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ ក្រសួងនឹងបន្តចេញលិខិតអនុញ្ញាតអោយសាងសង់ ប្រកបដោយសោភណភាពក្នុងរចនាបថខ្មែរ មានតំលាភាព និងប្រសិទ្ធភាពដើម្បីបំរើសាធារណៈប្រយោជន៍ ព្រមទាំងពង្រឹងការគ្រប់គ្រងលើក្រុមហ៊ុនធ្វើអាជីវកម្មសាងសង់ និងគូរប្លង់គ្រប់ប្រភេទ ។

៣១១- **ការបោសសំអាតមីន** : កម្ពុជាជាប្រទេសមួយដែលនៅមានមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (UXO) ច្រើនជាងគេនៅលើពិភពលោក ។ គ្រាប់មីន និងសារធាតុ UXO ទាំងនេះ ត្រូវបានបន្សល់ទុកតាំងពីសង្រ្គាមវៀតណាម និងជំលោះផ្ទៃក្នុង ក្នុងរយៈកាលក្រោយៗមកទៀត ហើយបានបន្តសម្លាប់ជីវិតជនស្លូតត្រង់រាប់រយនាក់ក្នុងមួយឆ្នាំៗ ។ គោលដៅរបស់រាជរដ្ឋាភិបាលគឺបោសសំអាតគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅតាមតំបន់មានគ្រោះថ្នាក់កំរិតខ្ពស់ អោយបានអស់ត្រឹមឆ្នាំ២០១២ និងរំដោះមីននៅទូទាំងប្រទេសអោយបានអស់ត្រឹមឆ្នាំ ២០២០ ។

៣១២- អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (CMAA) បានដឹកនាំរៀបចំផែនការសកម្មភាពកំចាត់មីនរយៈពេល៥ឆ្នាំ ២០០៤-២០០៨ ដើម្បីសំរេចអោយបាននូវគោលដៅយុទ្ធសាស្រ្តសកម្មភាពកំចាត់មីនរបស់រាជរដ្ឋាភិបាល ។ ដើម្បីសំរេចគោលដៅក្នុងការរំដោះមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ អជ្ញាធរមីនកម្ពុជានឹងអនុវត្តនូវសកម្មភាពដូចខាងក្រោម ÷

- ទី១- កំណត់យកការបោសសំអាតមីនពីតំបន់សង្ស័យមានមីនកំរិតខ្ពស់អោយអស់ត្រឹមឆ្នាំ២០០៩ ជាអាទិភាពចំបង ។
- ទី២- ធ្វើសមាហរណកម្មប្រតិបត្តិការដោះមីន ជាមួយនឹងកម្មវិធីអភិវឌ្ឍន៍ ។
- ទី៣- សំរបសំរួលជាមួយប្រតិបត្តិករដោះមីន ដើម្បីធ្វើការអង្កេតបច្ចេកទេសមួយ ត្រឹមឆ្នាំ២០០៥ ។
- ទី៤- ជួយកសាងសមត្ថភាពរបស់កងយោធពលខេមរភូមិន្ទក្នុងការដោះមីនដើម្បីអភិវឌ្ឍន៍ ។
- ទី៥- សំរបសំរួលជាមួយប្រតិបត្តិករដោះមីន ដើម្បីអប់រំពីគ្រោះថ្នាក់ដែលបណ្តាលពីមីន ។

ទី៦- ផ្សព្វផ្សាយពីសមិទ្ធផលនៃការកំចាត់មីន និងតំបន់ដែលអាចគ្រោះថ្នាក់ដោយសារមីន ។

ទី៧- កែលំអប្រសិទ្ធភាពចំណាយក្នុងការដោះមីន រហូតដល់ឆ្នាំ២០០៦ ។

ទី៨- ពង្រឹងការតាមដានពិនិត្យតំបន់ដែលបោសសំអាតមីនរួច ចាប់ពីឆ្នាំ២០០៥ ។

ទី៩- អនុវត្តស្តង់ដារសកម្មភាពមីនកម្ពុជា ចាប់ពីឆ្នាំ ២០០៥ ។

**កំណែទំរង់នេសាទ**

៣១៣- មច្ឆាជាតិមានសារៈសំខាន់ជាអាយុជីវិតដល់ប្រជាជនកម្ពុជារាប់លាននាក់ ដោយផ្តល់ជាស្បៀងអាហារជាចំណូល និងការរស់នៅ ។ អាទិភាពរបស់រាជរដ្ឋាភិបាលដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណលើវិស័យនេះរួមមាន ÷

- បង្កើតសហគមន៍អភិវឌ្ឍន៍វិស័យជលផល ដោយប្រគល់សិទ្ធិអំណាចទៅអោយសហគមន៍ជនបទ ដើម្បីអោយប្រជាកសិករអាចចូលរួមបានយ៉ាងសកម្ម ក្នុងការរៀបចំផែនការនិងកម្មវិធីនានា ហើយទទួលខុសត្រូវគ្រប់គ្រងធនធានជលផលដោយខ្លួនឯង ។
- បង្វែរឡូតិ៍នេសាទចប់កិច្ចសន្យាមួយចំនួនទុកជាកន្លែងអភិរក្សពូជត្រី សំរាប់បង្កើនផលស្តុកធម្មជាតិ ផង និងរក្សាពូជត្រីដែលស្ទើរផុតពូជអោយសំបូរឡើងវិញផង ។
- ជំរុញបង្កើនទំហំដែននេសាទសំរាប់ជូនប្រជាពលរដ្ឋប្រើប្រាស់ និងជំរុញការអភិវឌ្ឍន៍ផ្នែកវារីវប្បកម្ម ដើម្បីឆ្លើយតបទៅនឹងតំរូវការសាច់ត្រីកើនឡើងផង ព្រមទាំងបន្ថយសម្ពាធលើធនធានជលផលធម្មជាតិផងដែរ ។

**កំណែទំរង់ព្រៃឈើ**

៣១៤- ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនៅក្នុងវិស័យព្រៃឈើ គឺការធានាអោយមានការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ដោយឈរលើមូលដ្ឋាននៃសសរទ្រូង ៣ សំខាន់ ដូចខាងក្រោម ÷

ទី១- គោលនយោបាយគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ដោយមានការត្រួតពិនិត្យអាជីវកម្មព្រៃឈើយ៉ាងម៉ឺងម៉ាត់ និងសមស្របតាមនិយាមនៃការគ្រប់គ្រងព្រៃឈើជាអន្តរជាតិ ដែលតំរូវអោយមានទំហំព្រៃឈើបំរុងទុកគ្រប់គ្រាន់ សំរាប់ទប់ទល់ការប្រើប្រាស់របស់ប្រជាពលរដ្ឋ ការពារភាពរាំងស្ងួត និងទឹកជំនន់ ព្រមទាំងព្រៃលិចទឹកសំរាប់ទុកជាជម្រកមច្ឆាជាតិ ។

ទី២- ប្រព័ន្ធការពារធនធានធម្មជាតិ ដើម្បីធ្វើការអភិរក្សជីវសាស្ត្រចំរុះ និងប្រភេទដែលកម្រ ។

ទី៣- ការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍សហគមន៍ព្រៃឈើមួយ ដែលរឹងមាំ មានតំលាភាព និងមានការគ្រប់គ្រងដោយប្រជាពលរដ្ឋដោយផ្ទាល់នៅក្នុងតំបន់នោះ ។

៣១៥- ដើម្បីសំរេចបាននូវគោលដៅខាងលើ រាជរដ្ឋាភិបាលបានដាក់បញ្ចូលជាអាទិភាព នូវវិធានការយុទ្ធសាស្ត្រដូចខាងក្រោមនេះ ÷

១- ពង្រឹងការគ្រប់គ្រង និងអភិរក្សធនធានព្រៃឈើ

ក- រៀបចំធ្វើសនិទានកម្ម និងចំណាត់ថ្នាក់នៃសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ឡើងវិញ និងរក្សានូវធនធានព្រៃឈើដែលនៅសេសសល់ទាំងអស់ ដើម្បីធានាអោយមានមុខងារការពារប្រព័ន្ធអេកូឡូស៊ី និងការអភិរក្សជីវចំរុះដោយធ្វើការអនុម័ត និងអនុវត្តអនុក្រឹត្យស្តីពីការបង្កើតការចាត់ថ្នាក់ និងការចុះបញ្ជីសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ។

ខ-ពង្រឹងការអនុវត្តន៍ច្បាប់ស្តីពីព្រៃឈើ និងពិសេស បទបញ្ជាលេខ០១ បប ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ ២០០៤ ស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និងការហ៊ុមពទ្ធ័កាន់កាប់ដីព្រៃឈើ ។

គ-ពង្រឹងការអនុវត្តន៍យុទ្ធសាស្ត្រអភិរក្ស និងការពារប្រភេទព្រៃការពារ តំបន់ទីជំរាល តំបន់អភិរក្សធនធានសេនេទិច រុក្ខជាតិព្រៃឈើ និងសត្វព្រៃតំបន់ទេសចរណ៍ធម្មជាតិនិង តំបន់នៃប្រពន្ធ័មជ្ឈដ្ឋានពិសេសផ្សេងទៀត ដោយមានការចូលរួមជាអតិបរមាពីសំណាក់សហគមន៍មូលដ្ឋាន ។

ឃ- អនុវត្តអោយបានម៉ឺងម៉ាត់នូវក្រមបច្ចេកទេសគ្រប់គ្រងព្រៃឈើជាមូលដ្ឋាននិយ័តកម្ម សំរាប់ការគ្រប់គ្រង និងការប្រើប្រាស់ធនធានព្រៃឈើ រួមទាំងព្រៃសម្បទាន ប្រកបដោយចីរភាព ។

ង- ជំរុញយុទ្ធនាការយល់ដឹងពីសម្បត្តិធម្មជាតិព្រៃឈើ ។

២- ជំរុញព្រៃឈើអោយចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម

ក-លើកកំពស់តំលៃសេដ្ឋកិច្ច-សង្គមនៃការការពារ ecosystems និងការអភិរក្សជីវៈចំរុះនៃធនធានព្រៃឈើ ។

ខ-ជំរុញការផ្គត់ផ្គង់ឈើចេញពីប្រភពព្រៃដាំជំនួសប្រភពឈើចេញពីព្រៃធម្មជាតិ តាមរយៈការលើកទឹកចិត្តដល់ផ្នែកវិនិយោគឯកជន និងការចូលរួមរបស់ផ្នែកសាធារណៈ ។

គ-បង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ ការកែច្នៃ និងការរកទីផ្សារសំរាប់ផលិតផលព្រៃឈើ ជាពិសេសការដាំព្រៃឈើឡើងវិញ សំរាប់ឆ្លើយតបនឹងតំរូវការក្នុងស្រុក និងសំរាប់ការនាំចេញ ។

ឃ-បន្តជំរុញដំណើរការដាំដើមឈើឡើងវិញ នៅតាមទីកន្លែងដែលអាចដាំបាន និងការពារកូនឈើដែលបានដាំកន្លងមក ។

៣- ជំរុញព្រៃឈើអោយចូលរួមកាត់បន្ថយភាពក្រីក្រ

ក-ទទួលស្គាល់ និងការពារតាមផ្លូវច្បាប់នូវសិទ្ធិជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន ក្នុងការប្រើប្រាស់ធនធានព្រៃឈើ ដើម្បីរួមចំណែកក្នុងការធានាសន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ ។ សិទ្ធិទាំងនេះត្រូវបានការពារដោយច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានក្រោមច្បាប់ដទៃទៀត ។

ខ-បង្កើនផលប្រយោជន៍ដល់សហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់ និងគ្រប់គ្រងធនធានព្រៃឈើ តាមរយៈការអនុវត្តន៍ការអភិរក្សព្រៃឈើ និងសត្វព្រៃ ដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន ។

៤- <u>ពង្រឹងសមត្ថភាព និងអភិបាលកិច្ចល្អក្នុងវិស័យព្រៃឈើ</u>

ក- កសាងសមត្ថភាព ពង្រឹងស្ថាប័នគ្រប់គ្រង និងកម្មវិធីស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រព្រៃឈើ នៅគ្រប់លំដាប់ថ្នាក់ ។

ខ-បណ្តុះបណ្តាលបំពាក់បំប៉នការយល់ដឹងសាធារណៈដល់សហគមន៍មូលដ្ឋានដើម្បីអោយចូលរួមក្នុងការ អភិរក្សនិងគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព ។

គ-ពង្រឹងកិច្ចប្រតិបត្តិការរបស់រដ្ឋបាលព្រៃឈើ ដែលមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសំរេច និងអាច ប្រតិបត្តិបាននៅថ្នាក់មូលដ្ឋាន ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធ ។

## ៤.៣.២ ការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធ

៣១៦- ចតុកោណទី២នៃ **យុទ្ធសាស្ត្រចតុកោណ** គឺការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធ ដោយឈរលើសសរទ្រូងជាយុទ្ធសាស្ត្របួន គឺ ÷ ទី១- ការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ។ ទី២- ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ ។ ទី៣- ការអភិវឌ្ឍន៍វិស័យថាមពល និងបណ្តាញ អគ្គិសនី ។ និង ទី៤- ការអភិវឌ្ឍន៍បច្ចេកវិទ្យាពត៌មាននិងទូរគមនាគមន៍ ។ យុទ្ធសាស្ត្រ និងអាទិភាពសំរាប់ផ្នែក នីមួយៗ មានដូចខាងក្រោម ។

**ការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធ**

-ការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍
-ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ
-ការអភិវឌ្ឍន៍វិស័យថាមពលនិងបណ្តាញអគ្គិសនី
-ការអភិវឌ្ឍន៍បច្ចេកវិទ្យាពត៌មាន

### ការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍

៣១៧- ដូចបានលើកឡើងនៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល បណ្តាញគមនាគមន៍គឺជាសរសៃឈាមសំរាប់តភ្ជាប់គ្រប់ច្រកល្ហកនៃព្រះរាជាណាចក្រកម្ពុជា អោយក្លាយទៅជាសរីរាង្គកាយសេដ្ឋកិច្ចមួយ ។ ប្រព័ន្ធដឹកជញ្ជូនគឺជាឧបករណ៍សំរាប់អភិវឌ្ឍទីផ្សារក្នុងស្រុក ព្រមទាំងធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក ។ លើសពីនេះទៀត ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅមានតួនាទីដ៏សំខាន់ ជា «ក្បាលរថភ្លើងនៃកំណើនសេដ្ឋកិច្ច» ដែលអាចរួមចំណែកដ៏មានប្រសិទ្ធភាពបំផុតក្នុងការកាត់បន្ថយ ភាពក្រីក្រ និងទុក្ខលំបាកវេទនារបស់ប្រជាជន ។

៣១៨- អាទិភាពចំបងរបស់រាជរដ្ឋាភិបាល គឺបន្តស្តារ និងកសាងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនគ្រប់ប្រភេទ រួមមាន ÷ ថ្នល់ ស្ពាន ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងអាកាសយានដ្ឋាន សំរាប់តភ្ជាប់តំបន់នានាជាមួយគ្នានៅទូទាំងប្រទេស និងសំរាប់តភ្ជាប់ជាមួយបណ្តាប្រទេសជិតខាង និងជាមួយពិភពលោក ។ គោលដៅចំបងគឺការរៀបចំអោយមានប្រពន្ធ័គមនាគមន៍ដឹកជញ្ជូនមួយ ដែលងាយស្រួល មានស្ថេរភាព មានសុវត្ថិភាព មានប្រសិទ្ធភាពខាងសេដ្ឋកិច្ច និងមានតំលៃទាប ក្នុងទិសដៅសំរួលដល់ការធ្វើពាណិជ្ជកម្ម ជំរុញវិស័យ

ទេសចរណ៍ ការអភិវឌ្ឍន៍ជនបទ ការធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់ និងក្នុងសកលលោក និង ពិសេស ក្នុងកិច្ចការពារប្រទេសថែមទៀត ។ អាទិភាពដទៃទៀតដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ រួមមាន ÷

ទី១- បន្តកសាងបន្ថែមផ្លូវជនបទ និងបន្តថែរក្សាផ្លូវទាំងនេះ សំដៅលើកកំពស់ជីវភាពប្រជាពលរដ្ឋ នៅតាមមូលដ្ឋាន។

ទី២- ស្តារ និងអភិវឌ្ឍបណ្តាញផ្លូវដែក និងជំរុញការប្រើប្រាស់ផ្លូវដែកសំរាប់ការដឹកជញ្ជូនធុនធ្ងន់ ។

ទី៣- លើកកំពស់វិស័យអាកាសចរណ៍ស៊ីវិល ក្នុងទិសដៅធានាការចូលរួមយ៉ាងសកម្មក្នុងការលើក ស្ទួយកំណើនសេដ្ឋកិច្ចជាតិ និងជំរុញវិស័យទេសចរណ៍អោយអភិវឌ្ឍថែមទៀត ។

៣១៩- អាទិភាពសំរាប់រយៈពេលមធ្យមរបស់រាជរដ្ឋាភិបាល មានដូចតទៅ÷

ទី១- បន្តស្តារ និងកសាងឡើងវិញបណ្តាញផ្លូវជាតិសំខាន់ៗ ដើម្បីតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនផ្លូវគោកទូទាំង ប្រទេស ។

ទី២- បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ។

ទី៣- តភ្ជាប់ផ្លូវជាមួយប្រទេសជិតខាង ដើម្បីជំរុញពាណិជ្ជកម្មអន្តរជាតិ និងទេសចរណ៍ ។

ទី៤- បង្កើនចំណូលពីវិស័យដឹកជញ្ជូន ដើម្បីធានាការថែទាំ និងជួសជុលអោយបានជិតដល់ ។

ទី៥- ពង្រឹងការកសាងសមត្ថភាពស្ថាប័នលើផ្នែកគ្រប់គ្រងនិងផែនការកម្មវិស័យហេដ្ឋារចនាសម្ព័ន្ធ ។

ទី៦- ជំរុញការចូលរួមរបស់ផ្នែកឯកជន ក្នុងការធ្វើហិរញ្ញប្បទានសំរាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន ។

ទី៧- កែលំអសុវត្ថិភាពនៅតាមបណ្តាញដឹកជញ្ជូនទាំងអស់ ទាំងផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ។

៣២០- **ការដឹកជញ្ជូនតាមផ្លូវគោក** : បញ្ហាប្រឈមជាចំបងក្នុងការស្តារឡើងវិញនូវបណ្តាញផ្លូវគមនាគមន៍ គឺ ទន្លេមួយចំនួនមិនត្រឹមតែហូរកាត់តំបន់ជនបទប៉ុណ្ណោះទេ តែវាហូរកាត់ផ្លូវជាតិសំខាន់ៗទៀតផង ។ លើសពី នេះ ស្ពានមួយចំនួនធំមានលទ្ធភាពទ្រទំងន់បានត្រឹមតែ២០តោនប៉ុណ្ណោះ ហើយទទួលរងការបាក់ស្រុត ជាញឹកញាប់ ។ ដូចនេះ រាជរដ្ឋាភិបាលនីតិកាលទី ៣ បានផ្តល់អាទិភាពចំបងដល់ការថែទាំជាប្រចាំនូវ បណ្តាញផ្លូវទាំងនេះ ។ ក្រសួងសាធារណការ និងដឹកជញ្ជូន នឹង ÷ ១- រៀបចំផែនការកម្មវិធីថែទាំផ្លូវ ។ ២- ពិនិត្យជំរើសក្នុងការផ្តល់ហិរញ្ញប្បទានគាំទ្រដល់កម្មវិធីថែទាំផ្លូវថ្នល់ ដោយគិតទាំងការបង្កើតមូលនិធិ សំរាប់ថែទាំផ្លូវ ។ ៣- បង្កើតប្រព័ន្ធត្រួតពិនិត្យផ្លូវដោយរួមបញ្ចូលការបង់ប្រាក់ ។ ៤- អនុវត្តបទបញ្ញត្តិស្តីពី ទំងន់យានយន្ត ។ និង ៥- រៀបចំច្បាប់ស្តីពីផ្លូវថ្នល់ និងចរាចរ ដើម្បីកាត់បន្ថយអត្រាគ្រោះថ្នាក់ និងរឹត បន្តឹងការអនុវត្តន៍ច្បាប់សុវត្ថិភាពនៃការបើកបរ ។

៣២១- ដើម្បីធ្វើការស្តារ និងថែទាំប្រព័ន្ធផ្លូវជាតិ និងផ្លូវខេត្តនៅទូទាំងប្រទេស តំរូវការថវិកាមានប្រមាណយ៉ាង តិច ១០០លានដុល្លាក្នុង១ឆ្នាំ ក្នុងនោះ ប្រមាណ៣០ទៅ៤០លានដុល្លា សំរាប់ការថែទាំ ។ លើសពីនេះ

ការស្តារ និងថែទាំផ្លូវលំជនបទត្រូវការថវិកាប្រមាណ ៥០លានដុល្លាបន្ថែមទៀត ជារៀងរាល់ឆ្នាំ ។ យើងមិនរំពឹងថានឹងអាចកៀងគរធនធានទាំងនេះបានគ្រប់ចំនួនឡើយ ។ ដូចនេះ រាជរដ្ឋាភិបាលនឹងកំណត់អាទិភាពនៃតំរូវការ និងត្រូវរៀបចំផែនការស្តីពីការស្តារ និងថែទាំផ្លូវថ្នល់ ។ នៅក្នុងនីតិកាលទី ៣នេះ រាជរដ្ឋាភិបាលបានគ្រោងស្តារ និងជួសជុលឡើងវិញផ្លូវជាតិសំខាន់ៗប្រវែងជាង ២.០០០គម និងផ្លូវខេត្តប្រមាណ១.០០០ គម ។

៣២២- រាជរដ្ឋាភិបាលបានទទួលស្គាល់ថា ទីតាំងភូមិសាស្ត្ររបស់ប្រទេសបានផ្តល់កាលានុវត្តភាពជាយុទ្ធសាស្ត្រសំរាប់រៀបចំមជ្ឈមណ្ឌលគមនាគមន៍ដឹកជញ្ជូនក្នុងមហាអនុតំបន់ទន្លេមេគង្គ ។ រាជរដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់ក្នុងការពង្រីកពាណិជ្ជកម្មថែមទៀត ពិសេសជាមួយបណ្តាប្រទេសអាស៊ាន និងកែលំអប្រព័ន្ធគមនាគមន៍ឆ្លងកាត់ព្រំដែនជាមួយប្រទេសជិតខាង ។ ភាគច្រើននៃផ្លូវជាតិសំខាន់ៗត្រូវបានចាត់ទុកជាផ្លូវអាស៊ី-អាស៊ាន ឬផ្លូវតំបន់ សំរាប់សំរួលដល់គមនាគមន៍ដឹកជញ្ជូនអន្តរជាតិ ពាណិជ្ជកម្ម និងទេសចរណ៍ឆ្លងកាត់ព្រំដែន ។ ផ្លូវជាតិ និងផ្លូវខេត្តផ្សេងទៀតត្រូវបានប្រើប្រាស់ ដើម្បីគាំទ្រផ្លូវអាស៊ី-អាស៊ាន ផ្លូវហាយវ៉េក្នុងតំបន់ និងផ្លូវជាតិសំខាន់ៗ និងដើម្បីពង្រឹងចំណងទំនាក់ទំនង រវាងតំបន់សេដ្ឋកិច្ចនានានៅក្នុងប្រទេស ។ ក្នុងការរៀបចំផែនការវិស័យគមនាគមន៍ កម្ពុជាត្រូវបានបែងចែកជាតំបន់សេដ្ឋកិច្ចធំ ៣ គឺ÷ ទី១-តំបន់ទេសចរណ៍ រួមមាន ខេត្តសៀមរាប ឧត្តរមានជ័យ ព្រះវិហារ និងកំពង់ធំ ។ ទី២-តំបន់កសិឧស្សាហកម្ម និងទេសចរណ៍ធម្មជាតិគ្របដណ្តប់លើតំបន់ប៉ែកខាងកើតទន្លេមេគង្គ រួមមាន ស្ទឹងត្រែង រតនៈគីរី មណ្ឌលគីរី និងក្រចេះ ។ និងទី៣-តំបន់ឧស្សាហកម្មនៅតាមតំបន់ឆ្នេរសមុទ្រភាគខាងត្បូងប្រទេសទាំងមូល ។

៣២៣- ក្នុងក្របខ័ណ្ឌកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់ទន្លេមេគង្គ បណ្តាញផ្លូវថ្នល់ខាងក្រោមនេះនឹងត្រូវស្តារ និងជួសជុលឡើងវិញ÷

- ទី១-បន្តសាងសង់ផ្លូវជាតិលេខ ៦ សំរាប់តភ្ជាប់ខេត្តសៀមរាប និងប្រាសាទអង្គរវត្ត មកទីក្រុងភ្នំពេញ និងប៉ោយប៉ែត ព្រំដែនកម្ពុជា-ថៃ ។
- ទី២-ការលើកកំពស់គុណភាពផ្លូវជាតិលេខ១ និងផ្លូវជាតិលេខ៥ ជាដំណាក់កាលទី១ នៃគំរោងផ្លូវហាយវ៉េ រវាងហូជីមិញ-ភ្នំពេញ-បាងកក (អនុរបៀងកណ្តាលមហាអនុតំបន់ទន្លេមេគង្គ)។ រីឯផ្លូវជាតិលេខ៤៨ លេខ៣ និងលេខ៣១ (អនុរបៀងខាងត្បូងមហាអនុតំបន់ទន្លេមេគង្គ) នឹងត្រូវស្តារឡើងវិញផងដែរ ដើម្បីភ្ជាប់ក្រុងព្រះសីហនុទៅកាន់កំពង់ផែក្រុងបាងកក និងកំពង់ផែធំៗនៅក្នុងតំបន់មួយចំនួនទៀត ។
- ទី៣-ផ្លូវជាតិលេខ៧ នឹងត្រូវស្តារឡើងវិញ ក្រោមជំនួយឧបត្ថម្ភពីសាធារណរដ្ឋប្រជាមានិតចិន ដើម្បីភ្ជាប់ភាគខាងត្បូងនៃប្រទេសឡាវ ជាមួយខេត្តក្រចេះ តភ្ជាប់មកទីក្រុងភ្នំពេញ និងក្រុងព្រះសីហនុ ដោយកាត់តាមផ្លូវជាតិលេខ៤ ជាមួយនឹងការសង់ស្ពានឆ្លងកាត់ទន្លេមេគង្គនៅខេត្តកំពង់ចាម (អន្តររបៀងមហាអនុតំបន់ទន្លេមេគង្គ) ក្រោមជំនួយឧបត្ថម្ភពីរាជរដ្ឋាភិបាលជប៉ុន ។

៣២៤- ក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចកម្ពុជា- ថៃ ផ្លូវខេត្តមួយចំនួននឹងត្រូវស្តារឡើងវិញ ដើម្បីភ្ជាប់កម្ពុជាទៅតំបន់ព្រំប្រទល់កម្ពុជា- ថៃ ។ ការស្តារឡើងវិញនូវផ្លូវជាតិលេខ៧៨ លេខ៧៦អា លេខ៧៨អា លេខ៧៨បេ លេខ៧៦ លេខ៧៤ លេខ៧២ ផ្លូវខេត្តលេខ៣០៣អា លេខ៣០៣បេ ក្នុងខេត្តរតនៈគីរី និងខេត្តមណ្ឌលគីរី នឹងផ្តល់កាលានុវត្តភាពថ្មីមួយទៀត សំរាប់ការដឹកជញ្ជូនទំនិញ និងអ្នកដំណើរ ព្រមទាំងសំរួលពាណិជ្ជកម្ម និងទេសចរណ៍អន្តរជាតិ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងសង្គមកិច្ចទ្វេភាគី និងក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងសង្គមកិច្ចក្នុងតំបន់ត្រីកោណ ។

៣២៥- **ការដឹកជញ្ជូនតាមផ្លូវទឹក** : អាទិភាពសំរាប់កំពង់ផែនិងការដឹកជញ្ជូនតាមផ្លូវទឹក រួមមាន ÷ ការស្តារឡើងវិញនូវម៉ាស៊ីនបូមដី ដើម្បីបូមដីបាតទន្លេ ដែលជាផ្លូវទឹកសំខាន់ៗអោយជាប់ជាប្រចាំ ការលើកកំពស់គុណភាពកំពង់ផែភ្នំពេញ ក៏ដូចជាការកែលំអកំពង់ផែតូចៗតាមដងទន្លេនិងបឹង ព្រមជាមួយនឹងការជួសជុលកំពង់ចំឡងដែលមានស្រាប់ ។ រាជរដ្ឋាភិបាលជំរុញអោយមានការចូលរួមពីអង្គភាពស្វ័យហិរញ្ញប្បទានរបស់ផ្នែកឯកជន ក្នុងការគ្រប់គ្រងនិងថែទាំកំពង់ផែអន្តរជាតិភ្នំពេញ ក្រុងព្រះសីហនុ និងកោះកុង ហើយដែលអាចជួយខេត្តក្នុងការបង្កើតយន្តការហិរញ្ញវត្ថុមូលដ្ឋាន ដើម្បីថែទាំនិងអភិវឌ្ឍកំពង់ផែនៅក្នុងខេត្តរបស់ខ្លួន ។ រាជរដ្ឋាភិបាលនឹងបន្តកែលំអកំពង់ផែក្រុងព្រះសីហនុ តាមរយៈការសាងសង់ផែផ្ទុកថ្មីមួយប្រវែង៤០០ម៉ែត្រ ពង្រីកទីលានសំរាប់ផ្ទុកទំនិញប្រវែង១៦០ម៉ែត្រ កសាងកន្លែងចត ឬជួសជុលរថយន្តដឹកទំនិញទំហំ៦០.០០០ម៉ែត្រក្រឡា ព្រមជាមួយនឹងម៉ាស៊ីនស្ទូចទំនិញ ការកែលំអផ្លូវថ្នល់ ការផ្គត់ផ្គង់ចរន្ត អគ្គិសនី និងប្រព័ន្ធបំភ្លឺនៅតំបន់កំពង់ផែ ។ សន្តិសុខក្នុងតំបន់កំពង់ផែនឹងត្រូវពង្រឹងបន្ថែម ដើម្បីឆ្លើយតបទៅនឹងសន្ធិសញ្ញាស្តីពីការដឹកជញ្ជូនអន្តរជាតិតាមកប៉ាល់ និងសន្តិសុខនៅកំពង់ផែ (Convention on International Shipping and Port Security) ដោយយកចិត្តទុកដាក់ពិសេសនៅកំពង់ផែក្រុងព្រះសីហនុ កំពង់ផែភ្នំពេញ និងកំពង់ផែផ្សេងៗទៀត ដើម្បីទប់ទល់នឹងអំពើភេរវកម្ម ។

៣២៦- ក្នុងឋានៈជាប្រទេសមានដែនសមុទ្រ និងជាសមាជិកនៃអង្គការនាវាចរណ៍ពិភពលោក (International Maritime Organization) រាជរដ្ឋាភិបាលគ្រោងបង្កើតវិទ្យាស្ថានបណ្តុះបណ្តាលនាវាចរណ៍ ដើម្បីបណ្តុះបណ្តាលនាវិក សំរាប់ធ្វើប្រតិបត្តិការស្រាវជ្រាវ និងផ្តល់សេវាសង្គ្រោះដល់នាវាទាំងឡាយ ដែលឆ្លងកាត់ដែនទឹកកម្ពុជា ព្រមទាំងពង្រឹងការគ្រប់គ្រងនាវាដែលប្រើប្រាស់ទង់ជាតិកម្ពុជា និងការពារបូរណភាពដែនទឹករបស់កម្ពុជា ។

៣២៧- **បណ្តាញផ្លូវដែក** : បណ្តាញផ្លូវដែកជាផ្នែកមួយយ៉ាងសំខាន់ក្នុងប្រព័ន្ធដឹកជញ្ជូន។ នាពេលបច្ចុប្បន្ននេះ បណ្តាញផ្លូវដែកទទួលរងការខូចខាតយ៉ាងខ្លាំង និងមិនទាន់ត្រូវបានប្រើប្រាស់អោយអស់លទ្ធភាពនៅឡើយដែរ ។ អាទិភាពជាចំបងរបស់រាជរដ្ឋាភិបាលគឺស្តារឡើងវិញនូវបណ្តាញផ្លូវដែកដែលបានបាត់បង់ប្រមាណ៤៨គម តភ្ជាប់កម្ពុជាទៅកាន់តំបន់ព្រំដែនកម្ពុជា- ថៃ ។ បណ្តាញផ្លូវដែកភាគខាងត្បូងប្រទេសដែលតភ្ជាប់ពីភ្នំពេញទៅកំពង់ផែក្រុងព្រះសីហនុក៏ត្រូវស្តារឡើងវិញផងដែរ ដើម្បីកាត់បន្ថយតំលៃ

ប្រតិបត្តិការ និងដើម្បីបង្កើនលទ្ធភាពប្រកួតប្រជែងជាមួយនឹងការដឹកជញ្ជូនតាមផ្លូវគោក ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងពិនិត្យផងដែរ អំពីលទ្ធភាពស្តារឡើងវិញនូវបណ្តាញផ្លូវដែកភាគខាងជើងប្រទេស ។

៣២៨- **អាកាសចរណ៍ស៊ីវិល** : ការផ្តល់សេវាក្នុងក្របខ័ណ្ឌអាកាសចរណ៍ស៊ីវិល គឺជាបុរេលក្ខខ័ណ្ឌនៃការអភិវឌ្ឍន៍វិស័យទេសចរណ៍ ដែលអាចជះឥទ្ធិពលជាដុំកំភួនដល់ការរីកចំរើននៃសេដ្ឋកិច្ចជាតិ ។ ព្រលានយន្តហោះអន្តរជាតិភ្នំពេញ (ពោធិ៍ចិនតុង) នឹងត្រូវបន្តកែលំអទៀត តាមកិច្ចព្រមព្រៀង BOT ។ រាជរដ្ឋាភិបាលនឹងបន្តលើកកំពស់គុណភាពព្រលានយន្តហោះក្រុងព្រះសីហនុ និងព្រលានយន្តហោះអន្តរជាតិខេត្តសៀមរាប អោយបានស្របនឹងស្តង់ដារអន្តរជាតិ ដើម្បីបំពេញតំរូវការនៃការកើនឡើងនៃទេសចរដែលធ្វើដំណើរទៅកាន់តំបន់ទាំងនោះ ។ លើសពីនេះទៅទៀត ក៏ត្រូវកែលំអអាកាសយានដ្ឋានក្នុងស្រុកមួយចំនួន នៅភាគខាងជើងប្រទេស ដូចជា ព្រលានយន្តហោះនៅខេត្តស្ទឹងត្រែង ខេត្តរតនៈគីរី និងខេត្តមណ្ឌលគីរីជាដើម ។ ដើម្បីឆ្លើយតបនឹងកំរិតស្តង់ដារអន្តរជាតិស្តីពីសុវត្ថិភាព យើងត្រូវការបន្ទាន់នូវប្រព័ន្ធគ្រប់គ្រងចរាចរតាមផ្លូវអាកាស (ATM) និងប្រព័ន្ធទំនាក់ទំនងផ្លូវអាកាស (Communication-Navigation-Surveillance) ។

៣២៩- រាជរដ្ឋាភិបាលទទួលស្គាល់ថា សមត្ថភាពរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងការបំពេញភារកិច្ចរបស់ខ្លួននៅមានកំរិតនៅឡើយ ។ ដូចនេះ រាជរដ្ឋាភិបាលស្នើសុំអោយដៃគូអភិវឌ្ឍន៍របស់កម្ពុជាទាំងអស់ផ្តល់ការគាំទ្រដល់ការកសាងសមត្ថភាព ដើម្បីអាចអោយក្រសួងនេះមានលទ្ធភាពកំណត់ រៀបចំ អនុវត្តគ្រប់គ្រង និងសំរបសំរួលខាងគោលនយោបាយ ព្រមទាំងអាចអនុវត្តគំរោងវិនិយោគអាទិភាពរបស់ខ្លួន ។ រាជរដ្ឋាភិបាលលើកទឹកចិត្តអោយដៃគូអភិវឌ្ឍន៍កម្ពុជាទាំងអស់ ចូលរួមគាំទ្រដល់ក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងការរៀបចំការសិក្សាលើវិស័យទាំងមូល សំរាប់ជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយដឹកជញ្ជូនរយៈពេលវែង ។ នាពេលបច្ចុប្បន្ន ក្រសួងសាធារណការ និងដឹកជញ្ជូនកំពុងធ្វើសហប្រតិបត្តិការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការកែសំរួលរចនាសម្ព័ន្ធរបស់ក្រសួងឡើងវិញ ដើម្បីឆ្លើយតបនឹងតំរូវការនៃធនធានមនុស្ស ។ រាជរដ្ឋាភិបាលស្វាគមន៍ការជួយឧបត្ថម្ភរបស់ដៃគូអភិវឌ្ឍន៍ផ្សេងៗទៀតរបស់កម្ពុជា ដើម្បីកសាងសមត្ថភាពរបស់ក្រសួងនេះ ។

## ការគ្រប់គ្រងធនធានទឹក និង ប្រព័ន្ធធារាសាស្ត្រ

៣៣០- ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ គោលនយោបាយធនធានទឹកជាតិ គឺជាផ្នែកមួយនៃកម្មវិធីទូលំទូលាយរបស់រាជរដ្ឋាភិបាល ដែលផ្តល់ជាមូលដ្ឋានសំរាប់ការពារ គ្រប់គ្រង និងប្រើប្រាស់ទឹកសាប ទឹកប្រៃ និងធនធានទឹកសមុទ្រ ព្រមទាំងជីវសាស្ត្រចំរុះ អោយមានលក្ខណៈចីរភាព ស្មើភាព និងបំរើផលប្រយោជន៍សាធារណៈអោយមានប្រសិទ្ធិភាព ។ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើ÷

១- ការផ្តល់អោយពលរដ្ឋគ្រប់រូប នូវទឹកដែលមានសុវត្ថិភាព និងប្រកបដោយអនាម័យ ។

២- បញ្ចៀសពលរដ្ឋគ្រប់រូបពីការគំរាមកំហែងបាត់បង់ជីវិត ដែលបណ្តាលមកពីភាពចៃដន្យដែលទាក់ទងនឹងទឹក ។

៣- ផ្តល់ទឹកគ្រប់គ្រាន់ដល់កន្លែងណាដែលត្រូវការ ដើម្បីធានាបាននូវសន្តិសុខស្បៀង ការរស់នៅរបស់ប្រជាជន និងសកម្មភាពសេដ្ឋកិច្ច ព្រមទាំងកំរិតជីវភាពរស់នៅសមរម្យរបស់ប្រជាជន ។

៤- ធានាបរិស្ថានទឹកដែលគ្មានជាតិពុល និងការទ្រទ្រង់ជីវិតមច្ឆា និងប្រព័ន្ធអេកូឡូស៊ី ដែលរស់នៅក្នុងទឹក ។

៣៣១- នៅក្នុងនីតិកាលទី៣នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តការងារអាទិភាព ដូចតទៅ÷ ទី១- អភិវឌ្ឍ និងពង្រីកប្រព័ន្ធស្រោចស្រពផ្ទៃដី ។ ទី២- គ្រប់គ្រងធនធានទឹក ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការបង្កើនប្រសិទ្ធិភាពក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ។ ទី៣- បន្តបង្កើតនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសំរាប់សហគមន៍អ្នកប្រើប្រាស់ទឹក ។ និងទី៤- កាត់បន្ថយភាពងាយរងគ្រោះពីគ្រោះធម្មជាតិ និងការពឹងផ្អែកទាំងស្រុងលើលក្ខខ័ណ្ឌធម្មជាតិ ។

៣៣២- ដើម្បីអភិវឌ្ឍ និងពង្រីកប្រព័ន្ធស្រោចស្រពផ្ទៃដី ក្រសួងធនធានទឹក និងឧតុនិយមនឹងអនុវត្តនូវផែនការសកម្មភាពសំខាន់ៗ ដូចខាងក្រោម ដើម្បីធានាអោយមានទឹកគ្រប់គ្រាន់សំរាប់បំរើផលិតកម្មកសិកម្ម÷

១- ស្តារ និងសាងសង់ឡើងវិញនូវប្រព័ន្ធធារាសាស្ត្រ ដែលមានស្រាប់ក្នុងគោលបំណងឆ្លើយតបជាបន្ទាន់នូវតំរូវការទឹកសំរាប់កសិកម្ម ។

២- ប្រើប្រាស់បច្ចេកទេសសមស្របក្នុងការគ្រប់គ្រងទឹក សំរាប់តំបន់ទទួលទឹកភ្លៀងនិមួយៗ ។

៣- ជំរុញអោយមានការពង្រឹង និងពង្រីកបន្ថែមនូវអាងតំកល់ទឹក ស្រះទឹក ប្រឡាយនាំទឹក និងប្រព័ន្ធបញ្ចេញ- បញ្ចូលទឹក ដើម្បីធានាការផ្គត់ផ្គង់ទឹក និងចីរភាពខាងបរិស្ថាន ។

៤- ពង្រីកផ្ទៃដីដោយប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធបញ្ចេញ- បញ្ចូលទឹក នៅតាមតំបន់ដែលភាពក្រីក្រមានកំរិតខ្ពស់ ។

៥- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងដល់មន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ដើម្បីអនុវត្តយុទ្ធសាស្ត្រស្រោចស្រព និងដោះទឹក។

៦- កៀងគរការចូលរួមរបស់ប្រជាកសិករ អ្នកពាក់ព័ន្ធ និងផ្នែកឯកជន នៅគ្រប់ដំណាក់កាលនៃការរៀបចំគំរោង ការកែលំអ និងការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធបញ្ចេញ- បញ្ចូលទឹក ។

៧- សិក្សា និងរៀបចំផែនការអភិវឌ្ឍអាងទន្លេសំរាប់រយៈពេលខ្លី មធ្យម និងវែង ព្រមទាំងគិតគូរដល់ការប្រែប្រួលធារទឹកទន្លេ ការផ្លាស់ប្តូរចរន្តទឹក និងល្បាងទឹកធម្មជាតិក្រោមដី ដើម្បីធានាដល់ការប្រើប្រាស់ធនធានទឹក នាពេលបច្ចុប្បន្ន និងពេលអនាគត ។

៨- រៀបចំអភិក្រមចំរុះស្តីពីការអភិវឌ្ឍន៍ និងការគ្រប់គ្រងធនធានទឹក ដោយគិតគូរអោយបានច្បាស់លាស់នូវប្រភពទឹកទាំងអស់ និងការផ្សាភ្ជាប់គ្នារវាងធនធានទឹកជាមួយនឹងផលិតកម្មកសិកម្ម

យុទ្ធសាស្ត្រ និងការគ្រប់គ្រងប្រើប្រាស់ដីធ្លី ព្រមទាំងការងារបរិស្ថាន ។ ដើម្បីរក្សាប្រភពទឹក ក្រោមដី អាទិភាពត្រូវបានផ្តោតទៅលើការអភិវឌ្ឍន៍ធនធានទឹកនៅតាមទន្លេ និងស្ទឹង ។

៩- ពង្រឹងសមត្ថភាពរបស់សហគមន៍កសិករប្រើប្រាស់ទឹក (ស.ក.ប.ទ) ដើម្បីជំរុញការគ្រប់គ្រង និងការអភិវឌ្ឍន៍ ប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួម ព្រមទាំងស្វែងរកការគាំទ្រវិនិយោគពីភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ និងពីផ្នែកឯកជន ដើម្បីទ្រទ្រង់ដល់ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួមនេះ ។

៣៣៣- ដើម្បីធានាការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធិភាព ក្រសួងធនធានទឹក និងឧតុនិយមនឹងអនុវត្តសកម្មភាពសំខាន់ៗ ដូចខាងក្រោម ដើម្បីបង្កើនប្រសិទ្ធិភាពនៃប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ÷

១- ពង្រឹង និងជំរុញការអនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន អនុក្រឹត្យស្តីពីការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ និងបទបញ្ញត្តិពាក់ព័ន្ធនានាដើម្បីត្រួតពិនិត្យនិងទប់ស្កាត់នូវរាល់គំរោងសាងសង់នានា ដែលអាចមានផលប៉ះពាល់មកលើធនធានទឹកក៏ដូចជាប្រព័ន្ធអេកូឡូស៊ី ។

២- រៀបចំ និងអនុវត្តនីតិវិធីសិក្សាវាយតម្លៃផលប៉ះពាល់មកលើបរិស្ថាន និងសង្គម ព្រមទាំងវិធានការសិក្សារាំងខ្ទប់បាតុភាពទាំងនេះ ។

៣- រក្សាអោយបាននូវធារទឹកទន្លេ និងកំរិតកំពស់អប្បបរមានៃទឹកទន្លេ ស្ទឹង បឹងបួរ ព្រែក ដើម្បីធានាដល់ប្រព័ន្ធអេកូឡូស៊ី និងតំលៃខាងសង្គមនិងវប្បធម៌ ព្រមទាំងការធ្វើចរាចររបស់នាវា ។

៤- ហាមឃាត់ និងមានវិធានការជាបន្ទាន់ចំពោះសកម្មភាពលុបបំពេញ ការជីក ឬការរំលោភលើផ្លូវទឹកទន្លេ ស្ទឹង បឹងបួរ ព្រែក ឬក៏ដីទំនាបដែលលិចទឹកជាប្រចាំ និងសមុទ្រ ដោយគ្មានច្បាប់អនុញ្ញាត ហើយដែលអាចប៉ះពាល់ដល់ធនធានទឹក ក៏ដូចជាប្រព័ន្ធអេកូឡូស៊ី និងបរិស្ថាន ។

៥- ពង្រឹងកិច្ចអភិរក្សអាងទឹក និងបឹងបួរធម្មជាតិ ដែលមានលទ្ធភាពស្តុកទឹក ដើម្បីកាត់បន្ថយទឹកជំនន់ និងរក្សាបានប្រព័ន្ធអេកូឡូស៊ី ។

៦- បន្តពង្រឹង និងពង្រីកបន្ថែមនូវសហគមន៍កសិករប្រើប្រាស់ទឹក ដើម្បីចូលរួមក្នុងការគ្រប់គ្រង និងការបែងចែកទឹក ព្រមទាំងថែរក្សាបាននូវប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធិភាព និងចីរភាព ។

៣៣៤- ដើម្បីបន្ថយឥទ្ធិពលនៃគ្រោះមហន្តរាយធម្មជាតិមកលើប្រជាជន ក្រសួងធនធានទឹក និងឧតុនិយម នឹងចាត់វិធានការដូចខាងក្រោម ÷

ទី១- សិក្សាដើម្បីឈានទៅស្តារ និងកសាងប្រព័ន្ធទំនប់ការពារទឹកជំនន់ និងប្រព័ន្ធបញ្ចេញ- បញ្ចូលទឹក ដើម្បីកាត់បន្ថយការជះឥទ្ធិពលអាក្រក់នៃគ្រោះមហន្តរាយធម្មជាតិ ។

ទី២- ពង្រឹងសមត្ថភាពរបស់ក្រសួង ក្នុងការផ្តល់ពត៌មានស្តីពីការព្យាករណ៍អាកាសធាតុ និងទឹកជំនន់ តាមរយៈ ÷

- តំឡើងប្រព័ន្ធអង្កេតឧតុនិយម ដែលផ្តល់នូវទិន្នន័យឧតុនិយមជាក់លាក់ សំរាប់ការព្យាករណ៍ និងប្រព័ន្ធទិន្នន័យធាតុអាកាសសំរាប់ប្រើប្រាស់ក្នុងវិស័យកសិកម្ម និងការងារដទៃទៀត ។
- ពង្រឹង និងកសាងស្ថានីយ៍ជលសាស្ត្រ និងឧតុនិយម នៅតាមដងទន្លេមួយចំនួន និងការផ្សព្វផ្សាយពត៌មាន ។
- តំឡើងប្រព័ន្ធអង្កេតជលសាស្ត្រ ដែលផ្តល់នូវកំរិតកំពស់ទឹកជាក់លាក់ និងទិន្នន័យធារទឹកសំរាប់ការព្យាករណ៍ ។
- ទិន្នន័យជលសាស្ត្រ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំគំរោងដែលពាក់ព័ន្ធនឹងធនធានទឹក ការគ្រប់គ្រងធនធានទឹក និងសំរាប់គោលបំណងផ្សេងៗទៀត។

ទី៣- ពង្រឹងសមត្ថភាពក្នុងការឆ្លើយតបនឹងតំរូវការរបស់ប្រជាជន ដែលរងគ្រោះដោយសារគ្រោះរាំងស្ងួត និងទឹកជំនន់ ព្រមទាំងគ្រោះថ្នាក់ផ្សេងៗទៀតដែលបង្កឡើងដោយទឹក ។

ទី៤- រៀបចំ និងផ្សព្វផ្សាយពត៌មានដល់ប្រជាជន និងស្ថាប័នគ្រប់ជាន់ថ្នាក់ ដើម្បីអោយចូលរួមចាត់វិធានការសំរាប់កាត់បន្ថយគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ។

ទី៥- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគណៈកម្មាធិការទន្លេមេគង្គ ក្នុងការចាត់វិធានការទប់ទល់នឹងទឹកជំនន់ និងជាមួយកម្មវិធីអន្តរជាតិផ្សេងៗទៀត ដើម្បីកាត់បន្ថយគ្រោះថ្នាក់ ដែលបង្កឡើងដោយទឹក ។

## ការអភិវឌ្ឍន៍វិស័យថាមពល និងបណ្តាញអគ្គិសនី

៣៣៥- ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍន៍វិស័យថាមពល គឺធានាការផលិត និងការផ្គត់ផ្គង់ថាមពលអគ្គិសនី ដែលអាចឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងក្នុងតំលៃថោកសមរម្យ នឹងតំរូវការនៃការប្រើប្រាស់ដែលចេះតែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃរបស់ប្រជាពលរដ្ឋ ។ ការអភិវឌ្ឍន៍វិស័យ នេះទាមទារនូវថវិកាមូលធនយ៉ាងច្រើន ព្រមជាមួយនឹងការពង្រឹងសមត្ថភាពខាងស្ថាប័នទទួលខុសត្រូវនៅថ្នាក់ជាតិក្នុងការរៀបចំគំរោង ក្នុងកិច្ចប្រតិបត្តិការ និងក្នុងការថែទាំប្រព័ន្ធចែកចាយថាមពលទាំងនេះ ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលផ្តល់អាទិភាពខ្ពស់ ទៅលើការចូលរួមរបស់ផ្នែកឯកជននៅក្នុងផ្នែកផលិត និងនៅក្នុងប្រព័ន្ធចែកចាយថាមពលអគ្គិសនី ។

៣៣៦- ដោយសារមូលធនរបស់រដ្ឋនៅមានកំរិតនៅឡើយ ក្នុងការអនុវត្តន៍អោយបានសំរេចនូវទស្សនៈវិស័យនេះ រាជរដ្ឋាភិបាលបានកំណត់នូវយុទ្ធសាស្ត្ររយៈពេលខ្លី និងមធ្យមរបស់ខ្លួនដូចខាងក្រោម ÷

១- បន្តស្តារ និងសាងសង់បន្ថែមរោងចក្រផលិតថាមពលអគ្គិសនី ផ្អែកលើធនធានដែលមានស្រាប់ ។

២- បន្តជាវថាមពលអគ្គិសនីពីប្រទេសជិតខាង តាមរយៈការចុះកិច្ចព្រមព្រៀងទ្វេភាគី ។

៣- បន្តពង្រីកប្រព័ន្ធចែកចាយថាមពលអគ្គិសនីឱ្យដល់បណ្តាតំបន់ឆ្ងាយៗ តាមរយៈការសាងសង់រោងចក្រអគ្គិសនីបន្ថែម និងការជាវថាមពលពីប្រទេសជិតខាង ។

៣៣៧- នៅក្នុងនីតិកាលទីបីនេះ រាជរដ្ឋាភិបាលគ្រោងតំលើងរោងចក្រផលិតថាមពលអគ្គិសនីនៅស្ទឹងកំចាយ ស្ទឹងបាត់ដំបង ស្ទឹងអាទៃ និងស្ទឹងឬស្សីជ្រុំ និងតំលើងរោងចក្រថាមពលដើរដោយកំដៅនៅតំបន់មាត់សមុទ្រ ។ គំរោងសាងសង់ស្ថានីយ៍វារីអគ្គិសនីគីរីរម្យទី ៣ (១៣ MW) និងស្ទឹងកំចាយ (១៨០ MW) នឹងត្រូវអភិវឌ្ឍដោយការចូលរួមរបស់ផ្នែកឯកជន ហើយគ្រោងបញ្ចប់នៅត្រឹមដំណាច់ឆ្នាំ ២០១០ ។ ព្រមជាមួយគ្នានេះ គំរោងវារីអគ្គិសនីស្ទឹងឬស្សីជ្រុំកណ្តាល (១២៥ MW) នឹងត្រូវស្ថាបនាក្រោមក្របខ័ណ្ឌសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា និងប្រទេសចិន ។ ការសិក្សាពីសក្តានុពលភាពនៃទំនប់វារីអគ្គិសនី នៅស្ទឹងមេទឹក នឹងត្រូវធ្វើឡើងដោយប្រើកំចីពីរាជរដ្ឋាភិបាលថៃ ។ ចំណែកឯការស្ថាបនារោងចក្រអគ្គិសនីដែលប្រើឧស្ម័នធម្មជាតិនៅក្រុងព្រះសីហនុ ដែលមានអានុភាព ១៨០ MW នឹងត្រូវអនុវត្តជាពីរដំណាក់កាល (៩០ MW + ៩០MW) ដោយរំពឹងថានឹងទទួលហិរញ្ញប្បទានពីរាជរដ្ឋាភិបាលជប៉ុន ។ ដំណាក់កាលទី ១ នៃការសាងសង់នឹងត្រូវបញ្ចប់នៅឆ្នាំ ២០០៨ ។ គំរោងវារីអគ្គិសនីស្រែពកក្រោមទី២ ក៏រំពឹងថានឹងបានទទួលហិរញ្ញប្បទានពីរាជរដ្ឋាភិបាលជប៉ុនផងដែរ ។

៣៣៨- រាជរដ្ឋាភិបាលនឹងពង្រីកបន្ថែមទៀតបណ្តាញបញ្ជូននិងចែកចាយថាមពល ។ ផែនការមេសំរាប់ប្រព័ន្ធបញ្ជូននិងបែងចែកថាមពលអគ្គិសនីរបស់រាជរដ្ឋាភិបាល គ្រោងនឹងស្តារ និងស្ថាបនាឡើងវិញនូវបណ្តាញចែកចាយថាមពលអគ្គិសនី ដូចតទៅ÷

- បណ្តាញបញ្ជូនជាតិភាគខាងត្បូង ២២០kv តភ្ជាប់ពីប្រទេសវៀតណាម មកទីក្រុងភ្នំពេញ ដោយឆ្លងកាត់ខេត្តតាកែវ នឹងត្រូវបញ្ចប់នៅក្នុងឆ្នាំ ២០០៧ ក្រោមជំនួយឧបត្ថម្ភពី ADB និង NDF។
- គំរោងសាងសង់ខ្សែបញ្ជូនថាមពលតង់ស្យុងខ្ពស់ ២៣០kv តាកែវ- កំពត នឹងបញ្ចប់ក្នុងឆ្នាំ ២០០៧ ក្រោមការជួយឧបត្ថម្ភពីអាល្លឺម៉ង់ រួមជាមួយអនុស្ថានីយ៍ ២៣០/១១៥/២២ kv ដែលនឹងត្រូវតំឡើងនៅពាក់កណ្តាលផ្លូវនៅស្រុកឈូកដើម្បីផ្គត់ផ្គង់ការប្រើប្រាស់នៅតំបន់នោះ ព្រមទាំងបណ្តាញអគ្គិសនី ១១៥kv តភ្ជាប់ពីឈូកទៅបន្ទាយមាស សំរាប់ផ្គត់ផ្គង់តំបន់នោះ ពិសេស រោងចក្រផលិតជី និងស៊ីម៉ង់តិ៍ ។
- បណ្តាញបញ្ជូនជាតិតង់ស្យុងខ្ពស់ ២៣០kv តភ្ជាប់ពីកំពតទៅក្រុងព្រះសីហនុ ដើម្បីផ្គត់ផ្គង់ថាមពលអោយក្រុងព្រះសីហនុ ពិសេសអោយតំបន់ឧស្សាហកម្ម ដោយរំពឹងថានឹងបញ្ចប់ការស្ថាបនានៅឆ្នាំ ២០០៨ ក្រោមការឧបត្ថម្ភពី ADB និងអាល្លឺម៉ង់ ។ បណ្តាញនេះនឹងត្រូវប្រើប្រាស់ផងដែរសំរាប់បញ្ជូនថាមពលពីស្ថានីយ៍ដើរដោយកំដៅ ១៨០ MW ពីក្រុងព្រះសីហនុ មករាជធានីភ្នំពេញ ។
- បណ្តាញតភ្ជាប់ខ្សែបញ្ជូនថាមពលតង់ស្យុងខ្ពស់ ១១៥kv ពីព្រំដែនថៃមកខេត្តបន្ទាយមានជ័យ សៀមរាប និងបាត់ដំបង ក៏ត្រូវស្ថាបនាដោយដៃគូអភិវឌ្ឍន៍ឯកជនដែរ ហើយរំពឹងថានឹងត្រូវបញ្ចប់ នៅក្នុងឆ្នាំ២០០៧ ផងដែរ។

- ការសិក្សាពីសក្តានុពលភាពក្នុងការស្ថាបនាបណ្តាញតភ្ជាប់ប្រព័ន្ធបញ្ជូនភាគខាងជើង និងភាគខាង ត្បូង គ្រោងនឹងធ្វើឡើងដោយក្រុមហ៊ុន POSCON នៅក្នុងពេលឆាប់ៗខាងមុខនេះ ។ បន្ទាប់ពីការសិក្សារួចមក ការសាងសង់នឹងអាចចាប់ផ្តើមដំណើរការភ្លាមដែរ ។

៣៣៩- រាជរដ្ឋាភិបាលនឹងពិនិត្យឡើងវិញជាទៀងទាត់ នូវកិច្ចព្រមព្រៀងជាវថាមពលពីបណ្តាប្រទេសជិតខាង ។ រីឯបរិមាណនាំចូលថាមពលអគ្គិសនីក៏ត្រូវចរចាឡើងវិញដែរ ដើម្បីធានាការនាំចូលថាមពលអាចឆ្លើយតបតាមតម្រូវការរបស់ប្រទេស ។

**ការអភិវឌ្ឍន៍បច្ចេកវិទ្យាពត៌មាន និងទូរគមនាគមន៍**

៣៤០- ចក្ខុវិស័យជាយុទ្ធសាស្ត្ររយៈពេលវែងរបស់រាជរដ្ឋាភិបាល គឺអភិវឌ្ឍប្រព័ន្ធប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានគុណភាពខ្ពស់ ថ្លៃថោកសមរម្យ ស្របតាមស្តង់ដារអន្តរជាតិ និងមានសេវាកម្មទំនើបគ្របដណ្តប់ទូទាំងប្រទេស ។ ការសំរេចអោយបាននូវចក្ខុវិស័យនេះ ទាមទារអោយមានការវិនិយោគនៅលើបណ្តាញហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ សំរាប់បំរើអោយផ្នែកបច្ចេកវិទ្យាពត៌មាន និងទូរគមនាគមន៍ ពិសេសបណ្តាញខ្សែកាបអុបទិចដែលមានសមត្ថភាពខ្ពស់ ដែលអាចចូលរួមអភិវឌ្ឍបណ្តាញទូរគមនាគមន៍ជនបទ ប្រកបដោយប្រសិទ្ធភាពផងដែរ ។

៣៤១- ក្នុងនីតិកាលទីបីនេះ រាជរដ្ឋាភិបាលនឹងបន្តពង្រីកបណ្តាញទូរគមនាគមន៍ពីក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងខេត្តសៀមរាប ទៅកាន់បណ្តាទីប្រជុំជនដទៃទៀត ។ រាជរដ្ឋាភិបាលនឹងបង្កើតអោយមានទំនាក់ទំនងតាមរលកធាតុអាកាសកំរិតទាប ឬទំនាក់ទំនងតាមខ្សែកាបអុបទិច ដើម្បីតភ្ជាប់ ÷ ទី១- កំពង់ចាម- ភ្នំពេញ- តាកែវ- កំពត- ក្រុងព្រះសីហនុ ។ ទី២- កំពង់ចាម- កំពង់ធំ- សៀមរាប- ស៊ីសុផុន ។ ទី៣- កំពង់ចាម- ក្រចេះ- ស្ទឹងត្រែង ។ និង ទី៤- មណ្ឌលគីរី- ប៉ៃលិន- ព្រះវិហារ- ឧត្តរមានជ័យ ។ រីឯរចនាសម្ព័ន្ធប្រៃសណីយ៍ ព្រមទាំងសមត្ថភាពខាងផ្នែកស្ថាប័ន ក៏ត្រូវពង្រឹងអោយបានរឹងមាំដែរ ដើម្បីបង្កើនគុណភាពសេវានេះអោយកាន់តែប្រសើរឡើង ។ ព្រមជាមួយគ្នានេះ បណ្តាញផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ក៏ត្រូវពង្រឹងផងដែរ ក្នុងគោលដៅបង្កើនប្រសិទ្ធភាព ។ រាជរដ្ឋាភិបាលនឹងដាក់ចេញនូវបទដ្ឋានថ្នាក់ជាតិសំរាប់រៀបចំផែនការវិនិយោគ និងកិច្ចប្រតិបត្តិការនៅក្នុងគ្រប់សេវាទូរគមនាគមន៍ និងបច្ចេកវិទ្យាពត៌មាន រួមមានប្រព័ន្ធស្តង់ដារ និងបទដ្ឋានសំរាប់ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាពត៌មាន និងអ៊ិនទែរណិតផងដែរ ។

៣៤២- រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្តន៍គោលនយោបាយស្តីពីការបើកទូលាយផ្នែកបច្ចេកវិទ្យាពត៌មាន និងទូរគមនាគមន៍ សំរាប់លើកទឹកចិត្តការចូលរួមរបស់វិស័យឯកជន ដោយគ្មានការរើសអើង និងដោយឈរលើមូលដ្ឋាននៃការប្តេជ្ញាចិត្ត ព្រមទាំងកាតព្វកិច្ចទាំងឡាយរបស់កម្ពុជា ក្នុងក្របខ័ណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក ។

### ៤.៣.៣ ការអភិវឌ្ឍន៍វិស័យឯកជន និងការងារ

> **ការអភិវឌ្ឍន៍វិស័យឯកជន និងការងារ**
> - ការពង្រឹងវិស័យឯកជននិងទាក់ទាញវិនិយោគ
> - ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម
> - ការបង្កើតការងារ និងលក្ខខ័ណ្ឌការងារល្អប្រសើរ
> - ប្រព័ន្ធសុវត្ថិភាពសង្គមសំរាប់និយោជិត

៣៤៣- ការអភិវឌ្ឍន៍ផ្នែកឯកជននិងការងារ ជាចតុកោណទីបីក្នុងចំណោមចតុកោណយុទ្ធសាស្ត្រ សំរាប់កំណើនទាំងបួននៃយុទ្ធសាស្ត្រចតុកោណ ។ ចតុកោណនេះមានមុំយុទ្ធសាស្ត្របួន គឺ÷ទី១- ការពង្រឹងវិស័យ ឯកជន និងការទាក់ទាញការវិនិយោគ ។ ទី២- ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម ។ ទី៣- ការបង្កើតការងារ និងការធានាលក្ខខ័ណ្ឌការងារល្អប្រសើរ ។ និងទី៤- ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គមសំរាប់មន្ត្រី បុគ្គលិក កម្មករ ។ យុទ្ធសាស្ត្រនិង អាទិភាពក្នុងផ្នែកនីមួយៗខាងលើ មានដូចខាងក្រោម ។

### ការពង្រឹងវិស័យឯកជន និងការទាក់ទាញវិនិយោគ

៣៤៤- ដូចដែលបានគូសបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រចតុកោណ រាជរដ្ឋាភិបាលចាត់ទុកវិស័យឯកជន ជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច ។ រាជរដ្ឋាភិបាលនឹងបន្តតួនាទីជាយុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីបង្កើតបរិស្ថាន ធុរកិច្ចអោយកាន់តែប្រសើរសំរាបវិស័យឯកជន និងការគ្រប់គ្រងការអភិវឌ្ឍន៍ ។ រាជរដ្ឋាភិបាលនឹងបន្ត កិច្ចខិតខំប្រឹងប្រែងដើម្បីបើកច្រកចូលទៅកាន់ទីផ្សារអន្តរជាតិដ៏ធំទូលាយ តាមរយៈ ១- ការអនុវត្តន៍គោលនយោបាយសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក ។ ២- ការជំរុញអនុវត្តយ៉ាងសកម្ម នូវការស្តារនិងអភិវឌ្ឍន៍ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជាតិ ទាំងផ្នែករឹង ទាំងផ្នែកទន់ ។ ៣- ការបន្តពង្រឹងក្របខ័ណ្ឌច្បាប់ ព្រមទាំងបទបញ្ញត្តិ និងសមត្ថភាពស្ថាប័ន ដែលសំរួលដល់សកម្មភាពធុរកិច្ចពាណិជ្ជកម្ម និងការវិនិយោគទុនឯកជន ជាពិសេសសំរាប់ការប្រកួតប្រជែងដោយយុត្តិធម៌ តំលាភាពគណនេយ្យភាព និងសំរាប់ភាពជាដៃគូប្រកបដោយផ្លែផ្កាវវាងវិស័យឯកជនជាមួយនឹងវិស័យសាធារណៈ ។

៣៤៥- រាជរដ្ឋាភិបាលបានកំណត់ថា ការកែលំអបរិស្ថានសំរាប់ធុរកិច្ច និងការបង្កើតបរិស្ថានអំណោយផល សំរាប់ កិច្ចអភិវឌ្ឍន៍វិស័យឯកជន គឺជាបុរេលក្ខខ័ណ្ឌសំរាប់ជំរុញកំណើនសេដ្ឋកិច្ច បង្កើតការងារ កាត់បន្ថយ ភាពក្រីក្រ និងអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ។ ដើម្បីលុបបំបាត់កត្តារាំងស្ទះដល់ការអភិវឌ្ឍន៍វិស័យ ឯកជន និងក្នុងដំណើរការកំណែទំរង់រដ្ឋបាល និងតតិយុត្តិ រាជរដ្ឋាភិបាលបានបង្កើតវេទិការវាងរាជ រដ្ឋាភិបាល និងឯកជនចាប់តាំងពីឆ្នាំ១៩៩៩ ហើយមានការជួបប្រជុំទៀងទាត់រៀងរាល់៦ខែម្តង ដោយមានការគាំទ្រពីក្រុមការងារទាំង ៧ ។ ក្រុមការងារទាំងនេះបានជួបប្រជុំរៀងរាល់ខែ ដើម្បីដោះស្រាយបញ្ហាទាំងឡាយ ។ លើសពីនេះ ដើម្បីបន្តពង្រឹងយន្តការខាងស្ថាប័ន សំរាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ នៅក្នុងវេទិការវាងរាជរដ្ឋាភិបាលនិងផ្នែកឯកជន នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៤ កន្លងមក សម្តេច នាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានប្រកាសអំពីការបង្កើតគណៈកម្មាធិការដឹកនាំការងារសំរាប់ការអភិវឌ្ឍន៍ផ្នែកឯកជន ដោយមានឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន ឯកឧត្តម ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជាអនុប្រធាន និងឯកឧត្តម អគ្គទេសាភិបាលធនាគារជាតិកម្ពុជា និងឯកឧត្តម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងទេសចរណ៍ ជាសមាជិក ព្រមទាំងឯកឧត្តម អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអគ្គលេខាធិការ ។ គណៈកម្មាធិការនេះមានភារកិច្ចដូចតទៅ÷

១- ធ្វើជាសេនាធិការអោយប្រមុខរាជរដ្ឋាភិបាល ក្នុងការដឹកនាំ និងតាមដានការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណលើចំណុចទាំងឡាយពាក់ព័ន្ធនឹងការអភិវឌ្ឍន៍វិស័យឯកជន ។

២- លើកឡើង និងដាក់អោយអនុវត្តនូវវិធានការកែលំអបរិស្ថានវិនិយោគ ។

៣- លើកឡើង និងដាក់អោយអនុវត្តនូវវិធានការសំរួលពាណិជ្ជកម្ម ។

៤- លើកឡើង និងដាក់អោយអនុវត្តនូវវិធានការលើកកំពស់សហគ្រាសតូច និងមធ្យម ។ និង

៥- លើកឡើង និងដាក់អោយអនុវត្តនូវវិធានការដទៃទៀត ដើម្បីជំរុញការអភិវឌ្ឍន៍ផ្នែកឯកជន ។

៣៤៦- គណៈកម្មាធិការដឹកនាំការងារនេះមានអនុគណៈកម្មាធិការចំនួន ៣ សំរាប់ជួយការងារតាមវិស័យសំខាន់ៗ ចំនួន ៣ គឺ ÷ ១- អនុគណៈកម្មាធិការបរិស្ថានវិនិយោគ និងការចូលរួមរបស់ផ្នែកឯកជនក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ២- អនុគណៈកម្មាធិការសំរួលពាណិជ្ជកម្ម ដឹកនាំដោយឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។ ៣- អនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម ដឹកនាំដោយឯកឧត្តម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ គណៈកម្មាធិការដឹកនាំការងារ និងអនុគណៈកម្មាធិការទាំង៣នឹងបំពេញការងាររបស់ខ្លួនជាមួយដៃគូអភិវឌ្ឍន៍នានា ដែលមានបំណងជួយកម្ពុជាក្នុងការអភិវឌ្ឍន៍ផ្នែកឯកជន រួមមាន ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ UNDP JICA AusAid GTZ AFD និងអ្នកផ្តល់ជំនួយផ្សេងៗទៀត តាមរយៈអភិក្រមនៃការគ្រប់គ្រងទូទាំងផ្ទៃវិស័យសំរាប់អភិវឌ្ឍផ្នែកឯកជន ។

៣៤៧- រាជរដ្ឋាភិបាលនឹងបន្តសំរួល និងគាំទ្រវិនិយោគឯកជន នៅតាមវិស័យអាទិភាពទាំង ៦ គឺ÷

១- ការអភិវឌ្ឍន៍វិស័យកសិកម្ម និងកសិឧស្សាហកម្ម ក្នុងនោះផ្តល់អាទិភាពលើការដោះស្រាយទឹកសំរាប់កសិកម្ម ។

២- ការអភិវឌ្ឍន៍ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដឹកជញ្ជូន និងទូរគមនាគមន៍ ។

៣- ការអភិវឌ្ឍន៍វិស័យថាមពល និងអគ្គិសនី ។

៤- វិស័យឧស្សាហកម្មអតិពលកម្ម និងឧស្សាហកម្មកែច្នៃសំរាប់ការនាំចេញ ។

៥- វិស័យឧស្សាហកម្មទេសចរណ៍ ។

៦- ការអភិវឌ្ឍន៍ធនធានមនុស្ស ។

៣៤៨- ក្នុងការរៀបចំអោយកាន់តែប្រសើរឡើងនូវបរិស្ថានរួមសំរាប់ការអភិវឌ្ឍន៍របស់វិស័យឯកជន អាទិភាពចំបងរបស់រាជរដ្ឋាភិបាលនៅក្នុងនីតិកាលទី ៣ នេះ គឺប្រកាន់យកនូវវិធានការជាក់ស្តែងនានាដែលសំដៅ÷

- ពង្រឹងអភិបាលកិច្ចទាំងនៅក្នុងវិស័យសាធារណៈ ទាំងនៅក្នុងវិស័យឯកជន ។
- សំរួលពាណិជ្ជកម្ម និងកែលំអបរិយាកាសវិនិយោគ ។
- ជំរុញការអភិវឌ្ឍន៍ធនធានមនុស្សអោយឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងតំរូវការទីផ្សារ ។

៣៤៩- ដើម្បីសំរួលកិច្ចការពាណិជ្ជកម្ម រាជរដ្ឋាភិបាលនឹងប្រកាន់យកវិធានការដូចតទៅ÷

១- ធ្វើវិចារណកម្មទំរង់ការនានារបស់រាជរដ្ឋាភិបាល ដែលបង្កើតអោយមានចំណាយខ្ពស់ និងមានភាពយឺតយ៉ាវក្នុងការអនុម័តវិនិយោគរបស់ផ្នែកឯកជន ក្នុងនោះមាន អង្គភាពដែលស្ថិតនៅក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិសេស ទីចាត់ការគយនិងរដ្ឋាករ ក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសង្គមកិច្ច និងក្រសួងការងារ ។

២- កាត់បន្ថយចំណាយប្រតិបត្តិការរបស់ផ្នែកឯកជនលើការនាំចូល- នាំចេញ ស្របពេលជាមួយនឹងការបង្កើនចំណូលផ្លូវការរបស់រាជរដ្ឋាភិបាល ។

៣- កាត់បន្ថយចំណាយប្រតិបត្តិការបន្ថែមមិនចាំបាច់ និងត្រួតលើគ្នា ក្នុងការគ្រប់គ្រងកិច្ចដំណើរការពាណិជ្ជកម្ម ។

៤- កាត់បន្ថយពេលវេលាសំរាប់ការនាំចេញ- នាំចូលទំនិញ ។

៥- បង្កើនកំរិតប៉ាន់ប្រមាណបានអំពីពេលវេលា និងចំណាយលើដំណើរការនាំចេញ- នាំចូល ។ និង

៦- រក្សាសង្គតិភាពជាមួយគោលការណ៍ណែនាំរបស់អង្គការពាណិជ្ជកម្មពិភពលោក និងអង្គការគយពិភពលោក ក្នុងការសំរួលពាណិជ្ជកម្ម ។

៣៥០- ដើម្បីលើកកំពស់ហេដ្ឋារចនាសម្ព័ន្ធទីផ្សារ និងនិយ័តកម្ម រាជរដ្ឋាភិបាលនឹងអនុវត្តវិធានការ ដូចតទៅ÷

១- កាត់បន្ថយពេលវេលា និងចំណាយលើការត្រួតពិនិត្យគ្រប់ប្រភេទ ។

២- បង្កើតប្រព័ន្ធពត៌មាន ដើម្បីសំរួលអោយក្រុមហ៊ុនមានលទ្ធភាពទទួលឥណទានពីធនាគារ និងជួយធនាគារពាណិជ្ជកម្មក្នុងការវាយតំលៃសំណើសុំវិនិយោគ ។

៣- បង្កើតស្ថាប័នគ្រប់គ្រងទីផ្សារការងារ តាមរយៈការបង្កើតបញ្ជីការអំពីប្រភេទឯកទេសកម្ម ឬជំនាញដែលទីផ្សារត្រូវការ អំពីសេចក្តីត្រូវការក្នុងការបណ្តុះបណ្តាល និងអំពីធនធានមនុស្ស ដែលមានស្រាប់សំរាប់វិស័យឯកជន ។

៤- កែលំអហេដ្ឋារចនាសម្ព័ន្ធ ពង្រីកវិសាលភាពនៃបណ្តាញអគ្គិសនី ប្រព័ន្ធទូរស័ព្ទ និងទូរគមនាគមន៍ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងទឹកស្អុយ បង្កើនប្រសិទ្ធភាពកំពង់ផែ កាត់បន្ថយថ្លៃអគ្គិសនី ថ្លៃសេវាលើកដាក់នៅកំពង់ផែ និងថ្លៃទំនាក់ទំនង និងដឹកជញ្ជូន ។

៥- ទប់ស្កាត់កិច្ចព្រមព្រៀងអាជីវកម្មផ្តាច់មុខជាមួយក្រុមហ៊ុនណាមួយ តាមរយៈការបន្ធូរបន្ថយលើនីតិវិធីផ្តល់អាជ្ញាប័ណ្ណ និងតំរូវការត្រួតពិនិត្យនានា ។

៦- បង្កើនការចូលរួមរបស់ក្រុមហ៊ុននានា ពិសេសក្រុមហ៊ុនខ្នាតតូច និងមធ្យម នៅក្នុងសេដ្ឋកិច្ចផ្លូវការ ដោយកាត់បន្ថយបន្ទុកនិយ័តកម្មសំរាប់ក្រុមហ៊ុន ដែលក្នុងនោះមាន ការកាត់បន្ថយសោហ៊ុយចំណាយចុះឈ្មោះក្រុមហ៊ុន ការលុបចោលតម្រូវការអាជ្ញាប័ណ្ណមិនចាំបាច់ និងច្រើនហួសហេតុ ការលុបចោលកម្រិតទុនអប្បបរមាសំរាប់ការចុះបញ្ជី និងកំណែទំរង់របបអធិការកិច្ច ។

៧- រៀបចំក្របខ័ណ្ឌគតិយុត្តិ សំរាប់គ្រប់គ្រងការចូលរួមរបស់ផ្នែកឯកជននៅក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ។

៨- កែសំរួលបញ្ញត្តិស្តីពីការធ្វើការបន្ថែមម៉ោង ការផ្លាស់ប្តូរពេលធ្វើការ និងពេលឈប់សំរាក ដោយគោរពតាមនិយាមជាមូលដ្ឋានរបស់ច្បាប់ការងារ ដើម្បីជំរុញអោយឧស្សាហកម្មកាត់ដេរនៅកម្ពុជាកាន់តែមានភាពប្រកួតប្រជែងថែមទៀត ។

៣៥១- ដើម្បីបង្កើនលទ្ធភាពឈានចូលទីផ្សារ និងពត៌មានទីផ្សារ រាជរដ្ឋាភិបាលនឹងអនុវត្តវិធានការដូចតទៅ ÷

១- ពង្រឹងសកម្មភាពជំរុញវិស័យពាណិជ្ជកម្ម និងសកម្មភាពពត៌មានទីផ្សារ ។

២- អភិវឌ្ឍការចុះបញ្ជីសហគ្រាសតាមប្រព័ន្ធកុំព្យូទ័រ ។

៣- បង្កើតគេហទំព័រអ៊ិនទែណែត ដើម្បីផ្សព្វផ្សាយផលិតផលក្នុងស្រុក ។

៤- ពង្រឹងសមត្ថភាពទីចាត់ការគយ និងរដ្ឋាករ ដើម្បីទប់ស្កាត់ការរត់ពន្ធ ។

៥- អភិវឌ្ឍសក្តានុពលនាំចេញ តាមរយៈការបង្កើតតំបន់ឧស្សាហកម្មសំរាប់ក្រុមហ៊ុននាំចេញ ។

៣៥២- វិស័យទេសចរណ៍បានទាក់ទាញវិនិយោគឯកជនជាច្រើន ។ រាជរដ្ឋាភិបាលបន្តគាំទ្រវិស័យឯកជន ក្នុងការជួយអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សំរាប់ពង្រីកវិស័យទេសចរណ៍ ។ រាជរដ្ឋាភិបាលនឹង ÷

- អនុវត្តវិធានការនានា ដើម្បីធានាសុវត្ថិភាពរបស់ភ្ញៀវទេសចរណ៍នៅទូទាំងប្រទេស ពិសេសនៅគ្រប់រមនីយដ្ឋានទេសចរណ៍ ។
- ចាត់វិធានការនានា ដើម្បីទាក់ទាញវិនិយោគឯកជន សំរាប់ស្ពារ និងកសាងព្រលានយន្តហោះ ផ្លូវថ្នល់ ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទឹកស្អាត ព្រមទាំងការគ្រប់គ្រងកាកសំណល់ នៅតាមរមណីយដ្ឋានទេសចរណ៍ ។
- ក្នុងក្របខ័ណ្ឌគំរោងអភិវឌ្ឍន៍ទេសចរណ៍តាមទន្លេមេគង្គ រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាព ដើម្បី ÷
  - .កែលំអព្រលានយន្តហោះនៅខេត្តរតនគីរី និងស្ទឹងត្រែង ។
  - .កែលំអផ្លូវឆ្ពោះទៅសារមន្ទីរប្រល័យពូជសាសន៍ជើងឯក ។
  - .អនុវត្តគំរោងស្តីពីការគ្រប់គ្រងកាកសំណល់នៅខេត្តសៀមរាប ។
  - .សំរួលការធ្វើដំណើរទៅចំណុចច្រកព្រំដែនកោះក្រឡ ។
- គាំទ្រការសាងសង់ផ្លូវជាតិ តភ្ជាប់ពីព្រំដែនថៃទៅប្រទេសវៀតណាម ÷
  - .ផ្លូវជាតិលេខ ៦ ពីប៉ោយប៉ែត មកសៀមរាប ។
  - .ផ្លូវជាតិលេខ ៦៧ ពីចាមស្រយាម- អន្លង់វែង- សៀមរាប ។

.ផ្លូវជាតិលេខ ៤៨ ពីខេត្តកោះកុង មកស្រែអំបិល ។

.ផ្លូវជាតិលេខ ៧៨ ពីអូរយ៉ាដាវ មកបានលុង ។

- ការសាងសង់ព្រលានយន្តហោះនៅក្រុងព្រះសីហនុ និងកោះកុង ។
- ការជំរុញបង្កើតក្រុមប្រឹក្សាទីផ្សារទេសចរណ៍ ដើម្បីអោយផ្នែកឯកជនចូលរួមបាន ។
- បង្កើតការិយាល័យពត៌មានទេសចរណ៍នៅតាមព្រលានយន្តហោះ និងកំពង់ផែអន្តរជាតិ ។
- ផ្សព្វផ្សាយពីទេសចរណ៍តាមអ៊ិនទែណិត និងតាមទូរទស្សន៍ CTN CNN CCTV TV5 NHK និង KBS ។
- ជំរុញអោយបង្កើតសមាគមសណ្ឋាគារ និងផ្ទះសំណាក់ សមាគមអ្នកមគ្គុទ្ទេសក៍ភ្ញៀវ សមាគមអាកាសចរកម្ពុជា សមាគមភោជនីយដ្ឋាន និងសមាគមដឹកជញ្ជូន ។

## ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម

៣៥៣- ដូចមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ រាជរដ្ឋាភិបាលបានលើកទិសដៅជំរុញការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម (SME) ដោយបានកំណត់គោលនយោបាយដូចតទៅ ÷

ទី១- លើកទឹកចិត្តដល់ការរីកលូតលាស់ផ្នែក SME ជាពិសេស តាមរយៈការផ្តល់ឥណទានរយៈពេលមធ្យម និងរយៈពេលវែង ។

ទី២- ទប់ស្កាត់ការរត់ពន្ធគ្រប់ប្រភេទ ។

ទី៣- កាត់បន្ថយបែបបទសំរាប់ការចុះបញ្ជី និងការរៀបចំដំណើរការក្រុមហ៊ុន ។

ទី៤- សំរួលការនាំចេញ- នាំចូល តាមរយៈការកាត់បន្ថយបែបបទស្មុគ្រស្មាញ មានដូចជា អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតផ្សេងៗ ។ល។

ទី៥- ផ្តល់ការគាំពារដល់ឧស្សាហកម្មក្មេងខ្ចីមួយចំនួនក្នុងរយៈពេលសមស្របមួយ ។

ទី៦- ជំរុញសម្ព័ន្ធភាពរវាងសហគ្រាសខ្នាតតូចនិងមធ្យម ជាមួយនឹងឧស្សាហកម្មធុនធំ ។

ទី៧- ជំរុញបង្កើតមជ្ឈមណ្ឌលផលិតភាពជាតិ ដែលជួយដល់ឧស្សាសហកម្មធុនតូច និងមធ្យម តាមរយៈការលើកកំពស់ផលិតភាព និង ការកាត់បន្ថយថ្លៃដើមនៃផលិតកម្ម ។

ទី៨- បង្កើតវិទ្យាស្ថានស្តង់ដារជាតិ ដែលនឹងជួយធានាអោយគុណភាពផលិតផលក្នុងប្រទេស អាចឆ្លើយតបបានទៅនឹងស្តង់ដារតំបន់ និងអន្តរជាតិ ។

ទី៩- បង្កើតមន្ទីរពិសោធន៍ជាតិផ្នែករូបគីមី មីក្រូជីវៈ មេកានិច និងការធ្វើតេស្ត ដែលអាចកំណត់បានលើគុណភាព និងលក្ខណៈវិនិច្ឆ័យរបស់ផលិតផល ។

ទី១០- ពង្រឹងយន្តការការពារកម្មសិទ្ធិបញ្ញាឧស្សាហកម្ម ដែលការពារដល់ការលួចចម្លងដោយខុសច្បាប់ក្នុងការរិះរក និងប្រើប្រាស់បច្ចេកទេស និងបច្ចេកវិទ្យាថ្មី ព្រមទាំងផលិតផលថ្មី ។

ទី១១- ជំរុញដល់ការបណ្តុះបណ្តាលមុខវិជ្ជាជំនាញ ទាំងនៅក្នុង និងក្រៅប្រទេស ។

ទី១២- បង្កើនចលនា «ភូមិមួយ- ផលិតផលមួយ »។

ទី១៣- ពង្រឹងប្រព័ន្ធច្បាប់ដោយបង្កើតច្បាប់រោងចក្រ ច្បាប់តំបន់ឧស្សាហកម្ម ច្បាប់ប៉ាតង់ និងតក្កកម្មឧស្សាហកម្ម ច្បាប់រង្វាស់រង្វាល់ ច្បាប់សុវត្ថិភាពឧស្សាហកម្ម ។ល។

៣៥៤- រាជរដ្ឋាភិបាលយល់ច្បាស់ថា ឥណទានជនបទគឺជាយន្តការមួយយ៉ាងសំខាន់នៅក្នុងកិច្ចអភិវឌ្ឍន៍ជនបទ ។ ឥណទានជនបទបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើត និងការពង្រីកធុរកិច្ច ក៏ដូចជាការបង្កើនផលិតភាព ប្រាក់ចំណូល និងលើកកំពស់កំរិតជីវភាពរស់នៅរបស់ប្រជាជននៅជនបទ ។ រាជរដ្ឋាភិបាលនឹងបន្តជំរុញផ្នែកឥណទានជនបទ ដើម្បីផ្តល់ឥណទានតាមកំរិតការប្រាក់ សមស្របអាចត្រូវបានផ្តល់ជូនប្រជាជនក្រីក្រ ពិសេស ប្រជាជនដែលរស់នៅតំបន់ជនបទ និងនៅតាម តំបន់ព្រំដែន និងប្រជាជនដែលប្រកបអាជីវកម្មក្នុងសហគ្រាសតូច និងមធ្យម ។ រាជរដ្ឋាភិបាលនឹងអនុវត្តនូវបណ្តាវិធានការ ដូចខាងក្រោម ដើម្បីជំរុញកិច្ចអភិវឌ្ឍន៍របស់ផ្នែកមីក្រូហិរញ្ញវត្ថុ÷

១- ត្រួតពិនិត្យការគ្រប់គ្រង និងជំនាញបច្ចេកទេសរបស់អ្នកប្រតិបត្តិករឥណទាន ដើម្បីធានាចីរភាពខាងហិរញ្ញវត្ថុ ដោយកាត់បន្ថយហានិភ័យក្នុងការផ្តល់ឥណទាន និងលុបបំបាត់អំពើខុសឆ្គង ។

២- ពង្រឹងសមត្ថភាពក្នុងការអនុវត្តន៍ច្បាប់ និងបទបញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ការត្រួតពិនិត្យស្ថាប័នមីក្រូហិរញ្ញវត្ថុ ។

៣- ផ្តល់ការបណ្តុះបណ្តាលដល់ប្រតិបត្តិករឥណទាន ដើម្បីបង្កើនសមត្ថភាពជំនាញបច្ចេកទេស ដើម្បីបង្កើនប្រសិទ្ធភាព និងចីរភាពនៃកម្មវិធីឥណទាន ។

៤- ចរចាជាមួយនឹងប្រតិបត្តិករ ដើម្បីកាត់បន្ថយអត្រាការប្រាក់ និងបង្កើនការផ្តល់ឥណទាន ដើម្បីឆ្លើយតបនឹងតំរូវការ ។

៥- ជំរុញការកៀងគរសញ្ជ័យ ដើម្បីបង្កើនប្រភពឥណទានជនបទក្នុងស្រុក ។

៦- ជំរុញ និងបង្កើតបរិស្ថានប្រណាំងប្រជែង សំរាប់អ្នកប្រតិបត្តិការឥណទានជនបទ ។

៧- បន្តទាក់ទាញប្រភពធនធានហិរញ្ញវត្ថុពីក្រៅប្រទេស ។

៨- គាំទ្រប្រជាជនជនបទក្នុងការស្វែងរកទីផ្សារ ទាំងក្នុងនិងក្រៅប្រទេសសំរាប់លក់ផលិតផល តាមរយៈការជំរុញសហគ្រាសតូច និងមធ្យម ហើយផ្តល់ឥណទានសំរាប់គាំទ្រសហគ្រាសតូច និងមធ្យមខាងផ្នែកកសិឧស្សាហកម្ម ព្រមទាំងចលនាភូមិមួយ- ផលិតផលមួយ ។

៩- ពង្រីកការផ្តល់សេវាឥណទានដល់តំបន់ដាច់ស្រយាល ។

## ការបង្កើតការងារ និង ការធានាលក្ខខ័ណ្ឌការងារល្អប្រសើរជូនកម្មករ និង និយោជិត

៣៥៥- អាទិភាពរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី៣ នៃរដ្ឋសភា រួមមាន÷

ទី១- បង្កើតការងារអោយបានច្រើនជូនដល់ស្រទាប់យុវវ័យ ដែលត្រូវដល់អាយុឈានចូលក្នុងទីផ្សារពលកម្ម និងពលករកម្ពុជាទាំងអស់ តាមរយៈការដាក់ចេញនូវវិធានការនានា ដែលលើកទឹកចិត្តដល់ការវិនិយោគក្នុងស្រុក និងដែលទាក់ទាញវិនិយោគផ្ទាល់ពីបរទេស នៅតាមបណ្តាវិស័យជា

អាទិភាពទាំងឡាយ ពិសេសវិស័យកសិកម្ម កសិ-ឧស្សាហកម្ម ឧស្សាហកម្មអតិពលកម្ម និងទេសចរណ៍ ។

ទី២- បង្កើតស្ថាប័នបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជូនជនក្រីក្រ ភ្ជាប់ជាមួយនឹងមជ្ឈមណ្ឌល សំរាប់ជួយរកការងារអោយយុវជនធ្វើ ជាពិសេស យុវជនដែលទើបចេញពីសាលាអោយបានស្របតាមតំរូវការទីផ្សារពលកម្ម ។

ទី៣- រៀបចំប្រព័ន្ធស្ថិតិការងារ ។

៣៥៦- ការយកចិត្តទុកដាក់ក៏នឹងត្រូវបានផ្តោតជាពិសេសផងដែរទៅលើ ÷ ១- ការពង្រឹងការគ្រប់គ្រងពលករបរទេសនៅកម្ពុជា ក្នុងទិសដៅដោះស្រាយការងារធ្វើជូនប្រជាពលរដ្ឋ ។ ២- ស្រូបយកបច្ចេកវិទ្យាថ្មី សំរាប់ការអភិវឌ្ឍន៍ប្រទេសជាតិ ។ ៣- រៀបចំគោលនយោបាយការងារ និងការបណ្តុះបណ្តាល ដែលផ្សារភ្ជាប់នឹងគោលនយោបាយអប់រំប្រកបដោយប្រសិទ្ធភាព ដើម្បីលើកទឹកចិត្តដល់ការផ្លាស់ប្តូរទីកន្លែងជំនាញ ថ្មី ។ ៤- លើកទឹកចិត្តការនាំចេញនូវពលកម្ម ដើម្បីបង្កើនសុខុមាលភាព ធ្វើអោយប្រសើរឡើងនូវជំនាញ កាត់បន្ថយភាពគ្មានការងារធ្វើ និងបង្កើនប្រាក់ចំណូលរដ្ឋ ។ ការនាំចេញពលកម្មគឺជាជំរើសមួយទៀតសំរាប់កាត់បន្ថយភាពក្រីក្រ ដូចដែលធ្លាប់មានបទពិសោធន៍ក្នុងបណ្តាប្រទេសជិតខាង ។ ៥- បន្តគាំទ្រដល់ការអភិវឌ្ឍន៍ឧស្សាហកម្មអតិពលកម្មដើម្បីបង្កើតការងារ និងដើម្បីស្រូបយកចំនួនពលករដ៏ច្រើនលើសលប់ដែលមកពីទីជនបទ ។ ព្រមជាមួយនេះ ចាត់វិធានការដើម្បីបង្កើនផលិតភាពកសិកម្ម និងពិពិធកម្មដើម្បីបង្កើនប្រាក់ចំណូល និងកំរិតរស់នៅរបស់ប្រជាជនតាមជនបទ ដែលជាកត្តាមួយជួយកាត់បន្ថយភាពក្រីក្រ ។

## ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម សំរាប់មន្ត្រី បុគ្គលិក កម្មករ

៣៥៧- នៅក្នុងនីតិកាលទី៣ នេះ រាជរដ្ឋាភិបាលនឹងផ្តោតទៅលើអាទិភាពដូចតទៅ ÷ ១- ពង្រឹងយ៉ាងម៉ឺងម៉ាត់នូវការអនុវត្តន៍ច្បាប់ការងារ និងអនុសញ្ញាអន្តរជាតិនានាស្តីពីតួនាទីសហជីព ដើម្បីធានាយ៉ាងពិតប្រាកដនូវសិទ្ធិ និងផលប្រយោជន៍របស់កម្មករ និយោជិត និងនិយោជក ។ ២- កែលំអអោយកាន់តែប្រសើរឡើងនូវលក្ខខ័ណ្ឌការងាររបស់កម្មករ និងនិយោជិត ។ ៣- ពង្រឹងការអនុវត្តន៍ច្បាប់ស្តីពីរបបសន្តិសុខសង្គម ។ ៤- ពិនិត្យអំពីជំរើសសំរាប់អនុវត្តគោលការណ៍ផ្តល់របបសោធននិវត្តន៍ សំរាប់អ្នកបាត់បង់សមត្ថភាព ពលកម្ម និងអ្នកនៅក្នុងបន្ទុក និងការធានារ៉ាប់រងចំពោះគ្រោះថ្នាក់ការងារសំរាប់ជនទាំងឡាយ ដែលស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់ការងារ ។

៣៥៨- ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិនានា រាជរដ្ឋាភិបាលនឹងបង្កើនកិច្ចអន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច ក្នុងទិសដៅលើកស្ទួយកាលានុវត្តភាពការងារ កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋក្រីក្រ បង្កើនសកម្មភាពសង្គ្រោះបន្ទាន់ ដើម្បីជួយដល់អ្នករងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗ និង ពង្រីកកម្មវិធីស្តារលទ្ធភាពពលកម្មសំរាប់ជនពិការ ព្រមទាំងកម្មវិធីលើក

កំពស់សុខុមាលភាពរបស់ជនចាស់ជរា កុមារកំព្រា ស្ត្រីរងគ្រោះ ជនអនាថាគ្មានទីពឹង អតីតយុទ្ធជន និងគ្រួសារ ។

៣៥៩- រាជរដ្ឋាភិបាលបន្តជួយឧបត្ថម្ភអោយបានជិតដល់ចំពោះជនពិការ និងគ្រួសារយុទ្ធជន ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ព្រមទាំងជំរុញអោយម្ចាស់សហគ្រាស រោងចក្រ ឧបត្ថម្ភប្រាក់បៀវត្ស រួមជាមួយកំរៃបេឡាសន្តិសុខសង្គមដល់កម្មករជាជំហានៗ អោយបានសមស្របតាមកំរិតលក្ខខ័ណ្ឌទីផ្សារការងារ ។

## ៤.៣.៤ ការកសាងសមត្ថភាព និងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ធនធានមនុស្ស

៣៦០- ការកសាងសមត្ថភាព និងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ធនធានមនុស្សគឺជាចតុកោណយុទ្ធសាស្ត្រទី៤ នៃយុទ្ធសាស្ត្រចតុកោណ ។ មុំជាយុទ្ធសាស្ត្រទាំង៤ នៃចតុកោណនេះ គឺ ÷ ១- ការពង្រឹងគុណភាពអប់រំ ។ ២- ការពង្រឹងសេវាសុខាភិបាល ។ ៣- ការអនុវត្តន៍គោលនយោបាយស្តីពីយេនឌ័រ ។ និង៤- ការអនុវត្តន៍គោលនយោបាយប្រជាជន ។

**ការកសាងសមត្ថភាពនិងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ធនធានមនុស្ស**

- ការពង្រឹងគុណភាពអប់រំ
- ការពង្រឹងសេវាសុខាភិបាល
- ការអនុវត្តន៍គោលនយោបាយស្តីពីយេនឌ័រ
- ការអនុវត្តន៍គោលនយោបាយប្រជាជន ។

### ការពង្រឹងគុណភាពសេវាអប់រំ

៣៦១- ចតុកោណទី ៤នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា បានលើកឡើងអំពីអាទិភាពរបស់រាជរដ្ឋាភិបាលសំរាប់វិស័យអប់រំ ដែលនឹងត្រូវអនុវត្តនៅក្នុងនីតិកាលទី ៣ នេះ ។ អាទិភាពទាំងនេះរួមមាន ÷

១- ការធ្វើអោយសំរេចទិសដៅ *«អប់រំសំរាប់ទាំងអស់គ្នា»* តាមរយៈ ÷

- ការធានាសមធម៌ក្នុងការអប់រំមូលដ្ឋានរយៈពេល៩ឆ្នាំសំរាប់កុមារគ្រប់រូប និងការបង្កលក្ខណៈសម្បត្តិអនុគ្រោះនានា ដើម្បីអោយកូនចៅប្រជាពលរដ្ឋក្រីក្រមានលទ្ធភាពចូលសិក្សា ។
- ការបង្កើនអាហារូបករណ៍សំរាប់សិស្ស និងនិស្សិតក្រីក្រ ។
- ការលើកកំពស់គុណភាព និងបង្កើនចំនួនគ្រឹះស្ថានសិក្សាសាធារណៈ ពិសេសនៅតំបន់ជនបទ និងការឧបត្ថម្ភចំណាយប្រតិបត្តិការរបស់សាលារៀន ។

២- ការលើកកំពស់គុណភាពអប់រំតាមរយៈ ÷

- ការផ្តល់ការលើកទឹកចិត្តដល់គ្រូបង្រៀន ។
- ការធានាគុណភាពបណ្តុះបណ្តាល ។
- បង្កើនការផ្គត់ផ្គង់សំភារៈសិក្សា បណ្ណាល័យ មន្ទីរពិសោធន៍ និងអន្តេវាសិកដ្ឋាន សំរាប់សិស្សជានារី ។

- កំណែទំរង់កម្មវិធីសិក្សា និងកម្មវិធីបណ្តុះបណ្តាល ។
- ជំរុញកម្មវិធីអក្ខរកម្ម និងការអប់រំក្រៅប្រព័ន្ធសិក្សា ។

៣- ការបង្កើនចំណាយសំរាប់វិស័យអប់រំ និងការកៀងគរបង្កើនជំនួយអន្តរជាតិសំរាប់វិស័យអប់រំ ។

៤- ការពង្រឹងភាពជាដៃគូជាមួយផ្នែកឯកជននិងសហគមន៍អន្តរជាតិ ដើម្បីលើកកម្ពស់គុណភាពអប់រំ សំដៅឆ្លើយតបទៅនឹងស្តង់ដារអន្តរជាតិ និងភាពចាំបាច់នៃការអភិវឌ្ឍន៍ជាតិ ។

៣៦២- **ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ ២០០៤-២០០៨** បានកំណត់យុទ្ធសាស្ត្រដ៏ទូលំទូលាយមួយ សំរាប់អភិវឌ្ឍធនធានមនុស្សដែលមានជំនាញបច្ចេកទេសនិងវិទ្យាសាស្ត្រ ខ្ពស់ ដែលអាចឆ្លើយតបបានទៅនឹងតំរូវការទីផ្សារពលកម្ម ប្រកបដោយប្រសិទ្ធិភាព និងដោយមានស្មារតីសហគ្រិនភាព គំនិតច្នៃប្រឌិតខ្ពស់ ស្មារតីទទួលខុសត្រូវ វិន័យ សីលធម៌ គុណធម៌ល្អប្រសើរ មនសិការក្នុងការងារ និងអត្តចរិតស្លូតត្រង់ ដើម្បីលើកស្ទួយការអភិវឌ្ឍន៍ប្រទេសជាតិ ។

៣៦៣- រាជរដ្ឋាភិបាលនឹងបន្តពង្រឹងបន្ថែមទៀត នូវសមិទ្ធផលនៃការអប់រំសំរាប់ទាំងអស់គ្នា នៅក្នុងការអប់រំ មូលដ្ឋាន ។ ជោគជ័យទាំងនោះបានពឹងផ្អែកភាគច្រើនទៅនឹងលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ ដើម្បីប្រមូលធនធានសំរាប់អនុវត្តយុទ្ធសាស្ត្រនានា ដែលបានកំណត់នៅក្នុងផែនការជាតិអប់រំសំរាប់ទាំងអស់គ្នា ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងក្នុងកម្មវិធីគាំទ្រវិស័យអប់រំ ។ រាជរដ្ឋាភិបាលបានយល់យ៉ាងច្បាស់អំពីភាពចាំបាច់ ក្នុងការជំរុញល្បឿននៃការអនុវត្តន៍កំណែទំរង់វិស័យ អប់រំ តាមរយៈការលើកកំពស់ការអនុវត្តន៍កម្មវិធីសកម្មភាពជាអាទិភាពប្រចាំឆ្នាំ ។

៣៦៤- រាជរដ្ឋាភិបាលនឹងបន្តខិតខំបង្កើនចំណាយថវិកា និងកៀងគរជំនួយបរទេសអោយបានច្រើនថែមទៀត សំរាប់លើកទឹកចិត្តគ្រូបង្រៀន ធានាគុណភាពបណ្តុះបណ្តាល បង្កើនការផ្គត់ផ្គង់សំភារៈសិក្សា បណ្ណាល័យ និងមន្ទីរពិសោធន៍ បង្កើតអន្តេវាសិកដ្ឋានសំរាប់សិស្ស- និស្សិត ពិសេស សំរាប់សិស្ស- និស្សិតជានារីភេទ បន្តជំរុញកំណែទំរង់កម្មវិធីសិក្សា ផ្តល់អាហារូបករណ៍ដល់សិស្សនិងនិស្សិតក្រីក្រ ជំរុញកម្មវិធីអក្ខរកម្ម និងការអប់រំក្រៅប្រព័ន្ធ និងផ្តល់ថវិកាសំរាប់កសាងសាលារៀននៅតាមជនបទ ព្រមទាំងធានាការចំណាយប្រតិបត្តិការរបស់សាលារៀន ។

៣៦៥- រាជរដ្ឋាភិបាលនឹងបន្តពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន ព្រមទាំងជាមួយសហគមន៍ជាតិ និងអន្តរជាតិ ដើម្បីបង្កើននិងលើកកំពស់គុណភាពសេវាអប់រំ ទាំងក្នុងកំរិតមធ្យមសិក្សា បណ្តុះបណ្តាលវិជ្ជាជីវៈ និង បច្ចេកទេស ទាំងក្នុងកំរិតឧត្តមសិក្សា ក្នុងគោលដៅឆ្លើយតបបានយ៉ាងសមស្របទៅនឹងស្តង់ដារអន្តរជាតិ និងតំរូវការអភិវឌ្ឍន៍របស់ប្រទេស ។

៣៦៦- អាទិភាពទាំងឡាយដែលរាជរដ្ឋាភិបាលត្រូវអនុវត្តក្នុងវិស័យអប់រំ ដើម្បីសំរេចបាននូវយុទ្ធសាស្ត្រចតុកោណ មានដូចតទៅ ៖

- បង្កើនការចូលរៀនរបស់កុមារគ្រប់រូបប្រកបដោយសមធម៌ និងយកចិត្តទុកដាក់ដល់តុល្យភាពយេនឌ័រនៅគ្រប់ភូមិសិក្សា ចាប់តាំងពីការអប់រំកុមារតូច ការអប់រំកំរិតមូលដ្ឋាន ការអប់រំក្រោយកំរិតអប់រំមូលដ្ឋាន និងការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ទាំងក្នុងនិងក្រៅប្រព័ន្ធ ។ គោលដៅទាំងនេះត្រូវបានលើកឡើងនៅក្នុងផែនការជាតិអប់រំសំរាប់ទាំងអស់គ្នា និងយុទ្ធសាស្រ្តជាតិកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។
- លើកកំពស់គុណភាពនិងប្រសិទ្ធភាពនៃសេវាអប់រំ ដោយធានាអោយសិស្ស និងនិស្សិតមានចំណេះដឹងសមស្រប ក្រោយពេលបញ្ចប់ការសិក្សារបស់ខ្លួន ហើយអាចយកចំណេះដឹងនោះទៅបំរើអោយជីវភាពរស់នៅរបស់ពួកគេ ។
- លើកកំពស់ការកសាងនិងអភិវឌ្ឍន៍សមត្ថភាពមន្ត្រីនិងស្ថាប័ន ដើម្បីអនុវត្តវិមជ្ឈការ និងវិសហមជ្ឈការសេវាអប់រំ តាមរយៈការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព សំដៅឆ្លើយតបនឹងគោលនយោបាយកំណែទំរង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល ស្របពេលជាមួយគ្នានឹងការពង្រឹងសវនកម្ម និងពិនិត្យតាមដានការបំពេញការងារក្នុងវិស័យអប់រំ ។
- អភិវឌ្ឍកំលាំងយុវជនអោយចូលរួមអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្រ ដោយមានកម្មវិធីចំពោះមុខ សំរាប់យុវជននៅក្រៅសាលា និងកម្មវិធីយូរអង្វែងក្នុងការកសាងសមត្ថភាពនយោបាយសេដ្ឋកិច្ច វិទ្យាសាស្រ្ត សំរាប់យុវជនក្នុងសាលារៀន ជំរុញវិស័យអប់រំកាយ និងកីឡាអោយអភិវឌ្ឍឈានឡើង ដើម្បីអោយមនុស្សគ្រប់រូបមានសុខភាពល្អ សុខុមាលភាពល្អ និងមានសេចក្តីក្លាហានដើម្បីចូលរួមចំណែកក្នុងរាល់សកម្មភាពសង្គម ។
- ពង្រឹងភាពជាដៃគូ សំរាប់កៀងគរជំនួយអភិវឌ្ឍន៍វិស័យអប់រំ ដោយបង្កើនភាពជឿទុកចិត្តគ្នា រវាងក្រសួង និងស្ថាប័នក្នុងរាជរដ្ឋាភិបាលកម្ពុជា ទីភ្នាក់ងារផ្តល់ជំនួយជាតិ និងអន្តរជាតិ ព្រមទាំងប្រទេសជាមិត្តនានា ដោយឈរលើស្មារតីទទួលខុសត្រូវខ្ពស់ និងមានតំលាភាព ។
- កៀងគរធនធានពីគ្រប់ប្រភព ដើម្បីអនុវត្តកំណែទំរង់វិស័យអប់រំអោយទទួលបានជោគជ័យ ក្នុងនោះការបន្តពង្រឹងកិច្ចសហការរវាងក្រសួងអប់រំ យុវជននិងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងការបើកផ្តល់សាច់ប្រាក់អោយបានល្អប្រសើរ ។ ជាមួយគ្នានោះដែរ រាជរដ្ឋាភិបាលនឹងបន្តការយកចិត្តទុកដាក់ខ្ពស់ដល់ការលើកកំពស់ជីវភាពរស់នៅ និងលក្ខខ័ណ្ឌបំពេញការងាររបស់គ្រូបង្រៀន និងមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួងអប់រំ យុវជននិងកីឡា ជាមួយនិងដៃគូអភិវឌ្ឍន៍នានា ក្នុងការកៀងគរធនធានហិរញ្ញវត្ថុសំរាប់អភិវឌ្ឍវិស័យអប់រំ ក្នុងដំណាក់កាលចំពោះមុខ ក៏ដូចជាក្នុងពេលអនាគត ។

៣៦៧- សកម្មភាពអនុវត្តន៍បន្ត ដែលត្រូវប្រកាន់យកនៅឆ្នាំក្រោយ រួមមាន ÷

- ពិនិត្យកែសំរួលឡើងវិញ នូវផែនការយុទ្ធសាស្រ្តវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំ ដោយផ្អែកលើបទពិសោធន៍អនុវត្តកន្លងមក ។

- អង្កេតតាមដានចំណាយសាធារណៈ និងប្រើប្រាស់លទ្ធផលនៃការអង្កេតនេះ ដើម្បីកែលំអប្រព័ន្ធថវិកា សំរាប់វិស័យអប់រំ ។
- កែលំអដំណើរការថវិកាប្រចាំឆ្នាំ និងដំណើរការអនុម័តនិងអនុវត្តន៍កម្មវិធីសកម្មភាពជាអាទិភាព ដើម្បីធានាការផ្តល់ថវិកាបានទាន់ពេលវេលា និងអាចប៉ាន់ស្មានទុកជាមុនបាន ។
- លើកកំពស់ការគ្រប់គ្រងហិរញ្ញវត្ថុ សវនកម្មផ្ទៃក្នុង និងពង្រឹងយន្តការត្រួតពិនិត្យ ។
- អនុវត្តកំណែទំរង់បៀវត្សនៅទូទាំងវិស័យអប់រំ និងកម្មវិធីផ្តល់ការលើកទឹកចិត្តដល់នាយកសាលា និងគ្រូបង្រៀន ដោយផ្អែកលើការអនុវត្តន៍ការងារ ផ្សារភ្ជាប់នឹងជំហានទីមួយនៃការពង្រាយ និងចំណាត់ថ្នាក់ឡើងវិញ នូវបុគ្គលិកបង្រៀន និងបុគ្គលិកការិយាល័យ (មិនបង្រៀន) អោយមានប្រសិទ្ធភាពទៅតាមស្តង់ដារពង្រាយបុគ្គលិក ។
- រៀបចំផែនការកសាងសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ដើម្បីធ្វើជាមូលដ្ឋានក្នុងការសំរបសំរួលជំនួយក្រៅប្រទេស និងការត្រួតពិនិត្យតាមដានអំពីវឌ្ឍនភាព ។
- ពង្រឹងដំណើរការពិគ្រោះយោបល់រវាងក្រសួងអប់រំ យុវជននិងកីឡា ក្រសួងនិងស្ថាប័ននានារបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ នៅក្នុងការរៀបចំផែនការជាតិស្តីពីការអប់រំសំរាប់ទាំងអស់គ្នា ។

**ការកែលំអសេវាសុខាភិបាល**

៣៦៨- រាជរដ្ឋាភិបាលបានប្តេជ្ញាអនុវត្តប្រកបដោយប្រសិទ្ធភាព នូវច្បាប់ និងបទបញ្ញត្តិនានាស្តីពីសុខាភិបាល ដើម្បីធានាគុណភាពនៃការផ្តល់សេវាសុខាភិបាល និងឱសថ រួមទាំងឱសថបូរាណ តាមរយៈការផ្តល់ ពត៌មាន និងការត្រួតពិនិត្យ ដោយផ្សារភ្ជាប់ជាមួយនឹងការប្រើប្រាស់ឱសថសម័យ ។ អាទិភាពដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណសំរាប់វិស័យសុខាភិបាល រួមមាន÷

១- ការបង្កើនវិភាជន៍ធនធានសាធារណៈ និងជំនួយអន្តរជាតិ សំរាប់លើកកំពស់វិស័យសុខាភិបាល ។

២- ការលើកទឹកចិត្តការវិនិយោគឯកជនក្នុងវិស័យសុខាភិបាល សំដៅលើកកំពស់សុខភាពរបស់ប្រជាជន ។

៣- ការលើកកំពស់គុណភាពសេវាសុខាភិបាលអោយមានប្រសិទ្ធភាព សមធម៌ និងចីរភាព តាមរយៈ÷
- ផ្តល់អាទិភាពក្នុងការកសាងមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនៅទូទាំងប្រទេស ដើម្បីផ្តល់សេវាសុខាភិបាលនៅមូលដ្ឋាន ពិសេសដល់ជនក្រីក្រ និងក្រុមជនងាយរងគ្រោះ ។
- អនុញ្ញាតអោយប្រជាពលរដ្ឋក្រីក្រទទួលការពិនិត្យព្យាបាលរោគដោយឥតគិតថ្លៃ នៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ។
- ពង្រឹងនិងពង្រីកមូលនិធិប្រកបដោយសមធម៌ សំរាប់ជួយជនក្រីក្រអាចទទួលសេវាសុខភាពប្រកបដោយគុណភាព ។

៤- ធានាការផ្គត់ផ្គង់សេវាសុខភាពនិងឱសថ និងសុវត្ថិភាពចំណីអាហារ អោយមានស្តង់ដារគុណភាពខ្ពស់ តាមរយៈ÷

- ការអនុម័ត និងការអនុវត្តន៍ច្បាប់ និងបទបញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យសុខាភិបាលអោយមានប្រសិទ្ធិភាព ។
- លើកទឹកចិត្តការប្រើប្រាស់ឱសថបូរាណគួបផ្សំនឹងឱសថសម័យ ដោយផ្តល់ពតិមានច្បាស់លាស់ និងមានការត្រួតពិនិត្យត្រឹមត្រូវ ។

៥- បន្តអនុវត្តកម្មវិធីការពារនិងប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លង ។

៦- ជំរុញការថែទាំសុខភាពមាតានិងកុមារ ដើម្បីកាត់បន្ថយមរណភាពមាតា និងទារក ។

៣៦៩- ដើម្បីអនុវត្តគោលនយោបាយវិស័យសុខាភិបាលខាងលើ រាជរដ្ឋាភិបាលត្រូវផ្តល់អាទិភាពទៅលើការបង្កើនការវិភាជន៍ធនធានសាធារណៈសំរាប់វិស័យសុខាភិបាល និងត្រូវបន្តលើកទឹកចិត្តការចូលរួមរបស់សហគមន៍អន្តរជាតិ និងផ្នែកឯកជន ដើម្បីបង្កើនការវិនិយោគបន្ថែមទៀតនៅក្នុងវិស័យសុខាភិបាល សំដៅលើកកំពស់ស្ថានភាពសុខភាពរបស់ប្រជាជន ។ អាទិភាពនឹងត្រូវផ្តល់ទៅលើការសាងសង់មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ដែលអាចផ្តល់សេវាសុខាភិបាលតាមរូបភាពមួយ ដែលមានប្រសិទ្ធភាព សមធម៌ ចីរភាពសំរាប់ប្រជាពលរដ្ឋទូទាំងប្រទេស ពិសេសប្រជាជនក្រីក្រនិងក្រុមជនងាយរងគ្រោះ ។ រាជ- រដ្ឋាភិបាលនឹងបន្តយកចិត្តទុកដាក់អនុវត្តកម្មវិធីការពារ និងប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងនានា ព្រមទាំងជំរុញលើកទឹកចិត្តអោយមានការថែទាំសុខភាពមាតា និងកុមារ សំដៅកាត់បន្ថយមរណភាពមាតា និងកុមារ និងកែលំអសេវាសង្គ្រោះបន្ទាន់ និងផ្តល់ការអប់រំ និងពតិមានស្តីពីសុខភាព និងអនាម័យ ពិសេសនៅតាមតំបន់ជនបទ ។ ជនក្រីក្រនឹងបានទទួលការថែទាំសុខភាពដោយឥតបង់ថ្លៃ នៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ។ មូលនិធិប្រកបដោយសមធម៌ នឹងត្រូវបានពង្រឹង និងពង្រីកបន្ថែមទៀត ដើម្បីអោយជនក្រីក្រអាចទទួលសេវាសុខាភិបាលប្រកបដោយគុណភាព ។ រាជរដ្ឋាភិបាលនឹងទទួលយក និងជំរុញការអនុវត្តន៍ច្បាប់ និង បទបញ្ញតិនានាដែលពាក់ព័ន្ធនឹងវិស័យសុខាភិបាល ដើម្បីធានាសេវាសុខាភិបាល ឱសថ និងអាហារប្រកបដោយគុណភាព ។ រាជរដ្ឋាភិបាលនឹងបន្តលើកទឹកចិត្តការប្រើប្រាស់ឱសថបុរាណគួបផ្សំជាមួយឱសថសម័យ ដោយផ្តល់ពតិមាន និងមានការត្រួតពិនិត្យត្រឹមត្រូវ ។

៣៧០- ផែនការសកម្មភាពសុខាភិបាលឆ្នាំ ២០០៤-២០០៧ (ផ. ស. ស) បានផ្តល់នូវក្របខ័ណ្ឌសកម្មភាព ដែលត្រូវអនុវត្ត ដើម្បីសំរេចអោយបាននូវយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ។ សកម្មភាពក៏រិតគោលនយោបាយទាំងនេះនឹងត្រូវអនុវត្តលើការងារធំៗចំនួន៦ ដូចខាងក្រោម ÷

៣៧១- **ការផ្តល់សេវាសុខាភិបាល** : ដើម្បីលើកកំពស់គុណភាពការផ្តល់សេវាសុខាភិបាល រាជរដ្ឋាភិបាលទទួលស្គាល់អាទិភាពនៃការពង្រឹងការអនុវត្តន៍ការផ្តល់សំណុំសកម្មភាពអប្បបរិមា និងសំណុំសកម្មភាពបង្គ្រប់នៅទូទាំងប្រទេស ក៏ដូចជាការបង្កើតអោយមានប្រព័ន្ធផ្តល់ និងចែកចាយសំភារៈ ឱសថ និងគ្រឿងបរិក្ខារពេទ្យអោយបានល្អប្រសើរ ។ ចំពោះការអភិវឌ្ឍន៍សេវាសុខភាពសំរាប់មាតា និងកុមារ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើការអនុវត្តន៍សមាហរណកម្មថែទាំជំងឺកុមារ ទន្ទឹមនឹងការធានា

អោយមានតុល្យភាពរវាងសេវាការពារ និងសេវាព្យាបាល ។ ដើម្បីបង្កើនគុណភាពនៃការប្រើប្រាស់សេវាសុខាភិបាលប្រកបដោយគុណភាពចំពោះប្រជាជនក្រីក្រ រាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ផងដែរ ទៅលើប្រព័ន្ធមន្ទីរពេទ្យបង្អែក ។ សកម្មភាពទាំងអស់នេះ ទាមទារអោយមានការរៀបចំកែទំរង់រចនាសម្ព័ន្ធខាង ស្ថាប័ន និងការគ្រប់គ្រងសមស្រប ដើម្បីអាចមានលទ្ធភាពធ្វើសមាហរណកម្មកម្មវិធីជាតិ ពិសេសនៅតាមថ្នាក់ខេត្តនិងថ្នាក់ស្រុក អនុវត្តវិធីសាស្ត្រដោយផ្អែកលើគុណភាព និងអន្តរាគមន៍ដោយផ្អែកលើភស្តុតាង ព្រមទាំងជំរុញអោយមានការចូលរួមពីឯកជននិងសហគមន៍ក្នុងការរៀបចំផែនការ និងប្រតិបត្តិការផ្តល់សេវាសុខាភិបាលជាក់ស្តែង ។

៣៧២- **ការផ្លាស់ប្តូរឥរិយាបទនិងការប្រាស្រ័យទាក់ទង** : នៅក្នុងការផ្លាស់ប្តូរឥរិយាបទ និងការប្រាស្រ័យ ទាក់ទង ក្រសួងសុខាភិបាលនិងដៃគូអភិវឌ្ឍន៍នឹងសង្កត់ធ្ងន់ទៅលើតំរូវការ ដើម្បីពង្រឹងការអនុវត្តន៍ក្រម សីលធម៌វិជ្ជាជីវៈ ក៏ដូចជាការគាំទ្រ និងការលើកទឹកចិត្តដល់ក្រុមទ្រទ្រង់សុខភាពភូមិ និងគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព តាមរយៈការបណ្តុះបណ្តាល ការសំរបសំរួល និងការប្រាស្រ័យទាក់ទង ។ ការបណ្តុះបណ្តាលជំនាញសំរាប់ប្រាស្រ័យទាក់ទងអន្តរបុគ្គល ដោយផ្តោតទៅលើក្រុមជាក់លាក់ ដូចជា មាតា កុមារ និងយុវវ័យ ត្រូវបានលើកឡើងជាបញ្ហាសំខាន់ ដើម្បីធ្វើអោយប្រសើរឡើង នូវការផ្តល់សេវាដល់ក្រុមទាំងនោះ ។ ដើម្បីបង្កើនការផ្តល់សេវាប្រកបដោយគុណភាពដល់ប្រជាជនទាំងអស់ ពិសេស ចំពោះប្រជាជនក្រីក្រ កត្តាសំខាន់គឺការបង្កើនជំនឿទុកចិត្តរបស់អតិថិជនទៅលើការផ្តល់សេវា ។ សំភារៈសំរាប់ផ្សព្វផ្សាយពត៌មាន ការអប់រំ និងការប្រាស្រ័យទាក់ទង ត្រូវផ្តោតទៅលើអាកប្បកិរិយាក្នុងការស្វែងរកការព្យាបាលសមស្របរបស់អតិថិជន ហើយទាមទារអោយមានការផ្តល់ពត៌មានដល់អតិថិជន អំពីសេវាដែលរាជរដ្ឋាភិបាលអាចផ្តល់អោយ ។

៣៧៣- **ការបង្កើនគុណភាព** : អាទិភាពសំរាប់ការលើកកំពស់គុណភាពទូទាំងវិស័យនឹងផ្តោតលើការរៀបចំលក្ខណៈវិនិច្ឆ័យ និងការជំរុញការអនុវត្តន៍លក្ខណៈវិនិច្ឆ័យទាំងនេះ ។ ការចូលរួមរបស់ក្រុមអតិថិជន នៅក្នុងការពិភាក្សាអំពីការបង្កើនគុណភាព គឺជាយុទ្ធសាស្ត្រសំខាន់ដើម្បីបង្កើនគុណភាពសេវាសុខាភិបាល ។

៣៧៤- **ការអភិវឌ្ឍន៍ធនធានមនុស្ស** : អាទិភាពក្នុងការងារនេះ ពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងការអភិវឌ្ឍន៍គោលនយោបាយគ្រប់គ្រងធនធានមនុស្ស សំដៅលើកកំពស់ និងជំរុញការលើកទឹកចិត្តដល់បុគ្គលិក រួមមានប្រព័ន្ធត្រួតពិនិត្យ ប្រព័ន្ធផ្តល់រង្វាន់ និងវិន័យ ។ ជំរើសនៃការផ្តល់ការលើកទឹកចិត្តសំរាប់បុគ្គលិកដែលបំពេញការងារនៅតាមតំបន់ដាច់ស្រយាល ឬ ជំរើសនៃការបន្សាំប្រព័ន្ធបណ្តុះបណ្តាលទៅនឹងតំរូវការរបស់ប្រជាជនមកពីតំបន់ដាច់ស្រយាល ក៏ត្រូវបានលើកយកមកសិក្សាដែរ ។ ការបង្កើត និងការអនុវត្តន៍កម្មវិធីសិក្សា សំរាប់ IMCI និងការបណ្តុះបណ្តាលនឹងក្លាយជាអាទិភាពមួយក្នុងវិស័យសុខាភិបាល ។ ទន្ទឹមនេះ យុទ្ធសាស្ត្រជំហានលឿនស្តីពីការបណ្តុះបណ្តាលមុខវិជ្ជាឆ្មប នឹងត្រូវរៀបចំឡើង និងចាប់ផ្តើមអនុវត្ត ។

លើសពីនេះ កម្មវិធីបណ្តុះបណ្តាលសមស្របសំរាប់អ្នកស្ម័គ្រចិត្តនៃ VHSG និង HCMC ក៏នឹងត្រូវរៀបចំ និងដាក់អោយអនុវត្តផងដែរ ។

៣៧៥- **ហិរញ្ញប្បទានសុខាភិបាល** : ដើម្បីលើកកំពស់សេវាសំរាប់ការពារសុខភាពមាតា និងកុមារ (MCH) ចំណាយថវិកា ក៏ដូចជាធនធានក្រៅប្រទេសដែលប្រមូលផ្តុំលើការអនុវត្តន៍សកម្មភាព IMCI នឹងត្រូវបង្កើនឡើង ។ ដើម្បីលើកកំពស់លទ្ធភាពក្នុងការផ្តល់សេវានានាដល់ជនក្រីក្រ ប្រព័ន្ធមួយសំរាប់កំណត់អ្នកក្រីក្រ នឹងត្រូវបង្កើតឡើង ហើយនឹងត្រូវយកទៅអនុវត្ត ។ ទន្ទឹមនេះ ផែនការអនុគ្រោះប្រកបដោយតំលាភាព សំរាប់អនុវត្តមូលនិធិប្រកបដោយសមធម៌ នឹងត្រូវដាក់អោយដំណើរការក្នុងពេលខាងមុខ ។ អាទិភាពមួយសំរាប់ឆ្នាំ ២០០៤-២០០៥ គឺត្រូវពិនិត្យ តាមដាន និងវាយតំលៃការអនុវត្តន៍បែបផែនហិរញ្ញប្បទានផ្សេងៗនៅក្នុងវិស័យសុខាភិបាល ដូចជា មូលនិធិប្រកបដោយសមធម៌ និងគំរោងធានារ៉ាប់រង ដើម្បីកំណត់អំពីប្រសិទ្ធិភាពនៃបែបផែនទាំងនេះ ទៅលើជនក្រីក្រ ព្រមទាំងចងក្រងឯកសារស្តីពីមេរៀន និងបទពិសោធន៍ទាំងឡាយ ដែលទទួលបាន ។

៣៧៦- **ការអភិវឌ្ឍន៍ស្ថាប័ន** : នៅក្នុងបណ្តាផ្នែកគន្លឹះនៃការងារអភិវឌ្ឍន៍ស្ថាប័ន អាទិភាពចំបងសំរាប់ឆ្នាំ ២០០៤-២០០៥ គឺការពង្រឹងភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងនៅក្នុងក្រសួងសុខាភិបាល និងក្នុងប្រព័ន្ធផ្តល់សេវាសុខាភិបាល ទន្ទឹមនឹងការពង្រឹងភាពជាដៃគូ រវាងក្រសួងសុខាភិបាលនិងផ្នែកឯកជន ។ សកម្មភាពជាក់លាក់រួមមាន ÷ ១- ពង្រឹងតួនាទីស្ថាប័ននានារបស់ក្រសួងសុខាភិបាលនៅគ្រប់កំរិតទាំងអស់ ដើម្បីប្រឈមជាមួយនឹងការផ្លាស់ប្តូរទាំងឡាយដែលកើតឡើងនៅក្នុងដំណើរការកែទំរង់វិស័យសុខាភិបាល ដូចជាការចាប់ផ្តើមអនុវត្តទស្សនទានស្តីពីការគ្រប់គ្រងទូទាំងវិស័យ (Sector-Wide Management) ។ ២- ធានាអោយមានតំលាភាពស្តីពីតួនាទី និងមុខងារនៃការអភិវឌ្ឍន៍សមត្ថភាពជំនាញនិងភាពជាអ្នកដឹកនាំ ព្រមទាំងពង្រឹងការគ្រប់គ្រងនៅគ្រប់កំរិតនៃប្រព័ន្ធសុខាភិបាល ពិសេសនៅថ្នាក់ជាតិ ។ ៣- កំរិតទំហំនៃការអភិវឌ្ឍន៍ខាងស្ថាប័ន សំរាប់ផ្លាស់ប្តូរឥរិយាបទពីបែបផែនការិយាល័យធិបតេយ្យ ក្នុងការអនុវត្តន៍សេវាសុខាភិបាល ឆ្ពោះទៅរកវប្បធម៌គ្រប់គ្រងមួយដែលមានលក្ខណៈទន់ភ្លន់ និងច្នៃប្រឌិត ។ ៤- រៀបចំ អនុម័ត ព្រមទាំងពង្រឹងការអនុវត្តន៍ច្បាប់ និងបទបញ្ញត្តិនានា ដែលពាក់ពន្ធ័នឹងវិស័យសុខាភិបាល ។ ៥- រៀបចំប្រព័ន្ធលើកទឹកចិត្ត តាមរយៈបៀវត្សផ្អែកលើស្នាដៃជាក់ស្តែង រួមទាំងប្រព័ន្ធដែលប្រើប្រាស់ធនធានក្រៅប្រទេស ។ និង ៦- ការធ្វើសនិទានកម្មដំណើរការរៀបចំផែនការ ការពិនិត្យតាមដាន និងវាយតំលៃ ព្រមទាំងការសំរបសំរួល សំរាប់ការគ្រប់គ្រងទូទាំងវិស័យសុខាភិបាល ។

៣៧៧- **បញ្ហាអន្តរវិស័យ** : ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ឆ្នាំ២០០៣-២០០៧ បានលើកឡើងច្បាស់ថា ការងារគន្លឹះទាំង ៦ មានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធ ។ ទន្ទឹមនឹងពេលដែលការលើកកំពស់ការផ្តល់សេវាសុខាភិបាល គឺជាអាទិភាពចំបង ការសំរេចអោយបានគោលដៅនេះត្រូវពឹងអាស្រ័យផងដែរ ទៅនឹង

វឌ្ឍនភាពនៃការងារពាក់ព័ន្ធផ្សេងៗទៀត ។ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ក្រសួងសុខាភិបាលនឹងវិលេចការងារទាំង ៦ ដែលមានលក្ខណៈជាអន្តរវិស័យនេះ ទៅក្នុងផែនការប្រតិបត្តិការប្រចាំឆ្នាំរបស់ខ្លួន ។

៣៧៨- **អេដស៍** : ដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងការឆ្លងរាលដាលនៃជំងឺអេដស៍ អាទិភាពរបស់រាជរដ្ឋាភិបាលផ្តោតជាសំខាន់ទៅលើ ÷

១- ការបង្ការការឆ្លងជំងឺអេដស៍ តាមរយៈវិធានការដូចជា ÷

- ពង្រីកការអនុវត្តន៍កម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០% នៅទូទាំងប្រទេស ចំពោះអ្នករកស៊ីផ្លូវភេទ ។
- ពង្រីកកម្មវិធីបង្ការការឆ្លងជំងឺអេដស៍ ចំពោះក្រុមជនដែលមានការប្រថុយប្រថាននឹងការឆ្លងជំងឺនេះខ្ពស់ ដូចជាកងកំលាំងប្រដាប់អាវុធ កម្មកររោងចក្រ និងសិស្សានុសិស្ស ។
- បង្កើនការយល់ដឹងរបស់សាធារណជនលើជំងឺអេដស៍ តាមរយៈកម្មវិធី ដូចជាមិត្តអប់រំមិត្ត និងតាមរយៈការផ្សព្វផ្សាយតាមប្រព័ន្ធពតិមាន ដើម្បីបង្កើតអោយមានបរិស្ថានសុវត្ថិភាពមួយសំរាប់ការប្រតិបត្តិផ្លូវភេទ និងកាត់បន្ថយការឆ្លងជំងឺនេះ ។
- បន្តគាំទ្រកម្មវិធីបង្ការការចំលងជំងឺអេដស៍ពីប្តីទៅប្រពន្ធ និងពីម្តាយទៅកូន ដើម្បីបង្កើតអោយមានស្មារតីទទួលខុសត្រូវនៅក្នុងគ្រួសារ និងសង្គមជាតិ ។
- អភិវឌ្ឍកម្មវិធីសំដៅផ្តល់អំណាចអោយសហគមន៍មូលដ្ឋានមានលទ្ធភាពគ្រប់គ្រាន់ឆ្លើយតបនឹងការប្រឈមមុខនឹងជំងឺអេដស៍នៅក្នុងសហគមន៍របស់ខ្លួន ។
- បញ្ជ្រាបបញ្ហាជំងឺអេដស៍ទៅក្នុងគ្រប់គោលនយោបាយសាធារណៈរបស់រាជរដ្ឋាភិបាល ។

២- លើកកំពស់ការព្យាបាល និងថែទាំដល់អ្នកដែលមានផ្ទុកមេរោគអេដស៍ តាមរយៈវិធានការដូចជា ÷

- បង្កើនការទទួលបានសេវាគាំទ្រ និងថែទាំចំពោះអ្នកដែលមានផ្ទុកមេរោគអេដស៍ ដោយពង្រឹងបន្ថែមនូវប្រព័ន្ធធ្វើតេស្តឈាមដោយស្ម័គ្រចិត្តនិងដោយសំងាត់ ការព្យាបាល និងទទួលថ្នាំពន្យារការព្យាបាលពីការឆ្លងរោគរបេង ការព្យាបាលតាមផ្ទះ មណ្ឌលមិត្តជួយមិត្ត ។ល។
- សហការយ៉ាងជិតស្និទ្ធជាមួយប្រព័ន្ធផ្សព្វផ្សាយ និងសហគមន៍មូលដ្ឋានដើម្បីកាត់បន្ថយការរើសអើងប្រឆាំងនឹងអ្នកផ្ទុកមេរោគអេដស៍ ដើម្បីអោយពួកគេអាចបន្តការងារ និងជីវភាពគ្រួសារនៅក្នុងសហគមន៍ ។

៣- ការកាត់បន្ថយផលប៉ះពាល់បណ្តាលមកពីការឆ្លងជំងឺអេដស៍ តាមរយៈវិធានការដូចជា ÷

- ពង្រីកវិសាលភាពនៃសកម្មភាពគ្របដណ្តប់ក្រុមជនងាយរងគ្រោះដទៃទៀត ដូចជាកុមារ និងក្មេងកំព្រាដែលឆ្លងជំងឺអេដស៍ ។
- ផ្តល់ការគាំពារចំពោះអ្នកផ្ទុកមេរោគអេដស៍ដែលក្រីក្រ តាមរយៈការព្យាបាល និងការឧបត្ថម្ភ។

៣៧៩- ដើម្បីអោយការអនុវត្តន៍ការងារជាអាទិភាពទាំងនេះសំរេចទៅបាន អាជ្ញាធរជាតិប្រឆាំងនឹងជំងឺអេសដ៍នឹងចាត់វិធានការមួយចំនួនសំដៅពង្រឹងសមត្ថភាពស្ថាប័ន និងការគ្រប់គ្រងរបស់ខ្លួន តាមរយៈ ÷

១- ការពិនិត្យឡើងវិញនូវផែនការសកម្មភាពជាតិពហុវិស័យសំរាប់ការឆ្លើយតបនឹងការឆ្លងរាលដាលនៃជំងឺអេដស៍ ។

២- រៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការឆ្លងជំងឺអេដស៍ ប្រកបដោយប្រសិទ្ធភាព ។

៣- រៀបចំប្រព័ន្ធតាមដាន និងវាយតំលៃ សំរាប់អាជ្ញាធរគ្រប់កំរិត ។

៤- កៀងគរធនធានពីគ្រប់ប្រភព ដើម្បីអនុវត្តសកម្មភាពអាទិភាពដែលចង្អុលបង្ហាញដោយប្រព័ន្ធតាមដាន និងវាយតំលៃ ។

៥- ជំរុញអោយមានការគ្រប់គ្រងបែបវិមជ្ឈការ ការឆ្លើយតបទៅនឹងមេរោគអេដស៍ នៅតាមគណៈកម្មាធិការអេដស៍ខេត្ត- ក្រុង និងតាមលេខាធិការដ្ឋាននិមួយៗ ។

៦- បញ្រ្ជាបបញ្ហាអេដស៍ទៅក្នុងគោលនយោបាយវិស័យរបស់រាជរដ្ឋាភិបាល ។

៧- កសាងសមត្ថភាពអាជ្ញាធរអេដស៍ និងស្ថាប័នក្រោមឱវាទទាំងអស់ ។

៨- ពង្រឹងសមត្ថភាពអាជ្ញាធរអេដស៍ក្នុងការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ ។

៩- ពង្រឹងភាពជាដៃគូជាមួយសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក្នុងការរៀបចំ និងអនុវត្តន៍ផែនការយុទ្ធសាស្ត្រប្រឆាំងជំងឺអេដស៍ ។

**ការអនុវត្តន៍គោលនយោបាយយេនឌ័រ**

៣៨០- យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកំណត់ថា ស្ត្រី គឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិយើង ។ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តផែនការយុទ្ធសាស្ត្រ *«នារីរតនៈ»* ឬ ស្ត្រីគឺជាត្បូងមានតំលៃ ក្នុងគោលបំណងផ្តល់ជូនស្ត្រីខ្មែរ នូវតម្លៃ និងក្តីសង្ឃឹមក្នុងជីវិត និងដែលផ្តោតលើបញ្ហាយេនឌ័រ ។

៣៨១- រាជរដ្ឋាភិបាលផ្តល់អាទិភាពខ្ពស់ លើការលើកកំពស់តួនាទី និង ស្ថានភាពសង្គមរបស់ស្ត្រីកម្ពុជា ដោយយកចិត្តទុកដាក់ជំរុញការអនុវត្តន៍យុទ្ធសាស្ត្រយេនឌ័រ ការកសាងសមត្ថភាពស្ត្រីលើគ្រប់ផ្នែក ការកែប្រែឥរិយាបថក្នុងសង្គមដែលមានការរើសអើងចំពោះស្ត្រីភេទ និងការធានាសិទ្ធិដើម្បីអោយស្ត្រីភេទមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចូលរួមយ៉ាងសកម្ម និងដោយស្មើភាពក្នុងដំណើរការកសាងប្រទេស ។

៣៨២- យុទ្ធសាស្ត្រចតុកោណអះអាងពីគោលជំហរឥតរាថយរបស់រាជរដ្ឋាភិបាល ក្នុងការលើកកំពស់សិទ្ធិរបស់ស្ត្រីក្នុងការទទួលបានសេវាសុខភាព ការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ការចូលរួមក្នុងសកម្មភាព និងការអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការពារតាមផ្លូវច្បាប់ ជាពិសេសប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ និងការជួញដូរផ្លូវភេទ ។ រាជរដ្ឋាភិបាលបន្តពង្រឹងការចូលរួមរបស់ស្ត្រីអោយបានស៊ីជំរៅ ក្នុងការដឹកនាំនៅគ្រប់កំរិត ។

៣៨៣- ក្នុងការលើកស្ទួយសមភាពយេនឌ័រ ចំណុចជាអាទិភាពរបស់រាជរដ្ឋាភិបាល មានដូចជា÷

- បញ្ជ្រាបបញ្ហាយេនឌ័រ ដោយរៀបចំយុទ្ធសាស្រ្ត និងផែនការសកម្មភាពដើម្បីបញ្ជ្រាបបញ្ហាយេនឌ័រ ព្រមទាំងសហការជាមួយបណ្តាក្រសួងដែលពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីលើកស្ទួយបញ្ហាយេនឌ័រ នៅគ្រប់កម្មវិធីនយោបាយនៅគ្រប់កំរិត ។
- ពង្រឹងតួនាទីរបស់ស្រ្តីក្នុងការសំរេចចិត្ត ដោយអភិវឌ្ឍមុខជំនាញ និងជំនឿចិត្តរបស់ស្រ្តីនៅក្នុងនាទីសេវាសាធារណៈ ដើម្បីជំរុញការចូលរួមរបស់ស្រ្តីក្នុងការសំរេចចិត្ត ។
- កសាងការយល់ដឹងជាសាធារណៈពីបញ្ហាយេនឌ័រ តាមរយៈការលើកកំពស់សីលធម៌ និងតំលៃរបស់ ស្រ្តី ព្រមទាំងរៀបចំគោលនយោបាយថ្នាក់ជាតិស្តីពីយុវវ័យ ដោយសហការជាមួយក្រសួងអប់រំ យុវជននិងកីឡា ក្រសួងសង្គមកិច្ច បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍ផ្តល់ជំនួយ ។
- ជំរុញការផ្តល់អំណាចសេដ្ឋកិច្ចអោយស្រ្តី តាមរយៈការប្រែក្លាយមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្រ្តី អោយទៅជាមជ្ឈមណ្ឌលផ្តល់អំណាចអោយស្រ្តី ជំរុញការទទួលបាននូវឥណទានខ្នាតតូច និងសេវាទ្រទ្រង់ ធុរកិច្ច និងទីផ្សារ ពង្រីកការទទួលបាននូវបច្ចេកវិទ្យាកែច្នៃម្ហូបអាហារនៅតាមសហគមន៍មូលដ្ឋាន និងប្រែក្លាយគំរោងឥណទានខ្នាតតូច អោយទៅជាស្ថាប័នហិរញ្ញប្បទានខ្នាតតូច ដើម្បីពង្រីកសេវារបស់ខ្លួន ។
- លើកកំពស់ការទទួលបានសេវាសង្គមកិច្ច ដោយកសាងបន្ថែមនូវអន្តេវាសិកដ្ឋានសំរាប់សិស្សមធ្យមសិក្សាជានារី និងបង្កើតយន្តការគ្រប់គ្រងអន្តេវាសិកដ្ឋានតាមសហគមន៍ ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈមជ្ឈមណ្ឌលស្រ្តីនិងការផ្តល់អំណាច កសាងមណ្ឌលថែរក្សាទារក ព្រមទាំងបណ្តុះបណ្តាលអ្នកបំរើការផ្នែកនេះ ពង្រីកការអប់រំពីសុខភាពបន្តពូជនិងការពន្យារកំណើតនៅតាម សហគមន៍ ព្រមទាំងលើកកំពស់អាហារូបត្ថម្ភសំរាប់មាតា និងទារក ។
- ពង្រឹងសិទ្ធិនិងការការពារតាមផ្លូវច្បាប់ចំពោះស្រ្តី ដោយធ្វើការកែសំរួលពង្រាងច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ និងដាក់ជូនសភាជាតិ អនុវត្តផែនការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ គាំទ្រការរៀបចំច្បាប់ប្រឆាំងនឹងការជួញដូរមនុស្ស តាមដាន និងអនុវត្តអនុសញ្ញានិងពិធីសារនានាស្តីពីការប្រឆាំងការជួញដូរស្រ្តីនិងកុមារ បន្តយុទ្ធនាការឃោសនាប្រឆាំងការជួញដូរស្រ្តីនិងកុមារ និងរៀបចំការបណ្តុះបណ្តាលសំរាប់អ្នកធ្វើការផ្នែកសង្គមកិច្ច ។
- ចូលរួមចំណែកក្នុងអភិបាលកិច្ចល្អនិងកំណែទំរង់រដ្ឋបាល តាមរយៈការធ្វើវិចារណកម្មរចនាសម្ព័ន្ធរបស់ក្រសួងកិច្ចការនារី ឆ្លើយតបនឹងតំរូវការការងារ និងធានាការប្រើប្រាស់ធនធានមនុស្សប្រកបដោយប្រសិទ្ធភាពនិងមានការទទួលខុសត្រូវ បំពាក់ប្រព័ន្ធពត៌មានវិទ្យាដល់ក្រសួងកិច្ចការនារី និងមន្ទីរចំណុះតាមបណ្តាខេត្ត- ក្រុង ព្រមទាំងពង្រឹងសមត្ថភាពរបស់មន្រ្តីនិងស្ថាប័នក្រសួងនៅគ្រប់លំដាប់ថ្នាក់ ។

**ការអនុវត្តន៍គោលនយោបាយប្រជាសាស្ត្រ**

៣៨៤- យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលទទួលស្គាល់ថា អត្រាកំណើនប្រជាជនពេលបច្ចុប្បន្ន ជាបន្ទុកដ៏ធ្ងន់ធ្ងរមិនត្រឹមតែសំរាប់សេវាសាធារណៈប៉ុណ្ណោះទេ ថែមទាំងមានផលប៉ះពាល់ជាអវិជ្ជមាន ទៅលើភាពក្រីក្រផងដែរ ។ រាជរដ្ឋាភិបាលយល់យ៉ាងច្បាស់ពីផលវិបាកទាំងនេះ សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ។ ក្នុងន័យនេះ គោលនយោបាយប្រជាជនរបស់រាជរដ្ឋាភិបាល គឺសំដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងសំរេចអោយបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា ។ អាទិភាពដែលបានលើកឡើងក្នុងយុទ្ធសាស្ត្រចតុកោណ គឺ ÷

- គាំទ្រគូស្វាមីភរិយា និងគ្រួសារនីមួយៗ អោយធ្វើការសំរេចចិត្តដោយសេរី និងដោយទទួលខុសត្រូវលើចំនួនកូន និងការពន្យារកំណើត ព្រមទាំងធានានូវការផ្តល់ពត៌មាន ការអប់រំ ការផ្តល់សេវាកម្ម និងមធ្យោបាយពាក់ព័ន្ធផ្សេងៗ ដើម្បីអនុវត្តការសម្រេចចិត្តខាងលើ ។
- កាត់បន្ថយអត្រាខ្ពស់នៃលទ្ធភាពផ្តល់កំណើត និង បង្កើនការប្រើប្រាស់សេវាពន្យារកំណើត ។
- កាត់បន្ថយអត្រាស្លាប់របស់ទារក កុមារ និងម្តាយ ។
- ជំរុញអោយមានសមភាព និងសមធម៌យេនឌ័រ និងលើកកំពស់ការអភិវឌ្ឍន៍ធនធានមនុស្ស ។
- កាត់បន្ថយផលប៉ះពាល់នៃសម្ពាធប្រជាជន ទៅលើបរិស្ថាន និងធនធានធម្មជាតិ ។
- ពង្រឹងបន្ថែមទៀត ការទប់ស្កាត់ការរីករាលដាលនៃមេរោគហ៊ីវ/អេដស៍ ។
- បញ្ចូលកត្តាប្រជាជនទៅក្នុងគោលនយោបាយសេដ្ឋកិច្ច សង្គមកិច្ច និងផែនការនិងកម្មវិធីនានានៅគ្រប់កំរិតទាំងអស់ ។

## ជំពូកទី៩
## តំរូវការហិរញ្ញប្បទាន និងទិសដៅកៀរគរជំនួយផ្លូវការ

៣៨៥- ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជាតាមរយៈការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ច គឺជាអាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាល ។ «***យុទ្ធសាស្ត្រចតុកោណ***» ដែលបានបង្ហាញជូនដោយរាជរដ្ឋាភិបាលនីតិកាលទី៣ នៃរដ្ឋសភា មានទិសដៅជំរុញលើកកំពស់កំណើនសេដ្ឋកិច្ច ដោះស្រាយការងារសំរាប់ពលករកម្ពុជាគ្រប់រូប ធានាសមធម៌ក្នុងសង្គម និងបង្កើនប្រសិទ្ធភាពនៃវិស័យសាធារណៈ តាមរយៈការអនុវត្តន៍ផែនការសកម្មភាពអភិបាលកិច្ច និងការអនុវត្តន៍កម្មវិធីកំណែទំរង់ទូលំទូលាយ ក្នុងគ្រប់ផ្នែក- គ្រប់វិស័យ ។ «***យុទ្ធសាស្ត្រចតុកោណ***» ជ្រើសរើសចេញនូវសមាសធាតុសំខាន់ៗពី *«គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs)»* *«ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ ឆ្នាំ ២០០១-២០០៥»* របស់កម្ពុជាបច្ចុប្បន្ន ពី *«យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រឆ្នាំ ២០០៣-២០០៥»* និងពីគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីកំណែទំរង់សំខាន់ៗជាច្រើនទៀត ។ យុទ្ធសាស្ត្រ និងគោលនយោបាយទាំងនេះ នឹងត្រូវសំរេចអោយបានតាមរយៈការអនុវត្តន៍កម្មវិធីវិនិយោគសាធារណៈអាទិភាព (Public Investment Program) ដែលជាឧបករណ៍មួយក្នុងការអនុវត្តន៍អោយបានសំរេចនូវយុទ្ធសាស្ត្រ និងគោលនយោបាយទាំងនេះ ។ កម្មវិធីវិនិយោគសាធារណៈត្រូវបានរៀបចំសំរាប់រយៈពេល៣ឆ្នាំ ដើម្បីឆ្លុះបញ្ចាំងអំពីតំរូវការជាអាទិភាពជាក់ស្តែង ។ បណ្តាកម្មវិធី និងគំរោងក្នុងកម្មវិធីវិនិយោគសាធារណៈនឹងទទួលការគាំទ្រហិរញ្ញប្បទានពីថវិការដ្ឋ និងពីដៃគូអភិវឌ្ឍន៍របស់កម្ពុជា ។ កម្មវិធីវិនិយោគសាធារណៈនេះរួមមានបណ្តាកម្មវិធី និងគំរោងអាទិភាពរបស់រាជរដ្ឋាភិបាលដែលកំពុងអនុវត្ត និង/ឬដែលនឹងត្រូវអនុវត្តនៅតាមវិស័យនីមួយៗ ព្រមទាំងជាប្រភពពត៌មានដ៏សំខាន់ស្តីពីការធ្វើវិភាជន៍ថវិការដ្ឋ ក៏ដូចជាសំរាប់កៀងគរជំនួយពីដៃគូអភិវឌ្ឍន៍របស់កម្ពុជា ។

៣៨៦- បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកំពុងអនុវត្តនូវវិធានការនានា សំដៅពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ ។ លទ្ធផលជាក់ស្តែងដែលបានមកពីការចរចាកំណត់ពេលសងបំណុលដែលកម្ពុជាបានខ្ចីពីសហរដ្ឋអាមេរិក និងសហភាពរុស្ស៊ីកាលពីទសវត្សរ៍ឆ្នាំទី៧០ និង៨០ នឹងបង្កើនបន្ទុកបំណុលសំរាប់ចំណូលក្នុងស្រុកដែលនៅមានកំរិតរបស់រាជរដ្ឋាភិបាល ។ ដើម្បីលើកកំពស់ប្រសិទ្ធភាពនៃជំនួយអភិវឌ្ឍន៍ផ្លូវការ និងកាត់បន្ថយបន្ទុកដល់ប្រជាពលរដ្ឋស្រករក្រោយៗទៀត រាជរដ្ឋាភិបាលសូមស្នើអោយបណ្តាដៃគូអភិវឌ្ឍន៍របស់កម្ពុជាពិចារណាពីលទ្ធភាពផ្តល់ជំនួយឥតសំណងដើម្បីអភិវឌ្ឍវិស័យសង្គមកិច្ច ដោយរួមទាំងវិស័យសុខាភិបាល និងអប់រំ ការអភិវឌ្ឍន៍ធនធានមនុស្ស និងបច្ចេកវិទ្យាពត៌មាន ។ រាជរដ្ឋាភិបាលនឹងដាក់កំរិតការប្រើប្រាស់កំចីដែលមានលក្ខណៈសម្បទាន សំរាប់សកម្មភាពអភិវឌ្ឍន៍ណាដែលអាចផ្តល់លទ្ធផលសេដ្ឋកិច្ចមកវិញភ្លាមៗ សំរាប់សងការប្រាក់ និងកាតព្វកិច្ចបំណុល ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងមិនលើកទឹកចិត្ត

ដល់ការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍ទាំងឡាយ ដែលប្រើប្រាស់ហិរញ្ញប្បទានជាកំចីគ្មានលក្ខណៈសម្បទានឡើយ ។

## តារាងទី ៣ : ការសន្យា និងការប្រើប្រាស់ជំនួយ ឆ្នាំ ២០០១-២០០៣

ឯកតាគិតៈ លានដុល្លាអាមេរិក

| ដៃគូអភិវឌ្ឍន៍បរទេស | ការប្រើប្រាស់ជាក់ស្តែង | | |
|---|---|---|---|
| | ឆ្នាំ ២០០១ | ឆ្នាំ ២០០២ | ឆ្នាំ ២០០៣ |
| - អ្នកផ្តល់ជំនួយទ្វេភាគី (មិនគិតប្រទេសសហភាពអឺរ៉ុប) | ១៦៨ | ១៨២,៣ | ១៨១,២ |
| - ប្រទេសសហភាពអឺរ៉ុប និងគណៈកម្មការអឺរ៉ុប | ១០០,៦ | ១១១,៦ | ១២៦,៣ |
| ក- ភ្នាក់ងារអង្គការសហប្រជាជាតិ | | | |
| - ប្រភពធនធានសរុប | ៩០,៨ | ៨១,៨ | ៨៣,៩ |
| - ប្រភពធនធានផ្ទាល់ខ្លួន | ៤៤,៩ | ៤២,២ | ៤១,៨ |
| ខ- អ្នកផ្តល់ជំនួយពហុភាគីផ្សេងទៀត | ១១៤,៧ | ១៤៩,២ | ១៤៩,៣ |
| - អង្គការក្រៅរដ្ឋាភិបាល (ប្រភពជំនួយផ្ទាល់ខ្លួន) | ៤៣,៤ | ៤៥,៦ | ៤៧,២ |
| - ការប្រើប្រាស់ថវិកាសរុប[ក] | ៤៧១,៨ | ៥៣០,៩ | ៥៤៥,៨ |
| - សរុបការសន្យាផ្តល់ជំនួយ | ៦១០,៧ | ៦៣៥[ខ] | .......[គ] |
| - ការប្រើប្រាស់គិតជា% ធៀបនឹងការសន្យា | ៧៧,៣% | ៨៣,៦% | ....... |

កំណត់សំគាល់ :

ក- គិតបញ្ចូលតែធនធានរបស់ភ្នាក់ងារអង្គការសហប្រជាជាតិ ។"ប្រភពធនធានសរុប" របស់ភ្នាក់ងារអង្គការសហប្រជាជាតិ រួមបញ្ចូលទាំងធនធានរបស់ភ្នាក់ងារ និងធនធានកៀងគរពីប្រភពផ្សេងៗទៀត ដោយរួមទាំងពីអ្នកផ្តល់ជំនួយទ្វេភាគី ។

ខ- មិនគិតការសន្យាដែលប្រកាសដោយអង្គការក្រៅរដ្ឋាភិបាល ។

គ- កិច្ចប្រជុំពិគ្រោះយោបល់មិនបានដំណើរការសំរាប់ឆ្នាំ២០០៣ឡើយ ។

៣៨៧- ក្នុងបណ្តាឆ្នាំកន្លងមក ដៃគូអភិវឌ្ឍន៍បរទេសបានផ្តល់ការគាំទ្រដល់កម្មវិធីវិនិយោគសាធារណៈនេះ ។ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ឆ្នាំ១៩៩៦ ដៃគូអភិវឌ្ឍន៍បរទេសទ្វេភាគី និងពហុភាគីបានប្រកាសផ្តល់ជំនួយដែលមានតំលៃ៥០១លានដុល្លាអាមេរិក ។ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ឆ្នាំ១៩៩៧ ដៃគូអភិវឌ្ឍន៍បរទេសបានប្រកាសផ្តល់ជំនួយមានតំលៃ៤៥០លានដុល្លារអាមេរិក សំរាប់ឆ្នាំ១៩៩៩ មានចំនួន៤៧១លានដុល្លារអាមេរិក សំរាប់ឆ្នាំ២០០០ មាន៥៤៨លានដុល្លារអាមេរិក និងសំរាប់ឆ្នាំ២០០១ មាន៥៥៦លានដុល្លារ ។ នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ចុងក្រោយ ឆ្នាំ២០០២ ការសន្យាផ្តល់ហិរញ្ញប្បទានមានរហូតដល់៦៣៥លានដុល្លារអាមេរិក ។

៣៨៨- ក្នុងរយៈពេល៣ឆ្នាំចុងក្រោយ ២០០១-២០០៣ រាជរដ្ឋាភិបាលសូមរាយការណ៍ថា ការប្រើប្រាស់ជំនួយបានកើនឡើងជាលំដាប់ ពីជិត៤៧២លានដុល្លារអាមេរិក នាឆ្នាំ២០០១ ដល់ជាង៥៤៥លានដុល្លារអាមេរិក នាឆ្នាំ២០០៣ ។ ព្រមពេលជាមួយគ្នានេះ ការសន្យារបស់ដៃគូអភិវឌ្ឍន៍ក៏បានកើនឡើងពី៥៥៦លានដុល្លា អាមេរិក ក្នុងឆ្នាំ២០០១ ដល់៦៣៥លានដុល្លារអាមេរិក ក្នុងឆ្នាំ២០០៣ ។ មធ្យមភាគនៃការប្រើប្រាស់ជំនួយធៀបនឹងការសន្យាក៏បានកើនឡើងដែរ ក្នុងបណ្តាឆ្នាំកន្លងមក ។ ក្នុងឆ្នាំ២០០២ មធ្យមភាគនៃការប្រើប្រាស់ជំនួយធៀបនឹងការសន្យា កើនឡើងដល់៨៣,៦% ដែលកាលពីឆ្នាំ២០០១ មានត្រឹមតែ៧៧,៣%ប៉ុណ្ណោះ ដែលនេះជាសក្ខីភាពបញ្ជាក់អំពីសមត្ថភាពស្រូបយកជំនួយរបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលសូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍បរទេស ហើយសង្ឃឹមថា ដៃគូអភិវឌ្ឍន៍របស់កម្ពុជា នឹងបន្តផ្តល់ការគាំទ្រដល់កម្ពុជាបន្ថែមទៀត ដើម្បីអោយកម្ពុជាអាចសំរេចបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

៣៨៩- ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ទាំង៦លើកកន្លងមក រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងកៀងគរជំនួយបរទេសប្រមាណ៥០០លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ សំរាប់អនុវត្តគំរោងកំពុងដំណើរការនិងគំរោងថ្មីៗ ។ ដោយសារតែការងារជាអាទិភាពដែលស្នើឡើងដោយបណ្តាក្រសួងនានាមានចំនួនច្រើនសន្ធឹកសន្ធាប់ រាជរដ្ឋាភិបាលជួបប្រទះការលំបាក ក្នុងការកំរិតតំរូវការហិរញ្ញប្បទានរបស់ខ្លួនអោយស្ថិតក្នុងកំរិតដូចមុនៗបានឡើយ ។ តំរូវការហិរញ្ញប្បទានសរុបសំរាប់អនុវត្តកម្មវិធីកំពុងដំណើរការ និងកម្មវិធីថ្មីៗ ក្នុងរយៈពេល៣ឆ្នាំខាងមុខ ២០០៥-២០០៧ មានប្រមាណ**១.៩៣៧,៦លានដុល្លារអាមេរិក** ។ រាជរដ្ឋាភិបាលបានប្តេជ្ញាផ្តល់ប្រភពធនធានផ្ទាល់ចំនួន២៩០,៤លានដុល្លាអាមេរិកសំរាប់កម្មវិធីអភិវឌ្ឍន៍ទាំងនេះ ។ ដោយសារតំរូវការហិរញ្ញប្បទានសំរាប់ទ្រទ្រង់ថវិកាមានប្រមាណ១៥០លានដុល្លាអាមេរិក និងតំរូវការហិរញ្ញប្បទានសំរាប់ទ្រទ្រង់ជញ្ជីងទូទាត់មានប្រមាណ៦៦លានដុល្លាអាមេរិក **តំរូវការជំនួយហិរញ្ញប្បទានសរុបពីដៃគូអភិវឌ្ឍន៍សំរាប់រយៈពេល៣ឆ្នាំខាងមុខ មានចំនួន ១.៨៦៣,២លានដុល្លារអាមេរិក ពោលគឺ ៦២១,១លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ** ។ ដៃគូអភិវឌ្ឍន៍របស់យើងមួយចំនួន បានសន្យាផ្តល់ហិរញ្ញប្បទានរួចហើយ ចំនួន**១.០៦២,៦**លានដុល្លារអាមេរិក សំរាប់អនុវត្តកម្មវិធីអាទិភាពទាំងនេះ ។ ដូចនេះ **រាជរដ្ឋាភិបាលត្រូវស្វះស្វែងរកការគាំទ្របន្ថែមទៀតចំនួន ៨០០,៦លានដុល្លារអាមេរិក ពីដៃគូអភិវឌ្ឍន៍របស់ខ្លួន** ។

៣៩០- របាយនៃកម្មវិធីអភិវឌ្ឍន៍ជាអាទិភាពនៅក្នុងកម្មវិធីវិនិយោគសាធារណៈ ឆ្នាំ ២០០៥-២០០៧ តាមវិស័យមានដូចខាងក្រោម (តារាងទី៤) ៖

- វិស័យសង្គមកិច្ច មាន ៤៣,២%
- វិស័យសេដ្ឋកិច្ច មាន ១១,៦%
- ហេដ្ឋារចនាសម្ព័ន្ធ មាន ៣១,៨%

- កម្មវិធីអន្តរវិស័យ មាន ១៣,៨% ។

៣៩១- កម្មវិធីអភិវឌ្ឍន៍រយៈពេល៣ឆ្នាំ ដែលមានតំលៃសរុប ១.៩៣៧,៦លានដុល្លាអាមេរិក ត្រូវបានបែងចែកដូចខាងក្រោម ÷

- ៧៣,៥% សំរាប់វិនិយោគមូលធន និង ២៦,៥% សំរាប់ជំនួយបច្ចេកទេស ។
- គំរោងដែលកំពុងដំណើរការនិងគំរោងដែលបានសន្យាផ្តល់ហិរញ្ញប្បទាន នៅក្នុងកម្មវិធីវិនិយោគសាធារណៈ មាន៧៦,៩% និងគំរោងមានអាទិភាពខ្ពស់ មាន ២៣,១% ។

៣៩២- ផែនការចំណាយសំរាប់គំរោងកំពុងដំណើរការ និងគំរោងដែលបានសន្យាផ្តល់ហិរញ្ញប្បទាន សំរាប់រយៈពេល៣ឆ្នាំ ខាងមុខ រួមមាន ÷

- ៧៩,២% សំរាប់វិនិយោគមូលធន
- ២០,៨% សំរាប់ជំនួយបច្ចេកទេស ។

៣៩៣- ក្នុងផែនការចំណាយសរុបសំរាប់កម្មវិធី និងគំរោងដែលមានអាទិភាពខ្ពស់ ចំនួន៤៤៧,៦៣លានដុល្លារ អាមេរិក ហើយដែលត្រូវចាប់អនុវត្តក្នុងរយៈពេល៣ឆ្នាំខាងមុខ ២០០៥-២០០៧ វិនិយោគជាមូលធនមាន ប្រមាណ ៥៤,៥% និងជំនួយបច្ចេកទេស ៤៥,៥% ។ ខ្លឹមសារសង្ខេបស្តីពីផែនការតាមវិស័យ និងតាម ប្រភេទនៃកម្មវិធី (វិនិយោគមូលធន និងជំនួយបច្ចេកទេស) និងគំរោងកម្មវិធីដែលកំពុងដំណើរការ ព្រម ទាំងគំរោងថ្មីៗ ក៏ដូចជាការគៀងគរប្រភពធនធានតាមវិស័យនិមួយៗ មានបង្ហាញជូនក្នុងតារាងទី៤ និង ទី៥ ។ ម្យ៉ាងទៀត ពត៌មានបន្ថែមសំរាប់គំរោងនិងកម្មវិធីនិមួយៗដែលមានក្នុងកម្មវិធីវិនិយោគសាធារណៈ សំរាប់ឆ្នាំ២០០៥-២០០៧ មាននៅក្នុងឧបសម្ព័ន្ធទី១ ។

# តារាងទី ៤

## កម្មវិធីអភិវឌ្ឍន៍តាមវិស័យ: ឆ្នាំ ២០០៥ - ២០០៧

ឯកតាគិតៈ លានដុល្លារអាមេរិក

| វិស័យ | ទឹកប្រាក់សំរាប់ កម្មវិធីអភិវឌ្ឍន៍ ២០០៥ - ២០០៧ | | ធនធានដែលបានសន្យា | | | | គោលដៅកៀងគរ ធនធានសរុប | |
|---|---|---|---|---|---|---|---|---|
| | | | រាជរដ្ឋាភិបាល | | ដៃគូបរទេស | | | |
| | ដុល្លារ | % | ដុល្លារ | % | ដុល្លារ | % | ដុល្លារ | % |
| **វិស័យសង្គម** | | | | | | | | |
| • អប់រំ | ១៧៦,៥២ | ៩,១% | ៩,៥៣ | ៣,៣ % | ១៥១,៨៨ | ១៥,២% | ១៥,១០ | ២,៣% |
| • សុខាភិបាល | ៦៦០,៦៤ | ៣៤,១% | ២៣៩,២៦ | ៨២,៤% | ១៤៧,២៩ | ១៤,៨% | ២៧៤,០៨ | ៤២,១% |
| *សរុប* | ***៨៣៧,១៦*** | ***៤៣,២%*** | ***២៤៨,៧៩*** | ***៨៥,៧%*** | ***២២៩,១៧*** | ***៣០,០%*** | ***២៨៩,១៩*** | ***៤៤,៤%*** |
| **វិស័យសេដ្ឋកិច្ច** | | | | | | | | |
| • កសិកម្ម និង រៀបចំដែនដី | ១៧១,៤៣ | ៨,៨% | ៥,៥១ | ១,៩% | ១៣៥,៥៦ | ១៣,៦ % | ៣០,៣៥ | ៤,៧% |
| • កម្មន្តសាល និង ពាណិជ្ជកម្ម | ៥៤,០៦ | ២,៨% | ០ | ០,០% | ២០,៦០ | ២,១% | ៣៣,៤៧ | ៥,១% |
| *សរុប* | ***២២៥,៤៩*** | ***១១,៦%*** | ***៥,៥១*** | ***១,៩%*** | ***១៥៦,១៦*** | ***១៥,៧%*** | ***៦៣,៨២*** | ***៩,៨%*** |
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | |
| • ដឹកជញ្ជូន | ២៣៣,១១ | ១១,៥% | ១,៤១ | ០,៥ % | ១១៥,៧១ | ១១,៦% | ១០៥,៩៨ | ១៦,៣% |
| • ផ្គត់ផ្គង់ទឹក និងអនាម័យ | ២១៣,៤០ | ១១,០% | ១៨,៥២ | ៦,៤% | ១៦៥,៤១ | ១៦,៦% | ២៩,៤៦ | ៤,៥% |
| • ថាមពល និង អគ្គិសនី | ១១៦,១១ | ៦,០% | ៦,២០ | ២,១% | ១០៥,៧៨ | ១០,៦% | ៤,១២ | ០,៦% |
| • ទូរគមនាគមន៍ | ៦៤,១៩ | ៣,៣% | ៩,៦០ | ៣,៣% | ៥៤,១០ | ៥,៤% | ០,៥០ | ០,១% |
| *សរុប* | ***៦១៦,៨១*** | ***៣១,៨%*** | ***៣៥,៧៣*** | ***១២,៣%*** | ***៤៤១,០០*** | ***៤៤,៣%*** | ***១៤០,០៦*** | ***២១,៥%*** |
| **វិស័យដទៃផ្សេងទៀត** | | | | | | | | |
| • បរិស្ថាន និង អភិរក្ស | ៦៨,៥០ | ៣,៥% | ០,០០ | ០,០% | ១៨,៧៤ | ១,៩% | ៤៩,៧៦ | ៧,៦% |
| • សហគមន៍ និង សេវាសង្គម | ៦៣,៤៨ | ៣,៣% | ០,០០ | ០,០% | ៥០,៧២ | ៥,០% | ១២,៧៦ | ២,០% |
| • វប្បធម៌ និង សិល្បៈ | ៧,៨៥ | ០,៤% | ០,០០ | ០,០% | ០,០០ | ០,០% | ៧,៨៥ | ១,២% |
| • គ្រប់គ្រងអភិវឌ្ឍន៍ និង អភិបាលកិច្ច | ១១៨,២៩ | ៦,១% | ៣៥០,០០ | ០,១% | ៣០,៧៧ | ៣,១% | ៨៧,១៧ | ១៣,៤% |
| *សរុប* | ***២៥៨,១២*** | ***១៣,៣%*** | ***៣៥០,០០*** | ***០,១%*** | ***១០០,២៣*** | ***១០,១%*** | ***១៥៧,៥៤*** | ***២៤,២%*** |
| **សរុបៈ គ្រប់វិស័យ** | **១.៩៣៧,៥៩** | **១០០ %** | **២៩០,៣៩** | **១០០ %** | **៩៩៦,៥៧** | **១០០ %** | **៦៥០,៦២** | **១០០ %** |
| **សរុបៈ គំរោងកំពុងដំណើរការ** | ១.៤៨៩,៩៦ | ១០០,០% | ២៧៦,៩២ | ១០០,០% | ៨៨០,៦៧ | ១០០,០% | ៣៣២,៣៥ | ១០០,០% |
| **និងបានសន្យា** | ១.១៧៩,៥៤ | ៧៩,២% | ២២១,០៩ | ៧៩,៨% | ៧០៤,៤២ | ៨០,០% | ២៥៤,០២ | ៧,៦៤% |
| • វិនិយោគមូលធន | ៣១០,៤២ | ២០,៨% | ៥៥,៨៣ | ២០,២% | ១៧៦,២៥ | ២០,០% | ៧៨,៣៣ | ២៣,៦% |
| • ជំនួយបច្ចេកទេស | | | | | | | | |
| **សរុបៈ គំរោងក្នុងផែនការជាអទិភាពខ្ពស់** | ៤៤៧,៦៣ | ១០០,០% | ១៣,៤៦ | ១០០,០% | ១១៥,៩០ | ១០០,០% | ៣១៨,២៦ | ១០០,០% |
| • វិនិយោគជាទុន | ២៤៤,០៣ | ៥៤,៥% | ២,៩៤ | ២១,៨% | ៣៧,៣៦ | ៣២,២% | ២០៣,៧៣ | ៦៤,០% |
| • ជំនួយបច្ចេកទេស | ២០៣,៦០ | ៤៥,៥% | ១០,៥២ | ៧៨,២% | ៧៨,៥៤ | ៦៧,៨% | ១១៤,៥៣ | ៣៦,០% |
| **សរុបៈ គ្រប់វិស័យ** | **១.៩៣៧,៥៩** | **១០០,០%** | **២៩០,៣៩** | **១០០,០%** | **៩៩៦,៥៧** | **១០០,០%** | **៦៥០,៦២** | **១០០,០%** |
| • វិនិយោគជាទុន | ១.៤២៣,៥៧ | ៧៣,៥% | ២២៤,០៤ | ៧៧,១% | ៧៤១,៧៨ | ៧៤,៤% | ៤៥៧,៧៥ | ៧០,៤% |
| • ជំនួយបច្ចេកទេស | ៥១៤,០២ | ២៦,៥% | ៦៦,៣៥ | ២២,៩% | ២៥៤,៧៩ | ២៥,៦% | ១៩២,៨៧ | ២៩,៦% |

## តារាងទី ៥

## កម្មវិធីនិងគំរោង កំពុងដំណើរការ បានសន្យា និង ក្នុងផែនការជាអាទិភាពខ្ពស់តាមវិស័យ

ឯកតាគិតៈ លានដុល្លាអាមេរិក

| វិស័យ | ទឹកប្រាក់សំរាប់កម្មវិធីអភិវឌ្ឍន៍ | | | | ធនធានដែលបានសន្យា | | គោលដៅកៀងគរធនធាន |
|---|---|---|---|---|---|---|---|
| | ២០០៥ | ២០០៦ | ២០០៧ | ២០០៥-២០០៧ | រាជរដ្ឋាភិបាល | ដៃគូបរទេស | |
| **វិស័យសង្គមកិច្ច** | | | | | | | |
| អប់រំ | | | | | | | |
| • គំរោងកំពុងដំណើរការ និងបានសន្យា | ៥៥,៨៩ | ៥២,៣៦ | ៥៣,១៥ | ១៦១,៤១ | ៩,៥៣ | ១៥១,៨៨ | ០ |
| • គំរោងក្នុងផែនការជាអាទិភាពខ្ពស់ | ៧,៩០ | ៣,៩០ | ៣,៣១ | ១៥,១០ | ០ | ០ | ១៥,១០ |
| សរុបវិស័យអប់រំ | ៦៣,៧៩ | ៥៦,២៦ | ៥៦,៤៦ | ១៧៦,៥១ | ៩,៥៣ | ១៥១,៨៨ | ១៥,១០ |
| សុខាភិបាល | | | | | | | |
| • គំរោងកំពុងដំណើរការ និងបានសន្យា | ១៩៦,៦៨ | ២១២,៩៥ | ២៤៨,០៥ | ៦៥៧,៦៩ | ២៣៨,៨០ | ១៤៧,២៩ | ២៧១,៦០ |
| • គំរោងក្នុងផែនការជាអាទិភាពខ្ពស់ | ០,៧៣ | ១,១៦ | ១,០៦ | ២,៩៥ | ០,៤៦ | ០ | ២,៤៨ |
| សរុបវិស័យសុខាភិបាល | ១៩៧,៤១ | ២១៤,១១ | ២៤៩,១១ | ៦៦០,៦៤ | ២៣៩,២៦ | ១៤៧,២៩ | ២៧៤,០៨ |
| សរុប | | | | | | | |
| • គំរោងកំពុងដំណើរការ និងបានសន្យា | ២៥២,៥៨ | ២៦៥,៣២ | ៣០១,២០ | ៨១៩,១១ | ២៤៨,៣៣ | ២៩៩,១៧ | ២៧១,៦០ |
| • គំរោងក្នុងផែនការជាអាទិភាពខ្ពស់ | ៨,៦២ | ៥,០៥ | ៤,៣៧ | ១៨,០៥ | ០,៤៦ | ០,០០ | ១៧,៥៩ |
| **សរុបៈវិស័យសង្គមកិច្ច** | ២៦១,២០ | ២៧០,៣៧ | ៣០៥,៥៧ | ៨៣៧,១៦ | ២៤៨,៧៩ | ២៩៩,១៧ | ២៨៩,១៩ |
| **វិស័យសេដ្ឋកិច្ច** | | | | | | | |
